

# ព្រះ
# ត្រៃបិដកបាលី
# និង
# សេចក្តីប្រែជាភាសាខ្មែរ
# សុត្តន្តបិដក
# អង្គុត្តរនិកាយ   អដ្ឋកនិបាត
# នវមភាគ
# ៤៨



ផ្សព្វផ្សាយដោយសម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី
សម្តេចព្រះមហាសង្ឃរាជនៃគណៈធម្មយុត្តិកនិកាយ
នៃព្រះរាជាណាចក្រកម្ពុជា
*ព. ស. ២៥៥៣*

# SUTTANTAPIṬAKA

## AṄGUTTARANIKĀYA

## AṬṬHAKANIPĀTA

## NAVAMABHĀGA

## 48

សម្តេចព្រះអភិសិរីសុគន្ធាមហាសង្ឃរាជាធិបតី បួរ គ្រី

សម្តេចព្រះមហាសង្ឃរាជ នៃគណៈធម្មយុត្តិកនិកាយ នៃព្រះរាជាណាចក្រកម្ពុជា

# និយមវចនៈ

ព្រះត្រៃបិដកត្រូវបានបង្កើតឡើង ប្រមាណ៥០០ឆ្នាំប្លាយ ក្រោយអំពីការរំលត់ព្រះខន្ធចូលកាន់ ព្រះបរមនិព្វានរបស់សម្តេចព្រះសម្មាសម្ពុទ្ធព្រះបរមគ្រូជាអម្ចាស់នៃយើងគ្រប់គ្នា ។ គ្រប់ប្រទេស អ្នកកាន់ព្រះពុទ្ធសាសនា និងប្រទេសខ្លះមួយចំនួនមិនមែនអ្នកកាន់ព្រះពុទ្ធសាសនា គ្រប់អង្គការ ពុទ្ធិកសមាគម និងតាមបណ្ណាល័យជាតិធំ ៗ តែងតែបានទទួលយកមកតម្កល់ទុកធ្វើជាគ្រឹះ ដើម្បីធ្វើការស្រាវជ្រាវសិក្សាស្វែងយល់ តាមអ្វីដែលហៅថាព្រះពុទ្ធវាចា (ពុទ្ធធម៌) ។ កាលដើមឡើយគេនាំគ្នា កត់ត្រាលើស្លឹករឹត ព្រមទាំងសរសេរចារឹកលើផែនថ្ម និងលើផែនលោហៈក៏មាន លុះចំណេរតមក ក៏បាននាំគ្នាបោះពុម្ពលើក្រដាសចងក្រងជាសៀវភៅ (គម្ពីរ) រហូតបច្ចុប្បន្ននេះ បច្ចេកវិជ្ជាកាន់តែ ចម្រើនឡើង គេបានវាយបញ្ចូលក្នុងកុំព្យូទ័រ តែទោះបីជាបច្ចេកទេសម៉ាស៊ីនចម្រើនឡើងយ៉ាងណា ក៏នៅមិនអាចបោះបង់សៀវភៅចោលបានឡើយ ដូច្នេះហើយទើបយើងខ្ញុំបានខិតខំធ្វើឲ្យកើតមាន ឡើងនូវក្រុមអក្សរព្រះត្រៃបិដក ដើម្បីជួយធ្វើឲ្យអក្ខរៈខ្លះដែលរលុបមិនអាចអានច្បាស់បាន ឲ្យមាន ការច្បាស់តាមតួអក្ខរៈឡើងវិញ ។

ដោយសទ្ធាជ្រះថ្លាដ៏មុតមាំដែលមានចំពោះព្រះពុទ្ធសាសនា ហើយក៏ជាកាតព្វកិច្ចមួយដ៏ធំក្នុងតួនាទីជាពុទ្ធបរិស័ទ ដែលបានប្រគល់កាយថ្វាយជីវិត អ្នកធ្វើដំណើរតាមស្នាមព្រះបាទសម្តេចព្រះពុទ្ធអង្គ រួមកម្លាំងទ្រទ្រង់ បានធ្វើការលះបង់កម្លាំងកាយ វាចា ចិត្ត ទ្រព្យធនផ្ទាល់ ព្រមទាំងបបួលពុទ្ធបរិស័ទ ញាតិមិត្តជិតឆ្ងាយ ក្នុងនិងក្រៅប្រទេសធ្វើឡើង ដើម្បីជាពុទ្ធបូជា ធម្មបូជា សង្ឃបូជា ។

សូមសេចក្តីឧស្សាហ៍ក្នុងការជាកុសលនេះ សម្រេចប្រយោជន៍ជូនដល់ព្រះពុទ្ធសាសនាជូនដល់ពុទ្ធបរិស័ទ សូមបានប្រកបតែនឹងសេចក្តីសុខចម្រើនរុងរឿង ក្នុងលោកនេះផង និងលោកដទៃខាងមុខទៀតផង ជាកិយ្យោភាពតរៀងទៅ ។

វត្តបទុមជ. ថ្ងៃទី ០៨ ខែមិថុនា ឆ្នាំ ២០០៩

បួរ-គ្រី

VATT Botum Dhammavutt Sangkat Chatumuk Khan Daun Penh P.Penh

# សេចក្ដីណែនាំក្នុងការអាន

*១) ប្រសិនបើលោកអ្នកអាន បានឃើញពាក្យទាំងឡាយណា ដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ហើយបន្ទាប់មកបានឃើញព្យញ្ជនៈមួយតួទៀតនៅខាងចុងពាក្យនោះ សូមមេត្តាកត់សម្គាល់ថា ព្យញ្ជនៈដែលនៅខាងចុងនោះ គឺជាជើងរបស់ព្យញ្ជនៈដែលមានសញ្ញាលេខបូកនៅពីខាងក្រោម ដោយកំហុសបច្ចេកទេសកុំព្យូទ័រ ។*

*ឧទាហរណ៍*

*-ពាក្យខ្មែរ:* **សម្‌ល** *ក្នុងពាក្យនេះ ព្យញ្ជនៈ* **ល** *គឺជាជើងរបស់ព្យញ្ជនៈ* **ម** *ដូច្នេះពាក្យនេះគឺ* **សម្ល** *។*

*-ពាក្យបាលី:* **តស្‌ស** *គឺ* **តស្ស** *។*

*២) ចំពោះពាក្យខ្មែរ យើងសម្រេចយកតាមវចនានុក្រមខ្មែរ របស់សម្ដេចព្រះសង្ឃរាជជោតញ្ញាណោ (***ជួន-ណាត***) ជាគោល ។ ប៉ុន្តែបើពាក្យទាំងឡាយណា ដែលអាចសរសេរតាមបែបបុរាណក៏ត្រឹមត្រូវដែរនោះ យើងខ្ញុំសូមរក្សានូវពាក្យទាំងនោះទុកដដែល ។*

*៣) ចំពោះ* **សន្ធឹកច្រាប់ពាក្យខុស-ត្រូវ** *ដែលមាននៅផ្នែកខាងចុងនៃព្រះត្រៃបិដកច្បាប់ដើម ក្រុមយើងខ្ញុំសូមមិនដាក់ទៀតទេ ព្រោះក្រុមការងារយើងបានកែតម្រូវតាមនោះរួចរាល់ហើយ ។*

# សុត្តន្តបិដក

# អង្គុត្តរនិកាយ  អដ្ឋកនិបាត

## នវមភាគ

## ៤៨

## ព. ស. ២៤៩៨

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស អដ្ឋកនិបាតោ

# នវមោ ភាគោ

---

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## បណ្ណាសកេ មេត្តាវគ្គោ

[១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច មេត្តាយ ភិក្ខវេ ចេតោវិមុត្តិយា អាសេវិតាយ ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ អដ្ឋានិសំសា ចាដិកង្ខា ។ កតមេ អដ្ឋ ។ សុខំ សុបតិ សុខំ បដិពុជ្ឈតិ ន ចាបកំ សុបិនំ បស្សតិ មនុស្សានំ បិយោ ហោតិ អមនុស្សានំ បិយោ ហោតិ ទេវតា រក្ខន្តិ នាស្ស អគ្គិ វា វិសំ វា សត្ថំ វា កមតិ

# សុត្តន្តបិដក

# អង្គុត្តរនិកាយ អដ្ឋកនិបាត

## នវមភាគ

---

*សូមនមស្ការព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។*

## បណ្ណាសក មេត្តាវគ្គ

[១] *ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកានៃព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលបុគ្គលធ្វើឲ្យច្រើន ចម្រើន ធ្វើឲ្យរឿយៗ ធ្វើឲ្យដូចជាយាន ធ្វើឲ្យជាទីនៅ បានតាំងទុករឿយៗ បានសន្សំ បានប្រារព្ធល្អហើយ មានអានិសង្ស ៨ ប្រការជាប្រាកដ ។ អានិសង្ស ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺដេកលក់ជាសុខ ១ ភ្ញាក់ឡើងជាសុខ ១ មិនឃើញនូវសុបិនអាក្រក់ ១ ជាទីស្រឡាញ់នៃពួកមនុស្ស ១ ជាទីស្រឡាញ់នៃពួកអមនុស្ស ១ ពួកទេវតា តែងរក្សា ១ ភ្លើងក្តី ថ្នាំពិសក្តី សស្ត្រាវុធក្តី មិនប៉ះពាល់នូវបុគ្គលនោះ ១*

២



ឧត្តរឹ អប្បដិវិជ្ឈន្តោ ព្រហ្មលោកូបគោ ហោតិ ។ មេត្តាយ ភិក្ខវេ ចេតោវិមុត្តិយា អាសេវិតាយ ភាវិតាយ ពហុលីកតាយ យានីកតាយ វត្ថុកតាយ អនុដ្ឋិតាយ បរិចិតាយ សុសមារទ្ធាយ ឥមេ អដ្ឋានិសំសា បាដិកង្ខាតិ ។

យោ ច មេត្តំ ភាវយតិ  អប្បមាណំ បដិស្សតោ
តនូ សំយោជនា ហោន្តិ  បស្សតោ ឧបធិក្ខយំ
ឯកម្បិ ចេ បាណមទុដ្ឋចិត្តោ
មេត្តាយតិ កុសលំ[១] តេន ហោតិ
សព្វេ វ បាណេ មនសានុកម្បិ
បហូតមរិយោ ច ករោតិ បុញ្ញំ
យេ សត្តសណ្ឌំ បឋវឹ ជិនិត្វា[២]
រាជិសយោ យជមានានុបរិយគា[២]
សស្សមេធំ បុរិសមេធំ

១ ឱ. កុសលី ។ ២ ឱ. ម. វិជេត្វា ។ ៣ ឱ. យជមានានុបរិយយា ។

កាលបើមិនទាន់បានគុណវិសេសដ៏ខ្ពង់ខ្ពស់ទេ រមែងទៅកើតក្នុងព្រហ្ម-លោក ១ ។ ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិ ដែលបុគ្គលធ្វើឲ្យច្រើន ចម្រើន ធ្វើរឿយៗ ធ្វើឲ្យដូចជាយាន ធ្វើឲ្យជាទីនៅ បានតាំងទុករឿយៗ បានសន្សំ បានប្រារព្ធល្អហើយ រមែងមានអានិសង្ស ៨ប្រការនេះឯងជាប្រាកដ ។

បុគ្គលដែលនឹករលឹកចំពោះ ចម្រើននូវមេត្តា ប្រមាណមិនបាន
ពិចារណាឃើញនូវការអស់ទៅនៃឧបធិក្កិលេស សំយោជនៈ
ទាំងឡាយក៏ស្រាលស្តើង (ចាកខន្ធសន្តាន)

បើបុគ្គលមានចិត្ត មិនបានប្រទូស្តសត្វណាមួយ ឈ្មោះ
ថាជាប់មេត្តា កុសលក៏រមែងកើតមាន ដោយហេតុ
នោះ ចំណែកព្រះអរិយៈ មានចិត្តអនុគ្រោះសត្វទាំង-
ឡាយទាំងពួង តែងធ្វើបុណ្យច្រើន ពួកស្តេចណាដែល
ប្រាកដដូចជាឥសី បានឈ្នះនូវផែនដី ដែលពាសពេញ
ដោយមនុស្សសត្វ កាលឲ្យទាន ប្រព្រឹត្តរឿយៗ
(ដោយសង្គហវត្ថុ ៤ ប្រការ) គឺឈ្មោសវៃ ក្នុងការទំនុក
បម្រុងធញ្ញជាតិ ១ ឈ្មោសវៃក្នុងការទំនុកបម្រុងមនុស្ស១

៣

បណ្ណាសកេ មេត្តាវគ្គោ

សម្មាចាសំ វាជបេយ្យំ និរគ្គឡំ
មេត្តស្ស ចិត្តស្ស សុភាវិតស្ស
កលម្បិ តេ នានុភវន្តិ សោឡសឹ
ចន្ទប្បភា តារគណាវ សព្វេ

យោ ន ហន្តិ ន ឃាតេតិ ន ជិនាតិ ន ជាបយេ
មេត្តសោ[១] សព្វភូតានំ វេរន្តស្ស ន កេនចីតិ ។

[២] អដ្ឋិមេ ភិក្ខវេ ហេតូ អដ្ឋ បច្ចយា អាទិព្រហ្មចរិយិកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា សំវត្តន្តិ ។ កតមេ អដ្ឋ ។ ឥធ ភិក្ខវេ ភិក្ខុ សត្ថារំ ឧបនិស្សាយ វិហរតិ អញ្ញតរំ វា គរុដ្ឋានិយំ សព្រហ្មចារឹ

១ ឱ. ម. មេត្តំសោ ។

ការបង់ចិត្តមនុស្ស ១ ពោលពាក្យជាទីស្រឡាញ់ ១ មិនបាច់ប្រើរនុកទ្វារផ្ទះឡើយ ការឲ្យទានទាំងឡាយនោះ ក៏មិនដល់នូវចំណិតក្នុងចំណែក ១៦ នៃមេត្តាចិត្ត ដែលបានអប់រំហើយ ដូចជារស្មីព្រះចន្ទ្រនិងពួកផ្កាយទាំងពួង បុគ្គលណា ជាអ្នកមានចំណែកនៃមេត្តាសមាធិចិត្ត ចំពោះពួកសត្វទាំងអស់ មិនបៀតបៀន មិនសម្លាប់ មិនធ្វើសេចក្តីវិនាសដល់សត្វដទៃដោយខ្លួនឯង មិនប្រើអ្នកដទៃ ឲ្យធ្វើសេចក្តីវិនាសដល់សត្វដទៃ វេរារបស់បុគ្គលនោះមិនមានដោយហេតុណាមួយឡើយ ។

[២] ម្នាលភិក្ខុទាំងឡាយ ហេតុ ៨ យ៉ាង បច្ច័យ ៨ យ៉ាងនេះ ប្រព្រឹត្តទៅដើម្បីបាននូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនធ្លាប់បានដើម្បីជាភិយ្យោភាព ដ៏ធំទូលាយ ចម្រើន បរិបូណ៌នូវបញ្ញាដែលខ្លួនបានហើយ ។ ហេតុបច្ច័យ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ចូលទៅអាស្រ័យនៅនឹងគ្រូ ឬ សព្រហ្មចារីបុគ្គលណាមួយ ជាគរុដ្ឋានិយបុគ្គល (បុគ្គលតាំងនៅក្នុងស្ថានដែលគួរគោរព)

យត្ថស្ស តិព្វំ ហិរោត្តប្បំ បច្ចុបដ្ឋិតំ ហោតិ បេមញ្ច គារវោ ច អយំ ភិក្ខវេ បឋមោ ហេតុ បឋមោ បច្ចយោ អាទិព្រហ្មចរិយិកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា សំវត្តតិ ។ សោ តំ សត្ថារំ ឧបនិស្សាយ វិហរតិ អញ្ញតរំ វា គរុដ្ឋានិយំ សព្រហ្មចារឹ យត្ថស្ស តិព្វំ ហិរោត្តប្បំ បច្ចុបដ្ឋិតំ ហោតិ បេមញ្ច គារវោ ច សោ[១] កាលេន កាលំ ឧបសង្កមិត្វា បរិបុច្ឆតិ បរិបញ្ហតិ ឥទំ ភន្តេ កថំ ឥមស្ស កោ អត្ថោតិ ។ តស្ស តេ អាយស្មន្តោ អវិវដញ្ចេវ វិវដន្តិ[២] អនុត្តានីកតញ្ច ឧត្តានីករោន្តិ អនេកវិហិតេសុ ច កង្ខដ្ឋានិយេសុ ធម្មេសុ កង្ខំ បដិវិនោទេន្តិ អយំ ភិក្ខវេ ទុតិយោ ហេតុ ទុតិយោ បច្ចយោ អាទិព្រហ្មចរិយិកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា សំវត្តតិ ។

---

១ ឱ. ម. តេ ។ ២ ឱ. ម. វិវរន្តិ ។

ជាអ្នកមានហិរិ និង ឱត្តប្បៈដ៏ក្លៀវក្លា តម្កល់នូវសេចក្តីស្រឡាញ់ និងសេចក្តីគោរព ចំពោះបុគ្គលជាគរុដ្ឋានិយៈ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុ នេះជាបច្ច័យទី ១ ដែលប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវបញ្ញាជាខាងដើម នៃមគ្គព្រហ្មចារ្យដែលខ្លួនមិនធ្លាប់បាន ដើម្បីជាភិយ្យោភាព ដ៏ធំទូលាយ ចម្រើន បរិបូណ៌នូវបញ្ញាដែលខ្លួនបាន ។ បុគ្គលនោះចូលទៅអាស្រ័យនៅនឹងគ្រូនោះ ឬសព្រហ្មចារីបុគ្គលណាមួយ ជាគរុដ្ឋានិយៈ ជាអ្នកមានហិរិនិង ឱត្តប្បៈដ៏ក្លៀវក្លា តម្កល់សេចក្តីស្រឡាញ់ និងសេចក្តីគោរពចំពោះបុគ្គលគរុដ្ឋានិយៈ ភិក្ខុនោះចូលទៅរក (បុគ្គលនោះ) តាមកាលគួរ ហើយសាកសួរត្រង់ប្រស្នាថា បពិត្រលោកដ៏ចម្រើន ហេតុនេះដូចម្តេច សេចក្តីអធិប្បាយនៃភាសិតនេះដូចម្តេច ។ លោកដ៏មានអាយុទាំងឡាយនោះ បើកបង្ហាញនូវធម៌ដែលកំបាំងផង ធ្វើធម៌ដែលមានជម្រៅឲ្យរាក់ផង បន្ទោបង់នូវសេចក្តីសង្ស័យ ក្នុងធម៌ដែលគួរសង្ស័យច្រើនប្រការផង ដល់ភិក្ខុនោះ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ២ ជាបច្ច័យ ទី ២ ដែលប្រព្រឹត្តទៅដើម្បីបានចំពោះនូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យដែលខ្លួនមិនធ្លាប់បាន ដើម្បីជាភិយ្យោភាព ដ៏ធំទូលាយ ចម្រើន បរិបូណ៌នូវបញ្ញាដែលខ្លួនបាន ។

បណ្ណាសកេ មេត្តាវគ្គោ

សោ តំ ធម្មំ សុត្វា ទ្វយេន វូបកាសេន សម្បាទេតិ កាយវូបកាសេន ច ចិត្តវូបកាសេន ច អយំ ភិក្ខវេ តតិយោ ហេតុ តតិយោ បច្ចយោ អាទិ-ព្រហ្មចរិយិកាយ បញ្ញាយ អប្បដិលទ្ធាយ បដិ-លាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា សំវត្តតិ ។ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ អយំ ភិក្ខវេ ចតុត្ថោ ហេតុ ចតុត្ថោ បច្ចយោ អាទិព្រហ្មចរិយិកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា សំវត្តតិ ។ ពហុស្សុតោ ហោតិ សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យា-ណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ

ភិក្ខុនោះ លុះបានស្តាប់ធម៌នោះហើយ ទើបញ៉ាំងសេចក្តីស្ងប់រម្ងាប់ ២ ប្រការឲ្យសម្រេច គឺការស្ងប់រម្ងាប់កាយ ១ ស្ងប់រម្ងាប់ចិត្ត ១ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៣ ជាបច្ច័យទី ៣ ដែលប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនធ្លាប់បាន ដើម្បីជាភិយ្យោភាព ដ៏ធំទូលាយ ចម្រើន បរិបូណ៌នូវបញ្ញាដែលខ្លួនបាន ។ ភិក្ខុជាអ្នកមានសីល សង្រួមហើយក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីបន្តិចបន្តួច សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៤ ជាបច្ច័យទី ៤ ដែលប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវបញ្ញាជាខាងដើមនៃមគ្គព្រហ្មចារ្យដែលខ្លួនមិនធ្លាប់បាន ដើម្បីជាភិយ្យោ-ភាពដ៏ធំទូលាយ ចម្រើន បរិបូណ៌នូវបញ្ញាដែលខ្លួនបាន ។ ភិក្ខុជាអ្នករៀនសូត្រច្រើន ទ្រទ្រង់ព្រះសូត្រ ចេះចាំព្រះសូត្រ ធម៌ទាំងឡាយណាមានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ប្រកាសនូវព្រហ្ម-ចរិយធម៌ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ដ៏បរិបូណ៌បរិសុទ្ធទាំងអស់

តថារូបស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា អយំ ភិក្ខវេ បញ្ចមោ ហេតុ បញ្ចមោ បច្ចយោ អាទិព្រហ្មចរិយិកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា សំវត្តតិ ។ អារទ្ធវីរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ អយំ ភិក្ខវេ ឆដ្ឋោ ហេតុ ឆដ្ឋោ បច្ចយោ អាទិព្រហ្មចរិយិកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា សំវត្តតិ ។ សង្ឃគតោ ខោ បន អនានាកថិកោ ហោតិ អតិរច្ឆានកថិកោ សាមំ វា ធម្មំ ភាសតិ បរំ វា អជ្ឈេសតិ អរិយំ វា តុណ្ហីភាវំ នាតិមញ្ញតិ អយំ ភិក្ខវេ សត្តមោ ហេតុ សត្តមោ បច្ចយោ

ធម៌ទាំងឡាយ មានសភាពដូច្នោះ ភិក្ខុនោះ បានរៀនសូត្រច្រើន ទ្រទ្រង់ចាំស្ទាត់ រត់មាត់ ជាក់ច្បាស់ក្នុងចិត្ត យល់ច្បាស់ដោយទិដ្ឋិ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៥ ជាបច្ច័យទី ៥ ដែលប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនធ្លាប់បាន ដើម្បីជាភិយ្យោភាព ដ៏ធំទូលាយ ចម្រើន បរិបូណ៌នូវបញ្ញាដែលខ្លួនបាន ។ ភិក្ខុប្រារព្ធសេចក្តីព្យាយាម ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយ ហើយបំពេញនូវកុសលធម៌ទាំងឡាយ មានកម្លាំង មានសេចក្តីប្រឹងប្រែងដ៏មាំ មិនដាក់ធុរៈក្នុងធម៌ទាំងឡាយជាកុសល ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៦ ជាបច្ច័យទី ៦ ដែលប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនមិនធ្លាប់បាន ដើម្បីជាភិយ្យោភាពដ៏ធំទូលាយ ចម្រើន បរិបូណ៌នូវបញ្ញាដែលខ្លួនបាន ។ ភិក្ខុនៅក្នុងសង្ឃ មិនមែននិយាយផ្តេសផ្តាស មិនមែនជាអ្នកនិយាយតិរច្ឆានកថា រមែងសម្តែងធម៌ដោយខ្លួនឯងផង អារាធនាអ្នកឯទៀតឲ្យសម្តែងផង មិនមើលងាយព្រះអរិយៈដែលស្ងប់ស្ងៀមផង ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៧ ជាបច្ច័យទី ៧

៧



អាទិព្រហ្មចរិយិកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា សំវត្តតិ ។ បញ្ចសុ ខោ បន ឧបាទានក្ខន្ធេសុ ឧទយព្វយានុបស្សី វិហរតិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អដ្ឋង្គមោ ឥតិ វេទនា ឥតិ សញ្ញា ឥតិ សង្ខារា ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អដ្ឋង្គមោតិ អយំ ភិក្ខវេ អដ្ឋមោ ហេតុ អដ្ឋមោ បច្ចយោ អាទិព្រហ្មចរិយិកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា សំវត្តតិ ។ តមេនំ សព្រហ្មចារី ឯវំ សម្ភាវេន្តិ អាយស្មា[១] សត្ថារំ ឧបនិស្សាយ វិហរតិ អញ្ញតរំ វា គរុដ្ឋានិយំ សព្រហ្មចារឹ យត្ថស្ស តិព្វំ ហិរោត្តប្បំ បច្ចុបដ្ឋិតំ ហោតិ បេមញ្ច គារវោ ច អទ្ធា អយមាយស្មា ជានំ ជានាតិ បស្សំ បស្សតីតិ អយំបិ ធម្មោ បិយតាយ គរុតាយ ភាវនាយ សាមញ្ញាយ ឯកីភាវាយ សំវត្តតិ ។

១ ឱ. ម. អយំ ខោ អាយស្មា ។

ដែលប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យ ដែលខ្លួនធ្លាប់បាន ដើម្បីជាភិយ្យោភាព ដ៏ធំទូលាយ ចម្រើនបរិបូណ៌នូវបញ្ញា ដែលខ្លួនបាន ។ ភិក្ខុពិចារណាឃើញរឿយៗ នូវការកើតឡើងនិងសូន្យទៅក្នុងឧបាទានក្ខន្ធទាំងឡាយ ៥ ថា រូបដូច្នេះ ការកើតឡើងនៃរូបដូច្នេះ ការវិនាសនៃរូបដូច្នេះ វេទនាដូច្នេះ សញ្ញាដូច្នេះ សង្ខារទាំងឡាយដូច្នេះ វិញ្ញាណដូច្នេះ ការកើតឡើងនៃវិញ្ញាណដូច្នេះ ការវិនាសទៅនៃវិញ្ញាណដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ នេះជាហេតុទី ៨ ជាបច្ច័យទី ៨ ដែលប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវបញ្ញា ជាខាងដើមនៃមគ្គព្រហ្មចារ្យដែលខ្លួនមិនធ្លាប់បាន ដើម្បីជាភិយ្យោភាព ដ៏ធំទូលាយ ចម្រើន បរិបូណ៌នូវបញ្ញាដែលខ្លួនបានហើយ ។ ពួកសព្រហ្មចារីបុគ្គលតែងនាំគ្នាសរសើរនូវភិក្ខុនោះយ៉ាងនេះថា លោកដ៏មានអាយុ (នេះ) បានចូលទៅនៅអាស្រ័យនឹងគ្រូ ឬសព្រហ្មចារីបុគ្គលណាមួយជាគរុដ្ឋានិយៈ ជាអ្នកមានហិរិនិងឱត្តប្បៈ តម្កល់សេចក្ដីស្រឡាញ់ និងសេចក្ដីគោរពចំពោះបុគ្គលជាគរុដ្ឋានិយៈដោយគិតថា លោកដ៏មានអាយុនេះដឹងនូវហេតុដែលគួរដឹងឃើញនូវហេតុដែលគួរឃើញដោយពិត ធម៌នេះប្រព្រឹត្តទៅ ដើម្បីឲ្យគេស្រឡាញ់ ដើម្បីឲ្យគេគោរព ដើម្បីញុំាងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្ដីស្ងប់ស្ងាត់ ។

តំ ខោ បដាយមាយស្មា សត្ថារំ ឧបនិស្សាយ វិហរតិ អញ្ញតរំ វា គរុដ្ឋានិយំ សព្រហ្មចារឹ យត្ថស្ស តិព្វំ ហិរោត្តប្បំ បច្ចុបដ្ឋិតំ ហោតិ បេមញ្ច គារវោ ច សោ កាលេន កាលំ ឧបសង្កមិត្វា បរិបុច្ឆតិ បរិបញ្ហតិ ឥទំ ភន្តេ កថំ ឥមស្ស កោ អត្ថោតិ ។ តស្ស តេ អាយស្មន្តោ អវិវដញ្ចេវ វិវដន្តិ អនុត្តានីកតញ្ច ឧត្តានី-ករោន្តិ អនេកវិហិតេសុ ច កង្ខដ្ឋានិយេសុ ធម្មេសុ កង្ខំ បដិវិនោទេន្តិ អទ្ធា អយមាយស្មា ជានំ ជានាតិ បស្សំ បស្សតីតិ អយំបិ ធម្មោ បិយតាយ គរុតាយ ភាវនាយ សាមញ្ញាយ ឯកីភាវាយ សំវត្តតិ ។ តំ ខោ បដាយមាយស្មា ធម្មំ សុត្វា ទ្វយេន វូបកាសេន សម្បាទេតិ កាយវូបកាសេន ច ចិត្តវូបកាសេន ច អទ្ធា អយមាយស្មា ជានំ ជានាតិ បស្សំ បស្សតីតិ អយំបិ ធម្មោ បិយតាយ គរុតាយ ភាវនាយ សាមញ្ញាយ ឯកីភាវាយ សំវត្តតិ ។

ចំណែកលោកដ៏មានអាយុនេះ ចូលទៅនៅអាស្រ័យនឹងគ្រូនោះ ឬសព្រហ្មចារីបុគ្គលណាមួយ ជាគរុដ្ឋានិយៈ ជាអ្នកមានហិរិនិងឱត្តប្បៈតម្កល់សេចក្តីស្រឡាញ់ និងសេចក្តីគោរព ចំពោះបុគ្គល ជាគរុដ្ឋានិយៈលុះលោកដ៏មានអាយុនោះ ចូលទៅរកគ្រូនោះតាមកាល ដ៏សមគួរហើយសាកសួរត្រង់ប្រស្នាថា បពិត្រលោកដ៏ចម្រើន ហេតុនេះដូចម្តេច សេចក្តីអធិប្បាយនៃភាសិតនេះដូចម្តេច ។ លោកដ៏មានអាយុទាំងនោះ ក៏បើកបង្ហាញនូវធម៌ដែលកំបាំងផង ធ្វើធម៌ដែលមានជម្រៅឲ្យរាក់ផង បន្ទោ-បង់នូវសេចក្តីសង្ស័យ ក្នុងធម៌ទាំងឡាយដែលគួរសង្ស័យច្រើនប្រការផងដោយគិតថា លោកដ៏មានអាយុនេះ រមែងដឹងនូវហេតុដែលគួរដឹង ឃើញនូវហេតុដែលគួរឃើញដោយពិត ឯធម៌នេះប្រព្រឹត្តទៅ ដើម្បីឲ្យគេស្រឡាញ់ ដើម្បីឲ្យគេគោរព ដើម្បីញុំាងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្តីស្ងប់ស្ងាត់ ។ លុះលោកមានអាយុនេះ ស្តាប់ធម៌នោះហើយ ទើបញុំាងការស្ងប់រម្ងាប់ ២ ប្រការឲ្យសម្រេច គឺការស្ងប់រម្ងាប់កាយ ១ ស្ងប់រម្ងាប់ចិត្ត ១ ដោយគិតថា លោកដ៏មានអាយុនេះ រមែងដឹងនូវហេតុដែលគួរដឹង ឃើញនូវហេតុដែលគួរឃើញដោយពិត ធម៌នេះឯងប្រព្រឹត្តទៅ ដើម្បីឲ្យគេស្រឡាញ់ ដើម្បីឲ្យគេគោរព ដើម្បីញុំាងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្តីស្ងប់ស្ងាត់ ។

៩

បណ្ណាសកេ មេត្តាវគ្គោ

សីលវា ខោ បនាយមាយស្មា បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ អទ្ធា អយមាយស្មា ជានំ ជានាតិ បស្សំ បស្សតីតិ អយំបិ ធម្មោ បិយតាយ គរុតាយ ភាវនាយ សាមញ្ញាយ ឯកីភាវាយ សំវត្តតិ ។ ពហុស្សុតោ ខោ បនាយមាយស្មា សុតធរោ សុតសន្និចយោ យេ តេ ធម្មា អាទិកល្យាណា មជ្ឈេកល្យាណា បរិយោសានកល្យាណា សាត្ថំ សព្យញ្ជនំ កេវលបរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ អភិវទន្តិ តថារូបាស្ស ធម្មា ពហុស្សុតា ហោន្តិ ធតា វចសា បរិចិតា មនសានុបេក្ខិតា ទិដ្ឋិយា សុប្បដិវិទ្ធា អទ្ធា អយមាយស្មា ជានំ ជានាតិ បស្សំ បស្សតីតិ អយំបិ ធម្មោ បិយតាយ គរុតាយ ភាវនាយ សាមញ្ញាយ ឯកីភាវាយ សំវត្តតិ ។ អារទ្ធវីរិយោ ខោ បនាយមាយស្មា វិហរតិ អកុសលានំ ធម្មានំ បហានាយ

ចំណែកខាងលោកដ៏មានអាយុនេះ ជាអ្នកមានសីល សង្រួមហើយក្នុងបាតិមោក្ខសំវរៈ បរិបូណ៌ដោយអាចារៈនិងគោចរៈ ឃើញភ័យក្នុងទោសទាំងឡាយបន្តិចបន្តួច សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយក៏គិតថា លោកដ៏មានអាយុនេះ រមែងដឹងនូវហេតុដែលគួរដឹង ឃើញនូវហេតុដែលគួរឃើញដោយពិត ធម៌នេះឯងប្រព្រឹត្តទៅ ដើម្បីឲ្យគេស្រឡាញ់ ដើម្បីឲ្យគេគោរព ដើម្បីញ៉ាំងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្តីស្ងប់ស្ងាត់ ។ ចំណែកលោកដ៏មានអាយុនេះ ជាអ្នករៀនសូត្រច្រើន ទ្រទ្រង់ព្រះសូត្រ ចេះដឹងព្រះសូត្រ ធម៌ទាំងឡាយណា មានពីរោះបទដើម ពីរោះបទកណ្តាល ពីរោះបទចុង ប្រកាសនូវព្រហ្មចរិយធម៌ ព្រមទាំងអត្ថ ព្រមទាំងព្យញ្ជនៈ ដ៏បរិបូណ៌ បរិសុទ្ធទាំងអស់ ធម៌ទាំងឡាយមានសភាពដូច្នោះ ភិក្ខុនោះបានរៀនសូត្រច្រើន ទ្រទ្រង់ ចាំស្ទាត់ រត់មាត់ ជាក់ច្បាស់ក្នុងចិត្ត យល់ច្បាស់ដោយទិដ្ឋិ ក៏គិតថា លោកដ៏មានអាយុនេះ រមែងដឹងនូវហេតុដែលគួរដឹង ឃើញនូវហេតុដែលគួរឃើញដោយពិត ធម៌នេះឯងប្រព្រឹត្តទៅ ដើម្បីឲ្យគេស្រឡាញ់ ដើម្បីឲ្យគេគោរព ដើម្បីញ៉ាំងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្តីស្ងប់ស្ងាត់ ។ ចំណែកខាងលោកដ៏មានអាយុនេះ ប្រារព្ធនូវសេចក្តីព្យាយាម ដើម្បីលះបង់នូវអកុសលធម៌ទាំងឡាយ

កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ធម្មបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ អទ្ធា អយមាយស្មា ជានំ ជានាតិ បស្សំ បស្សតីតិ អយំបិ ធម្មោ បិយតាយ គរុតាយ ភាវនាយ សាមញ្ញាយ ឯកីភាវាយ សំវត្តតិ ។ សង្ឃគតោ ខោ បនាយមាយស្មា អនានាកថិកោ អតិរច្ឆានកថិកោ សាមំ វា ធម្មំ ភាសតិ បរំ វា អជ្ឈេសតិ អរិយំ វា តុណ្ហីភាវំ នាតិមញ្ញតិ អទ្ធា អយមាយស្មា ជានំ ជានាតិ បស្សំ បស្សតីតិ អយំបិ ធម្មោ បិយតាយ គរុតាយ ភាវនាយ សាមញ្ញាយ ឯកីភាវាយ សំវត្តតិ ។ បញ្ចសុ ខោ បនាយមាយស្មា ឧបាទានក្ខន្ធេសុ ឧទយព្វយានុបស្សី វិហរតិ ឥតិ រូបំ ឥតិ រូបស្ស សមុទយោ ឥតិ រូបស្ស អត្ថង្គមោ ឥតិ វេទនា ឥតិ សញ្ញា ឥតិ សង្ខារា ឥតិ វិញ្ញាណំ ឥតិ វិញ្ញាណស្ស សមុទយោ ឥតិ វិញ្ញាណស្ស អត្ថង្គមោតិ

ដើម្បីបំពេញនូវកុសលធម៌ទាំងឡាយ ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងមាំ មិនដាក់ធុរៈក្នុងធម៌ជាកុសល ក៏គិតថា លោកដ៏មានអាយុនេះ រមែងដឹងនូវហេតុដែលគួរដឹង ឃើញនូវហេតុដែលគួរឃើញដោយពិត ធម៌នេះឯងប្រព្រឹត្តទៅ ដើម្បីឲ្យគេស្រឡាញ់ ដើម្បីឲ្យគេគោរព ដើម្បីញ៉ាំងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្តីស្ងប់ស្ងាត់ ។ ចំណែកខាងលោកដ៏មានអាយុនេះ តាំងនៅក្នុងសង្ឃ មិនមែននិយាយពាក្យផ្តេសផ្តាស មិនមែននិយាយតិរច្ឆានកថា តែងសម្តែងធម៌ដោយខ្លួនឯងផង អារាធនាអ្នកដទៃឲ្យសម្តែងផង មិនមើលងាយនូវព្រះអរិយៈដែលស្ងប់ស្ងៀមផង ដោយគិតថា លោកដ៏មានអាយុនេះ រមែងដឹងនូវហេតុដែលគួរដឹង ឃើញនូវហេតុដែលគួរឃើញដោយពិត ធម៌នេះឯងប្រព្រឹត្តទៅ ដើម្បីឲ្យគេស្រឡាញ់ ដើម្បីឲ្យគេគោរព ដើម្បីញ៉ាំងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្តីស្ងប់ស្ងាត់ ។ ក៏ឯលោកដ៏មានអាយុនេះ ពិចារណាឃើញរឿយៗ នូវការចម្រើនឡើង និងការសាបសូន្យទៅ ក្នុងឧបាទានក្ខន្ធទាំងឡាយ ៥ ថា រូបដូច្នេះ ការកើតឡើងនៃរូបដូច្នេះ ការវិនាសទៅនៃរូបដូច្នេះ វេទនាដូច្នេះ សញ្ញាដូច្នេះ សង្ខារទាំងឡាយដូច្នេះ វិញ្ញាណដូច្នេះ ការកើតឡើងនៃវិញ្ញាណដូច្នេះ ការវិនាសនៃវិញ្ញាណដូច្នេះ

អត្ថា អយមាយស្មា ជានំ ជានាតិ បស្សំ បស្សតីតិ អយំបិ ធម្មោ បិយតាយ គរុតាយ ភាវនាយ សាមញ្ញាយ ឯកីភាវាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ អដ្ឋ ហេតូ អដ្ឋ បច្ចយា អាទិព្រហ្មចរិយិកាយ បញ្ញាយ អប្បដិលទ្ធាយ បដិលាភាយ បដិលទ្ធាយ ភិយ្យោភាវាយ វេបុល្លាយ ភាវនាយ បារិបូរិយា សំវត្តន្តីតិ ។

[៣] អដ្ឋហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ សព្រហ្មចារីនំ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ កាតមេហិ អដ្ឋហិ ។ ឥធ ភិក្ខវេ ភិក្ខុ អប្បិយបសំសី ច ហោតិ បិយគរហី ច លាភកាមោ ច សក្ការកាមោ ច អហិរិកោ ច អនោត្តប្បី ច បាបិច្ឆោ ច មិច្ឆាទិដ្ឋិ ច ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សព្រហ្មចារីនំ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ អដ្ឋហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ

ក៏គិតថា លោកដ៏មានអាយុនេះ រមែងដឹងនូវហេតុដែលគួរដឹង ឃើញនូវហេតុដែលគួរឃើញដោយពិត ធម៌នេះឯងប្រព្រឹត្តទៅ ដើម្បីឲ្យគេស្រឡាញ់ ដើម្បីឲ្យគេគោរព ដើម្បីញ៉ាំងគុណឲ្យចម្រើន ដើម្បីភាពជាសមណៈ ដើម្បីសេចក្ដីស្ងប់ស្ងាត់ ។ ម្នាលភិក្ខុទាំងឡាយ ហេតុទាំង ៨ យ៉ាង បច្ច័យទាំង ៨ យ៉ាងនេះឯង ប្រព្រឹត្តទៅ ដើម្បីបានចំពោះនូវបញ្ញាជាខាងដើមនៃមគ្គព្រហ្មចារ្យដែលខ្លួនមិនធ្លាប់បាន ដើម្បីជាភិយ្យោភាពដ៏ធំទូលាយ ចម្រើនបរិបូណ៌នូវបញ្ញាដែលខ្លួនបាន ។

[៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរនៃសព្រហ្មចារីបុគ្គលទាំងឡាយ ។ ធម៌ ៨ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកសរសើរចំពោះបុគ្គលមិនជាទីស្រឡាញ់ ១ តិះដៀលនូវជនជាទីស្រឡាញ់ ១ ប្រាថ្នាលាភ ១ ប្រាថ្នាសក្ការៈ ១ មិនខ្មាសបាប ១ មិនខ្លាចបាប ១ ប្រាថ្នាលាមក ១ យល់ខុស ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាងនេះឯង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរ នៃសព្រហ្មចារីបុគ្គលទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាង

សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។ កតមេហិ អដ្ឋហិ ។ ឥធ ភិក្ខវេ ភិក្ខុ ន អប្បិយបសំសី ច ហោតិ ន បិយគរហី ច ន លាភកាមោ ច ន សក្ការកាមោ ច ហិរិមា ច ឱត្តប្បី ច អប្បិច្ឆោ ច សម្មាទិដ្ឋិ ច ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ចាតិ ។

[៤] អដ្ឋហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ សព្រហ្មចារីនំ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ កតមេហិ អដ្ឋហិ ។ ឥធ ភិក្ខវេ ភិក្ខុ លាភកាមោ ច ហោតិ សក្ការកាមោ ច អនវញ្ញត្តិ-កាមោ ច អកាលញ្ញូ ច អមត្តញ្ញូ ច អសុចិ ច ពហុ-ភាណី ច អក្កោសកបរិភាសកោ ច សព្រហ្មចារីនំ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតោ ភិក្ខុ

រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរនៃសព្រហ្មចារីបុគ្គលទាំងឡាយ ។ ធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនសរសើរនូវបុគ្គលមិនជាទីស្រឡាញ់ ១ មិនតិះដៀលនូវជនជាទីស្រឡាញ់ ១ មិនប្រាថ្នាលាភ ១ មិនប្រាថ្នាសក្ការៈ ១ មានសេចក្តីខ្មាសបាប ១ មានសេចក្តីខ្លាចបាប ១ ប្រាថ្នាតិច ១ មានសេចក្តីយល់ត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាងនេះឯង ទើបជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ នៃសព្រហ្មចារីបុគ្គលទាំងឡាយ ។

[៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាង រមែងមិនជាទីស្រឡាញ់ មិនជាទីពេញចិត្ត មិនជាទីគោរព មិនជាទីសរសើរ នៃសព្រហ្មចារីបុគ្គលទាំងឡាយ ។ ធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រាថ្នាលាភ ១ ប្រាថ្នាសក្ការៈ ១ ប្រាថ្នាមិនឲ្យគេមើលងាយ ១ មិនស្គាល់កាល ១ មិនស្គាល់ប្រមាណ ១ មានការងារមិនស្អាត ១ និយាយច្រើន ១ ជេរប្រទេចផ្តាសានូវសព្រហ្មចារីបុគ្គលទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាងនេះឯង

សព្រហ្មចារីនំ អប្បិយោ ច ហោតិ អមនាបោ ច អគរុ ច អភាវនីយោ ច ។ អដ្ឋហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ច ។ កតមេហិ អដ្ឋហិ ។ ឥធ ភិក្ខវេ ភិក្ខុ ន លាភកាមោ ច ន សក្ការកាមោ ច ន អនវញ្ញត្តិកាមោ ច កាលញ្ញូ ច មត្តញ្ញូ ច សុចិ ច ន ពហុភាណី ច អនក្កោសកបរិភាសកោ ច សព្រហ្មចារីនំ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សព្រហ្មចារីនំ បិយោ ច ហោតិ មនាបោ ច គរុ ច ភាវនីយោ ចាតិ ។

[៥] អដ្ឋិមេ ភិក្ខវេ លោកធម្មា លោកំ អនុ-បរិវត្តន្តិ លោកោ ច អដ្ឋ លោកធម្មេ អនុបរិវត្តតិ ។ កតមេ អដ្ឋ ។ លាភោ ច អលាភោ ច យសោ ច អយសោ ច និន្ទា ច បសំសា ច សុខំ ច ទុក្ខំ ច ។ ឥមេ ខោ ភិក្ខវេ អដ្ឋ លោកធម្មា

រមែង មិនជាទីស្រឡាញ់ មិនជាទីគាប់ចិត្ត មិនជាទីគោរព មិនជាទីសរសើរ នៃសព្រហ្មចារីបុគ្គលទាំងឡាយឡើយ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាង រមែងជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព គួរជាទីសរសើរ នៃសព្រហ្មចារីបុគ្គលទាំងឡាយ ។ ធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនប្រាថ្នាលាភ ១ មិនប្រាថ្នាសក្ការៈ ១ មិនមែនជាអ្នកប្រាថ្នាមិនឲ្យអ្នកដទៃមើលងាយ ១ ស្គាល់កាល ១ ស្គាល់ប្រមាណ ១ មានការងារស្អាត ១ មិននិយាយច្រើន ១ មិនជេរប្រទេចផ្តាសានូវសព្រហ្មចារីបុគ្គលទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាងនេះឯង ទើបជាទីស្រឡាញ់ ជាទីពេញចិត្ត ជាទីគោរព ជាទីសរសើរ នៃសព្រហ្មចារីបុគ្គលទាំងឡាយ ។

[៥] ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំងឡាយ ៨ យ៉ាងនេះ តែងជាប់តាមនូវសត្វលោក ទាំងសត្វលោក ក៏វិលទៅតាមនូវលោកធម៌ទាំង ៨ ដែរ ។ លោកធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ។ គឺលាភ ១ អលាភ ១ យស ១ អយស ១ និន្ទា ១ បសំសា ១ សុខ ១ ទុក្ខ ១ ។ ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំង ៨ យ៉ាងនេះឯង

លោកំ អនុបរិវត្តន្តិ លោកោ ច ឥមេ អដ្ឋ លោកធម្មេ អនុបរិវត្តតីតិ ។

លាភោ អលាភោ ច យសាយសោ ច
និន្ទា បសំសា ច សុខំ ទុក្ខញ្ច
ឯតេ អនិច្ចា មនុជេសុ ធម្មា
អសស្សតា វិបរិណាមធម្មា
ឯតេ ច ញត្វា សតិមា សុមេធោ
អវេក្ខតិ វិបរិណាមធម្មេ
ឥដ្ឋស្ស ធម្មា ន មថេន្តិ ចិត្តំ
អនិដ្ឋតោ នោ បដិឃាតមេតិ
តស្សានុរោធា អថ វា វិរោធា
វិធូបិតា អត្ថគតា ន សន្តិ
បទញ្ច ញត្វា វិរជំ អសោកំ
សម្មប្បជានាតិ ភវស្ស បារគូតិ ។

តែងជាប់តាមសត្វលោក ទាំងសត្វលោក ក៏វិលទៅតាមនូវលោកធម៌ ទាំង ៨ យ៉ាងនេះដែរ ។

ធម៌ទាំងឡាយនេះគឺ លាភៈ ១ អលាភៈ ១ យសៈ ១ អយសៈ ១ និន្ទា ១ បសំសា ១ សុខ ១ ទុក្ខ ១ ជាធម៌មិនទៀង ក្នុងមនុស្សជាតិទាំងឡាយ ជាធម៌មិនឋិតថេរ មានសេចក្ដីប្រែប្រួលជាធម្មតា ចំណែកបុគ្គលអ្នកមានប្រាជ្ញា មានស្មារតី លុះដឹងនូវធម៌នេះហើយ រមែងពិចារណានូវធម៌ដែលមានសេចក្ដីប្រែប្រួលជាធម្មតា ឥដ្ឋារម្មណ៍ទាំងឡាយ រមែងមិនញាំញីនូវចិត្តរបស់បុគ្គលនោះបាន ទាំងអនិដ្ឋារម្មណ៍ក៏មិនអាចប៉ះទង្គិចបាន សេចក្ដីត្រេកអរ ឬជាសេចក្ដីថ្នាំងថ្នាក់ចិត្ត ក៏បុគ្គលនោះបានកម្ចាត់បង់ហើយដល់នូវសេចក្ដីវិនាស មិនមានតទៅទៀតឡើយ បុគ្គលអ្នកដល់នូវត្រើយនៃភព រមែងដឹងច្បាស់ដោយប្រពៃ ព្រោះដឹងច្បាស់នូវបទគឺព្រះនិព្វានដែលមិនមានធូលីគឺកិលេស មិនមានសេចក្ដីសោក ។

[៦] អដ្ឋិមេ ភិក្ខវេ លោកធម្មា លោកំ អនុបរិវត្តន្តិ លោកោ ច អដ្ឋ លោកធម្មេ អនុបរិវត្តតិ ។ កតមេ អដ្ឋ ។ លាភោ ច អលាភោ ច យសោ ច អយសោ ច និន្ទា ច បសំសា ច សុខំ ច ទុក្ខំ ច ។ ឥមេ ខោ ភិក្ខវេ អដ្ឋ លោកធម្មា លោកំ អនុបរិវត្តន្តិ លោកោ ច ឥមេ អដ្ឋ លោកធម្មេ អនុបរិវត្តតិ ។ អស្សុតវតោ ភិក្ខវេ បុថុជ្ជនស្ស ឧប្បជ្ជតិ លាភោបិ អលាភោបិ យសោបិ អយសោបិ និន្ទាបិ បសំសាបិ សុខំបិ ទុក្ខំបិ សុតវតោបិ ភិក្ខវេ អរិយសាវកស្ស ឧប្បជ្ជតិ លាភោបិ អលាភោបិ យសោបិ អយសោបិ និន្ទាបិ បសំសាបិ សុខំបិ ទុក្ខំបិ ។ តត្រ ភិក្ខវេ កោ វិសេសោ កោ អធិប្បាយសោ កឹ នានាករណំ សុតវតោ អរិយសាវកស្ស អស្សុតវតា បុថុជ្ជនេនាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំបដិសរណា សាធុ វត ភន្តេ ភគវន្តំ យេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។

[៦] ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំង ៨ យ៉ាងនេះ តែងជាប់តាមសត្វលោក ទាំងសត្វលោក ក៏វិលទៅតាមនូវលោកធម៌ទាំង ៨ យ៉ាងដែរ ។ លោកធម៌ ៨ យ៉ាង តើដូចម្តេចខ្លះ ។ គឺលាភ ១ អលាភ ១ យស ១ អយស ១ និន្ទា ១ បសំសា ១ សុខ ១ ទុក្ខ ១ ។ ម្នាលភិក្ខុទាំងឡាយ លោកធម៌ទាំង ៨ យ៉ាងនេះឯង តែងជាប់តាមសត្វលោក ទាំងសត្វលោក ក៏វិលទៅតាមនូវលោកធម៌ទាំង ៨ យ៉ាងដែរ ។ ម្នាលភិក្ខុទាំងឡាយ លាភក្តី អលាភក្តី យសក្តី អយសក្តី និន្ទាក្តី បសំសាក្តី សុខក្តី ទុក្ខក្តី តែងកើតឡើងដល់បុថុជ្ជនអ្នកមិនចេះដឹង ម្នាលភិក្ខុទាំងឡាយ លាភក្តី អលាភក្តី យសក្តី អយសក្តី និន្ទាក្តី បសំសាក្តី សុខក្តី ទុក្ខក្តី តែងកើតឡើងដល់អរិយសាវ័ក អ្នកចេះដឹងដែរ ។ ម្នាលភិក្ខុទាំងឡាយ ចុះក្នុងលោកធម៌ទាំងនោះមានសេចក្តីប្លែកគ្នាដូចម្តេច មានអធិប្បាយដូចម្តេច មានហេតុផ្សេងគ្នាដូចម្តេច របស់អរិយសាវ័កអ្នកចេះដឹង និងបុថុជ្ជនអ្នកមិនចេះដឹង ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយ មានព្រះដ៏មានព្រះភាគជាមូល មានព្រះដ៏មានព្រះភាគជាអ្នកណែនាំ មានព្រះដ៏មានព្រះភាគជាទីពឹងរបស់យើងទាំងឡាយ ស្រាប់ហើយ បពិត្រព្រះអង្គដ៏ចម្រើន សេចក្តីនៃភាសិតនោះជាក់ច្បាស់ដល់ព្រះដ៏មានព្រះភាគដោយល្អស្រាប់ហើយ ភិក្ខុទាំងឡាយបានស្តាប់ (ធម៌) របស់ព្រះដ៏មានព្រះភាគ នឹងចងចាំទុកបាន ។

តេនហិ ភិក្ខវេ សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច អស្សុតវតោ ភិក្ខវេ បុថុជ្ជនស្ស ឧប្បជ្ជតិ លាភោ សោ ន ឥតិ បដិសញ្ចិក្ខតិ ឧប្បន្នោ ខោ មេ អយំ លាភោ សោ ច ខោ អនិច្ចោ ទុក្ខោ វិបរិណាមធម្មោតិ យថាភូតំ នប្បជានាតិ ឧប្បជ្ជតិ អលាភោ ឧប្បជ្ជតិ យសោ ឧប្បជ្ជតិ អយសោ ឧប្បជ្ជតិ និន្ទា ឧប្បជ្ជតិ បសំសា ឧប្បជ្ជតិ សុខំ ឧប្បជ្ជតិ ទុក្ខំ សោ ន ឥតិ បដិសញ្ចិក្ខតិ ឧប្បន្នំ ខោ មេ ឥទំ ទុក្ខំ តញ្ច ខោ អនិច្ចំ ទុក្ខំ វិបរិណាមធម្មន្តិ យថាភូតំ នប្បជានាតិ ។ តស្ស លាភោបិ ចិត្តំ បរិយាទាយ តិដ្ឋតិ អលាភោបិ ចិត្តំ បរិយាទាយ តិដ្ឋតិ យសោបិ ចិត្តំ បរិយាទាយ តិដ្ឋតិ អយសោបិ ចិត្តំ បរិយាទាយ តិដ្ឋតិ និន្ទាបិ ចិត្តំ បរិយាទាយ តិដ្ឋតិ

ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ ចូរអ្នកទាំងឡាយ ប្រុងស្តាប់ធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនេះ ទទួលព្រះពុទ្ធដីកាព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគបានត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ លាភតែងកើតឡើងដល់បុថុជ្ជនអ្នកមិនចេះដឹង បុថុជ្ជននោះមិនពិចារណាមិនដឹងច្បាស់តាមពិតដូច្នេះថា លាភនេះកើតឡើងដល់អាត្មាអញហើយ លាភនោះឯង មិនទៀង ជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា អលាភរមែងកើតឡើង យសរមែងកើតឡើង អយសរមែងកើតឡើង និន្ទារមែងកើតឡើង បសំសារមែងកើតឡើង សុខរមែងកើតឡើង ទុក្ខរមែងកើតឡើង (ដល់បុថុជ្ជនអ្នកមិនចេះដឹង) បុថុជ្ជននោះមិនពិចារណា មិនដឹងច្បាស់តាមពិតដូច្នេះថា ទុក្ខនេះកើតឡើងដល់អាត្មាអញហើយ ទុក្ខនោះឯងមិនទៀង ជារបស់អត់ធន់បានដោយក្រ មានសេចក្តីប្រែប្រួលជាធម្មតា ។ លាភក្តីរមែងគ្របសង្កត់ចិត្តរបស់បុថុជ្ជននោះ អលាភក្តី រមែងគ្របសង្កត់ចិត្ត យសក្តីរមែងគ្របសង្កត់ចិត្ត អយសក្តី រមែងគ្របសង្កត់ចិត្ត និន្ទាក្តី រមែងគ្របសង្កត់ចិត្ត

១៧



បសំសាបិ ចិត្តំ បរិយាទាយ តិដ្ឋតិ សុខំបិ ចិត្តំ បរិយាទាយ តិដ្ឋតិ ទុក្ខំបិ ចិត្តំ បរិយាទាយ តិដ្ឋតិ ។ សោ ឧប្បន្នំ លាភំ អនុរុជ្ឈតិ អលាភេ បដិវិរុជ្ឈតិ ឧប្បន្នំ យសំ អនុរុជ្ឈតិ អយសេ បដិវិរុជ្ឈតិ ឧប្បន្នំ បសំសំ អនុរុជ្ឈតិ និន្ទាយ បដិវិរុជ្ឈតិ ឧប្បន្នំ សុខំ អនុរុជ្ឈតិ ទុក្ខេ បដិវិរុជ្ឈតិ ។ សោ ឯវំ អនុរោធវិរោធសមាបន្នោ ន បរិមុច្ចតិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ ន បរិមុច្ចតិ ទុក្ខស្មាតិ វទាមិ ។ សុតវតោ ខោ ភិក្ខវេ អរិយសាវកស្ស ឧប្បជ្ជតិ លាភោ សោ ឥតិ បដិសញ្ចិក្ខតិ ឧប្បន្នោ ខោ មេ អយំ លាភោ សោ ច ខោ អនិច្ចោ ទុក្ខោ វិបរិណាមធម្មោតិ យថាភូតំ បជានាតិ ឧប្បជ្ជតិ អលាភោ ឧប្បជ្ជតិ យសោ ឧប្បជ្ជតិ អយសោ ឧប្បជ្ជតិ និន្ទា ឧប្បជ្ជតិ បសំសា ឧប្បជ្ជតិ សុខំ ឧប្បជ្ជតិ ទុក្ខំ សោ ឥតិ បដិសញ្ចិក្ខតិ ឧប្បន្នំ ខោ មេ ឥទំ ទុក្ខំ តញ្ច ខោ អនិច្ចំ ទុក្ខំ វិបរិណាមធម្មន្តិ យថាភូតំ បជានាតិ ។

បសំសាក្តី រមែងគ្របសង្កត់ចិត្ត សុខក្តី រមែងគ្របសង្កត់ចិត្ត ទុក្ខក្តីរមែងគ្របសង្កត់ចិត្ត ។ បុថុជ្ជននោះ តែងត្រេកអរនឹងលាភដែលកើតឡើង តូចចិត្តព្រោះអលាភ ត្រេកអរនឹងយសដែលកើតឡើង តូចចិត្តព្រោះអយស ត្រេកអរនឹងបសំសាដែលកើតឡើង តូចចិត្តព្រោះនិន្ទា ត្រេកអរនឹងសុខដែលកើតឡើង តូចចិត្តព្រោះទុក្ខ ។ បុថុជ្ជននោះប្រកបនូវសេចក្តីត្រេកអរនិងសេចក្តីតូចចិត្តយ៉ាងនេះហើយ រមែងមិនរួចចាកជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ តថាគតពោលថាមិនរួចចាកវដ្តទុក្ខឡើយ ។ ម្នាលភិក្ខុទាំងឡាយ លាភកើតឡើងដល់អរិយសាវ័កអ្នកចេះដឹង អរិយសាវ័កនោះពិចារណាដឹងច្បាស់តាមពិតដូច្នេះថា លាភនេះកើតឡើងដល់អាត្មាអញហើយ លាភនោះឯងមិនទៀងជាទុក្ខ មានសេចក្តីប្រែប្រួលជាធម្មតា អលាភកើតឡើង យសកើតឡើង អយសកើតឡើង និន្ទាកើតឡើង បសំសាកើតឡើង សុខកើតឡើង ទុក្ខកើតឡើង អរិយសាវ័កនោះ ពិចារណាដឹងច្បាស់តាមពិតដូច្នេះថា ទុក្ខកើតឡើងដល់អាត្មាអញហើយ ទុក្ខនោះឯង ក៏មិនទៀង អត់ធន់បានដោយក្រ មានសេចក្តីប្រែប្រួលជាធម្មតា ។

ឥទំ ទុក្ខំ តញ្ច ខោ អនិច្ចំ ទុក្ខំ វិបរិណាមធម្មន្តិ យថាភូតំ បជានាតិ[១] តស្ស លាភោបិ ចិត្តំ ន បរិយាទាយ តិដ្ឋតិ អលាភោបិ ចិត្តំ ន បរិយាទាយ តិដ្ឋតិ យសោបិ ចិត្តំ ន បរិយាទាយ តិដ្ឋតិ អយសោបិ ចិត្តំ ន បរិយាទាយ តិដ្ឋតិ និន្ទាបិ ចិត្តំ ន បរិយាទាយ តិដ្ឋតិ បសំសាបិ ចិត្តំ ន បរិយាទាយ តិដ្ឋតិ សុខំបិ ចិត្តំ ន បរិយាទាយ តិដ្ឋតិ ទុក្ខំបិ ចិត្តំ ន បរិយាទាយ តិដ្ឋតិ ។ សោ ច ឧប្បន្នំ លាភំ នានុរុជ្ឈតិ អលាភេ នប្បដិវិរុជ្ឈតិ ឧប្បន្នំ យសំ នានុរុជ្ឈតិ អយសេ នប្បដិវិរុជ្ឈតិ ឧប្បន្នំ បសំសំ នានុរុជ្ឈតិ និន្ទាយ នប្បដិវិរុជ្ឈតិ ឧប្បន្នំ សុខំ នានុរុជ្ឈតិ ទុក្ខេ នប្បដិវិរុជ្ឈតិ ។ សោ ឯវំ អនុរោធវិរោធវិប្បហីនោ បរិមុច្ចតិ ជាតិយា ជរាយ មរណេន សោកេហិ បរិទេវេហិ ទុក្ខេហិ ទោមនស្សេហិ ឧបាយាសេហិ បរិមុច្ចតិ ទុក្ខស្មាតិ វទាមិ ។

---

១ ឱ. ម. ឥទំ ទុក្ខំ តញ្ច ខោ អនិច្ចំ ទុក្ខំ វិបរិណាមធម្មន្តិ យថាភូតំ បជានាតីតិ ន ទិស្សន្តិ ។ ឥមេ បាឋា អតិរេកា មញ្ញេ ។

អរិយសាវ័ក ដឹងច្បាស់តាមពិតថា នេះជាទុក្ខ ទុក្ខនោះឯង ក៏មិនទៀង អត់ធន់បានដោយក្រ មានសេចក្តីប្រែប្រួលជាធម្មតា លាភក្តី មិនគ្រប សង្កត់ចិត្តរបស់អរិយសាវ័កនោះ អលាភក្តី ក៏មិនគ្របសង្កត់ចិត្ត យសក្តី ក៏មិនគ្របសង្កត់ចិត្ត អយសក្តី ក៏មិនគ្របសង្កត់ចិត្ត និន្ទាក្តី ក៏មិនគ្រប សង្កត់ចិត្ត បសំសាក្តី ក៏មិនគ្របសង្កត់ចិត្ត សុខក្តី ក៏មិនគ្របសង្កត់ចិត្ត ទុក្ខក្តី ក៏មិនគ្របសង្កត់ចិត្តបាន ។ អរិយសាវ័កនោះ មិនត្រេកអរនឹងលាភ ដែលកើតឡើង មិនអាក់អន់ព្រោះអលាភ មិនត្រេកអរនឹងយសដែលកើត ឡើង មិនអាក់អន់ព្រោះអយស មិនត្រេកអរនឹងបសំសាដែលកើតឡើង មិនអាក់អន់ព្រោះនិន្ទា មិនត្រេកអរនឹងសុខដែលកើតឡើង មិនអាក់អន់ ព្រោះសេចក្តីទុក្ខ ។ អរិយសាវ័កនោះ លះបង់សេចក្តីត្រេករនិងសេចក្តី អាក់អន់យ៉ាងនេះហើយ រមែងរួចចាកជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាសៈ តថាគតពោលថារួចស្រឡះចាកវដ្តទុក្ខ ។

១៩

## បណ្ណាសកេ មេត្តាវគ្គោ

អយំ ខោ ភិក្ខវេ វិសេសោ អយំ អធិប្បាយសោ ឥទំ នានាករណំ សុតវតោ អរិយសាវកស្ស អស្សុតវតា បុថុជ្ជនេនាតិ ។

លាភោ អលាភោ ច យសាយសោ ច
និន្ទា បសំសា ច សុខំ ទុក្ខញ្ច
ឯតេ អនិច្ចា មនុជេសុ ធម្មា
អសស្សតា វិបរិណាមធម្មា
ឯតេ ច ញត្វា សតិមា សុមេធោ
អវេក្ខតិ វិបរិណាមធម្មេ
ឥដ្ឋស្ស ធម្មា ន មថេន្តិ ចិត្តំ
អនិដ្ឋតោ នោ បដិឃាតមេតិ
តស្សានុរោធា អថ វា វិរោធា
វិធូបិតា អត្ថគតា ន សន្តិ
បទញ្ច ញត្វា វិរជំ អសោកំ
សម្មប្បជានាតិ ភវស្ស ចារគូតិ ។

បណ្ណាសក មេត្តាវគ្គ

ម្នាលភិក្ខុទាំងឡាយ នេះឯងជាសេចក្តីប្លែកគ្នា នេះជាអធិប្បាយ នេះជាហេតុផ្សេងៗ គ្នា នៃអរិយសាវ័កអ្នកចេះដឹង និងបុថុជ្ជនអ្នកមិនចេះដឹង ។

ធម៌ទាំងឡាយនេះ គឺលាភ ១ អលាភ ១ យស ១ អយស ១ និន្ទា ១ បសំសា ១ សុខ ១ ទុក្ខ ១ ជាធម៌មិនទៀងក្នុងមនុស្សជាតិទាំងឡាយ ជាធម៌មិនឋិតថេរ មានសេចក្តីប្រែប្រួលជាធម្មតា ចំណែកបុគ្គលអ្នកមានប្រាជ្ញា មានស្មារតី លុះដឹងនូវធម៌ទាំងនេះហើយ រមែងពិចារណាឃើញច្បាស់នូវធម៌ដែលមានសេចក្តីប្រែប្រួលជាធម្មតា ឥដ្ឋារម្មណ៍ រមែងមិនញ៉ាំញីចិត្តរបស់បុគ្គលនោះបាន ទាំងអនិដ្ឋារម្មណ៍ ក៏មិនអាចប៉ះទង្គិចបាន សេចក្តីត្រេកអរ ឬថា សេចក្តីថ្នាំងថ្នាក់ ក៏បុគ្គលនោះបានកម្ចាត់បង់ហើយ ដល់នូវសេចក្តីវិនាស មិនមានតទៅទៀតឡើយ បុគ្គលអ្នកដល់នូវត្រើយនៃភព រមែងដឹងច្បាស់ដោយប្រពៃ ព្រោះដឹងច្បាស់នូវបទ គឺព្រះនិព្វានដែលមិនមានធូលីគឺកិលេស មិនមានសេចក្តីសោក ។

[៧] ឯកំ សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ ។ អចិរប្បក្កន្តេ ទេវទត្តេ តត្រ ខោ ភគវា ទេវទត្តំ អារព្ភ ភិក្ខូ អាមន្តេសិ សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ អត្តវិបត្តិំ បច្ចវេក្ខិតា ហោតិ សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ បរវិបត្តិំ បច្ចវេក្ខិតា ហោតិ សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ អត្តសម្បត្តិំ បច្ចវេក្ខិតា ហោតិ សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ បរសម្បត្តិំ បច្ចវេក្ខិតា ហោតិ ។ អដ្ឋហិ ភិក្ខវេ អសទ្ធម្មេហិ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ កតមេហិ អដ្ឋហិ ។ លាភេន ភិក្ខវេ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។

[៧] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅលើភ្នំគិជ្ឈកូដ ទៀបក្រុងរាជគ្រឹះ ។ កាលដែលទេវទត្តភិក្ខុ ចៀសចេញមិនយូរប៉ុន្មាន ក្នុងទីនោះឯង ព្រះមានព្រះភាគទ្រង់ប្រារព្ធនូវទេវទត្តភិក្ខុ ហើយត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិនៃខ្លួនសព្វៗ កាល ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិរបស់បុគ្គលដទៃសព្វៗ កាល ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវសម្បត្តិនៃខ្លួនសព្វៗ កាល ជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវសម្បត្តិរបស់បុគ្គលដទៃសព្វៗ កាល ជាការប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវអសទ្ធម្មទាំងឡាយ ៨ ប្រការគ្របសង្កត់ហើយ មានចិត្តត្រូវអសទ្ធម្មរួបរឹតហើយ ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនអាចអ្នកណាស្រោចស្រង់បាន ។ អសទ្ធម្ម ៨ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវលាភគ្របសង្កត់ហើយ មានចិត្តដែលលាភរួបរឹតហើយ ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនអាចអ្នកណាស្រោចស្រង់បាន ។

២១

## បណ្ណាសកេ មេត្តាវគ្គោ

អលាភេន ភិក្ខវេ យសេន ភិក្ខវេ អយសេន ភិក្ខវេ សក្ការេន ភិក្ខវេ អសក្ការេន ភិក្ខវេ បាបិច្ឆតាយ ភិក្ខវេ បាបមិត្តតាយ ភិក្ខវេ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ អសទ្ធម្មេហិ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។

សាធុ ភិក្ខវេ ភិក្ខុ ឧប្បន្នំ លាភំ អភិភុយ្យ អភិភុយ្យ វិហរេយ្យ ឧប្បន្នំ អលាភំ ឧប្បន្នំ យសំ ឧប្បន្នំ អយសំ ឧប្បន្នំ សក្ការំ ឧប្បន្នំ អសក្ការំ ឧប្បន្នំ បាបិច្ឆតំ ឧប្បន្នំ បាបមិត្តតំ អភិភុយ្យ អភិភុយ្យ វិហរេយ្យ កិញ្ច ភិក្ខវេ ភិក្ខុ អត្ថវសំ បដិច្ច ឧប្បន្នំ លាភំ អភិភុយ្យ អភិភុយ្យ វិហរេយ្យ ។ បេ ។ យញ្ហិស្ស ភិក្ខវេ ឧប្បន្នំ លាភំ អនភិភុយ្យ វិហរតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា ឧប្បន្នំ លាភំ អភិភុយ្យ វិហរតោ

ម្នាលភិក្ខុទាំងឡាយ ត្រូវអលាភ ម្នាលភិក្ខុទាំងឡាយត្រូវយស ម្នាលភិក្ខុទាំងឡាយត្រូវអយស ម្នាលភិក្ខុទាំងឡាយត្រូវសក្ការៈ ម្នាលភិក្ខុទាំងឡាយត្រូវអសក្ការៈ ម្នាលភិក្ខុទាំងឡាយ ត្រូវសេចក្ដីប្រាថ្នាដ៏លាមក ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវបាបមិត្តគ្របសង្កត់ហើយ មានចិត្តត្រូវបាបមិត្តរួបរឹតហើយ ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនអាចអ្នកណាស្រោចស្រង់បាន ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវអសទ្ធម្មទាំង ៨ ប្រការនេះឯង គ្របសង្កត់ មានចិត្តត្រូវអសទ្ធម្មរួបរឹត ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនអាចអ្នកណាស្រោចស្រង់បាន ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុគ្របសង្កត់ ញាំញីនូវលាភ ដែលកើតឡើងហើយជាការប្រពៃ នូវអលាភ ដែលកើតឡើងហើយ នូវយសដែលកើតឡើងហើយ នូវអយស ដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្ដីប្រាថ្នាលាមកដែលកើតឡើងហើយ គ្របសង្កត់ ញាំញីនូវបាបមិត្តដែលកើតឡើងហើយ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគ្របសង្កត់ ញាំញីនូវលាភ ដែលកើតឡើងហើយ តើព្រោះអាស្រ័យនូវអំណាចប្រយោជន៍ដូចម្ដេច ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា អាសវៈទាំងឡាយណា ជាសភាវៈចង្អៀតចង្អល់រោលរាល កើតឡើងដល់ភិក្ខុនោះ ព្រោះមិនបានគ្របសង្កត់នូវលាភ ដែលកើតឡើងហើយ

ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ យញ្ហិស្ស ភិក្ខវេ ឧប្បន្នំ អលាភំ ឧប្បន្នំ យសំ ឧប្បន្នំ អយសំ ឧប្បន្នំ សក្ការំ ឧប្បន្នំ អសក្ការំ ឧប្បន្នំ បាបិច្ឆតំ ឧប្បន្នំ បាបមិត្តតំ អនភិភុយ្យ វិហរតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា ឧប្បន្នំ បាបមិត្តតំ អភិភុយ្យ វិហរតោ ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។ ឥមំ ខោ ភិក្ខវេ ភិក្ខុ អត្ថវសំ បដិច្ច ឧប្បន្នំ លាភំ អភិភុយ្យ អភិភុយ្យ វិហរេយ្យ ឧប្បន្នំ អលាភំ ឧប្បន្នំ យសំ ឧប្បន្នំ អយសំ ឧប្បន្នំ សក្ការំ ឧប្បន្នំ អសក្ការំ ឧប្បន្នំ បាបិច្ឆតំ ឧប្បន្នំ បាបមិត្តតំ អភិភុយ្យ អភិភុយ្យ វិហរេយ្យ

អាសវៈទាំងឡាយនោះ ជាសភាវៈចង្អៀតចង្អល់ ពោលពល រមែងមិនមាន ដល់ភិក្ខុនោះយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ព្រោះថា អាសវៈទាំងឡាយណា ជាសភាវៈចង្អៀតចង្អល់ ពោលពល កើតឡើងដល់ភិក្ខុនោះ កាលមិនបានគ្របសង្កត់នូវអលាភ ដែលកើតឡើងហើយ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាលាមក ដែលកើតឡើងហើយ នូវបាបមិត្តដែលកើតឡើងហើយ អាសវៈទាំងឡាយនោះ ជាសភាវៈចង្អៀតចង្អល់ពោលពល រមែងមិនមានដល់ភិក្ខុ កាលគ្របសង្កត់នូវបាបមិត្តដែលកើតឡើងហើយយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគ្របសង្កត់ញាំញីនូវលាភ ដែលកើតឡើងហើយ នូវអលាភដែលកើតឡើងហើយ នូវយស ដែលកើតឡើងហើយ នូវអយស ដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាលាមក ដែលកើតឡើងហើយ គ្របសង្កត់ញាំញីនូវបាប-មិត្ត ដែលកើតឡើងហើយ ព្រោះអាស្រ័យនូវអំណាចប្រយោជន៍នេះឯង

តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ ឧប្បន្នំ លាភំ អភិភុយ្យ អភិភុយ្យ វិហរិស្សាម ឧប្បន្នំ អលាភំ ឧប្បន្នំ យសំ ឧប្បន្នំ អយសំ ឧប្បន្នំ សក្ការំ ឧប្បន្នំ អសក្ការំ ឧប្បន្នំ ចាបិច្ឆតំ ឧប្បន្នំ ចាបមិត្តតំ អភិភុយ្យ អភិភុយ្យ វិហរិស្សាមាតិ ។ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[៨] ឯកំ សមយំ អាយស្មា ឧត្តរោ មហិសវត្ថុស្មឹ វិហរតិ សង្ខេយ្យកេ បព្វតេ វដ្ដជាលិកាយំ[១] ។ តត្រ ខោ អាយស្មា ឧត្តរោ ភិក្ខូ អាមន្តេសិ សាធាវុសោ ភិក្ខុ កាលេន កាលំ អត្តវិបត្តឹ បច្ចវេក្ខិតា ហោតិ សាធាវុសោ ភិក្ខុ កាលេន កាលំ បរវិបត្តឹ បច្ចវេក្ខិតា ហោតិ សាធាវុសោ ភិក្ខុ កាលេន កាលំ អត្តសម្បត្តឹ បច្ចវេក្ខិតា ហោតិ សាធាវុសោ ភិក្ខុ កាលេន កាលំ បរសម្បត្តឹ បច្ចវេក្ខិតា ហោតីតិ ។

---

១ ឱ. ធវជាតិកាយំ ។

ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ គប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយ គួរជាអ្នកគ្របសង្កត់ញាំញីនូវលាភដែលកើតឡើងហើយ យើងទាំងឡាយគួរជាអ្នកគ្របសង្កត់ ញាំញីនូវអលាភដែលកើតឡើងហើយ នូវយស ដែលកើតឡើងហើយ នូវអយស ដែលកើតឡើងហើយ នូវសក្ការៈ ដែលកើតឡើងហើយ នូវអសក្ការៈ ដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាលាមកដែលកើតឡើងហើយ នូវបាបមិត្តដែលកើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសិក្សាយ៉ាងនេះឯង ។

[៨] សម័យមួយ ព្រះឧត្តរដ៏មានអាយុ គង់ក្នុងវិហារឈ្មោះវដ្ដជាលិកា ទៀបភ្នំឈ្មោះសង្ខេយ្យកៈ ជិតស្រុកមហិសវត្ថុ ។ ក្នុងទីនោះព្រះឧត្តរដ៏មានអាយុហៅភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិនៃខ្លួនសព្វៗ កាល ជាការប្រពៃ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិរបស់បុគ្គលដទៃសព្វៗ កាល ជាការប្រពៃ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវសម្បត្តិនៃខ្លួនសព្វៗ កាល ជាការប្រពៃ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវសម្បត្តិរបស់អ្នកដទៃសព្វ ៗ កាល ជាការប្រពៃ ។

តេន ខោ បន សមយេន វេស្សវណោ មហារាជា ឧត្តរទិសាយ ទក្ខិណាទិសំ គច្ឆតិ កេនចិ ទេវ ករណីយេន ។ អស្សោសិ ខោ វេស្សវណោ មហារាជា អាយស្មតោ ឧត្តរស្ស មហិសវត្ថុស្មឹ សង្ខេយ្យកេ បព្វតេ វដ្ដជាលិកាយំ ភិក្ខូនំ ឯវំ ធម្មំ ទេសេន្តស្ស សាធាវុសោ ភិក្ខុ កាលេន កាលំ អត្តវិបត្តឹ បច្ចវេក្ខិតា ហោតិ សាធាវុសោ ភិក្ខុ កាលេន កាលំ បរវិបត្តឹ បច្ចវេក្ខិតា ហោតិ សាធាវុសោ ភិក្ខុ កាលេន កាលំ អត្តសម្បត្តឹ បច្ចវេក្ខិតា ហោតិ សាធាវុសោ ភិក្ខុ កាលេន កាលំ បរសម្បត្តឹ បច្ចវេក្ខិតា ហោតីតិ ។ អថខោ វេស្សវណោ មហារាជា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ មហិសវត្ថុស្មឹ សង្ខេយ្យកេ បព្វតេ វដ្ដជាលិកាយំ អន្តរហិតោ ទេវេសុ តាវត្តឹសេសុ បាតុរហោសិ ។ អថខោ វេស្សវណោ មហារាជា យេន សក្កោ ទេវានមិន្ទោ តេនុបសង្កមិ ឧបសង្កមិត្វា

សម័យនោះឯង មហារាជឈ្មោះវេស្សវ័ណចេញអំពីឧត្តរទិសទៅកាន់ទក្សិណទិស ដោយកិច្ចនីមួយ ។ មហារាជឈ្មោះវេស្សវ័ណ បានឮថេរវាចានៃព្រះឧត្តរដ៏មានអាយុ កំពុងសម្តែងធម៌ដល់ភិក្ខុទាំងឡាយ ក្នុងវិហារឈ្មោះវដ្តជាលិកា ទៀបភ្នំសង្ខេយ្យកៈ ជិតស្រុកមហិសវត្ថុ យ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិនៃខ្លួនសព្វៗកាល ជាការប្រពៃ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិរបស់អ្នកដទៃសព្វៗកាល ជាការប្រពៃ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវសម្បត្តិនៃខ្លួនសព្វៗ កាល ជាការប្រពៃ ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវសម្បត្តិរបស់អ្នកដទៃសព្វៗ កាល ជាការប្រពៃ ។ លំដាប់នោះ មហារាជឈ្មោះវេស្សវ័ណ ក៏បាត់អំពីវដ្ត-ជាលិកាវិហារ ទៀបភ្នំសង្ខេយ្យកៈ ជិតស្រុកមហិសវត្ថុ ទៅប្រាកដក្នុងតាវត្តិង្សទេវលោក ដូចបុរសមានកម្លាំងលាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញយ៉ាងនោះឯង ។ លំដាប់នោះ មហារាជវេស្សវ័ណចូលទៅគាល់ព្រះឥន្ទ្រជាធំ ជាងពួកទេវតា លុះចូលទៅដល់ហើយ

សក្កំ ទេវានមិន្ទំ ឯតទវោច យគ្ឃេ មារិស ជានេយ្យាសិ ឯសោ អាយស្មា ឧត្តរោ មហិសវត្ថុស្មឹ សង្ខេយ្យកេ បព្វតេ វដជាលិកាយំ ភិក្ខូនំ ឯវំ ធម្មំ ទេសេតិ សាធាវុសោ ភិក្ខុ កាលេន កាលំ អត្តវិបត្តឹ ។ បេ ។ បរសម្បត្តឹ បច្ចវេក្ខិតា ហោតីតិ ។

អថខោ សក្កោ ទេវានមិន្ទោ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ទេវេសុ តាវត្តឹសេសុ អន្តរហិតោ មហិសវត្ថុស្មឹ សង្ខេយ្យកេ បព្វតេ វដជាលិកាយំ អាយស្មតោ ឧត្តរស្ស សម្មុខេ បាតុរហោសិ ។ អថខោ សក្កោ ទេវានមិន្ទោ យេនា-យស្មា ឧត្តរោ តេនុបសង្កមិ ឧបសង្កមិត្វា អាយស្មន្តំ ឧត្តរំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតោ ខោ សក្កោ ទេវានមិន្ទោ អាយស្មន្តំ ឧត្តរំ ឯតទវោច សច្ចំ កិរ ភន្តេ អាយស្មា ឧត្តរោ ភិក្ខូនំ ឯវំ ធម្មំ ទេសេសិ សាធាវុសោ ភិក្ខុ កាលេន កាលំ អត្តវិបត្តឹ ។ បេ ។ បរសម្បត្តឹ បច្ចវេក្ខិតា ហោតីតិ ។

បានទូលពាក្យនេះ នឹងព្រះឥន្ទ្រជាធំ ជាងពួកទេវតាថា បពិត្រលោកជាម្ចាស់យើង សូមទ្រង់ជ្រាប ព្រះឧត្តរដ៏មានអាយុនុ៎ះ សម្តែងធម៌ដល់ភិក្ខុទាំងឡាយ ក្នុងវដ្តជាលិកាវិហារ ទៀបភ្នំសង្ខេយ្យកៈ ជិតស្រុកមហិសវត្ថុយ៉ាងនេះថា ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិរបស់ខ្លួនសព្វៗ កាល ជាការប្រពៃ ។ បេ ។ ជាអ្នកពិចារណានូវសម្បត្តិរបស់អ្នកដទៃ ។

គ្រានោះ សក្កៈជាធំជាងពួកទេវតា ក៏បាត់អំពីទេវលោក ទៅប្រាកដក្នុងទីចំពោះមុខព្រះឧត្តរដ៏មានអាយុ ក្នុងវដ្តជាលិកាវិហារ ទៀបភ្នំសង្ខេយ្យកៈ ជិតស្រុកមហិសវត្ថុ ដូចបុរសមានកម្លាំង លាដៃដែលបត់ចូល ឬបត់ចូលនូវដៃដែលលាចេញយ៉ាងនោះឯង ។ លំដាប់នោះ សក្កៈជាធំជាងពួកទេវតា ចូលទៅរកព្រះឧត្តរដ៏មានអាយុ ត្រង់កន្លែងដែលលោកគង់នៅ លុះចូលទៅហើយ ថ្វាយបង្គំព្រះឧត្តរដ៏មានអាយុ ហើយឋិតនៅក្នុងទីសមគួរ ។ លុះសក្កៈជាធំជាងពួកទេវតា ឋិតនៅក្នុងទីសមគួរហើយ បានដំណាលពាក្យនេះនឹងព្រះឧត្តរដ៏មានអាយុដូច្នេះថា បានឮថាព្រះឧត្តរដ៏មានអាយុ សម្តែងធម៌ដល់ភិក្ខុទាំងឡាយថា ម្នាលអាវុសោទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិនៃខ្លួន ជាការប្រពៃ ។ បេ ។ ជាអ្នកពិចារណានូវសម្បត្តិរបស់អ្នកដទៃពិតមែនឬ ។

ឯវំ ទេវានមិន្ទាតិ ។ កឹ បន ភន្តេ អាយស្មតោ ឧត្តរស្ស សកំ បដិភាណំ ឧទាហុ តស្ស ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។ តេនហិ ទេវានមិន្ទ ឧបមំ តេ ករិស្សាមិ ឧបមាយមិធេកច្ចេ វិញ្ញូ បុរិសា ភាសិតស្ស អត្ថំ អាជានន្តិ សេយ្យថាបិ ទេវានមិន្ទ គាមស្ស វា និគមស្ស វា អវិទូរេ មហាធញ្ញរាសិ តតោ មហាជនកាយោ ធញ្ញំ អាហរេយ្យ កាយេហិបិ[១] សីសកេហិបិ[២] ឧច្ឆង្គេហិបិ[៣] អញ្ជលីហិបិ យោ នុ ខោ ទេវានមិន្ទ មហាជនកាយោ ឧបសង្កមិត្វា ឯវំ បុច្ឆេយ្យ កុតោ ឥមំ ធញ្ញំ អាហរថាតិ ។ កថំ ព្យាករមានោ នុ ខោ ទេវានមិន្ទ សោ មហាជន-កាយោ សម្មា ព្យាករមានោ ព្យាករេយ្យាតិ ។ អមុម្ហា មហាធញ្ញរាសិម្ហា អាហរាមាតិ ខោ ភន្តេ សោ មហា-ជនកាយោ សម្មា ព្យាករមានោ ព្យាករេយ្យាតិ ។ ឯវមេវ ខោ ទេវានមិន្ទ យំ កិញ្ចិ សុភាសិតំ សព្វន្តំ តស្ស ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស

១ ឱ. កាចេហិបិ ។ ម. កាជេហិបិ ។ ២ ឱ. ម. បិដកេហិបិ ។ ៣ ឱច្ឆង្គេហិបិ ។

ថ្វាយព្រះពរ ទេវានមិន្ទ ។ បពិត្រលោកដ៏ចម្រើន ចុះការសម្តែងតាមសេចក្តីយល់របស់ខ្លួនព្រះឧត្តរដ៏មានអាយុឬ ឬក៏សម្តែងតាមព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ។ ថ្វាយព្រះពរទេវានមិន្ទ បើដូច្នោះ អាត្មាភាពនឹងឧបមាថ្វាយមហាបពិត្រ ពួកវិញ្ញូបុរសក្នុងលោកនេះ គង់ដឹងនូវសេចក្តីអធិប្បាយនៃភាសិតដោយសេចក្តីឧបមា ថ្វាយព្រះពរ ទេវានមិន្ទ ដូចជាគំនរស្រូវដ៏ធំ ក្នុងទីជិតស្រុកក្តី និគមក្តី ពួកមហាជននាំយកស្រូវអំពីគំនរនោះ ដោយអម្រែកទាំងឡាយខ្លះ ដោយល្អីទាំងឡាយខ្លះ ដោយថ្នក់ទាំងឡាយខ្លះ ដោយកម្ប្រង់ដៃទាំងឡាយខ្លះ ថ្វាយព្រះពរ ទេវានមិន្ទ ពួកមហាជនណា ដែលមិនបានចូលទៅ (នឹងគេ) គប្បីសួរយ៉ាងនេះថា អ្នកទាំងឡាយ នាំយកស្រូវនេះអំពីទីណា ។ ថ្វាយព្រះពរ ទេវានមិន្ទ ពួកមហាជននោះ កាលនឹងឆ្លើយប្រាប់ គប្បីឆ្លើយប្រាប់តាមទំនងដូចម្តេច ។ បពិត្រលោកដ៏ចម្រើន ពួកមហាជននោះ កាលឆ្លើយប្រាប់ គប្បីឆ្លើយប្រាប់តាមទំនងថា យើងទាំងឡាយ នាំមកអំពីគំនរស្រូវធំឯណោះដូច្នេះ ។ ថ្វាយព្រះពរ ទេវានមិន្ទ ពាក្យឯណានីមួយជាសុភាសិត សុភាសិតទាំងអស់នោះ ជាព្រះពុទ្ធដីកា នៃព្រះដ៏មានព្រះភាគ អរហន្តសម្មាសម្ពុទ្ធអង្គនោះ

២៧

## បណ្ណាសកេ មេត្តាវគ្គោ

តតោ ឧចាជាយុចាជាយ មយំ ជញ្ញ[១] ច ភណាមាតិ ។ អច្ឆរិយំ ភន្តេ អព្ភុតំ ភន្តេ យាវសុភាសិតញ្ចិទំ អាយស្មតា ឧត្តរេន យំ កិញ្ចិ សុភាសិតំ សព្វន្តំ តស្ស ភគវតោ វចនំ អរហតោ សម្មាសម្ពុទ្ធស្ស តតោ ឧចាជាយុចាជាយ មយំ ជញ្ញ ច ភណាមាតិ ឯវមិទំ ភន្តេ ឧត្តរ ឯកំ[២] សមយំ ភគវា រាជគហេ វិហរតិ គិជ្ឈកូដេ បព្វតេ អចិរប្បក្កន្តេ ទេវទត្តេ តត្រ ខោ ភគវា ទេវទត្តំ អារព្ភ ភិក្ខូ អាមន្តេសិ សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ អត្តវិបត្តឹ បច្ចវេក្ខិតា ហោតិ សាធុ ភិក្ខវេ ភិក្ខុ កាលេន កាលំ បរវិបត្តឹ អត្តសម្បត្តឹ បរសម្បត្តឹ បច្ចវេក្ខិតា ហោតិ ។ អដ្ឋហិ ភិក្ខវេ អសទ្ធម្មេហិ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាចាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ កតមេហិ អដ្ឋហិ ។

---

១ ឱ. ម. មយញ្ចញ្ញេ ច ។ ២ អយំ បាហោ ឱ. ម. បោត្ថកេសុ ន ទិស្សតិ ។

យើងទាំងឡាយ នាំចេញមកអំពីព្រះពុទ្ធដីកានោះ ទើបសម្តែង ដូចជាស្រូវ យ៉ាងនោះដែរ ។ បពិត្រលោកដ៏ចម្រើន អស្ចារ្យណាស់ បពិត្រលោកដ៏ចម្រើន ចំឡែកណាស់ ពាក្យនេះ ព្រះឧត្តរដ៏មានអាយុពោលហើយដោយប្រពៃ (ព្រោះ) ពាក្យឯណានីមួយជាសុភាសិត ពាក្យទាំងអស់នោះ ជាព្រះពុទ្ធដីការបស់ព្រះដ៏មានព្រះភាគអរហន្តសម្មាសម្ពុទ្ធព្រះអង្គនោះ យើងទាំងឡាយក៏ពោលនូវស្រូវប្រៀបធៀបនឹងព្រះពុទ្ធដីកានោះដែរ បពិត្រព្រះឧត្តរដ៏ចម្រើន សេចក្តីនេះយ៉ាងនេះ សម័យមួយព្រះដ៏មានព្រះភាគ គង់លើភ្នំគិជ្ឈកូដ ជិតក្រុងរាជគ្រឹះ កាលដែលព្រះទេវទត្ត ចៀសចេញទៅមិនយូរប៉ុន្មាន ក្នុងទីនោះឯងព្រះដ៏មានព្រះភាគ ទ្រង់ប្រារព្ធនូវទេវទត្ត ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណានូវវិបត្តិនៃខ្លួនជាការប្រពៃ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកពិចារណា នូវវិបត្តិរបស់អ្នកដទៃ នូវសម្បត្តិរបស់ខ្លួន នូវសម្បត្តិរបស់អ្នកដទៃ ជាការប្រពៃ ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្ត ត្រូវអសទ្ធម្មទាំង ៨ ប្រការគ្របសង្កត់ហើយ មានចិត្តត្រូវអសទ្ធម្មរួបរឹតហើយ ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនអាចអ្នកណាស្រោចស្រង់បាន ។ អសទ្ធម្ម ៨ ប្រការ តើដូចម្តេច ។

លាភេន ភិក្ខវេ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ អលាភេន ភិក្ខវេ យសេន ភិក្ខវេ អយសេន ភិក្ខវេ សក្ការេន ភិក្ខវេ អសក្ការេន ភិក្ខវេ បាបិច្ឆតាយ ភិក្ខវេ បាបមិត្តតាយ ភិក្ខវេ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ អសទ្ធម្មេហិ អភិភូតោ បរិយាទិន្នចិត្តោ ទេវទត្តោ អាបាយិកោ នេរយិកោ កប្បដ្ឋោ អតេកិច្ឆោ ។ សាធុ ភិក្ខវេ ភិក្ខុ ឧប្បន្នំ លាភំ អភិភុយ្យ អភិភុយ្យ វិហរេយ្យ ឧប្បន្នំ អលាភំ ឧប្បន្នំ យសំ ឧប្បន្នំ អយសំ ឧប្បន្នំ សក្ការំ ឧប្បន្នំ អសក្ការំ ឧប្បន្នំ បាបិច្ឆតំ ឧប្បន្នំ បាបមិត្តតំ អភិភុយ្យ អភិភុយ្យ វិហរេយ្យ ។

ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវលាភគ្របសង្កត់ហើយ មានចិត្តត្រូវលាភរួបរឹតហើយ ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនអាចអ្នកណាស្រោចស្រង់បាន ។ ម្នាលភិក្ខុទាំងឡាយ ត្រូវអលាភ ម្នាលភិក្ខុទាំងឡាយ ត្រូវយស ម្នាលភិក្ខុទាំងឡាយ ត្រូវអយស ម្នាលភិក្ខុទាំងឡាយ ត្រូវសក្ការៈ ម្នាលភិក្ខុទាំងឡាយ ត្រូវអសក្ការៈ ម្នាលភិក្ខុទាំងឡាយ ដែលត្រូវសេចក្តីប្រាថ្នាលាមក ម្នាលភិក្ខុទាំងឡាយ ទេវទត្តត្រូវបាបមិត្តគ្របសង្កត់ហើយ មានចិត្តដែលត្រូវបាបមិត្តរួបរឹតហើយ ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនមានអ្នកណាស្រោចស្រង់បាន ។ ម្នាលភិក្ខុទាំងឡាយ ទេវទត្ត ត្រូវអសទ្ធម្មទាំងឡាយ ៨ ប្រការនេះឯងគ្របសង្កត់ហើយ មានចិត្តត្រូវអសទ្ធម្មរួបរឹតហើយ ទៅកើតក្នុងអបាយ ទៅកាន់នរក តាំងនៅអស់ ១ កប្ប មិនអាចអ្នកណាស្រោចស្រង់បាន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុគ្របសង្កត់ ញាំញីនូវលាភ ដែលកើតឡើងហើយ ជាការប្រពៃ នូវអលាភដែលកើតឡើងហើយ នូវយសដែលកើតឡើងហើយ នូវអយសដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាលាមកដែលកើតឡើងហើយ គ្របសង្កត់ញាំញីនូវបាបមិត្តដែលកើតឡើងហើយ ។

២៩

បណ្ណាសកេ មេត្តាវគ្គោ

កិញ្ច ភិក្ខវេ ភិក្ខុ អត្ថវសំ បដិច្ច ឧប្បន្នំ លាភំ អភិភុយ្យ អភិភុយ្យ វិហរេយ្យ ឧប្បន្នំ អលាភំ ឧប្បន្នំ យសំ ឧប្បន្នំ អយសំ ឧប្បន្នំ សក្ការំ ឧប្បន្នំ អសក្ការំ ឧប្បន្នំ បាបិច្ឆតំ ឧប្បន្នំ បាបមិត្តតំ អភិភុយ្យ អភិភុយ្យ វិហរេយ្យ យញ្ហិស្ស ភិក្ខវេ ឧប្បន្នំ លាភំ អនភិភុយ្យ វិហរតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា ឧប្បន្នំ លាភំ អភិភុយ្យ វិហរតោ ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។ យញ្ហិស្ស ភិក្ខវេ ឧប្បន្នំ អលាភំ ឧប្បន្នំ យសំ ឧប្បន្នំ អយសំ ឧប្បន្នំ សក្ការំ ឧប្បន្នំ អសក្ការំ ឧប្បន្នំ បាបិច្ឆតំ ឧប្បន្នំ បាបមិត្តតំ អនភិភុយ្យ វិហរតោ ឧប្បជ្ជេយ្យុំ អាសវា វិឃាតបរិឡាហា ឧប្បន្នំ បាបមិត្តតំ អភិភុយ្យ វិហរតោ ឯវំស តេ អាសវា វិឃាតបរិឡាហា ន ហោន្តិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុគ្របសង្កត់ ញាំញីនូវលាភ ដែលកើតឡើងហើយ គ្របសង្កត់ ញាំញីនូវអលាភ ដែលកើតឡើងហើយ នូវយសដែលកើតឡើងហើយ នូវអយស ដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាលាមក ដែលកើតឡើងហើយ តើព្រោះអាស្រ័យអំណាចប្រយោជន៍ដូចម្តេច ម្នាលភិក្ខុទាំងឡាយ ព្រោះថា អាសវៈទាំងឡាយណាជាសភាវៈចង្អៀតចង្អល់ពោលពាលកើតឡើងដល់ភិក្ខុនោះ កាលមិនបានគ្របសង្កត់នូវលាភ ដែលកើតឡើងហើយ អាសវៈទាំងឡាយនោះជាសភាវៈចង្អៀតចង្អល់ ពោលពាលរមែងមិនមានដល់ភិក្ខុនោះ កាលគ្របសង្កត់នូវលាភ ដែលកើតឡើងហើយយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះថា អាសវៈទាំងឡាយណា ជាសភាវៈចង្អៀតចង្អល់ ពោលពាល គប្បីកើតឡើងដល់ភិក្ខុនោះ កាលមិនបានគ្របសង្កត់ នូវអលាភ ដែលកើតឡើងហើយ នូវយសដែលកើតឡើងហើយ នូវអយស ដែលកើតឡើងហើយ នូវសក្ការៈដែលកើតឡើងហើយ នូវអសក្ការៈ ដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នាលាមកដែលកើតឡើងហើយ នូវបាបមិត្ត ដែលកើតឡើងហើយ អាសវៈទាំងឡាយនោះ ជាសភាវៈចង្អៀតចង្អល់ ពោលពាល រមែងមិនមានដល់ភិក្ខុនោះ កាលគ្របសង្កត់នូវបាបមិត្តដែលកើតឡើងបានយ៉ាងនេះ ។

៣០



ឥជំ ខោ ភិក្ខវេ ភិក្ខុ អត្តវសំ បដិច្ច ឧប្បន្នំ លាភំ អភិភុយ្យ អភិភុយ្យ វិហរេយ្យ ឧប្បន្នំ អលាភំ ឧប្បន្នំ យសំ ឧប្បន្នំ អយសំ ឧប្បន្នំ សក្ការំ ឧប្បន្នំ អសក្ការំ ឧប្បន្នំ ចាបិច្ឆតំ ឧប្បន្នំ ចាបមិត្តតំ អភិភុយ្យ អភិភុយ្យ វិហ-រេយ្យ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ ឧប្បន្នំ លាភំ អភិភុយ្យ អភិភុយ្យ វិហរិស្សាម ឧប្បន្នំ អលាភំ ឧប្បន្នំ យសំ ឧប្បន្នំ អយសំ ឧប្បន្នំ សក្ការំ ឧប្បន្នំ អសក្ការំ ឧប្បន្នំ ចាបិច្ឆតំ ឧប្បន្នំ ចាបមិត្តតំ អភិភុយ្យ អភិភុយ្យ វិហរិស្សា-មាតិ ។ ឯវញ្ហិ រោ ភិក្ខវេ សិក្ខិតព្វន្តិ ។ ឯត្តាវតា ភន្តេ ឧត្តរ មនុស្សេសុ ចតស្សោ បរិសា ភិក្ខូ ភិក្ខុនិយោ ឧចាសកា ឧចា-សិកាយោ ណាយំ ជម្មបរិយាយោ កិស្មិញ្ចិ បតិដ្ឋិតោ ឧគ្គណ្ហាតុ ភន្តេ អាយស្មា ឧត្តរោ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុគ្របសង្កត់ ញាំញីនូវលាភ ដែលកើតឡើង ហើយ គ្របសង្កត់ ញាំញីនូវអលាភ ដែលកើតឡើងហើយ នូវយស ដែលកើតឡើងហើយ នូវអយស ដែលកើតឡើងហើយ នូវសក្ការៈ ដែល កើតឡើងហើយ នូវអសក្ការៈ ដែលកើតឡើងហើយ នូវសេចក្តីប្រាថ្នា លាមក ដែលកើតឡើងហើយ នូវបាបមិត្ត ដែលកើតឡើងហើយ ព្រោះ អាស្រ័យនូវអំណាចប្រយោជន៍នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ព្រោះ ហេតុនោះ ភិក្ខុក្នុងសាសនានេះ គប្បីសិក្សាយ៉ាងនេះថា យើងទាំងឡាយ គួរជាអ្នកគ្របសង្កត់ ញាំញីនូវលាភ ដែលកើតឡើងហើយ យើងទាំង-ឡាយ គួរជាអ្នកគ្របសង្កត់ញាំញីនូវអលាភ ដែលកើតឡើងហើយ នូវ យស ដែលកើតឡើងហើយ នូវអយស ដែលកើតឡើងហើយ នូវសក្ការៈ ដែលកើតឡើងហើយ នូវអសក្ការៈ ដែលកើតឡើងហើយ នូវសេចក្តី ប្រាថ្នាលាមក ដែលកើតឡើងហើយ នូវបាបមិត្ត ដែលកើតឡើងហើយ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ត្រូវសិក្សាយ៉ាងនេះឯង ។ បពិត្រ ព្រះឧត្តរដ៏ចម្រើន បណ្តាបរិសទ្យទាំង ៤ ពួក គឺ ភិក្ខុ ភិក្ខុនី ឧបាសក ឧបា-សិកា ធម្មបរិយាយនេះ មិនទាន់តាំងនៅក្នុងបរិសទ្យណាទេ បពិត្រ លោកដ៏ចម្រើន សូមព្រះឧត្តរដ៏មានអាយុ កាន់យកនូវធម្មបរិយាយនេះ

ឥមំ ធម្មបរិយាយំ បរិយាបុណាតុ ភន្តេ អាយស្មា ឧត្តរោ ឥមំ ធម្មបរិយាយំ ធារេតុ ភន្តេ អាយស្មា ឧត្តរោ ឥមំ ធម្មបរិយាយំ អត្ថសញ្ហិតោ អយំ ភន្តេ ធម្មបរិយាយោ អាទិព្រហ្មចរិយកោតិ ។

[៩] កុលបុត្តោតិ ភិក្ខវេ នន្ទំ សម្មា វទមានោ វទេយ្យ ពលវាតិ ភិក្ខវេ នន្ទំ សម្មា វទមានោ វទេយ្យ បាសាទិកោតិ ភិក្ខវេ នន្ទំ សម្មា វទមានោ វទេយ្យ តិព្វរាគោតិ ភិក្ខវេ នន្ទំ សម្មា វទមានោ វទេយ្យ ។ កិមញ្ញត្រ ភិក្ខវេ នន្ទោ ឥន្ទ្រិយេសុ គុត្តទ្វារោ ភោជនេ មត្តញ្ញូ ជាគរិយ-មនុយុត្តោ សតិសម្បជញ្ញេន សមន្នាគតោ យេហិ នន្ទោ សក្កោតិ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរិតុន្តិ ។

តត្រិទំ ភិក្ខវេ នន្ទស្ស ឥន្ទ្រិយេសុ គុត្តទ្វារតាយ ហោតិ ។ សចេ ភិក្ខវេ នន្ទស្ស បុរត្ថិមា ទិសា អាលោកេតព្វា ហោតិ សព្វញ្ចេតសោ សមន្នាហរិត្វា

បពិត្រលោកដ៏ចម្រើន សូមព្រះឧត្តរដ៏មានអាយុ រៀនយកនូវធម្មបរិយាយនេះ បពិត្រលោកដ៏ចម្រើន សូមព្រះឧត្តរដ៏មានអាយុ ទ្រទ្រង់នូវធម្ម-បរិយាយនេះ បពិត្រលោកដ៏ចម្រើន ធម្មបរិយាយនេះ ប្រកបដោយប្រយោជន៍ជាខាងដើមនៃមគ្គព្រហ្មចរិយធម៌ ។

[៩] ម្នាលភិក្ខុទាំងឡាយ អ្នកផងកាលបើពោលតាមត្រឹមត្រូវ គប្បីពោលនូវនន្ទភិក្ខុថាជាកុលបុត្តដូច្នេះ ម្នាលភិក្ខុទាំងឡាយ អ្នកផងកាលបើពោលតាមត្រឹមត្រូវ គប្បីពោលនូវនន្ទភិក្ខុថាជាអ្នកមានកម្លាំងកាយដូច្នេះ ម្នាលភិក្ខុទាំងឡាយ អ្នកផងកាលបើពោលតាមត្រឹមត្រូវ គប្បីពោលនូវនន្ទ-ភិក្ខុថាជាអ្នកគួរនាំមកនូវសេចក្តីជ្រះថ្លាដូច្នេះ ម្នាលភិក្ខុទាំងឡាយ អ្នកផងកាលបើពោលតាមត្រឹមត្រូវ គប្បីពោលនូវនន្ទភិក្ខុថាជាអ្នកមានរាគៈដ៏ក្លៀវក្លាដូច្នេះ ។ ម្នាលភិក្ខុទាំងឡាយ ចាំបាច់ពោលទៅថ្វីក្នុងទីដទៃ ថានន្ទភិក្ខុគ្រប់គ្រងទ្វារក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណក្នុងភោជន ប្រកបរឿយៗ នូវការភ្ញាក់រលឹកប្រកបដោយសតិនិងសម្បជញ្ញៈ ទើបនន្ទ-ភិក្ខុអាចដើម្បីប្រព្រឹត្តនូវព្រហ្មចរិយធម៌ឲ្យបរិបូណ៌ បរិសុទ្ធបាន ។

ម្នាលភិក្ខុទាំងឡាយ ហេតុដែលនន្ទភិក្ខុមានទ្វារគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយនោះយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ បើនន្ទភិក្ខុរមិលមើលទៅទិសខាងកើត លុះតែប្រមូលនូវហេតុទាំងអស់ ដោយចិត្ត

នន្ទោ បុរត្ថិមំ ទិសំ អាលោកេតិ ឯវំ មេ បុរត្ថិមំ ទិសំ អាលោកយតោ នាភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវិស្សន្តីតិ ។ ឥតិហ តត្រ សម្បជានោ ហោតិ ។ សចេ ភិក្ខវេ នន្ទស្ស បច្ឆិមា ទិសា អាលោកេតព្វា ហោតិ ឧត្តរា ទិសា អាលោកេតព្វា ហោតិ ទក្ខិណា ទិសា អាលោកេតព្វា ហោតិ ឧទ្ធំ ឧល្លោកេតព្វា[១] ហោតិ អធោ ឱលោកេតព្វា[២] ហោតិ អនុទិសា អនុវិលោកេតព្វា ហោតិ សព្វញ្ចេតសោ សមន្នាហរិត្វា នន្ទោ អនុទិសំ អនុវិលោកេតិ ឯវំ មេ អនុទិសំ អនុវិលោកយតោ នាភិជ្ឈាទោមនស្សា បាបកា អកុសលា ធម្មា អន្វាស្សវិស្សន្តីតិ ។ ឥតិហ តត្រ សម្បជានោ ហោតិ ។ ឥទំ ខោ ភិក្ខវេ នន្ទស្ស ឥន្ទ្រិយេសុ គុត្តទ្វារតាយ ហោតិ ។

តត្រិទំ ភិក្ខវេ នន្ទស្ស ភោជនេ មត្តញ្ញុតាយ ហោតិ ឥធ ភិក្ខវេ នន្ទោ បដិសង្ខា យោនិសោ អាហារំ អាហារេតិ នេវ ទវាយ

---

១ ឱ. ម. ឧល្លោកេតព្វំ ។ ២ ឱ. ឱលោកេតព្វំ ។

ទើបនន្ទភិក្ខុរមិលមើលនូវទិសខាងកើត ដោយគំនិតថា អកុសលធម៌ទាំង-ឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្សនឹងមិនជាប់តាមអាត្មាអញ ដែលកំពុងរមិលមើលទិសខាងកើតយ៉ាងនេះ ។ ព្រោះហេតុនោះ ក្នុងសាសនានេះ នន្ទភិក្ខុទើបឈ្មោះថាជាអ្នកមានសេចក្តីដឹងខ្លួន ក្នុងការគ្រប់គ្រងទ្វារនោះ ។ ម្នាលភិក្ខុទាំងឡាយ បើនន្ទភិក្ខុរមិលមើលទិសខាងលិច រមិលមើលទិសខាងជើង រមិលមើលទិសខាងត្បូង ងើយមើលទៅទិសខាងលើឱនមើលទិសខាងក្រោម ងាកមើលទៅទិសជាលំដាប់ លុះតែប្រមូលនូវហេតុទាំងអស់ដោយចិត្ត ទើបនន្ទភិក្ខុងាកមើលនូវទិសជាលំដាប់ដោយគំនិតថា អកុសលធម៌ទាំងឡាយដ៏លាមក គឺអភិជ្ឈានិងទោមនស្ស នឹងមិនជាប់តាមអាត្មាអញ ដែលកំពុងងាកមើលទិសជាលំដាប់ ។ ព្រោះហេតុនោះ ក្នុងសាសនានេះនន្ទភិក្ខុទើបឈ្មោះថាជាអ្នកមានសេចក្តីដឹងខ្លួនក្នុងការគ្រប់គ្រងទ្វារយ៉ាងនេះ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលនន្ទភិក្ខុមានឥន្ទ្រិយគ្រប់គ្រងហើយយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ហេតុដែលនន្ទភិក្ខុស្គាល់ប្រមាណក្នុងភោជននោះយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ នន្ទភិក្ខុពិចារ-ណាដោយឧបាយ ហើយទើបបរិភោគនូវអាហារ មិនមែនដើម្បីលេង

ន មទាយ ន មណ្ឌនាយ ន វិភូសនាយ យាវទេវ ឥមស្ស កាយស្ស ឋិតិយា យាបនាយ វិហឹសុបរតិយា ព្រហ្មចរិយានុគ្គហាយ ឥតិ បុរាណញ្ច វេទនំ បដិ-ហង្ខាមិ នវញ្ច វេទនំ ន ឧប្បាទេស្សាមិ យាត្រា ច មេ ភវិស្សតិ អនវជ្ជតា ច ផាសុវិហារោ ចាតិ ។ ឯវំ ខោ ភិក្ខវេ នន្ទស្ស ភោជនេ មត្តញ្ញុតាយ ហោតិ ។

តត្រិទំ ភិក្ខវេ នន្ទស្ស ជាគរិយានុយោគស្មឹ ហោតិ ឥធ ភិក្ខវេ នន្ទោ ទិវសំ ចង្កមេន និសជ្ជាយ អាវ-រណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា បឋមំ យាមំ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ រត្តិយា មជ្ឈិមំ យាមំ ទក្ខិណេន បស្សេន សីហសេយ្យំ កប្បេតិ បាទេន បាទំ អច្ចាធាយ សតោ សម្បជានោ ឧដ្ឋានសញ្ញំ មនសិការិត្វា រត្តិយា បច្ឆិមំ យាមំ បច្ចុដ្ឋាយ ចង្កមេន និសជ្ជាយ អាវរណីយេហិ ធម្មេហិ ចិត្តំ បរិសោធេតិ ។ ឯវំ ខោ ភិក្ខវេ នន្ទស្ស ជាគរិយានុយោគស្មឹ ហោតិ ។

មិនមែនដើម្បីស្រវឹង មិនមែនដើម្បីតាក់តែងរាងកាយ មិនមែនដើម្បីផូរផង់ គ្រាន់តែឲ្យតាំងនៅនៃកាយនេះ ដើម្បីញ៉ាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ ដើម្បីបំបាត់បង់នូវសេចក្តីលំបាក ដើម្បីអនុគ្រោះដល់ព្រហ្មចារ្យ អាត្មាអញនឹងកម្ចាត់បង់នូវវេទនាចាស់ផង ញ៉ាំងវេទនាថ្មី មិនឲ្យកើតឡើងបានផង ការប្រព្រឹត្តទៅនៃឥរិយាបថក្តី ការមិនមានទោសក្តី ការនៅសប្បាយក្តី នឹងមានដល់អាត្មាអញ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលនន្ទភិក្ខុស្គាល់ប្រមាណ ក្នុងភោជនយ៉ាងនេះឯង ។

ម្នាលភិក្ខុទាំងឡាយ ហេតុដែលនន្ទភិក្ខុប្រកបរឿយៗ ក្នុងការភ្ញាក់រលឹកនោះយ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះនន្ទភិក្ខុជម្រះចិត្តចាកអាវរណីយធម៌ ដោយការចង្រ្កម ដោយការអង្គុយអស់មួយថ្ងៃ ជម្រះចិត្តចាកអាវរណីយធម៌ ដោយការចង្រ្កម ដោយការអង្គុយអស់បឋមយាមនៃរាត្រី សម្រេចនូវសីហសេយ្យ ដោយផ្អៀងទៅខាងស្តាំ តម្រួតជើង ដោយជើង ជាអ្នកមានសតិសម្បជញ្ញៈ ធ្វើទុកក្នុងចិត្តនូវឧដ្ឋានសញ្ញា អស់មជ្ឈិមយាមនៃរាត្រី ហើយក្រោកឡើង ជម្រះចិត្តចាកអាវរណីយធម៌ ដោយការចង្រ្កម ដោយការអង្គុយ អស់បច្ឆិមយាមនៃរាត្រី ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលនន្ទភិក្ខុប្រកបរឿយៗ ក្នុងការភ្ញាក់រលឹកយ៉ាងនេះឯង ។

តត្រិទំ ភិក្ខវេ នន្ទស្ស សតិសម្បជញ្ញស្មឹ ហោតិ ឥធ ភិក្ខវេ នន្ទស្ស វិទិតា វេទនា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ វិទិតា សញ្ញា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ វិទិតា វិតក្កា ឧប្បជ្ជន្តិ វិទិតា ឧបដ្ឋហន្តិ វិទិតា អព្ភត្ថំ គច្ឆន្តិ ។ ឥទំ ខោ ភិក្ខវេ នន្ទស្ស សតិសម្បជញ្ញស្មឹ ហោតីតិ ។ កិមញ្ញត្រ ភិក្ខវេ នន្ទោ ឥន្ទ្រិយេសុ គុត្តទ្វារោ ភោជនេ មត្តញ្ញូ ជាគរិយមនុយុត្តោ សតិសម្បជញ្ញេន សមន្នាគតោ យេហិ នន្ទោ សក្កោតិ បរិបុណ្ណំ បរិសុទ្ធំ ព្រហ្មចរិយំ ចរិតុន្តិ ។

[១០] ឯកំ សមយំ ភគវា ចម្បាយំ វិហរតិ គគ្គរាយ បោក្ខរណិយា តីរេ ។ តេន ខោ បន សមយេន ភិក្ខូ ភិក្ខុំ អាបត្តិយា ចោទេន្តិ ។ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ អញ្ញេនាញ្ញំ បដិចរតិ ពហិទ្ធា កថំ អបនាមេតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ ។

ម្នាលភិក្ខុទាំងឡាយ ហេតុដែលនន្ទភិក្ខុ មានសតិសម្បជញ្ញៈនោះ យ៉ាងនេះ ម្នាលភិក្ខុទាំងឡាយ ក្នុងសាសនានេះ វេទនាកើតឡើងដល់នន្ទភិក្ខុ ក៏ដឹងច្បាស់ វេទនាប្រាកដឡើង ក៏ដឹងច្បាស់ ដល់នូវសេចក្តីវិនាស ក៏ដឹងច្បាស់ សញ្ញាដែលកើតឡើង ក៏ដឹងច្បាស់ សញ្ញាប្រាកដឡើង ក៏ដឹងច្បាស់ សញ្ញាដល់នូវសេចក្តីវិនាស ក៏ដឹងច្បាស់ វិតក្កៈដែលកើតឡើង ក៏ដឹងច្បាស់ វិតក្កៈដែលប្រាកដឡើង ក៏ដឹងច្បាស់ វិតក្កៈដែលដល់នូវសេចក្តីវិនាស ក៏ដឹងច្បាស់ ។ ម្នាលភិក្ខុទាំងឡាយ ហេតុដែលនន្ទភិក្ខុមានសតិសម្បជញ្ញៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចាំបាច់ពោលទៅថ្វីក្នុងទីដទៃថា នន្ទភិក្ខុគ្រប់គ្រងទ្វារ ក្នុងឥន្ទ្រិយទាំងឡាយ ដឹងប្រមាណ ក្នុងភោជន ប្រកបរឿយៗ នូវការភ្ញាក់រលឹក ប្រកបដោយសតិសម្បជញ្ញៈ ទើបនន្ទភិក្ខុអាចប្រព្រឹត្តព្រហ្មចរិយធម៌ ឲ្យបរិបូណ៌បរិសុទ្ធបាន ។

[១០] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្បែរឆ្នេរស្រះបោក្ខរណីឈ្មោះគគ្គរា ជិតក្រុងចម្បា ។ សម័យនោះឯង ភិក្ខុទាំងឡាយចោទភិក្ខុផងគ្នាដោយអាបត្តិ ។ ភិក្ខុនោះ កាលត្រូវពួកភិក្ខុផងគ្នា ចោទដោយអាបត្តិក៏អាងពាក្យដទៃដោយពាក្យដទៃ បដិសេធពាក្យទៅខាងក្រៅ ធ្វើសេចក្តីក្រោធផង ទោសផង សេចក្តីមិនពេញចិត្តផង ឲ្យកើតប្រាកដ ។

អថខោ ភគវា ភិក្ខូ អាមន្តេសិ និទ្ធមថេតំ[១] ភិក្ខវេ បុគ្គលំ និទ្ធមថេតំ ភិក្ខវេ បុគ្គលំ ។ អបនេយ្យោ ភិក្ខវេ បុគ្គលោ កឹ បរបុត្តោ[២] វិហេឋេតិ ឥធ ភិក្ខវេ ឯកច្ចស្ស បុគ្គលស្ស តាទិសំយេវ ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ សម្មិញ្ជិតំ បសារិតំ សង្ឃាដិបត្តចីវរធារណំ សេយ្យថាបិ អញ្ញេសំ ភទ្ទកានំ ភិក្ខូនំ យាវស្ស ភិក្ខូ អាបត្តឹ ន បស្សន្តិ យតោ ច ខ្វស្ស ភិក្ខូ អាបត្តឹ បស្សន្តិ តមេនំ ឯវំ ជានន្តិ សមណទូសីវាយំ សមណ-បលាបោ សមណការណ្ឌវោតិ តមេនំ ឥតិ វិទិត្វា ពហិទ្ធា នាសេន្តិ ។ តំ កិស្ស ហេតុ ។ មា អញ្ញេ ភទ្ទកេ ភិក្ខូ ទូសេសីតិ ។ សេយ្យ-ថាបិ ភិក្ខវេ សម្បន្នេ យវករណេ យវទូសី

---

១ ឱ. ធមថេតំ ។ ម. ទមថេតំ ។ ២ ឱ. កឹ វោ បរបុត្តា ។ ម. កឹ សោ បរបុត្តោ ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរបណ្តេញនូវបុគ្គលនេះចេញ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរបណ្តេញនូវបុគ្គលនេះចេញ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល (នោះ) ជាបុគ្គលគួរបណ្តេញចេញ បុគ្គលដូចជាកូននៃបុគ្គលដទៃ រមែងបៀតបៀនបានទេដឹង ម្នាលភិក្ខុទាំងឡាយ ការឈានទៅមុខនិងថយក្រោយ ការមើលទូទៅមើលផ្សេងៗ ការបត់អវយវៈចូល ការលាអវយវៈចេញ ការទ្រទ្រង់នូវសង្ឃាដី បាត្រ ចីវរ របស់បុគ្គលពួកខ្លះក្នុងសាសនានេះ ប្រាកដដូច្នោះ ដូចដំណើរនៃពួកភិក្ខុដ៏ចម្រើនដទៃ ពួកភិក្ខុមិនឃើញនូវអាបត្តិរបស់ភិក្ខុនោះ លុះកាលណាពួកភិក្ខុ ឃើញនូវអាបត្តិភិក្ខុនោះ ក៏ដឹងនូវភិក្ខុនោះយ៉ាងនេះថា ភិក្ខុនេះ ជាអ្នកប្រទូស្តដល់សមណៈដូចជាសំដីឬ អង្កាមក្នុងសមណៈ ជាសំរាមក្នុងសមណៈ លុះពួកភិក្ខុដឹងច្បាស់នូវភិក្ខុនោះ ដូច្នេះហើយ ក៏ធ្វើឲ្យវិនាសទៅខាងក្រៅ (ជំនុំសង្ឃ) ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា អ្នកកុំប្រទូស្តភិក្ខុល្អទាំងឡាយឯទៀតឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចយ៉ាងស្មៅដែលបង្ខូចស្រូវ

ជាយេថ យវកលាបោ យវការណ្ឌវោ តស្ស តាទិសំ-យេវ មូលំ ហោតិ សេយ្យថាបិ អញ្ញេសំ ភទ្ទកានំ យវានំ តាទិសំយេវ ទណ្ឌំ ហោតិ សេយ្យថាបិ អញ្ញេសំ ភទ្ទកានំ យវានំ តាទិសំយេវ បលាសំ[១] ហោតិ សេយ្យថាបិ អញ្ញេសំ ភទ្ទកានំ យវានំ យាវស្ស សីសំ ន និព្វត្តតិ យតោ ច ខ្វស្ស សីសំ និព្វត្តតិ តមេនំ ឯវំ ជានន្តិ យវទូសីវាយំ យវបលាបោ យវការណ្ឌវោតិ តមេនំ ឥតិ វិទិត្វា សមូលំ ឧប្បាដេត្វា ពហិទ្ធា យវករណស្ស ឆឌ្ឌេន្តិ ។ តំ កិស្ស ហេតុ ។ មា អញ្ញេ ភទ្ទកេ យវេ ទូសេសីតិ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចស្ស បុគ្គលស្ស តាទិសំយេវ ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ សម្មិញ្ជិតំ បសារិតំ សង្ឃាដិបត្តចីវរធារណំ សេយ្យថាបិ អញ្ញេសំ ភទ្ទកានំ ភិក្ខូនំ យាវស្ស ភិក្ខូ អាបត្តឹ ន បស្សន្តិ យតោ ច ខ្វស្ស ភិក្ខូ អាបត្តឹ បស្សន្តិ

១ ឱ. ម. បត្តំ ។

ជាសំដីក្នុងស្រូវ ជាសំរាមដល់ស្រូវ ដុះឡើងក្នុងស្រែនៃស្រូវដ៏ល្អ គល់ស្មៅនោះក៏ដូច្នោះដែរ ដូចគល់នៃស្រូវដ៏ចម្រើនដទៃ ដើមក៏ដូច្នោះដែរ ដូចជាដើមនៃស្រូវដ៏ចម្រើនដទៃ ស្លឹកក៏ដូច្នោះដែរ ដូចជាស្លឹកនៃស្រូវ ដ៏ចម្រើនដទៃ កំណត់ត្រឹមកួរនៃស្មៅនោះមិនទាន់កើត លុះកាលណាកួរនៃស្មៅនោះកើតឡើង អ្នកផងទើបដឹងស្មៅនោះយ៉ាងនេះថា នេះជាស្មៅបង្ខូចស្រូវ ជាសំដីក្នុងស្រូវ ជាសំរាមដល់ស្រូវ លុះអ្នកផងដឹងច្បាស់នូវស្មៅនោះយ៉ាងនេះហើយ ក៏ដករំលើងទាំងឫសចោលទៅ ខាងក្រៅនៃស្រែស្រូវ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា កុំឲ្យបង្ខូចស្រូវទាំងឡាយ ឯទៀតបានឡើយ សេចក្តីនេះយ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ការឈានទៅមុខ និងការថយក្រោយ ការមើលទួទៅ ការមើលផ្សេងៗ ការបត់អវយវៈចូល ការលាអវយវៈចេញ ការទ្រទ្រង់នូវសង្ឃាដី បាត្រ ចីវរ របស់បុគ្គលពួកខ្លះ ក្នុងសាសនានេះ ប្រាកដដូចយ៉ាងដំណើរនៃពួកភិក្ខុល្អដទៃ កំណត់ត្រឹមពួកភិក្ខុ មិនឃើញនូវអាបត្តិរបស់ភិក្ខុនោះ ក្នុងកាលណាពួកភិក្ខុឃើញនូវអាបត្តិរបស់ភិក្ខុនោះ

តមេនំ ឯវំ ជានន្តិ សមណទូសីវាយំ សមណបលាបោ សមណការណ្ឌវោតិ តមេនំ ឥតិ វិទិត្វា ពហិទ្ធា នាសេន្តិ ។ តំ កិស្ស ហេតុ ។ មា អញ្ញេ ភទ្ទកេ ភិក្ខូ ទូសេសីតិ ។ សេយ្យថាបិ ភិក្ខវេ មហតោ ធញ្ញរាសិស្ស ផុសយមានស្ស តត្ថ យានិ តានិ ធញ្ញានិ ទឡ្ហានិ សារវន្តានិ តានិ ឯកមន្តំ បុញ្ជំ ហោតិ យានិ បន តានិ ធញ្ញានិ ទុព្វលានិ បលា-បានិ តានិ វាតោ ឯកមន្តំ អបវហតិ តមេនំ សាមិកា សម្មជ្ជនឹ គហេត្វា ភិយ្យោសោ មត្តាយ អបសម្មជ្ជន្តិ ។ តំ កិស្ស ហេតុ ។ មា អញ្ញេ ភទ្ទកេ ធញ្ញេ ទូសេសីតិ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចស្ស បុគ្គលស្ស តាទិសំយេវ ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ សម្មិញ្ជិតំ បសារិតំ សង្ឃាដិបត្តចីវរធារណំ សេយ្យថាបិ អញ្ញេសំ ភទ្ទកានំ ភិក្ខូនំ យាវស្ស ភិក្ខូ អាបត្តឹ ន បស្សន្តិ យតោ ច ខ្វស្ស ភិក្ខូ អាបត្តឹ បស្សន្តិ

*ក៏ដឹងនូវភិក្ខុនោះយ៉ាងនេះថា ភិក្ខុនេះជាអ្នកប្រទូស្តសមណៈ ដូចជាសំដី ឬ អង្កាមក្នុងសមណៈ ជាសំរាមដល់សមណៈ លុះពួកភិក្ខុដឹងច្បាស់នូវភិក្ខុនោះដូច្នេះហើយ ក៏ធ្វើឲ្យវិនាសទៅខាងក្រៅ (ជំនុំសង្ឃ) ក្នុងកាលនោះក៏យ៉ាងនោះឯង ។ ដំណើរនោះព្រោះហេតុអ្វី ។ ព្រោះថា កុំឲ្យប្រទូស្តភិក្ខុល្អទាំងឡាយឯទៀតឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចយ៉ាងគំនរស្រូវដ៏ធំដែលគេកំពុងរោយ ស្រូវណា ក្នុងគំនរទាំងនោះ ដែលជាស្រូវសុទ្ធ ជាស្រូវមានគ្រាប់ ស្រូវទាំងនោះ ក៏ទៅជាគំនរដោយឡែក ចំណែកស្រូវណា ជាស្រូវមានកម្លាំងថយ ជាសំដីស្រូវ ខ្យល់ក៏បក់ស្រូវទាំងនោះ ទៅជាគំនរដោយឡែក ពួកម្ចាស់ក៏យកអំបោសទៅបោសស្រូវនោះ (ឲ្យស្អាតចេញ) ដោយក្រៃលែង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា កុំឲ្យបង្ខូចស្រូវល្អទាំង-ឡាយឯទៀតបានឡើយ យ៉ាងណាមិញ ។ ម្នាលភិក្ខុទាំងឡាយ ដំណើរប្រាកដដូច្នោះគឺ ការឈានទៅមុខ និងការថយក្រោយ ការមើលទូទៅ ការមើលផ្សេងៗ ការបត់អវយវៈចូល ការលាអវយវៈចេញ ការទ្រទ្រង់នូវសង្ឃាដី បាត្រ ចីវរ របស់បុគ្គលពួកខ្លះ ក្នុងសាសនានេះ ប្រាកដដូចយ៉ាងដំណើរនៃពួកភិក្ខុល្អដទៃ កំណត់ត្រឹមពួកភិក្ខុ មិនឃើញនូវអាបត្តិរបស់ភិក្ខុនោះ លុះកាលណាពួកភិក្ខុឃើញអាបត្តិរបស់ភិក្ខុនោះ*

តមេនំ ឯវំ ជានន្តិ សមណទូសីវាយំ សមណបលាបោ សមណការណ្ឌវោតិ តមេនំ ឥតិ វិទិត្វា ពហិទ្ធា នាសេន្តិ ។ តំ កិស្ស ហេតុ ។ មា អញ្ញេ ភទ្ទកេ ភិក្ខូ ទូសេសីតិ ។ សេយ្យថាបិ ភិក្ខវេ បុរិសោ ឧទបានបនាឡិយត្ថិកោ តិណ្ហំ កុឋារឹ អាទាយ វនំ បវិសេយ្យ សោ តន្តនេវ រុក្ខំ កុឋារិបាសេន អាកោ-ដេតិ ។ តត្ថ យានិ តានិ រុក្ខានិ ទឡ្ហានិ សារវន្តានិ តានិ កុឋារិបាសេន អាកោដិតានិ កក្ខឡំ បដិនទន្តិ ។ យានិ បន តានិ រុក្ខានិ អន្តោបូតីនិ អវស្សុតានិ កសម្ពុជាតានិ តានិ កុឋារិបាសេន អាកោដិតានិ ទទ្ទរំ បដិនទន្តិ ។ តមេនំ មូលេ ឆិន្ទតិ មូលេ ឆិន្ទិត្វា អគ្គេ ឆិន្ទតិ អគ្គេ ឆិន្ទិត្វា អន្តោ សុវិសោធិតំ វិសោធេតិ អន្តោ សុវិសោធិតំ វិសោធេត្វា ឧទបានបនាឡឹ យោជេតិ ។ ឯវមេវ ខោ ភិក្ខវេ ឥធេកច្ចស្ស បុគ្គលស្ស តាទិសំយេវ ហោតិ អភិក្កន្តំ បដិក្កន្តំ អាលោកិតំ វិលោកិតំ សម្មិញ្ជិតំ បសារិតំ សង្ឃាដិបត្តចីវរធារណំ

ក៏ដឹងភិក្ខុនោះយ៉ាងនេះថា ភិក្ខុនេះជាអ្នកប្រទូស្តសមណៈ ដូចជាសំដី ឬ អង្កាមក្នុងសមណៈ ជាសំរាមដល់សមណៈ លុះពួកភិក្ខុ ដឹងច្បាស់នូវភិក្ខុនោះដូច្នេះហើយ ធ្វើឲ្យវិនាសទៅខាងក្រៅ (ជំនុំសង្ឃ) ក្នុងកាលនោះ ក៏យ៉ាងនោះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា កុំឲ្យប្រទូស្តពួកភិក្ខុល្អទាំងឡាយឯទៀតបានឡើយ ។ ម្នាលភិក្ខុទាំងឡាយ ដូចយ៉ាងបុរសត្រូវការថាំងសម្រាប់ដងទឹកអណ្តូង ក៏ត្រូវកាន់យក ដឹងដ៏មុតចូលទៅព្រៃ បុរសនោះគោះមើលឈើនោះ ដោយស្ទាបដឹង ។ ឈើទាំងនោះ ឈើណា ជាឈើមាំមួន មានខ្លឹម ឈើទាំងនោះ កាលត្រូវគេគោះ ដោយស្ទាបដឹងហើយ ក៏បញ្ចេញសូរបែបរឹងតាន់ ។ ចំណែកឈើទាំងឡាយណា ជាឈើស្អុយក្នុង ជាឈើពុក ជាឈើជ្រោកជ្រាក ឈើទាំងនោះ កាលត្រូវគេគោះ ដោយស្ទាបដឹងហើយ ក៏បញ្ចេញសូរបែបព្រុកៗ ។ បុរសនោះក៏កាត់យកឈើនោះត្រង់គល់ លុះកាត់គល់ហើយ ទើបកាត់ចុង លុះកាត់ចុងហើយ ទើបសម្អាតខាងក្នុងឲ្យស្អាត លុះសម្អាតខាងក្នុង ឲ្យស្អាតហើយ ទើបធ្វើទៅជាថាំងសម្រាប់ដងទឹកអណ្តូង យ៉ាងណា ។ ម្នាលភិក្ខុទាំងឡាយ ការឈានទៅមុខ និងការថយក្រោយ ការមើលទួទៅ ការមើលផ្សេងៗ ការបត់អវយវៈចូល ការលាអវយវៈចេញ ការទ្រទ្រង់នូវសង្ឃាដី បាត្រ ចីវរ

៣៩

បណ្ណាសកេ មេត្តាវគ្គោ

សេយ្យថាបិ អញ្ញេសំ ភទ្ទកានំ ភិក្ខូនំ យាវស្សុ ភិក្ខូ អាបត្តឹ ន បស្សន្តិ យតោ ច ខ្វស្សុ ភិក្ខូ អាបត្តឹ បស្សន្តិ តមេនំ ឯវំ ជានន្តិ សមណទូសី-វាយំ សមណបលាចោ សមណការណ្ឌវោតិ តមេនំ ឥតិ វិទិត្វា ពហិទ្ធា នាសេន្តិ ។ តំ កិស្ស ហេតុ ។ មា អញ្ញេ ភទ្ទកេ ភិក្ខូ ទូសេសីតិ ។

សំវាសាយ វិជានេថ ចាបិច្ឆកោធនោ ឥតិ[១]
មក្ខី ថម្ភី បលាសី ច ឥស្សុកី មច្ឆរី សឋោ
សណ្ហវាចោ ជនវតិ សមណោ វិយ ភាសតិ
រហោ ករោតិ ករណំ ចាបទិដ្ឋិ អនាទរោ
សំសប្បី ច មុសាវាទី តំ វិទិត្វា យថា កថំ
សព្វេ សមគ្គា ហុត្វាន អភិនិព្វជ្ជយាថ[២] នំ

១ ឱ. ម. បាបិច្ឆោកោធនោ ឥតិ ។ ២ ម. អភិនិព្វជ្ជយេថ ។

តែងមានដល់បុគ្គលពួកខ្លះ ក្នុងសាសនានេះ ប្រាកដដូចយ៉ាងដំណើរនៃពួកភិក្ខុល្អដទៃ កំណត់ត្រឹមពួកភិក្ខុមិនទាន់ឃើញនូវអាបត្តិរបស់ភិក្ខុនោះ លុះកាលណាពួកភិក្ខុឃើញនូវអាបត្តិរបស់ភិក្ខុនោះហើយ ក៏ដឹងនូវភិក្ខុនោះយ៉ាងនេះថា ភិក្ខុនេះជាអ្នកប្រទូស្តសមណៈ ដូចជាសំដី ឬ អង្កាមក្នុងសមណៈ ជាសំរាមដល់សមណៈ លុះពួកភិក្ខុ ដឹងច្បាស់នូវភិក្ខុនោះដូច្នេះហើយ ធ្វើឲ្យវិនាសទៅខាងក្រៅ (ជំនុំសង្ឃ) ក្នុងកាលនោះ ក៏យ៉ាងនោះដែរ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ព្រោះថា កុំឲ្យប្រទូស្តពួកភិក្ខុល្អឯទៀតបានឡើយ ។

ដោយការនៅរួមគ្នា បុគ្គលគប្បីដឹងថា បុគ្គលមានប្រាថ្នាដ៏លាមក មានសេចក្តីក្រោធ ជាអ្នកលុបគុណ រឹងត្អឹងលើកខ្លួន ប្រណែន មានសេចក្តីកំណាញ់ ជាអ្នកអួតអាង មានសម្តីទន់ភ្លន់ និយាយក្នុងកណ្តាលប្រជុំជន ដូចជាសមណៈ តែជាអ្នកមានទិដ្ឋិអាក្រក់ មិនអើពើ (ក្នុងធម៌វិន័យ) ជាបុគ្គលរឡេមរឡាម ពោលនូវពាក្យកុហក តែងធ្វើនូវអំពើ (អាក្រក់) ក្នុងទីស្ងាត់ យ៉ាងណា អ្នកទាំងឡាយទាំងអស់គ្នា លុះដឹងច្បាស់នូវពាក្យនោះ យ៉ាងណាហើយ គួរជាអ្នកព្រមព្រៀងគ្នា ចូរបណ្តេញនូវបុគ្គលនោះចេញ

៤០



ការណ្ឌវំ និទ្ធមវា(១) កសម្ពុំ អបកស្សវា(២)
តតោ បលាបេ វាហេថ អស្សមណេ សមណមានិនេ
និទ្ធមិត្វាន ចាបិច្ឆំ(៣) ចាបលាចារគោចរេ
សុទ្ធាសុទ្ធេហិ សំវាសំ កប្បយវ្ហោ បដិស្សតា
តតោ សមគ្គា និបកា ទុក្ខស្សន្តំ ករិស្សថាតិ ។

មេត្តាវគ្គោ បឋមោ ។

## តស្សុទ្ទានំ

មេត្តបញ្ញា ច ទ្វេ ច បិយេ ទ្វេ ចាប្បិយេ ទ្វេ ច
លោកាលោកវិបត្តិយោ(៤) ទេវទត្តោ ច ឧត្តរោ
នន្ទោ ការណ្ឌវេន ចាតិ ។

---

១ ឱ. ម. និទ្ធមថ ។ ២ ឱ. អបកស្សថ ។ ម. អវកស្សថ ។ ៣ ឱ. ម. បាបិច្ឆេ ។
៤ ឱ. ម. មេត្តំ បញ្ញា ច ទ្វេ បិយា ទ្វេ ច លោកវិបត្តិយោតិ ទិស្សន្តិ ។

កម្ចាត់បង់នូវបុគ្គលដូចជាសំរាម កម្ចាត់បង់នូវបុគ្គលជ្រោកជ្រាកចេញ លំដាប់អំពីនោះ អ្នកទាំងឡាយ ចូរបន្សាត់នូវបុគ្គលទាំងឡាយ ដូចជាសំដី ឬ អង្កាម មិនមែនជាសមណៈ លើកខ្លួនថាជាសមណៈនោះចេញ លុះអ្នកទាំង-ឡាយ កម្ចាត់បង់នូវបុគ្គលប្រាថ្នាលាមក មានអាចារៈនិងគោចរៈដ៏លាមកចេញហើយ ជាអ្នកមានស្មារតី ចូរកំណត់នូវការនៅរួមគ្នា ដោយបុគ្គលបរិសុទ្ធ និងមិនបរិសុទ្ធ គួរជាអ្នកព្រមព្រៀងគ្នា មានប្រាជ្ញាដ៏ខ្ជាប់ខ្ជួន នឹងធ្វើនូវទីបំផុតនៃទុក្ខបាន ។

ចប់ មេត្តាវគ្គ ទី ១ ។

# ឧទ្ទានក្នុងមេត្តាវគ្គនោះគឺ

និយាយអំពីអានិសង្សមេត្តាចេតោសមាធិ ១ អំពីការបានបញ្ញាពីរលើក អំពីបុគ្គលជាទីស្រឡាញ់ពីរលើក អំពីបុគ្គលមិនជាទីស្រឡាញ់ពីរលើក អំពីលោកធម៌ និងការប្រាស-ចាកលោកធម៌ ១ អំពីទេវទត្ត ១ អំពីព្រះឧត្តរៈ ១ អំពីព្រះនន្ទៈ ១ អំពីសមណៈដូចជាសំរាម ១ ។

# មហាវគ្គោ

[១១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា វេរញ្ជាយំ វិហរតិ នឡេរុបុចិមណ្ឌរុក្ខមូលេ ។ អថខោ វេរញ្ជោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ វេរញ្ជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច សុតមេតំ ភោ គោតម សមណោ គោតមោ ន ព្រាហ្មណេ ជិណ្ណេ វុឌ្ឍេ មហល្លកេ អទ្ធគតេ វយោអនុប្បត្តេ អភិវាទេតិ វា បច្ចុដ្ឋេតិ វា អាសនេន វា និមន្តេតីតិ តយិទំ ភោ គោតម តថេវ ន ហិ ភវំ គោតមោ ព្រាហ្មណេ ជិណ្ណេ វុឌ្ឍេ មហល្លកេ អទ្ធគតេ វយោអនុប្បត្តេ អភិ-វាទេតិ វា បច្ចុដ្ឋេតិ វា អាសនេន វា និមន្តេតិ

# មហាវគ្គ

[១១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយព្រះដ៏មានព្រះភាគទ្រង់គង់នៅក្បែរដើមស្តៅ ជាលំនៅរបស់នឡេរុយក្ស ជិតស្រុកវេរញ្ជា ។ គ្រានោះ វេរញ្ជព្រាហ្មណ៍ ចូលសំដៅទៅត្រង់ទី ដែលព្រះមានព្រះភាគគង់ លុះចូលទៅដល់ហើយ ធ្វើសេចក្តីរីករាយ ជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ទើបអង្គុយក្នុងទីដ៏សមគួរ ។ កាលដែលវេរញ្ជព្រាហ្មណ៍ អង្គុយក្នុងទីដ៏សមគួរហើយ បានក្រាបទូលព្រះមានព្រះភាគយ៉ាងនេះថា បពិត្រព្រះគោតមដ៏ចម្រើន ខ្ញុំបានឮពាក្យថា ព្រះសមណគោតម មិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយ ដែលចាស់ជរា ជាព្រឹទ្ធាចារ្យមានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុជ្រុលចូលក្នុងបច្ឆិមវ័យហើយ ទោះបីគ្រាន់តែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះ ឲ្យអង្គុយលើអាសនៈ (ព្រះអង្គក៏មិនធ្វើ) បពិត្រព្រះគោតមដ៏ចម្រើន ពាក្យដែលខ្ញុំបានឮមកនោះ ជាប្រាកដថា ព្រះគោតមដ៏ចម្រើន មិនសំពះ មិនក្រោកទទួលព្រាហ្មណ៍ទាំងឡាយ ដែលចាស់ជរា ជាព្រឹទ្ធាចារ្យមានអាយុច្រើន រស់នៅបានយូរឆ្នាំមកហើយ មានអាយុជ្រុលចូលមកក្នុងបច្ឆិមវ័យហើយ ជាសូម្បីត្រឹមតែអញ្ជើញហៅរកព្រាហ្មណ៍ទាំងនោះ ដោយអាសនៈ ( ព្រះអង្គក៏មិនធ្វើ )

តយិទំ ភោ គោតម ន សម្បន្នមេវាតិ ។ នាហន្តំ ព្រាហ្មណ បស្សាមិ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ យមហំ អភិវាទេយ្យំ វា បច្ចុដ្ឋេយ្យំ វា អាសនេន វា និមន្តេយ្យំ យញ្ហិ ព្រាហ្មណ តថាគតោ អភិវាទេយ្យ វា បច្ចុដ្ឋេយ្យ វា អាសនេន វា និមន្តេយ្យ មុទ្ធាបិ តស្ស វិបតេយ្យាតិ ។ អរសរូបោ ភវំ គោតមោតិ ។ អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អរស-រូបោ សមណោ គោតមោតិ យេ តេ ព្រាហ្មណ រូបរសា សទ្ទរសា គន្ធរសា រសរសា ផោដ្ឋព្វរសា តេ តថាគតស្ស បហីនា ឧច្ឆិន្នមូលា តាលា-វត្ថុកតា អនភាវំកតា អាយតឹ អនុប្បាទធម្មា

បពិត្រព្រះគោតមដ៏ចម្រើន កិច្ចមានមិនសំពះជាដើមនោះ ជាទំនងពុំសមគួរឡើយ ។ ព្រះដ៏មានព្រះភាគត្រាស់ថា ម្នាលព្រាហ្មណ៍ ក្នុងលោកព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្សជាសម្មតិទេព និងមនុស្សដ៏សេស តថាគត មិនឃើញអ្នកណាមួយ ល្មមឲ្យតថាគតសំពះ ឬក្រោកទទួល ឬអញ្ជើញហៅរកឲ្យអង្គុយលើអាសនៈឡើយ ម្នាលព្រាហ្មណ៍ ព្រោះថាបើតថាគតសំពះអ្នកណាឬក្រោកទទួលអ្នកណា ឬក៏អញ្ជើញហៅរកដោយអាសនៈ ក្បាលរបស់អ្នកនោះ នឹងដាច់ធ្លាក់ចេញចាកក ។ វេរញ្ជព្រាហ្មណ៍ក៏ពោលពាក្យច្រឡោះបោះ ទៅរកព្រះសាស្តាថា ព្រះគោតមដ៏ចម្រើន ជាមនុស្សសោះកក្រោះ ឥតរសជាតិទេតើ ។ ព្រះដ៏មានព្រះភាគត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សសោះកក្រោះ ឥតរសជាតិ ដែលគេថា នោះត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះរសជាតិ គឺរូប សំឡេងក្លិនរសផោដ្ឋព្វ ទាំងប៉ុន្មាននោះ តថាគតបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោតដែលគេគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ ជាធម៌លែងមានបែបភាពតទៅទៀតហើយ ជាធម៌លែងមានកំណើតតទៅមុខទៀតហើយ

៤៣



អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អរសរូបោ សមណោ គោតមោតិ នោ ច ខោ យំ ត្វំ សន្ធាយ វទេសីតិ ។ និព្ភោគោ ភវំ គោតមោតិ ។ អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ និព្ភោគោ សមណោ គោតមោតិ យេ តេ ព្រាហ្មណ រូបភោគា សទ្ទភោគា គន្ធភោគា រសភោគា ផោដ្ឋព្វភោគា តេ តថាគតស្ស បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំកតា អាយតឹ អនុប្បាទធម្មា អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ និព្ភោគោ សមណោ គោតមោតិ នោ ច ខោ យំ ត្វំ សន្ធាយ វទេសីតិ ។ អកិរិយវាទោ ភវំ គោតមោតិ ។ អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អកិរិយវាទោ សមណោ គោតមោតិ

ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សសោះកក្រោះ ឥតមានរសជាតិនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុដែលព្រាហ្មណ៍ឯងនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន គ្មានគ្រឿងប្រើការទេតើ ។ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សប្រើការមិនកើត ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះគ្រឿងប្រើការ គឺរូប សំឡេង ក្លិន រស ផោដ្ឋព្វទាំងប៉ុន្មាននោះ តថាគតបានលះស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោតដែលគេគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ ជាធម៌លែងមានបែបភាពតទៅទៀតហើយ ជាធម៌មិនមានកំណើត តទៅខាងមុខទៀតទេ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាមនុស្សប្រើការមិនកើតនោះ គឺជាសម្តីត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុដែលអ្នកនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអកិរិយវាទទេតើ ។ ព្រះសាស្តាទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអកិរិយវាទ ដែលគេថានោះត្រូវហើយ

អហញ្ហិ ព្រាហ្មណ អកិរិយំ វទាមិ កាយទុច្ចរិតស្ស វចីទុច្ចរិតស្ស មនោទុច្ចរិតស្ស អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ អកិរិយំ វទាមិ អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អកិរិយវាទោ សមណោ គោតមោតិ នោ ច ខោ យំ ត្វំ សន្ធាយ វទេសីតិ ។

ឧច្ឆេទវាទោ ភវំ គោតមោតិ ។ អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ឧច្ឆេទវាទោ សមណោ គោតមោតិ អហញ្ហិ ព្រាហ្មណ ឧច្ឆេទំ វទាមិ រាគស្ស ទោសស្ស មោហស្ស អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ ឧច្ឆេទំ វទាមិ អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ឧច្ឆេទវាទោ សមណោ គោតមោតិ នោ ច ខោ យំ ត្វំ សន្ធាយ វទេសីតិ ។ ជេគុច្ឆី ភវំ គោតមោតិ ។

ម្នាលព្រាហ្មណ៍ ពីព្រោះតថាគត ប្រកាន់និយាយហាមឃាត់ថា មិនត្រូវអ្នកណាមួយ ធ្វើកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតឡើយ តែងនិយាយហាមឃាត់ថា មិនត្រូវអ្នកណាមួយ ធ្វើនូវធម៌ទាំងឡាយ ជាអកុសលអាក្រក់ច្រើនប្រការនោះឡើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអកិរិយវាទនោះ គឺជាសម្តីត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកនិយាយសំដៅនោះទេ ។

ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាឧច្ឆេទវាទទេតើ ។ ព្រះសាស្តាទ្រង់ត្រាស់តបថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាឧច្ឆេទវាទ ដែលគេថា នោះត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះតថាគត ប្រកាន់និយាយថា ឲ្យសត្វកាត់ផ្តាច់ផ្តិលនូវរាគៈ ទោសៈ មោហៈ តថាគតតែងនិយាយថា ឲ្យសត្វកាត់ផ្តាច់ផ្តិលនូវធម៌ទាំងឡាយ ជាអកុសលអាក្រក់ច្រើនយ៉ាងនេះចេញ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាឧច្ឆេទវាទនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុដែលអ្នកនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអ្នកខ្ពើមរអើម (ណាស់) ទេតើ ។

អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ជេគុច្ឆី សមណោ គោតមោតិ អហញ្ហិ ព្រាហ្មណ ជេគុច្ឆំ វទាមិ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ជេគុច្ឆំ វទាមិ អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ជេគុច្ឆី សមណោ គោតមោតិ នោ ច ខោ យំ ត្វំ សន្ធាយ វទេសីតិ ។ វេនយិកោ ភវំ គោតមោតិ ។ អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ វេនយិកោ សមណោ គោតមោតិ អហញ្ហិ ព្រាហ្មណ វិនយាយ ធម្មំ ទេសេមិ រាគស្ស ទោសស្ស មោហស្ស អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ វិនយាយ ធម្មំ ទេសេមិ អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ វេនយិកោ សមណោ គោតមោតិ នោ ច ខោ យំ ត្វំ សន្ធាយ វទេសីតិ ។

ព្រះសម្ពុទ្ធទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកខ្ពើមរអើម ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះតថាគត តែងនិយាយថា គួរខ្ពើមរអើមសេចក្ដីប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត តថាគតតែងនិយាយថា គួរខ្ពើមរអើមសេចក្ដីប្រកបចិត្ត ផ្ដេកផ្ដិតទៅរកអកុសលធម៌ទាំង-ឡាយដ៏អាក្រក់ច្រើនប្រការ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកខ្ពើមរអើមនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្ដែមិនមែនត្រូវត្រង់ហេតុដែលអ្នកនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអ្នកបំផ្លាញទេតើ ។ ព្រះលោកនាថជាម្ចាស់ទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនងគួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកបំផ្លាញ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះតថាគតសម្ដែងធម៌ចំពោះផ្លូវប្រតិបត្តិ ដែលបំផ្លាញបង់នូវ រាគៈ ទោសៈ មោហៈ តថាគតសម្ដែងធម៌ចំពោះផ្លូវប្រតិបត្តិ ដែលរំលាងបង់នូវអកុសលធម៌ទាំងឡាយដ៏អាក្រក់ច្រើនប្រការ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកបំផ្លាញនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្ដែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកនិយាយសំដៅនោះទេ ។

តបស្សី ករំ គោតមោតិ ។ អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ តបស្សី សមណោ គោតមោតិ តបនីយាហំ ព្រាហ្មណ ចាបកេ អកុសលេ ធម្មេ វទាមិ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោ-ទុច្ចរិតំ យស្ស ខោ ព្រាហ្មណ តបនីយា ចាបកា អកុសលា ធម្មា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំកតា អាយតឹ អនុប្បាទ-ធម្មា តមហំ តបស្សីតិ វទាមិ តថាគតស្ស ខោ ព្រាហ្មណ តបនីយា ចាបកា អកុសលា ធម្មា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំកតា អាយតឹ អនុប្បាទធម្មា អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ តបស្សី សមណោ គោតមោតិ

ព្រាហ្មណ៍ពោលថា ព្រះគោតមដ៏ចម្រើន ជាអ្នកដុតកម្ដៅទេតើ ។ ព្រះសព្វញ្ញូទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង គួរឲ្យអ្នកផងគេថា ព្រះសមណគោតម ជាអ្នកដុតកម្ដៅ ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះតថាគតប្រកាន់និយាយថា ការប្រព្រឹត្តអាក្រក់ដោយកាយ វាចា ចិត្ត ជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ ជាអកុសលធម៌ដ៏អាក្រក់ អកុសលធម៌ទាំងឡាយដ៏អាក្រក់ ដែលជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ (នោះ) បើអ្នកណាបានលះបង់ស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោត ដែលគេគាស់រំលើង ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ តថាគតហៅអ្នកនោះថា អ្នកដុតកម្ដៅ ម្នាលព្រាហ្មណ៍ អកុសលធម៌ទាំងឡាយដ៏អាក្រក់ ជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ តថាគតបានលះបង់ស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោត ដែលគេគាស់រំលើងឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផងគេថា ព្រះសមណគោតម ជាអ្នកដុតកម្ដៅនោះ គឺត្រូវត្រង់ហេតុនេះឯង

នោ ច ខោ យំ ត្វំ សន្ធាយ វទេសីតិ ។ អបគព្ភោ ភវំ គោតមោតិ ។ អត្ថិ ខ្វេស ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អបគព្ភោ សមណោ គោតមោតិ យស្ស ខោ ព្រាហ្មណ អាយតឹ គព្ភសេយ្យា បុនព្ភវាភិនិព្វត្តិ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំកតា អាយតឹ អនុប្បាទធម្មា តមហំ អបគព្ភោតិ វទាមិ តថាគតស្ស ខោ ព្រាហ្មណ អាយតឹ គព្ភសេយ្យា បុនព្ភវាភិនិព្វត្តិ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំកតា អាយតឹ អនុប្បាទធម្មា អយំ ខោ ព្រាហ្មណ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អបគព្ភោ សមណោ គោតមោតិ នោ ច ខោ យំ ត្វំ សន្ធាយ វទេសិ ។

ប៉ុន្តែមិនមែនត្រូវត្រង់ហេតុដែលអ្នកនិយាយសំដៅនោះទេ ។ ព្រាហ្មណ៍ពោលថាព្រះគោតមដ៏ចម្រើន ជាមនុស្សឥតកំណើតទេតើ ។ ព្រះដ៏មានជោគទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ពិតមែន មានហេតុជាទំនង់គួរឲ្យអ្នកផង់គេថា ព្រះសមណគោតម ជាមនុស្សឥតកំណើត ដែលគេថានោះត្រូវហើយ ម្នាលព្រាហ្មណ៍ ពីព្រោះកិរិយាដេក ក្នុងគភ៌តទៅទៀត ដំណើរកើត ក្នុងភពតទៅទៀត បើអ្នកណាបានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចដើមត្នោតដែលគេគាស់រំលើង់ឲ្យលែងដុះតទៅទៀតហើយ ធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅទៀតហើយ តថាគតហៅអ្នកនោះថា អ្នកឥតកំណើត ម្នាលព្រាហ្មណ៍ កិរិយាដេកក្នុងគភ៌តទៅទៀត ដំណើរកើត ក្នុងភពតទៅមុខទៀត តថាគតបានលះបង់ស្រឡះហើយ បានផ្តាច់ផ្តិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើតដូចជាដើមត្នោតដែលគេគាស់រំលើង់ ឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតទៅខាងមុខទៀតហើយ ម្នាលព្រាហ្មណ៍ ដែលអ្នកផង់គេថា ព្រះសមណគោតម ជាមនុស្សឥតកំណើតនោះ គឺត្រូវត្រង់ហេតុនេះឯង ប៉ុន្តែមិនមែនត្រូវត្រង់ហេតុ ដែលអ្នកនិយាយសំដៅនេះទេ ។

សេយ្យថាបិ ព្រាហ្មណ កុក្កុដិយា អណ្ឌានិ អដ្ឋ វា ទស វា ទ្វាទស វា តានស្សុ កុក្កុដិយា សម្មាអធិសយិតានិ សម្មាបរិសេទិតានិ សម្មាបរិភាវិតានិ យោ នុ ខោ តេសំ កុក្កុដច្ឆាបកានំ បឋមតរំ ចាទនខសិខាយ វា មុខតុណ្ឌកេន វា អណ្ឌកោសំ បទាលេត្វា សោត្ថិនា អភិនិព្ភិជ្ជេយ្យ កិន្តិ ស្វាស្ស វចនីយោ ជេដ្ឋោ វា កនិដ្ឋោ វាតិ ។ ជេដ្ឋោតិស្ស ភោ គោតម វចនីយោ សោ ហិ នេសំ ភោ គោតម ជេដ្ឋោ ហោតីតិ ។ ឯវមេវ ខោ អហំ ព្រាហ្មណ អវិជ្ជាគតាយ បជាយ អណ្ឌភូតាយ បរិយោនទ្ធាយ អវិជ្ជណ្ឌកោសំ បទាលេត្វា ឯកោវ លោកេ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ អហញ្ហិ ព្រាហ្មណ ជេដ្ឋោ សេដ្ឋោ លោកស្ស អារទ្ធំ ខោ បន មេ ព្រាហ្មណ វីរិយំ អហោសិ អសល្លីនំ ឧបដ្ឋិតា សតិ អប្បមុដ្ឋា បស្សទ្ធោ កាយោ អសារទ្ធោ

ម្នាលព្រាហ្មណ៍ ដូចជាស៊ុតមាន់ទាំងឡាយ ៨ ក្តី ១០ ក្តី ១២ ក្តី ស៊ុតមាន់ទាំងនោះ គឺមេមាន់ក្រាប ដោយប្រពៃហើយ ធ្វើឲ្យកក់ក្តៅ ដោយប្រពៃហើយ ឲ្យចាប់ក្លិនមេ ដោយប្រពៃហើយ (លុះដល់វេលាញាស់) ក៏បណ្តាកូនមាន់ទាំងនោះ កូនមាន់ណា ទម្លាយសម្បកស៊ុត ដោយចុងក្រចកជើង ឬ ដោយចុងចំពុះ ហើយញាស់ចេញមកដោយស្រួលមុនគេបំផុត បើដូច្នេះ តើអ្នកផងគួរហៅកូនមាន់នោះថា កូនច្បង ឬ កូនពៅហ្ន៎ ។ ព្រាហ្មណ៍ក្រាបទូលថា បពិត្រព្រះគោតមដ៏ចម្រើន (កូនមាន់នោះ) គេគួរហៅថា កូនច្បង បពិត្រព្រះគោតមដ៏ចម្រើន ពីព្រោះវាជាបងគេបំផុត ។ ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ កាលបើពពួកសត្វ ដូចជាស៊ុត (មាន់) មានអវិជ្ជាគឺសេចក្តីល្ងង់ ដូចជាសម្បកស៊ុតកំពុងរួបរឹតក្នុងលោក មានតែតថាគតម្នាក់ឯង ដែលទម្លាយសម្បកស៊ុតគឺសេចក្តីល្ងង់ហើយត្រាស់ដឹងខ្លួនឯងដោយប្រពៃ នូវសម្មាសម្ពោធិញ្ញាណ ដែលមិនមានគុណជាតឯទៀតប្រសើរជាងឡើយ ម្នាលព្រាហ្មណ៍ តថាគតឯង ជាចម្បង ជាបុគ្គលប្រសើរបំផុតជាងសត្វលោក ម្នាលព្រាហ្មណ៍ ព្យាយាមតថាគតបានតាំងផ្តើមហើយ មិនបន្ធូរបន្ថយឡើយ ទាំងស្មារតីតថាគតក៏ប្រុងមិនឲ្យមានភ្លាត់ កាយសោត ក៏ស្ងប់រម្ងាប់ មិនក្រវល់ក្រវាយ

សមាហិតំ ចិត្តំ ឯកគ្គំ សោ ខោ អហំ ព្រាហ្មណ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ចេតសោ ឧបសម្បជ្ជ វិហាសឹ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហាសឹ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហាសឹ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេសឹ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយជ្ឈានំ ឧបសម្បជ្ជ វិហាសឹ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោម-នស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិចារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហាសឹ សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិ-លេសេ មុទុភូតេ កម្មនិយេ ឋិតេ អានេញ្ជប្បត្តេ

ចិត្តក៏នឹងល្អ ជាចិត្តមានអារម្មណ៍តែមួយ ម្នាលព្រាហ្មណ៍ តថាគត នោះ លុះស្ងាត់ចាកកាមទាំងឡាយ ស្ងាត់ចាកធម៌ទាំងឡាយ ជាអកុសលហើយក៏ចូលបឋមជ្ឈាន ដែលប្រកបដោយវិតក្កវិចារៈ មានបីតិនិងសុខ ដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ព្រោះរម្ងាប់វិតក្កវិចារៈ តថាគតបានចូលដល់ទុតិយជ្ឈាន ជាធម្មជាត កើតមានក្នុងសន្តាន ចិត្តប្រកបដោយសេចក្តីជ្រះថ្លា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខ កើតអំពីសមាធិ ព្រោះលះបង់បីតិចេញហើយ តថាគត ជាបុគ្គលព្រងើយផង មានសតិសម្បជញ្ញៈផង សោយសុខដោយនាមកាយផង ព្រះអរិយៈទាំងឡាយ តែងសរសើរនូវបុគ្គលដែលបាននូវតតិយជ្ឈាននោះថា បុគ្គលអ្នកបានតតិយជ្ឈាន មានចិត្តព្រងើយ មានស្មារតី មានប្រក្រតីនៅជាសុខ ព្រោះតតិយជ្ឈានណា តថាគត ក៏បានដល់នូវតតិយជ្ឈាននោះ ព្រោះលះបង់នូវសេចក្តីសុខផង ព្រោះលះបង់នូវសេចក្តីទុក្ខផង ព្រោះរំលត់នូវសោមនស្សនិងទោមនស្សអំពីមុនផង តថាគតបានចូលដល់ចតុត្ថជ្ឈាន ដែលឥតទុក្ខឥតសុខ មានសតិដ៏ស្អាត ប្រាកដចំពោះត្រង់ឧបេក្ខា កាលដែលចិត្តខ្ជាប់ខ្ជួន បរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មងជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រយ៉ាងនេះហើយ

បុព្វេនិវាសានុស្សតិញ្ញាណាយ ចិត្តំ អភិនិន្នាមេសឹ សោ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ តិស្សោបិ ជាតិយោ ចតស្សោបិ ជាតិយោ បញ្ចបិ ជាតិយោ ទសបិ ជាតិយោ វីសម្បិ ជាតិយោ តឹសម្បិ ជាតិយោ ចត្តាឡីសម្បិ ជាតិយោ បញ្ញាសម្បិ ជាតិយោ ជាតិសតម្បិ ជាតិ-សហស្សម្បិ ជាតិសតសហស្សម្បិ អនេកេបិ សំវដ្ដ-កប្បេ អនេកេបិ វិវដ្ដកប្បេ អនេកេបិ សំវដ្ដវិវដ្ដ-កប្បេ អមុត្រាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ អមុត្រ ឧទបាទឹ តត្រាបាសឹ ឯវំនាមោ ឯវំគោត្តោ ឯវំវណ្ណោ ឯវមាហារោ ឯវំសុខទុក្ខប្បដិសំវេទី ឯវមាយុបរិយន្តោ សោ តតោ ចុតោ ឥធូបបន្នោតិ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរាមិ ។ អយំ ខោ មេ ព្រាហ្មណ រត្តិយា បឋមេ យាមេ បឋមា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ

តថាគតក៏បានបង្អោនចិត្តចូលទៅក្នុងបុព្វេនិវាសានុស្សតិញ្ញាណ តថាគតក៏រលឹកជាតិ ដែលបានអាស្រ័យនៅអំពីមុខ ជាអនេកជាតិ គឺរលឹកបាន ១ ជាតិ ២ ជាតិ ៣ ជាតិ ៤ ជាតិ ៥ ជាតិ ១០ ជាតិ ២០ ជាតិ ៣០ ជាតិ ៤០ ជាតិ ៥០ ជាតិ ១០០ ជាតិ ១ ពាន់ជាតិ ១ សែនជាតិក៏បាន រលឹកបានច្រើនសំវដ្តកប្ប ច្រើនវិវដ្តកប្ប ច្រើនសំវដ្តវិវដ្តកប្បក៏បាន ដូច្នេះថា តថាគតបានកើតក្នុងភពឯណោះ មានឈ្មោះយ៉ាងនេះ មានគោត្តយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ តថាគតច្យុតចាកអត្តភាពនោះហើយ បានទៅកើតក្នុងភពឯណោះ ដែលទៅកើតក្នុងភពនោះ តថាគត មានឈ្មោះយ៉ាងនេះ មានគោត្តយ៉ាងនេះ មានសម្បុរយ៉ាងនេះ មានអាហារយ៉ាងនេះ បានសោយសុខទុក្ខយ៉ាងនេះ មានកំណត់អាយុប៉ុណ្ណេះ តថាគតច្យុតចាកអត្តភាពនោះហើយ មកកើតក្នុងភពនេះ ។ តថាគតរលឹកតាមនូវជាតិ ដែលអាស្រ័យនៅពីមុនបានច្រើនជាតិ ព្រមទាំងអាការព្រមទាំងឧទ្ទេសយ៉ាងនេះ ។ ម្នាលព្រាហ្មណ៍ បឋម-វិជ្ជានេះហើយ ដែលតថាគតបានក្នុងយាមជាដំបូងនៃរាត្រី អវិជ្ជាខ្ចាត់បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើង ដល់តថាគត

យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហ-
រតោ ។ អយំ ខោ មេ ព្រាហ្មណ បឋមា អភិនិព្ភិទា
អហោសិ កុក្កុដច្ឆាបកស្សេវ អណ្ឌកោសម្ហា ។
សោ ឯវំ សមាហិតេ ចិត្តេ បរិសុទ្ធេ បរិយោទាតេ
អនង្គណេ វិគតូបក្កិលេសេ មុទុភូតេ កម្មនិយេ ឋិតេ
អានេញ្ជប្បត្តេ សត្តានំ ចុតូបបាតញាណាយ ចិត្តំ
អភិនិន្នាមេសឹ ។ សោ ទិព្វេន ចក្ខុនា វិសុទ្ធេន
អតិក្កន្តមានុសកេន សត្តេ បស្សាមិ ចវមានេ ឧប-
បជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ
ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាមិ ឥមេ វត
ភោន្តោ សត្តា កាយទុច្ចរិតេន សមន្នាគតា វចីទុច្ចរិតេន
សមន្នាគតា មនោទុច្ចរិតេន សមន្នាគតា អរិយានំ
ឧបវាទកា មិច្ឆាទិដ្ឋិកា មិច្ឆាទិដ្ឋិកម្មសមាទានា តេ
កាយស្ស ភេទា បរម្មរណា ទុគ្គតឹ វិនិបាតំ
និរយំ ឧបបន្នា ឥមេ វា បន ភោន្តោ សត្តា

ដូចជាបុគ្គលដែលមិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តបញ្ជូនទៅ ។ ម្នាលព្រាហ្មណ៍ នេះឯងជាការញាស់ចេញជាដំបូងរបស់តថាគត ដូចជាកូនមាន់ញាស់ចេញចាកសម្បកស៊ុត ។ កាលដែលចិត្តខ្ជាប់ខ្ជួនបរិសុទ្ធផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មង ជាចិត្តទន់សមគួរដល់កម្ម ជាចិត្តនឹងធឹងមិនញាប់ញ័រយ៉ាងនេះហើយ តថាគតទើបបង្អោនចិត្ត ដើម្បីដឹងនូវចុតិនិងបដិសន្ធិនៃសត្វទាំងឡាយ (ចុតូ-បបាតញ្ញាណ) ។ តថាគតពិចារណាមើលនូវសត្វទាំងឡាយ ដែលច្យុតនិងចាប់បដិសន្ធិ ថោកទាបនិងឧត្តម មានសណ្ឋានល្អនិងអាក្រក់ទៅកាន់សុគតិនិងទុគ្គតិ ដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធ ក្រៃលែងជាងចក្ខុរបស់មនុស្សសាមញ្ញ ក៏ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្មថា អើហ្ន៎! សត្វទាំងឡាយអម្បាលនេះ ប្រកបដោយកិរិយាប្រព្រឹត្តអាក្រក់ដោយកាយ ដោយវាចា ដោយចិត្ត និយាយតិះដៀលអរិយបុគ្គលទាំងឡាយ ជាមិច្ឆាទិដ្ឋិ ប្រកាន់មាំនូវកម្មជាមិច្ឆាទិដ្ឋិ សត្វទាំងនោះ លុះរំលាយខន្ធ បន្ទាប់អំពីមរណៈ ក៏ទៅកើតឯអបាយ ទុគ្គតិ វិនិបាត នរក មួយសោត ឱហ្ន៎! សត្វទាំងឡាយនេះ

កាយសុចរិតេន សមន្នាគតា វចីសុចរិតេន សមន្នា-
គតា មនោសុចរិតេន សមន្នាគតា អរិយានំ អនុប-
វាទកា សម្មាទិដ្ឋិកា សម្មាទិដ្ឋិកម្មសមាទានា តេ
កាយស្ស ភេទា បរម្មរណា សុគតឹ សគ្គំ លោកំ
ឧបបន្នាតិ ។ ឥតិ ទិព្វេន ចក្ខុនា វិសុទ្ធេន
អតិក្កន្តមានុសកេន សត្តេ បស្សាមិ ចវមានេ
ឧបបជ្ជមានេ ហីនេ បណីតេ សុវណ្ណេ ទុព្វណ្ណេ សុគតេ
ទុគ្គតេ យថាកម្មូបគេ សត្តេ បជានាមិ ។ អយំ
ខោ មេ ព្រាហ្មណ រត្តិយា មជ្ឈិមេ យាមេ ទុតិយា
វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ
វិហតោ អាលោកោ ឧប្បន្នោ យថាតំ អប្បមត្តស្ស
អាតាបិនោ បហិតត្តស្ស វិហរតោ ។ អយំ ខោ មេ
ព្រាហ្មណ ទុតិយា អភិនិព្ភិទា អហោសិ កុក្កុដច្ឆា-
បកស្សេវ អណ្ឌកោសម្ហា ។ សោ ឯវំ សមាហិតេ
ចិត្តេ បរិសុទ្ធេ បរិយោទាតេ អនង្គណេ វិគតូបក្កិ-
លេសេ មុទុភូតេ កម្មនីយេ ឋិតេ អានេញ្ជប្បត្តេ

ប្រកបដោយកិរិយាប្រព្រឹត្តល្អដោយកាយ ដោយវាចា ដោយចិត្ត មិនតិះដៀលអរិយបុគ្គលទាំងឡាយ ជាសម្មាទិដ្ឋិ ប្រកាន់មាំនូវកម្មជាសម្មាទិដ្ឋិ សត្វទាំងនោះលុះរំលាងខន្ធបន្ទាប់ពីមរណៈ ក៏ទៅកើតឯឋានសុគតិសួគ៌ទេវលោក ។ តថាគតពិចារណាមើលសត្វទាំងឡាយ ដែលច្យុតនិងចាប់បដិសន្ធិ ថោកទាបនិងឧត្តម មានសណ្ឋានល្អនិងអាក្រក់ ទៅកាន់សុគតិនិងទុគ្គតិដោយចក្ខុដូចជាទិព្វ ដ៏បរិសុទ្ធក្រៃលែងជាងចក្ខុរបស់មនុស្សសាមញ្ញ ក៏ដឹងច្បាស់នូវសត្វទាំងឡាយ ដែលអន្ទោលទៅតាមកម្ម ដោយប្រការដូច្នេះ ។ ម្នាលព្រាហ្មណ៍ វិជ្ជាទី ២ នេះហើយ ដែលតថាគតបានក្នុងយាមជាកណ្តាលនៃរាត្រី អវិជ្ជាខ្ចាត់បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺក៏កើតឡើងដល់តថាគត ដូចជាបុគ្គលមិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តបញ្ជូនទៅ ។ ម្នាលព្រាហ្មណ៍ នេះឯងជាការញាស់ចេញ ជាគម្រប់ ២ របស់តថាគត ដូចជាកូនមាន់ដែលញាស់ចេញចាកសម្បកស៊ុត ។ កាលដែលចិត្តខ្ជាប់ខ្ជួនបរិសុទ្ធ ផូរផង់ មិនមានកិលេស ប្រាសចាកសេចក្តីសៅហ្មងជាចិត្តទន់ សមគួរដល់កម្ម ជាចិត្តនឹងធឹង មិនញាប់ញ័រយ៉ាងនេះហើយ

៨៣



អាសវានំ ខយញាណាយ ចិត្តំ អភិនិន្នាមេសឹ ។ សោ ឥទំ ទុក្ខន្តិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខសមុទយោតិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខនិរោធោតិ យថាភូតំ អព្ភញ្ញាសឹ អយំ ទុក្ខនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសឹ ឥមេ អាសវាតិ យថាភូតំ អព្ភញ្ញាសឹ អយំ អាសវសមុទយោតិ យថាភូតំ អព្ភញ្ញាសឹ អយំ អាសវនិរោធោតិ យថាភូតំ អព្ភញ្ញាសឹ អយំ អាសវនិរោធគាមិនី បដិបទាតិ យថាភូតំ អព្ភញ្ញាសឹ តស្ស មេ ឯវំ ជានតោ ឯវំ បស្សតោ កាមាសវាបិ ចិត្តំ វិមុច្ចិត្ថ ភវាសវាបិ ចិត្តំ វិមុច្ចិត្ថ អវិជ្ជាសវាបិ ចិត្តំ វិមុច្ចិត្ថ វិមុត្តស្មឹ វិមុត្តមិតិ ញាណំ អហោសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសឹ ។ អយំ ខោ មេ ព្រាហ្មណ រត្តិយា បច្ឆិមេ យាមេ តតិយា វិជ្ជា អធិគតា អវិជ្ជា វិហតា វិជ្ជា ឧប្បន្នា តមោ វិហតោ អាលោកោ ឧប្បន្នោ

តថាគតទើបបង្អោនចិត្តទៅ ដើម្បីដឹងនូវធម៌ជាគ្រឿងអស់ទៅនៃអាសវៈទាំងឡាយ (អាសវក្ខយញ្ញាណ) ។ តថាគតដឹងប្រាកដតាមពិតថា នេះជាទុក្ខ ដឹងប្រាកដតាមពិតថា នេះជាហេតុនាំឲ្យកើតទុក្ខ ដឹងប្រាកដតាមពិតថា នេះជាសេចក្តីរំលត់ទុក្ខ ដឹងប្រាកដតាមពិតថា នេះជាឧបាយឲ្យបានដល់នូវសេចក្តីរលត់ទុក្ខ ដឹងប្រាកដតាមពិតថា ធម៌ប៉ុណ្ណេះជាអាសវៈ ដឹងប្រាកដតាមពិតថា ធម៌នេះជាហេតុនាំឲ្យកើតអាសវៈ ដឹងប្រាកដតាមពិតថា នេះជាសេចក្តីរលត់នៃអាសវៈ ដឹងប្រាកដតាមពិតថា នេះជាឧបាយឲ្យបានដល់នូវសេចក្តីរលត់នៃអាសវៈ កាលដែលតថាគតដឹងយ៉ាងនេះ ឃើញយ៉ាងនេះ ចិត្តនៃតថាគតក៏ផុតចាកគ្រឿងត្រាំគឺកាមផង គឺភពផង គឺអវិជ្ជាផង កាលបើចិត្តនៃតថាគតបានរួចផុតស្រឡះហើយ សេចក្តីដឹងថាចិត្តផុតស្រឡះ ក៏កើតប្រាកដឡើង តថាគតដឹងច្បាស់ថាកំណើតរបស់អញអស់ហើយ ព្រហ្មចរិយធម៌ អញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ចអញក៏បានធ្វើស្រេចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅដើម្បីសោឡសកិច្ចនេះទៀតមិនមានឡើយ ។ ម្នាលព្រាហ្មណ៍ វិជ្ជាទី ៣ នេះហើយ ដែលតថាគតបានក្នុងយាមជាទីបំផុតនៃរាត្រី អវិជ្ជាខ្ចាត់បាត់ទៅ វិជ្ជាក៏កើតឡើង ងងឹតខ្ចាត់បាត់ទៅ ពន្លឺកើតឡើង ដល់តថាគត

យថាតំ អប្បមត្តស្ស អាតាបិនោ បហិតត្តស្ស វិហារតោ ។ អយំ ខោ មេ ព្រាហ្មណ តតិយា អភិនិព្ភិទា អហោសិ កុក្កុដច្ឆាបកស្សេវ អណ្ឌកោសម្ហាតិ ។ ឯវំ វុត្តេ វេរញ្ជោ ព្រាហ្មណោ ភគវន្តំ ឯតទវោច ជេដ្ឋោ ភវំ គោតមោ សេដ្ឋោ ភវំ គោតមោ អភិក្កន្តំ ភោ គោតម អភិក្កន្តំ ភោ គោតម សេយ្យថាបិ ភោ គោតម និក្កុជ្ជិតំ វា ឧក្កុជ្ជេយ្យ បដិច្ឆន្នំ វា វិវរេយ្យ មូឡ្ហស្ស វា មគ្គំ អាចិក្ខេយ្យ អន្ធការេ វា តេលប្បជ្ជោតំ ធារេយ្យ ចក្ខុមន្តោ រូបានិ ទក្ខន្តីតិ ឯវមេវ ភោតា គោតមេន អនេកបរិយាយេន ធម្មោ បកាសិតោ ឯសាហំ ភវន្តំ គោតមំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភវំ គោតមោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

ដូចជាបុគ្គល មិនប្រហែសធ្វេស ខំប្រឹងដុតបំផ្លាញកិលេស មានចិត្តបញ្ជូនទៅ ។ ម្នាលព្រាហ្មណ៍ នេះឯងជាការញាស់ជាគម្រប់ ៣ របស់តថាគត ដូចគ្នានឹងការញាស់ចេញរបស់កូនមាន់អំពីសម្បកស៊ុត ។ កាលបើព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វេរញ្ជព្រាហ្មណ៍ បានក្រាបទូលព្រះដ៏មានព្រះភាគវិញថា ព្រះគោតមដ៏ចម្រើន ព្រះអង្គជាចម្បងជាងមនុស្ស ព្រះគោតមដ៏ចម្រើន ព្រះអង្គប្រសើរបំផុតជាងមនុស្ស បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះគោតមដ៏ចម្រើន ធម៌ដែលព្រះគោតមដ៏ចម្រើនសម្តែងហើយដោយអនេកបរិយាយយ៉ាងនេះ (ភ្លឺច្បាស់ណាស់) គួរនាដូចជាមនុស្សចាប់របស់ដែលគេផ្កាប់ចុះ ឲ្យផ្ងារឡើង ពុំនោះដូចមនុស្សបើកបង្ហាញរបស់ដែលគេលាក់បិទបាំង ពុំនោះសោត ដូចជាមនុស្សប្រាប់ផ្លូវដល់អ្នកវង្វេងទិស ឬក៏ដូចជាមនុស្សកាន់ប្រទីបទ្រោលបំភ្លឺក្នុងទីងងឹត ដោយគិតថាមនុស្សអ្នកមានភ្នែក នឹងឃើញនូវរូបទាំងឡាយបាន ខ្ញុំព្រះអង្គនុំះសូមដល់នូវព្រះគោតមដ៏ចម្រើនផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក ចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះគោតមដ៏ចម្រើន ជ្រាបនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់សរណៈស្មើដោយជីវិត ។

[១២] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តេន ខោ បន សមយេន សម្ពហុលា អភិញ្ញាតា អភិញ្ញាតា លិច្ឆវី សន្ថាគារេ សន្និសិន្នា សន្និបតិតា អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសន្តិ ធម្មស្ស វណ្ណំ ភាសន្តិ សង្ឃស្ស វណ្ណំ ភាសន្តិ ។ តេន ខោ បន សមយេន សីហោ សេនាបតិ និគណ្ឋសាវកោ តស្សំ បរិសាយំ និសិន្នោ ហោតិ ។ អថខោ សីហស្ស សេនាបតិស្ស ឯតទហោសិ និស្សំសយំ ខោ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ភវិស្សតិ តថា ហិមេ សម្ពហុលា អភិញ្ញាតា អភិញ្ញាតា លិច្ឆវី សន្ថាគារេ សន្និសិន្នា សន្និបតិតា អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសន្តិ ធម្មស្ស វណ្ណំ ភាសន្តិ សង្ឃស្ស វណ្ណំ ភាសន្តិ យន្នូនាហំ តំ ភគវន្តំ ទស្សនាយ ឧបសង្កមេយ្យំ អរហន្តំ សម្មាសម្ពុទ្ធន្តិ ។ អថខោ សីហោ សេនាបតិ យេន និគណ្ឋោ នាដបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា និគណ្ឋំ នាដបុត្តំ ឯតទវោច

បណ្ណាសក មហាវគ្គ

[១២] *សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងកូដាគារសាលា នាមហាវ័ន ជិតក្រុងវេសាលី ។ សម័យនោះឯង ពួកលិច្ឆវីជនច្រើននាក់ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ អង្គុយប្រជុំគ្នាក្នុងសណ្ឋាគារសាលា ពោលសរសើរគុណព្រះពុទ្ធ សរសើរគុណព្រះធម៌ សរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយ ។ ជួនសម័យនោះឯង សីហសេនាបតី ជាសាវ័ករបស់និគន្ថនាដបុត្រ អង្គុយក្នុងបរិសទ្យនោះដែរ ។ គ្រានោះ សីហសេនាបតី មានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគអង្គនោះជាក់ជាអរហន្តសម្មាសម្ពុទ្ធប្រាកដ បានជាពួកលិច្ឆវីជនច្រើននាក់ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញទាំងនោះ អង្គុយប្រជុំគ្នាក្នុងសណ្ឋាគារសាលា ពោលសរសើរគុណព្រះពុទ្ធ សរសើរគុណព្រះធម៌ សរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយ បើដូច្នោះ គួរតែអញចូលទៅ ដើម្បីជួបនឹងព្រះដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។ លំដាប់នោះ សីហសេនាបតី ចូលទៅឯលំនៅនិគន្ថនាដបុត្រ លុះចូលទៅដល់ហើយ បានស្នើសេចក្តីនេះនឹងនិគន្ថនាដបុត្រថា*

ឥច្ឆាមហំ ភន្តេ សមណំ គោតមំ ទស្សនាយ ឧប-
សង្កមិតុន្តិ ។ កឹ បន ត្វំ សីហ កិរិយវាទោ សមានោ
អកិរិយវាទំ សមណំ គោតមំ ទស្សនាយ ឧបសង្កមិ-
ស្សសិ សមណោ ហិ សីហ គោតមោ អកិរិយវាទោ
សមានោ អកិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ
វិនេតីតិ ។ អថខោ សីហស្ស សេនាបតិស្ស យោ អហោសិ
គមិយាភិសង្ខារោ ភគវន្តំ ទស្សនាយ សោ បដិប្បស្សម្ភិ ។
ទុតិយម្បិ ខោ សម្ពហុលា អភិញ្ញាតា អភិញ្ញាតា លិច្ឆវី
សន្ធាគារេ សន្និសិន្នា សន្និបតិតា អនេកបរិយាយេន
ពុទ្ធស្ស វណ្ណំ ភាសន្តិ ធម្មស្ស វណ្ណំ ភាសន្តិ សង្ឃស្ស
វណ្ណំ ភាសន្តិ ។ ទុតិយម្បិ ខោ សីហស្ស សេនាបតិស្ស
ឯតទហោសិ និស្សំសយំ ខោ សោ ភគវា អរហំ សម្មា-
សម្ពុទ្ធោ ភវិស្សតិ តថា ហិមេ សម្ពហុលា អភិញ្ញាតា
អភិញ្ញាតា លិច្ឆវី សន្ធាគារេ សន្និសិន្នា សន្និបតិតា
អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសន្តិ ធម្មស្ស វណ្ណំ
ភាសន្តិ សង្ឃស្ស វណ្ណំ ភាសន្តិ យន្នូនាហំ តំ ភគវន្តំ
ទស្សនាយ ឧបសង្កមេយ្យំ អរហន្តំ សម្មាសម្ពុទ្ធន្តិ ។

បពិត្រលោកដ៏ចម្រើន ខ្ញុំចង់ចូលទៅដើម្បីជួបនឹងព្រះសមណគោតម ។ និគន្ថនាដបុត្រតបថា ម្នាលសីហៈ អ្នកឯង ជាកិរិយវាទ នឹងចូលទៅជួបព្រះសមណគោតម ជាអកិរិយវាទដូចម្តេចកើត ម្នាលសីហៈ ព្រោះថា សមណគោតម ជាអកិរិយវាទតែងសម្តែងធម៌ ដើម្បីឃាត់កិច្ចការថាមិនត្រូវធ្វើ ទាំងទូន្មានពួកសាវ័កដោយធម៌នោះដែរ ។ លំដាប់នោះ ការប្រុងប្រៀបដំណើរដើម្បីទៅជួបព្រះដ៏មានព្រះភាគ របស់សីហសេនាបតី ក៏ត្រឡប់ជាអាក់ខានទៅវិញ ។ ពួកលិច្ឆវីជនច្រើននាក់ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ អង្គុយប្រជុំគ្នាក្នុងសណ្ឋាគារសាលា ពោលសរសើរគុណព្រះពុទ្ធ សរសើរគុណព្រះធម៌ សរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយ ក្នុងលើកទី ២ ទៀត ។ សីហសេនាបតី មានសេចក្តីត្រិះរិះក្នុងលើកទី ២ ទៀតដូច្នេះថា ព្រះដ៏មានព្រះភាគអង្គនោះ ជាក់ជាព្រះអរហន្តសម្មាសម្ពុទ្ធប្រាកដ បានជាពួកលិច្ឆវីជនច្រើននាក់ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញទាំងនេះ អង្គុយប្រជុំគ្នាក្នុងសណ្ឋាគារសាលា ពោលសរសើរគុណព្រះពុទ្ធ សរសើរគុណព្រះធម៌ សរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយ បើដូច្នោះគួរតែអញចូលទៅ ដើម្បីជួបនឹងព្រះដ៏មានព្រះភាគ ជាព្រះអរហន្តសម្មាសម្ពុទ្ធអង្គនោះ ។

អថខោ សីហោ សេនាបតិ យេន និគណ្ឋោ នាដបុត្តោ តេនុបសង្កមិ ឧបសង្កមិត្វា និគណ្ឋំ នាដបុត្តំ ឯតទវោច ឥច្ឆាមហំ ភន្តេ សមណំ គោតមំ ទស្សនាយ ឧបសង្កមិតុន្តិ ។ កឹ បន ត្វំ សីហ កិរិយវាទោ សមានោ អកិរិយវាទំ សមណំ គោតមំ ទស្សនាយ ឧបសង្កមិស្សសិ សមណោ ហិ សីហ គោតមោ អកិរិយវាទោ អកិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ ទុតិយម្បិ ខោ សីហស្ស សេនាបតិស្ស យោ អហោសិ គមិយាភិសង្ខារោ ភគវន្តំ ទស្សនាយ សោ បដិប្បស្សម្ភិ ។ តតិយម្បិ ខោ សម្ពហុលា អភិញ្ញាតា អភិញ្ញាតា លិច្ឆវី សន្ថាគារេ សន្និសិន្នា សន្និបតិតា អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសន្តិ ធម្មស្ស វណ្ណំ ភាសន្តិ សង្ឃស្ស វណ្ណំ ភាសន្តិ ។ តតិយម្បិ ខោ សីហស្ស សេនាបតិស្ស ឯតទហោសិ

លំដាប់នោះ សីហសេនាបតី ក៏ចូលទៅឯលំនៅរបស់និគន្ថនាដបុត្រ លុះចូលទៅដល់ហើយ បានស្នើសេចក្តីនេះនឹងនិគន្ថនាដបុត្រថា បពិត្រលោកដ៏ចម្រើន ខ្ញុំចង់ចូលទៅដើម្បីជួបព្រះសមណគោតម ។ និគន្ថនាដបុត្រតបថា ម្នាលសីហៈ ចំណែកអ្នកឯង ជាកិរិយវាទ នឹងចូលទៅដើម្បីជួបព្រះសមណ-គោតម ជាអកិរិយវាទដូចម្តេចកើត ម្នាលសីហៈ ព្រោះថា សមណគោតម ជាអកិរិយវាទ តែងសម្តែងធម៌ដើម្បីឃាត់ថា កិច្ចការមិនត្រូវធ្វើ ទាំងទូន្មានពួកសាវ័កដោយធម៌នោះដែរ ។ ការប្រុងប្រៀបដំណើរដើម្បីទៅជួបព្រះដ៏មានព្រះភាគ របស់សីហសេនាបតី ក៏ត្រឡប់ជាអាក់ខានទៅវិញ ក្នុងលើកទី ២ ទៀត ។ ពួកលិច្ឆវីជនច្រើននាក់ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញ អង្គុយប្រជុំគ្នាក្នុងសណ្ឋាគារសាលា ពោលសរសើរគុណព្រះពុទ្ធ សរសើរគុណព្រះធម៌ សរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយ ក្នុងលើកទី ៣ ទៀត ។ សីហសេនាបតី មានសេចក្តីត្រិះរិះក្នុងលើកទី ៣ ដូច្នេះថា

និស្សំសយំ ខោ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ភវិស្សតិ តថា ហិមេ សម្ពហុលា អភិញ្ញាតា អភិញ្ញាតា លិច្ឆវី សន្ថាគារេ សន្និសិន្នា សន្និបតិតា អនេកបរិយាយេន ពុទ្ធស្ស វណ្ណំ ភាសន្តិ ធម្មស្ស វណ្ណំ ភាសន្តិ សង្ឃស្ស វណ្ណំ ភាសន្តិ កឹ ហិមេ ករិស្សន្តិ និគណ្ឋា អបលោកិតា វា អនបលោកិតា វា យន្នូនាហំ អនបលោកេត្វាវ និគណ្ឋេ តំ ភគវន្តំ ទស្សនាយ ឧបសង្កមេយ្យំ អរហន្តំ សម្មាសម្ពុទ្ធន្តិ ។ អថខោ សីហោ សេនាបតិ បញ្ច-មត្តេហិ រថសតេហិ ទិវា ទិវស្ស វេសាលិយា និយ្យាសិ ភគវន្តំ ទស្សនាយ យាវតិកា យានស្ស ភូមិ យានេន គន្ត្វា យានា បច្ចោរោហិត្វា បត្តិកោ វ អារាមំ ចាវិសិ ។ អថខោ សីហោ សេនាបតិ យេន ភគវា តេនុប-សង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សីហោ សេនាបតិ ភគវន្តំ ឯតទវោច សុតមេតំ ភន្តេ អកិរិយវាទោ សមណោ គោតមោ អកិរិយាយ ធម្មំ ទេសេតិ

ព្រះដ៏មានព្រះភាគនោះ ជាក់ជាព្រះអរហន្តសម្មាសម្ពុទ្ធប្រាកដ បាន ជាពួកលិច្ឆវីជនច្រើននាក់ ដែលមានកេរ្តិ៍ឈ្មោះល្បីល្បាញទាំងនេះ អង្គុយ ប្រជុំគ្នាក្នុងសណ្ឋាគារសាលា ពោលសរសើរគុណព្រះពុទ្ធ សរសើរគុណ ព្រះធម៌ សរសើរគុណព្រះសង្ឃ ដោយអនេកបរិយាយ ក៏ឯនិគ្រន្ថទាំង-ឡាយនេះ ទោះបីអញលាក្តី មិនលាក្តី នឹងហ៊ានធ្វើអ្វី បើដូច្នោះ អញ មិនបាច់លានិគន្ថនាដបុត្រទេ នឹងចូលទៅដើម្បីជួបព្រះដ៏មានព្រះភាគ ជា ព្រះអរហន្តសម្មាសម្ពុទ្ធនោះតែម្តង ។ លំដាប់នោះ សីហសេនាបតីចេញ ទៅអំពីក្រុងវេសាលីពេលជ្រេពីត្រង់ដោយរថចំនួនប្រាំរយ ដើម្បីជួបព្រះដ៏ មានព្រះភាគ ទី(ទៅ)ដោយយានបានត្រឹមណា ក៏ទៅដោយយានត្រឹមនោះ ហើយចុះអំពីយានដើរដោយជើងចូលទៅកាន់អារាម ។ លំដាប់នោះ សីហ-សេនាបតី ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះសីហសេ-នាបតី អង្គុយក្នុងទីសមគួរហើយ បានក្រាបទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮពាក្យនេះថា ព្រះសមណគោតម ជាអកិរិយវាទ តែងសម្តែងធម៌ ដើម្បីឃាត់ថា កិច្ចការមិនត្រូវធ្វើ

៥៩



តេន ច សាវកេ វិនេតីតិ យេ តេ ភន្តេ ឯវមាហំសុ អកិរិយវាទោ សមណោ គោតមោ អកិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ កិញ្ចិ តេ ភន្តេ ភគវតោ វុត្តវាទិនោ ន ច ភគវន្តំ អភូតេន អព្ភាចិក្ខន្តិ ធម្មស្ស ចានុធម្មំ ព្យាករោន្តិ ន ច កោចិ សហធម្មិកោ វាទានុវាទោ គារយ្ហដ្ឋានំ អាគច្ឆតិ អនព្ភក្ខាតុកាមា ហិ មយំ ភន្តេ ភគវន្តន្តិ ។ អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អកិរិយវាទោ សមណោ គោតមោ អកិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ កិរិយវាទោ សមណោ គោតមោ កិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ឧច្ឆេទវាទោ សមណោ គោតមោ ឧច្ឆេទាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។

ទាំងទូន្មានពួកសាវ័កដោយធម៌នោះដែរ បពិត្រព្រះអង្គដ៏ចម្រើន ជនទាំងឡាយណា ពោលពាក្យយ៉ាងនេះថា ព្រះសមណគោតម ជាអកិរិយវាទ តែងសម្ដែងធម៌ ដើម្បីឃាត់ថា កិច្ចការមិនត្រូវធ្វើ ទាំងទូន្មានពួកសាវ័កដោយធម៌នោះដែរ បពិត្រព្រះអង្គដ៏ចម្រើន ចុះជនទាំងឡាយនោះ ឈ្មោះថាអ្នកពោលតាមពាក្យដែលព្រះដ៏មានព្រះភាគពោលហើយផង ឈ្មោះថាមិនពោលបង្កាច់ព្រះដ៏មានព្រះភាគដោយពាក្យមិនពិតផង ឈ្មោះថាព្យាករនូវធម៌សមគួរដល់ធម៌ផង លំអាននៃពាក្យតូចធំ ប្រកបដោយធម៌តិចតួច រមែងមិនមកកាន់ឋានៈ គួរតិះដៀលផងទេឬ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះយើងខ្ញុំមិនបានប្រាថ្នាពោលបង្កាច់ព្រះដ៏មានព្រះភាគឡើយ ។ ព្រះសាស្ដាទ្រង់ត្រាស់តបថា ម្នាលសីហៈ ដែលអ្នកផងថា ព្រះសមណគោតម ជាអកិរិយ-វាទ តែងសម្ដែងធម៌ដើម្បីឃាត់ថា កិច្ចការមិនត្រូវធ្វើ ទាំងទូន្មានពួកសាវ័កដោយធម៌នោះដែរ ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ ដែលអ្នកផងថា ព្រះសមណគោតម ជាកិរិយវាទ តែងសម្ដែងធម៌ ដើម្បីធ្វើដែរ ទាំងទូន្មានពួកសាវ័កដោយធម៌នោះត្រូវហើយ ។ ម្នាលសីហៈ ដែលអ្នកផងថា ព្រះសមណគោតម ជាឧច្ឆេទវាទ តែងសម្ដែងធម៌ដើម្បីកាត់ផ្ដាច់ផ្ដិលដែរ ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ដែលគេថានោះត្រូវហើយ ។

អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ជេគុច្ឆី សមណោ គោតមោ ជេគុច្ឆិតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ វេនយិកោ សមណោ គោតមោ វិនយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ តបស្សី សមណោ គោតមោ តបស្សិតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អបគព្ភោ សមណោ គោតមោ អបគព្ភតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អត្ថិ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អស្សត្ថោ សមណោ គោតមោ អស្សាសាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។

ម្នាលសីហៈ ដែលអ្នកផងថា ព្រះសមណគោតម ជាអ្នកខ្ពើមរអើម តែង សម្ដែងធម៌ ដើម្បីសេចក្ដីខ្ពើមរអើម ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ត្រូវហើយ ។ ម្នាលសីហៈ ដែលអ្នកផងថា ព្រះសមណគោតម ជា អ្នកបំផ្លាញ តែងសម្ដែងធម៌ ដើម្បីបំផ្លាញ ទាំងទូន្មានពួកសាវ័កដោយធម៌ នោះ ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ ដែលអ្នកផងថា ព្រះ សមណគោតម ជាអ្នកដុតកម្ដៅ តែងសម្ដែងធម៌ ដើម្បីដុតកម្ដៅ ទាំងទូន្មាន ពួកសាវ័កដោយធម៌នោះ ដែលគេថានោះត្រូវហើយ ។ ម្នាលសីហៈ ដែល អ្នកផងថា ព្រះសមណគោតម ជាមនុស្សឥតកំណើត តែងសម្ដែងធម៌ ដើម្បីឥតកំណើត ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ដែលគេថានោះត្រូវ ហើយ ។ ម្នាលសីហៈ ដែលអ្នកផងថា ព្រះសមណគោតម ជាអ្នកល្ហួង លោម ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ដែលគេថា នោះត្រូវហើយ ។

កតមោ ច សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អកិរិយវាទោ សមណោ គោតមោ អកិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អហញ្ហិ សីហ អកិរិយំ វទាមិ កាយទុច្ចរិតស្ស វចីទុច្ចរិតស្ស មនោទុច្ចរិតស្ស អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ អកិរិយំ វទាមិ ។ អយំ ខោ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អកិរិយវាទោ សមណោ គោតមោ អកិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ កតមោ ច សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ កិរិយវាទោ សមណោ គោតមោ កិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អហញ្ហិ សីហ កិរិយំ វទាមិ កាយសុចរិតស្ស វចីសុចរិតស្ស មនោសុចរិតស្ស អនេកវិហិតានំ កុសលានំ ធម្មានំ កិរិយំ វទាមិ ។ អយំ ខោ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ

ម្នាលសីហៈ ចុះបរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាអកិរិយវាទ តែងសម្តែងធម៌ ដើម្បីឃាត់ថា កិច្ចការមិនត្រូវធ្វើ ទាំងទូន្មានពួកសាវ័កដោយធម៌នោះ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះថាតថាគតតែងនិយាយថា មិនគួរធ្វើកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិតទេ តែងនិយាយថា មិនគួរធ្វើអកុសលទាំងឡាយដ៏អាក្រក់ ច្រើនប្រការទេ ។ ម្នាលសីហៈ នេះឯងជាបរិយាយដែលអ្នកផងថា ព្រះសមណ-គោតម ជាអកិរិយវាទ តែងសម្តែងធម៌ ដើម្បីឃាត់ថា កិច្ចការមិនត្រូវធ្វើទាំងទូន្មានពួកសាវ័កដោយធម៌នោះ ។ ម្នាលសីហៈ ចុះបរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាកិរិយវាទ តែងសម្តែងធម៌ ដើម្បីធ្វើ ទាំងទូន្មានពួកសាវ័កដោយធម៌នោះ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះថា តថាគតតែងនិយាយថា គួរធ្វើកាយសុចរិត វចីសុចរិត មនោសុចរិត តែងនិយាយថា គួរធ្វើកុសលធម៌ទាំងឡាយច្រើនប្រការ ។ ម្នាលសីហៈ នេះឯង ជាបរិយាយ ដែលអ្នកផងថា

៦២



កិរិយវាទោ សមណោ គោតមោ កិរិយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ កតមោ ច សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ឧច្ឆេទវាទោ សមណោ គោតមោ ឧច្ឆេទាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អហញ្ហិ សីហ ឧច្ឆេទំ វទាមិ រាគស្ស ទោសស្ស មោហស្ស អនេក-វិហិតានំ បាបកានំ អកុសលានំ ធម្មានំ ឧច្ឆេទំ វទាមិ ។ អយំ ខោ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ឧច្ឆេទវាទោ សមណោ គោតមោ ឧច្ឆេទាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ កតមោ ច សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ ជេគុច្ឆី សមណោ គោតមោ ជេគុច្ឆិតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អហញ្ហិ សីហ ជិគុច្ឆាមិ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន ជិគុច្ឆាមិ អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា ។ អយំ ខោ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ

ព្រះសមណគោតម ជាកិរិយវាទ តែងសម្តែងធម៌ ដើម្បីធ្វើ ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ។ ម្នាលសីហៈ ចុះបរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាឧច្ឆេទវាទ តែងសម្តែងធម៌ ដើម្បីកាត់ផ្តាច់ផ្តិល ទាំងទូន្មានពួកសាវ័កដោយធម៌នោះ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះថា តថាគតតែងនិយាយ ចំពោះការកាត់ផ្តាច់ផ្តិលរាគៈ ទោសៈ មោហៈ តែងនិយាយចំពោះការកាត់ផ្តាច់ផ្តិលនូវអកុសលធម៌ទាំងឡាយច្រើនប្រការ ។ ម្នាលសីហៈ នេះឯងជាបរិយាយ ដែលអ្នកផងថា ព្រះសមណគោតម ជាឧច្ឆេទវាទ តែងសម្តែងធម៌ ដើម្បីកាត់ផ្តាច់ផ្តិល ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ។ ម្នាលសីហៈ ចុះបរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាអ្នកខ្ពើមរអើម តែងសម្តែងធម៌ ដើម្បីខ្ពើមរអើម ទាំងទូន្មានពួកសាវ័កដោយធម៌នោះ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះថា តថាគតខ្ពើមរអើមកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ខ្ពើមរអើម ការប្រកបចិត្ត ផ្តេកផ្តិតទៅរកអកុសលធម៌ទាំងឡាយដ៏អាក្រក់ច្រើនប្រការ ។ ម្នាលសីហៈ នេះឯងជាបរិយាយដែលអ្នកផងថា

ជេគុច្ឆី សមណោ គោតមោ ជេគុច្ឆិតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ កតមោ ច សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ វេនយិកោ សមណោ គោតមោ វិនយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ អហញ្ហិ សីហ វិនយាយ ធម្មំ ទេសេមិ រាគស្ស ទោសស្ស មោហស្ស អនេកវិហិតានំ បាបកានំ អកុសលានំ ធម្មានំ វិនយាយ ធម្មំ ទេសេមិ ។ អយំ ខោ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ វេនយិកោ សមណោ គោតមោ វិនយាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ កតមោ ច សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ តបស្សី សមណោ គោតមោ តបស្សិតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ តបនីយាហំ សីហ បាបកេ អកុសលេ ធម្មេ វទាមិ កាយទុច្ចរិតំ វចីទុច្ចរិតំ មនោទុច្ចរិតំ ។ យស្ស ខោ សីហ តបនីយា បាបកា អកុសលា ធម្មា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំកតា

ព្រះសមណគោតម ជាអ្នកខ្ពើមរអើម តែងសម្ដែងធម៌ ដើម្បីខ្ពើមរអើម ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ។ ម្នាលសីហៈ ចុះបរិយាយ ដែលអ្នកផងថា ព្រះសមណគោតម ជាអ្នកបំផ្លាញ តែងសម្ដែងធម៌ ដើម្បីបំផ្លាញ ទាំងទូន្មានពួកសាវ័កដោយធម៌នោះ តើដូចម្ដេច ។ ម្នាលសីហៈ ព្រោះថា តថាគតសម្ដែងធម៌ ដើម្បីបំផ្លាញរាគៈ ទោសៈ មោហៈ សម្ដែងធម៌ ដើម្បីបំផ្លាញអកុសលធម៌ទាំងឡាយ ដ៏អាក្រក់ ច្រើនប្រការ ។ ម្នាលសីហៈ នេះឯងជាបរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាអ្នកបំផ្លាញ តែងសម្ដែងធម៌ដើម្បីបំផ្លាញទាំងទូន្មាន ពួកសាវ័កដោយធម៌នោះ ។ ម្នាលសីហៈ ចុះបរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាអ្នកដុតកម្ដៅ តែងសម្ដែងធម៌ ដើម្បីដុតកម្ដៅ ទាំងទូន្មានពួកសាវ័កដោយធម៌នោះ តើដូចម្ដេច ។ ម្នាលសីហៈ តថាគត តែងនិយាយចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ ជាអកុសលធម៌ដ៏អាក្រក់ ។ ម្នាលសីហៈ អកុសលធម៌ទាំងឡាយដ៏អាក្រក់ ដែលជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ បើអ្នកណា បានលះបង់ស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើតដូចជាដើមត្នោត ដែលគេគាស់រំលើងឲ្យលែងដុះ តទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាព តទៅទៀតហើយ

អាយតឹ អនុប្បាទធម្មា តមហំ តបស្សីតិ វទាមិ ។ តថាគតស្ស ខោ សីហ តបនីយា បាបកា អកុសលា ធម្មា បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំកតា អាយតឹ អនុប្បាទធម្មា ។ អយំ ខោ សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ តបស្សី សមណោ គោតមោ តបស្សិតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ កតមោ ច សីហ បរិយាយោ យេន មំ បរិយាយេន សម្មា វទមានោ វទេយ្យ អបគព្ភោ សមណោ គោតមោ អបគព្ភតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។ យស្ស ខោ សីហ អាយតឹ គព្ភសេយ្យា បុនព្ភវាភិនិព្វត្តិ បហីនា ឧច្ឆិន្នមូលា តាលាវត្ថុកតា អនភាវំកតា អាយតឹ អនុប្បាទធម្មា តមហំ អបគព្ភោតិ វទាមិ ។ តថាគតស្ស ខោ សីហ អាយតឹ គព្ភសេយ្យា បុនព្ភវាភិនិព្វត្តិ បហីនា ឧច្ឆិន្នមូលា

ឲ្យជាធម៌លែងមានកំណើតតទៅមុខទៀតហើយ តថាគតហៅអ្នកនោះថា អ្នកដុតកម្ដៅ ។ ម្នាលសីហៈ អកុសលធម៌ទាំងឡាយដ៏អាក្រក់ ដែលជាទីតាំងនៃសេចក្ដីក្ដៅក្រហាយ តថាគតបានលះបង់ស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់ហើយ បានធ្វើមិនឲ្យមានទីកើត ដូចជាដើមត្នោតដែលគេគាស់រំលើងឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាព តទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅមុខទៀតហើយ ។ ម្នាលសីហៈ នេះឯងជាបរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាអ្នកដុតកម្ដៅ តែងសម្ដែងធម៌ដើម្បីដុតកម្ដៅ ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ។ ម្នាលសីហៈ បរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាមនុស្សមិនមានកំណើត តែងសម្ដែងធម៌ដើម្បីមិនមានកំណើត ទាំងទូន្មានពួកសាវ័កដោយធម៌នោះ តើដូចម្ដេច ។ ម្នាលសីហៈ កិរិយាដេកក្នុងគភ៌តទៅទៀត ដំណើរកើតក្នុងភពតទៅទៀត បើអ្នកណាបានលះស្រឡះហើយ បានផ្ដាច់ផ្ដិលឫសគល់អស់ហើយ បានធ្វើមិនឲ្យមានទីកើតដូចជាដើមត្នោត ដែលគេគាស់រំលើងឲ្យលែងដុះតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ តថាគតហៅអ្នកនោះថា ជាអ្នកមិនមានកំណើត ។ ម្នាលសីហៈ កិរិយាដេកនៅក្នុងគភ៌តទៅទៀត ដំណើរកើតក្នុងភពតទៅទៀត តថាគត បានលះបង់ស្រឡះហើយ បានផ្ដាច់ផ្ដិលអស់ហើយ

តាលាវត្ថុកតា អនភាវំកតា អាយតឹ អនុប្បាទធម្មា ។
អយំ ខោ សីហ បរិយាយោ យេន មំ បរិយាយេន
សម្មា វទមានោ វទេយ្យ អបគព្ភោ សមណោ គោតមោ
អបគព្ភតាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។
កតមោ ច សីហ បរិយាយោ យេន មំ បរិយាយេន
សម្មា វទមានោ វទេយ្យ អស្សត្ថោ សមណោ គោតមោ
អស្សាសាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។
អហញ្ហិ សីហ អស្សត្ថោ បរមេន អស្សាសេន
អស្សាសាយ ធម្មំ ទេសេមិ តេន ច សាវកេ វិនេមិ ។
អយំ ខោ សីហ បរិយាយោ យេន មំ បរិយាយេន
សម្មា វទមានោ វទេយ្យ អស្សត្ថោ សមណោ គោតមោ
អស្សាសាយ ធម្មំ ទេសេតិ តេន ច សាវកេ វិនេតីតិ ។
ឯវំ វុត្តេ សីហោ សេនាបតិ ភគវន្តំ ឯតទវោច អភិក្កន្តំ
ភន្តេ អភិក្កន្តំ ភន្តេ ។ បេ ។ ឧបាសកំ មំ ភន្តេ
ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។

បានធ្វើមិនឲ្យមានទីកើតដូចជាដើមត្នោត ដែលគេកាត់រំលើងឲ្យលែងដុះតទៅទៀតហើយ បានធ្វើឲ្យលែងមានបែបភាពតទៅទៀតហើយ ឲ្យជាធម៌លែងមានកំណើតតទៅខាងមុខទៀតហើយ ។ ម្នាលសីហៈ នេះឯងជាបរិយាយ ដែលអ្នកផងថា ព្រះសមណគោតម ជាអ្នកមិនមានកំណើត តែងសម្តែងធម៌ ដើម្បីមិនមានកំណើត ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ។ ម្នាលសីហៈ បរិយាយដែលអ្នកផងថា ព្រះសមណ-គោតម ជាអ្នកល្ហួងលោម តែងសម្តែងធម៌ ដើម្បីល្ហួងលោម ទាំងទូន្មានពួកសាវ័កដោយធម៌នោះ តើដូចម្តេច ។ ម្នាលសីហៈ ព្រោះថា តថាគតជាអ្នកល្ហួងលោម តែងសម្តែងធម៌ ដើម្បីល្ហួងលោម ដោយសេចក្តីល្ហួងលោមយ៉ាងក្រៃលែង ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ។ ម្នាលសីហៈ នេះឯង ជាបរិយាយដែលអ្នកផងថា ព្រះសមណគោតម ជាអ្នកល្ហួងលោម តែងសម្តែងធម៌ ដើម្បីល្ហួងលោម ទាំងទូន្មានពួកសាវ័កដោយធម៌នោះ ។ កាលបើព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះហើយ សីហ-សេនាបតី បានក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ពេកណាស់ បពិត្រព្រះអង្គដ៏ចម្រើន ច្បាស់ពេកណាស់ ។ បេ ។ បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមតាំងអំពីថ្ងៃនេះទៅ សូមព្រះដ៏មានព្រះភាគ ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក ដល់សរណៈ ស្មើដោយជីវិត ។

អនុវិច្ចការំ ខោ សីហ ករោហិ អនុវិច្ចការោ តុម្ហាទិសានំ ញាតមនុស្សានំ សាធុ ហោតីតិ ។ ឥមិនាបាហំ ភន្តេ ភគវតោ ភិយ្យោសោ មត្តាយ អត្តមនោ អភិរទ្ធោ យំ មំ ភគវា ឯវមាហ អនុវិច្ច-ការំ ខោ សីហ ករោហិ អនុវិច្ចការោ តុម្ហាទិសានំ ញាតមនុស្សានំ សាធុ ហោតីតិ មញ្ហិ ភន្តេ អញ្ញតិ-ត្ថិយា សាវកំ លភិត្វា កេវលកប្បំ វេសាលឹ បដាកំ បរិហរេយ្យុំ សីហោ អម្ហាកំ សេនាបតិ សាវកត្តំ ឧបគតោតិ អថ ច បន មំ ភគវា ឯវមាហ អនុវិច្ចការំ ខោ សីហ ករោហិ អនុវិច្ចការោ តុម្ហាទិ-សានំ ញាតមនុស្សានំ សាធុ ហោតីតិ ឯសាហំ ភន្តេ

ព្រះសាស្តាទ្រង់ត្រាស់ថា ម្នាលសីហៈ អ្នកចូរធ្វើនូវការពិចារណារួចហើយសឹមធ្វើ (ព្រោះ) ការពិចារណារួចហើយសឹមធ្វើ រមែងជាគុណគាប់ប្រសើររបស់ពួកមនុស្សអ្នកចេះដឹងប្រហែលនឹងអ្នក ។ សីហសេនាបតីក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីពេញចិត្តត្រេកអរលើសលុបហួសប្រមាណចំពោះភាសិតរបស់ព្រះអង្គ ដោយហេតុដែលព្រះអង្គសម្តែងនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលសីហៈ អ្នកចូរធ្វើនូវការពិចារណារួចហើយសឹមធ្វើ (ព្រោះ) ការពិចារណារួចហើយសឹមធ្វើ រមែងជាគុណគាប់ប្រសើររបស់ពួកមនុស្សអ្នកចេះដឹងប្រហែលនឹងអ្នក បពិត្រព្រះអង្គដ៏ចម្រើន ដ្បិតពួកអន្យតិរ្ថិយ បានខ្ញុំព្រះអង្គជាសាវ័កហើយ ក៏ដង្ហែទង់ ចូលទៅកាន់ក្រុងវេសាលីទាំងមូល ហើយប្រកាសសេចក្តីថា សីហសេនាបតី បានចុះចូលមក ជាសាវ័ករបស់ពួកយើងហើយ ចម្លែកតែព្រះដ៏មានព្រះភាគត្រឡប់ជាទ្រង់ត្រាស់ចំពោះខ្ញុំព្រះអង្គយ៉ាងនេះវិញថា ម្នាលសីហៈ អ្នកចូរធ្វើនូវការពិចារណារួចហើយសឹមធ្វើ (ព្រោះ) ការពិចារណារួចហើយសឹមធ្វើ រមែងជាគុណគាប់ប្រសើរ របស់មនុស្សអ្នកចេះដឹង ប្រហែលនឹងអ្នក បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ

ទុតិយម្បិ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណាគតន្តិ ។ ទីឃរត្តំ ខោ តេ សីហ និគណ្ឋានំ ឱបានភូតំ កុលំ យេន នេសំ ឧបគតានំ បិណ្ឌបាតំ[១] ទាតព្វំ មញ្ញេយ្យាសីតិ ។ ឥមិនាបាហំ ភន្តេ ភគវតោ ភិយ្យោសោ មត្តាយ អត្តមនោ អភិរទ្ធោ យំ មំ ភគវា ឯវមាហ ទីឃរត្តំ ខោ សីហ និគណ្ឋានំ ឱបានភូតំ កុលំ យេន នេសំ ឧបគតានំ បិណ្ឌបាតំ ទាតព្វំ មញ្ញេយ្យាសីតិ សុតមេតំ ភន្តេ សមណោ គោតមោ ឯវមាហ មយ្ហមេវ ទានំ ទាតព្វំ ន អញ្ញេសំ ទានំ ទាតព្វំ មយ្ហមេវ សាវកានំ ទានំ ទាតព្វំ ន អញ្ញេសំ សាវកានំ ទានំ ទាតព្វំ មយ្ហមេវ ទិន្នំ មហប្ផលំ

---

១ ឱ. ម. បិណ្ឌកំ ។

សូមដល់ព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក ចាប់ដើមតាំងពីថ្ងៃនេះទៅ សូមព្រះដ៏មានព្រះភាគ ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណៈស្មើដោយជីវិត ជាគម្រប់ពីរដងផង ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលសីហៈ ត្រកូលរបស់អ្នក ដូចជាអណ្តូងទឹក របស់ពួកនិគ្រន្ថ អស់កាលយូរណាស់មកហើយ អ្នកគប្បីសម្គាល់នូវបិណ្ឌបាត ដែលអ្នកគួរឲ្យដល់ពួកនិគ្រន្ថ ដែលចូលមករកនោះផង ។ សីហសេនាបតី ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីពេញចិត្ត ត្រេកអរលើសលុបហួសប្រមាណចំពោះភាសិតរបស់ព្រះអង្គ ដោយហេតុដែលព្រះអង្គ បានសម្តែងនឹងខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលសីហៈ ត្រកូលរបស់អ្នក ដូចជាអណ្តូងទឹក របស់ពួកនិគ្រន្ថ អស់កាលយូរណាស់មកហើយ អ្នកគប្បីសម្គាល់នូវបិណ្ឌបាត ដែលអ្នកគួរឲ្យដល់ពួកនិគ្រន្ថ ដែលចូលមករកនោះផង បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គធ្លាប់ឮពាក្យនេះថា ព្រះសមណគោតម ទ្រង់ត្រាស់យ៉ាងនេះថា បុគ្គលត្រូវឲ្យទានដល់តថាគតតែម្យ៉ាង មិនត្រូវឲ្យទានដល់ពួកសាស្តាដទៃឡើយ បុគ្គលត្រូវឲ្យទានដល់ពួកសាវ័ករបស់តថាគតតែម្យ៉ាង មិនត្រូវឲ្យទានដល់ពួកសាវ័ក របស់ពួកសាស្តាដទៃឡើយ បុគ្គលឲ្យទានដល់តថាគតតែម្យ៉ាង ទើបមានផលច្រើន

៦៨



ន អញ្ញេសំ ទិន្នំ មហប្ផលំ មយ្ហមេវ សាវកានំ ទិន្នំ មហប្ផលំ ន អញ្ញេសំ សាវកានំ ទិន្នំ មហប្ផលន្តិ អថ ច បន មំ ភគវា និគណ្ឋេសុបិ ទានេ សមាទបេតិ អបិ ច ភន្តេ មយមេត្ថ កាលំ ជានិស្សាម ឯសាហំ ភន្តេ តតិយម្បិ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ មំ ភន្តេ ភគវា ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណង្គតន្តិ ។ អថខោ ភគវា សីហស្ស សេនាបតិស្ស អនុបុព្វីកថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិសំសំ បកា-សេសិ ។ យទា ភគវា អញ្ញាសិ សីហំ សេនាបតឹ កល្លចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ ឧទគ្គចិត្តំ បសន្នចិត្តំ អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។

ឲ្យដល់ពួកសាស្តាដទៃ មិនមានផលច្រើនឡើយ បុគ្គលឲ្យទានដល់ពួកសាវ័ករបស់តថាគតតែម្យ៉ាង ទើបមានផលច្រើន ឲ្យទានដល់ពួកសាវ័ករបស់ពួកសាស្តាដទៃ មិនមានផលច្រើនឡើយ តែឥឡូវនេះព្រះដ៏មានព្រះភាគត្រឡប់ជាបបួលខ្ញុំព្រះអង្គឲ្យធ្វើទានក្នុងពួកនិគ្រន្ថ បពិត្រព្រះអង្គដ៏ចម្រើន ចំណែកខាងខ្ញុំព្រះអង្គគង់នឹងដឹងនូវកាលគួរក្នុងទាននុ៎ះ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គនេះ សូមដល់នូវព្រះដ៏មានព្រះភាគផង ព្រះធម៌ផង ព្រះភិក្ខុសង្ឃផង ជាទីពឹងទីរលឹក បពិត្រព្រះអង្គដ៏ចម្រើន ចាប់ដើមតាំងអំពីថ្ងៃនេះទៅ សូមព្រះដ៏មានព្រះភាគ ចាំទុកនូវខ្ញុំព្រះអង្គថាជាឧបាសក អ្នកដល់នូវសរណៈ ស្មើដោយជីវិត ជាគម្រប់បីដងផង ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងអនុបុព្វីកថាចំពោះសីហសេនាបតី គឺទ្រង់ប្រកាសនូវទានកថា សីលកថា សគ្គកថា នូវទោសរបស់កាមដ៏លាមក សៅហ្មង និងអានិសង្សក្នុងការចេញចាកកាម ។ កាលណាព្រះដ៏មានព្រះភាគទ្រង់ជ្រាបថា សីហសេនាបតី មានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តខ្ពស់ មានចិត្តជ្រះថ្លាហើយ ទើបទ្រង់ប្រកាសនូវធម្មទេសនា ដែលព្រះពុទ្ធទាំងឡាយ តែងលើកឡើងសម្តែងដោយព្រះអង្គឯង គឺទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ។

៦៩



សេយ្យថាបិ នាម សុក្កវត្ថំ អបគតកាឡកំ សម្ម-
ទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ សីហស្ស សេនា-
បតិស្ស តស្មឹយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ
ឧទបាទិ យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធ-
ធម្មន្តិ ។ អថខោ សីហោ សេនាបតិ ទិដ្ឋធម្មោ
បត្តធម្មោ វិទិតធម្មោ បរិយោគាឡ្ហធម្មោ តិណ្ណវិចិកិច្ឆោ
វិគតកថំកថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ សត្ថុ
សាសនេ ភគវន្តំ ឯតទវោច អធិវាសេតុ មេ ភន្តេ
ភគវា ស្វាតនាយ ភត្តំ សទ្ធឹ ភិក្ខុសង្ឃេនាតិ ។
អធិវាសេសិ ភគវា តុណ្ហីភាវេន ។ អថខោ សីហោ
សេនាបតិ ភគវតោ អធិវាសនំ វិទិត្វា ឧដ្ឋាយាសនា
ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។
អថខោ សីហោ សេនាបតិ អញ្ញតរំ បុរិសំ អាមន្តេសិ
គច្ឆ ត្វំ អម្ភោ បុរិស បវត្តមំសំ ជានាហីតិ ។

ធម្មតាសំពត់សស្អាត មិនជិតប្រឡាក់ដោយវត្ថុមានពណ៌ខ្មៅ គួរទទួលទឹកជ្រលក់បានដោយល្អ មានឧបមាដូចម្ដេចមិញ ធម្មចក្ខុគឺសោតាបត្តិមគ្គដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល ក៏កើតឡើងដល់សីហសេនាបតីក្នុងទីនោះឯងថា ធម្មជាតណាមួយ ដែលកើតឡើង ធម្មជាតទាំងអស់នោះ តែងរលត់ទៅវិញជាធម្មតា មានឧបមេយ្យដូច្នោះឯង ។ គ្រានោះ សីហសេនាបតី បានឃើញអរិយសច្ចធម៌ហើយ បានលុះអរិយសច្ចធម៌ហើយ បានដឹងច្បាស់អរិយសច្ចធម៌ហើយ បានជ្រៀតជាក់អរិយសច្ចធម៌ហើយ ឆ្លងផុតសេចក្ដីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវភាពជាអ្នកក្លាហានមិនជឿស្ដាប់បុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្ដាហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់ទទួលនូវភត្តរបស់ខ្ញុំព្រះអង្គ ជាមួយនឹងភិក្ខុសង្ឃ ដើម្បីឆាន់ក្នុងថ្ងៃស្អែក ។ ព្រះដ៏មានព្រះភាគទ្រង់ទទួលដោយតុណ្ហីភាព ។ លំដាប់នោះ សីហសេនាបតី ដឹងច្បាស់ថា ព្រះដ៏មានព្រះភាគទទួលនិមន្តន៍ហើយ ទើបក្រោកចាកទីអង្គុយ ថ្វាយបង្គំព្រះដ៏មានព្រះភាគធ្វើប្រទក្សិណ ហើយដើរចេញទៅ ។ លំដាប់នោះ សីហសេនាបតី បានហៅបុរស ១ នាក់មកថា ម្នាលបុរសដ៏ចម្រើន អ្នកចូរទៅ ចូរដឹងនូវសាច់ ដែលគួរប្រព្រឹត្តទៅតាមប្រក្រតី (សាច់ទុកលក់) ។

៧០



អថខោ សីហោ សេនាបតិ តស្សា រត្តិយា អច្ចយេន សកេ និវេសនេ បណីតំ ខាទនីយំ ភោជនីយំ បដិយាទេត្វា ភគវតោ កាលំ អារោចាបេសិ កាលោ ភន្តេ សីហស្ស សេនាបតិស្ស និវេសនេ និដ្ឋិតំ ភត្តន្តិ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន សីហស្ស សេនាបតិស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ សទ្ធឹ ភិក្ខុសង្ឃេន ។ តេន ខោ បន សមយេន សម្ពហុលា និគណ្ឋា វេសាលិយំ រថិយាយ រថិយំ សិង្ឃាដកេន សិង្ឃាដកំ ពាហា បគ្គយ្ហ កន្ទន្តិ អជ្ជ សីហេន សេនាបតិនា ថូលំ បសុំ វធិត្វា សមណស្ស គោតមស្ស ភត្តំ កតំ សមណោ គោតមោ ជានំ ឧទ្ទិស្ស កតំ មំសំ បរិភុញ្ជតិ បដិច្ចកម្មន្តិ ។

លំដាប់នោះ សីហសេនាបតី ក៏ចាត់ចែង ខាទនីយភោជនីយាហារ ដ៏ផ្ចិតផ្ចង់ ក្នុងផ្ទះរបស់ខ្លួន ដោយកាលកន្លងទៅនៃរាត្រីនោះ ទើបប្រើបុរសនោះឲ្យទៅក្រាបទូលនូវភត្តកាលដល់ព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន កាលគួរហើយ ភត្តក្នុងផ្ទះរបស់សីហសេនាបតី សម្រេចហើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ស្តេចចូលទៅកាន់លំនៅរបស់សីហសេនាបតី លុះចូលទៅដល់ហើយ ទ្រង់គង់លើអាសនៈ ដែលសីហសេនាបតីក្រាលបម្រុងទុក ជាមួយនឹងភិក្ខុសង្ឃ ។ ក្នុងសម័យនោះ ពួកនិគ្រន្ថជាច្រើន នាក់ផ្គងនូវដើមដៃស្រែកកន្ទក់កន្ទេញ សព្វច្រកសព្វផ្លូវត្រឡែងកែងក្នុងក្រុងវេសាលីថា ថ្ងៃនេះសីហសេនាបតី សម្លាប់សត្វមានសរីរៈធាត់ធំ ធ្វើភត្តដើម្បីសមណគោតមៗ ទុកជាដឹង គង់ឆាន់នូវសាច់ដែលគេសម្លាប់ចំពោះខ្លួន (ព្រះសមណគោតមនេះឈ្មោះថាត្រូវ) បដិច្ចកម្ម[១] ។

---

១-ពាក្យថា បដិច្ចកម្មនេះ ជាឈ្មោះអំពើរបស់អ្នកដែលគ្រាន់តែបរិភោគសាច់ ក៏បាននាមថាសម្លាប់សត្វដែរ ឬ ជាឈ្មោះអំពើដែលគេសម្លាប់ព្រោះអាស្រ័យខ្លួន ពុំនោះសោត ពាក្យថា បដិច្ចកម្មនេះ ជាឈ្មោះរបស់និមិត្តកម្ម ។ លទ្ធិពួកនិគ្រន្ថប្រកាន់ថា បដិច្ចកម្មនោះជាអកុសលត្រូវបានដល់អ្នកឲ្យពាក់កណ្តាល អ្នកទទួលពាក់កណ្តាល ។ អដ្ឋកថា ។

៧១



អថខោ អញ្ញតរោ បុរិសោ យេន សីហោ សេនាបតិ តេនុបសង្កមិ ឧបសង្កមិត្វា សីហស្ស សេនាបតិស្ស ឧបកណ្ណកេ អារោចេសិ យគ្ឃេ ភន្តេ ជានេយ្យាសិ ឯតេ សម្ពហុលា និគណ្ឋា វេសាលិយំ រថិយាយ រថិយំ សិង្ឃាដកេន សិង្ឃាដកំ ពាហា បគ្គយ្ហ កន្ទន្តិ អជ្ជ សីហេន សេនាបតិនា ថូលំ បសុំ វធិត្វា សមណស្ស គោតមស្ស ភត្តំ កតំ សមណោ គោតមោ ជានំ ឧទ្ទិស្ស កតំ មំសំ បរិភុញ្ជតិ បដិច្ចកម្មន្តិ ។ អលំ អយ្យា ទីឃរត្តញ្ហិ តេ អាយស្មន្តោ អវណ្ណកាមា ពុទ្ធស្ស អវណ្ណ-កាមា ធម្មស្ស អវណ្ណកាមា សង្ឃស្ស ន ច បនេតេ អាយស្មន្តោ ជីរន្តិ តំ ភគវន្តំ អសតា តុច្ឆា មុសា អភូតេន អព្ភាចិក្ខន្តា ន ច មយំ ជីវិតហេតុបិ សញ្ចិច្ច បាណំ ជីវិតា វោរោបេយ្យាមាតិ ។ អថខោ សីហោ សេនាបតិ ពុទ្ធប្បមុខំ ភិក្ខុសង្ឃំ បណីតេន ខាទនីយេន ភោជនីយេន សហត្ថា សន្តប្បេសិ សម្បវារេសិ ។

លំដាប់នោះ បុរសម្នាក់ ក៏ចូលទៅឯកន្លែង ដែលសីហសេនាបតីនៅ លុះចូលទៅដល់ហើយ ក៏ខ្សឹបប្រាប់ក្បែរត្រចៀកនៃសីហសេនាបតីថា សូមព្រះតេជព្រះគុណជ្រាប ពួកនិគ្រន្ថជាច្រើន ទាំងអម្បាលនេះ ផ្គងដើមដៃកន្ទក់កន្ទេញ សព្វច្រកសព្វផ្លូវត្រឡែងកែង ជិតក្រុងវេសាលីថា ក្នុងថ្ងៃនេះ សីហសេនាបតី សម្លាប់សត្វមានសរីរៈធាត់ធំ ធ្វើកត្តដើម្បីព្រះសមណគោតមៗ ទុកជាដឹងក៏គង់ឆាន់នូវសាច់ដែលគេសម្លាប់ចំពោះខ្លួនព្រះសមណគោតមនេះ ឈ្មោះថា ត្រូវបដិច្ចកម្ម ។ លោកម្ចាស់ទាំង-ឡាយ មិនគួរសោះ ព្រោះថា លោកដ៏មានអាយុទាំងនោះ ប្រាថ្នារកទោសព្រះពុទ្ធ ប្រាថ្នារកទោសព្រះធម៌ ប្រាថ្នារកទោសព្រះសង្ឃ អស់កាលជាយូរណាស់មកហើយ តែលោកដ៏មានអាយុទាំងនោះ មិនអៀនសោះ នៅតែពោលបង្កាច់ព្រះដ៏មានព្រះភាគនោះ ដោយពាក្យមិនមាន ពាក្យទទេ ជាពាក្យកុហក មិនពិត ទាំងពួកយើងក៏មិនក្លែងផ្តាច់បង់សត្វចាកជីវិតព្រោះហេតុតែជីវិត (របស់ខ្លួនឡើយ) ។ លំដាប់នោះ សីហសេនាបតី ញុំាំងភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឲ្យឆាន់ឆ្អែតស្កប់ស្កល់ ដោយខាទនីយភោជនីយាហារដ៏ឧត្តមដោយដៃខ្លួនឯង ។

អថខោ សីហោ សេនាបតិ តំ ភគវន្តំ ភុត្តាវឹ ឱនីត-បត្តបាណឹ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ សីហំ សេនាបតឹ ភគវា ធម្មិយា កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា ឧដ្ឋាយា-សនា បក្កាមីតិ ។

[១៣] អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានិយោ រាជរហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេវ សំខ្យំ គច្ឆតិ ។ កតមេហិ អដ្ឋហិ ។ ឥធ ភិក្ខវេ រញ្ញោ ភទ្រោ អស្សាជានិយា ឧភតោ សុជាតោ ហោតិ មាតិតោ ច បិតិតោ ច យស្សំ ទិសាយំ អញ្ញេបិ ភទ្រា អស្សាជានិយា ជាយន្តិ តស្សំ ទិសាយំ ជាតោ ហោតិ យំ ខោ បនស្ស ភោជនំ ទេន្តិ អល្លំ វា សុក្ខំ វា តំ សក្កច្ចំយេវ បរិភុញ្ជតិ អវិកិរន្តោ ជេគុច្ឆី ហោតិ ឧច្ចារំ វា បស្សាវំ វា អភិនិសីទិតុំ វា អភិនិបជ្ជិតុំ វា សោរតោ ហោតិ សុខសំវាសោ ន ច អញ្ញេ អស្សេ ឧព្វេជេតា

កាលដែលព្រះដ៏មានព្រះភាគអង្គនោះ ឆាន់រួច លែងដាក់ព្រះហស្តទៅក្នុងបាត្រទៀតហើយ សីហសេនាបតី ក៏អង្គុយក្នុងទីសមគួរ ។ កាលដែលសីហសេនាបតី អង្គុយក្នុងទីដ៏សមគួរហើយ ទើបព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា ហើយក្រោកចាកអាសនៈស្តេចចេញទៅ ។

[១៣] ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អ របស់ស្តេចដែលប្រកបដោយអង្គ ៨ យ៉ាង ជាសត្វគួរដល់ព្រះរាជា ជារាជបម្រើដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ អង្គ ៨ យ៉ាងដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងលោកនេះ សេះអាជានេយ្យដ៏ល្អ របស់ស្តេចជាសត្វមានកំណើត ដ៏ល្អទាំងពីរខាង គឺទាំងខាងមេនិងខាងបា ១ សេះអាជានេយ្យទាំងឡាយដ៏ល្អដទៃទៀត កើតក្នុងទិសណា ក៏កើតក្នុងទិសនោះ ១ ជនទាំងឡាយ ឲ្យស្មៅស្រស់ក្តី ស្មៅស្ងួតក្តីណាដល់វា វាក៏ចេះតែស៊ីស្មៅស្រស់ឬស្មៅស្ងួតនោះ ដោយគោរព មិនឲ្យរាត់រាយ ១ ជាសត្វខ្ពើមរអើមនឹងការអង្គុយសង្កត់នូវឧច្ចារៈ និងបស្សាវៈ ១ វាជាសត្វត្រេកអរ តែងសប្បាយ មិនបៀតបៀននូវពួកសេះដទៃ ១

យានិ ខោ បនស្ស តានិ សាថេយ្យានិ កូដេយ្យានិ ជិម្ហេយ្យានិ វង្កេយ្យានិ តានិ យថាភូតំ សារថិស្ស អាវិកត្តា ហោតិ តេសមស្ស សារថិ អភិនិម្មទនាយ វាយមតិ វាហី ខោ បន ហោតិ កាមញ្ញេ អស្សា វហន្តុ វា មា វា អហាមេត្ថ វហិស្សាមីតិ ចិត្តំ ឧប្បាទេតិ គច្ឆន្តោ ខោ បន ឧជុមគ្គេនេវ គច្ឆតិ ថាមវា ហោតិ យាវ ជីវិតមរណបរិយាទានា ថាមំ ឧបទំសេតា ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតោ រញ្ញោ ភទ្រោ អស្សាជានិយោ រាជារហោ ហោតិ រាជភោគ្គោ រញ្ញោ អង្គន្តេ្វវ សំខ្យំ គច្ឆតិ ។ ឯវមេវ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ អដ្ឋហិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារ-គោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី

ការអួតអាង កោង មិតពត់និងការវៀចទាំងឡាយណារបស់វា វាក៏ធ្វើនូវការអួតអាងជាដើមនោះ ឲ្យជាក់ច្បាស់គួរតាមពិត ដល់នាយសារថីៗ ក៏ព្យាយាមដើម្បីញ៉ាំញីនូវការអួតអាងជាដើមរបស់វា ១ ជាសត្វតែងនាំទៅ តែងញុំាងចិត្តឲ្យកើតឡើងថា ពួកសេះដទៃ ទោះនាំទៅក៏ដោយ មិននាំទៅក៏ដោយ អញនឹងនាំទៅដោយពិតក្នុងទីនោះ កាលដែលទៅក៏រមែងទៅតាមផ្លូវត្រង់តែម្យ៉ាង ១ ជាសត្វមានកម្លាំងមាំមួន ដែលនឹងថយកម្លាំងត្រាតែសេចក្ដីស្លាប់គ្របសង្កត់ជីវិត ១ ។ ម្នាលភិក្ខុទាំងឡាយ សេះអាជានេយ្យដ៏ល្អរបស់ស្ដេច ប្រកបដោយអង្គ ៨ យ៉ាងនេះឯង ជាសត្វគួរដល់ព្រះរាជា ជារាជបម្រើ ដល់នូវការរាប់ថាជាអង្គរបស់ព្រះរាជា ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក៏យ៉ាងនោះដែរ ជាអ្នកប្រកបដោយធម៌ ៨ យ៉ាង ទើបជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីលហើយនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។ ធម៌ ៨ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល តែងសង្រួមក្នុងបាតិមោក្ខសំវរសីល ជាអ្នកបរិបូណ៌ ដោយអាចារៈនិងគោចរៈ ១ ឃើញភ័យក្នុងទោសទាំងឡាយ សូម្បីមានប្រមាណតិចតួច

សមាទាយ សិក្ខតិ សិក្ខាបទេសុ យំ ខោ បនស្ស ភោជនំ ទេតិ លូខំ វា បណីតំ វា តំ សក្កច្ចំយេវ បរិភុញ្ជតិ អវិហញ្ញមានោ ជេគុច្ឆី ហោតិ កាយទុច្ចរិតេន វចីទុច្ចរិតេន មនោទុច្ចរិតេន ជិគុច្ឆតិ បាបកានំ អកុសលានំ ធម្មានំ សមាបត្តិយា សោរតោ ហោតិ សុខសំវាសោ ន អញ្ញេ ភិក្ខូ ឧព្ពេជេតា យានិ ខោ បនស្ស តានិ សាថេយ្យានិ កូដេយ្យានិ ជិម្ហេយ្យានិ វង្កេយ្យានិ តានិ យថាភូតំ អាវិកត្តា ហោតិ សត្ថរិ វា វិញ្ញូសុ វា សព្រហ្មចារីសុ តេសមស្ស សត្ថា វា វិញ្ញូ វា សព្រហ្មចារី អភិនិម្មទនាយ វាយមតិ សិក្ខិតា ខោ បន ហោតិ កាមញ្ញេ ភិក្ខូ សិក្ខន្តុ វា មា វា អហមេត្ថ សិក្ខិស្សាមីតិ ចិត្តំ ឧប្បាទេតិ គច្ឆន្តោ ខោ បន ឧជុមគ្គេនេវ គច្ឆតិ តត្រាយំ ឧជុមគ្គោ សេយ្យថីទំ សម្មាទិដ្ឋិ ។ បេ ។ សម្មាសមាធិ អារទ្ធវីរិយោ វិហរតិ កាមំ តចោ ច ន្ហារុ ច អដ្ឋិ ច អវសិស្សតុ សរីរេ ឧបសុស្សតុ មំសលោហិតំ

សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជនប្រគេននូវភោជនណាមួយ ទោះសៅហ្មងក្តី ឧត្តមក្តីដល់លោកៗ ក៏ចេះតែឆាន់នូវភោជននោះដោយគោរព មិនរើសអើង ១ ជាអ្នកខ្ពើមរអើមចំពោះកាយទុច្ចរិត វចីទុច្ចរិត មនោទុច្ចរិត ខ្ពើមរអើមចំពោះការជួបប្រសព្វនឹងអកុសលធម៌ទាំងឡាយដ៏លាមក ១ លោកជាអ្នករីករាយ មានការនៅសប្បាយ មិនបៀតបៀនពួកភិក្ខុដទៃ ១ ការអួតអាង កោង មិតពត់និងការវៀចទាំងឡាយណារបស់លោកៗ ជាអ្នកធ្វើនូវការអួតអាងជាដើមនោះ ឲ្យជាក់ច្បាស់តាមពិតចំពោះព្រះសាស្តា ឬ សព្រហ្មចារីជាវិញ្ញូជន ព្រះសាស្តាឬសព្រហ្មចារីជាវិញ្ញូជនតែងព្យាយាមដើម្បីញ៉ាំញីនូវការអួតអាងជាដើមនោះរបស់លោក ១ ជាអ្នកសិក្សា ញុំាងចិត្តឲ្យកើតឡើងថា ពួកភិក្ខុដទៃ ទោះសិក្សាក៏ដោយ មិនសិក្សាដ៏ដោយ អញនឹងសិក្សាក្នុងធម្មវិន័យនេះ ដោយពិត លោកកាលនឹងទៅ ក៏ទៅតាមផ្លូវត្រង់តែម្យ៉ាង បណ្តាផ្លូវត្រង់ទាំងនោះ ផ្លូវត្រង់នេះគឺសម្មាទិដ្ឋិ ១ ។ បេ ។ សម្មាសមាធិ ១ ជាអ្នកមានសេចក្តីព្យាយាមតឹងតែងថា ស្បែក សរសៃនិងឆ្អឹង ចូរស្ងិតក្រៀមចុះ សាច់និងឈាម ចូររីងស្ងួតក្នុងសរីរៈចុះ

យន្តំ បុរិសត្ថាមេន បុរិសវីរិយេន បុរិសបរក្កមេន បត្តព្វំ ន តំ អបាបុណិត្វា វីរិយស្ស សណ្ឋានំ ភវិស្សតីតិ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

[១៤] អដ្ឋ ភិក្ខវេ អស្សខឡុង្កេ អដ្ឋ ច អស្សទោសេ ទេសេស្សាមិ អដ្ឋ បុរិសខឡុង្កេ អដ្ឋ ច បុរិសទោសេ តំ សុណាថ ។ បេ ។ កតមេ ច ភិក្ខវេ អដ្ឋ អស្សខឡុង្កា អដ្ឋ ច អស្សទោសា ។ ឥធ ភិក្ខវេ ឯកច្ចោ អស្សខឡុង្កោ បេហីតិ វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា បច្ឆតោ បដិសក្កតិ បិដ្ឋិតោ រថំ បវត្តេតិ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ អស្ស-ខឡុង្កោ ហោតិ អយំ ភិក្ខវេ បឋមោ អស្សទោសោ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ អស្សខឡុង្កោ បេហីតិ វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា

កិច្ចណា ដែលអ្នកផងត្រូវដល់ ដោយកម្លាំងនៃបុរស ព្យាយាមនៃបុរស សេចក្តីប្រឹងប្រែងនៃបុរស បើមិនទាន់ដល់នូវកិច្ចនោះទេ ក៏មិនបញ្ឈប់សេចក្តីព្យាយាម ១ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាងនេះឯង ទើបជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលបុគ្គលឧទ្ទិសចំពោះអ្នកមានសីលហើយនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តដ៏ប្រសើររបស់សត្វលោក ។

[១៤] ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្តែងនូវសេះមានពុតត្បុត ៨ យ៉ាង និងទោសនៃសេះ ៨ យ៉ាង បុរសមានពុតត្បុត ៨ យ៉ាង នឹងទោសនៃបុរស ៨ យ៉ាង ចូរអ្នកទាំងឡាយ ចាំស្តាប់នូវធម៌នោះចុះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុត ៨ យ៉ាង និងទោសនៃសេះ ៨ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏ត្រឡប់ថយក្រោយ ញ៉ាំងរថឲ្យត្រឡប់ថយក្រោយ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន

បច្ឆា លង្ឃិបតិ កុព្វរំ បហរតិ តិទណ្ឌំ ភញ្ជតិ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ អស្សខឡុង្កោ ហោតិ អយំ ភិក្ខវេ ទុតិយោ អស្សទោសោ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ អស្សខឡុង្កោ បេហីតិ វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា រថីសាយ សត្ថឹ ឧស្សជ្ជិត្វា រថីសំយេវ អជ្ឈោមទ្ទតិ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ អស្សខឡុង្កោ ហោតិ អយំ ភិក្ខវេ តតិយោ អស្សទោសោ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ អស្សខឡុង្កោ បេហីតិ វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា ឧម្មក្កំ គណ្ហាតិ ឧព្វជុមំ រថំ ករោតិ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ អស្សខឡុង្កោ ហោតិ អយំ ភិក្ខវេ ចតុត្ថោ អស្សទោសោ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ អស្សខឡុង្កោ បេហីតិ វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា លង្ឃេតិ បុរិមំ កាយំ បគ្គណ្ហាតិ បុរិមេ ចាទេ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ អស្សខឡុង្កោ ហោតិ អយំ ភិក្ខវេ បញ្ចមោ អស្សទោសោ ។

ក៏ប្រាយជើងខាងក្រោយ ទង្គិចក្បាលនឹងក្បាលក្រពើរថ បំបាក់ឈើជា ៣ កំណាត់ (ចែរថ) ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះក្នុងលោកនេះបែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ២ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថី និយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏លើកនូវជើង ពាក់លើចន្ទោលនៃរថ ញាំញីនូវចន្ទោលរថ ឲ្យខ្ទេចខ្ទី ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះបែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ៣ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏ប្រកាន់ខុសផ្លូវធ្វើរថឲ្យខុសផ្លូវ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ៤ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ដាស់តឿន ក៏លោតកញ្ឆោលកាយខាងមុខ ផ្គងនូវជើងទាំងពីរខាងមុខ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះបែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ៥ ។

បុន ចបរំ ភិក្ខវេ ឥធេកច្ចោ អស្សខឡុង្កោ បេហីតិ វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា អធាទយិត្វា បតោទយដ្ឋឹ ទន្តេហិ មុខាធានំ វិទ្ធំសិត្វា យេនកាមំ បក្កមតិ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ អស្សខឡុង្កោ ហោតិ អយំ ភិក្ខវេ ឆដ្ឋោ អស្សទោសោ ។ បុន ចបរំ ភិក្ខវេ ឥធេកច្ចោ អស្សខឡុង្កោ បេហីតិ វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា នេវ អភិក្កមតិ នោ បដិក្កមតិ តត្ថេវ ខីលដ្ឋាយិដ្ឋិតោ ហោតិ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ អស្សខឡុង្កោ ហោតិ អយំ ភិក្ខវេ សត្តមោ អស្សទោសោ ។ បុន ចបរំ ភិក្ខវេ ឥធេ-កច្ចោ អស្សខឡុង្កោ បេហីតិ វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា បុរិមេវ បាទេ សំហរិត្វា បច្ឆិមេ បាទេ សំហរិត្វា តត្ថេវ ចត្តារោ បាទេ អភិនិសីទតិ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ អស្សខឡុង្កោ ហោតិ អយំ ភិក្ខវេ អដ្ឋមោ អស្សទោសោ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏មិនអើពើនឹងដងជន្លួញ ខាំផ្ដាច់នូវខ្សែបង្ហៀរ ដោយធ្មេញទាំងឡាយ ហើយគេចចេញទៅ តាមសេចក្ដីប្រាថ្នា ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ៦ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏មិនឈានទៅមុខ មិនឈានថយក្រោយ នៅឈរនឹងថ្កល់ដូចជាសសរខឿនក្នុងទីនោះដដែល ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ៧ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏កន្ដ្រាញជើងទាំងពីរខាងមុខ កន្ដ្រាញជើងទាំងពីរខាងក្រោយ ហើយក្រាបសង្កត់នូវជើងទាំង ៤ ក្នុងទីនោះឯង ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់សេះទី ៨ ។

ឥមេ ខោ ភិក្ខវេ អដ្ឋ អស្សខឡុង្កា អដ្ឋ ច អស្ស-
ទោសា ។ កតមេ ច ភិក្ខវេ អដ្ឋ បុរិសខឡុង្កា អដ្ឋ
ច បុរិសទោសា ។ ឥធ ភិក្ខវេ ភិក្ខុំ ភិក្ខូ អាបត្តិយា
ចោទេន្តិ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយ-
មានោ ន សរាមិ ន សរាមីតិ អាបត្តិយាវ និព្វេឋេតិ
សេយ្យថាបិ សោ ភិក្ខវេ អស្សខឡុង្កោ បេហីតិ
វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា បច្ចតោ
បដិសក្កតិ បិដ្ឋិតោ រថំ បវត្តេតិ តថូបមាហំ ភិក្ខវេ
ឥមំ បុគ្គលំ វទាមិ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុរិស-
ខឡុង្កោ ហោតិ អយំ ភិក្ខវេ បឋមោ បុរិសទោសោ ។
បុន ចបរំ ភិក្ខវេ ភិក្ខុំ ភិក្ខូ អាបត្តិយា ចោទេន្តិ
សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ
ចោទកំយេវ បដិប្ផរតិ កឹ នុ ខោ តុយ្ហំ ពាលស្ស
អព្យត្តស្ស ភណិតេន ត្វំបិ នាម ភណិតព្វំ មញ្ញសីតិ

ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុត ៨ យ៉ាង និងទោសនៃសេះ ៨ យ៉ាង នេះឯង ។ ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុត ៨ យ៉ាង និងទោសនៃបុរស ៨ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ក្នុងសាសនានេះ ដាស់តឿនភិក្ខុផងគ្នា ដោយអាបត្តិ ភិក្ខុនោះ កាលដែលភិក្ខុទាំងឡាយ ដាស់តឿនដោយអាបត្តិ ក៏បណ្តោះបណ្តែអំពីអាបត្តិថា ខ្ញុំនឹកមិនឃើញទេៗ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតនោះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏ត្រឡប់ថយក្រោយ ញុំាងរថឲ្យត្រឡប់ខាងក្រោយ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់បុរសទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកភិក្ខុដាស់តឿនភិក្ខុផងគ្នា ដោយអាបត្តិ ភិក្ខុនោះ កាលដែលពួកភិក្ខុដាស់តឿនដោយអាបត្តិ ក៏តបតនឹងពាក្យចោទវិញថា ប្រយោជន៍អ្វី អញនឹងនិយាយជាមួយអ្នកឯង ដែលជាមនុស្សពាល មិនឈ្លាសវៃ អម្បាលយ៉ាងអញ អ្នកឯងហ៊ានសម្គាល់ថាជាបុគ្គល គួរគេស្តីថាបានទៅហើយ

សេយ្យថាបិ សោ ភិក្ខវេ អស្សខឡុង្កោ បេហីតិ វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា បច្ឆា លង្ឃិបតិ កុព្វរំ បហរតិ តិទណ្ឌំ ភញ្ជតិ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុរិសខឡុង្កោ ហោតិ អយំ ភិក្ខវេ ទុតិយោ បុរិស-ទោសោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុំ ភិក្ខូ អាបត្តិយា ចោទេន្តិ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ ចោទកស្សេវ បច្ចារោបេតិ ត្វំបិ ខោសិ ឥត្ថន្នាមំ អាបត្តឹ អាបន្នោ ត្វំ តាវ បឋមំ បដិករោហីតិ សេយ្យថាបិ សោ ភិក្ខវេ អស្សខឡុង្កោ បេហីតិ វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា ឦសាយ សត្តឹ ឧស្សជ្ជិត្វា ឦសំយេវ អជ្ឈោមទ្ទតិ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុរិស-ខឡុង្កោ ហោតិ អយំ ភិក្ខវេ តតិយោ បុរិសទោសោ ។

ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតនោះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏ប្រាយជើងខាងក្រោយទង្គិចក្បាលនឹងក្បាលក្រពើរថ បំបាក់ឈើជា ៣ កំណាត់ (ចែរថ) មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់បុរសទី ២ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកភិក្ខុដាស់តឿនភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលដែលពួកភិក្ខុដាស់តឿនដោយអាបត្តិ ក៏ត្រឡប់លើកទោស ដល់ភិក្ខុអ្នកដាស់តឿនវិញថា អ្នកឯងទេតើ ដែលត្រូវអាបត្តិឈ្មោះនេះ អ្នកឯងចូរសម្តែងអាបត្តិមុនសិនទៅ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតនោះ ដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏លើកនូវជើងពាក់លើចន្ទោលរថ ហើយញាំញីនូវចន្ទោលរថឲ្យខ្ទេចខ្ទីមានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់បុរសទី ៣ ។

បុន ចបរំ ភិក្ខវេ ភិក្ខុំ ភិក្ខូ អាបត្តិយា ចោទេន្តិ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ អញ្ញេនាញ្ញំ បដិចរតិ ពហិទ្ធា កថំ អបនាមេតិ កោបញ្ច ទោសញ្ច អប្បច្ចយញ្ច បាតុករោតិ សេយ្យថាបិ សោ ភិក្ខវេ អស្សខឡុង្កោ បេហីតិ វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា ឧម្មគ្គំ គណ្ហាតិ ឧព្វដុមំ រថំ ករោតិ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុរិសខឡុង្កោ ហោតិ អយំ ភិក្ខវេ ចតុត្ថោ បុរិសទោសោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុំ ភិក្ខូ អាបត្តិយា ចោទេន្តិ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ សង្ឃមជ្ឈេ ពាហាវិក្ខេបកំ ភណតិ សេយ្យថាបិ សោ ភិក្ខវេ អស្សខឡុង្កោ បេហីតិ វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា លង្ឃេតិ បុរិមំ កាយំ បគ្គណ្ហាតិ បុរិមេ បាទេ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុរិសខឡុង្កោ ហោតិ

ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកភិក្ខុដាស់តឿនភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលដែលពួកភិក្ខុ ដាស់តឿនដោយអាបត្តិ ក៏បិទបាំងនូវហេតុដទៃ ដោយហេតុដទៃ ទាត់ពាក្យសម្តីចោលទៅខាងក្រៅ ធ្វើនូវសេចក្តីក្រោធផង នូវទោសផង នូវសេចក្តីមិនត្រេកអរផង ឲ្យប្រាកដ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតនោះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏ប្រកាន់ខុសផ្លូវ ធ្វើរថឲ្យខុសផ្លូវមានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំង-ឡាយ នេះជាទោសរបស់បុរសទី ៤ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកភិក្ខុដាស់តឿនភិក្ខុផងគ្នាដោយអាបត្តិ ភិក្ខុនោះ កាលដែលពួកភិក្ខុដាស់តឿនដោយអាបត្តិ ក៏និយាយឆ្កាដៃ ក្នុងកណ្តាលជំនុំសង្ឃ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតនោះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ដាស់តឿន ក៏លោតកញ្ឆោលកាយខាងមុខ ផ្គងនូវជើងទាំងពីរខាងមុខ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង

អយំ ភិក្ខវេ បញ្ចមោ បុរិសទោសោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុំ ភិក្ខូ អាបត្តិយា ចោទេន្តិ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ អនាទយិត្វា សង្ឃំ អនាទ-យិត្វា ចោទកំ សាបត្តិកោវ យេនកាមំ បក្កមតិ សេយ្យថាបិ សោ ភិក្ខវេ អស្សខឡុង្កោ បេហីតិ វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា អនាទយិត្វា បតោទយដ្ឋឹ ទន្តេហិ មុខាធានំ វិធំសិត្វា យេនកាមំ បក្កមតិ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុរិសខឡុង្កោ ហោតិ អយំ ភិក្ខវេ ឆដ្ឋោ បុរិសទោសោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុំ ភិក្ខូ អាបត្តិយា ចោទេន្តិ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ នេវាហំ អាបន្នោម្ហិ ន បនាហំ អាបន្នោម្ហីតិ សោ តុណ្ហីភាវេន សង្ឃំ វិហេឋេតិ សេយ្យថាបិ សោ ភិក្ខវេ អស្សខឡុង្កោ បេហីតិ វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា

ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់បុរសទី ៥ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកភិក្ខុដាស់តឿនភិក្ខុផងគ្នា ដោយអាបត្តិ ភិក្ខុនោះកាលដែលភិក្ខុទាំងឡាយដាស់តឿន ដោយអាបត្តិ ក៏មិនអើពើនឹងសង្ឃ មិនអើ-ពើនឹងភិក្ខុអ្នកដាស់តឿន ដើរចេញទៅទាំងអាបត្តិ កាន់ទីតាមសេចក្តីប្រាថ្នា ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតនោះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏មិនអើពើនឹងជង់ជន្ទួញ ខាំផ្តាច់នូវខ្សែបង្ហៀរដោយធ្មេញទាំងឡាយ ហើយគេចចេញទៅតាមសេចក្តីប្រាថ្នា មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់បុរសទី ៦ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ពួកភិក្ខុដាស់តឿនភិក្ខុផងគ្នា ដោយអាបត្តិ ភិក្ខុនោះកាលដែលពួកភិក្ខុដាស់តឿនដោយអាបត្តិ ក៏ប្រកែកថាខ្ញុំមិនត្រូវអាបត្តិទេៗ ភិក្ខុនោះរមែងបៀតបៀននូវសង្ឃដោយតុណ្ហីភាព ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតនោះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន

នេវ អភិក្កមតិ នោ បដិក្កមតិ តត្ថេវ ខីលដ្ឋាយិដ្ឋិតោ ហោតិ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុរិសខឡុង្កោ ហោតិ អយំ ភិក្ខវេ សត្តមោ បុរិសខឡុង្កោ ។ បុន ចបរំ ភិក្ខវេ ភិក្ខុំ ភិក្ខូ អាបត្តិយា ចោទេន្តិ សោ ភិក្ខុ ភិក្ខូហិ អាបត្តិយា ចោទិយមានោ ឯវមាហ កឹ នុ ខោ តុម្ហេ អាយស្មន្តោ អតិពាឡ្ហំ មយិ ព្យាវដា យាវ ឥទានាហំ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិស្សាមីតិ សោ សិក្ខំ បច្ចក្ខាយ ហីនាយាវត្តិត្វា ឯវមាហ ឥទានិ ខោ តុម្ហេ អាយស្មន្តោ អត្តមនា ហោថាតិ សេយ្យថាបិ សោ ភិក្ខវេ អស្សខឡុង្កោ បេហីតិ វុត្តោ វិទ្ធោ សមានោ ចោទិតោ សារថិនា បុរិមេ វ ចាទេ សំហរិត្វា បច្ឆិមេ ចាទេ សំហរិត្វា តត្ថេវ ចត្តារោ ចាទេ អភិនិសីទតិ តថូបមាហំ ភិក្ខវេ ឥមំ បុគ្គលំ វទាមិ

ក៏មិនឈានទៅមុខ មិនឈានថយក្រោយ នៅឈរនឹងថ្កល់ ដូចជាសសរខឿន ក្នុងទីនោះដដែល មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះមានឧបមេយ្យដូច្នោះឯង ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់បុរសទី ៧ ។ ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ពួកភិក្ខុ ដាស់តឿនភិក្ខុផងគ្នា ដោយអាបត្តិ ភិក្ខុនោះ កាលដែលពួកភិក្ខុចោទដោយអាបត្តិ ក៏ពោលយ៉ាងនេះថា លោកទាំង-ឡាយដ៏មានអាយុ ហេតុអ្វីក៏បានជាខំខ្វល់ខ្វាយនឹងខ្ញុំខ្លាំងម៉្លេះ ណ្ហើយចុះ ខ្ញុំនឹងលាសិក្ខា ត្រឡប់មកកាន់ភេទថោកទាបវិញ ក្នុងឥឡូវនេះ ភិក្ខុនោះក៏លាសិក្ខា ហើយត្រឡប់មកកាន់ភេទថោកទាប រួចពោលយ៉ាងនេះថា ឥឡូវនេះ លោកទាំងឡាយដ៏មានអាយុ ចូរមានចិត្តត្រេកអរចុះ ម្នាលភិក្ខុទាំងឡាយ សេះមានពុតត្បុតនោះ កាលដែលនាយសារថីនិយាយថា ឯងចូរដើរទៅ ហើយចាក់ ដាស់តឿន ក៏កន្ដុញជើងទាំងពីរខាងមុខ កន្ដុញជើងទាំងពីរខាងក្រោយ ក្រាបសង្កត់នូវជើងទាំង ៤ ក្នុងទីនោះឯង មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុគ្គលនេះ មានឧបមេយ្យដូច្នោះឯង

ឯវរូបោបិ ភិក្ខវេ ឥធេកច្ចោ បុរិសខឡុង្កោ ហោតិ អយំ ភិក្ខវេ អដ្ឋមោ បុរិសទោសោ ។ ឥមេ ខោ ភិក្ខវេ អដ្ឋ បុរិសខឡុង្កា អដ្ឋ ច បុរិសទោសាតិ ។

[១៨] អដ្ឋិមានិ ភិក្ខវេ មលានិ ។ កតមានិ អដ្ឋ ។ អសជ្ឈាយមលា ភិក្ខវេ មន្តា អនុដ្ឋានមលា ភិក្ខវេ ឃរា មលំ ភិក្ខវេ វណ្ណស្ស កោសជ្ជំ បមាទោ ភិក្ខវេ រក្ខតោ មលំ មលំ ភិក្ខវេ ឥត្ថិយា ទុច្ចរិតំ មច្ឆេរំ ភិក្ខវេ ទទតោ មលំ មលា ភិក្ខវេ បាបកា អកុសលា ធម្មា អស្មឹ លោកេ បរម្ហិ ច តតោ ច ភិក្ខវេ មលា មលតរំ អវិជ្ជា បរមំ មលំ ។ ឥមានិ ខោ ភិក្ខវេ អដ្ឋ មលានីតិ ។

ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុតពួកខ្លះ ក្នុងលោកនេះ បែបនេះឯង ម្នាលភិក្ខុទាំងឡាយ នេះជាទោសរបស់បុរសទី ៨ ។ ម្នាលភិក្ខុទាំងឡាយ បុរសមានពុតត្បុត ៨ យ៉ាង និងទោសនៃបុរស ៨ យ៉ាងនេះឯង ។

[១៥] ម្នាលភិក្ខុទាំងឡាយ មន្ទិលនេះមាន ៨ យ៉ាង ។ មន្ទិល ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មន្តទាំងឡាយ មានការមិនស្វាធ្យាយ ជាមន្ទិល ១ ម្នាលភិក្ខុទាំងឡាយ ផ្ទះទាំងឡាយមានការមិនថែទាំ ជាមន្ទិល ១ ម្នាលភិក្ខុទាំងឡាយ ការខ្ជិលច្រអូស ជាមន្ទិលនៃសម្បុរសវីរៈ ១ ម្នាលភិក្ខុទាំងឡាយ ការប្រហែសធ្វេស ជាមន្ទិលនៃអ្នកថែរក្សា ១ ម្នាលភិក្ខុទាំងឡាយ ការប្រព្រឹត្តអាក្រក់ [១] (ចំពោះប្តី) ជាមន្ទិលរបស់ស្ត្រី ១ ម្នាលភិក្ខុទាំងឡាយ សេចក្តីកំណាញ់ ជាមន្ទិលរបស់អ្នកឲ្យ ១ ម្នាលភិក្ខុទាំងឡាយ អកុសលធម៌ដ៏លាមក ជាមន្ទិលក្នុងលោកនេះនិងលោកខាងមុខ ១ ម្នាលភិក្ខុទាំងឡាយ មន្ទិលដ៏លើស ជាងមន្ទិលទាំងនោះគឺអវិជ្ជា ជាមន្ទិលយ៉ាងក្រៃលែង ១ ។ ម្នាលភិក្ខុទាំងឡាយ មន្ទិល ៨ យ៉ាងនេះឯង ។

---

១ - សំដៅយកការប្រព្រឹត្តក្បត់ចិត្តប្តី ។

អសជ្ឈាយមលា មន្តា អនុដ្ឋានមលា ឃរា
មលំ វណ្ណស្ស កោសជ្ជំ បមាទោ រក្ខតោ មលំ
មលិត្ថិយា ទុច្ចរិតំ មច្ឆេរំ ទទតោ មលំ
មលា វេ បាបកា ធម្មា អស្មឹ លោកេ បរម្ហិ ច
តតោ មលា មលតរំ អវិជ្ជា បរមំ មលន្តិ ។

[១៦] អដ្ឋហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ ទូតេយ្យំ គន្តុមរហតិ ។ កតមេហិ អដ្ឋហិ ។ ឥធ ភិក្ខវេ ភិក្ខុ សោតា ច ហោតិ សាវេតា ច ឧគ្គហេតា ច ធារេតា ច វិញ្ញាតា ច វិញ្ញាបេតា ច កុសលោ ច សហិតាសហិតស្ស នោ ច កលហការកោ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ទូតេយ្យំ គន្តុមរហតិ ។

មន្តទាំងឡាយ មានការមិនស្វាធ្យាយ ជាមន្ទិល ផ្ទះទាំង-ឡាយ មានការមិនថែទាំជាមន្ទិល ការខ្ជិលច្រអូស ជាមន្ទិលនៃពណ៌សម្បុរ ការប្រហែសធ្វេស ជាមន្ទិលនៃអ្នកថែរក្សា ការប្រព្រឹត្តអាក្រក់ (ចំពោះប្តី) ជាមន្ទិលរបស់ស្ត្រី សេចក្តីកំ-ណាញ់ ជាមន្ទិលរបស់អ្នកឲ្យ អកុសលធម៌ដ៏លាមក ជាមន្ទិលក្នុងលោកនេះ និងលោកខាងមុខ មន្ទិលដ៏លើសជាងមន្ទិលទាំងនោះគឺអវិជ្ជា ជាមន្ទិលយ៉ាងក្រៃលែង ។

[១៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាង ទើបគួរ ដើម្បីដល់នូវទូតកម្ម[១]បាន ។ ធម៌ ៨ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្តាប់ខ្លួនឯង ១ ជាអ្នកញុំាងបុគ្គលដទៃឲ្យស្តាប់ ១ ជាអ្នករៀនខ្លួនឯង ១ ជាអ្នកយល់ច្បាស់នូវសេចក្តីមានប្រយោជន៍ និងមិនមានប្រយោជន៍ ១ ជាអ្នកញុំាងបុគ្គលដទៃឲ្យយល់ច្បាស់នូវសេចក្តីមានប្រយោជន៍ និងមិនមានប្រយោជន៍ ១ ជាអ្នកឈ្លាសក្នុងអំពើមានប្រយោជន៍ និងមិនមានប្រយោជន៍ ១ ជាអ្នកមិនធ្វើនូវការឈ្លោះប្រកែក ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាងនេះ ទើបគួរ ដើម្បីដល់នូវទូតកម្មបាន ។

---

១ - បានសេចក្តីថាគួរធ្វើជាទូត គឺជាអ្នកទទួលពាក្យបណ្តាំ ។

អដ្ឋហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ សារីបុត្តោ ចូតេយ្យំ គន្តុមរហតិ ។ កតមេហិ អដ្ឋហិ ។ ឥធ ភិក្ខវេ សារីបុត្តោ សោតា ច ហោតិ សាវេតា ច ឧគ្គហេតា ច ធារេតា ច វិញ្ញាតា ច វិញ្ញាបេតា ច កុសលោ ច សហិតាសហិតស្ស នោ ច កលហ-ការកោ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតោ សារីបុត្តោ ចូតេយ្យំ គន្តុមរហតីតិ ។

យោ វេ ន ព្យាធតិ បត្វា បរិសំ ឧគ្គហាវាទិនំ
ន ច ហាបេតិ វចនំ ន ច ហាបេតិ សាសនំ
អសន្ទិទ្ធំ តេ ភណាតិ[១] បុច្ឆិតោ ន ច កុប្បតិ
ស វេ តាទិសកោ ភិក្ខុ ចូតេយ្យំ គន្តុមរហតីតិ ។

[១៧] អដ្ឋហិ ភិក្ខវេ អាការេហិ ឥត្ថី បុរិសំ ពន្ធតិ ។

១ ម. អសន្ទិទ្ធញ្ច ភណតិ ។

ម្នាលភិក្ខុទាំងឡាយ សារីបុត្រប្រកបដោយធម៌ ៨ យ៉ាង ទើបគួរដើម្បីដល់ទូតកម្មបាន ។ ធម៌ ៨ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ សារីបុត្រជាអ្នកស្ដាប់ខ្លួនឯង ១ ជាអ្នកញ៉ាំងបុគ្គលដទៃឲ្យស្ដាប់ ១ ជាអ្នករៀនខ្លួនឯង ១ ជាអ្នកចងចាំទុក ១ ជាអ្នកយល់ច្បាស់ (នូវសេចក្ដីមានប្រយោជន៍និងមិនមានប្រយោជន៍) ១ ជាអ្នកញ៉ាំងបុគ្គលដទៃឲ្យយល់ច្បាស់ (នូវសេចក្ដីមានប្រយោជន៍និងមិនមានប្រយោជន៍) ១ ជាអ្នកឈ្លាស ក្នុងអំពើមានប្រយោជន៍ និងមិនមានប្រយោជន៍ ១ ជាអ្នកមិនធ្វើនូវការឈ្លោះប្រកែក ១ ។ ម្នាលភិក្ខុទាំងឡាយ សារីបុត្រប្រកបដោយធម៌ ៨ យ៉ាងនេះឯង ទើបគួរ ដើម្បីដល់នូវទូតកម្មបាន ។

ភិក្ខុណានិយាយ ទៅរកបរិសទ្យ ដែលជាអ្នកពោលពាក្យ
លើកតម្កើង ក៏មិនតក់ស្លុតផង មិនឲ្យបាត់ពាក្យផង មិនឲ្យ
បាត់ពាក្យបណ្ដាំផង ពោលពាក្យ មិនឲ្យគេមានសេចក្ដី
សង្ស័យផង គេសួរមិនខឹងផង ភិក្ខុប្រាកដដូច្នោះនោះឯង
គួរដើម្បីដល់នូវទូតកម្មបាន ។

[១៧] ម្នាលភិក្ខុទាំងឡាយ ស្ត្រីតែងចងបុរសដោយអាការ ៨ យ៉ាង ។

កាតមេហិ អដ្ឋហិ ។ រូបេន ភិក្ខវេ ឥត្ថី បុរិសំ ពន្ធតិ ហសិតេន ភិក្ខវេ ឥត្ថី បុរិសំ ពន្ធតិ ភណិតេន ភិក្ខវេ ឥត្ថី បុរិសំ ពន្ធតិ គីតេន ភិក្ខវេ ឥត្ថី បុរិសំ ពន្ធតិ រោណ្ណេន ភិក្ខវេ ឥត្ថី បុរិសំ ពន្ធតិ អាកប្បេន ភិក្ខវេ ឥត្ថី បុរិសំ ពន្ធតិ វនភង្គេន ភិក្ខវេ ឥត្ថី បុរិសំ ពន្ធតិ ផស្សេន ភិក្ខវេ ឥត្ថី បុរិសំ ពន្ធតិ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហាការេហិ ឥត្ថី បុរិសំ ពន្ធតិ ។ តេហិ ភិក្ខវេ សត្តា សុពទ្ធា យេវ ចាសេន ពទ្ធាតិ ។

[១៨] អដ្ឋហិ ភិក្ខវេ អាការេហិ បុរិសោ ឥត្ថឹ ពន្ធតិ ។ កាតមេហិ អដ្ឋហិ ។ រូបេន ភិក្ខវេ បុរិសោ ឥត្ថឹ ពន្ធតិ ហសិតេន ភិក្ខវេ បុរិសោ ឥត្ថឹ ពន្ធតិ ភណិតេន ភិក្ខវេ បុរិសោ ឥត្ថឹ ពន្ធតិ គីតេន ភិក្ខវេ បុរិសោ ឥត្ថឹ ពន្ធតិ រោណ្ណេន ភិក្ខវេ បុរិសោ ឥត្ថឹ ពន្ធតិ អាកប្បេន ភិក្ខវេ បុរិសោ ឥត្ថឹ ពន្ធតិ

អាការ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចង់បុរសដោយរូប ១ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចង់បុរស ដោយសំណើច ១ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចង់បុរស ដោយនិយាយ ១ ម្នាលភិក្ខុទាំង-ឡាយ ស្ត្រីចង់បុរស ដោយចម្រៀង ១ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចង់បុរសដោយយំ ១ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចង់បុរស ដោយការស្អាង (មានវិធីស្លៀកពាក់ជាដើម) ១ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចង់បុរស ដោយគ្រឿងបណ្ណាការមានផ្កាឈើនិងផ្លែឈើ ដែលខ្លួនកាច់មកអំពីព្រៃ ១ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចង់បុរស ដោយផស្សៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ស្ត្រីចង់បុរស ដោយអាការ ៨ យ៉ាងនេះឯង ម្នាលភិក្ខុទាំង-ឡាយ ពួកសត្វដែលស្ត្រីចង់ក្រៀក ដោយអាការទាំង ៨ យ៉ាងនេះឯង ឈ្មោះថា ជាប់អន្ទាក់ ។

[១៨] ម្នាលភិក្ខុទាំងឡាយ បុរសចង់ស្ត្រី ដោយអាការ ៨ យ៉ាង ។ អាការ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ បុរសចង់ស្ត្រី ដោយរូប ១ ម្នាលភិក្ខុទាំងឡាយ បុរសចង់ស្ត្រី ដោយសំណើច ១ ម្នាលភិក្ខុទាំងឡាយ បុរសចង់ស្ត្រី ដោយនិយាយ ១ ម្នាលភិក្ខុទាំងឡាយ បុរសចង់ស្ត្រី ដោយចម្រៀង ១ ម្នាលភិក្ខុទាំងឡាយ បុរសចង់ស្ត្រី ដោយយំ ១ ម្នាលភិក្ខុទាំងឡាយ បុរសចង់ស្ត្រី ដោយការស្អាង ១

វេនភង្គេន ភិក្ខវេ បុរិសោ ឥត្ថឹ ពន្ធតិ ផស្សេន ភិក្ខវេ បុរិសោ ឥត្ថឹ ពន្ធតិ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហា-ការេហិ បុរិសោ ឥត្ថឹ ពន្ធតិ តេហិ ភិក្ខវេ សត្តា សុពទ្ធាយេវ ចាសេន ពទ្ធាតិ ។

[១៩] ឯកំ សមយំ ភគវា វេរញ្ជាយំ វិហរតិ នឡេរុបូចិមណ្ឌេ[១] ។ អថខោ បហារាទោ អសុរិន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតំ ខោ បហារាទំ អសុរិន្ទំ ភគវា ឯតទវោច អបិ[២] បន បហារាទ អសុរា មហាសមុទ្ទេ អភិរមន្តីតិ ។ អភិរមន្តិ ភន្តេ អសុរា មហាសមុទ្ទេតិ ។ កតិ បន បហារាទ មហាសមុទ្ទេ អច្ឆរិយា អព្ភុតធម្មា យេ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តីតិ ។ អដ្ឋ ភន្តេ មហាសមុទ្ទេ អច្ឆរិយា អព្ភុតធម្មា យេ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

១ ឱ. ម. នឡេរុបុចិមណ្ឌមូលេ ។ ២ ម. កិម្បន ។

ម្នាលភិក្ខុទាំងឡាយ បុរសចង់ស្ត្រី ដោយគ្រឿងបណ្ណាការ ដែលខ្លួនកាច់មកអំពីព្រៃ ១ ម្នាលភិក្ខុទាំងឡាយ បុរសចង់ស្ត្រី ដោយផស្សៈ ១ ។ ម្នាលភិក្ខុទាំងឡាយ បុរសចង់ស្ត្រី ដោយអាការ ៨ យ៉ាងនេះឯង ម្នាលភិក្ខុទាំងឡាយ ពួកសត្វដែលបុរសចង់ក្រៀក ដោយអាការ ៨ យ៉ាងនោះឯង ឈ្មោះថា ជាប់អន្ទាក់ ។

[១៩] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់នៅក្រោមដើមស្តៅជាលំនៅនៃនឡេរុយក្ខ ទៀបស្រុកវេរញ្ជា ។ គ្រានោះ បហារាទ អសុរិន្ទ (ស្តេចអសុរឈ្មោះបហារាទ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគហើយឋិតនៅក្នុងទីសមគួរ ។ លុះបហារាទ អសុរិន្ទឋិតនៅក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលបហារាទ ចុះពួកអសុរ តែងរីករាយ ក្នុងមហាសមុទ្រដែរ ឬ ។ បពិត្រព្រះអង្គដ៏ចម្រើន ពួកអសុរ តែងរីករាយ ក្នុងមហាសមុទ្រដែរ ។ ម្នាលបហារាទ ចុះក្នុងមហាសមុទ្រ មានហេតុជាអស្ចារ្យចម្លែកប៉ុន្មានយ៉ាងបានជាពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងមហាសមុទ្រ មានហេតុជាអស្ចារ្យ ចម្លែក ៨ យ៉ាង បានជាពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។

កតមេ អដ្ឋ ។ មហាសមុទ្ទោ ភន្តេ អនុបុព្វនិន្នោ អនុបុព្វបោណោ អនុបុព្វបព្ភារោ នាយតកេនេវ បបាតោ ។ យស្មិំ ភន្តេ មហាសមុទ្ទោ អនុបុព្វនិន្នោ អនុបុព្វបោណោ អនុបុព្វបព្ភារោ នាយតកេនេវ បបាតោ អយំ ភន្តេ មហាសមុទ្ទេ បឋមោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។ បុន ចបរំ ភន្តេ មហាសមុទ្ទោ ឋិតធម្មោ វេលន្នាតិវត្តតិ ។ យស្មិំ ភន្តេ មហាសមុទ្ទោ ឋិតធម្មោ វេលន្នាតិវត្តតិ អយំ ភន្តេ មហាសមុទ្ទេ ទុតិយោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។ បុន ចបរំ ភន្តេ មហាសមុទ្ទោ ន មតេន កុណបេន សំវត្តតិ[1] យំ ហោតិ មហាសមុទ្ទេ មតំ កុណបំ តំ ខិប្បមេវ តីរំ វាហេតិ

១ ឱ. ម. សំវសតិ ។

ហេតុជាអស្ចារ្យចម្លែក ៨ យ៉ាង តើដូចម្តេចខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន មហាសមុទ្រ មានទំនាបទៅដោយលំដាប់ មានទីជម្រាលទៅដោយលំដាប់ មានទីទេរទៅដោយលំដាប់ មិនមែនចោតជ្រៅទៅតែម្តង ដូចជាអណ្តូងទេ ។ បពិត្រព្រះអង្គដ៏ចម្រើន មហាសមុទ្រមានទំនាបទៅដោយលំដាប់ មានទីជម្រាលទៅដោយលំដាប់ មានទីទេរទៅដោយលំដាប់ មិនចោតជ្រៅទៅតែម្តង ដូចជាអណ្តូង ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុអស្ចារ្យទី ១ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត មហាសមុទ្រ មានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើង ឬ ជោរហួសច្រាំងទៅបាន ។ បពិត្រព្រះអង្គដ៏ចម្រើន មហាសមុទ្រ មានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើង ឬ ជោរហួសច្រាំងទៅបាន ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុអស្ចារ្យចម្លែកទី ២ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត មហាសមុទ្រ មិនដែលនៅរួមដោយសាកសពស្លាប់ទេ បើសាកសពស្លាប់ណាមានក្នុងមហាសមុទ្រ រលកតែងបន្សាត់សាកសពស្លាប់នោះ ទៅរកច្រាំង

ថលំ ឧស្សាទេតិ[១] ។ យម្បិ ភន្តេ មហាសមុទ្ទោ ន មតេន កុណបេន សំវត្តតិ យំ ហោតិ មហាសមុទ្ទេ មតំ កុណបំ តំ ខិប្បមេវ តីរំ វាហេតិ ថលំ ឧស្សាទេតិ អយំ ភន្តេ មហាសមុទ្ទេ តតិយោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។ បុន ចបរំ ភន្តេ យា កាចិ មហានទិយោ សេយ្យថីទំ គង្គា យមុនា អចិរវតី សរភូ មហី តា មហាសមុទ្ទំ បត្វា ជហន្តិ បុរិមានិ នាមគោត្តានិ មហាសមុទ្ទោត្វេវ សំខ្យំ គច្ឆន្តិ ។ យម្បិ ភន្តេ យា កាចិ មហានទិយោ សេយ្យថីទំ គង្គា ។ បេ ។ មហាសមុទ្ទោត្វេវ សំខ្យំ គច្ឆន្តិ អយំ ភន្តេ មហាសមុទ្ទេ ចតុត្ថោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។ បុន ចបរំ ភន្តេ យា កាចិ លោកេ សវន្តិយោ មហាសមុទ្ទំ អប្បេន្តិ

១ ម. ថលេ ឧស្សារេតិ ។

ផាត់ឡើងទៅលើគោកមួយរំពេច ។ បពិត្រព្រះអង្គដ៏ចម្រើន មហាសមុទ្រ មិនដែលនៅរួម ដោយសាកសពស្លាប់ បើសាកសពស្លាប់ណា មាននៅក្នុងមហាសមុទ្រ រលកតែងបន្សាត់សាកសពស្លាប់នោះ ទៅរកច្រាំង ផាត់ឡើងទៅលើគោកមួយរំពេច ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុអស្ចារ្យចម្លែកទី ៣ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ទន្លេធំៗ ទាំងឡាយណាមួយ គឺទន្លេគង្គា យមុនា អចិរវតី សរភូ មហី កាលបើទន្លេទាំងនោះ ហូរទៅដល់មហាសមុទ្រហើយ រមែងលះបង់នាមនិងគោត្រដើម (របស់ខ្លួន) ហើយដល់នូវកិរិយារាប់បញ្ចូលថា មហាសមុទ្រតែម្យ៉ាង ។ បពិត្រព្រះអង្គដ៏ចម្រើន ទន្លេធំៗ ទាំងឡាយណាមួយ គឺទន្លេគង្គា ។ បេ ។ ដល់នូវកិរិយារាប់ថា មហាសមុទ្រតែម្យ៉ាង ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុអស្ចារ្យចម្លែកទី ៤ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីក-រាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ទឹកទន្លេទាំងឡាយណាមួយក្នុងលោក ដែលហូរស្រោចទៅរកមហាសមុទ្រក្តី

យា ច(១) អន្តលិក្ខា ធារា បបតន្តិ ន តេន មហា-
សមុទ្ទស្ស ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ ។ យម្បិ ភន្តេ
យា កាចិ លោកេ សវន្តិយោ មហាសមុទ្ទំ អប្បេន្តិ
យា ច(២) អន្តលិក្ខា ធារា បបតន្តិ ន តេន មហា-
សមុទ្ទស្ស ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ អយំ ភន្តេ
មហាសមុទ្ទេ បញ្ចមោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា
ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។ បុន ចបរំ
ភន្តេ មហាសមុទ្ទោ ឯករសោ លោណរសោ ។ យម្បិ
ភន្តេ មហាសមុទ្ទោ ឯករសោ លោណរសោ អយំ ភន្តេ
មហាសមុទ្ទេ ឆដ្ឋោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា
ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។ បុន ចបរំ
ភន្តេ មហាសមុទ្ទោ ពហុរតនោ អនេករតនោ តត្រិមានិ
រតនានិ សេយ្យថីទំ មុត្តា មណិ វេឡុរិយោ(៣) សង្ខោ
សិលា បវាឡំ រជតំ ជាតរូបំ លោហិតង្គោ មសារគល្លំ ។

---

១-២ ឱ. ម. យា កាចិ ។ ៣ ឱ. ម. វេឡុរិយោ ។ អដ្ឋកថាយម្បិ ទិស្សតិ ។

ធារទឹកភ្លៀងទាំងឡាយណា ដែលហូរធ្លាក់ចុះមកអំពីអាកាសក្តី មហាសមុទ្រក៏មិនប្រាកដជាស្រក ឬ ពេញដោយទឹកទន្លេនិងធារទឹកភ្លៀងនោះឡើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ទឹកទន្លេទាំងឡាយណាមួយក្នុងលោក ដែលហូរស្រោច ទៅរកមហាសមុទ្រក្តី ធារទឹកភ្លៀងទាំងឡាយណា ដែលហូរធ្លាក់ចុះមកអំពីអាកាសក្តី មហាសមុទ្រ ក៏មិនប្រាកដជាស្រក ឬ ពេញដោយទឹកទន្លេនិងធារទឹកភ្លៀងនោះ ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុអស្ចារ្យចម្លែកទី ៥ ក្នុងមហាសមុទ្រដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត មហាសមុទ្រ មានរសតែមួយ គឺរសប្រៃ ។ បពិត្រព្រះអង្គដ៏ចម្រើន មហាសមុទ្រមានរសតែមួយ គឺរសប្រៃដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុ អស្ចារ្យចម្លែកទី ៦ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត មហាសមុទ្រ មានរតនៈ (ទ្រព្យជាគ្រឿងពេញចិត្ត) ច្រើនយ៉ាង មិនមែនមានតែរតនៈម្យ៉ាងទេ ឯរតនៈទាំងនេះ ដែលមាននៅក្នុងមហាសមុទ្រនោះ គឺកែវមុក្តា កែវមណី កែវពិទូរ្យ សង្ខ សិលា កែវប្រពាឡ ប្រាក់ មាស កែវក្រហម (ត្បូងទទឹម) និងកែវមរកត ។

យម្បិ ភន្តេ មហាសមុទ្ទោ ពហុរតនោ អនេករតនោ តត្រិមានិ រតនានិ សេយ្យថីទំ មុត្តា មណិ វេឡុរិយោ សង្ខោ សិលា បវាឡំ រជតំ ជាតរូបំ លោហិតង្កោ មសារគល្លំ អយំ ភន្តេ មហាសមុទ្ទេ សត្តមោ អច្ឆ-រិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។ បុន ចបរំ ភន្តេ មហាសមុទ្ទោ មហតំ ភូតានំ អាវាសោ តត្រិមេ ភូតា តិមិ តិមិង្គលា តិមិរ-មិង្គលា អសុរា នាគា គន្ធព្វា សន្តិ មហាសមុទ្ទេ យោជនសតិកាបិ អត្តភាវា ទ្វិយោជនសតិកាបិ អត្តភាវា តិយោជនសតិកាបិ អត្តភាវា ចតុយោជន-សតិកាបិ អត្តភាវា បញ្ចយោជនសតិកាបិ អត្តភាវា ។ យម្បិ ភន្តេ មហាសមុទ្ទោ មហតំ ភូតានំ អាវាសោ តត្រិមេ ភូតា តិមិ តិមិង្គលា តិមិរមិង្គលា អសុរា នាគា គន្ធព្វា សន្តិ មហាសមុទ្ទេ យោជន-សតិកាបិ អត្តភាវា ។ បេ ។ តិយោជនសតិកាបិ

បពិត្រព្រះអង្គដ៏ចម្រើន មហាសមុទ្រ មានរតនៈច្រើនយ៉ាង មិនមែនមានរតនៈម្យ៉ាងទេ ឯរតនៈទាំងនេះ ដែលមាននៅក្នុងមហាសមុទ្រនោះ គឺកែវមុក្តា កែវមណី កែវពិទូរ្យ សង្ខ សិលា កែវប្រពាឡ ប្រាក់ មាស កែវក្រហម និងកែវមរកត ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុអស្ចារ្យចម្លែកទី ៧ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន មួយវិញទៀត មហាសមុទ្រជាទីនៅអាស្រ័យនៃពួកសត្វធំៗ ជាច្រើន ពួកសត្វធំៗ ទាំងនេះ ដែលនៅក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គលៈ ឈ្មោះតិមិរមិង្គលៈ និងពួកអសុរ នាគ គន្ធព្វ ដែលមានក្នុងមហាសមុទ្រ មានអត្តភាព ១០០ យោជន៍ខ្លះ មានអត្តភាព ២០០ យោជន៍ខ្លះ មានអត្តភាព ៣០០ យោជន៍ខ្លះ មានអត្តភាព ៤០០ យោជន៍ខ្លះ មានអត្តភាព ៥០០ យោជន៍ខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន មហាសមុទ្រជាទីនៅអាស្រ័យនៃពួកសត្វធំៗ ជាច្រើន ពួកសត្វធំៗ ទាំងនេះ ដែលនៅអាស្រ័យក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គលៈ ឈ្មោះតិមិរមិង្គលៈនិងពួកអសុរ នាគ គន្ធព្វ ដែលមានក្នុងមហាសមុទ្រ មានអត្តភាព ១០០ យោជន៍ខ្លះ ។ បេ ។ មានអត្តភាព ៣០០ យោជន៍ខ្លះ

ចតុយោជនសតិកាបិ បញ្ចយោជនសតិកាបិ អត្តភាវា អយំ ភន្តេ មហាសមុទ្ទេ អដ្ឋមោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា អសុរា មហា-សមុទ្ទេ អភិរមន្តិ ។ ឥមេ ខោ ភន្តេ មហា-សមុទ្ទេ អដ្ឋ អច្ឆរិយា អព្ភុតធម្មា យេ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។ អបិ បន ភន្តេ ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តីតិ ។ អភិរមន្តិ បហារាទ ភិក្ខូ ឥមស្មឹ ធម្មវិនយេតិ ។ កតិ បន ភន្តេ ឥមស្មឹ ធម្មវិនយេ អច្ឆរិយា អព្ភុតធម្មា យេ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តីតិ ។ អដ្ឋ បហារាទ ឥមស្មឹ ធម្មវិនយេ អច្ឆរិយា អព្ភុតធម្មា យេ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។ កតមេ អដ្ឋ ។ សេយ្យថាបិ បហារាទ មហាសមុទ្ទោ អនុបុព្វនិន្នោ អនុបុព្វ-បោណោ អនុបុព្វបព្ភារោ នាយតកេនេវ បបាតោ

មានអត្តភាព ២០០ យោជន៍ខ្លះ មានអត្តភាព ៥០០ យោជន៍ខ្លះ ដោយហេតុណា បពិត្រព្រះអង្គដ៏ចម្រើន នេះជាហេតុអស្ចារ្យចម្លែក ទី ៨ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយ ក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុជាអស្ចារ្យចម្លែក ក្នុងមហាសមុទ្រ មាន ៨ យ៉ាងនេះឯង ដែលពួកអសុរឃើញហើយៗ តែងរីករាយ ក្នុងមហាសមុទ្រ ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះពួកភិក្ខុ តែងរីករាយ ក្នុងធម្មវិន័យនេះដែរឬ ។ ម្នាលបហារាទ ពួកភិក្ខុតែងរីករាយ ក្នុងធម្មវិន័យនេះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ក្នុងធម្មវិន័យនេះ មានហេតុជាអស្ចារ្យចម្លែក ប៉ុន្មានយ៉ាង ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ ក្នុងធម្ម-វិន័យនេះ មានហេតុជាអស្ចារ្យចម្លែក ៨ យ៉ាង ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។ ហេតុជាអស្ចារ្យចម្លែក ៨ យ៉ាង តើដូចម្តេច ។ ម្នាលបហារាទ មហាសមុទ្រដែលមានទំនាបទៅដោយលំដាប់ មានទីជម្រាលទៅដោយលំដាប់ មានទីទេរទៅដោយលំដាប់ មិនចោតជ្រោទៅតែម្តង ដូចអណ្តូងទេ យ៉ាងណាមិញ

ឯវមេវ ខោ បហារាទ ឥមស្មឹ ធម្មវិនយេ អនុបុព្វ-
សិក្ខា អនុបុព្វកិរិយា អនុបុព្វប្បដិបទា នាយតកេនេវ
អញ្ញាបដិវេធោ ។ យម្បិ បហារាទ ឥមស្មឹ ធម្មវិនយេ
អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វប្បដិបទា នាយ-
តកេនេវ អញ្ញាបដិវេធោ អយំ បហារាទ ឥមស្មឹ
ធម្មវិនយេ បឋមោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា
ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។ សេយ្យថាបិ
បហារាទ មហាសមុទ្ទោ ឋិតធម្មោ វេលំ នាតិវត្តតិ
ឯវមេវ ខោ បហារាទ យំ មយា សាវកានំ សិក្ខាបទំ
បញ្ញត្តំ តំ មម សាវកា ជីវិតហេតុបិ នាតិក្កមន្តិ ។
យម្បិ បហារាទ មយា សាវកានំ សិក្ខាបទំ បញ្ញត្តំ
តំ មម សាវកា ជីវិតហេតុបិ នាតិក្កមន្តិ អយំ បហារាទ
ឥមស្មឹ ធម្មវិនយេ ទុតិយោ អច្ឆរិយោ អព្ភុតធម្មោ យំ
ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។

ម្នាលបហារាទ ក្នុងធម្មវិន័យនេះ មានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្ដីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងអរហត្តផលតែម្ដងទេ ក៏យ៉ាងនោះដែរ ។ ម្នាលបហារាទ ក្នុងធម្មវិន័យនេះ មានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្ដីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងអរហត្តផលតែម្ដងទេ ដោយហេតុណា ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែកទី ១ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ មហាសមុទ្រដែលមានទឹកតាំងនៅនឹងជាធម្មតា មិនដែលឡើង ឬជោរហួសច្រាំងទៅ យ៉ាងណាមិញ ម្នាលបហារាទ សិក្ខាបទណាដែលតថាគត បានបញ្ញត្តដល់សាវ័កទាំងឡាយហើយ ពួកសាវ័កតថាគត សូម្បីមានហេតុដល់ជីវិត ក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទនោះឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលបហារាទ សិក្ខាបទណា ដែលតថាគតបានបញ្ញត្តដល់សាវ័កទាំងឡាយហើយ ពួកសាវ័កតថាគត សូម្បីមានហេតុដល់ជីវិត ក៏មិនហ៊ានប្រព្រឹត្តកន្លងសិក្ខាបទនោះ ដោយហេតុណា ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែកទី ២ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយក្នុងធម្មវិន័យនេះ ។

សេយ្យថាបិ បហារាទ មហាសមុទ្ទោ ន មតេន កុណ-
បេន សំវត្តតិ យំ ហោតិ មហាសមុទ្ទេ មតំ កុណបំ តំ
ខិប្បមេវ តីរំ វាហេតិ ថលំ ឧស្សារេតិ ឯវមេវ ខោ
បហារាទ យោ សោ បុគ្គលោ ទុស្សីលោ បាបធម្មោ
អសុចិសំកស្សរសមាចារោ បដិច្ឆន្នកម្មន្តោ អស្ស-
មណោ សមណប្បដិញ្ញោ អព្រហ្មចារី ព្រហ្មចារីបដិញ្ញោ
អន្តោបូតិ អវស្សុតោ កសម្ពុកជាតោ ន តេន សង្ឃោ
សំវសតិ ខិប្បមេវ នំ សន្និបតិត្វា ឧក្ខិបតិ កិញ្ចាបិ សោ
ហោតិ មជ្ឈេ ភិក្ខុសង្ឃស្ស និសិន្នោ អថខោ សោ
អារកាវ សង្ឃម្ហា សង្ឃោ ច តេន ។ យម្បិ បហារាទ
យោ សោ បុគ្គលោ ទុស្សីលោ បាបធម្មោ អសុចិ-
សំកស្សរសមាចារោ បដិច្ឆន្នកម្មន្តោ អស្សមណោ
សមណប្បដិញ្ញោ អព្រហ្មចារី ព្រហ្មចារីបដិញ្ញោ អន្តោ-
បូតិ អវស្សុតោ កសម្ពុកជាតោ ន តេន សង្ឃោ សំវត្តតិ

ម្នាលបហារាទ មហាសមុទ្រដែលមិននៅរួមដោយសាកសពស្លាប់ បើសាកសពស្លាប់ណា ដែលមានក្នុងមហាសមុទ្រ រលកតែងបន្សាត់សាកសពនោះទៅរកច្រាំង ផាត់ឡើងទៅលើគោកមួយរំពេច យ៉ាងណាមិញ ម្នាលបហារាទ បុគ្គលណាជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ មានមារយាទមិនស្អាត គួរឲ្យគេរង្កៀស បិទបាំងអំពើអាក្រក់ទុក មិនមែនជាសមណៈ ប្តេជ្ញាខ្លួនថាជាសមណៈ ជាអ្នកប្រព្រឹត្តធម៌មិនប្រសើរ ប្តេជ្ញាខ្លួនជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយក្នុង មានចិត្តជោកដោយរាគៈ ក្រខ្វក់ដូចសំរាម សង្ឃនៅរួមជាមួយនឹងបុគ្គលនោះមិនបាន សង្ឃតែងប្រជុំគ្នានាំយកបុគ្គលនោះចេញមួយរំពេច បុគ្គលនោះទុកជាអង្គុយនៅក្នុងកណ្តាលជំនុំសង្ឃពិតមែន ប៉ុន្តែ បុគ្គលនោះឈ្មោះថានៅឆ្ងាយអំពីសង្ឃ ចំណែកខាងសង្ឃ ក៏ឈ្មោះថានៅឆ្ងាយអំពីបុគ្គលនោះដែរ ។ ម្នាលបហារាទ បុគ្គលណាជាអ្នកទ្រុស្តសីល មានធម៌អាក្រក់ មានមារយាទមិនស្អាត គួរឲ្យគេរង្កៀស បិទបាំងអំពើអាក្រក់ទុក មិនមែនជាសមណៈ ប្តេជ្ញាខ្លួនថាជាសមណៈ ជាអ្នកប្រព្រឹត្តធម៌មិនប្រសើរ ប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយក្នុង មានចិត្តជោកដោយរាគៈ ក្រខ្វក់ដូចសំរាម សង្ឃនៅរួមជាមួយនឹងបុគ្គលនោះ មិនបាន

ខិប្បមេវ នំ សន្និបតិត្វា ឧក្ខិបតិ កិញ្ចាបិ សោ ហោតិ មជ្ឈេ ភិក្ខុសង្ឃស្ស និសិន្នោ អថខោ សោ អារកាវ សង្ឃម្ហា សង្ឃោ ច តេន អយំ បហារាទ ឥមស្មឹ ធម្មវិនយេ តតិយោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។ សេយ្យថាបិ បហារាទ យា កាចិ មហានទិយោ សេយ្យថីទំ គង្គា យមុនា អចិរវតី សរភូ មហី តា មហាសមុទ្ទំ បត្វា ជហន្តិ បុរិមានិ នាមគោត្តានិ មហាសមុទ្ទោត្វេវ សំខ្យំ គច្ឆន្តិ ឯវមេវ ខោ បហារាទ ចត្តារោមេ វណ្ណា ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា តេ តថាគតប្បវេទិតេ ធម្ម-វិនយេ អគារស្មា អនគារិយំ បព្វជិត្វា ជហន្តិ បុរិមានិ នាមគោត្តានិ សមណោ សក្យបុត្តិយោត្វេវ សំខ្យំ គច្ឆន្តិ ។ យម្បិ បហារាទ ចត្តារោមេ វណ្ណា ខត្តិយា ព្រាហ្មណា វេស្សា សុទ្ទា តេ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិត្វា ជហន្តិ

សង្ឃតែងប្រជុំគ្នា នាំយកបុគ្គលនោះចេញមួយរំពេច បុគ្គលនោះទុកជាអង្គុយនៅក្នុងកណ្តាលជំនុំសង្ឃពិតមែន ប៉ុន្តែបុគ្គលនោះឈ្មោះថានៅឆ្ងាយអំពីសង្ឃ ចំណែកខាងសង្ឃក៏ឈ្មោះថា នៅឆ្ងាយអំពីបុគ្គលនោះ ដោយហេតុណា ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែកទី ៣ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ ទន្លេធំៗ ទាំងឡាយណាមួយ គឺទន្លេ គង្គា យមុនា អចិរវតី សរភូ មហី កាលបើទន្លេទាំងនោះ ហូរចូលទៅដល់មហាសមុទ្រហើយ តែងលះបង់នាមនិងគោត្រដើម (របស់ខ្លួន) ហើយដល់នូវកិរិយារាប់ថាជាមហាសមុទ្រតែម្យ៉ាង យ៉ាងណាមិញ ម្នាលបហារាទ វណ្ណៈគឺត្រកូល ៤ ពួកនេះ គឺក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ បើវណ្ណៈទាំងនោះចេញចាកផ្ទះបួស ក្នុងធម្មវិន័យ ដែលតថាគតសម្តែងហើយ រមែងលះបង់នាមនិងគោត្រដើម (របស់ខ្លួន) ហើយដល់នូវកិរិយារាប់ថាជាសមណសក្យបុត្រតែម្យ៉ាង ក៏យ៉ាងនោះដែរ ។ ម្នាលបហារាទ វណ្ណៈ ៤ ពួកនេះគឺ ក្សត្រិយ៍ ១ ព្រាហ្មណ៍ ១ វេស្សៈ ១ សុទ្ទៈ ១ វណ្ណៈទាំងនោះចេញចាកផ្ទះបួស ក្នុងធម្មវិន័យ ដែលតថាគតសម្តែងហើយ

បុរិមានិ នាមគោត្តានិ សមណោ សក្យបុត្តិយោត្វេវ សំខ្យំ គច្ឆន្តិ អយម្បិ បហារាទ ឥមស្មឹ ធម្មវិនយេ ចតុត្ថោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។ សេយ្យថាបិ បហារាទ យា កាចិ លោកេ សវន្តិយោ មហាសមុទ្ទំ អប្បេន្តិ យា ច អន្តលិក្ខា ធារា បបតន្តិ ន តេន មហាសមុទ្ទស្ស ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ ឯវមេវ ខោ បហារាទ ពហូ ចេបិ ភិក្ខូ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយន្តិ ន តេន និព្វានធាតុយា ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ ។ យម្បិ បហារាទ ពហូ ចេបិ ភិក្ខូ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយន្តិ ន តេន និព្វានធាតុយា ឩនត្តំ វា បូរត្តំ វា បញ្ញាយតិ អយំ បហារាទ ឥមស្មឹ ធម្មវិនយេ បញ្ចមោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។ សេយ្យថាបិ បហារាទ មហាសមុទ្ទោ ឯករសោ លោណរសោ ឯវមេវ ខោ បហារាទ អយំ ធម្មវិនយោ ឯករសោ វិមុត្តិរសោ ។

រមែងលះបង់នាមនិងគោត្រដើម (របស់ខ្លួន) ដល់នូវកិរិយារាប់ថាជាសមណសក្យបុត្រតែម្យ៉ាង ដោយហេតុណា ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែក ទី ៤ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ ទឹកទន្លេទាំងឡាយណាមួយក្នុងលោក ដែលហូរស្រោចចុះទៅ កាន់មហាសមុទ្រក្តី ធារទឹកភ្លៀងទាំងឡាយណា ដែលធ្លាក់ចុះមកអំពីអាកាសក្តី មហាសមុទ្រក៏មិនប្រាកដជាស្រក ឬពេញដោយទឹកនោះ យ៉ាងណាមិញ ម្នាលបហារាទ ទោះបី ពួកភិក្ខុច្រើនរូបបរិនិព្វានដោយអនុបាទិសេសនិព្វានធាតុ និព្វានធាតុក៏មិនប្រាកដជាខ្វះ ឬពេញ ដោយភិក្ខុទាំងនោះ ក៏យ៉ាងនោះដែរ ។ ម្នាលបហារាទ ទោះបី ពួកភិក្ខុច្រើនរូបបរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ និព្វានធាតុក៏មិនប្រាកដជាខ្វះ ឬពេញដោយភិក្ខុទាំងនោះ ដោយហេតុណា ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែកទី ៥ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ មហាសមុទ្រ ដែលមានរសតែមួយ គឺរសប្រៃ យ៉ាងណាមិញ ម្នាលបហារាទ ធម្មវិន័យនេះមានរសតែមួយ គឺវិមុត្តិរស ក៏យ៉ាងនោះដែរ ។

យម្បិ បហារាទ អយំ ធម្មវិនយោ ឯករសោ វិមុត្តិរសោ អយំ បហារាទ ឥមស្មឹ ធម្មវិនយេ ឆដ្ឋោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។ សេយ្យថាបិ បហារាទ មហាសមុទ្ទោ ពហុរតនោ អនេករតនោ តត្រិមានិ រតនានិ សេយ្យថីទំ មុត្តា មណិ វេឡុរិយោ សង្ខោ សិលា បវាឡំ រជតំ ជាតរូបំ លោហិតង្កោ មសារគល្លំ ឯវមេវ ខោ បហារាទ អយំ ធម្មវិនយោ ពហុរតនោ អនេករតនោ តត្រិមានិ រតនានិ សេយ្យថីទំ ចត្តារោ សតិ-ប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ ។ យម្បិ បហារាទ អយំ ធម្មវិនយោ ពហុរតនោ អនេករតនោ តត្រិមានិ រតនានិ សេយ្យថីទំ ចត្តារោ សតិប្បដ្ឋានា ចត្តារោ សម្មប្បធានា ចត្តារោ ឥទ្ធិបាទា បញ្ចិន្ទ្រិយានិ បញ្ច ពលានិ សត្ត ពោជ្ឈង្គា អរិយោ អដ្ឋង្គិកោ មគ្គោ

ម្នាលបហារាទ ធម្មវិន័យនេះ មានរសតែមួយគឺវិមុត្តិរស ដោយហេតុណា ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែកទី ៦ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ មហាសមុទ្រ មានរតនៈច្រើនយ៉ាង មិនមែនមានតែមួយទេ រតនៈទាំងនេះ ក្នុងមហាសមុទ្រនោះគឺកែវមុក្តា កែវមណី កែវពិទូរ្យ ស័ង្ខ សិលា កែវប្រពាឡ ប្រាក់ មាស កែវក្រហម (ត្បូងទទឹម) កែវមរកត យ៉ាងណាមិញ ម្នាលបហារាទ ធម្មវិន័យនេះ មានរតនៈច្រើនយ៉ាង មិនមែនមានត្រឹមតែមួយទេ រតនៈទាំងនេះក្នុងធម្មវិន័យនោះ គឺសតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ និងមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ក៏យ៉ាងនោះដែរ ។ ម្នាលបហារាទ ធម្មវិន័យនេះ មានរតនៈច្រើនយ៉ាង មិនមែនមានត្រឹមតែមួយទេ រតនៈទាំងនេះក្នុងធម្មវិន័យនោះគឺ សតិប្បដ្ឋាន ៤ សម្មប្បធាន ៤ ឥទ្ធិបាទ ៤ ឥន្ទ្រិយ ៥ ពលៈ ៥ ពោជ្ឈង្គ ៧ មគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដោយហេតុណា

អយំ បហារាទ ឥមស្មឹ ធម្មវិនយេ សត្តមោ អច្ឆរិយោ
អព្ភុតធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ
អភិរមន្តិ ។ សេយ្យថាបិ បហារាទ មហាសមុទ្ទោ
មហតំ ភូតានំ អាវាសោ តត្រិមេ ភូតា តិមិ តិមិង្គលា
តិមិរមិង្គលា អសុរា នាគា គន្ធព្វា សន្តិ មហាសមុទ្ទេ
យោជនសតិកាបិ អត្តភាវា ទ្វិយោជនសតិកាបិ អត្ត-
ភាវា តិយោជនសតិកាបិ អត្តភាវា ចតុយោជនសតិ-
កាបិ អត្តភាវា បញ្ចយោជនសតិកាបិ អត្តភាវា ឯវមេវ
ខោ បហារាទ អយំ ធម្មវិនយោ មហតំ ភូតានំ អាវាសោ
តត្រិមេ ភូតា សោតាបន្នោ សោតាបត្តិផលសច្ឆិ-
កិរិយាយ បដិបន្នោ សកទាគាមី សកទាគាមិផល-
សច្ឆិកិរិយាយ បដិបន្នោ អនាគាមី អនាគាមិផល-
សច្ឆិកិរិយាយ បដិបន្នោ អរហា អរហត្តាយ បដិបន្នោ ។

ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែកទី ៧ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ មហាសមុទ្រដែលជាទីនៅអាស្រ័យនៃពួកសត្វធំៗ ជាច្រើនពួក សត្វធំៗ ទាំងនេះ ដែលនៅក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គលៈ ឈ្មោះតិមិរមិង្គលៈ និងពួកអសុរ នាគ គន្ធព្វ ដែលមានក្នុងមហាសមុទ្រ មានអត្តភាព ១០០ យោជន៍ខ្លះ មានអត្តភាព ២០០ យោជន៍ខ្លះ មានអត្តភាព ៣០០ យោជន៍ខ្លះ មានអត្តភាព ៤០០ យោជន៍ខ្លះ មានអត្តភាព ៥០០ យោជន៍ខ្លះ យ៉ាងណាមិញ ម្នាលបហារាទ ធម្មវិន័យនេះ ជាទីនៅអាស្រ័យនៃពួកបុគ្គលធំៗ ជាច្រើន បុគ្គលទាំងនេះក្នុងធម្មវិន័យនោះគឺ សោតាបន្នបុគ្គលនិងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល សកទាគាមិបុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទាគាមិផល អនាគាមិបុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល អរហន្ត និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីភាវៈនៃខ្លួនជាអរហន្ត ក៏យ៉ាងនេះដែរ ។

យម្បិ បហារាទ អយំ ធម្មវិនយោ មហាតំ ភូតានំ អាវាសោ តត្រិមេ ភូតា សោតាបន្នោ សោតាបត្តិផល-សច្ឆិកិរិយាយ បដិបន្នោ សកទាគាមី សកទាគាមិ-ផលសច្ឆិកិរិយាយ បដិបន្នោ អនាគាមី អនាគាមិ-ផលសច្ឆិកិរិយាយ បដិបន្នោ អរហា អរហត្តាយ បដិបន្នោ អយំ បហារាទ ឥមស្មឹ ធម្មវិនយេ អដ្ឋមោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។ ឥមេ ខោ បហារាទ ឥមស្មឹ ធម្មវិនយេ អដ្ឋ អច្ឆរិយា អព្ភុតធម្មា យេ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តីតិ ។

[២០] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុប្បាសាទេ ។ តេន ខោ បន សមយេន ភគវា តទហុបោសថេ ភិក្ខុសង្ឃ-បរិវុតោ និសិន្នោ ហោតិ ។ អថខោ អាយស្មា អានន្ទោ អភិក្កន្តាយ រត្តិយា និក្ខន្តេ បឋមេ យាមេ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា

ម្នាលបហារាទ ធម្មវិន័យនេះ ជាទីនៅអាស្រ័យនៃពួកបុគ្គលធំៗ ជាច្រើន បុគ្គលទាំងនេះ ក្នុងធម្មវិន័យនោះ គឺសោតាបន្នបុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល សកទាគាមិ-បុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសកទា-គាមិផល អនាគាមិបុគ្គលនិងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល អរហន្តនិងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីភាវៈនៃខ្លួនជាអរហន្ត ដោយហេតុណា ម្នាលបហារាទ នេះជាហេតុអស្ចារ្យចម្លែកទី ៨ ក្នុងធម្មវិន័យនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីក-រាយ ក្នុងធម្មវិន័យនេះ ។ ម្នាលបហារាទ ក្នុងធម្មវិន័យនេះ មានហេតុជាអស្ចារ្យចម្លែកទាំង ៨ យ៉ាងនេះឯង ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។

[២០] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងមិគារ-មាតុប្រាសាទ ក្នុងបុព្វារាម ទៀបក្រុងសាវត្ថី ។ សម័យនោះឯង ព្រះដ៏មានព្រះភាគ មានភិក្ខុសង្ឃចោមរោម ទ្រង់គង់ក្នុងឧបោសថថ្ងៃនោះ ។ លុះវេលារាត្រី អស់ហើយ បឋមយាម កន្លងទៅហើយ ព្រះអានន្ទដ៏មានអាយុ ក៏ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង

១០០



យេន ភគវា តេនញ្ជលឹ បណាមេត្វា ភគវន្តំ ឯតទវោច អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បឋមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខូនំ ចាតិមោក្ខន្តិ ។ ឯវំ វុត្តេ ភគវា តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ អាយស្មា អានន្ទោ អភិក្កន្តាយ រត្តិយា និក្ខន្តេ មជ្ឈិមេ យាមេ ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលឹ បណាមេត្វា ភគវន្តំ ឯតទវោច អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ មជ្ឈិមោ យាមោ ចិរនិសិន្នោ ភិក្ខុសង្ឃោ ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខូនំ ចាតិមោក្ខន្តិ ។ ទុតិយម្បិ ខោ ភគវា តុណ្ហី អហោសិ ។ តតិយម្បិ ខោ អាយស្មា អានន្ទោ អភិក្កន្តាយ រត្តិយា និក្ខន្តេ បច្ឆិមេ យាមេ ឧទ្ធស្តេ អរុណេ នន្ទិមុខិយា រត្តិយា ឧដ្ឋាយាសនា ឯកំសំ ឧត្តរាសង្គំ ករិត្វា យេន ភគវា តេនញ្ជលឹ បណាមេត្វា ភគវន្តំ ឯតទវោច

លើកអញ្ជលីប្រណម្យ ចំពោះព្រះដ៏មានព្រះភាគ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រីអស់ហើយ បឋមយាម កន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់សម្តែងបាតិមោក្ខដល់ភិក្ខុទាំងឡាយ ។ កាលដែលព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគក៏គង់ស្ងៀម ។ កាលបើវេលារាត្រី អស់ហើយ មជ្ឈិមយាម កន្លងទៅហើយ ព្រះអានន្ទដ៏មានអាយុ ក៏ក្រោកចាកអាសនៈ ធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង លើកអញ្ជលីប្រណម្យ ចំពោះព្រះដ៏មានព្រះភាគ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ អស់វារៈជាគម្រប់ពីរដងទៀតថា បពិត្រព្រះអង្គដ៏ចម្រើន វេលារាត្រី អស់ហើយ មជ្ឈិមយាម កន្លងទៅហើយ ភិក្ខុសង្ឃអង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ សម្តែងបាតិមោក្ខដល់ភិក្ខុទាំងឡាយ ។ ព្រះដ៏មានព្រះភាគ ទ្រង់គង់ស្ងៀមអស់វារៈ ជាគម្រប់ពីរដង ។ កាលបើវេលារាត្រី អស់ហើយ បច្ឆិមយាម កន្លងទៅហើយ រាត្រីប្រាកដដូចជាមានមុខស្រស់ (បំព្រង) ក្នុងពេលដែលអរុណរះឡើង ព្រះអានន្ទដ៏មានអាយុ ក៏ក្រោកចាកអាសនៈ ហើយធ្វើឧត្តរាសង្គៈឆៀងស្មាម្ខាង លើកអញ្ជលី ប្រណម្យ ចំពោះព្រះដ៏មានព្រះភាគ ក្រាបបង្គំទូល ព្រះដ៏មានព្រះភាគ អស់វារៈជាគម្រប់ ៣ ដងទៀតដូច្នេះថា

បណ្ណាសកេ មហាវគ្គោ

អភិក្កន្តា ភន្តេ រត្តិ និក្ខន្តោ បច្ឆិមោ យាមោ ឧទ្ធស្តំ អរុណំ នន្ទិមុខី រត្តិ ចិរនិសិន្នោ ភិក្ខុសង្ឃោ ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខូនំ បាតិមោក្ខន្តិ ។ អបរិសុទ្ធា អានន្ទ បរិសាតិ ។ អថខោ អាយស្មតោ មហាមោគ្គល្លានស្ស ឯតទហោសិ កំ នុ ខោ ភគវា បុគ្គលំ សន្ធាយ ឯវ-មាហ អបរិសុទ្ធា អានន្ទ បរិសាតិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ សព្វាវន្តំ ភិក្ខុសង្ឃំ ចេតសា ចេតោ បរិច្ច មនសាកាសិ ។ អទ្ទសា ខោ អាយស្មា មហាមោគ្គល្លានោ តំ បុគ្គលំ ទុស្សីលំ បាបធម្មំ អសុចិសំកស្សរសមាចារំ បដិច្ឆន្នកម្មន្តំ អស្សមណំ សមណបដិញ្ញំ អព្រហ្មចារឹ ព្រហ្មចារីបដិញ្ញំ អន្តោបូតឹ អវស្សុតំ កសម្ពុកជាតំ មជ្ឈេ ភិក្ខុសង្ឃស្ស និសិន្នំ ទិស្វា ឧដ្ឋាយាសនា យេន សោ បុគ្គលោ តេនុបសង្កមិ ឧបសង្កមិត្វា តំ បុគ្គលំ ឯតទវោច

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះរាត្រី អស់ហើយ បច្ឆិមយាមកន្លងទៅហើយ អរុណក៏រះហើយ រាត្រីក៏ប្រាកដដូចជាមុខស្រស់ហើយ ភិក្ខុសង្ឃក៏អង្គុយចាំយូរហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់សម្តែងបាតិមោក្ខដល់ភិក្ខុទាំងឡាយ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ មានបរិសទ្យមិនបរិសុទ្ធទេ ។ គ្រានោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ព្រះដ៏មានព្រះភាគ ទ្រង់ដៅយកបុគ្គលណាហ្ន៎ បានជាទ្រង់ត្រាស់ថា ម្នាលអានន្ទ បរិសទ្យ មិនបរិសុទ្ធទេយ៉ាងនេះ ។ លំដាប់នោះ ព្រះមហាមោគ្គល្លានដ៏មានអាយុ ស្ទង់មើលចិត្ត (របស់ភិក្ខុសង្ឃ) ដោយចិត្ត (របស់លោក) ហើយធ្វើទុកក្នុងចិត្តចំពោះភិក្ខុ-សង្ឃទាំងអស់នោះ ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ បានឃើញបុគ្គលនោះទ្រុស្តសីល មានធម៌លាមក មានមារយាទមិនស្អាត គួរឲ្យរង្កៀស មានអំពើអាក្រក់បិទបាំងទុក មិនមែនជាសមណៈ ប្តេជ្ញាខ្លួនថាជាសមណៈ ប្រព្រឹត្តធម៌មិនប្រសើរ ប្តេជ្ញាខ្លួនថាជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ស្អុយក្នុង មានចិត្តជោកដោយរាគៈ ក្រខ្វក់ដូចសំរាម អង្គុយនៅក្នុងកណ្តាលភិក្ខុសង្ឃ លុះឃើញហើយ ក៏ក្រោកចាកអាសនៈចូលទៅរកបុគ្គលនោះ លុះចូលទៅជិតហើយ ក៏ពោលចំពោះទៅបុគ្គលនោះដូច្នេះថា

ឧដ្ឋេហាវុសោ ទិដ្ឋោសិ ភគវតា នត្ថិ តេ ភិក្ខូហិ សទ្ធឹ សំវាសោតិ ។ ឯវំ វុត្តេ សោ បុគ្គលោ តុណ្ហី អហោសិ ។ ទុតិយម្បិ ខោ អាយស្មា មហាមោគ្គល្លានោ តំ បុគ្គលំ ឯតទវោច ឧដ្ឋេហាវុសោ ទិដ្ឋោសិ ភគវតា នត្ថិ តេ ភិក្ខូហិ សទ្ធឹ សំវាសោតិ ។ ទុតិយម្បិ ខោ សោ បុគ្គលោ តុណ្ហី អហោសិ ។ តតិយម្បិ ខោ អាយស្មា មហាមោគ្គល្លានោ តំ បុគ្គលំ ឯតទវោច ឧដ្ឋេហាវុសោ ទិដ្ឋោសិ ភគវតា នត្ថិ តេ ភិក្ខូហិ សទ្ធឹ សំវាសោតិ ។ តតិយម្បិ ខោ សោ បុគ្គលោ តុណ្ហី អហោសិ ។ អថខោ អាយស្មា មហាមោគ្គល្លានោ តំ បុគ្គលំ ពាហាយំ គហេត្វា ពហិទ្វារកោដ្ឋកា និក្ខាមេត្វា សូចិឃដិកំ ទត្វា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ ឯតទវោច និក្ខាមិតោ សោ ភន្តេ បុគ្គលោ មយា បរិសុទ្ធា បរិសា ឧទ្ទិសតុ ភន្តេ ភគវា ភិក្ខូនំ បាតិមោក្ខន្តិ ។

នែអាវុសោ អ្នកចូរក្រោកចេញ ដ្បិតព្រះដ៏មានព្រះភាគទ្រង់បានឃើញអ្នកច្បាស់ហើយ អ្នកលែងបាននៅរួមជាមួយនឹងភិក្ខុទាំងឡាយហើយ ។ កាលដែលព្រះមហាមោគ្គល្លាន ពោលយ៉ាងនេះហើយ បុគ្គលនោះក៏នៅស្ងៀម ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ បាននិយាយនឹងបុគ្គលនោះជាគម្រប់ពីរដងទៀតដូច្នេះថា នែអាវុសោ អ្នកចូរក្រោកចេញ ដ្បិតព្រះដ៏មានព្រះភាគទ្រង់បានឃើញអ្នកច្បាស់ហើយ អ្នកលែងបាននៅរួមជាមួយនឹងភិក្ខុទាំងឡាយហើយ ។ បុគ្គលនោះក៏នៅស្ងៀម អស់វារៈពីរដងទៀត ។ ព្រះមហាមោគ្គល្លានដ៏មានអាយុ បាននិយាយនឹងបុគ្គលនោះជាគម្រប់បីដងទៀតដូច្នេះថា នែអាវុសោ អ្នកចូរក្រោកចេញ ដ្បិតព្រះដ៏មានព្រះភាគទ្រង់បានឃើញអ្នកច្បាស់ហើយ អ្នកលែងបាននៅរួមជាមួយភិក្ខុទាំងឡាយទៀតហើយ ។ បុគ្គលនោះក៏នៅស្ងៀម អស់វារៈជាគម្រប់បីដងទៀត ។ ទើបព្រះមហាមោគ្គល្លានដ៏មានអាយុ ចាប់ដើមដៃបុគ្គលនោះទាញចេញទៅខាងក្រៅស៊ុមទ្វារ ហើយខ្ទាស់គន្លឹះនិងរនុកទ្វារ រួចចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គល (ទ្រុស្តសីល) នោះ ខ្ញុំព្រះអង្គបានបណ្តេញឲ្យដើរចេញហើយ ឥឡូវនេះ បរិសទ្យបរិសុទ្ធហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះអង្គទ្រង់សម្តែងបាតិមោក្ខដល់ភិក្ខុទាំងឡាយ ។

អច្ឆរិយំ មោគ្គល្លាន អព្ភុតំ មោគ្គល្លាន យាវតា[១] ពាហាគហណាបិ នាម សោ មោឃបុរិសោ អាគមិស្សតីតិ ។ អថខោ ភគវា ភិក្ខូ អាមន្តេសិ តុម្ហេវ ទានិ ភិក្ខវេ ឧបោសថំ ករេយ្យាថ បាតិមោក្ខំ ឧទ្ទិសេយ្យាថ ។ នទានាហំ ភិក្ខវេ អជ្ជតគ្គេ[២] បាតិមោក្ខំ ឧទ្ទិសិស្សាមិ ។ អដ្ឋានមេតំ ភិក្ខវេ អនវកាសោ យំ តថាគតោ អបរិសុទ្ធាយ បរិសាយ បាតិមោក្ខំ ឧទ្ទិសេយ្យ ។ អដ្ឋិមេ ភិក្ខវេ មហាសមុទ្ទេ អច្ឆរិយា អព្ភុតធម្មា យេ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។ កតមេ អដ្ឋ ។ មហាសមុទ្ទោ ភិក្ខវេ អនុបុព្វនិន្នោ អនុបុព្វបោណោ អនុបុព្វបព្ភារោ នាយតកោនេវ បបាតោ ។ យម្បិ ភិក្ខវេ មហាសមុទ្ទោ អនុបុព្វនិន្នោ អនុបុព្វបោណោ អនុបុព្វបព្ភារោ នាយតកោនេវ បបាតោ

១ ឱ. ម. យាវ ។ ២ ម. ឯត្ថន្តរេ ឧបោសថំ ករិស្សាមីតិ បាឋោ ទិស្សតិ ។

ព្រះអង្គទ្រង់ត្រាស់ថា ម្នាលមោគ្គល្លាន ហេតុនេះ អស្ចារ្យណាស់ ម្នាលមោគ្គល្លាន ហេតុនេះចម្លែកណាស់ មោឃបុរសនោះ មិនសមបើនឹងបង្អង់ទាល់តែចាប់ទាញដៃចេញសោះ ។ លំដាប់នោះ ព្រះមានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយគប្បីធ្វើឧបោសថ គប្បីសម្តែងបាតិមោក្ខចុះ ។ ម្នាលភិក្ខុទាំង-ឡាយ ឥឡូវនេះ តថាគត ឈប់សម្តែងបាតិមោក្ខ ចាប់ដើមតាំងអំពីថ្ងៃនេះតទៅ ។ ម្នាលភិក្ខុទាំងឡាយ ព្រះតថាគតគប្បីសម្តែងនូវបាតិមោក្ខដល់បរិសទ្យ មិនបរិសុទ្ធ ដោយហេតុណា ហេតុនុ៎ះមិនមែនជាឋានៈ មិនមែនជាបច្ច័យឡើយ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងមហាសមុទ្រ មានហេតុជាអស្ចារ្យចម្លែក ៨ យ៉ាងនេះ ដែលពួកអសុរឃើញហើយៗ តែងរីក-រាយក្នុងមហាសមុទ្រ ។ ហេតុជាអស្ចារ្យចម្លែក ៨ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ មានទំនាបទៅដោយលំដាប់ មានទីជម្រាលទៅដោយលំដាប់ មានទីទេរទៅដោយលំដាប់ មិនមែនចោតជ្រៅតែម្តង ដូចជាអណ្តូងទេ ។ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ មានទំនាបទៅដោយលំដាប់ មានទីជម្រាលទៅដោយលំដាប់ មានទីទេរទៅដោយលំដាប់ មិនមែនចោតជ្រៅទៅតែម្តង ដូចជាអណ្តូង ដោយហេតុណា

អយំ ភិក្ខវេ មហាសមុទ្ទេ បឋមោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។ យថា បុរិមេន(១) តថា វិត្ថារោ ។ បេ ។ បុន ចបរំ ភិក្ខវេ មហាសមុទ្ទោ មហតំ ភូតានំ អាវាសោ តត្រិមេ ភូតា តិមិ តិមិង្គលា តិមិរមិង្គលា អសុរា នាគា គន្ធព្វា សន្តិ មហាសមុទ្ទេ យោជនសតិកាបិ អត្តភាវា ។ បេ ។ បញ្ចយោជនសតិកាបិ អត្តភាវា ។ យម្បិ ភិក្ខវេ មហាសមុទ្ទោ មហតំ ភូតានំ អាវាសោ តត្រិមេ ភូតា តិមិ តិមិង្គលា តិមិរមិង្គលា អសុរា នាគា គន្ធព្វា សន្តិ មហាសមុទ្ទេ យោជនសតិកាបិ អត្តភាវា ។ បេ ។ បញ្ចយោជនសតិកាបិ អត្តភាវា អយំ ភិក្ខវេ មហាសមុទ្ទេ អដ្ឋមោ អច្ឆរិយោ អព្ភុតធម្មោ យំ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។

១ ម. បុរិមេ ។

ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ១ ក្នុងមហាសមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។ សេចក្តីពិស្តារដូចពាក្យខាងដើមដែរ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត មហាសមុទ្រ ជាទីនៅអាស្រ័យនៃពួកសត្វធំៗ ជាច្រើន ពួកសត្វធំៗ ទាំងនេះ ដែលនៅក្នុងមហាសមុទ្រនោះគឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គលៈ ឈ្មោះតិមិរមិង្គលៈ និងពួកអសុរ នាគ គន្ធព្វ ដែលមានអត្តភាព ១០០ យោជន៍ខ្លះ ។ បេ ។ មានអត្តភាព ៥០០ យោជន៍ខ្លះ តែងនៅក្នុងមហាសមុទ្រ ។ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ ជាទីនៅអាស្រ័យនៃពួកសត្វធំៗ ជាច្រើន ពួកសត្វធំៗ ទាំងនេះ ដែលនៅក្នុងមហាសមុទ្រនោះ គឺត្រីឈ្មោះតិមិ ឈ្មោះតិមិង្គលៈ ឈ្មោះតិមិរមិង្គលៈ និងពួកអសុរ នាគ គន្ធព្វ មានអត្តភាព ១០០ យោជន៍ខ្លះ ។ បេ ។ មានអត្ត-ភាព ៥០០ យោជន៍ខ្លះ តែងនៅក្នុងមហាសមុទ្រ ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ៨ ក្នុងមហា-សមុទ្រ ដែលពួកអសុរឃើញហើយៗ តែងរីករាយក្នុងមហាសមុទ្រ ។

ឥមេ ខោ ភិក្ខវេ មហាសមុទ្ទេ អដ្ឋ អច្ឆរិយា អព្ភុតធម្មា យេ ទិស្វា ទិស្វា អសុរា មហាសមុទ្ទេ អភិរមន្តិ ។ អដ្ឋិមេ[១] ភិក្ខវេ ឥមស្មឹ ធម្មវិនយេ អច្ឆរិយា អព្ភុតធម្មា យេ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។ កតមេ អដ្ឋ ។ សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ អនុបុព្វនិន្នោ អនុបុព្វពោណោ អនុបុព្វបព្ភារោ នាយតកេនេវ បបាតោ ឯវមេវ ខោ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វប្បដិបទា នាយតកេនេវ អញ្ញាបដិវេធោ ។ យម្បិ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ អនុបុព្វសិក្ខា អនុបុព្វកិរិយា អនុបុព្វប្បដិបទា នាយតកេនេវ អញ្ញាបដិវេធោ អយំ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ បឋមោ អច្ឆរិយោ អព្ភុតធម្មោ

---

១ ម. ឯវមេវ ខោ ភិក្ខវេ អដ្ឋ ឥមស្មឹ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងមហាសមុទ្រ មានហេតុជាអស្ចារ្យចម្លែក ៨ យ៉ាងនេះឯង ដែលពួកអសុរឃើញហើយៗ តែងរីករាយ ក្នុងមហា-សមុទ្រ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានហេតុជាអស្ចារ្យចម្លែក ៨ យ៉ាងនេះ ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។ ហេតុជាអស្ចារ្យចម្លែក ៨ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ ដែលមានទំនាបទៅដោយលំដាប់ មានទីជម្រាលទៅដោយលំដាប់ មានទីទេរទៅដោយលំដាប់ មិនចោតជ្រៅទៅតែម្ដង ដូចជាអណ្ដូង យ៉ាងណាមិញ ម្នាលភិក្ខុទាំង-ឡាយ ក្នុងធម្មវិន័យនេះ មានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្ដីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងនូវអរហត្តផលតែម្ដងទេ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានការសិក្សាដោយលំដាប់ មានកិច្ចដែលត្រូវធ្វើដោយលំដាប់ មានសេចក្ដីប្រតិបត្តិដោយលំដាប់ មិនមែនបានត្រាស់ដឹងនូវអរហត្តផលតែម្ដងទេ ដោយហេតុណា ម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ១ ក្នុងធម្មវិន័យនេះ

យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។ បេ ។ សេយ្យថាបិ ភិក្ខវេ មហាសមុទ្ទោ មហតំ ភូតានំ អាវាសោ តត្រិមេ ភូតា តិមិ តិមិង្គលា តិមិរមិង្គលា អសុរា នាគា គន្ធព្វា សន្តិ មហាសមុទ្ទេ យោជនសតិកាបិ អត្តភាវា ។ បេ ។ បញ្ចយោជនសតិកាបិ អត្តភាវា ឯវមេវ ខោ ភិក្ខវេ អយំ ធម្មវិនយោ មហតំ ភូតានំ អាវាសោ តត្រិមេ ភូតា សោតាបន្នោ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ ។ បេ ។ អរហា អរហត្តាយ បដិបន្នោ ។ យម្បិ ភិក្ខវេ អយំ ធម្មវិនយោ មហតំ ភូតានំ អាវាសោ តត្រិមេ ភូតា សោតាបន្នោ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ ។ បេ ។ អរហា អរហត្តាយ បដិបន្នោ អយំ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ អដ្ឋមោ អច្ឆរិយោ អព្ភុតធម្មោ

ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មហាសមុទ្រ ជាទីអាស្រ័យនៃពួកសត្វធំៗ ជាច្រើនពួកសត្វធំៗ ទាំងនេះ ដែលនៅក្នុងមហាសមុទ្រនោះ គឺ ត្រីឈ្មោះតិមិឈ្មោះតិមិង្គលៈ ឈ្មោះតិមិរមិង្គលៈ និងពួកអសុរ នាគ គន្ធព្វ ដែលមានអត្តភាព ១០០ យោជន៍ខ្លះ ។ បេ ។ មានអត្តភាព ៥០០ យោជន៍ខ្លះដែលនៅក្នុងមហាសមុទ្រ យ៉ាងណាមិញ ។ បេ ។ ម្នាលភិក្ខុទាំងឡាយធម្មវិន័យនេះ ជាទីនៅអាស្រ័យនៃពួកបុគ្គលធំៗ ជាច្រើនពួក បុគ្គលទាំងនេះ ក្នុងធម្មវិន័យនោះ គឺ សោតាបន្នបុគ្គល និងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផល ។ បេ ។ អរហន្តនិងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីភាវៈនៃខ្លួនជាអរហន្ត ក៏យ៉ាងនោះដែរ ។ម្នាលភិក្ខុទាំងឡាយ ធម្មវិន័យនេះ ជាទីនៅអាស្រ័យនៃពួកបុគ្គលធំៗ ជាច្រើន បុគ្គលទាំងនេះក្នុងធម្មវិន័យនោះ គឺសោតាបន្នបុគ្គលនិងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ នូវសោតាបត្តិផល ។ បេ ។ អរហន្តនិងបុគ្គលដែលកំពុងប្រតិបត្តិ ដើម្បីភាវៈនៃខ្លួនជាអរហន្ត ដោយហេតុណាម្នាលភិក្ខុទាំងឡាយ នេះជាហេតុអស្ចារ្យចម្លែកទី ៨ ក្នុងធម្មវិន័យនេះ

១០៧



យំ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តិ ។ ឥមេ ខោ ភិក្ខវេ ឥមស្មឹ ធម្មវិនយេ អដ្ឋ អច្ឆរិយា អព្ភុតធម្មា យេ ទិស្វា ទិស្វា ភិក្ខូ ឥមស្មឹ ធម្មវិនយេ អភិរមន្តីតិ ។

មហាវគ្គោ ទុតិយោ ។

## តស្សុទ្ទានំ

វេរញ្ជ សីហោ អាជញ្ញា[១] ខឡុង្គេន[២] មលានិ ច
ទូតា[៣]ទ្វេ ច ពន្ធនន្តិ បហារាទ ឧបោសថោតិ ។

---

១ ឱ. ម. អាជញ្ញំ ។ ២ ឱ. ម. ខឡុង្កេន ។ ៣ ឱ. ម. ទូតេយ្យំ ទ្វេ ។

ដែលពួកភិក្ខុឃើញហើយៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។ ម្នាលភិក្ខុទាំងឡាយ ក្នុងធម្មវិន័យនេះ មានហេតុជាអស្ចារ្យចម្លែក ៨ យ៉ាងនេះឯង ដែលពួកភិក្ខុឃើញហើយ ៗ តែងរីករាយ ក្នុងធម្មវិន័យនេះ ។

ចប់ មហាវគ្គទី ២ ។

# ឧទ្ទាននៃមហាវគ្គនោះគឺ

និយាយអំពីវេរញ្ជព្រាហ្មណ៍ ១ អំពីសីហសេនាបតី ១ អំពីសេះអាជានេយ្យ ១ អំពីពុតត្បុតរបស់សេះ ១ អំពីមន្ទិល ១ អំពីភិក្ខុដែលគួរធ្វើជាទូត ១ អំពីចំណងមាន ២ លើក អំពីបហារាទអសុរ ១ អំពីឧបោសថ ១ ។

# គហបតិវគ្គោ

[២១] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ។ បេ ។ អដ្ឋហិ ភិក្ខវេ អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នាគតំ ឧគ្គំ គហបតឹ វេសាលិកំ ធារេថាតិ ។ ឥទមវោច ភគវា ឥទំ វត្វាន សុគតោ ឧដ្ឋាយាសនា វិហារំ បាវិសិ ។ អថខោ អញ្ញតរោ ភិក្ខុ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ឧគ្គស្ស គហបតិនោ វេសាលិ-កស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ ឧគ្គោ គហបតិ វេសាលិកោ យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ឧគ្គំ គហបតឹ វេសាលិកំ សោ ភិក្ខុ ឯតទវោច អដ្ឋហិ ខោ ត្វំ គហបតិ អច្ឆរិយេហិ អព្ភុត-ធម្មេហិ សមន្នាគតោ ភគវតា ព្យាកតោ ។

# គហបតិវគ្គ

[២១] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងកូដាគារ-សាលា នាព្រៃមហាវ័ន ជិតក្រុងវេសាលី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយ ។ បេ ។ ម្នាលភិក្ខុទាំង-ឡាយ អ្នកទាំងឡាយ ចូរចាំទុកនូវឧគ្គគហបតី អ្នកស្រុកវេសាលី ថាជាអ្នកប្រកបដោយធម៌ អស្ចារ្យចម្លែក ៨ យ៉ាង ។ ព្រះដ៏មានព្រះភាគ បានត្រាស់នូវពាក្យនេះ លុះព្រះសុគត ទ្រង់ត្រាស់នូវពាក្យនេះរួចហើយ ទើបក្រោកចាកអាសនៈ ហើយទ្រង់ស្តេចចូលទៅកាន់វិហារ ។ គ្រានោះ មានភិក្ខុ ១ រូប ស្លៀកស្បង់ប្រដាប់បាត្រនិងចីវរក្នុងបុព្វណ្ហសម័យ ចូលទៅកាន់លំនៅ របស់ឧគ្គគហបតី អ្នកស្រុកវេសាលី លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈ ដែលគេក្រាលទុក ។ ទើបឧគ្គគហបតី អ្នកស្រុកវេសាលី ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ ថ្វាយបង្គំភិក្ខុនោះដោយគោរព ហើយអង្គុយក្នុងទីសម-គួរ ។ លុះឧគ្គគហបតី អ្នកស្រុកវេសាលី អង្គុយក្នុងទីសមគួរហើយ ភិក្ខុនោះក៏បានពោលដូច្នេះថា ម្នាលគហបតី អ្នកប្រកបដោយធម៌អស្ចារ្យចម្លែក ៨ យ៉ាង ដែលព្រះដ៏មានព្រះភាគ ទ្រង់ព្យាករហើយ ។

កតមេ តេ គហបតិ អដ្ឋ អច្ឆរិយា អព្ភុតធម្មា យេហិ ត្វំ សមន្នាគតោ ភគវតា ព្យាកតោតិ ។ ន ខោ អហំ ភន្តេ ជានាមិ កតមេហិ អហំ អដ្ឋហិ អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នាគតោ ភគវតា ព្យាកតោ អបិ ច ភន្តេ យេ មេ អដ្ឋ អច្ឆរិយា អព្ភុតធម្មា សំវិជ្ជន្តិ តេ សុណាហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។ ឯវំ គហបតីតិ ខោ សោ ភិក្ខុ ឧគ្គស្ស គហបតិនោ វេសាលិកស្ស បច្ចស្សោសិ ។ ឧគ្គោ គហបតិ វេសាលិកោ ឯតទវោច យទាហំ ភន្តេ ភគវន្តំ បឋមំ ទូរតោវ អទ្ទសំ សហ ទស្សនេនេវ មេ ភន្តេ ភគវតោ ចិត្តំ បសីទិ ។ អយំ ខោ មេ ភន្តេ បឋមោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។ សោ ខោ អហំ ភន្តេ បសន្នចិត្តោ ភគវន្តំ បយិរុបាសឹ តស្ស មេ ភគវា អនុបុព្វីកថំ កថេសិ

ម្នាលគហបតី អ្នកប្រកបដោយធម៌អស្ចារ្យ ចម្លែកទាំងឡាយណា ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយ ធម៌អស្ចារ្យចម្លែកទាំង ៨ នោះ តើដូចម្តេច ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាមិនដឹងសោះថា ខ្ញុំករុណាប្រកបដោយធម៌អស្ចារ្យចម្លែក ៨ យ៉ាងដូចម្តេចខ្វះ ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយ បពិត្រលោកម្ចាស់ដ៏ចម្រើន ប៉ុន្តែធម៌អស្ចារ្យចម្លែក ៨ យ៉ាងណា ដែលមានដល់ខ្ញុំករុណា លោកម្ចាស់ចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ ខ្ញុំព្រះករុណានឹងសម្តែងនូវធម៌អស្ចារ្យចម្លែកទាំងនោះ ។ ភិក្ខុនោះទទួលស្តាប់ពាក្យឧគ្គគហបតីអ្នកស្រុកវេសាលីថា ចម្រើនពរគហបតី ។ ឧគ្គគហបតីអ្នកស្រុកវេសាលីបានពោលដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន កាលណាបើខ្ញុំករុណាបានឃើញព្រះដ៏មានព្រះភាគ អំពីចម្ងាយជាដំបូងហើយ បពិត្រលោកម្ចាស់ដ៏ចម្រើន ចិត្តខ្ញុំករុណា ក៏ជ្រះថ្លាចំពោះព្រះដ៏មានព្រះភាគ ដោយគ្រាន់តែបានឃើញប៉ុណ្ណោះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នោះជាធម៌អស្ចារ្យចម្លែកទី ១ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន លុះខ្ញុំករុណា មានចិត្តជ្រះថ្លាហើយ ក៏ចូលទៅអង្គុយជិតព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងនូវអនុបុព្វីកថា ដល់ខ្ញុំករុណា

សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិសំសំ បកាសេសិ ។ យទា មំ ភគវា អញ្ញាសិ កល្លចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ ឧទគ្គចិត្តំ បសន្នចិត្តំ អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។ សេយ្យថាបិ នាម សុទ្ធវត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ ខោ មេ តស្មឹយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ សមុទយធម្មំ សព្វន្តំ និរោធធម្មន្តិ ។ សោ ខោ អហំ ភន្តេ ទិដ្ឋធម្មោ បត្តធម្មោ វិទិតធម្មោ បរិយោគាឡ្ហធម្មោ តិណ្ណវិចិកិច្ឆោ វិគតកថំ-កថោ វេសារជ្ជប្បត្តោ អបរប្បច្ចយោ សត្ថុ សាសនេ តត្រេវ ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ អគមាសឹ

គឺទ្រង់សម្តែងទានកថា សីលកថា សគ្គកថា ទោសរបស់កាមទាំងឡាយ ដ៏លាមក សៅហ្មង និងអានិសង្សក្នុងការចេញចាកកាម ។ ព្រះមានព្រះភាគទ្រង់ជ្រាបថា ខ្ញុំព្រះករុណាមានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លា ក្នុងកាលណាហើយ ព្រះដ៏មានព្រះភាគក៏ទ្រង់សម្តែងធម៌ទេសនា ដែលព្រះពុទ្ធទាំងឡាយទ្រង់លើកឡើងសម្តែងដោយព្រះអង្គឯង គឺទ្រង់សម្តែងទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ក្នុងកាលនោះ ។ សំពត់ស្អាតមិនប្រឡាក់ពណ៌ខ្មៅ គួរទទួលទឹកជ្រលក់បានដោយប្រពៃ យ៉ាងណាមិញ ធម្មចក្ខុ គឺសោតាបត្តិមគ្គ ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងដល់ខ្ញុំករុណា លើអាសនៈនោះឯងថា ធម្មជាតណាមួយ ដែលកើតឡើងជាធម្មតា ធម្មជាតទាំងអស់នោះតែងរលត់ទៅវិញជាធម្មតា ក៏យ៉ាងនោះដែរ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាបានឃើញអរិយសច្ចធម៌ បានដល់អរិយសច្ចធម៌ បានដឹងច្បាស់អរិយសច្ចធម៌ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ បានឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លាហើយ មិនបានជឿស្តាប់បុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា បានដល់ព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងក្នុងទីនោះ

ព្រហ្មចរិយបញ្ចមានិ ច សិក្ខាបទានិ សមាទយឹ ។ អយំ ខោ មេ ភន្តេ ទុតិយោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។ តស្ស មយ្ហំ ភន្តេ ចតស្សោ កោមារិយោ បជាបតិយោ អហេសុំ ។ អថខ្វាហំ ភន្តេ យេន តា បជាបតិយោ តេនុបសង្កមឹ ឧបសង្កមិត្វា តា បជាបតិយោ ឯតទវោចំ មយា ខោ ភគិនិយោ ព្រហ្មចរិយបញ្ចមានិ សិក្ខាបទានិ សមាទិន្នានិ យា ឥច្ឆតិ សា ឥមេវ[១] ភោគេ ភុញ្ជតុ បុញ្ញានិ ច ករោតុ សកានិ វា ញាតិកុលានិ គច្ឆតុ ហោតិ វា បន បុរិសាធិប្បាយោ តស្ស វោ ទម្មីតិ ។ ឯវំ វុត្តេ សា ភន្តេ ជេដ្ឋា បជាបតិ មំ ឯតទវោច ឥត្ថន្នាមស្ស មំ អយ្យបុត្ត បុរិសស្ស ទេហីតិ ។ អថខោ អហំ ភន្តេ តំ បុរិសំ បក្កោសាបេត្វា វាមេន ហត្ថេន បជាបតឹ គហេត្វា ទក្ខិណេន ហត្ថេន ភិង្ការំ គហេត្វា តស្ស បុរិសស្ស ឱណោជេសឹ

១ ឱ. ម. ឥធេវ ។

ទាំងបានសមាទាននូវសិក្ខាបទទាំងឡាយ មានព្រហ្មចរិយៈជាគម្រប់ ៥ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ២ តែងមានដល់ខ្ញុំព្រះករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាមាននាងកុមារីជាប្រពន្ធ ៤ នាក់ បពិត្រលោកម្ចាស់ដ៏ចម្រើន លំដាប់នោះ ខ្ញុំព្រះករុណាចូលទៅរកប្រពន្ធទាំងនោះ លុះចូលទៅដល់ហើយ ក៏ពោលទៅនឹងប្រពន្ធទាំងនោះ ដូច្នេះថា ម្នាលនាងទាំងឡាយ យើងសមាទាន សិក្ខាបទទាំងឡាយ មានព្រហ្មចរិយៈជាគម្រប់ ៥ ហើយ (បើ) នាងណាប្រាថ្នានាងនោះ ចូរប្រើប្រាស់នូវភោគៈទាំងឡាយនេះផង ចូរធ្វើបុណ្យទាំងឡាយផងចុះ ឬថា ទៅកាន់ត្រកូលញាតិ ជារបស់ខ្លួនក៏បាន ពុំនោះសោត នាងទាំងឡាយ ត្រូវការបុរសណា យើងនឹងឲ្យនាងទាំងឡាយទៅបុរសនោះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលដែលខ្ញុំករុណានិយាយយ៉ាងនេះហើយ នាងដែលជាប្រពន្ធច្បងនោះ និយាយនឹងខ្ញុំករុណាថា បពិត្រអយ្យបុត្ត ចូរអ្នកឲ្យខ្ញុំទៅបុរសឈ្មោះនេះចុះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ឯខ្ញុំករុណាក៏ឲ្យគេហៅបុរសនោះមក ហើយដៃឆ្វេងកាន់ប្រពន្ធ ដៃស្តាំកាន់កុណ្ឌី (ច្រួចទឹក) ប្រគល់ឲ្យដល់បុរសនោះ

កោមារី ខោ បនាហំ ភន្តេ នានំ(១) បរិច្ចជន្តោ នាភិជានាមិ ចិត្តស្ស អញ្ញថត្តំ ។ អយំ ខោ មេ ភន្តេ តតិយោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។ សំវិជ្ជន្តិ ខោ បន មេ ភន្តេ កុលេ ភោគា តេ ច ខោ អប្បដិវិភត្តា សីលវន្តេហិ កល្យាណធម្មេហិ ។ អយំ ខោ មេ ភន្តេ ចតុត្ថោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។ យំ ខោ បនាហំ ភន្តេ ភិក្ខុំ បយិរុបាសាមិ សក្កច្ចំយេវ បយិរុបាសាមិ នោ អសក្កច្ចំ ។ អយំ ខោ មេ ភន្តេ បញ្ចមោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។ សោ ចេ មេ អាយស្មា ធម្មំ ទេសេតិ សក្កច្ចំយេវ សុណាមិ នោ អសក្កច្ចំ នោ ចេ មេ អាយស្មា ធម្មំ ទេសេតិ អហមស្ស ធម្មំ ទេសេមិ ។ អយំ ខោ មេ ភន្តេ ឆដ្ឋោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។ អនច្ឆរិយំ ខោ បន មំ ភន្តេ ទេវតា ឧបសង្កមិត្វា អារោចេន្តិ ស្វាក្ខាតោ គហបតិ ភគវតា ធម្មោតិ ។

១ ឱ. ម. ទារំ ។

បពិត្រលោកម្ចាស់ដ៏ចម្រើន កាលខ្ញុំករុណា លះបង់នូវនាង់កុមារី ឲ្យទៅជាទានហើយ ក៏មិនដឹងធ្វើចិត្តឲ្យប្រែប្រួលឡើយ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៣ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ភោគៈទាំងឡាយ មានច្រើនក្នុងត្រកូលរបស់ខ្ញុំករុណា តែភោគៈទាំងនោះមិនបានចែកមុខ អំពីលោកអ្នកមានសីលមានកល្យាណធម៌ទាំងឡាយទេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៤ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បើខ្ញុំករុណាចូលទៅអង្គុយជិតភិក្ខុណា តែងចូលទៅអង្គុយជិតដោយគោរព មិនមែនចូលទៅអង្គុយជិតដោយមិនគោរពទេ ។ បពិត្រលោកដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៥ តែងមានដល់ខ្ញុំករុណា ។ បើលោកដ៏មានអាយុនោះ សម្តែងធម៌ដល់ខ្ញុំករុណា ខ្ញុំករុណាតែងស្តាប់ដោយគោរព មិនមែនស្តាប់ដោយមិនគោរពទេ បើលោកដ៏មានអាយុមិនសម្តែងធម៌ដល់ខ្ញុំករុណាទេ ខ្ញុំករុណាតែងសម្តែងធម៌ដល់លោកដ៏មានអាយុនោះវិញ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៦ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកទេវតាតែងចូលមករកខ្ញុំករុណាហើយប្រាប់ថា ម្នាលគហបតី ធម៌ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ ដោយប្រពៃដូច្នេះ មិនជាទីអស្ចារ្យទេ ។

១១៣

បណ្ណាសកេ គហបតិវគ្គោ

ឯវំ វុត្តេ អហំ ភន្តេ តា ទេវតា ឯវំ វទាមិ វទេយ្យាថ វា ឯវំ ខោ តុម្ហេ ទេវតេ នោ វា វទេយ្យាថ អថខោ ស្វាក្ខាតោ ភគវតា ធម្មោតិ ។ ន ខោ បនាហំ ភន្តេ អភិជានាមិ តតោនិទានំ ចិត្តស្ស ឧណ្ណត្តិ មំ វា ទេវតា ឧបសង្កមន្តិ អហំ វា ទេវតាហិ សទ្ធឹ សល្លបាមិ ។ អយំ ខោ មេ ភន្តេ សត្តមោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។ យានិមានិ ភន្តេ ភគវតា ទេសិតានិ បញ្ចោរម្ភាគិយានិ សញ្ញោជនានិ នាហំ តេសំ កិញ្ចិ អត្តនិ អប្បហីនំ សមនុបស្សាមិ ។ អយំ ខោ មេ ភន្តេ អដ្ឋមោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។ ឥមេ ខោ ភន្តេ អដ្ឋ អច្ឆរិយា អព្ភុតធម្មា សំវិជ្ជន្តិ ន ច ខោ អហំ ជានាមិ កតមេហិ ចាហំ អដ្ឋហិ អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នាគតោ ភគវតា ព្យាកតោតិ ។

បពិត្រលោកម្ចាស់ដ៏ចម្រើន កាលដែលទេវតា និយាយយ៉ាងនេះហើយ ខ្ញុំករុណា ក៏និយាយទៅរកពួកទេវតាទាំងនោះយ៉ាងនេះថា ម្នាលទេវតាទាំងឡាយ អ្នកទាំងឡាយ គប្បីពោលយ៉ាងនេះក្តី មិនគប្បីពោលយ៉ាងនេះក្តី ឯធម៌ពិតព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ ដោយប្រពៃមែន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំមិនដឹងថាចិត្តដែលប៉ោងឡើង ព្រោះរឿងនោះជាហេតុទេ ពួកទេវតាតែងចូលមករកខ្ញុំករុណាក៏មាន ខ្ញុំករុណាតែងចរចាជាមួយនឹងពួកទេវតាក៏មាន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៧ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន សញ្ញោជនធម៌ទាំងឡាយ ជាចំណែកខាងក្រោម ៥ យ៉ាងណា ដែលព្រះដ៏មានព្រះភាគទ្រង់សម្តែងហើយ បណ្តាសញ្ញោជនៈទាំងនោះ ខ្ញុំករុណាពិចារណារក សញ្ញោជនធម៌ បន្តិចបន្តួច ដែលមិនទាន់លះបង់ក្នុងខ្លួនមិនឃើញឡើយ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៨ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌អស្ចារ្យចម្លែកទាំង ៨ នេះឯង តែងមាន (ដល់ខ្ញុំករុណា) ចំណែកខ្ញុំករុណាមិនដឹងសោះថា ខ្ញុំករុណាប្រកប ដោយធម៌អស្ចារ្យចម្លែក ៨ យ៉ាង ដូចម្តេចខ្លះ ដែលព្រះដ៏មានព្រះភាគទ្រង់បានព្យាករហើយ ។

អថខោ សោ ភិក្ខុ ឧគ្គស្ស គហបតិនោ វេសាលិកស្ស និវេសនេ បិណ្ឌបាតំ គហេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ សោ ភិក្ខុ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ យាវតកោ អហោសិ ឧគ្គេន គហបតិនា វេសាលិកេន សទ្ធឹ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។ សាធុ សាធុ ភិក្ខុ យថាតំ ឧគ្គោ គហបតិ វេសាលិកោ សម្មា ព្យាករមានោ ព្យាករេយ្យ ឥមេហេវ ខោ ភិក្ខុ អដ្ឋហិ អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នាគតោ ឧគ្គោ គហបតិ វេសាលិកោ មយា ព្យាកតោ ឥមេហិ ច បន ភិក្ខុ អដ្ឋហិ អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នាគតំ ឧគ្គំ គហបតិ វេសាលិកំ ធារេថាតិ ។

[២២] ឯកំ សមយំ ភគវា វជ្ជីសុ វិហរតិ ហត្ថិគាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ អដ្ឋហិ ភិក្ខវេ អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នាគតំ ឧគ្គំ គហបតឹ ហត្ថិគាមកំ ធារេថាតិ ។

គ្រានោះ ភិក្ខុនោះទទួលចង្ហាន់បិណ្ឌបាត ក្នុងលំនៅរបស់ឧគ្គគហបតី អ្នកស្រុកវេសាលី ហើយក៏ក្រោកចាកអាសនៈ ចៀសចេញទៅ ។ លុះភិក្ខុនោះ ត្រឡប់ពីបិណ្ឌបាត ក្នុងវេលាខាងក្រោយនៃភត្តហើយ ក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះមានព្រះភាគ ហើយក៏អង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះអង្គុយ ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលនូវរឿងរ៉ាវទាំងអស់នោះ ដែលខ្លួនចរចាទាំងប៉ុន្មានជាមួយនឹងឧគ្គគហបតី អ្នកស្រុកវេសាលី ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ ឧគ្គគហបតី អ្នកស្រុកវេសាលី កាលបើព្យាករឲ្យសមហេតុ ឈ្មោះថាព្យាករតាមពិត ម្នាលភិក្ខុ ឧគ្គគហបតី អ្នកស្រុកវេសាលី ប្រកបដោយធម៌អស្ចារ្យចម្លែក ៨ យ៉ាងនេះឯង ដែលតថាគតបានព្យាករហើយ ម្នាលភិក្ខុ មួយទៀត អ្នកទាំងឡាយ ចូរចាំទុកនូវឧគ្គគហបតី អ្នកស្រុកវេសាលី ថាប្រកបដោយធម៌អស្ចារ្យចម្លែកទាំង ៨ យ៉ាងនេះចុះ ។

[២២] សម័យមួយ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងហត្ថិគ្រាម ក្នុងដែនវជ្ជី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកនូវឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម ថាជាអ្នកប្រកបដោយធម៌ អស្ចារ្យចម្លែក ៨ ប្រការ ។

១១៤

## បណ្ណាសកេ គហបតិវគ្គោ

ឥទមវោច ភគវា ឥទំ វត្វាន សុគតោ ឧដ្ឋាយាសនា វិហារំ បាវិសិ ។ អថខោ អញ្ញតរោ ភិក្ខុ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ឧគ្គស្ស គហបតិនោ ហត្ថិគាមកស្ស និវេសនំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ ឧគ្គោ គហបតិ ហត្ថិគាមកោ យេន សោ ភិក្ខុ តេនុបសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ឧគ្គំ គហបតឹ ហត្ថិគាមកំ សោ ភិក្ខុ ឯតទវោច អដ្ឋហិ ខោ ត្វំ គហបតិ អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នាគតោ ភគវតា ព្យាកតោ កតមេ តេ គហបតិ អដ្ឋ អច្ឆរិយា អព្ភុតធម្មា យេហិ ត្វំ សមន្នាគតោ ភគវតា ព្យាកតោតិ ។ ន ខោ អហំ ភន្តេ ជានាមិ កតមេហិ អហំ អដ្ឋហិ អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នាគតោ ភគវតា ព្យាកតោ អបិច ភន្តេ យេមេ អដ្ឋ អច្ឆរិយា អព្ភុតធម្មា សំវិជ្ជន្តិ តេ សុណោហិ សាធុកំ មនសិករោហិ ភាសិស្សាមីតិ ។

ព្រះដ៏មានព្រះភាគ បានត្រាស់ពាក្យនេះ លុះព្រះសុគត ទ្រង់ត្រាស់ពាក្យនេះរួចហើយ ក៏ក្រោកចាកអាសនៈ ស្តេចចូលទៅកាន់វិហារ ។ គ្រានោះ ភិក្ខុ ១ រូបស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ចូលទៅកាន់លំនៅរបស់ឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ លំដាប់នោះ ឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ ថ្វាយបង្គំភិក្ខុនោះ ហើយអង្គុយក្នុងទីសមគួរ ។ លុះឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម អង្គុយក្នុងទីសមគួរហើយ ភិក្ខុនោះពោលដូច្នេះថា ម្នាលគហបតី អ្នកប្រកបដោយធម៌ អស្ចារ្យចម្លែក ៨ យ៉ាង ដែលព្រះដ៏មានព្រះភាគ ទ្រង់ព្យាករហើយ ម្នាលគហបតី អ្នកប្រកបដោយធម៌ អស្ចារ្យ ៨ យ៉ាងណា ដែលព្រះដ៏មានព្រះភាគ ទ្រង់ព្យាករហើយ ធម៌អស្ចារ្យចម្លែក ៨ យ៉ាងនោះ តើដូចម្តេច ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាមិនដឹងសោះថា ខ្ញុំករុណាប្រកបដោយធម៌ អស្ចារ្យ ចម្លែក ៨ យ៉ាង ដូចម្តេចខ្លះ ដែលព្រះដ៏មានព្រះភាគ ទ្រង់ព្យាករហើយទេ បពិត្រលោកម្ចាស់ដ៏ចម្រើន ក៏ប៉ុន្តែ ធម៌អស្ចារ្យចម្លែក ៨ យ៉ាងណា ដែលមានដល់ខ្ញុំករុណា សូមលោកម្ចាស់ស្តាប់នូវធម៌ អស្ចារ្យ ចម្លែកទាំងនោះ សូមធ្វើទុកក្នុងចិត្តដោយប្រពៃចុះ ខ្ញុំករុណានឹងសម្តែង ។

ឯវំ គហបតីតិ ខោ សោ ភិក្ខុ ឧគ្គស្ស គហបតិនោ ហត្ថិគ្គាមកស្ស បច្ចស្សោសិ ។ ឧគ្គោ គហបតិ ហត្ថិគ្គាមកោ ឯតទវោច យទាហំ ភន្តេ នាគវនេ បរិចរន្តោ ភគវន្តំ បឋមំ ទូរតោវ អទ្ទសំ សហ ទស្សនេនេវ មេ ភន្តេ ភគវតោ ចិត្តំ បសីទិ សុរាមទោ ច បហីយិ ។ អយំ ខោ មេ ភន្តេ បឋមោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។ សោ ខោ អហំ ភន្តេ បសន្នចិត្តោ ភគវន្តំ បយិរុបាសឹ តស្ស មេ ភគវា អនុបុព្វីកថំ កថេសិ សេយ្យថីទំ ទានកថំ សីលកថំ សគ្គកថំ កាមានំ អាទីនវំ ឱការំ សង្កិលេសំ នេក្ខម្មេ អានិសំសំ បកាសេសិ ។ យទា មំ ភគវា អញ្ញាសិ កល្លចិត្តំ មុទុចិត្តំ វិនីវរណចិត្តំ ឧទគ្គចិត្តំ បសន្នចិត្តំ អថ យា ពុទ្ធានំ សាមុក្កំសិកា ធម្មទេសនា តំ បកាសេសិ ទុក្ខំ សមុទយំ និរោធំ មគ្គំ ។

ភិក្ខុនោះទទួលស្តាប់ពាក្យឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាមថា ចម្រើនពរ គហបតី ។ ឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម បានពោលដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន កាលណាខ្ញុំករុណា កំពុងត្រាច់ទៅក្នុងនាគវ័ន បានឃើញព្រះដ៏មានព្រះភាគជាដំបូងអំពីចម្ងាយ បពិត្រលោកដ៏ចម្រើន ចិត្តខ្ញុំករុណាក៏ជ្រះថ្លាចំពោះព្រះដ៏មានព្រះភាគ ដោយគ្រាន់តែឃើញប៉ុណ្ណោះ ទាំងការស្រវឹងសុរា ក៏ស្វាងទៅ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ១ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន លុះខ្ញុំករុណាមានចិត្ត ជ្រះថ្លាហើយ ក៏ចូលទៅអង្គុយជិតព្រះមានព្រះភាគ ព្រះអង្គទ្រង់សម្តែងអនុបុព្វីកថាដល់ខ្ញុំករុណា គឺទ្រង់ប្រកាសទានកថា សីលកថា សគ្គកថា ទោសរបស់កាមដ៏លាមកសៅហ្មង និងអានិសង្សក្នុងការចេញចាកកាម ។ ព្រះមានព្រះភាគ ទ្រង់ជ្រាបថា ខ្ញុំករុណាមានចិត្តស្រួល មានចិត្តទន់ មានចិត្តផុតចាកនីវរណធម៌ មានចិត្តអណ្តែតឡើង មានចិត្តជ្រះថ្លា ក្នុងកាលណា ព្រះអង្គក៏ទ្រង់សម្តែងធម៌ទេសនាដែលព្រះពុទ្ធទាំងឡាយទ្រង់លើកឡើងសម្តែង ដោយព្រះអង្គឯង គឺទ្រង់សម្តែងទុក្ខសច្ច សមុទយសច្ច និរោធសច្ច មគ្គសច្ច ក្នុងកាលនោះ ។

សេយ្យថាបិ នាម សុទ្ធវត្ថំ អបគតកាឡកំ សម្មទេវ រជនំ បដិគ្គណ្ហេយ្យ ឯវមេវ ខោ មេ តស្មឹយេវ អាសនេ វិរជំ វីតមលំ ធម្មចក្ខុំ ឧទបាទិ យំ កិញ្ចិ សមុទយ-ធម្មំ សព្វន្តំ និរោធធម្មន្តិ ។ សោ ខោ អហំ ភន្តេ ទិដ្ឋធម្មោ បត្តធម្មោ វិទិតធម្មោ បរិយោគាឡ្ហធម្មោ តិណ្ណវិចិកិច្ឆោ វិគតកថំកថោ វេសារជ្ជប្បត្តោ អបរ-ប្បច្ចយោ សត្ថុ សាសនេ តត្ថេវ ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ អគមាសឹ ព្រហ្មចរិយបញ្ចមានិ ច សិក្ខាបទានិ សមាទិយឹ ។ អយំ ខោ មេ ភន្តេ ទុតិយោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។ តស្ស មយ្ហំ ភន្តេ ចតស្សោ កោមារិយោ បជាបតិយោ អហេសុំ ។ អថខ្វាហំ ភន្តេ យេន តា បជាបតិយោ តេនុបសង្កមឹ ឧបសង្កមិត្វា តា បជាបតិយោ ឯតទវោចំ មយា ខោ ភគិនិយោ ព្រហ្មចរិយបញ្ចមានិ សិក្ខាបទានិ សមាទិន្នានិ

សំពត់សស្អាត មិនប្រឡាក់ពណ៌ខ្មៅ គួរទទួលទឹកជ្រលក់បានដោយប្រពៃ យ៉ាងណាមិញ ធម្មចក្ខុគឺសោតាបត្តិមគ្គ ដ៏ប្រាសចាកធូលី ប្រាសចាកមន្ទិល កើតឡើងដល់ខ្ញុំករុណា លើអាសនៈនោះឯងថា ធម្មជាតណាមួយ ដែលកើតឡើងហើយជាធម្មតា ធម្មជាតទាំងអស់នោះ មានការរលត់ទៅវិញជាធម្មតា ក៏យ៉ាងនោះដែរ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណា បានឃើញអរិយសច្ចធម៌ បានដល់អរិយសច្ចធម៌ បានដឹងច្បាស់អរិយសច្ចធម៌ បានចុះចិត្តស៊ប់ក្នុងអរិយសច្ចធម៌ បានឆ្លងផុតសេចក្តីសង្ស័យ មិនមានងឿងឆ្ងល់ ដល់នូវសេចក្តីក្លៀវក្លា មិនជឿស្តាប់បុគ្គលដទៃ ក្នុងសាសនានៃព្រះសាស្តា បានដល់នូវព្រះពុទ្ធផង ព្រះធម៌ផង ព្រះសង្ឃផង ជាទីពឹងក្នុងទីនោះ ទាំងបានសមាទាននូវសិក្ខាបទទាំងឡាយមានព្រហ្មចរិយៈជាគម្រប់ ៥ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ២ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាមាននាងកុមារីជាប្រពន្ធ ៤ នាក់ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន លំដាប់នោះ ខ្ញុំករុណាចូលទៅរកប្រពន្ធទាំងនោះ លុះចូលទៅដល់ហើយ បាននិយាយទៅនឹងប្រពន្ធទាំងនោះ ដូច្នេះថា ម្នាលនាងទាំងឡាយ យើងបានសមាទានសិក្ខាបទទាំងឡាយ មានព្រហ្មចរិយៈជាគម្រប់៥ ហើយ

យា ឥច្ឆតិ សា ឥមេវ ភោគេ ភុញ្ជតុ បុញ្ញានិ ច ករោតុ សកានិ វា ញាតិកុលានិ គច្ឆតុ ហោតិ វា បន បុរិសាធិប្បាយោ កស្ស វោ ទម្មីតិ ។ ឯវំ វុត្តេ សា ភន្តេ ជេដ្ឋា បជាបតិ មំ ឯតទវោច ឥត្ថន្នាមស្ស មំ អយ្យបុត្ត បុរិសស្ស ទេហីតិ ។ អថខោ អហំ ភន្តេ តំ បុរិសំ បក្កោសាបេត្វា វាមេន ហត្ថេន បជាបតឹ គហេត្វា ទក្ខិណេន ហត្ថេន ភិង្ការំ គហេត្វា តស្ស បុរិសស្ស ឱណោជេសឹ ។ កោមារឹ ខោ បនាហំ ភន្តេ ទារំ បរិច្ចជន្តោ នាភិជានាមិ ចិត្តស្ស អញ្ញថត្តំ ។ អយំ ខោ មេ ភន្តេ តតិយោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។ សំវិជ្ជន្តិ ខោ បន មេ ភន្តេ កុលេ ភោគា តេ ច ខោ អប្បដិវិភត្តា សីលវន្តេហិ កល្យាណធម្មេហិ ។ អយំ ខោ មេ ភន្តេ ចតុត្ថោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។ យំ ខោ បនាហំ ភន្តេ ភិក្ខុំ បយិរុបា-សាមិ សក្កច្ចំយេវ បយិរុបាសាមិ នោ អសក្កច្ចំ

បើនាងណាប្រាថ្នា នាងនោះចូរប្រើប្រាស់នូវភោគសម្បត្តិ ទាំងនេះផង ចូរធ្វើបុណ្យទាំងឡាយផងចុះ ឬថា ទៅកាន់ត្រកូលញាតិរបស់ខ្លួនក៏បាន ពុំនោះសោត នាងទាំងឡាយត្រូវការបុរសណា យើងនឹងឲ្យនាងទាំងឡាយ ទៅបុរសនោះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលដែលខ្ញុំករុណា និយាយយ៉ាងនេះហើយ នាងដែលជាប្រពន្ធច្បងនោះ ក៏និយាយនឹងខ្ញុំករុណាដូច្នេះថា បពិត្រអយ្យបុត្ត សូមអ្នកឲ្យខ្ញុំទៅបុរសឈ្មោះនេះចុះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ទើបខ្ញុំករុណាក៏ឲ្យគេហៅបុរសនោះមក ហើយដៃឆ្វេងកាន់ប្រពន្ធ ដៃស្តាំកាន់កុណ្ឌី (ច្រួចទឹក) ប្រគល់ឲ្យទៅបុរសនោះ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលខ្ញុំករុណា លះបង់នាងកុមារីឲ្យទៅជាទានហើយ ក៏មិនដឹងធ្វើចិត្តឲ្យប្រែប្រួលឡើយ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៣ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ភោគសម្បត្តិទាំងឡាយ មានច្រើន ក្នុងត្រកូលរបស់ខ្ញុំករុណា តែភោគសម្បត្តិទាំងនោះ មិនទាន់បានចែកមុខ អំពីអ្នកមានសីល មានកល្យាណធម៌ទាំងឡាយទេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៤ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បើខ្ញុំករុណាចូលទៅអង្គុយជិតភិក្ខុណា តែងចូលទៅអង្គុយជិតដោយគោរព មិនបានចូលទៅអង្គុយជិតដោយមិនគោរពទេ

១១៩

បណ្ណាសកេ គហបតិវគ្គោ

សោ ចេ មេ អាយស្មា ធម្មំ ទេសេសិ សក្កច្ចំយេវ សុណាមិ នោ អសក្កច្ចំ នោ ចេ មេ អាយស្មា ធម្មំ ទេសេសិ អហមស្ស ធម្មំ ទេសេមិ ។ អយំ ខោ មេ ភន្តេ បញ្ចមោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។ អនច្ឆរិយំ ខោ បន មេ ភន្តេ សង្ឃេ និមន្តិតេ ទេវតា ឧបសង្កមិត្វា អារោចេន្តិ អសោកោ គហបតិ ភិក្ខុ ឧភតោ ភាគវិមុត្តោ អសោកោ បញ្ញាវិមុត្តោ អសោកោ កាយសក្ខី អសោកោ ទិដ្ឋិប្បត្តោ អសោកោ សទ្ធាវិមុត្តោ អសោកោ ធម្មានុសារី អសោកោ សទ្ធានុសារី

*បើលោកដ៏មានអាយុនោះ សម្តែងធម៌ដល់ខ្ញុំករុណា ខ្ញុំករុណាតែងស្តាប់ដោយគោរព មិនបានស្តាប់ដោយមិនគោរពទេ ប្រសិនបើ លោកដ៏មានអាយុមិនសម្តែងធម៌ដល់ខ្ញុំករុណាទេ ខ្ញុំករុណាតែងសម្តែងធម៌ដល់លោកដ៏មានអាយុនោះវិញ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៥ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលដែលខ្ញុំករុណា និមន្តព្រះសង្ឃមកហើយ ពួកទេវតា ចូលទៅប្រាប់ថា ម្នាលគហ-បតី ភិក្ខុឯណោះជាឧភតោភាគវិមុត្ត[១] ភិក្ខុឯណោះជាបញ្ញាវិមុត្ត[២] ភិក្ខុឯណោះ ជាកាយសក្ខី[៣] ភិក្ខុឯណោះជាទិដ្ឋិប្បត្តៈ[៤] ភិក្ខុឯណោះជាសទ្ធាវិមុត្ត[៥] ភិក្ខុឯណោះជាធម្មានុសារី[៦] ភិក្ខុឯណោះជាសទ្ធានុសារី[៧]*

---

១ បានដល់បុគ្គល ដែលផុតស្រឡះចាកចំណែកទាំងពីរ គឺផុតស្រឡះចាករូបកាយ ដោយអរូបសមាបត្តិ ១ ផុតស្រឡះចាកនាមកាយ ដោយមគ្គ ១ ។

២ បានដល់បុគ្គលជា សុក្ខវិបស្សក: ។

៣ បានដល់បុគ្គល ដែលបាននូវឈានសម្ផស្ស ជាដំបូង ទើបធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ជាខាងក្រោយ ។

៤ បានដល់បុគ្គល ដែលដឹងច្បាស់ ឃើញច្បាស់ ធ្វើឲ្យជាក់ច្បាស់ ដោយបញ្ញាថា សង្ខារទាំងឡាយ រមែងនាំមកនូវទុក្ខ មានតែព្រះនិព្វាន ទើបបានសុខ គឺថា ឃើញច្បាស់នូវអរិយសច្ចទាំង ៤ ដោយបញ្ញា ។

៥ បានដល់បុគ្គលដែលផុតស្រឡះចាកកិលេសដោយសទ្ធា សេចក្តីដូចគ្នានិងទិដ្ឋិប្បត្តបុគ្គល ប្លែកគ្នាតែត្រង់សេចក្តីជឿស៊ប់សួន ក្នុងខណ:ដែលបាននូវមគ្គជាចំណែកខាងដើម ។

៦ បានដល់បុគ្គលដែលចម្រើននូវមគ្គ មានធម៌គឺបញ្ញាជាប្រធាន ។

៧ ប្រហែលគ្នានឹងធម្មានុសារីបុគ្គល ។

អសោកោ សីលវា កល្យាណធម្មោ អសោកោ ទុស្សីលោ បាបធម្មោតិ ។ សច្ចំ ខោ បនាហំ ភន្តេ បរិវិសន្តោ នាភិជានាមិ ឯវំ ចិត្តំ ឧប្បាទេន្តោ ឥមស្ស វា ថោកំ ទេមិ ឥមស្ស វា ពហុកន្តិ អថខ្វាហំ ភន្តេ សមចិត្តោវ ទេមិ ។ អយំ ខោ មេ ភន្តេ ឆដ្ឋោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។ អនច្ឆរិយំ ខោ បន មំ ភន្តេ ទេវតា ឧបសង្កមិត្វា អារោចេន្តិ ស្វាក្ខាតោ គហបតិ ភគវតា ធម្មោតិ ។ ឯវំ វុត្តេ អហំ ភន្តេ តា ទេវតា ឯវំ វទាមិ វទេយ្យាថ វា ឯវំ ខោ តុម្ហេ ទេវតេ នោ វា វទេយ្យាថ អថខោ ស្វាក្ខាតោ ភគវតា ធម្មោតិ ។ ន ខោ បនាហំ ភន្តេ អភិជានាមិ តតោនិទានំ ចិត្តស្ស ឧណ្ណន្តិ មំ វា ទេវតា ឧបសង្កមន្តិ អហំ វា ទេវតាហិ សទ្ធឹ សល្លបាមិ ។ អយំ ខោ មេ ភន្តេ សត្តមោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។

ភិក្ខុឯណោះជាអ្នកមានសីល មានកល្យាណធម៌ ភិក្ខុឯណោះជាអ្នកទ្រុស្ត សីល មានធម៌ដ៏លាមក ហេតុនេះ មិនជាអស្ចារ្យទេ ។ បពិត្រលោក ម្ចាស់ដ៏ចម្រើន កាលខ្ញុំករុណា កំពុងអង្គាសព្រះសង្ឃ មិនដឹងធ្វើចិត្តឲ្យ កើតឡើងយ៉ាងនេះថា អាត្មាអញ ឲ្យវត្ថុតិច ដល់ភិក្ខុនេះផង ឲ្យវត្ថុ ច្រើនដល់ភិក្ខុនេះផងទេ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាឲ្យទាន មានចិត្តស្មើដោយពិត ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យ ចម្លែកទី ៦ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកទេវតា តែងចូលមករកខ្ញុំករុណា ហើយប្រាប់ថា ម្នាលគហបតី ព្រះធម៌ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយដោយប្រពៃ មិនជា អស្ចារ្យទេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន កាលដែលពួកទេវតាពោល យ៉ាងនេះហើយ ខ្ញុំករុណា ក៏និយាយទៅរកទេវតាទាំងនោះយ៉ាងនេះ ថា ម្នាលទេវតា អ្នកទាំងឡាយ គប្បីពោលយ៉ាងនេះក្តី មិនគប្បី ពោលយ៉ាងនេះក្តី ឯធម៌ពិត ព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ ដោយប្រពៃមែន ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំករុណាមិនដឹងថាចិត្ត ដែលប៉ោងឡើង ព្រោះរឿងនោះជាហេតុទេ ទោះពួកទេវតា ចូលមករក ខ្ញុំករុណាក្តី ខ្ញុំករុណាចរចាជាមួយនឹងពួកទេវតាក្តី ។ បពិត្រលោក ម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៧ តែងមានដល់ខ្ញុំករុណា ។

១២១

បណ្ណាសកេ  គហបតិវគ្គោ

សចេ ខោ បនាហំ ភន្តេ ភគវតា[1] បឋមតរំ កាលំ ការេយ្យំ អនច្ឆរិយំ ខោ បនេតំ យម្មំ ភគវា ឯវំ ព្យាករេយ្យ នត្ថិ តំ សំយោជនំ យេន សំយោជនេន សំយុត្តោ ឧគ្គោ គហបតិ ហត្ថិគាមកោ បុន ឥមំ លោកំ អាគច្ឆេយ្យាតិ ។ អយំ ខោ មេ ភន្តេ អដ្ឋមោ អច្ឆរិយោ អព្ភុតធម្មោ សំវិជ្ជតិ ។ ឥមេ ខោ ភន្តេ អដ្ឋ អច្ឆរិយា អព្ភុតធម្មា សំវិជ្ជន្តិ ន ច ខោ អហំ ជានាមិ កតមេហិ ចាហំ អដ្ឋហិ អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នាគតោ ភគវតា ព្យាកតោតិ ។ អថខោ សោ ភិក្ខុ ឧគ្គស្ស គហបតិនោ ហត្ថិគាមកស្ស និវេសនេ បិណ្ឌបាតំ គហេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ សោ ភិក្ខុ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ

១ ឱ. ម. ភគវតោ ។

បពិត្រលោកម្ចាស់ដ៏ចម្រើន ប្រសិនបើខ្ញុំករុណា គប្បីធ្វើមរណកាល មុនព្រះដ៏មានព្រះភាគ ព្រះអង្គគប្បីព្យាករយ៉ាងនេះ ចំពោះខ្ញុំករុណាថា ឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម ប្រកបដោយសំយោជនៈណាហើយ គប្បីមកកាន់មនុស្សលោកនេះម្តងទៀត សំយោជនៈនោះគ្មានទេ ហេតុនុ៎ះមិនជាអស្ចារ្យទេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន នេះជាធម៌អស្ចារ្យចម្លែកទី ៨ តែងមានដល់ខ្ញុំករុណា ។ បពិត្រលោកម្ចាស់ដ៏ចម្រើន ធម៌ជាទីអស្ចារ្យចម្លែកទាំង ៨ នេះ តែងមាន (ដល់ខ្ញុំករុណា) តែថា ខ្ញុំករុណាមិនដឹងសោះថា ខ្ញុំករុណាប្រកបដោយធម៌ ជាអស្ចារ្យចម្លែក ៨ យ៉ាង ដូចម្តេចខ្លះ ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយទេ ។ លំដាប់នោះ ភិក្ខុនោះ ទទួលចង្ហាន់បិណ្ឌបាត ក្នុងលំនៅរបស់ឧគ្គគហបតី អ្នកស្រុកហត្ថិ-គ្រាម រួចក្រោកចាកអាសនៈ ចៀសចេញទៅ ។ លុះភិក្ខុនោះត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយនៃភត្ត ហើយក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ

យាវតកោ អហោសិ ឧគ្គេន គហបតិនា ហត្ថិគ្គាមកេន សទ្ធឹ កថាសល្លាបោ តំ សព្វំ ភគវតោ អារោចេសិ ។ សាធុ សាធុ ភិក្ខុ យថាតំ ឧគ្គោ គហបតិ ហត្ថិ-គ្គាមកោ សម្មា ព្យាករមានោ ព្យាករេយ្យ ឥមេហេវ ខោ ភិក្ខុ អដ្ឋហិ អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នា-គតោ ឧគ្គោ គហបតិ ហត្ថិគ្គាមកោ មយា ព្យាកតោ ឥមេហិ ច បន ភិក្ខុ អដ្ឋហិ អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នាគតំ ឧគ្គំ គហបតឹ ហត្ថិគ្គាមកំ ធារេថាតិ[១] ។

[២៣] ឯកំ សមយំ ភគវា អាឡវិយំ វិហរតិ អគ្គាឡវេ ចេតិយេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ សត្តហិ ភិក្ខវេ អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នាគតំ ហត្ថកំ អាឡវកំ ធារេថ ។ កតមេហិ សត្តហិ ។ សទ្ធោ ភិក្ខវេ ហត្ថកោ អាឡវកោ សីលវា ភិក្ខវេ ហត្ថកោ អាឡវកោ ហិរិមា ភិក្ខវេ ហត្ថកោ អាឡវកោ ឱត្តប្បី ភិក្ខវេ ហត្ថកោ អាឡវកោ ពហុស្សុតោ ភិក្ខវេ ហត្ថកោ អាឡវកោ

១ ម. ធារេហីតិ ។

ក៏ក្រាបបង្គំទូលនូវហេតុទាំងអស់នោះ ដែលខ្លួនចរចាទាំងប៉ុន្មាន ជាមួយនឹងឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ ឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម កាលបើព្យាករឲ្យសមហេតុ ឈ្មោះថា ព្យាករតាមពិត ម្នាលភិក្ខុ ឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាម ប្រកបដោយធម៌អស្ចារ្យចម្លែក ៨ ប្រការនេះឯង ដែលតថាគតព្យាករហើយ ម្នាលភិក្ខុ អ្នកចូរចាំទុកនូវឧគ្គគហបតី អ្នកស្រុកហត្ថិគ្រាមថា ប្រកបដោយធម៌អស្ចារ្យចម្លែក ៨ ប្រការនេះចុះ ។

[២៣] សម័យមួយ ព្រះមានព្រះភាគកាលគង់ក្នុងអគ្គាឡវចេតិយ ជិតស្រុកអាឡវី ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគត្រាស់ហៅភិក្ខុទាំង-ឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកនូវហត្ថកអាឡវកថាជាអ្នកប្រកបដោយធម៌អស្ចារ្យ ចម្លែក ៧ ប្រការ ។ ហត្ថកអាឡវកប្រកបដោយធម៌ អស្ចារ្យចម្លែក ៧ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានសទ្ធា ១ ម្នាលភិក្ខុទាំងឡាយ ហត្ថក-អាឡវក មានសីល ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានសេចក្តីខ្មាសបាប ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវកមានសេចក្តីខ្លាចបាប ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក ជាពហុស្សូត ១

១២៣

បណ្ណាសកេ គហបតិវគ្គោ

ចាគវា ភិក្ខវេ ហត្ថកោ អាឡវកោ បញ្ញវា ភិក្ខវេ
ហត្ថកោ អាឡវកោ ។ ឥមេហិ ខោ ភិក្ខវេ សត្តហិ
អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នាគតំ ហត្ថកំ អាឡ-
វកំ ធារេថាតិ ។ ឥទមវោច ភគវា ឥទំ វត្វាន
សុគតោ ឧដ្ឋាយាសនា វិហារំ បាវិសិ ។ អថខោ
អញ្ញតរោ ភិក្ខុ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរ-
មាទាយ យេន ហត្ថកស្ស អាឡវកស្ស និវេសនំ
តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។
អថខោ ហត្ថកោ អាឡវកោ យេន សោ ភិក្ខុ តេនុ-
បសង្កមិ ឧបសង្កមិត្វា តំ ភិក្ខុំ អភិវាទេត្វា ឯកមន្តំ
និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ហត្ថកំ អាឡវកំ សោ
ភិក្ខុ ឯតទវោច សត្តហិ ខោ ត្វំ អាវុសោ អច្ឆរិយេហិ
អព្ភុតធម្មេហិ សមន្នាគតោ ភគវតា ព្យាកតោ ។ កត-
មេហិ សត្តហិ ។ សទ្ធោ ភិក្ខវេ ហត្ថកោ អាឡវកោ

ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានចាគៈ ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំង-ឡាយ ចូរចាំទុកនូវហត្ថកអាឡវកថា ជាអ្នកប្រកបដោយធម៌ អស្ចារ្យចម្លែក ៧ ប្រការនេះឯង ។ ព្រះដ៏មានព្រះភាគ បានត្រាស់ពាក្យនេះ លុះព្រះសុគត ទ្រង់ត្រាស់ពាក្យនេះរួចហើយ ទ្រង់ក្រោកចាកអាសនៈ ស្ដេចចូលទៅកាន់វិហារ ។ គ្រានោះ ភិក្ខុ ១ រូបស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់លំនៅរបស់ហត្ថកអាឡវក លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ លំដាប់នោះ ហត្ថកអាឡវក ចូលទៅរកភិក្ខុនោះ លុះចូលទៅដល់ហើយ ថ្វាយបង្គំភិក្ខុនោះ ហើយអង្គុយក្នុងទីសមគួរ ។ លុះហត្ថកអាឡវក អង្គុយក្នុងទីសមគួរហើយ ភិក្ខុនោះ បានពោលថា ម្នាលអាវុសោ អ្នកប្រកបដោយធម៌អស្ចារ្យចម្លែក ៧ ប្រការ ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយ ។ ប្រកបដោយធម៌អស្ចារ្យចម្លែក ៧ ប្រការ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានសទ្ធា ១

សីលវា ហិរិមា ឱត្តប្បី ពហុស្សុតោ ចាគវា បញ្ញវា ភិក្ខវេ ហត្ថកោ អាឡវកោតិ ។ ឥមេហិ ខោ ត្វំ អាវុសោ សត្តហិ អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នាគតោ ភគវតា ព្យាកតោតិ ។ កច្ចិត្ថ ភន្តេ ន កោចិ គិហី អហោសិ ឱទាតវសនោតិ ។ ន ហេត្ថ អាវុសោ កោចិ គិហី អហោសិ ឱទាតវសនោតិ ។ សាធុ ភន្តេ យទេត្ថ ន កោចិ គិហី អហោសិ ឱទាតវសនោតិ ។ អថខោ សោ ភិក្ខុ ហត្ថកស្ស អាឡវកស្ស និវេសនេ បិណ្ឌបាតំ គហេត្វា ឧដ្ឋាយាសនា បក្កាមិ ។ អថខោ សោ ភិក្ខុ បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ យេន ហត្ថកស្ស អាឡវកស្ស និវេសនំ តេនុបសង្កមឹ

មានសីល ១ មានសេចក្តីខ្មាសបាប ១ មានសេចក្តីខ្លាចបាប ១ ជាពហុស្សូត ១ មានចាគៈ ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវកៈ មានបញ្ញា ១ ។ ម្នាលអាវុសោ អ្នកប្រកបដោយធម៌អស្ចារ្យចម្លែក ៧ ប្រការនេះ ដែលព្រះដ៏មានព្រះភាគ ទ្រង់ព្យាករហើយ ។ ហត្ថក-អាឡវកៈ សួរតបថា បពិត្រលោកម្ចាស់ដ៏ចម្រើន ចុះគ្រហស្ថនីមួយ អ្នកស្លៀកស មិនមានក្នុងហេតុដែលព្យាករនេះទេ ឬ ។ ម្នាលអាវុសោ គ្រហស្ថនីមួយអ្នកស្លៀកស មិនមានក្នុងហេតុព្យាករនេះទេ ។ បពិត្រលោកម្ចាស់ដ៏ចម្រើន បើគ្រហស្ថនីមួយអ្នកស្លៀកស មិនមានក្នុងហេតុព្យាករនេះទេ នុ៎ះជាការប្រពៃហើយ ។ លំដាប់នោះ ភិក្ខុនោះទទួលបិណ្ឌបាត ក្នុងលំនៅហត្ថកអាឡវកៈហើយ ក៏ក្រោកចាកអាសនៈចៀសចេញទៅ ។ លុះភិក្ខុនោះត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយនៃភត្ត ហើយក៏ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះភិក្ខុនោះ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គស្លៀកស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងវេលាបុព្វណ្ហសម័យ ហើយចូលទៅកាន់លំនៅ របស់ហត្ថកអាឡវកៈ

ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ អថខោ ភន្តេ ហត្ថកោ អាឡវកោ យេនាហំ តេនុបសង្កមិ ឧបសង្ក-មិត្វា មំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អហំ ភន្តេ ហត្ថកំ អាឡវកំ ឯតទ-វោចំ សត្តហិ ខោ ត្វំ អាវុសោ អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នាគតោ ភគវតា ព្យាកតោ ។ កតមេហិ សត្តហិ ។ សទ្ធោ ភិក្ខវេ ហត្ថកោ អាឡវកោ សីលវា ហិរិមា ឱត្តប្បី ពហុស្សុតោ ចាគវា បញ្ញវា ភិក្ខវេ ហត្ថកោ អាឡវកោតិ ។ ឥមេហិ ខោ ត្វំ អាវុសោ សត្តហិ អច្ឆរិយេហិ អព្ភុតធម្មេហិ សមន្នាគតោ ភគវតា ព្យាកតោតិ ។ ឯវំ វុត្តេ ភន្តេ ហត្ថកោ អាឡវកោ មំ ឯតទវោច កច្ចិត្ថ ភន្តេ ន កោចិ គិហី អហោសិ ឱទាតវសនោតិ ។ ន ហេត្ថ អាវុសោ កោចិ គិហី អហោសិ ឱទាតវសនោតិ ។

លុះចូលទៅដល់ហើយ ក៏អង្គុយលើអាសនៈដែលគេក្រាលទុក ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ហត្ថកអាឡវកចូលទៅរកខ្ញុំព្រះអង្គ លុះចូលទៅដល់ហើយ ក៏ថ្វាយបង្គំខ្ញុំព្រះអង្គហើយ អង្គុយក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះហត្ថកអាឡវក អង្គុយក្នុងទីសមគួរហើយ ខ្ញុំព្រះអង្គបានពោលទៅដូច្នេះថា ម្នាលអាវុសោ អ្នកប្រកបដោយធម៌អស្ចារ្យចម្លែក ៧ ប្រការ ដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករហើយ ។ ប្រកបដោយធម៌អស្ចារ្យចម្លែក ៧ ប្រការ តើដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានសទ្ធា ១ មានសីល ១ មានសេចក្ដីខ្មាសបាប ១ មានសេចក្ដីខ្លាចបាប ១ ជាពហុស្សូត ១ មានចាគៈ ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានបញ្ញា ១ ។ ម្នាលអាវុសោ អ្នកប្រកបដោយធម៌អស្ចារ្យចម្លែក ៧ ប្រការនេះឯង ដែលព្រះដ៏មានព្រះភាគ ទ្រង់ព្យាករហើយ ។ បពិត្រព្រះអង្គដ៏ច្រើន កាលដែលខ្ញុំព្រះអង្គពោលយ៉ាងនេះហើយ ហត្ថកអាឡវកនិយាយនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន គ្រហស្ថនីមួយអ្នកស្បៀកស មិនមានក្នុងហេតុព្យាករនេះទេឬ ។ ម្នាលអាវុសោ គ្រហស្ថនីមួយអ្នកស្បៀកស មិនមានក្នុងហេតុព្យាករនេះទេ ។

សាធុ ភន្តេ យទេត្ថ ន កោចិ គិហី អហោសិ ឱទាតវសនោតិ ។ សាធុ សាធុ ភិក្ខុ អប្បិច្ឆោ សោ កុលបុត្តោ សន្តេយេវ អត្តនិ កុសលេ ធម្មេ ន ឥច្ឆតិ បរេហិ ញាយមានេ ។ តេនហិ ត្វំ ភិក្ខុ ឥមិនា អច្ឆរិយេន អព្ភុតធម្មេន សមន្នាគតំ ហត្ថកំ អាឡវកំ ធារេហិ យថិទំ ។ បេ ។ អប្បិច្ឆតាយាតិ ។

[២៨] ឯកំ សមយំ ភគវា អាឡវិយំ វិហរតិ អគ្គាឡវេ ចេតិយេ ។ អថខោ ហត្ថកោ អាឡវកោ បញ្ចមត្តេហិ ឧបាសកសតេហិ បរិវុតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ ហត្ថកំ អាឡវកំ ភគវា ឯតទវោច មហតី ខោ ត្យាយំ ហត្ថក បរិសា កថំ បន ត្វំ ហត្ថក ឥមំ មហតឹ បរិសំ សង្គណ្ហាសីតិ ។ យានិមានិ ភន្តេ ភគវតា ទេសិតានិ ចត្តារិ សង្គហវត្ថូនិ តេហាហំ ឥមំ មហតឹ បរិសំ សង្គណ្ហាមិ ។

បពិត្រលោកម្ចាស់ដ៏ចម្រើន បើគ្រហស្ថនីមួយអ្នកស្មៀកស មិនមានក្នុងហេតុព្យាករនេះទេ នុ៎ះជាការប្រពៃហើយ ។ ព្រះអង្គត្រាស់ថា ម្នាលភិក្ខុ ប្រពៃហើយ ប្រពៃហើយ កុលបុត្រនោះជាអ្នកប្រាថ្នាតិច កាលបើកុសលធម៌មាននៅក្នុងខ្លួនហើយ រមែងមិនប្រាថ្នាឲ្យអ្នកដទៃដឹងទេ ។ ម្នាលភិក្ខុ បើដូច្នោះ អ្នកចូរចាំទុកនូវហត្ថកអាឡវក ថាជាអ្នកប្រកបដោយធម៌អស្ចារ្យចម្លែកនេះគឺ ។ បេ ។ ភាពជាអ្នកប្រាថ្នាតិច ។

[២៤] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងអគ្គាឡវចេតិយ ជិតស្រុកអាឡវី ។ គ្រានោះ ហត្ថកអាឡវក មានឧបាសកចំនួន ៥០០ នាក់ចោមរោម ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះហត្ថកអាឡវក អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលហត្ថកៈ ពួកបរិសទ្យរបស់អ្នកច្រើនណាស់ ម្នាលហត្ថកៈ ចុះអ្នកសង្គ្រោះបរិសទ្យច្រើននេះដូចម្តេចខ្លះ ។ បពិត្រព្រះអង្គដ៏ចម្រើន សង្គហវត្ថុទាំងឡាយ ៤ ប្រការណា ដែលព្រះដ៏មានព្រះភាគ ទ្រង់សម្តែងហើយ ខ្ញុំព្រះអង្គរមែងសង្គ្រោះបរិសទ្យច្រើននេះ ដោយសង្គហវត្ថុទាំងឡាយនោះ ។

១២៧



អហំ ភន្តេ យំ ជានាមិ អយំ ទានេន សង្គហេតព្វោតិ តំ ទានេន សង្គណ្ហាមិ យំ ជានាមិ អយំ បេយ្យវាចេន[១] សង្គហេតព្វោតិ តំ បេយ្យវាចេន សង្គណ្ហាមិ យំ ជានាមិ អយំ អត្ថចរិយាយ សង្គហេតព្វោតិ តំ អត្ថចរិយាយ សង្គណ្ហាមិ យំ ជានាមិ អយំ សមានត្តតាយ សង្គហេតព្វោតិ តំ សមានត្តតាយ សង្គណ្ហាមិ ។ សំវិជ្ជន្តេ ខោ បន មេ ភន្តេ កុលេ ភោគា ទលិទ្ទស្ស ខោ នោ តថា សោតព្វំ មញ្ញន្តីតិ ។ សាធុ សាធុ ហត្ថក យោនិ ខោ ត្យាយំ ហត្ថក មហតឹ បរិសំ សង្គហេតុំ ។ យេបិ ហិ កេចិ ហត្ថក អតីតមទ្ធានំ មហតឹ បរិសំ សង្គហេសុំ សព្វេ តេ ឥមេហេវ ចតូហិ សង្គហវត្ថូហិ មហតឹ បរិសំ សង្គហេសុំ ។ យេបិ ហិ កេចិ ហត្ថក អនាគតមទ្ធានំ មហតឹ បរិសំ សង្គណ្ហិស្សន្តិ

១ ឱ. ម. បេយ្យវជ្ជេន ។

បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ដឹងនូវបុគ្គលណាថា បុគ្គលនេះ គួរសង្គ្រោះដោយការឲ្យ ខ្ញុំព្រះអង្គក៏សង្គ្រោះបុគ្គលនោះ ដោយការឲ្យ ខ្ញុំព្រះអង្គដឹងនូវបុគ្គលណាថា បុគ្គលនេះ គួរសង្គ្រោះដោយសម្ដី ជាទីស្រឡាញ់ ខ្ញុំព្រះអង្គក៏សង្គ្រោះបុគ្គលនោះ ដោយសម្ដី ជាទីស្រឡាញ់ ខ្ញុំព្រះអង្គដឹងនូវបុគ្គលណាថា បុគ្គលនេះ គួរសង្គ្រោះដោយការប្រព្រឹត្តនូវប្រយោជន៍ ខ្ញុំព្រះអង្គ ក៏សង្គ្រោះបុគ្គលនោះ ដោយការប្រព្រឹត្តនូវប្រយោជន៍ ខ្ញុំព្រះអង្គដឹងនូវបុគ្គលណាថា បុគ្គលនេះ គួរសង្គ្រោះដោយការតាំងខ្លួនឲ្យស្មើៗ ខ្ញុំព្រះអង្គក៏សង្គ្រោះបុគ្គលនោះ ដោយការតាំងខ្លួនឲ្យស្មើៗ ។ បពិត្រព្រះអង្គដ៏ចម្រើន ភោគសម្បត្តិក្នុងត្រកូលរបស់ខ្ញុំព្រះអង្គមានច្រើន ពួកមហាជន រមែងមិនសម្គាល់នូវពាក្យរបស់ជនអ្នកកម្សត់ថាជាពាក្យគួរស្ដាប់ ដូចជាពាក្យរបស់ខ្ញុំព្រះអង្គទេ ។ ម្នាលហត្ថកៈ ប្រពៃហើយ ប្រពៃហើយ ម្នាលហត្ថកៈ នេះជាឧបាយរបស់អ្នកដើម្បីសង្គ្រោះនូវបរិសទ្យច្រើន ។ ម្នាលហត្ថកៈ ព្រោះថា ពួកជនណាមួយ បានសង្គ្រោះ បរិសទ្យច្រើន ក្នុងកាលកន្លងទៅហើយ ជនទាំងអស់នោះ បានសង្គ្រោះនូវបរិសទ្យច្រើន ដោយសង្គហវត្ថុទាំង ៤ នេះឯង ។ ម្នាលហត្ថកៈ ពួកជនណាមួយ នឹងសង្គ្រោះបរិសទ្យច្រើន ក្នុងកាលជា

សព្វេ តេ ឥមេហេវ ចតូហិ សង្គហវត្ថូហិ មហតឹ បរិសំ សង្គណ្ហិស្សន្តិ ។ យេបិ ហិ កេចិ ហត្ថក ឯតរហិ មហតឹ បរិសំ សង្គណ្ហន្តិ សព្វេ តេ ឥមេហេវ ចតូហិ សង្គហវត្ថូហិ មហតឹ បរិសំ សង្គណ្ហន្តីតិ ។ អថខោ ហត្ថកោ អាឡវកោ ភគវតា ធម្មិយា កថាយ សន្ទស្សិតោ សមាទបិតោ សមុត្តេជិតោ សម្បហំសិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា អចិរបក្កន្តេ ហត្ថកេ អាឡវកេ ភិក្ខូ អាមន្តេសិ អដ្ឋហិ ភិក្ខវេ អច្ឆរិ-យេហិ អព្ភុតធម្មេហិ សមន្នាគតំ ហត្ថកំ អាឡវកំ ធារេថ ។ កតមេហិ អដ្ឋហិ ។ សទ្ធោ ភិក្ខវេ ហត្ថកោ អាឡវកោ សីលវា ហិរិមា ឱត្តប្បី ពហុស្សុតោ ចាគវា បញ្ញវា ភិក្ខវេ ហត្ថកោ អាឡវកោ អប្បិច្ឆោ ភិក្ខវេ ហត្ថកោ អាឡវកោ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ អច្ឆរិយេហិ អព្ភុត-ធម្មេហិ សមន្នាគតំ ហត្ថកំ អាឡវកំ ធារេថាតិ ។

អនាគត ជនទាំងអស់នោះនឹងសង្គ្រោះនូវបរិសទ្យច្រើន ដោយសង្គហវត្ថុទាំង ៤ នេះ ឯង ។ ម្នាលហត្ថកៈ ពួកជនណាមួយ សង្គ្រោះបរិសទ្យច្រើន ក្នុងកាលឥឡូវនេះ ជនទាំងអស់នោះ តែងសង្គ្រោះនូវបរិសទ្យច្រើន ដោយសង្គហវត្ថុទាំង ៤ នេះឯង ។ លំដាប់នោះ ហត្ថកអាឡវកកាលដែលព្រះដ៏មានព្រះភាគ ទ្រង់ពន្យល់ណែនាំ ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏ក្រោកចាកអាសនៈថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណចៀសចេញទៅ ។ លុះហត្ថកអាឡវក ចៀសចេញទៅមិនយូរប៉ុន្មាន ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកនូវហត្ថកអាឡវកថាជាអ្នកប្រកបដោយធម៌អស្ចារ្យចម្លែក ៨ ប្រការ ។ ហត្ថកអាឡវក ប្រកបដោយធម៌អស្ចារ្យចម្លែក ៨ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានសទ្ធា ១ មានសីល ១ មានសេចក្តីខ្មាសបាប ១ មានសេចក្តីខ្លាចបាប ១ ជាពហុស្សូត ១ មានចាគៈ ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានបញ្ញា ១ ម្នាលភិក្ខុទាំងឡាយ ហត្ថកអាឡវក មានសេចក្តីប្រាថ្នាតិច ១ ។ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ ចូរចាំទុកនូវហត្ថកអាឡវក ថាជាអ្នកប្រកបដោយធម៌អស្ចារ្យចម្លែក ៨ ប្រការនេះចុះ ។

[២៨] ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថខោ មហានាមោ សក្កោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ មហានាមោ សក្កោ ភគវន្តំ ឯតទវោច កិត្តាវតា នុ ខោ ភន្តេ ឧបាសកោ ហោតីតិ ។ យតោ ខោ មហានាម ពុទ្ធំ សរណំ គតោ ហោតិ ធម្មំ សរណំ គតោ ហោតិ សង្ឃំ សរណំ គតោ ហោតិ ឯត្តាវតា ខោ មហានាម ឧបាសកោ ហោតីតិ ។

កិត្តាវតា បន ភន្តេ ឧបាសកោ សីលវា ហោតីតិ ។ យតោ ខោ មហានាម ឧបាសកោ បាណាតិបាតា បដិវិរតោ ហោតិ អទិន្នាទានា បដិវិរតោ ហោតិ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ មុសាវាទា បដិវិរតោ ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ឯត្តាវតា ខោ មហានាម ឧបាសកោ សីលវា ហោតីតិ ។

បណ្ណាសក  គហបតិវគ្គ

[២៥] *សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងនិគ្រោធារាម ជិតក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ គ្រានោះ សក្យមហានាម ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចគង់ក្នុងទីដ៏សមគួរ ។ លុះសក្យមហានាម គង់ក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលបានជាឧបាសក តើដោយហេតុដូចម្តេច ។ បពិត្រមហានាម បុគ្គលអ្នកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ដោយហេតុណា បពិត្រមហានាម បុគ្គលបានជាឧបាសក ដោយហេតុប៉ុណ្ណោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសកអ្នកមានសីល តើដោយហេតុដូចម្តេច ។ បពិត្រមហានាម ឧបាសកជាអ្នកវៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ដោយហេតុណា បពិត្រមហានាម ឧបាសក អ្នកមានសីល ដោយហេតុប៉ុណ្ណោះឯង ។*

កិត្តាវតា បន ភន្តេ ឧបាសកោ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយាតិ ។ យតោ ខោ មហានាម ឧបាសកោ អត្តនា ច សទ្ធាសម្បន្នោ ហោតិ នោ បរំ សទ្ធាសម្បទាយ សមាទបេតិ អត្តនា ច សីលសម្បន្នោ ហោតិ នោ បរំ សីលសម្បទាយ សមាទបេតិ អត្តនា ច ចាគសម្បន្នោ ហោតិ នោ បរំ ចាគសម្បទាយ សមាទបេតិ អត្តនា ច ភិក្ខូនំ ទស្សនកាមោ ហោតិ នោ បរំ ភិក្ខូនំ ទស្សនេ សមាទបេតិ អត្តនា ច សទ្ធម្មំ សោតុកាមោ ហោតិ នោ បរំ សទ្ធម្មស្សវនេ សមាទបេតិ អត្តនា ច សុតានំ ធម្មានំ ធារកជាតិកោ ហោតិ នោ បរំ ធម្មធារណាយ សមាទបេតិ អត្តនា ច សុតានំ[១] ធម្មានំ អត្ថុបបរិក្ខី ហោតិ នោ បរំ អត្ថុបបរិក្ខាយ សមាទបេតិ អត្តនា ច អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ នោ បរំ ធម្មានុធម្មប្បដិបត្តិយា សមាទបេតិ

១ ឱ. អត្តនា ធតានំ ។

បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសក អ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិបត្តិ ដើម្បីប្រយោជន៍បុគ្គលដទៃទេ តើដោយហេតុដូចម្តេច ។ បពិត្រមហានាម ឧបាសកអ្នកបរិបូណ៌ ដោយសទ្ធា ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសទ្ធា ១ អ្នកបរិបូណ៌ដោយសីល ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសីល ១ អ្នកបរិបូណ៌ដោយចាគៈ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយចាគៈ ១ អ្នកចង់ជួបប្រទះពួកភិក្ខុដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យជួបប្រទះពួកភិក្ខុ ១ អ្នកចង់ស្តាប់ព្រះសទ្ធម្មដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យបានស្តាប់ព្រះសទ្ធម្ម ១ អ្នកទ្រទ្រង់ធម៌ទាំងឡាយដែលបានស្តាប់ហើយ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យទ្រទ្រង់នូវធម៌ ១ អ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលបានស្តាប់ហើយ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យពិចារណានូវអត្ថ ១ អ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯង មិនបបួលបុគ្គលដទៃ ឲ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ដោយហេតុណា

ឯត្តាវតា ខោ មហានាម ឧបាសកោ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយាតិ ។

កិត្តាវតា បន ភន្តេ ឧបាសកោ អត្តហិតាយ ច បដិបន្នោ ហោតិ បរហិតាយ ចាតិ ។ យតោ ខោ មហានាម ឧបាសកោ អត្តនា ច សទ្ធាសម្បន្នោ ហោតិ បរញ្ច សទ្ធាសម្បទាយ សមាទបេតិ អត្តនា ច សីលសម្បន្នោ ហោតិ បរញ្ច សីលសម្បទាយ សមាទបេតិ អត្តនា ច ចាគសម្បន្នោ ហោតិ បរញ្ច ចាគសម្បទាយ សមាទបេតិ អត្តនា ច ភិក្ខូនំ ទស្សនកាមោ ហោតិ បរញ្ច ភិក្ខូនំ ទស្សនេ សមាទបេតិ អត្តនា ច សទ្ធម្មំ សោតុកាមោ ហោតិ បរញ្ច សទ្ធម្មស្សវនេ សមាទបេតិ អត្តនា ច សុតានំ ធម្មានំ ធារកជាតិកោ ហោតិ បរញ្ច ធម្មធារណាយ សមាទបេតិ អត្តនា ច សុតានំ ធម្មានំ អត្ថុបបរិក្ខី ហោតិ បរញ្ច អត្ថុបបរិក្ខាយ សមាទបេតិ

បពិត្រមហានាម ឧបាសក អ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិ-បត្តិ ដើម្បីប្រយោជន៍បុគ្គលដទៃ ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។ បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសក អ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង តើដោយហេតុដូចម្ដេច ។ បពិត្រមហានាម ឧបាសក អ្នកបរិបូណ៌ដោយសទ្ធា ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសទ្ធា ១ អ្នកបរិបូណ៌ដោយសីល ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសីល ១ អ្នកបរិបូណ៌ដោយចាគៈដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយចាគៈ ១ អ្នកចង់ជួបប្រទះពួកភិក្ខុដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យបានជួបប្រទះពួកភិក្ខុ ១ អ្នកចង់ស្ដាប់ព្រះសទ្ធម្មដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យបានស្ដាប់ព្រះសទ្ធម្ម ១ អ្នកទ្រទ្រង់នូវធម៌ទាំងឡាយដែលបានស្ដាប់ហើយដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យទ្រទ្រង់នូវធម៌ ១ អ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលបានស្ដាប់ហើយដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យពិចារណានូវអត្ថ ១

អត្តនា ច អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ បរញ្ច ធម្មានុធម្មប្បដិបត្តិយា សមាទបេតិ ឯត្តាវតា ខោ មហានាម ឧបាសកោ អត្តហិតាយ ច បដិបន្នោ ហោតិ បរហិតាយ ចាតិ ។

[២៦] ឯកំ សមយំ ភគវា រាជគហេ វិហរតិ ជីវកម្ពវនេ ។ អថខោ ជីវកោ កោមារភច្ចោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ជីវកោ កោមារភច្ចោ ភគវន្តំ ឯតទវោច កិត្តាវតា នុ ខោ ភន្តេ ឧបាសកោ ហោតីតិ ។ យតោ ខោ ជីវក ពុទ្ធំ សរណំ គតោ ហោតិ ធម្មំ សរណំ គតោ ហោតិ សង្ឃំ សរណំ គតោ ហោតិ ឯត្តាវតា ខោ ជីវក ឧបាសកោ ហោតីតិ ។

កិត្តាវតា បន ភន្តេ ឧបាសកោ សីលវា ហោតីតិ ។ យតោ ខោ ជីវក ឧបាសកោ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ឯត្តាវតា ខោ ជីវក ឧបាសកោ សីលវា ហោតីតិ ។

អ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ដោយហេតុណា បពិត្រមហានាម ឧបាសក អ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង ដោយហេតុមានប្រមាណប៉ុណ្ណោះ ។

[២៦] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងជីវកម្ពវ័ន ជិតក្រុងរាជគ្រឹះ ។ គ្រានោះ ជីវកកោមារភច្ច ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីដ៏សមគួរ ។ លុះជីវកកោមារភច្ច អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន បុគ្គលបានជាឧបាសក តើដោយហេតុដូចម្តេច ។ ម្នាលជីវក បុគ្គលអ្នកដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ដោយហេតុណា ម្នាលជីវក បុគ្គលនោះ បានជាឧបាសក ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។

បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសកអ្នកមានសីល តើដោយហេតុដូចម្តេច ។ ម្នាលជីវក ឧបាសកជាអ្នកវៀរចាកបាណាតិបាត ។ បេ ។ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ដោយហេតុណា ម្នាលជីវក ឧបាសកជាអ្នកមានសីល ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។

១៣៣

បណ្ណាសកេ គហបតិវគ្គោ

កិត្តាវតា បន ភន្តេ ឧបាសកោ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយាតិ ។ យតោ ខោ ជីវក ឧបាសកោ អត្តនា ច សទ្ធាសម្បន្នោ ហោតិ នោ បរំ សទ្ធាសម្បទាយ សមាទបេតិ ។ បេ ។ អត្តនា ច អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ នោ បរំ ធម្មានុធម្មប្បដិបត្តិយា សមាទបេតិ ឯត្តាវតា ខោ ជីវក ឧបាសកោ អត្តហិតាយ បដិបន្នោ ហោតិ នោ បរហិតាយាតិ ។

កិត្តាវតា បន ភន្តេ ឧបាសកោ អត្តហិតាយ ច បដិបន្នោ ហោតិ បរហិតាយ ចាតិ ។ យតោ ខោ ជីវក ឧបាសកោ អត្តនា ច សទ្ធាសម្បន្នោ ហោតិ បរញ្ច សទ្ធាសម្បទាយ សមាទបេតិ អត្តនា ច សីលសម្បន្នោ ហោតិ បរញ្ច សីលសម្បទាយ សមាទបេតិ អត្តនា ច ចាគសម្បន្នោ ហោតិ បរញ្ច ចាគសម្បទាយ សមាទបេតិ អត្តនា ច ភិក្ខូនំ ទស្សនកាមោ ហោតិ បរញ្ច ភិក្ខូនំ ទស្សនេ សមាទបេតិ អត្តនា ច សទ្ធម្មំ សោតុកាមោ ហោតិ

បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសក អ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិបត្តិ ដើម្បីប្រយោជន៍បុគ្គលដទៃ តើដោយហេតុដូចម្តេច ។ ម្នាលជីវក ឧបាសក អ្នកបរិបូណ៌ដោយសទ្ធា ដោយខ្លួនឯង តែមិនបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ ដោយសទ្ធា ១ ។ បេ ។ អ្នកដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯង តែមិនបបួលបុគ្គលដទៃ ឲ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ដោយហេតុណា ម្នាលជីវក ឧបាសកអ្នកប្រតិបត្តិដើម្បីប្រយោជន៍ផ្ទាល់ខ្លួន មិនប្រតិបត្តិ ដើម្បីប្រយោជន៍បុគ្គលដទៃ ដោយហេតុមានប្រមាណប៉ុណ្ណេះឯង ។

បពិត្រព្រះអង្គដ៏ចម្រើន ចុះឧបាសកអ្នកប្រតិបត្តិ ដើម្បីប្រយោជន៍ផ្ទាល់ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង តើដោយហេតុដូចម្តេច ។ ម្នាលជីវក ឧបាសក អ្នកបរិបូណ៌ដោយសទ្ធា ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសទ្ធា ១ អ្នកបរិបូណ៌ដោយសីលដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយសីល ១ អ្នកបរិបូណ៌ដោយចាគៈ ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យបរិបូណ៌ដោយចាគៈ ១ អ្នកចង់ចូលប្រទះពួកភិក្ខុដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យចូលប្រទះពួកភិក្ខុ ១ អ្នកចង់ស្តាប់ព្រះសទ្ធម្មដោយខ្លួនឯង

បរញ្ច សទ្ធម្មស្សវនេ សមាទបេតិ អត្តនា ច សុតានំ ធម្មានំ ធារកជាតិកោ ហោតិ បរញ្ច ធម្មធារណាយ សមាទបេតិ អត្តនា ច សុតានំ ធម្មានំ អត្ថុបបរិក្ខី ហោតិ បរញ្ញច អត្ថុបបរិក្ខាយ សមាទបេតិ អត្តនា ច អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ បរញ្ច ធម្មានុធម្មប្បដិបត្តិយា សមាទបេតិ ឯត្តាវតា ខោ ជីវក ឧបាសកោ អត្តហិតាយ ច បដិបន្នោ ហោតិ បរហិតាយ ចាតិ ។

[២៧] អដ្ឋិមានិ ភិក្ខវេ ពលានិ ។ កតមានិ អដ្ឋ ។ រោណ្ណពលា ភិក្ខវេ ទារកា កោធពលា មាតុគ្គាមា អាវុធពលា ចោរា ឥស្សរិយពលា រាជានោ ឧជ្ឈត្តិពលា ពាលា និជ្ឈត្តិពលា បណ្ឌិតា បដិសង្ខានពលា ពហុស្សុតា ខន្តិពលា សមណ-ព្រាហ្មណា ។ ឥមានិ ខោ ភិក្ខវេ អដ្ឋ ពលានីតិ ។

ទាំងបបួលបុគ្គលដទៃ ឲ្យបានស្តាប់នូវព្រះសទ្ធម្ម ១ ជាអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ដែលបានស្តាប់ហើយដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យទ្រទ្រង់នូវធម៌ ១ អ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលបានស្តាប់ហើយ ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យពិចារណានូវអត្ថ ១ អ្នកដឹងច្បាស់នូវអត្ថ ដឹងច្បាស់នូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ដោយខ្លួនឯង ទាំងបបួលបុគ្គលដទៃ ឲ្យប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ដោយហេតុណា ម្នាលជីវក ឧបាសក អ្នកប្រតិបត្តិដើម្បីប្រយោជន៍ផ្ទាល់ខ្លួនផង ដើម្បីប្រយោជន៍បុគ្គលដទៃផង ដោយហេតុមានប្រមាណប៉ុណ្ណោះឯង ។

[២៧] ម្នាលភិក្ខុទាំងឡាយ កម្លាំងនេះមាន ៨ យ៉ាង ។ កម្លាំង ៨ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកក្មេងមានការយំជាកម្លាំង ១ ពួកមាតុគ្រាមមានសេចក្តីក្រោធ ជាកម្លាំង ១ ពួកចោរមានគ្រឿងអាវុធ ជាកម្លាំង ១ ពួកព្រះរាជាមានឥស្សរិយៈ ជាកម្លាំង ១ ពួកជនពាលមានការលើកទោស ជាកម្លាំង ១ ពួកបណ្ឌិតមានការរំពឹងគិតជាកម្លាំង ១ ពួកពហុស្សូតមានការពិចារណាជាកម្លាំង ១ ពួកសមណ-ព្រាហ្មណ៍មានការអត់ធន់ ជាកម្លាំង ១ ។ ម្នាលភិក្ខុទាំងឡាយ កម្លាំងមាន ៨ យ៉ាងនេះឯង ។

[២៨] អថខោ អាយស្មា សារីបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ សារីបុត្តំ ភគវា ឯតទវោច កតិ នុ ខោ សារីបុត្ត ខីណាសវស្ស ភិក្ខុនោ ពលានិ យេហិ ពលេហិ សមន្នាគតោ ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ អដ្ឋ ភន្តេ ខីណាសវស្ស ភិក្ខុនោ ពលានិ យេហិ ពលេហិ សមន្នាគតោ ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ កតមានិ អដ្ឋ ។ ឥធ ភន្តេ ខីណាសវស្ស ភិក្ខុនោ អនិច្ចតោ សព្វេ សង្ខារា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ ។ យម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ អនិច្ចតោ សព្វេ សង្ខារា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ

បណ្ណាសក គហបតិវគ្គ

[២៨] គ្រានោះ ព្រះសារីបុត្រដ៏មានអាយុ បានចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគរួចអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះសារីបុត្តដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលសារីបុត្ត ភិក្ខុជាខីណាស្រព ប្រកបដោយកម្លាំងទាំងឡាយណា រមែងប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ កម្លាំងទាំងនោះ របស់ភិក្ខុជាខីណាស្រព តើមានប៉ុន្មានយ៉ាង ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ប្រកបដោយកម្លាំងទាំងឡាយណា រមែងប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ កម្លាំងទាំងនោះ របស់ភិក្ខុជាខីណាស្រពមាន ៨ យ៉ាង ។ ៨ យ៉ាង តើដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ក្នុងសាសនានេះ ឃើញច្បាស់នូវសង្ខារទាំងពួងថា មិនទៀង ដោយបញ្ញាដ៏ប្រពៃ គួរតាមពិត ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព ឃើញច្បាស់នូវសង្ខារទាំងពួងថា មិនទៀង ដោយបញ្ញាដ៏ប្រពៃ គួរតាមពិត ដោយកម្លាំងណា

ឥទម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិ-ជានាតិ ខីណា មេ អាសវាតិ ។ បុន ចបរំ ភន្តេ ខីណាសវស្ស ភិក្ខុនោ អង្គារកាសូបមា កាមា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ ។ យម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ អង្គារកាសូបមា កាមា យថាភូតំ សម្មប្បញ្ញាយ សុទិដ្ឋា ហោន្តិ ឥទម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ បុន ចបរំ ភន្តេ ខីណាសវស្ស ភិក្ខុនោ វិវេកនិន្នំ ចិត្តំ ហោតិ វិវេកពោណំ វិវេកបព្ភារំ វិវេកដ្ឋំ នេក្ខម្មាភិរតំ ព្យន្តីភូតំ សព្វសោ អាសវដ្ឋានីយេហិ ធម្មេហិ ។

បពិត្រព្រះអង្គដ៏ចម្រើន (ម្យ៉ាងទៀត) ភិក្ខុជាខីណាស្រព ប្តេជ្ញានូវកិរិយាអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ ព្រោះអាស្រ័យកម្លាំងណា កម្លាំងនេះ ជាកម្លាំងរបស់ភិក្ខុជាខីណាស្រព ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណាស្រព ឃើញច្បាស់នូវកាមទាំងឡាយ មានឧបមាដូចជារណ្តៅ ដ៏ពេញដោយរងើកភ្លើង ដោយបញ្ញាដ៏ប្រពៃ គួរតាមពិត ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រពឃើញច្បាស់នូវកាមទាំងឡាយ ដែលមានឧបមាដូចជារណ្តៅដ៏ពេញដោយរងើកភ្លើង ដោយបញ្ញាដ៏ប្រពៃ គួរតាមពិត ដោយកម្លាំងណា បពិត្រព្រះអង្គដ៏ចម្រើន (ម្យ៉ាងទៀត) ភិក្ខុជាខីណាស្រព ប្តេជ្ញានូវកិរិយាអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ ព្រោះអាស្រ័យកម្លាំងណា កម្លាំងនេះ ជាកម្លាំងរបស់ភិក្ខុជាខីណាស្រព ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ចិត្តរបស់ភិក្ខុជាខីណាស្រព តែងឱនទៅរកវិវេក ឈានទៅរកវិវេក បែរទៅរកវិវេក តម្កល់នៅក្នុងវិវេក ត្រេកអរចំពោះក្នុងការចេញចាកកាម ជាចិត្តប្រាសចាកធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈដោយប្រការទាំងពួង ។

យម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ វិវេកនិន្នំ ចិត្តំ ហោតិ វិវេកចោណំ វិវេកបព្ភារំ វិវេកដ្ឋំ នេក្ខម្មាភិរតំ ព្យន្តីភូតំ សព្វសោ អាសវដ្ឋានីយេហិ ធម្មេហិ ឥទម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ បុន ចបរំ ភន្តេ ខីណាសវស្ស ភិក្ខុនោ ចត្តារោ សតិប្បដ្ឋានា ភាវិតា ហោន្តិ សុភា-វិតា ។ យម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ ចត្តារោ សតិប្បដ្ឋានា ភាវិតា ហោន្តិ សុភាវិតា ឥទម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ បុន ចបរំ ភន្តេ ខីណាសវស្ស ភិក្ខុនោ ចត្តារោ ឥទ្ធិបាទា ភាវិតា ហោន្តិ សុភាវិតា ។ បេ ។ បញ្ចិន្ទ្រិយានិ ភាវិតានិ ហោន្តិ សុភាវិតានិ

បពិត្រព្រះអង្គដ៏ចម្រើន ចិត្តរបស់ភិក្ខុ ជាខីណាស្រព តែងឱនទៅរកវិវេក ឈានទៅរកវិវេក បែរទៅរកវិវេក តម្កល់នៅក្នុងវិវេក ត្រេកអរចំពោះក្នុងការចេញចាកកាម ជាចិត្តប្រាសចាកធម៌ទាំងឡាយ ដែលជាទីតាំងនៃអាសវៈ ដោយប្រការទាំងពួង ដោយកម្លាំងណា បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណាស្រព ប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ ព្រោះអាស្រ័យកម្លាំងណា កម្លាំងនេះ ជាកម្លាំងរបស់ភិក្ខុ ជាខីណាស្រព ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណាស្រព បានចម្រើន អប់រំល្អហើយ នូវសតិប្បដ្ឋានទាំង ៤ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព បានចម្រើន អប់រំល្អហើយ នូវសតិប្បដ្ឋាន ៤ ដោយកម្លាំងណា បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណាស្រព ប្តេជ្ញានូវការអស់ទៅនៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ ព្រោះអាស្រ័យកម្លាំងណា កម្លាំងនេះ ជាកម្លាំងរបស់ភិក្ខុ ជាខីណាស្រព ។ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ភិក្ខុជាខីណាស្រព បានចម្រើនអប់រំល្អហើយ នូវឥទ្ធិបាទ ៤ ។ បេ ។ បានចម្រើន អប់រំល្អហើយ នូវឥន្ទ្រិយ ៥

សត្ត ពោជ្ឈង្គា ភាវិតា ហោន្តិ សុភាវិតា អរិយោ អដ្ឋង្គិកោ មគ្គោ ភាវិតោ ហោតិ សុភាវិតោ ។ យម្បិ ភន្តេ ខីណាសវស្ស ភិក្ខុនោ អរិយោ អដ្ឋង្គិកោ មគ្គោ ភាវិតោ ហោតិ សុភាវិតោ ឥទម្បិ ភន្តេ ខីណាស-វស្ស ភិក្ខុនោ ពលំ ហោតិ យំ ពលំ អាគម្ម ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។ ឥមានិ ខោ ភន្តេ អដ្ឋ ខីណាសវស្ស ភិក្ខុនោ ពលានិ យេហិ ពលេហិ សមន្នាគតោ ខីណាសវោ ភិក្ខុ អាសវានំ ខយំ បដិជានាតិ ខីណា មេ អាសវាតិ ។

[២៩] ខណកិច្ចោ លោកោតិ ភិក្ខវេ អស្សុតវា បុថុជ្ជនោ ភាសតិ នោ ច ខោ សោ ជានាតិ ខណំ វា អក្ខណំ វា ។ អដ្ឋិមេ ភិក្ខវេ អក្ខណា អសមយា ព្រហ្មចរិយវាសាយ ។ កតមេ អដ្ឋ ។

បានចម្រើន អប់រំល្អហើយ នូវពោជ្ឈង្គ ៧ បានចម្រើន អប់រំល្អហើយនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណាស្រព បានចម្រើន អប់រំល្អហើយនូវមគ្គប្រកបដោយអង្គ ៨ ដ៏ប្រសើរ ដោយកម្លាំងណា បពិត្រព្រះអង្គដ៏ចម្រើន (ម្យ៉ាងទៀត) ភិក្ខុជាខីណាស្រព ប្តេជ្ញានូវការអស់ទៅ នៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយរបស់អាត្មាអញអស់ហើយ ព្រោះអាស្រ័យកម្លាំងណា កម្លាំងនេះ ជាកម្លាំងរបស់ភិក្ខុជាខីណាស្រព ។ បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុជាខីណា-ស្រពប្រកបដោយកម្លាំងទាំងឡាយណា រមែងប្តេជ្ញានូវការអស់ទៅ នៃអាសវៈទាំងឡាយថា អាសវៈទាំងឡាយ របស់អាត្មាអញអស់ហើយ កម្លាំងទាំងនោះ របស់ភិក្ខុជាខីណាស្រព មាន ៨ យ៉ាងនេះឯង ។

[២៩] ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនមិនមានការចេះដឹង រមែងនិយាយថា សត្វលោកមានកិច្ចក្នុងខណៈ សត្វលោកមានកិច្ចក្នុងខណៈ តែបុថុជ្ជននោះ មិនដឹងនូវខណៈឬអក្ខណៈទេ ។ ម្នាលភិក្ខុទាំងឡាយ អក្ខណៈ អស-ម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យនេះមាន ៨ យ៉ាង ។ ៨ យ៉ាងតើអ្វីខ្លះ ។

៩៨ ភិក្ខវេ តថាគតោ ច លោកេ ឧប្បន្នោ ហោតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា ធម្មោ ច ទេសិយតិ ឧបសមិកោ បរិនិព្វានិកោ សម្ពោធគាមី សុគត-ប្បវេទិតោ អយញ្ច បុគ្គលោ និរយំ ឧបបន្នោ ហោតិ ។ អយំ ភិក្ខវេ បឋមោ អក្ខណោ អសមយោ ព្រហ្មចរិយវាសាយ ។ បុន ចបរំ ភិក្ខវេ តថាគតោ ច លោកេ ឧប្បន្នោ ហោតិ ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា ធម្មោ ច ទេសិយតិ ឧបសមិកោ បរិនិព្វានិកោ សម្ពោធគាមី សុគត-ប្បវេទិតោ អយញ្ច បុគ្គលោ តិរច្ឆានយោនឹ ឧបបន្នោ ហោតិ ។ បេ ។ អយញ្ច បុគ្គលោ

ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ដោយប្រពៃចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់ នូវត្រៃ-លោក ទ្រង់ប្រសើរដោយសីលាទិគុណ ឥតមានបុគ្គលណាស្មើ ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មាន ដូចនាយសារថី ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ជ្រាបច្បាស់នូវចតុរារិយសច្ច ទ្រង់មានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ បានកើតឡើង ក្នុងលោកនេះ ទាំងធម៌ដែលធ្វើកិលេសឲ្យស្ងប់រម្ងាប់ ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ជាដំណើរដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសទុក ព្រះអង្គក៏បានសម្តែងហើយ តែទាស់បុគ្គលនេះទៅកើតក្នុងនរក ។ ម្នាលភិក្ខុទាំងឡាយនេះជាអក្ខណៈ អសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យទី ១ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគត ។ បេ ។ ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ជ្រាបច្បាស់នូវចតុរារិយសច្ច ទ្រង់មានដំណើរទៅកាន់ត្រៃភពខ្ជាក់ចោលហើយ រមែងកើតឡើងក្នុងលោក ទាំងធម៌ដែលធ្វើកិលេសឲ្យស្ងប់រម្ងាប់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ជាដំណើរដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសទុក ព្រះអង្គបានសម្តែងហើយ តែទាស់បុគ្គលនេះ ទៅកើតក្នុងកំណើតតិរច្ឆាន ។ បេ ។ តែទាស់បុគ្គលនេះ

បិត្តិវិសយំ ឧបបន្នោ ហោតិ ។ បេ ។ អយញ្ច បុគ្គលោ អញ្ញតរំ ទីឃាយុកំ ទេវនិកាយំ ឧបបន្នោ ហោតិ ។ បេ ។ អយញ្ច បុគ្គលោ បច្ចន្តិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ សោ ច ហោតិ អវិញ្ញាតារេសុ មិលក្ខូសុ[១] យត្ថ នត្ថិ គតិ ភិក្ខូនំ ភិក្ខុនីនំ ឧបាសកានំ ឧបាសិកានំ ។ បេ ។ អយញ្ច បុគ្គលោ មជ្ឈិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ សោ ច ហោតិ មិច្ឆាទិដ្ឋិកោ វិបរីតទស្សនោ នត្ថិ ទិន្នំ នត្ថិ យិដ្ឋំ នត្ថិ ហុតំ នត្ថិ សុកតទុក្កដានំ កម្មានំ ផលំ វិបាកោ នត្ថិ អយំ លោកោ នត្ថិ បរោ លោកោ នត្ថិ មាតា នត្ថិ បិតា នត្ថិ សត្តា ឱបបាតិកា នត្ថិ លោកេ សមណព្រាហ្មណា សម្មគ្គតា សម្មាបដិបន្នា យេ ឥមញ្ច លោកំ បរញ្ច លោកំ សយំ អភិញ្ញា សច្ឆិកត្វា បវេទេន្តីតិ ។ បេ ។ អយញ្ច បុគ្គលោ មជ្ឈិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ សោ ច ហោតិ ទុប្បញ្ញោ ជឡោ

១ ឱ. មិលក្ខេសុ ។

ទៅកើតក្នុងបិត្តិវិស័យ ។ បេ ។ តែទាស់បុគ្គលនេះ ទៅកើតក្នុងពួកទេវតា ណាមួយមានអាយុវែង ។ បេ ។ តែទាស់បុគ្គលនេះ ជាអ្នកមកកើតក្នុងពួក-បច្ចន្តិមជនបទទាំងជាអ្នកបានទៅកើតក្នុងពួកមិលក្ខជន ដែលមិនដឹងការខុសត្រូវច្បាស់លាស់ ដែលជាប្រទេសគ្មានភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ទៅដល់ ។ បេ ។ បុគ្គលនេះ បានមកកើត ក្នុងពួកមជ្ឈិមជនបទហើយ ទាស់តែបុគ្គលនោះ ជាមិច្ឆាទិដ្ឋិ មានសេចក្ដីឃើញវិបរិតថា ទានដែលបុគ្គលឲ្យហើយគ្មានផល ការបូជាធំគ្មានផល ការបូជាតូចគ្មានផល ផលនិងវិបាករបស់កម្ម ដែលសត្វធ្វើល្អនិងធ្វើអាក្រក់ មិនមាន លោកនេះ ក៏មិនមាន លោកដទៃ ក៏មិនមាន មាតាក៏មិនមាន បិតាក៏មិនមាន ពួកសត្វជាឱបបាតិកៈក៏មិនមាន ពួកសមណព្រាហ្មណ៍ក្នុងលោក ជាអ្នកព្រមព្រៀងគ្នា ប្រតិបត្តិដោយល្អ ធ្វើឲ្យជាក់ច្បាស់នូវលោកនេះ និងលោកខាងមុខ ព្រោះដឹងច្បាស់ដោយខ្លួនឯង ហើយញុាំងអ្នកដទៃឲ្យត្រាស់ដឹងផង ក៏មិនមាន ។ បេ ។ បុគ្គលនេះ បានមកកើតក្នុងពួកមជ្ឈិមជនបទហើយ ទាស់តែបុគ្គលនោះ ជាអ្នកអប្បឥតប្រាជ្ញា ល្ងង់ខ្លៅ

១៤១



ឯឡមូគោ ន បដិពលោ សុភាសិតទុព្ភាសិតស្ស អត្ថមញ្ញាតុំ ។ អយំ ភិក្ខវេ សត្តមោ អក្ខណោ អសមយោ ព្រហ្មចរិយវាសាយ ។ បុន ចបរំ ភិក្ខវេ តថាគតោ ច លោកេ អនុប្បន្នោ ហោតិ អរហំ សម្មា-សម្ពុទ្ធោ ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវា ធម្មោ ច ន ទេសិយតិ ឧបសមិកោ បរិនិព្វានិកោ សម្ពោធគាមី សុគតប្បវេទិតោ អយញ្ច បុគ្គលោ មជ្ឈិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ សោ ច ហោតិ បញ្ញវា អជឡោ អនេឡមូគោ បដិពលោ សុភាសិតទុព្ភាសិតស្ស អត្ថមញ្ញាតុំ ។ អយំ ភិក្ខវេ អដ្ឋមោ អក្ខណោ អសមយោ ព្រហ្មចរិយវាសាយ ។ ឥមេ ខោ ភិក្ខវេ អដ្ឋ អក្ខណា អសមយា ព្រហ្ម-ចរិយវាសាយ ។ ឯកោ ច ខោ ភិក្ខវេ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយ ។ កតមោ ឯកោ ។

ជាមនុស្សគ មិនអង់អាច ដើម្បីដឹងសេចក្តីនៃសុភាសិតនិងទុព្ភាសិតបាន ។ ម្នាលភិក្ខុទាំងឡាយ នេះជាអក្ខណៈ អសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យទី ៧ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ព្រះតថាគត ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួង ចំពោះព្រះអង្គ ។ បេ ។ ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច មានដំណើរទៅកាន់ត្រៃភពខ្ទាក់ចោលហើយ មិនកើតឡើងក្នុងលោក ទាំងធម៌ដែលធ្វើកិលេសឲ្យស្ងប់រម្ងាប់ ប្រព្រឹត្តទៅ ដើម្បីព្រះនិព្វាន ជាដំណើរ ដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគត ទ្រង់ប្រកាសទុក ព្រះអង្គក៏មិនបានសម្តែង បុគ្គលនេះ បានកើតក្នុងមជ្ឈិមជនបទ ក៏ឯបុគ្គលនោះ ជាអ្នកមានប្រាជ្ញា មិនល្ងង់ខ្លៅ មិនជាមនុស្សគ អង់អាច ដើម្បីដឹងសេចក្តីនៃសុភាសិត និងទុព្ភាសិតបាន ។ ម្នាលភិក្ខុទាំងឡាយ នេះជាអក្ខណៈ អសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យទី ៨ ។ ម្នាលភិក្ខុទាំងឡាយ អក្ខណៈ អសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យមាន ៨ យ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ខណៈ និងសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យ មានតែមួយ ។ មួយតើដូចម្តេច ។

ឥធ ភិក្ខវេ តថាគតោ លោកេ ឧប្បន្នោ ហោតិ អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវម-នុស្សានំ ពុទ្ធោ ភគវា ធម្មោ ច ទេសិយតិ ឧបសមិកោ បរិនិព្វានិកោ សម្ពោធគាមី សុគត-ប្បវេទិតោ អយញ្ច បុគ្គលោ មជ្ឈិមេសុ ជនបទេសុ បច្ចាជាតោ ហោតិ សោ ច ហោតិ បញ្ញវា អជឡោ អនេឡមូគោ បដិពលោ សុភាសិតទុព្ភាសិ-តស្ស អត្ថមញ្ញាតុំ ។ អយំ ភិក្ខវេ ឯកោវ ខណោ ច សមយោ ច ព្រហ្មចរិយវាសាយាតិ ។

មនុស្សលោកំ លទ្ធាន សទ្ធម្មេ សុប្បវេទិតេ
យេ ខណំ នាធិគច្ឆន្តិ អតិនាមេន្តិ តេ ខណំ
ពហូហិ អក្ខណា វុត្តា បុគ្គលស្សន្តរាយិកា

ម្នាលភិក្ខុទាំងឡាយ ព្រះតថាគត ឆ្ងាយចាកកិលេស ទ្រង់ត្រាស់ដឹងនូវញេយ្យធម៌ទាំងពួងដោយប្រពៃចំពោះព្រះអង្គ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ទ្រង់មានដំណើរល្អ ទ្រង់ជ្រាបច្បាស់នូវលោក ទ្រង់ប្រសើរដោយសីលាទិគុណឥតមានបុគ្គលណាស្មើ ទ្រង់ទូន្មាននូវបុរសដែលគួរទូន្មានដូចនាយសារថី ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ជ្រាបច្បាស់នូវចតុរារិយសច្ច ទ្រង់មានដំណើរទៅកាន់ត្រៃភពខ្ចាក់ចោលហើយ បានកើតឡើងក្នុងលោកនេះ ទាំងធម៌ ដែលធ្វើកិលេសឲ្យស្ងប់រម្ងាប់ ប្រព្រឹត្តទៅដើម្បីព្រះនិព្វាន ជាដំណើរដើម្បីត្រាស់ដឹង ជាធម៌ដែលព្រះសុគតទ្រង់ប្រកាសទុក ព្រះអង្គក៏បានសម្តែងហើយទាំងបុគ្គលនេះបានកើតក្នុងពួកមជ្ឈិមជនបទ ថែមទាំងបុគ្គលនោះ ជាអ្នកមានប្រាជ្ញា មិនល្ងង់ខ្លៅ មិនជាមនុស្សគអង់អាច ដើម្បីដឹងសេចក្តីនៃសុភាសិតនិងទុព្ភាសិតបាន ។ ម្នាលភិក្ខុទាំងឡាយ នេះជាខណៈនិងសម័យ នៃការនៅប្រព្រឹត្តព្រហ្មចារ្យតែមួយ ។

ពួកជនណា បាននូវមនុស្សលោកហើយ ( បានកើតជាមនុស្ស )
តែមិនជួបប្រទះនូវខណៈ ក្នុងព្រះសទ្ធម្ម ដែលព្រះតថាគត
ទ្រង់សម្តែងដោយល្អ ជនទាំងនោះ ឈ្មោះថាកន្លងបង់នូវ
ខណៈ អក្ខណៈទាំងឡាយ ដែលអ្នកប្រាជ្ញទាំងឡាយជា
ច្រើន បានពោលហើយថា ធ្វើនូវសេចក្តីអន្តរាយដល់បុគ្គល

១៤៣

បណ្ណាសកេ គហបតិវគ្គោ

កទាចិ ករហចិ លោកោ ឧប្បជ្ជន្តិ តថាគតា
តយិទំ សម្មុខីភូតំ យំ លោកស្មឹ សុទុល្លភំ
មនុស្សប្បដិលាភោ ច សទ្ធម្មស្ស ច ទេសនា
អលំ វាយមិតុំ តត្ថ អត្តកាមេន ជន្តុនា ។
កថំ វិជញ្ញា សទ្ធម្មំ ខណោ វោ មា ឧបច្ចគា
ខណាតីតា ហិ សោចន្តិ និរយម្ហិ សមប្បិតា ។
ឥធ ចេ ន វិរាធេតិ សទ្ធម្មស្ស និយាមិតំ
វាណិជោវ អតីតត្ថោ ចិរត្តនុតបិស្សតិ
អវិជ្ជានិវុតោ បោសោ សទ្ធម្មំ អបរាធិកោ
ជាតិមរណសំសារំ ចិរំ បច្ចានុភោស្សតិ

ព្រះតថាគតទាំងឡាយ ទ្រង់កើតឡើង ក្នុងលោកម្ដង ៗ ការកើតឡើង នៃព្រះតថាគតទាំងឡាយណា ដែលសត្វបានដោយកម្រក្រៃពេក ក្នុងលោក ការកើតឡើងនៃព្រះតថាគតទាំងឡាយនោះ ក៏កើតចំពោះមុខហើយ ការបានអត្តភាពជាមនុស្សផង ការសម្ដែងនូវព្រះសទ្ធម្មផង (ក៏បានកើតចំពោះមុខហើយ) ជនអ្នកមានសេចក្ដីប្រាថ្នានូវប្រយោជន៍ គួរព្យាយាមក្នុងព្រះសទ្ធម្មនោះ ។ បុគ្គលគប្បីដឹងច្បាស់ នូវព្រះសទ្ធម្មដោយហេតុដូចម្ដេច ខណៈកុំកន្លងនូវអ្នកទាំងឡាយឡើយ ព្រោះថា ពួកជនដែលខណៈកន្លងហើយ រមែងសង្រេងសង្រៃក្នុងនរកត្រៀបត្រា ។ បើបុគ្គលណា ក្នុងលោកនេះ ញុំាងសេចក្ដីកំណត់នូវព្រះសទ្ធម្ម គឺអរិយមគ្គ មិនឲ្យសម្រេចទេ បុគ្គលនោះជាអ្នកកន្លងបង់នូវប្រយោជន៍ រមែងសង្រេងសង្រៃ អស់រាត្រីយូរ ដូចជាពាណិជ ដែលកន្លងបង់នូវប្រយោជន៍ ដូច្នោះដែរ សត្វដែលអវិជ្ជា រួបរឹតហើយ មិនញុំាងព្រះសទ្ធម្ម ឲ្យសម្រេចបាន គង់នឹងត្រឡប់មកកាន់សង្សារ គឺការកើតនិងការស្លាប់ អស់កាលដ៏យូរ

យេ ច លទ្ធា មនុស្សត្តំ សទ្ធម្មេ សុប្បវេទិតេ
អកំសុ សត្ថុ វចនំ ករិស្សន្តិ ករោន្តិ វា
ខណំ បច្ចវិតុំ[១] លោកេ ព្រហ្មចរិយំ អនុត្តរំ
យេ មគ្គំ បដិបជ្ជឹសុ តថាគតប្បវេទិតំ
យេ សំវរា ចក្ខុមតា ទេសិតាទិច្ចពន្ធុនា
តេសុ គុត្តា សទា សតោ វិហារេថ អនវស្សុតោ
សព្វេ អនុសយេ ឆេត្វា មារធេយ្យសរានុគេ
តេ វេ បារគតា លោកេ យេ បត្តា អាសវក្ខយន្តិ ។

[៣០] ឯកំ សមយំ ភគវា ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ ។ តេន ខោ បន សមយេន អាយស្មា អនុរុទ្ធោ ចេតីសុ វិហរតិ បាចីនវំសទាយេ ។ អថខោ អាយស្មតោ អនុរុទ្ធស្ស រហោគតស្ស បដិសល្លីនស្ស ឯវំ ចេតសោ បរិវិតក្កោ ឧទបាទិ អប្បិច្ឆស្សាយំ ធម្មោ

១. បច្ចវិទុន្តិ បដិវិជ្ឈឹសូតិ អដ្ឋកថាយំ ទិស្សតិ ។

មួយទៀត ពួកជនណា បាននូវអត្តភាពជាមនុស្ស ក្នុងព្រះសទ្ធម្ម ដែលព្រះតថាគត សម្តែងល្អហើយ បានធ្វើហើយ នឹងធ្វើ ឬកំពុងធ្វើ តាមពាក្យនៃព្រះសាស្តា ពួកជនណា ដើរទៅកាន់ផ្លូវ ដែលព្រះតថាគត សម្តែងទុកហើយ ពួកជននោះ ឈ្មោះថា ត្រាស់ដឹងនូវខណៈ និងព្រហ្មចារ្យដ៏ប្រសើរក្នុងលោក សេចក្តីសង្រួមណា ដែលព្រះពុទ្ធជាអាទិច្ចពន្ធុ ព្រះអង្គមានចក្ខុ បានសម្តែងហើយ បុគ្គលមានចិត្តមិនទទឹកដោយកិលេស ជាអ្នកមានស្មារតីគ្រប់កាល គប្បីគ្រប់គ្រងក្នុងសេចក្តីសង្រួមទាំងនោះ ពួកជនណា បានដល់នូវការអស់ទៅនៃអាសវៈ ជនទាំងនោះ បានកាត់នូវអនុស័យទាំងពួង ដែលទៅកាន់សង្សារ ជាលំនៅនៃមារហើយ ដល់នូវត្រើយ គឺព្រះនិព្វាន ក្នុងលោក ។

[៣០] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់សត្វម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ ។ ក្នុងសម័យនោះ ព្រះអនុរុទ្ធដ៏មានអាយុ គង់នៅក្នុងបាចីនវង្សទាយវ័ន ក្នុងដែនចេតី ។ គ្រានោះ ព្រះអនុរុទ្ធដ៏មានអាយុ នៅក្នុងទីស្ងាត់ពួនសម្ងំ មានចិត្តត្រិះរិះកើតឡើងយ៉ាងនេះថា នេះជាធម៌របស់អ្នកប្រាថ្នាតិច

នាយំ ធម្មោ មហិច្ឆស្ស សន្តុដ្ឋស្សាយំ ធម្មោ នាយំ ធម្មោ អសន្តុដ្ឋស្ស បវិវិត្តស្សាយំ ធម្មោ នាយំ ធម្មោ សង្គណិការាមស្ស អារទ្ធវីរិយស្សាយំ ធម្មោ នាយំ ធម្មោ កុសីតស្ស ឧបដ្ឋិតស្សតិស្សាយំ ធម្មោ នាយំ ធម្មោ មុដ្ឋស្សតិស្ស សមាហិតស្សាយំ ធម្មោ នាយំ ធម្មោ អសមាហិតស្ស បញ្ញវតោ អយំ ធម្មោ នាយំ ធម្មោ ទុប្បញ្ញស្សាតិ ។ អថខោ ភគវា អាយស្មតោ អនុរុទ្ធស្ស ចេតសា ចេតោបរិវិតក្កមញ្ញាយ សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ភគ្គេសុ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ អន្តរហិតោ ចេតីសុ បាចីនវំសទាយេ អាយស្មតោ អនុរុទ្ធស្ស សម្មុខេ បាតុរហោសិ និសីទិ ភគវា បញ្ញត្តេ អាសនេ ។

នេះមិនមែនជាធម៌របស់អ្នកប្រាជ្ញាច្រើន នេះជាធម៌របស់អ្នកសន្តោស នេះមិនមែនជាធម៌របស់អ្នកមិនសន្តោស នេះជាធម៌របស់អ្នកស្ងាត់ នេះមិនមែនជាធម៌របស់អ្នកត្រេកអរ ក្នុងការច្រឡូកច្រឡំដោយពួក នេះជាធម៌របស់អ្នកប្រារព្ធព្យាយាម នេះមិនមែនជាធម៌របស់អ្នកខ្ជិលច្រអូស នេះជាធម៌របស់អ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់អ្នកភ្លេចស្មារតី នេះជាធម៌របស់អ្នកមានចិត្តតាំងមាំ នេះមិនមែនជាធម៌របស់អ្នកមានចិត្តមិនតាំងមាំ នេះជាធម៌របស់អ្នកមានប្រាជ្ញា នេះមិនមែនជាធម៌របស់អ្នកឥតប្រាជ្ញា ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីត្រិះរិះក្នុងចិត្ត របស់ព្រះអនុរុទ្ធដ៏មានអាយុ ដោយព្រះហឫទ័យនៃព្រះអង្គហើយ ក៏បាត់អំពីភេសកឡាវ័ន ជាទីឲ្យអភ័យដល់សត្វម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ ស្រាប់តែមកប្រាកដ ក្នុងទីចំពោះមុខនៃព្រះអនុរុទ្ធដ៏មានអាយុ ក្នុងបាចីនវំសទាយវ័ន ក្នុងដែនចេតី ព្រះអង្គទ្រង់គង់លើអាសនៈដែលគេក្រាលថ្វាយ ដូចជាបុរសមានកម្លាំង លានូវដៃដែលខ្លួនបត់ចូល ឬបត់ចូលនូវដៃ ដែលខ្លួនលាចេញ ដូច្នោះឯង ។

អាយស្មាបិ ខោ អនុរុទ្ធោ ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ អាយស្មន្តំ អនុរុទ្ធំ ភគវា ឯតទវោច សាធុ សាធុ អនុរុទ្ធ សាធុ ខោ ត្វំ អនុរុទ្ធ យន្តំ មហាបុរិសវិតក្កំ[១] វិតក្កេសិ អប្បិច្ឆស្សាយំ ធម្មោ នាយំ ធម្មោ មហិច្ឆស្ស សន្តុដ្ឋស្សាយំ ធម្មោ នាយំ ធម្មោ អសន្តុដ្ឋស្ស បវិវិត្តស្សាយំ ធម្មោ នាយំ ធម្មោ សង្គណិការាមស្ស អារទ្ធវីរិយស្សាយំ ធម្មោ នាយំ ធម្មោ កុសីតស្ស ឧបដ្ឋិតស្សតិស្សាយំ ធម្មោ នាយំ ធម្មោ មុដ្ឋស្សតិស្ស សមាហិតស្សាយំ ធម្មោ នាយំ ធម្មោ អសមាហិតស្ស បញ្ញវតោ អយំ ធម្មោ នាយំ ធម្មោ ទុប្បញ្ញស្សាតិ ។ តេនហិ ត្វំ អនុរុទ្ធ ឥមំ អដ្ឋមំ មហាបុរិសវិតក្កំ វិតក្កេសិ និប្បបញ្ចារាមស្សាយំ ធម្មោ និប្បបញ្ចរតិនោ នាយំ ធម្មោ បបញ្ចារាមស្ស បបញ្ចរតិនោតិ ។

---

១ ឱ. សត្ត មហាបុរិសវិតក្កេ ។

ព្រះអនុរុទ្ធដ៏មានអាយុ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីដ៏សមគួរ ។ លុះព្រះអនុរុទ្ធដ៏មានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលអនុរុទ្ធ ប្រពៃហើយៗ ម្នាលអនុរុទ្ធ អ្នកបានត្រិះរិះ នូវមហាបុរិសវិតក្កៈប្រពៃហើយថា នេះជាធម៌របស់អ្នកប្រាថ្នាតិច នេះមិនមែនជាធម៌របស់អ្នកប្រាថ្នាច្រើន នេះជាធម៌របស់អ្នកសន្តោស នេះមិនមែនជាធម៌របស់អ្នកមិនសន្តោស នេះជាធម៌របស់អ្នកស្ងាត់ នេះមិនមែនជាធម៌របស់អ្នកត្រេកអរ ក្នុងការនៅច្រឡូកច្រឡំដោយពួក នេះជាធម៌របស់អ្នកប្រារព្ធព្យាយាម នេះមិនមែនជាធម៌របស់អ្នកខ្ជិលច្រអូស នេះជាធម៌របស់អ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់អ្នកភ្លេចស្មារតី នេះជាធម៌របស់អ្នកមានចិត្តតាំងមាំ នេះមិនមែនជាធម៌របស់អ្នកមានចិត្តមិនតាំងមាំ នេះជាធម៌របស់អ្នកមានប្រាជ្ញា នេះមិនមែនជាធម៌របស់អ្នកឥតប្រាជ្ញា ។ ម្នាលអនុរុទ្ធ បើដូច្នោះ អ្នកត្រិះរិះនូវមហាបុរិសវិតក្កៈ ទី ៨ នេះថា នេះជាធម៌របស់អ្នកមាននិប្បបញ្ចធម៌ គឺព្រះនិព្វាន ជាទីត្រេកអរ អ្នកត្រេកអរក្នុងនិប្បបញ្ចធម៌ នេះមិនមែនជាធម៌របស់អ្នកមានបបញ្ចធម៌[១] ជាទីត្រេកអរ អ្នកត្រេកអរក្នុងបបញ្ចធម៌ ។

១- តណ្ហា ទិដ្ឋិ មានះ ។ អដ្ឋកថា ។

១៤៧



យតោ ខោ ត្វំ អនុរុទ្ធ ឥមេ អដ្ឋ មហាបុរិសវិតក្កេ វិតក្កេស្សសិ តតោ ត្វំ អនុរុទ្ធ យាវទេវ អាកង្ខិស្សសិ វិវិច្ចេវ កាមេហិ វិវិច្ច អកុសលេហិ ធម្មេហិ សវិតក្កំ សវិចារំ វិវេកជំ បីតិសុខំ បឋមជ្ឈានំ ឧបសម្បជ្ជ វិហរិស្សសិ ។ យតោ ខោ ត្វំ អនុរុទ្ធ ឥមេ អដ្ឋ មហាបុរិសវិតក្កេ វិតក្កេស្សសិ តតោ ត្វំ អនុរុទ្ធ យាវទេវ អាកង្ខិស្សសិ វិតក្កវិចារានំ វូបសមា អជ្ឈត្តំ សម្បសាទនំ ចេតសោ ឯកោទិភាវំ អវិតក្កំ អវិចារំ សមាធិជំ បីតិសុខំ ទុតិយជ្ឈានំ ឧបសម្បជ្ជ វិហរិស្សសិ ។ យតោ ខោ ត្វំ អនុរុទ្ធ ឥមេ អដ្ឋ មហាបុរិសវិតក្កេ វិតក្កេស្សសិ តតោ ត្វំ អនុរុទ្ធ យាវទេវ អាកង្ខិស្សសិ បីតិយា ច វិរាគា ឧបេក្ខកោ ច វិហរិស្សសិ សតោ ច សម្បជានោ សុខញ្ច កាយេន បដិសំវេទេស្សសិ យន្តំ អរិយា អាចិក្ខន្តិ ឧបេក្ខកោ សតិមា សុខវិហារីតិ តតិយជ្ឈានំ ឧបសម្បជ្ជ វិហរិស្សសិ ។

ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះ ម្នាលអនុរុទ្ធ កាលនោះ អ្នកនឹងប្រាថ្នាដរាបណា អ្នកនឹងស្ងាត់ចាកកាមទាំង-ឡាយ ស្ងាត់ចាកអកុសលធម៌ទាំងឡាយ ដល់បឋមជ្ឈាន ប្រកបដោយវិតក្កៈ និងវិចារៈ មានបីតិនិងសុខ កើតអំពីសេចក្តីស្ងប់ស្ងាត់ដរាបនោះ ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះ ម្នាលអនុរុទ្ធ កាលនោះ អ្នកនឹងប្រាថ្នាដរាបណា ព្រោះរម្ងាប់នូវវិតក្កៈ និងវិចារៈ អ្នកនឹងដល់នូវទុតិយជ្ឈាន ជាធម្មជាត កើតមានក្នុងសន្តាននៃខ្លួន ប្រកបដោយសេចក្តីជ្រះថ្លា គឺសទ្ធា មានសភាពជាចិត្តខ្ពស់ឯក មិនមានវិតក្កៈ មិនមានវិចារៈ មានតែបីតិនិងសុខដែលកើតអំពីសមាធិគឺបឋមជ្ឈាន (ដរាប់នោះ) ។ ម្នាលអនុរុទ្ធ កាលណា អ្នកត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះ ម្នាលអនុរុទ្ធ កាលនោះ អ្នកនឹងប្រាថ្នា ដរាបណា អ្នកនឹងប្រកបដោយឧបេក្ខា ព្រោះមានចិត្តនឿយណាយចាកបីតិ មានស្មារតីដឹងខ្លួន សោយនូវសេចក្តីសុខ ដោយនាមកាយ ព្រះអរិយៈទាំងឡាយតែងសរសើរនូវបុគ្គល ដែលបានតតិយជ្ឈាននោះថា បុគ្គលនេះប្រកបដោយឧបេក្ខា មានស្មារតី មានធម៌ជាគ្រឿងនៅជាសុខដូច្នេះ ព្រោះតតិយជ្ឈានណា អ្នកនឹងដល់នូវតតិយជ្ឈាននោះ (ដរាបនោះ) ។

យតោ ខោ ត្វំ អនុរុទ្ធ ឥមេ អដ្ឋ មហាបុរិសវិតក្កេ វិតក្កេស្សសិ តតោ ត្វំ អនុរុទ្ធ យាវទេវ អាកង្ខិស្សសិ សុខស្ស ច បហានា ទុក្ខស្ស ច បហានា បុព្វេវ សោមនស្សទោមនស្សានំ អត្ថង្គមា អទុក្ខមសុខំ ឧបេក្ខាសតិបារិសុទ្ធឹ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរិ-ស្សសិ ។ យតោ ខោ ត្វំ អនុរុទ្ធ ឥមេ ច អដ្ឋ មហា-បុរិសវិតក្កេ វិតក្កេស្សសិ ឥមេសញ្ច ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ភវិស្សសិ អកិច្ឆលាភី អកសិរលាភី តតោ តុយ្ហំ អនុរុទ្ធ សេយ្យថាបិ នាម គហបតិស្ស វា គហបតិ-បុត្តស្ស វា នានារត្តានំ ទុស្សានំ ទុស្សករណ្ឌកោ បូរោ ឯវមេវ តេ បំសុកូលចីវរំ ខាយិស្សតិ សន្តុដ្ឋស្ស វិហរតោ រតិយា អបរិតស្សាយ ផាសុវិហារាយ ឱក្កមនាយ និព្វានស្ស ។ យតោ ខោ ត្វំ អនុរុទ្ធ ឥមេ ច អដ្ឋ មហាបុរិសវិតក្កេ វិតក្កេស្សសិ

ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះ ម្នាលអនុរុទ្ធ កាលនោះ អ្នកនឹងប្រាថ្នា ដរាបណា អ្នកនឹងដល់នូវចតុត្ថជ្ឈាន ជាធម្មជាត មានអារម្មណ៍មិនមែនជាទុក្ខ មិនមែនជាសុខ គឺឧបេក្ខា មានសតិដ៏បរិសុទ្ធដោយឧបេក្ខា ព្រោះលះបង់នូវសុខផង លះបង់នូវទុក្ខផង អស់ទៅនៃសោមនស្សនិងទោមនស្សផង (ដរាបនោះ) ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះផង ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយនូវឈានទាំង ៤ នេះ ប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នផង ម្នាលអនុរុទ្ធ ដូចជាទូសម្រាប់ដាក់សំពត់ដ៏ពេញដោយសំពត់ទាំងឡាយ ដែលគេជ្រលក់ដោយពណ៌ផ្សេងៗ របស់គហបតី ឬ គហបតិបុត្ត យ៉ាងណាមិញ បំសុកូលចីវរ ក៏នឹងប្រាកដដល់អ្នកដែលសន្តោស ដើម្បីសេចក្ដីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីចុះកាន់ព្រះនិព្វាន ក្នុងកាលនោះក៏យ៉ាងនោះដែរ ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះផង

១៤៩



ឥមេសញ្ច ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ភវិស្សសិ អកិច្ឆលាភី អកសិរលាភី តតោ តុយ្ហំ អនុរុទ្ធ សេយ្យថាបិ នាម គហបតិស្ស វា គហបតិបុត្តស្ស វា សាលីនំ ឱទនោ វិចិតកាឡកោ អនេកសូបោ អនេកព្យញ្ជនោ ឯវមេវ តេ បិណ្ឌិយាលោបភោជនំ ខាយិស្សតិ សន្តុដ្ឋស្ស វិហរតោ រតិយា អបរិតស្សាយ ផាសុវិហារាយ ឱក្កមនាយ និព្វានស្ស ។ យតោ ខោ ត្វំ អនុរុទ្ធ ឥមេ ច អដ្ឋ មហាបុរិសវិតក្កេ វិតក្កេស្សសិ ឥមេសញ្ច ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ភវិស្សសិ អកិច្ឆលាភី អកសិរលាភី តតោ តុយ្ហំ អនុរុទ្ធ សេយ្យថាបិ នាម គហបតិស្ស វា គហបតិបុត្តស្ស វា កូដាគារំ ឧល្លិត្តាវលិត្តំ និវាតំ ផុសិតគ្គឡំ បិហិតវាតបានំ ឯវមេវ តេ រុក្ខមូលសេនាសនំ ខាយិស្សតិ សន្តុដ្ឋស្ស វិហរតោ រតិយា អបរិតស្សាយ ផាសុវិហារាយ ឱក្កមនាយ និព្វានស្ស ។

ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយនូវឈានទាំង ៤ នេះ ប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នផង ម្នាលអនុរុទ្ធ ដូចជាបាយនៃស្រូវសាលីរបស់គហបតី ឬ គហបតិបុត្ត ដែលប្រាសចាកពណ៌ខ្មៅ មានសម្លច្រើនមុខ មានម្ហូបគ្រឿមច្រើនមុខ យ៉ាងណាមិញ ភោជន ជាដុំ ជាពំនូត នឹងប្រាកដដល់អ្នកដែលសន្តោស ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីចុះកាន់ព្រះនិព្វាន ក្នុងកាលនោះយ៉ាងនោះដែរ ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះផង ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយនូវឈានទាំង ៤ នេះ ដែលប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅសប្បាយ ក្នុងបច្ចុប្បន្នផង ម្នាលអនុរុទ្ធ ដូចជាផ្ទះកំពូល របស់គហបតី ឬគហបតិបុត្ត ដែលគេលាបខាងក្នុង និងខាងក្រៅ មិនមានខ្យល់ (ចេញចូល) មានគន្លឹះដ៏ជិតស្និទ្ធ មានបង្អួចបិទហើយ យ៉ាងណាមិញ រុក្ខមូលសេនាសនៈ ក៏នឹងប្រាកដដល់អ្នកដែលសន្តោស ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីចុះកាន់ព្រះនិព្វាន ក្នុងកាលនោះ ក៏យ៉ាងនោះដែរ ។

យតោ ខោ ត្វំ អនុរុទ្ធ ឥមេ ច អដ្ឋ មហាបុរិសវិតក្កេ វិតក្កេស្សសិ ឥមេសញ្ច ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ភវិស្សសិ អកិច្ឆលាភី អកសិរលាភី តតោ តុយ្ហំ អនុរុទ្ធ សេយ្យថាបិ នាម គហបតិស្ស វា គហបតិបុត្តស្ស វា បល្លង្កោ គោណកត្ថតោ បដិកត្ថតោ បដលិកត្ថតោ កាទលិមិគបវរប្បច្ចត្ថរណោ សឧត្តរច្ឆទោ ឧភតោលោហិតកូបធានោ ឯវមេវ តេ តិណសន្ថរកោ សយនាសនំ ខាយិស្សតិ សន្តុដ្ឋស្ស វិហរតោ រតិយា អបរិតស្សាយ ផាសុវិហារាយ ឱក្កមនាយ និព្វានស្ស ។ យតោ ខោ ត្វំ អនុរុទ្ធ ឥមេ ច អដ្ឋ មហាបុរិសវិតក្កេ វិតក្កេស្សសិ ឥមេសញ្ច ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ភវិស្សសិ អកិច្ឆលាភី អកសិរលាភី

ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះផង ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយ នូវឈានទាំង ៤ នេះ ដែលប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នផង ម្នាលអនុរុទ្ធ ដូចជាបល្លង្ក (គ្រែដែលមានជើងខ្ពស់វិចិត្រដោយរូបសត្វសាហាវ) របស់គហបតី ឬ គហបតិបុត្ត ដែលក្រាលដោយព្រំ មានរោមវែងជាង ៤ ធ្នាប់ ដែលក្រាលដោយកម្រាលមានពណ៌ស ដែលធ្វើដោយរោមសត្វ ដែលក្រាលដោយកម្រាលធ្វើដោយរោមសត្វ ជាផ្កាចង្កោម មានកម្រាលដ៏ឧត្តម ដែលគេធ្វើដោយស្បែកសត្វឈ្មុស មានខ្នើយមានពណ៌ក្រហម ទាំងពីរខាង គឺខ្នើយក្បាលនិងខ្នើយជើង ព្រមទាំងពិតាន មានពណ៌ក្រហមពីខាងលើ យ៉ាងណាមិញ ទីដេកនិងទីអង្គុយ ដែលធ្វើដោយកម្រាលស្មៅ ក៏នឹងប្រាកដ ដល់អ្នកដែលសន្តោស ដើម្បីសេចក្តីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីចុះកាន់ព្រះនិព្វាន ក្នុងកាលនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអនុរុទ្ធ កាលណា អ្នកនឹងត្រិះរិះនូវមហាបុរិសវិតក្កៈទាំង ៨ នេះផង ជាអ្នកបានតាមប្រាថ្នា បានមិនលំបាក បានដោយងាយ នូវឈានទាំង ៤ នេះ ប្រព្រឹត្តទៅក្នុងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នផង

តតោ តុយ្ហំ អនុរុទ្ធ សេយ្យថាបិ នាម គហបតិស្ស វា គហបតិបុត្តស្ស វា នានាភេសជ្ជានិ សេយ្យថីទំ សប្បិ នវនីតំ តេលំ មធុ ផាណិតំ ឯវមេវ តេ បូតិមុត្តភេសជ្ជំ ខាយិស្សតិ សន្តុដ្ឋស្ស វិហរតោ រតិយា អបរិតស្សាយ ផាសុវិហារាយ ឱក្កមនាយ និព្វានស្ស ។ តេនហិ ត្វំ អនុរុទ្ធ អាយតិកម្បិ វស្សាវាសំ ឥធេវ ចេតីសុ បាចីន-វំសទាយេ វិហរេយ្យាសីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អនុរុទ្ធោ ភគវតោ បច្ចស្សោសិ ។ អថខោ ភគវា អាយស្មន្តំ អនុរុទ្ធំ ឥមិនា ឱវាទេន ឱវទិត្វា សេយ្យថាបិ នាម ពលវា បុរិសោ សម្មិញ្ជិតំ វា ពាហំ បសារេយ្យ បសារិតំ វា ពាហំ សម្មិញ្ជេយ្យ ឯវមេវ ចេតីសុ បាចីន-វំសទាយេ អន្តរហិតោ ភគ្គេសុ សុំសុមារគិរេ ភេស-កឡាវនេ មិគទាយេ បាតុរហោសិ និសីទិ ភគវា បញ្ញត្តេ អាសនេ ។ និសជ្ជ ខោ ភគវា ភិក្ខូ អាមន្តេសិ អដ្ឋ វោ ភិក្ខវេ មហាបុរិសវិតក្កេ ទេសិស្សាមិ តំ សុណាថ ។ បេ ។ កតមេ ច ភិក្ខវេ អដ្ឋ មហាបុរិសវិតក្កា ។

ម្នាលអនុរុទ្ធ ដូចជាភេសជ្ជៈផ្សេងៗ គឺទឹកដោះថ្លា ទឹកដោះខាប់ ប្រេង ទឹកឃ្មុំ ទឹកអំពៅ របស់គហបតី ឬ គហបតិបុត្ត យ៉ាងណាមិញ ថ្នាំដែលត្រាំដោយទឹកមូត្រស្អុយ នឹងប្រាកដដល់អ្នកដែលសន្ដោស ដើម្បីសេចក្ដីត្រេកអរ ដើម្បីមិនតក់ស្លុត ដើម្បីនៅសប្បាយ ដើម្បីចុះកាន់ព្រះនិព្វាន ក្នុងកាលនោះ ក៏យ៉ាងនោះដែរ ។ ម្នាលអនុរុទ្ធ បើដូច្នោះ អ្នកគប្បីនៅចាំវស្សាតទៅទៀត ក្នុងបាចីនវំសទាយវ័ន ជិតដែនចេតីនេះចុះ ។ ព្រះអនុរុទ្ធដ៏មានអាយុ ទទួលស្ដាប់ព្រះពុទ្ធដីកាថា ព្រះករុណាព្រះអង្គ ។ គ្រានោះព្រះដ៏មានព្រះភាគ ទ្រង់ទូន្មានព្រះអនុរុទ្ធដ៏មានអាយុ ដោយឱវាទនេះ ហើយក៏បាត់អំពីបាចីនវំសទាយវ័ន ក្នុងដែនចេតី មកប្រាកដក្នុងភេសកឡាវ័ន ជាទីឲ្យនូវអភ័យដល់ពួកសត្វម្រឹគ ជិតក្រុងសុំសុមារគិរៈ ក្នុងភគ្គជនបទ ព្រះអង្គគង់លើអាសនៈ ដែលគេក្រាលថ្វាយ ដូចជាបុរសមានកម្លាំង លាដៃដែលខ្លួនបត់ចូល ឬបត់ចូលនូវដៃដែលខ្លួនលាចេញដូច្នោះឯង ។ លុះព្រះដ៏មានព្រះភាគ ទ្រង់គង់ហើយ ត្រាស់ហៅភិក្ខុទាំងឡាយមកថា ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងនូវមហាបុរិសវិតក្កៈ ៨ យ៉ាងដល់អ្នកទាំងឡាយ អ្នកទាំងឡាយចូរស្ដាប់នូវពាក្យនោះចុះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ចុះមហាបុរិសវិតក្កៈ ៨ យ៉ាង តើអ្វីខ្លះ ។

អប្បិច្ឆស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ មហិច្ឆស្ស សន្តុដ្ឋស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ អសន្តុដ្ឋស្ស បវិវិត្តស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ សង្គណិ-កាវាមស្ស អារទ្ធវីរិយស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ កុសីតស្ស ឧបដ្ឋិតស្សតិស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ មុដ្ឋស្សតិស្ស សមាហិតស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ អសមាហិតស្ស បញ្ញវតោ អយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ ទុប្បញ្ញស្ស និប្បបញ្ចារា-មស្សាយំ ភិក្ខវេ ធម្មោ និប្បបញ្ចរតិនោ នាយំ ធម្មោ បបញ្ចារាមស្ស បបញ្ចរតិនោ ។

អប្បិច្ឆស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ មហិច្ឆស្សាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ ភិក្ខវេ ភិក្ខុ អប្បិច្ឆោ សមានោ

ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រាថ្នាតិច នេះមិនមែនជាធម៌របស់អ្នកប្រាថ្នាច្រើន ១ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានសេចក្តីសន្តោស នេះមិនមែនជាធម៌របស់អ្នកមិនមានសេចក្តីសន្តោស ១ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកស្ងាត់ នេះមិនមែនជាធម៌របស់អ្នកត្រេកអរដោយពួក ១ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រារព្ធសេចក្តីព្យាយាម នេះមិនមែនជាធម៌របស់អ្នកខ្ជិលច្រអូស ១ ម្នាលភិក្ខុទាំង-ឡាយ នេះជាធម៌របស់អ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់អ្នកភ្លេចស្មារតី ១ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានចិត្តតាំងមាំ នេះមិនមែនជាធម៌របស់អ្នកមានចិត្តមិនតាំងមាំ ១ ម្នាលភិក្ខុទាំង-ឡាយ នេះជាធម៌របស់អ្នកមានប្រាជ្ញា នេះមិនមែនជាធម៌របស់អ្នកឥតប្រាជ្ញា ១ ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមាននិប្បបញ្ចធម៌ គឺព្រះនិព្វាន ជាទីត្រេកអរ អ្នកត្រេកអរក្នុងនិប្បបញ្ចធម៌ នេះមិនមែនជាធម៌របស់អ្នកមានបបញ្ចធម៌ ជាទីត្រេកអរ អ្នកត្រេកអរ ក្នុងបបញ្ចធម៌ ១ ។

ឯពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រាថ្នាតិច នេះមិនមែនជាធម៌របស់អ្នកប្រាថ្នាច្រើនដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះដែលតថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រាថ្នាតិច

១៨៣



អប្បិច្ឆោតិ មំ ជានេយ្យុន្តិ ន ឥច្ឆតិ សន្តុដ្ឋោ សមានោ សន្តុដ្ឋោតិ មំ ជានេយ្យុន្តិ ន ឥច្ឆតិ បវិវិត្តោ សមានោ បវិវិត្តោតិ មំ ជានេយ្យុន្តិ ន ឥច្ឆតិ អារទ្ធវីរិយោ សមានោ អារទ្ធវីរិយោតិ មំ ជានេយ្យុន្តិ ន ឥច្ឆតិ ឧបដ្ឋិតស្សតិ សមានោ ឧបដ្ឋិតស្សតីតិ មំ ជានេយ្យុន្តិ ន ឥច្ឆតិ សមា-ហិតោ សមានោ សមាហិតោតិ មំ ជានេយ្យុន្តិ ន ឥច្ឆតិ បញ្ញវា សមានោ បញ្ញវាតិ មំ ជានេយ្យុន្តិ ន ឥច្ឆតិ និប្បបញ្ចារាមោ សមានោ និប្បបញ្ចារាមោតិ មំ ជានេ-យ្យុន្តិ ន ឥច្ឆតិ ។ អប្បិច្ឆស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ មហិច្ឆស្សាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

រមែងមិនប្រាថ្នាថាពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកប្រាថ្នាតិចដូច្នេះ ជាអ្នកមានសេចក្តីសន្តោស រមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកមានសេចក្តីសន្តោសដូច្នេះ ជាអ្នកស្ងាត់ រមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកស្ងាត់ដូច្នេះ ជាអ្នកប្រារព្ធសេចក្តីព្យាយាម រមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកប្រារព្ធសេចក្តីព្យាយាម ដូច្នេះ ជាអ្នកមានស្មារតីខ្ជាប់ខ្ជួន រមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកមានស្មារតីខ្ជាប់ខ្ជួនដូច្នេះ ជាអ្នកមានចិត្តតាំងមាំ រមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកមានចិត្តតាំងមាំ ដូច្នេះ ជាអ្នកមានប្រាជ្ញា រមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកមានប្រាជ្ញា ដូច្នេះ ជាអ្នកមាននិប្បបញ្ចធម៌ ជាទីត្រេកអរ រមែងមិនប្រាថ្នាថា ពួកជន គប្បីដឹងនូវអាត្មាអញថាជាអ្នកមាននិប្បបញ្ចធម៌ ជាទីត្រេកអរដូច្នេះ ។ ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រាថ្នាតិច នេះមិនមែនជាធម៌របស់អ្នកប្រាថ្នាច្រើនដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះតថាគតបានពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

សន្តុដ្ឋស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ អសន្តុដ្ឋស្សាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ ភិក្ខវេ ភិក្ខុ សន្តុដ្ឋោ ហោតិ ឥតរីតរចីវរបិណ្ឌបាតសេនាសនគិលានប្បច្ចយភេសជ្ជបរិក្ខារេន សន្តុដ្ឋស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ អសន្តុដ្ឋស្សាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

បវិវិត្តស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ សង្គណិការាមស្សាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ ភិក្ខវេ ភិក្ខុនោ បវិវិត្តស្ស វិហរតោ ភវន្តិ ឧបសង្កមិតារោ ភិក្ខូ ភិក្ខុនិយោ ឧបាសកា ឧបាសិកាយោ រាជានោ រាជមហាមត្តា តិត្ថិយា តិត្ថិយស្សាវកា ។ តត្រ ភិក្ខុ វិវេកនិន្នេន ចិត្តេន វិវេកបោណេន វិវេកបព្ភារេន វិវេកដ្ឋេន នេក្ខម្មាភិរតេន

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានសេចក្តីសន្តោស នេះមិនមែនជាធម៌របស់អ្នកមិនមានសេចក្តីសន្តោសដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកសន្តោសដោយចីវរ បិណ្ឌបាត សេនាសនៈ គិលានប្បច្ចយ-ភេសជ្ជបរិក្ខារតាមមាន តាមបាន ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានសេចក្តីសន្តោស នេះមិនមែនជាធម៌របស់អ្នកមិនមានសេចក្តីសន្តោសដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកស្ងាត់ នេះមិនមែនជាធម៌ របស់អ្នកត្រេកអរ ដោយពួកដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះតថាគត ពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងប់ស្ងាត់នៅមានពួកភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ព្រះរាជា មហាមាត្យរបស់ព្រះរាជា តិរ្ថិយ និងសាវ័ករបស់តិរ្ថិយ រមែងចូលទៅរកភិក្ខុនោះ ។ ក្នុងទីនោះ ភិក្ខុមានចិត្តឱនទៅរកវិវេក ឈានទៅរកវិវេក បែរទៅរកវិវេក តម្កល់នៅក្នុងវិវេក ត្រេកអរចំពោះក្នុងការចេញចាកកាម

អញ្ញថត្ត ឧយ្យោជនិកប្បដិសំយុត្តំយេវ កាថំ កត្តា ហោតិ បរិវិត្តស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ សង្គណិការាមស្សាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

អារទ្ធវិរិយស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ កុសីតស្សាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ ភិក្ខវេ ភិក្ខុ អារទ្ធវិរិយោ វិហរតិ អកុសលានំ ធម្មានំ បហានាយ កុសលានំ ធម្មានំ ឧបសម្បទាយ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ អារទ្ធវិរិយស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ កុសីត-ស្សាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

ឧបដ្ឋិតស្សតិស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ មុដ្ឋ-ស្សតិស្សាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។

ជាអ្នកធ្វើតាមនូវពាក្យ ដែលប្រកបចំពោះដោយពាក្យ ដែលគួរបញ្ជូនទៅដោយពិត ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកស្ងាត់ នេះមិនមែនជាធម៌របស់អ្នកត្រេកអរដោយពួកដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រារព្ធព្យាយាម នេះមិនមែនជាធម៌របស់អ្នកខ្ជិលច្រអូសដូច្នេះនេះដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកប្រារព្ធសេចក្តីព្យាយាម ដើម្បីលះបង់នូវពួកអកុសលធម៌ ដើម្បីញុំាងពួកកុសលធម៌ឲ្យកើតឡើង ជាអ្នកមានកម្លាំង មានសេចក្តីប្រឹងប្រែងមាំ មិនទម្លាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកប្រារព្ធព្យាយាម នេះមិនមែនជាធម៌របស់អ្នកខ្ជិលច្រអូសដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះតថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់អ្នកភ្លេចស្មារតីដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។

ឥធ ភិក្ខវេ ភិក្ខុ សតិមា ហោតិ បរមេន សតិនេបក្កេន សមន្នាគតោ ចិរកតម្បិ ចិរភាសិតម្បិ សរិតា អនុស្សរិតា ឧបដ្ឋិតស្សតិស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ មុដ្ឋស្សតិស្សាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

សមាហិតស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ អសមាហិតស្សាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។ ឥធ ភិក្ខវេ ភិក្ខុ វិវិច្ចេវ កាមេហិ ។ បេ ។ ចតុត្ថជ្ឈានំ ឧបសម្បជ្ជ វិហរតិ សមាហិតស្សាយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ អសមាហិតស្សាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

បញ្ញវតោ អយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ ទុប្ប-ញ្ញស្សាតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ច វុត្តំ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានស្មារតី ប្រកបដោយស្មារតី និងភាពជាអ្នកមានប្រាជ្ញាចាស់ក្លាដ៏ខ្ពង់ខ្ពស់ នឹកឃើញ រឭកបានរឿយៗ នូវអំពើដែលធ្វើរួចយូរហើយផង នូវសម្តីដែលនិយាយរួចយូរហើយផង ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានស្មារតីខ្ជាប់ខ្ជួន នេះមិនមែនជាធម៌របស់អ្នកភ្លេចស្មារតីដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានចិត្តតាំងមាំ នេះមិនមែនជាធម៌ របស់អ្នកមានចិត្តមិនតាំងមាំដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ស្ងប់ស្ងាត់ចាកកាមទាំង-ឡាយ ។ បេ ។ ដល់នូវចតុត្ថជ្ឈាន ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានចិត្តតាំងមាំ នេះមិនមែនជាធម៌របស់អ្នកមានចិត្តមិនតាំងមាំដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌ របស់អ្នកមានប្រាជ្ញា នេះមិនមែនជាធម៌ របស់អ្នកឥតប្រាជ្ញាដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។

ឥធ ភិក្ខវេ ភិក្ខុ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា បញ្ញវតោ អយំ ភិក្ខវេ ធម្មោ នាយំ ធម្មោ ទុប្បញ្ញស្សាតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តំ ។

និប្បបញ្ចារាមស្សាយំ ភិក្ខវេ ធម្មោ និប្បបញ្ចរតិនោ នាយំ ធម្មោ បបញ្ចារាមស្ស បបញ្ចរតិនោតិ ឥតិ ខោ បនេតំ វុត្តំ កិញ្ចេតំ បដិច្ចំ វុត្តំ ។ ឥធ ភិក្ខវេ ភិក្ខុនោ បបញ្ចនិរោធេ ចិត្តំ បក្ខន្ទតិ បសីទតិ សន្តិដ្ឋតិ វិមុច្ចតិ និប្បបញ្ចារាមស្សាយំ ភិក្ខវេ ធម្មោ និប្បបញ្ចរតិនោ នាយំ ធម្មោ បបញ្ចារាមស្ស បប-ញ្ចរតិនោតិ ឥតិ យន្តំ វុត្តំ ឥទមេតំ បដិច្ច វុត្តន្តិ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានប្រាជ្ញា ប្រកបដោយប្រាជ្ញា ជាដំណើរទៅកាន់សេចក្តីចម្រើន និងសេចក្តីវិនាស ជាប្រាជ្ញាដ៏ប្រសើរ ជាគ្រឿងត្រាស់ដឹង ជាដំណើរទៅកាន់ការអស់ទៅនៃទុក្ខដោយប្រពៃ ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមានប្រាជ្ញា នេះមិនមែនជាធម៌របស់អ្នកឥតប្រាជ្ញាដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

ពាក្យថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមាននិប្បបញ្ចធម៌ជាទីត្រេកអរ អ្នកត្រេកអរ ក្នុងនិប្បបញ្ចធម៌ នេះមិនមែនជាធម៌របស់អ្នកមានបបញ្ចធម៌ជាទីត្រេកអរ អ្នកត្រេកអរ ក្នុងបបញ្ចធម៌ដូច្នេះនេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ តើព្រោះអាស្រ័យហេតុដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ចិត្តរបស់ភិក្ខុក្នុងសាសនានេះ រមែងស្ទុះទៅ រមែងជ្រះថ្លា រមែងតាំងនៅ រមែងបង្អោនទៅក្នុងកិរិយារលត់នៃបបញ្ចធម៌ គឺព្រះនិព្វាន ពាក្យណាថា ម្នាលភិក្ខុទាំងឡាយ នេះជាធម៌របស់អ្នកមាននិប្បបញ្ចធម៌ ជាទីត្រេកអរ អ្នកត្រេកអរ ក្នុងនិប្បបញ្ចធម៌ នេះមិនមែនជាធម៌របស់អ្នកមានបបញ្ចធម៌ជាទីត្រេកអរ អ្នកត្រេកអរ ក្នុងបបញ្ចធម៌ដូច្នេះ ដែលតថាគតពោលហើយ ពាក្យនុ៎ះ តថាគតពោលហើយ ព្រោះអាស្រ័យហេតុនេះ ។

អថខោ អាយស្មា អនុរុទ្ធោ អាយតិកម្បិ វស្សាវាសំ តត្ថេវ ចេតីសុ ចាចីនវំសទាយេ វិហាសិ ។ អថខោ អាយស្មា អនុរុទ្ធោ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ន ចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ អញ្ញតរោ ច បនាយស្មា អនុរុទ្ធោ អរហតំ អហោសិ ។ អថខោ អាយស្មា អនុរុទ្ធោ អរហត្តប្បត្តោ តាយំ វេលាយំ ឥមា គាថាយោ អភាសិ

មម សង្កប្បមញ្ញាយ សត្ថា លោកេ អនុត្តរោ
មនោមយេន កាយេន ឥទ្ធិយា ឧបសង្កមិ

គ្រានោះ ព្រះអនុរុទ្ធដ៏មានអាយុ ក៏នៅចាំវស្សាតទៅ ក្នុងបាចីនវំសទាយវ័ន ក្នុងដែនចេតីនោះឯង ។ លំដាប់នោះព្រះអនុរុទ្ធដ៏មានអាយុតែម្នាក់ឯង ចៀសចេញចាកពួក មិនមានសេចក្តីប្រមាទ មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ពួកកុលបុត្តចេញចាកផ្ទះចូលកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មានលោកក៏បានធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌ ដែលមានព្រហ្មចរិយៈជាទីបំផុតនោះ ដោយបញ្ញាដ៏ឧត្តមរបស់ខ្លួនក្នុងបច្ចុប្បន្ន ក៏ដឹងច្បាស់ថា ជាតិអស់ហើយ ព្រហ្មចរិយធម៌ បាននៅរួចហើយ សោឡសកិច្ច បានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះ មិនមានទៀតឡើយ មានសេចក្តីសរសើរថា បណ្តាព្រះអរហន្តទាំងឡាយ ព្រះអនុរុទ្ធដ៏មានអាយុ ជាព្រះអរហន្តមួយអង្គដែរ ។ លុះព្រះអនុរុទ្ធដ៏មានអាយុ បានដល់ព្រះអរហត្តហើយ បានពោលគាថាទាំងឡាយនេះក្នុងវេលានោះថា

ព្រះសាស្តា ជាបុគ្គលប្រសើរក្នុងលោក ព្រះអង្គទ្រង់
ជ្រាបច្បាស់នូវសេចក្តីត្រិះរិះ របស់អាត្មាអញ ទ្រង់មាន
កាយសម្រេចដោយចិត្ត ទ្រង់ស្តេចចូលមក ដោយឫទ្ធិ

១៤៩



យថា មេ អហុ សង្កប្បោ តតោ ឧត្តរិ ទេសយិ
និប្បបញ្ចរតោ ពុទ្ធោ និប្បបញ្ចំ អទេសយិ
តស្សាហំ ធម្មមញ្ញាយ វិហាសឹ សាសនេ រតោ
តិស្សោ វិជ្ជា អនុប្បត្តា កតំ ពុទ្ធស្ស សាសនន្តិ ។

គហបតិវគ្គោ តតិយោ ។

## តស្សុទ្ទានំ ភវតិ

ទ្វេ ឧគ្គា ទ្វេ ច ហត្ថកា មហានាមេន ជីវកោ
ទ្វេ ពលា អក្ខណា វុត្តា អនុរុទ្ធេន តេ ទសាតិ ។

*តម្រិះរបស់អាត្មាអញ កើតមានយ៉ាងណា ព្រះអង្គក៏ទ្រង់សម្តែងនូវធម៌ដ៏លើសលុបយ៉ាងនោះ ព្រះពុទ្ធទ្រង់ត្រេកអរក្នុងនិប្បបញ្ចធម៌ ក៏ទ្រង់សម្តែងនូវនិប្បបញ្ចធម៌ អាត្មាអញបានដឹងច្បាស់នូវធម៌របស់ព្រះអង្គ ក៏ត្រេកអរ ក្នុងសាសនា វិជ្ជាទាំង ៣ អាត្មាអញក៏បានសម្រេចហើយ សាសនារបស់ព្រះពុទ្ធ អាត្មាអញ ក៏បានធ្វើហើយ ។*

ចប់ គហបតិវគ្គ ទី ៣ ។

## ឧទ្ទាននៃគហបតិវគ្គនោះគឺ

*និយាយអំពីឧគ្គគហបតី ពីរលើក ហត្ថកអាឡវកពីរលើក សក្កមហានាម ១ ជីវកកោមារភច្ច ១ កម្លាំងពីរលើក អក្ខណៈ ១ ជាគម្រប់ ១០ និងព្រះអនុរុទ្ធ ។*

# ទានវគ្គោ

[៣១] អដ្ឋិមានិ ភិក្ខវេ ទានានិ ។ កតមានិ អដ្ឋ ។ អាសជ្ជ ទានំ ទេតិ ភយា ទានំ ទេតិ អទាសិ មេតិ ទានំ ទេតិ ទស្សតិ មេតិ ទានំ ទេតិ សាហុ ទានន្តិ ទានំ ទេតិ អហំ បចាមិ ឥមេ ន បចន្តិ នារហាមិ បចន្តោ អបចន្តានំ ទានំ ន ទាតុន្តិ[១] ទានំ ទេតិ ឥមំ មេ ទានំ ទទតោ កល្យាណោ កិត្តិសទ្ទោ អព្ភុគ្គច្ឆតីតិ ទានំ ទេតិ ចិត្តាលង្ការចិត្តបរិក្ខារត្ថំ ទានំ ទេតិ ។ ឥមានិ ខោ ភិក្ខវេ អដ្ឋ ទានានីតិ ។

[៣២] សទ្ធា ហិរិយំ កុសលញ្ច ទានំ
ធម្មា ឯតេ សប្បុរិសានុយាតា
ឯតញ្ហិ មគ្គំ ទិវិយំ វទន្តិ
ឯតេន ហិ គច្ឆតិ ទេវលោកន្តិ ។

[៣៣] អដ្ឋិមានិ ភិក្ខវេ ទានវត្ថូនិ ។ កតមានិ អដ្ឋ ។ ឆន្ទា ទានំ ទេតិ ទោសា ទានំ ទេតិ មោហា ទានំ ទេតិ ភយា ទានំ ទេតិ

១ ឱ. អទាតុន្តិ ។

# ទានវគ្គ

[៣១] ម្នាលភិក្ខុទាំងឡាយ ទាននេះមាន ៨ យ៉ាង ។ ទាន ៨ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលឲ្យទាន ព្រោះបានចាត់ចែងទុកស្រេច ១ ឲ្យទានព្រោះភ័យ ១ ឲ្យទានដោយគិតថា គេបានឲ្យដល់អញ ១ ឲ្យទានដោយគិតថា គេនឹងឲ្យដល់អញវិញ ១ ឲ្យទានដោយគិតថា ទានជាការប្រពៃ ១ ឲ្យទានដោយគិតថា អញចម្អិន បុគ្គលទាំងឡាយនេះ មិនទាន់ចម្អិន អញកាលចម្អិន មិនគួរ ដើម្បីមិនឲ្យទានដល់បុគ្គលមិនទាន់ចម្អិន ១ ឲ្យទានដោយគិតថា កាលបើអញឲ្យនូវទាននេះ កិត្តិស័ព្ទដ៏ពីរោះរមែងខ្ចរខ្ចាយទៅ ១ ឲ្យទានដើម្បីជាគ្រឿងប្រដាប់នៃចិត្ត និងជាបរិក្ខារនៃចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ទានមាន ៨ យ៉ាងនេះឯង ។

[៣២] សទ្ធាទាន ហិរិទាន កុសលទាន ធម៌ទាំងនេះ
ជាធម៌តាំងនៅក្នុងពួកសប្បុរស សប្បុរសទាំងឡាយ តែង
ពោលនូវធម៌នេះថាជាផ្លូវទៅកាន់ទេវលោក ព្រោះថាបុគ្គល
តែងទៅកាន់ទេវលោកបានដោយធម៌នេះ ។

[៣៣] ម្នាលភិក្ខុទាំងឡាយ ទានវត្ថុនេះមាន ៨ យ៉ាង ។ ទានវត្ថុ ៨ យ៉ាង តើដូចម្តេចខ្លះ ។ គឺបុគ្គលឲ្យទាន ព្រោះសេចក្តីស្រឡាញ់ ១ ឲ្យទានព្រោះសេចក្តីខឹង ១ ឲ្យទានព្រោះសេចក្តីល្ងង់ ១ ឲ្យទានព្រោះសេចក្តីភ័យ ១

ជិន្នបុព្វំ កាតបុព្វំ បិតុបិតាមហេហិ ជាវហាសិំ ថោរាណំ កុលវំសំ ហាបេតុន្តិ ទានំ ទេតិ ឥមាហំ ទានំ ទត្វា កាយស្ស ភេទា បរម្មរណា សុគតិំ សគ្គំ លោកំ ឧបបជ្ជិស្សាមីតិ ទានំ ទេតិ ឥមំ មេ ទានំ ទទតោ ចិត្តំ បសីទតិ អត្តមនតា សោមនស្សំ ឧបជាយតីតិ ទានំ ទេតិ ចិត្តាលង្ការចិត្តបរិក្ខារត្ថំ ទានំ ទេតិ ។ ឥមានិ ខោ ភិក្ខវេ អដ្ឋ ទានវត្ថូនីតិ ។

[៣៤] អដ្ឋង្គសមន្នាគតេ ភិក្ខវេ ខេត្តេ ពីជំ វុត្តំ ន មហប្ផលំ ហោតិ ន មហស្សាទំ ន ផាតិសេយ្យន្តិ ។ កថំ អដ្ឋង្គសមន្នាគតេ ។ ឥធ ភិក្ខវេ ខេត្តំ ឧន្នមិនិន្នាមិ ច ហោតិ ចាសាណសក្ខរិលំ ហោតិ ឧសរញ្ច ហោតិ ន ច គម្ភីរសិតំ ហោតិ ន អាយសម្បន្នំ ហោតិ ន អបាយសម្បន្នំ ហោតិ ន មាតិកាសម្បន្នំ ហោតិ ន មរិយាទសម្បន្នំ ហោតិ ។ ឯវំ អដ្ឋង្គសមន្នាគតេ ភិក្ខវេ ខេត្តេ ពីជំ វុត្តំ ន មហប្ផលំ ហោតិ ន មហស្សាទំ ន ផាតិសេយ្យន្តិ ។

ឲ្យទានព្រោះគិតថា ជីដូនជីតាទាំងឡាយ (របស់អញ) ធ្លាប់ឲ្យ ធ្លាប់ធ្វើមក អញមិនគួរញុំាងវង្សត្រកូល ពីបូរាណនុ៎ះឲ្យវិនាស ១ ឲ្យទានព្រោះគិតថា អញបានឲ្យទាននេះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ នឹងទៅកើតក្នុងសុគតិ សួគ៌ ទេវលោក ១ ឲ្យទានព្រោះគិតថា កាលអញឲ្យទាននេះ ចិត្តរមែងជ្រះថ្លា ទាំងសេចក្តីពេញចិត្តនិងសោមនស្ស ក៏រមែងកើតឡើង ១ ឲ្យទាន ដើម្បីជាគ្រឿងប្រដាប់នៃចិត្តនិងជាបរិក្ខារនៃចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ ទានវត្ថុមាន ៨ យ៉ាងនេះឯង ។

[៣៤] ម្នាលភិក្ខុទាំងឡាយ ពូជដែលបុគ្គលសាបព្រោះ ក្នុងស្រែប្រកបដោយអង្គ ៨ ជាពូជមិនមានផលច្រើន មិនមានសេចក្តីត្រេកអរច្រើន មិនចម្រើន ។ ស្រែប្រកបដោយអង្គ ៨ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ស្រែក្នុងលោកនេះ ជាស្រែមានទីទួលខ្ពស់ ទីទំនាបខ្លះ ១ មានថ្មនិងក្រួស ១ មានទឹកប្រៃ ១ គន្លងនង្គ័លមិនជ្រៅ ១ មិនបរិបូណ៌ដោយផ្លូវទឹកសម្រាប់បញ្ចូល ១ មិនបរិបូណ៌ដោយផ្លូវទឹកសម្រាប់បញ្ចេញ ១ មិនបរិបូណ៌ដោយប្រឡាយទឹក ១ មិនបរិបូណ៌ដោយភ្លឺ ១ ។ ម្នាលភិក្ខុទាំងឡាយ ពូជដែលបុគ្គលសាបព្រោះ ក្នុងស្រែប្រកបដោយអង្គ ៨ យ៉ាងនេះ ជាពូជមិនមានផលច្រើន មិនមានសេចក្តីត្រេកអរច្រើន មិនចម្រើនទេ ។

ឯវមេវ ខោ ភិក្ខវេ អដ្ឋង្គសមន្នាគតេសុ សមណ-
ព្រាហ្មណេសុ ទានំ ទិន្នំ ន មហប្ផលំ ហោតិ ន
មហានិសំសំ ន មហាជុតិកំ ន មហាវិប្ផារំ ។ កថំ
អដ្ឋង្គសមន្នាគតេសុ ។ ឥធ ភិក្ខវេ សមណព្រាហ្មណា
មិច្ឆាទិដ្ឋិកា ហោន្តិ មិច្ឆាសង្កប្បា មិច្ឆាវាចា មិច្ឆា-
កម្មន្តា មិច្ឆាអាជីវា មិច្ឆាវាយាមា មិច្ឆាសតិនោ
មិច្ឆាសមាធិនោ ។ ឯវំ អដ្ឋង្គសមន្នាគតេសុ ភិក្ខវេ
សមណព្រាហ្មណេសុ ទានំ ទិន្នំ ន មហប្ផលំ ហោតិ
ន មហានិសំសំ ន មហាជុតិកំ ន មហាវិប្ផារំ ។

អដ្ឋង្គសមន្នាគតេ ច ភិក្ខវេ ខេត្តេ ពីជំ វុត្តំ
មហប្ផលំ ហោតិ មហស្សាទំ ផាតិសេយ្យន្តិ ។ កថំ
អដ្ឋង្គសមន្នាគតេ ។ ឥធ ភិក្ខវេ ខេត្តំ អនុន្នមិនិន្នាមិ ច
ហោតិ អបាសាណសក្ខរិលញ្ច ហោតិ អនូសរញ្ច ហោតិ
គម្ភីរសិតំ ហោតិ អាយសម្បន្នំ ហោតិ អបាយសម្បន្នំ
ហោតិ មាតិកាសម្បន្នំ ហោតិ មរិយាទសម្បន្នំ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ទានដែលបុគ្គលឲ្យ ចំពោះពួកសមណព្រាហ្មណ៍ដែលប្រកបដោយអង្គ ៨ ជាទានមិនមានផលច្រើន មិនមានអានិសង្សច្រើន មិនមានសេចក្តីរុងរឿងច្រើន មិនផ្សាយទៅច្រើន ក៏យ៉ាងនោះដែរ ។ សមណព្រាហ្មណ៍ ដែលប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ក្នុងលោកនេះ ជាអ្នកយល់ឃើញខុស ១ ត្រិះរិះខុស ១ និយាយខុស ១ ធ្វើការងារខុស ១ ចិញ្ចឹមជីវិតខុស ១ ព្យាយាមខុស ១ នឹករលឹកខុស ១ តាំងចិត្តខុស ១ ។ ម្នាលភិក្ខុទាំងឡាយ ទានដែលបុគ្គលឲ្យ ចំពោះសមណព្រាហ្មណ៍ដែលប្រកបដោយអង្គ ៨ យ៉ាងនេះ ជាទានមិនមានផលច្រើន មិនមានអានិសង្សច្រើន មិនមានសេចក្តីរុងរឿងច្រើន មិនផ្សាយទៅច្រើន ។

ម្នាលភិក្ខុទាំងឡាយ ចំណែកខាងពូជដែលបុគ្គលសាបព្រោះ ក្នុងស្រែប្រកបដោយអង្គ ៨ ទើបជាពូជមានផលច្រើន មានសេចក្តីត្រេកអរច្រើន មានសេចក្តីចម្រើន ។ ស្រែប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ស្រែក្នុងលោកនេះ មិនមានទីទួលខ្ពស់ ឬទីទំនាបខ្លះ ១ មិនមានថ្មនិងក្រួស ១ មិនមានទឹកប្រៃ ១ មានគន្លងនង្គ័លជ្រៅ ១ បរិបូណ៌ដោយផ្លូវទឹក សម្រាប់បញ្ចូល ១ បរិបូណ៌ដោយផ្លូវទឹក សម្រាប់បញ្ចេញ ១ បរិបូណ៌ដោយប្រឡាយទឹក ១ បរិបូណ៌ដោយភ្លឺ ១ ។

១៦៣

## បណ្ណាសកេ ទានវគ្គោ

ឯវំ អដ្ឋង្គសមន្នាគតេ ភិក្ខវេ ខេត្តេ ពីជំ វុត្តំ មហប្ផលំ ហោតិ មហស្សាទំ ផាតិសេយ្យន្តិ ។ ឯវមេវ ខោ ភិក្ខវេ អដ្ឋង្គសមន្នាគតេសុ សមណព្រាហ្មណេសុ ទានំ ទិន្នំ មហប្ផលំ ហោតិ មហានិសំសំ មហាជុតិកំ មហាវិប្ផារំ ។ កថំ អដ្ឋង្គសមន្នាគតេសុ ។ ឥធ ភិក្ខវេ សមណព្រាហ្មណា សម្មាទិដ្ឋិកា ហោន្តិ សម្មាសង្កប្បា សម្មាវាចា សម្មាកម្មន្តា សម្មាអាជីវា សម្មាវាយាមា សម្មាសតិនោ សម្មាសមាធិនោ ។ ឯវំ អដ្ឋង្គសមន្នាគតេសុ ភិក្ខវេ សមណព្រាហ្មណេសុ ទានំ ទិន្នំ មហប្ផលំ ហោតិ មហានិសំសំ មហាជុតិកំ មហាវិប្ផារន្តិ ។

យថាបិ ខេត្តេ សម្បន្នេ បវុត្តា ពីជសម្បទា
ទេវេ សមាទយន្តម្ហិ ហោតិ ធញ្ញាយ សម្បទា
អនីតិសម្បទា ហោតិ វិរូឡ្ហិ ភវតិ សម្បទា
វេបុល្លំ សម្បទា ហោតិ ផលំ វេ ហោតិ សម្បទា ។

ម្នាលភិក្ខុទាំងឡាយ ពូជដែលបុគ្គលសាបព្រោះ ក្នុងស្រែប្រកបដោយអង្គ ៨ យ៉ាងនេះ ជាពូជមានផលច្រើន មានសេចក្តីត្រេកអរច្រើន មានសេចក្តីចម្រើន ។ ម្នាលភិក្ខុទាំងឡាយ ទានដែលបុគ្គលឲ្យហើយ ចំពោះសមណព្រាហ្មណ៍ដែលប្រកបដោយអង្គ ៨ ជាទានមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ក៏យ៉ាងនោះដែរ ។ សមណព្រាហ្មណ៍ ប្រកបដោយអង្គ ៨ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ពួកសមណព្រាហ្មណ៍ ក្នុងលោកនេះ ជាអ្នកយល់ឃើញត្រូវ ១ ត្រិះរិះត្រូវ ១ និយាយត្រូវ ១ ធ្វើការងារត្រូវ ១ ចិញ្ចឹមជីវិតត្រូវ ១ ព្យាយាមត្រូវ ១ នឹករលឹកត្រូវ ១ តាំងចិត្តត្រូវ ១ ។ ម្នាលភិក្ខុទាំងឡាយ ទានដែលបុគ្គលឲ្យហើយ ចំពោះពួកសមណព្រាហ្មណ៍ដែលប្រកបដោយអង្គ ៨ យ៉ាងនេះ ទើបជាទានមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ។

ពូជដ៏បរិបូណ៌ ដែលគេសាបព្រោះ ក្នុងស្រែដ៏ល្អ កាលបើ
មានភ្លៀងស្រួល ការបរិបូណ៌ ដោយគ្រាប់ស្រូវ ក៏រមែង
មាន គឺបរិបូណ៌ ដោយការមិនអន្តរាយ ១ ការចម្រើន
ឡើង បរិបូណ៌ ១ ការលូតលាស់ បរិបូណ៌ ១
ផ្លែហ្នឹងឯង បរិបូណ៌ ១ មានឧបមាយ៉ាងណាមិញ ។

ឯវំ  សម្បន្នសីលេសុ  ជិន្នា  ភោជនសម្បទា
សម្បទានំ  ឧបនេតិ  សម្បន្នំ  ហិស្ស  តំ  កាតំ
តស្មា  សម្បទមាកង្ខី  សម្បន្នត្ថូធ  បុក្កលោ[១]
សម្បន្នបញ្ញេ  សេវេថ  ឯវំ  ឥជ្ឈន្តិ  សម្បទា ។
វិជ្ជាចរណសម្បន្នោ  លទ្ធា  ចិត្តស្ស  សម្បទា
ករោតិ  កម្មសម្បទំ  លភតិ  ចត្ថសម្បទំ  ។
លោកំ  ញត្វា  យថាភូតំ  បប្បុយ្យ  ទិដ្ឋិសម្បទំ
មក្កសម្បទមាគម្ម  យាតិ  សម្បន្នមានសោ  ។
ឱធុនិត្វា  មលំ  សព្វំ  បត្វា  និព្វានសម្បទំ
មុច្ចតិ  សព្វទុក្ខេហិ  សា  ហោតិ  សព្វសម្បទាតិ ។

[៣៩] អដ្ឋិមា  ភិក្ខវេ  ទានូបបត្តិយោ ។ កតមា  អដ្ឋ ។

១ ឱ. សម្បន្នត្ថោធ  បុគ្គលោ ។

ភោជនដ៏បរិបូណ៌ ដែលបុគ្គលឲ្យហើយ ចំពោះពួកបុគ្គលមានសីលបរិបូណ៌ រមែងញុំាងចំណែកកុសលឲ្យកើតឡើង កុសលកម្មដែលបុគ្គលនោះធ្វើហើយ ឈ្មោះថាកម្មដ៏បរិបូណ៌មានឧបមេយ្យយ៉ាងនោះដែរ ព្រោះហេតុនោះ បុគ្គលក្នុងលោកនេះ ជាអ្នកបរិបូណ៌ មានប្រាថ្នានូវសេចក្តីបរិបូណ៌ គួរសេពគប់នូវបុគ្គលដែលមានបញ្ញាដ៏បរិបូណ៌ ការបរិបូណ៌រមែងសម្រេចយ៉ាងនេះឯង ។ បុគ្គលអ្នកបរិបូណ៌ដោយវិជ្ជានិងចរណៈ បាននូវសេចក្តីបរិបូណ៌នៃចិត្ត រមែងធ្វើនូវកម្ម ដ៏បរិបូណ៌ផង បាននូវប្រយោជន៍ក៏បរិបូណ៌ ។ បុគ្គលដឹងច្បាស់នូវសត្វលោក តាមសេចក្តីពិត រមែងសម្រេចនូវវិបស្សនាសម្មាទិដ្ឋិដ៏បរិបូណ៌ បុគ្គលអាស្រ័យនូវមគ្គដ៏បរិបូណ៌ មានចិត្តដ៏បរិបូណ៌ រមែងដល់នូវ (ព្រះអរហត្ត) ។ បុគ្គលកម្ចាត់បង់នូវមន្ទិលទាំងពួង ដល់នូវព្រះនិព្វាន ដ៏បរិបូណ៌ រមែងរួចចាកទុក្ខទាំងពួង ការរួចចាកទុក្ខនោះឯង ទើបឈ្មោះថា សេចក្តីបរិបូណ៌គ្រប់យ៉ាង ។

[៣៥] ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃទាននេះ មាន ៨ យ៉ាង ។ ការកើតឡើងនៃទាន ៨ យ៉ាង តើដូចម្តេចខ្លះ ។

ឥធ ភិក្ខវេ ឯកច្ចោ ទានំ ទេតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថំ បទីបេយ្យំ សោ យំ ទេតិ តំ បច្ចាសឹសតិ សោ បស្សតិ ខត្តិយមហាសាលេ វា ព្រាហ្មណមហាសាលេ វា គហបតិមហាសាលេ វា បញ្ចហិ កាមគុណេហិ សមប្បិតេ សមង្គីភូតេ បរិចារយមានេ ។ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរម្មរណា ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា សហព្យតំ ឧបបជ្ជេយ្យន្តិ សោ តំ ចិត្តំ បទហតិ តំ ចិត្តំ អធិដ្ឋាតិ តំ ចិត្តំ ភាវេតិ តស្ស តំ ចិត្តំ ហីនេធិមុត្តំ ឧត្តរឹ អភាវិតំ កាយស្ស ភេទា បរម្មរណា ខត្តិយមហាសាលានំ វា ព្រាហ្មណមហាសាលានំ វា គហបតិមហាសាលានំ វា សហព្យតំ ឧបបជ្ជតិ តញ្ច ខោ សីលវតោ វទាមិ នោ ទុស្សីលស្ស ឥជ្ឈតិ ភិក្ខវេ សីលវតោ ចេតោបណិធិ សុទ្ធត្តា[១] ។

១ ឱ. វិសុទ្ធត្តា ។

ម្នាលភិក្ខុទាំងឡាយ បុគ្គលពួកខ្លះ ក្នុងលោកនេះ ឲ្យទានគឺបាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ប្រទីប ជាទាន ដល់សមណៈឬព្រាហ្មណ៍ បុគ្គលនោះឲ្យនូវវត្ថុណា ក៏ប្រាថ្នានូវវត្ថុនោះ បុគ្គលនោះ ឃើញពួកខត្តិយមហាសាលក្តី ព្រាហ្មណមហាសាលក្តី គហបតិមហាសាលក្តី ដែលកំពុងឆ្អែតស្កប់ស្កល់ មូលមិត្រ បម្រើដោយកាមគុណទាំង ៥ ។ បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អញលុះបែកធ្លាយរាងកាយ ស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងខត្តិយមហាសាលក្តី ព្រាហ្មណមហាសាលក្តី គហបតិមហា-សាលក្តី បុគ្គលនោះ ក៏តម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនបានចម្រើនគុណធម៌ដ៏លើសលុបឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកខត្តិយមហាសាលខ្លះ ព្រាហ្មណមហាសាលខ្លះ គហបតិ-មហាសាលខ្លះ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯងចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ សេចក្តីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីល រមែងសម្រេចព្រោះចិត្តដ៏បរិសុទ្ធ ១ ។

ឥធ បន ភិក្ខវេ ឯកច្ចោ ទានំ ទេតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថំ បទីបេយ្យំ សោ យំ ទេតិ តំ បច្ចាសីសតិ តស្ស សុតំ ហោតិ ចាតុម្មហារាជិកា ទេវា ទីឃាយុកា វណ្ណវន្តោ សុខពហុលាតិ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរម្មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ សោ តំ ចិត្តំ ទហតិ តំ ចិត្តំ អធិដ្ឋាតិ តំ ចិត្តំ ភាវេតិ តស្ស តំ ចិត្តំ ហីនេធិមុត្តំ ឧត្តរឹ អភាវិតំ កាយស្ស ភេទា បរម្មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជតិ តញ្ច ខោ សីលវតោ វទាមិ នោ ទុស្សីលស្ស ឥជ្ឈតិ ភិក្ខវេ សីលវតោ ចេតោបណិធិ សុទ្ធត្តា ។ ឥធ បន ភិក្ខវេ ឯកច្ចោ ទានំ ទេតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថំ បទីបេយ្យំ

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ឲ្យទានគឺបាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ប្រទីប ជាទានដល់សមណៈ ឬ ព្រាហ្មណ៍ បុគ្គលនោះឲ្យវត្ថុណា ក៏ប្រាថ្នាវត្ថុនោះ បុគ្គលនោះ បានឮថា ពួកទេវតាចាតុម្មហារាជិកៈ មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អាត្មាអញ លុះបែកធ្លាយរាងកាយស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកទេវតាចាតុម្មហារាជិកៈ បុគ្គលនោះ តម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះក៏ចុះស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនចម្រើនគុណធម៌លើសលុបឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាចាតុម្មហារាជិកៈ ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីល រមែងសម្រេចព្រោះចិត្តបរិសុទ្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ឲ្យទានគឺបាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ប្រទីប ជាទានដល់សមណៈ ឬព្រាហ្មណ៍

១៦៧



សោ យំ ទេតិ តំ បច្ចាសីសតិ តស្ស សុតំ ហោតិ តាវត្តឹសា ទេវា ។ បេ ។ យាមា ទេវា... តុសិតា ទេវា... និម្មានរតី ទេវា... បរនិម្មិតវសវត្តី ទេវា ទីឃា-យុកា វណ្ណវន្តោ សុខពហុលាតិ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរម្មរណា បរនិ-ម្មិតវសវត្តីនំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ សោ តំ ចិត្តំ ទហតិ តំ ចិត្តំ អធិដ្ឋាតិ តំ ចិត្តំ ភាវេតិ តស្ស តំ ចិត្តំ ហីនេធិមុត្តំ ឧត្តរឹ អភាវិតំ កាយស្ស ភេទា បរម្មរណា បរនិម្មិតវសវត្តីនំ ទេវានំ សហព្យតំ ឧបបជ្ជតិ តញ្ច ខោ សីលវតោ វទាមិ នោ ទុស្សី-លស្ស ឥជ្ឈតិ ភិក្ខវេ សីលវតោ ចេតោបណិធិ សុទ្ធត្តា ។ ឥធ បន ភិក្ខវេ ឯកច្ចោ ទានំ ទេតិ សមណស្ស វា ព្រាហ្មណស្ស វា អន្នំ បានំ វត្ថំ យានំ មាលាគន្ធវិលេបនំ សេយ្យាវសថំ បទីបេយ្យំ

បុគ្គលនោះឲ្យវត្ថុណា ក៏ប្រាថ្នាវត្ថុនោះ បុគ្គលនោះ បានឮថា ពួកទេវតាតាវត្តិង្ស ។ បេ ។ ពួកទេវតាយាមៈ . . . ពួកទេវតាតុសិត . . . ពួកទេវតានិម្មានរតី . . . ពួកទេវតា បរនិម្មិតវសវត្តី មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន បុគ្គលនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អាត្មាអញ លុះបែកធ្លាយរាងកាយស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកទេវតាបរនិម្មិតវសវត្តី បុគ្គលនោះ តម្កល់ចិត្តនោះ អធិដ្ឋានចិត្តនោះ ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ចុះស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនបានចម្រើនគុណធម៌ ដ៏លើសលុបឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាបរនិម្មិតវសវត្តី ម្នាលភិក្ខុទាំងឡាយ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលឡើយ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្ត របស់បុគ្គលមានសីល រមែងសម្រេច ព្រោះចិត្តបរិសុទ្ធ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ឲ្យទានគឺ បាយ ទឹក សំពត់ យានជំនិះ កម្រងផ្កា គ្រឿងក្រអូប គ្រឿងលាប ទីដេក ទីអាស្រ័យនៅ គ្រឿងប្រដាប់ប្រទីប ជាទានដល់សមណៈ ឬព្រាហ្មណ៍

សោ យំ ទេតិ តំ បច្ចាសឹសតិ តស្ស សុតំ ហោតិ ព្រហ្មកាយិកា ទេវា ទីឃាយុកា វណ្ណវន្តោ សុខ-ពហុលាតិ តស្ស ឯវំ ហោតិ អហោ វតាហំ កាយស្ស ភេទា បរម្មរណា ព្រហ្មកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យន្តិ សោ តំ ចិត្តំ ទហតិ តំ ចិត្តំ អធិដ្ឋាតិ តំ ចិត្តំ ភាវេតិ តស្ស តំ ចិត្តំ ហីនេវិមុត្តំ ឧត្តរឹ អភាវិតំ កាយស្ស ភេទា បរម្មរណា ព្រហ្មកា-យិកានំ ទេវានំ សហព្យតំ ឧបបជ្ជតិ តញ្ច ខោ សីលវតោ វទាមិ នោ ទុស្សីលស្ស វីតរាគស្ស នោ សរាគស្ស ឥជ្ឈតិ ភិក្ខវេ សីលវតោ ចេតោបណិធិ វីតរាគត្តា ។ ឥមា ខោ ភិក្ខវេ អដ្ឋ ទានូបបត្តិយោតិ ។

[៣៦] តីណិមានិ ភិក្ខវេ បុញ្ញកិរិយាវត្ថូនិ ។ កតមានិ តីណិ ។ ទានមយំ បុញ្ញកិរិយាវត្ថុ[១]

១ ឱ. បុញ្ញកិរិយវត្ថុំ ។

បុគ្គលនោះឲ្យវត្ថុណា ក៏ប្រាថ្នាវត្ថុនោះ បុគ្គលនោះ បានឮថា ពួកទេវតា ព្រហ្មកាយិកៈ មានអាយុវែង មានសម្បុរល្អ មានសេចក្តីសុខច្រើន បុគ្គលនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ឱហ្ន៎ អាត្មាអញលុះបែកធ្លាយរាងកាយ ស្លាប់ទៅ សូមឲ្យទៅកើតជាមួយនឹងពួកទេវតាព្រហ្មកាយិកៈ បុគ្គលនោះ តម្កល់ចិត្តនោះ តាំងចិត្តនោះ ចម្រើនចិត្តនោះ ចិត្តរបស់បុគ្គលនោះ ក៏ចុះស៊ប់ក្នុងកាមគុណដ៏ថោកទាប មិនចម្រើនគុណធម៌ ដ៏លើសលុបឡើងទៅទៀត លុះបែកធ្លាយរាងកាយស្លាប់ទៅរមែងទៅកើត ជាមួយនឹងពួកទេវតា ព្រហ្មកាយិកៈ តថាគតពោលនូវការសម្រេចនោះឯង ចំពោះបុគ្គលមានសីល មិនចំពោះបុគ្គលទ្រុស្តសីលទេ ទានចំពោះបុគ្គលប្រាសចាករាគៈ មិនចំពោះបុគ្គល ប្រកបដោយរាគៈទេ ម្នាលភិក្ខុទាំងឡាយ សេចក្តីប្រាថ្នាដោយចិត្តរបស់បុគ្គលមានសីល រមែងសម្រេចព្រោះប្រាសចាករាគៈ ១ ។ ម្នាលភិក្ខុទាំងឡាយ ការកើតឡើងនៃទានមាន ៨ ប្រការនេះឯង ។

[៣៦] ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុនេះមាន ៣ យ៉ាង ។ បុញ្ញកិរិយាវត្ថុ ៣ យ៉ាង តើដូចម្តេចខ្លះ ។ គឺទានមយបុញ្ញ-កិរិយាវត្ថុ ( វត្ថុជាទីតាំងនៃការបំពេញបុណ្យសម្រេចអំពីការឲ្យ ) ១

សីលមយំ បុញ្ញកិរិយាវត្ថុ ភាវនាមយំ បុញ្ញកិរិយាវត្ថុ ។ ឥធ ភិក្ខវេ ឯកច្ចស្ស ទានមយំ បុញ្ញកិរិយាវត្ថុ បរិត្តំ កតំ ហោតិ សីលមយំ បុញ្ញកិរិយាវត្ថុ បរិត្តំ កតំ ហោតិ ភាវនាមយំ បុញ្ញកិរិយាវត្ថុ នាភិសម្ភោតិ ។ សោ កាយស្ស ភេទា បរម្មរណា មនុស្សទោភគ្យំ[១] ឧបបជ្ជតិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស ទានមយំ បុញ្ញកិរិយាវត្ថុ មត្តសោ កតំ ហោតិ សីលមយំ បុញ្ញកិរិយាវត្ថុ មត្តសោ កតំ ហោតិ ភាវនាមយំ បុញ្ញកិរិយាវត្ថុ នាភិសម្ភោតិ ។ សោ កាយស្ស ភេទា បរម្មរណា មនុស្សសោភគ្យំ[២] ឧបបជ្ជតិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស ទានមយំ បុញ្ញកិរិយាវត្ថុ អធិមត្តំ កតំ ហោតិ សីលមយំ បុញ្ញកិរិយាវត្ថុ អធិមត្តំ កតំ ហោតិ ភាវនាមយំ បុញ្ញកិរិយាវត្ថុ នាភិសម្ភោតិ ។ សោ កាយស្ស ភេទា បរម្មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។

១ ឱ. មនុស្សទោភគ្គំ ។ ២ ឱ. មនុស្សសោភគ្គំ ។

សីលមយបុញ្ញកិរិយាវត្ថុ (វត្ថុជាទីតាំងនៃការបំពេញបុណ្យសម្រេចអំពីការរក្សាសីល) ១ ភាវនាមយបុញ្ញកិរិយាវត្ថុ (វត្ថុជាទីតាំងនៃការបំពេញបុណ្យសម្រេចអំពីការចម្រើន) ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុ មានប្រមាណតិច ធ្វើសីល-មយបុញ្ញកិរិយាវត្ថុ មានប្រមាណតិច ប៉ុន្តែ ភាវនាមយបុញ្ញកិរិយាវត្ថុមិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតក្នុងត្រកូលមនុស្សថោកទាប ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុ ល្មមប្រមាណ ធ្វើសីលមយបុញ្ញកិរិយាវត្ថុ ក៏ល្មមប្រមាណ ប៉ុន្តែភាវនាមយ-បុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងកើតក្នុងត្រកូលមនុស្សដ៏ខ្ពង់ខ្ពស់ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃលែង ធ្វើសីលមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃលែង ប៉ុន្តែភាវនាម-យបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកទេវតាចាតុម្មហារាជិកៈ ។

តត្រ ភិក្ខវេ ចត្តារោ មហារាជានោ ទានមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ ករិត្វា សីលមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ ករិត្វា ចាតុម្មហារាជិកេ ទេវេ ទសហិ ឋានេហិ អធិគណ្ហន្តិ ទិព្វេន អាយុនា ទិព្វេន វណ្ណេន ទិព្វេន សុខេន ទិព្វេន យសេន ទិព្វេន អាធិបតេយ្យេន ទិព្វេហិ រូបេហិ ទិព្វេហិ សទ្ទេហិ ទិព្វេហិ គន្ធេហិ ទិព្វេហិ រសេហិ ទិព្វេហិ ផោដ្ឋព្វេហិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស ទានមយំ បុញ្ញកិរិយាវត្ថុ អធិមត្តំ កតំ ហោតិ សីលមយំ បុញ្ញកិរិយាវត្ថុ អធិមត្តំ កតំ ហោតិ ភាវនាមយំ បុញ្ញកិរិយាវត្ថុ នាភិសម្ភោតិ ។ សោ កាយស្ស ភេទា បរម្មរណា តាវតឹសានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ តត្រ ភិក្ខវេ សក្កោ ទេវានមិន្ទោ ទានមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ ករិត្វា សីលមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ ករិត្វា តាវតឹសេ ទេវេ ទសហិ ឋានេហិ អធិគណ្ហាតិ ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហិ ។

ម្នាលភិក្ខុទាំងឡាយ បណ្ដាទេវតាទាំងនោះ មហារាជទាំង ៤ អង្គ បានធ្វើទានមយបុញ្ញកិរិយាវត្ថុ ច្រើនក្រៃពេក ធ្វើសីលមយបុញ្ញកិរិយាវត្ថុ ច្រើនក្រៃពេក រមែងខ្ពង់ខ្ពស់កន្លងនូវពួកទេវតាចាតុម្មហារាជិកៈ ដោយស្ថាន ១០ យ៉ាងគឺ អាយុជាទិព្វ ១ ពណ៌ជាទិព្វ ១ សុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុច្រើនក្រៃលែង ធ្វើសីលមយបុញ្ញកិរិយាវត្ថុច្រើនក្រៃលែងប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកទេវតាតាវត្តិង្ស ។ ម្នាលភិក្ខុទាំងឡាយ បណ្ដាទេវតាទាំងនោះ សក្កទេវរាជជាធំជាងទេវតា បានធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក ធ្វើសីលមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក រមែងខ្ពង់ខ្ពស់កន្លងទេវតាជាន់តាវត្តិង្ស ដោយស្ថាន ១០ យ៉ាងគឺ អាយុជាទិព្វ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្វ ១ ។

១៧១

បណ្ណាសកេ ទានវគ្គោ

ឥធ បន ភិក្ខវេ ឯកច្ចស្ស ទានមយំ បុញ្ញកិរិយាវត្ថុ អធិមត្តំ កតំ ហោតិ សីលមយំ បុញ្ញកិរិយាវត្ថុ អធិមត្តំ កតំ ហោតិ ភាវនាមយំ បុញ្ញកិរិយាវត្ថុ នាភិសម្ភោតិ ។ សោ កាយស្ស ភេទា បរម្មរណា យាមានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ តត្រ ភិក្ខវេ សុយាមោ ទេវបុត្តោ ទានមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ ករិត្វា សីលមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ ករិត្វា យាមេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហាតិ ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស ទានមយំ បុញ្ញកិរិយាវត្ថុ អធិមត្តំ កតំ ហោតិ សីលមយំ បុញ្ញកិរិយាវត្ថុ អធិមត្តំ កតំ ហោតិ ភាវនាមយំ បុញ្ញកិរិយាវត្ថុ នាភិសម្ភោតិ ។ សោ កាយស្ស ភេទា បរម្មរណា តុសិតានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ តត្រ ភិក្ខវេ សន្តុសិតោ ទេវបុត្តោ ទានមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ ករិត្វា សីលមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ ករិត្វា តុសិតេ ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហាតិ

ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុច្រើនក្រៃលែង ធ្វើសីលមយបុញ្ញកិរិយាវត្ថុ ច្រើនក្រៃលែង ប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាជាន់យាមៈ ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទេវតាទាំងនោះ សុយាមទេវបុត្រ បានធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក បានធ្វើសីលមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក រមែងខ្ពង់ខ្ពស់កន្លងនូវពួកទេវតាជាន់យាមៈ ដោយស្ថាន ១០ យ៉ាងគឺ អាយុជាទិព្យ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្យ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុច្រើនក្រៃលែង ធ្វើសីលមយបុញ្ញកិរិយាវត្ថុច្រើនក្រៃលែង ប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតាជាន់តុសិត ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទេវតាទាំងនោះ សន្តុសិតទេវបុត្រ បានធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក បានធ្វើសីលមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក រមែងខ្ពង់ខ្ពស់កន្លងនូវពួកទេវតា ជាន់តុសិតដោយស្ថាន ១០ យ៉ាងគឺ

ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស ទានមយំ បុញ្ញកិរិយាវត្ថុ អតិរេកំ កតំ ហោតិ សីលមយំ បុញ្ញកិរិយាវត្ថុ អតិរេកំ កតំ ហោតិ ភាវនាមយំ បុញ្ញកិរិយាវត្ថុ នាភិសម្ភោតិ ។ សោ កាយស្ស ភេទា បរម្មរណា និម្មានរតីនំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ តត្រ ភិក្ខវេ សុនិម្មិតោ ទេវបុត្តោ ទានមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ ករិត្វា សីលមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ ករិត្វា និម្មានរតី ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហាតិ ទិព្វេន អាយុនា ។ បេ ។ ទិព្វេហិ ផោដ្ឋព្វេហិ ។ ឥធ បន ភិក្ខវេ ឯកច្ចស្ស ទានមយំ បុញ្ញកិរិយាវត្ថុ អធិមត្តំ កតំ ហោតិ សីលមយំ បុញ្ញកិរិយាវត្ថុ អធិមត្តំ កតំ ហោតិ ភាវនាមយំ បុញ្ញកិរិយាវត្ថុ នាភិសម្ភោតិ ។ សោ កាយស្ស ភេទា បរម្មរណា បរនិម្មិតវសវត្តីនំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។

អាយុជាទិព្វ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុច្រើនក្រៃលែង ធ្វើសីលមយបុញ្ញកិរិយាវត្ថុ ច្រើនក្រៃលែង ប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនសម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏រមែងទៅកើតជាមួយនឹងពួកទេវតា និម្មានរតី ។ ម្នាលភិក្ខុទាំងឡាយ បណ្តាទេវតាទាំងនោះ សុនិម្មិតទេវបុត្រ បានធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក បានធ្វើសីលមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃពេក រមែងខ្ពង់ខ្ពស់កន្លងពួកទេវតានិម្មានរតី ដោយស្ថាន ១០ យ៉ាងគឺ អាយុជាទិព្វ ១ ។ បេ ។ ផោដ្ឋព្វៈជាទិព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលខ្លះ ក្នុងលោកនេះ ធ្វើទានមយបុញ្ញកិរិយាវត្ថុដ៏ច្រើនក្រៃលែង ធ្វើសីលមយបុញ្ញកិរិយាវត្ថុ ដ៏ច្រើនក្រៃលែង ប៉ុន្តែភាវនាមយបុញ្ញកិរិយាវត្ថុ មិនទាន់សម្រេចនៅឡើយ ។ បុគ្គលនោះ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ ក៏រមែងទៅកើត ជាមួយនឹងពួកទេវតា បរនិម្មិតវសវត្តី ។

តត្រ ភិក្ខវេ បរនិម្មិតវសវត្តី ទេវបុត្តោ[១] ទានមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ ការិត្វា សីលមយំ បុញ្ញកិរិយាវត្ថុំ អតិរេកំ ការិត្វា បរនិម្មិតវសវត្តី ទេវេ ទសហិ ឋានេហិ អធិគ្គណ្ហាតិ ទិព្វេន អាយុនា ទិព្វេន វណ្ណេន ទិព្វេន សុខេន ទិព្វេន យសេន ទិព្វេន អាធិបតេយ្យេន ទិព្វេហិ រូបេហិ ទិព្វេហិ សទ្ទេហិ ទិព្វេហិ គន្ធេហិ ទិព្វេហិ រសេហិ ទិព្វេហិ ផោដ្ឋព្វេហិ ។ ឥមានិ ខោ ភិក្ខវេ តីណិ បុញ្ញកិរិយាវត្ថូនីតិ ។

[៣៧] អដ្ឋិមានិ ភិក្ខវេ សប្បុរិសទានានិ ។ កតមានិ អដ្ឋ ។ សុចឹ ទេតិ បណីតំ ទេតិ កាលេន ទេតិ កប្បិយំ ទេតិ វិចេយ្យ ទេតិ អភិណ្ហំ ទេតិ ទទំ ចិត្តំ បសាទេតិ ទត្វា អត្តមនោ ហោតិ ។ ឥមានិ ខោ ភិក្ខវេ អដ្ឋ សប្បុរិសទានានីតិ ។

សុចឹ បណីតំ កាលេន កប្បិយំ បានភោជនំ
អភិណ្ហំ ទទាតិ ទានានិ សុខេត្តេសុ[២] ព្រហ្មចារិសុ
នេវ វិប្បដិសារិយំ[៣] ចជិត្វា អាមិសំ ពហុំ
ឯវំ ទិន្នានិ ទានានិ វណ្ណយន្តិ វិបស្សិនោ

---

១ ឱ. វសវត្តិ ទេវបុត្តោ ។ ២ ឱ. សុខេត្តេ ។ ៣ ឱ. ន ច វិប្បដិសារិស្ស ។

ម្នាលភិក្ខុទាំងឡាយ បណ្ដាទេវតាទាំងនោះ បរនិម្មិតវសវត្តីទេវបុត្រ បានធ្វើទានមយបុញ្ញកិរិយាវត្ថុ ដ៏ច្រើនក្រៃពេក បានធ្វើសីលមយបុញ្ញកិរិយាវត្ថុ ដ៏ច្រើនក្រៃពេក រមែងខ្ពង់ខ្ពស់កន្លងនូវពួកទេវតាបរនិម្មិតវសវត្តី ដោយស្ថាន ១០ យ៉ាង គឺ អាយុជាទិព្វ ១ ពណ៌ជាទិព្វ ១ សុខជាទិព្វ ១ យសជាទិព្វ ១ អធិបតីជាទិព្វ ១ រូបជាទិព្វ ១ សំឡេងជាទិព្វ ១ ក្លិនជាទិព្វ ១ រសជាទិព្វ ១ ផោដ្ឋព្វៈជាទិព្វ ១ ។ ម្នាលភិក្ខុទាំងឡាយ បុញ្ញកិរិយាវត្ថុ មាន ៣ យ៉ាងនេះឯង ។

[៣៧] ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាននេះមាន ៨ យ៉ាង ។ សប្បុរិសទាន ៨ យ៉ាង តើដូចម្ដេចខ្លះ ។ គឺបុគ្គលឲ្យវត្ថុស្អាត ១ ឲ្យវត្ថុថ្លៃថ្លា ១ ឲ្យតាមកាល ១ ឲ្យវត្ថុគួរ ១ ជ្រើសរើសហើយទើបឲ្យ ១ ឲ្យទានរឿយៗ ១ កំពុងឲ្យញុំាងចិត្តឲ្យជ្រះថ្លា ១ លុះឲ្យផុតហើយ រមែងមានសេចក្ដីពេញចិត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ សប្បុរិសទាន ៨ យ៉ាងនេះឯង ។

បុគ្គល រមែងឲ្យនូវទានទាំងឡាយគឺ ទឹកនិងភោជន ដ៏ស្អាត
ថ្លៃថ្លា តាមកាល វត្ថុដ៏គួររឿយៗ ចំពោះព្រហ្មចារីបុគ្គល
ទាំងឡាយ ដូចជាស្រែដ៏ល្អ ពួកអ្នកប្រាជ្ញ រមែងសរសើរ
នូវទានទាំងឡាយ ដែលបុគ្គលលះបង់នូវអាមិសៈ ជាច្រើន
ដែលមិនគួរឲ្យកើតសេចក្ដីក្ដៅក្រហាយ ហើយឲ្យយ៉ាងនេះ

ឯវំ យជិត្វា មេធាវី សទ្ធោ មុត្តេន ចេតសា
អព្យាបជ្ឈំ សុខំ លោកំ បណ្ឌិតោ ឧបបជ្ជតីតិ ។

[៣៨] សប្បុរិសោ ភិក្ខវេ កុលេ ជាយមានោ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ហោតិ មាតាបិតូនំ អត្ថាយ ហិតាយ សុខាយ ហោតិ បុត្តទារស្ស អត្ថាយ ហិតាយ សុខាយ ហោតិ ទាសកម្មករបោរិសស្ស អត្ថាយ ហិតាយ សុខាយ ហោតិ មិត្តាមច្ចានំ អត្ថាយ ហិតាយ សុខាយ ហោតិ បុព្វបេតានំ អត្ថាយ ហិតាយ សុខាយ ហោតិ រញ្ញោ អត្ថាយ ហិតាយ សុខាយ ហោតិ ទេវតានំ អត្ថាយ ហិតាយ សុខាយ ហោតិ សមណព្រាហ្មណានំ អត្ថាយ ហិតាយ សុខាយ ហោតិ ។

អ្នកប្រាជ្ញមានបញ្ញា ជាអ្នកមានសទ្ធា បានបូជាយ៉ាងនេះ ហើយ មានចិត្តរួចស្រឡះ រមែងចូលទៅកាន់ទេវលោក ដែលមិនមានសេចក្តីទុក្ខ មានតែសេចក្តីសុខ ។

[៣៨] ម្នាលភិក្ខុទាំងឡាយ សប្បុរស កាលកើតក្នុងត្រកូល រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់មាតាបិតា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់បុត្តភរិយា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់បុរសជាទាសកម្មករ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់មិត្តនិងអាមាត្យទាំងឡាយ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ពួកញាតិ ដែលចែកឋានទៅកាន់បរលោក ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ព្រះរាជា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ពួកទេវតា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់សមណព្រាហ្មណ៍ទាំងឡាយ ។

១៧៤



សេយ្យថាបិ ភិក្ខវេ មហាមេឃោ សព្វសស្សានិ សម្បាទេន្តោ ពហុនោ ជនស្ស អត្ថាយ ហិតាយ ។ បេ ។ ហោតិ ឯវមេវ ខោ ភិក្ខវេ សប្បុរិសោ កុលេ ជាយមានោ ពហុនោ ជនស្ស អត្ថាយ ហិតាយ សុខាយ ហោតិ មាតាបិតូនំ អត្ថាយ ហិតាយ សុខាយ ហោតិ បុត្តទារស្ស អត្ថាយ ហិតាយ សុខាយ ហោតិ ទាសកម្មករបោរិសស្ស អត្ថាយ ហិតាយ សុខាយ ហោតិ មិត្តាមច្ចានំ អត្ថាយ ហិតាយ សុខាយ ហោតិ បុព្វបេតានំ អត្ថាយ ហិតាយ សុខាយ ហោតិ រញ្ញោ អត្ថាយ ហិតាយ សុខាយ ហោតិ ទេវតានំ អត្ថាយ ហិតាយ សុខាយ ហោតិ សមណ-ព្រាហ្មណានំ អត្ថាយ ហិតាយ សុខាយ ហោតីតិ ។

ម្នាលភិក្ខុទាំងឡាយ មហាមេឃ កាលញ៉ាំងសំទូងទាំងអស់ ឲ្យសម្រេច ព្រម រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើនដល់ជនច្រើន ។ បេ ។ មានឧបមាដូចម្តេចមិញ ម្នាលភិក្ខុទាំងឡាយ សប្បុរស កាលកើតក្នុងត្រកូល រមែងប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ជនច្រើន ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់មាតានិងបិតាទាំងឡាយ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់បុត្តភរិយា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ដល់បុរសជាទាសកម្មករ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់មិត្តនិងអាមាត្យទាំងឡាយ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ពួកញាតិ ដែលចែកឋានទៅកាន់បរលោក ប្រព្រឹត្តទៅដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ព្រះរាជា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់ពួកទេវតា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខដល់សមណព្រាហ្មណ៍ទាំងឡាយ ក៏មានឧបមេយ្យដូច្នោះដែរ ។

ពហូនំ វត អត្ថាយ សប្បញ្ញោ ឃរមាវសំ
មាតរំ បិតរំ បុព្វេ រត្តិន្ទិវមតន្ទិតោ
បូជេតិ សហធម្មេន បុព្វេ កតមនុស្សរំ
អនាគារេ បព្វជិតេ អបាយេ ព្រហ្មចារិនោ[(១)]
និវិដ្ឋសទ្ធោ បូជេតិ ញត្វា ធម្មេ ច បេសលោ
រញ្ញោ ហិតោ ទេវហិតោ ញាតីនំ សខិនំ ហិតោ
សព្វេសំ សហិតោ ហោតិ សទ្ធម្មេ សុបតិដ្ឋិតោ
វិនេយ្យ មច្ឆេរមលំ សលោកំ ភជតេ សិវន្តិ ។

[៣៩] អដ្ឋិមេ ភិក្ខវេ បុញ្ញាភិសន្ទា កុសលាភិសន្ទា សុខស្សាហារា សោវគ្គិកា សុខវិបាកា សគ្គសំវត្តនិកា ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តន្តិ ។ កតមេ អដ្ឋ ។

១ ឱ. អបចេ ព្រហ្មចារយោ ។

បុគ្គលប្រកបដោយបញ្ញា កាលនៅគ្រប់គ្រងផ្ទះ រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ពួកជនច្រើន ជាអ្នកមិនខ្ជិលច្រអូសក្នុងវេលាយប់និងថ្ងៃ កាលនឹករលឹកដល់បុព្វការគុណដែលមាតានិងបិតាធ្វើហើយ រមែងបូជាមាតាបិតាជាមុន ដោយហេតុប្រកបដោយធម៌ រមែងកោតក្រែងចំពោះបព្វជិតជាអនាគារិកបុគ្គល ជាព្រហ្មចារីបុគ្គលមានសទ្ធាតម្កល់មាំ មានសីលជាទីស្រឡាញ់ លុះដឹងច្បាស់នូវធម៌ទាំងឡាយហើយ រមែងបូជា បុគ្គលណាដែលមានប្រយោជន៍ដល់ព្រះរាជា មានប្រយោជន៍ដល់ទេវតា មានប្រយោជន៍ដល់ពួកញាតិ ដល់មិត្តសំឡាញ់ តម្កល់ស៊ប់ក្នុងព្រះសទ្ធម្ម បុគ្គលនោះឈ្មោះថាមានប្រយោជន៍ដល់បុគ្គលទាំងអស់ បុគ្គលណាកម្ចាត់បង់នូវមន្ទិលគឺសេចក្តីកំណាញ់ បុគ្គលនោះ រមែងជួបប្រទះនូវលោកក្សេមក្សាន្ត ។

[៣៩] ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅដើម្បីសួគ៌ ៨ យ៉ាងនេះ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។ អានិសង្សនៃបុណ្យ អានិសង្សនៃកុសល ៨ យ៉ាងដូចម្តេចខ្លះ ។

ឥធ ភិក្ខវេ អរិយសាវកោ ពុទ្ធំ សរណំ គតោ ហោតិ អយំ ភិក្ខវេ បឋមោ បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ អរិយសាវកោ ធម្មំ សរណំ គតោ ហោតិ អយំ ភិក្ខវេ ទុតិយោ បុញ្ញាភិសន្ទោ ។ បេ ។ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ អរិយសាវកោ សង្ឃំ សរណំ គតោ ហោតិ អយំ ភិក្ខវេ តតិយោ បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតិ ។ បញ្ចិមានិ ភិក្ខវេ ទានានិ មហាទានានិ អគ្គញ្ញានិ រត្តញ្ញានិ វំសញ្ញានិ

ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ក្នុងសាសនានេះ ជាអ្នកដល់នូវព្រះពុទ្ធជាទីពឹង ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីសួគ៌ទី ១ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវ័ក ជាអ្នកដល់នូវព្រះធម៌ជាទីពឹង ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សនៃបុណ្យទី ២ ។ បេ ។ រមែងប្រព្រឹត្តទៅ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវ័ក ជាអ្នកដល់នូវព្រះសង្ឃជាទីពឹង នេះជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីសួគ៌ទី ៣ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ ទានទាំង ៥ យ៉ាងនេះ ចាត់ជាមហាទាន ដែលអ្នកប្រាជ្ញដឹងថាជារបស់ប្រសើរ ដឹងថាជារបស់ប្រព្រឹត្តទៅអស់រាត្រីយូរ ដឹងថាជាវង្សនៃ (កល្យាណជន)

បោរាណានិ អសង្កិណ្ណានិ អសង្កិណ្ណបុព្វានិ ន សង្កិយន្តិ ន សង្កិយិស្សន្តិ អប្បដិកុដ្ឋានិ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ ។ កតមានិ បញ្ច ។ ឥធ ភិក្ខវេ អរិយសាវកោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ ហោតិ បាណាតិបាតា បដិវិរតោ ភិក្ខវេ អរិយសាវកោ អបរិមាណានំ សត្តានំ អភយំ ទេតិ អវេរំ ទេតិ អព្យាបជ្ឈំ ទេតិ អបរិមាណានំ សត្តានំ អភយំ ទត្វា អវេរំ ទត្វា អព្យាបជ្ឈំ ទត្វា អបរិមាណស្ស អភយស្ស អវេរស្ស អព្យាបជ្ឈស្ស ភាគី ហោតិ ។ ឥទំ ភិក្ខវេ បឋមំ ទានំ មហាទានំ អគ្គញ្ញំ រត្តញ្ញំ វំសញ្ញំ បោរាណំ អសង្កិណ្ណំ អសង្កិណ្ណបុព្វំ ន សង្កិយតិ ន សង្កិយិស្សតិ អប្បដិកុដ្ឋំ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ

ជារបស់មានមកក្នុងកាលមុន ជារបស់មិនពោយរាយ ជារបស់មិនធ្លាប់ពោយរាយហើយ រមែងមិនខ្ចាត់ខ្ចាយ (ក្នុងកាលឥឡូវនេះ) នឹងមិនខ្ចាត់ខ្ចាយ (ក្នុងអនាគត) ពួកសមណព្រាហ្មណ៍ ជាវិញ្ញូជន ក៏មិនដែលតិះដៀលឡើយ ។ ទាន ៥ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ លះបង់បាណាតិបាត វៀរចាកបាណាតិបាត ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ជាអ្នកវៀរចាកបាណាតិបាត ឈ្មោះថាឲ្យនូវអភ័យ ឲ្យនូវអំពើមិនមានពៀរ ឲ្យនូវអំពើមិនមានទុក្ខ ដល់សត្វទាំងឡាយមានប្រមាណមិនបាន លុះឲ្យនូវអភ័យ ឲ្យនូវអំពើមិនមានពៀរ ឲ្យនូវអំពើមិនមានទុក្ខ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ រមែងជាអ្នកមានចំណែក នៃសេចក្តីមិនមានភ័យ មិនមានពៀរ មិនមានទុក្ខ មានប្រមាណមិនបានវិញ ។ ម្នាលភិក្ខុទាំងឡាយ នេះជាទានទី ១ ចាត់ជាមហាទាន ដែលអ្នកប្រាជ្ញដឹងថាជារបស់ប្រសើរ ដឹងថាជារបស់ប្រព្រឹត្តទៅអស់រាត្រីយូរ ដឹងថាជាវង្សនៃ (កល្យាណជន) ជារបស់មានមកក្នុងកាលមុន ជារបស់មិនពោយរាយ មិនធ្លាប់ពោយរាយហើយ រមែងមិនខ្ចាត់ខ្ចាយ នឹងមិនខ្ចាត់ខ្ចាយ ពួកសមណព្រាហ្មណ៍ ជាវិញ្ញូជន ក៏មិនដែលតិះដៀលឡើយ

១៧៩



អយំ ភិក្ខវេ ចតុត្ថោ បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្ត-និកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតិ ។ បុន ចបរំ ភិក្ខវេ អរិយស្សាវកោ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ហោតិ ។ បេ ។ កាមេសុ មិច្ឆាចារំ បហាយ កាមេសុ មិច្ឆាចារា បដិវិរតោ ហោតិ ។ បេ ។ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ ហោតិ ។ បេ ។ សុរាមេរយ-មជ្ជប្បមាទដ្ឋានំ បហាយ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ភិក្ខវេ អរិយស្សាវកោ អបរិមាណានំ សត្តានំ អភយំ ទេតិ អវេរំ ទេតិ អព្យាបជ្ឈំ ទេតិ អបរិមាណានំ សត្តានំ អភយំ ទត្វា អវេរំ ទត្វា អព្យាបជ្ឈំ ទត្វា អបរិមាណស្ស អភយស្ស អវេរស្ស អព្យាបជ្ឈស្ស ភាគី ហោតិ ឥទំ ភិក្ខវេ បញ្ចមំ ទានំ មហាទានំ អគ្គញ្ញំ រត្តញ្ញំ វំសញ្ញំ

ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីសួគ៌ទី ៤ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត អរិយសាវ័ក លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន ។ បេ ។ លះបង់កាមេសុមិច្ឆាចារ វៀរចាកកាមេសុមិច្ឆាចារ ។ បេ ។ លះបង់មុសាវាទ វៀរចាកមុសាវាទ ។ បេ ។ លះបង់សុរាមេរយមជ្ជប្បមាទដ្ឋាន វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ឈ្មោះថា ឲ្យនូវអភ័យ ឲ្យនូវអំពើមិនមានពៀរ ឲ្យនូវអំពើមិនមានទុក្ខ ដល់សត្វទាំងឡាយ មានប្រមាណមិនបាន លុះឲ្យនូវអភ័យ ឲ្យនូវអំពើមិនមានពៀរ ឲ្យនូវអំពើមិនមានទុក្ខ ដល់សត្វទាំងឡាយ មានប្រមាណមិនបានហើយ រមែងជាអ្នក មានចំណែក នៃសេចក្តីមិនមានភ័យ មិនមានពៀរ មិនមានទុក្ខ មានប្រមាណមិនបានវិញ ម្នាលភិក្ខុទាំងឡាយ នេះជាទានទី ៥ ចាត់ជាមហាទាន ដែលអ្នកប្រាជ្ញដឹងថាជារបស់ប្រសើរ ដឹងថាជារបស់ប្រព្រឹត្តទៅអស់រាត្រីយូរ ដឹងថាជាវង្សនៃ (កល្យាណជន)

ចោរាណំ អសង្កិយំ្ហ អសង្កិយ្ហាបុព្វំ ន សង្កិយតិ ន សង្កិយិស្សតិ អប្បដិកុដ្ឋំ សមណេហិ ព្រាហ្មណេហិ វិញ្ញូហិ អយំ ភិក្ខវេ អដ្ឋមោ បុញ្ញាភិសន្ទោ កុសលាភិសន្ទោ សុខស្សាហារោ សោវគ្គិកោ សុខវិបាកោ សគ្គសំវត្តនិកោ ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តតិ ។ ឥមេ ខោ ភិក្ខវេ អដ្ឋ បុញ្ញាភិសន្ទា កុសលាភិសន្ទា សុខស្សាហារា សោវគ្គិកា សុខវិបាកា សគ្គសំវត្តនិកា ឥដ្ឋាយ កន្តាយ មនាបាយ ហិតាយ សុខាយ សំវត្តន្តីតិ ។

[៤០] បាណាតិបាតោ ភិក្ខវេ អាសេវិតោ ភាវិតោ ពហុលីកតោ និរយសំវត្តនិកោ តិរច្ឆានយោនិសំវត្តនិកោ បិត្តិវិសយសំវត្តនិកោ ។ យោ សព្វលហុសោ បាណាតិបាតស្ស វិបាកោ មនុស្សភូតស្ស អប្បាយុកសំវត្តនិកោ ហោតិ ។ អទិន្នាទានំ ភិក្ខវេ

ជារបស់មានមកក្នុងកាលមុន មិនរោយរាយ មិនធ្លាប់រោយរាយហើយ រមែងមិនខ្វាត់ខ្វាយ នឹងមិនខ្វាត់ខ្វាយ ពួកសមណព្រាហ្មណ៍ ជាវិញ្ញូជន ក៏មិនដែលតិះដៀលឡើយ ម្នាលភិក្ខុទាំងឡាយ នេះជាអានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីសួគ៌ទី ៨ រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីករាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។ ម្នាលភិក្ខុទាំងឡាយ អានិសង្សនៃបុណ្យ អានិសង្សនៃកុសល ជាអាហារនៃសេចក្តីសុខ ជាធម៌ឲ្យនូវអារម្មណ៍ដ៏ល្អលើស ជាផលនៃសេចក្តីសុខ ប្រព្រឹត្តទៅ ដើម្បីសួគ៌ ៨ ប្រការនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីសេចក្តីត្រេកអរ ដើម្បីសេចក្តីរីក-រាយ ដើម្បីសេចក្តីពេញចិត្ត ដើម្បីសេចក្តីចម្រើន ដើម្បីសេចក្តីសុខ ។

[៤០] ម្នាលភិក្ខុទាំងឡាយ បាណាតិបាត ដែលបុគ្គលសេពផ្ចឹកហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃបាណាតិបាត ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីមានអាយុខ្លី ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ អទិន្នាទាន

១៨១



អាសេវិតំ ភាវិតំ ពហុលីកតំ និរយសំវត្តនិកំ តិរច្ឆានយោនិសំវត្តនិកំ បិត្តិវិសយសំវត្តនិកំ ។ យោ សព្វលហុសោ អទិន្នាទានស្ស វិបាកោ មនុស្សភូតស្ស ភោគព្យសនសំវត្តនិកោ ហោតិ ។ កាមេសុ មិច្ឆាចារោ ភិក្ខវេ អាសេវិតោ ភាវិតោ ពហុលីកតោ និរយសំវត្តនិកោ តិរច្ឆានយោនិសំវត្តនិកោ បិត្តិវិសយសំវត្តនិកោ ។ យោ សព្វលហុសោ កាមេសុ មិច្ឆាចារស្ស វិបាកោ មនុស្សភូតស្ស សបត្តវេរសំវត្តនិកោ ហោតិ ។ មុសាវាទោ ភិក្ខវេ អាសេវិតោ ភាវិតោ ពហុលីកតោ និរយសំវត្តនិកោ តិរច្ឆានយោនិសំវត្តនិកោ បិត្តិវិសយសំវត្តនិកោ ។ យោ សព្វលហុសោ មុសាវាទស្ស វិបាកោ មនុស្សភូតស្ស អភូតព្ភក្ខានសំវត្តនិកោ ហោតិ ។ បិសុណា ភិក្ខវេ វាចា អាសេវិតា ភាវិតា ពហុលីកតា និរយសំវត្តនិកា តិរច្ឆានយោនិសំវត្តនិកា បិត្តិវិសយសំវត្តនិកា ។ យោ សព្វលហុសោ បិសុណាយ វាចាយ វិបាកោ មនុស្សភូតស្ស មិត្តេហិ ភេទនសំវត្តនិកោ ហោតិ ។ ផរុសា ភិក្ខវេ វាចា អាសេវិតា ភាវិតា

ដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បី នរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃអទិន្នាទានដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បី វិនាសនៃភោគៈ ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ កាមេសុមិច្ឆា-ចារ ដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិ-វិស័យ ។ ផលនៃកាមេសុមិច្ឆាចារ ដែលស្រាលជាងផលទាំងអស់ រមែង ប្រព្រឹត្តទៅ ដើម្បីសត្រូវនិងពៀរ ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំង-ឡាយ មុសាវាទ ដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រ-ព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បី បិត្តិវិស័យ ។ ផលនៃមុសាវាទ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្ត ទៅ ដើម្បីគេពោលបង្កាច់ ដោយពាក្យមិនពិត ដល់កើតជាមនុស្ស ។ ម្នាល ភិក្ខុទាំងឡាយ បិសុណាវាចា ដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើ ឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃបិសុណាវាចា ដែលស្រាលជាងផល ទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីបែកបាក់ចាកមិត្រ ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ ផរុសវាចា ដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ

ពហុលីកតា និរយសំវត្តនិកា តិរច្ឆានយោនិសំវត្តនិកា បិត្តិវិសយសំវត្តនិកា ។ យោ សព្វលហុសោ ផរុសាយ វាចាយ វិបាកោ មនុស្សភូតស្ស អមនាបសទ្ទសំវត្តនិកោ ហោតិ ។ សម្ផប្បលាបោ ភិក្ខវេ អាសេវិតោ ភាវិតោ ពហុលីកតោ និរយសំវត្តនិកោ តិរច្ឆានយោនិសំវត្តនិកោ បិត្តិវិសយសំវត្តនិកោ ។ យោ សព្វលហុសោ សម្ផប្បលាបស្ស វិបាកោ មនុស្សភូតស្ស អនាទេយ្យវាចាសំវត្តនិកោ ហោតិ ។ សុរាមេរយបានំ ភិក្ខវេ អាសេវិតំ ភាវិតំ ពហុលីកតំ និរយសំវត្តនិកំ តិរច្ឆានយោនិសំវត្តនិកំ បិត្តិវិសយសំវត្តនិកំ ។ យោ សព្វលហុសោ សុរាមេរយបានស្ស វិបាកោ មនុស្សភូតស្ស ឧម្មត្តកសំវត្តនិកោ ហោតីតិ ។

ទានវគ្គោ ចតុត្ថោ ។

## តត្រុទ្ទានំ

ទ្វេ ទានានិ វត្ថុញ្ច ខេត្តំ ទានូបបត្តិ កិរិយំ
ទ្វេ សប្បុរិសា សព្វលហុសោ អភិសន្ទោ ច វុត្តីតិ ។

ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃផរុសវាចា ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីសំឡេងមិនជាទីគាប់ចិត្ត ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ សម្ផប្បលាបៈដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិវិស័យ ។ ផលនៃសម្ផប្បលាបៈដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីពាក្យដែលមិនគួរកាន់យក ដល់កើតជាមនុស្ស ។ ម្នាលភិក្ខុទាំងឡាយ ការផឹកនូវសុរានិងមេរ័យដែលបុគ្គលថ្នឹកហើយ ចម្រើនហើយ ធ្វើឲ្យច្រើនហើយ ប្រព្រឹត្តទៅ ដើម្បីនរក ប្រព្រឹត្តទៅ ដើម្បីកំណើតតិរច្ឆាន ប្រព្រឹត្តទៅ ដើម្បីបិត្តិ-វិស័យ ។ ផលនៃការផឹកនូវសុរាមេរ័យ ដែលស្រាលជាងផលទាំងអស់ រមែងប្រព្រឹត្តទៅ ដើម្បីភាពជាឆ្កួត ដល់កើតជាមនុស្ស ។

ចប់ ទានវគ្គ ទី ៤ ។

# ឧទ្ទានក្នុងវគ្គនោះគឺ

និយាយអំពីទានពីរលើក អំពីទានវត្ថុ ១ អំពីបុញ្ញក្ខេត្ត ១ អំពីការកើតឡើងនៃទាន ១ អំពីបុញ្ញកិរិយាវត្ថុ ១ អំពីសប្បុរសពីរលើក អំពីផលដ៏ស្រាលជាងផលទាំងអស់ ១ អំពីអានិសង្ស ១ ។

# ឧបោសថវគ្គោ

[៤១] ឯវម្មេ សុតំ ។ ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច អដ្ឋង្គ-សមន្នាគតោ ភិក្ខវេ ឧចោសថោ ឧបវុត្ថោ មហប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោ ។ កថំ ឧបវុត្ថោ ច ភិក្ខវេ អដ្ឋង្គសមន្នាគតោ ឧចោសថោ មហប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោ ។ ឥធ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យាវជីវំ អរហន្តោ ចាណាតិចាតំ បហាយ ចាណាតិចាតា បដិវិរតា និហិតទណ្ឌា និហិតសត្ថា លជ្ជី ទយាបន្នា សព្វប្បាណភូតហិតានុកម្បិនោ វិហរន្តិ

# ឧបោសថវគ្គ

[៤១] ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុងសាវត្ថី ។ ក្នុងទីនោះឯង ព្រះមានព្រះភាគ ទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលស្តាប់ព្រះពុទ្ធដីកាព្រះមានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះមានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលភិក្ខុទាំងឡាយ ឧបោសថ ប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ។ ម្នាលភិក្ខុទាំងឡាយ ចុះឧបោសថ ប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គល ចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័ក ក្នុងសាសនានេះ ពិចារណាថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ ជាអ្នកមានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដល់សព្វសត្វ ដរាបអស់ជីវិត

អហំបជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វប្បាណភូតហិតានុកម្បី វិហរាមិ ឥមិនាបង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា បឋមេន អង្គេន សមន្នាគតោ ហោតិ ។ បេ ។ យាវជីវំ អរហន្តោ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតា ទិន្នាទាយី ទិន្នប្បាដិកង្ខី អត្ថេនេន សុចិភូតេន អត្តនា វិហរន្តិ អហំបជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ អទិន្នាទានំ បហាយ អទិន្នាទានា បដិវិរតោ ទិន្នាទាយី ទិន្នប្បាដិកង្ខី អត្ថេនេន សុចិភូតេន អត្តនា វិហរាមិ ឥមិនាបង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា ទុតិយេន អង្គេន សមន្នាគតោ ហោតិ ។ បេ ។ យាវជីវំ អរហន្តោ អព្រហ្មចរិយំ បហាយ ព្រហ្មចារិនោ អារាចារិនោ វិរតា មេថុនា គាមធម្មា

ក្នុងថ្ងៃនេះ ចំណែកខ្ញុំនអញ លះបង់នូវបាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដល់សព្វសត្វ អស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថ ប្រកបដោយអង្គទី ១ នេះឯង ។ បេ ។ ព្រះអរហន្តទាំងឡាយ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែវត្ថុដែលគេឲ្យ ប្រាថ្នាចំពោះវត្ថុដែលគេឲ្យ មានខ្លួនដ៏ស្អាត មិនមែនជាអ្នកលួច ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្ញុំនអញ លះបង់អទិន្នាទាន វៀរចាកអទិន្នាទាន កាន់យកតែវត្ថុដែលគេឲ្យ ប្រាថ្នាចំពោះតែវត្ថុដែលគេឲ្យ មានខ្លួនដ៏ស្អាត មិនមែនជាអ្នកលួច អស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំនអញចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថ ប្រកបដោយអង្គទី ២ នេះឯង ។ បេ ។ ព្រះអរហន្តទាំងឡាយ លះបង់អព្រហ្មចរិយៈ ជាអ្នកមានព្រហ្មចារ្យ ប្រព្រឹត្តឆ្ងាយ វៀរចាកមេថុន ដែលជាធម៌របស់អ្នកស្រុក ដរាបអស់ជីវិត

អហំបជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ អព្រហ្មចរិយំ បហាយ ព្រហ្មចារី អារាចារី វិរតោ មេថុនា គាមធម្មា ឥមិនាបង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា តតិយេន អង្គេន សមន្នាគតោ ហោតិ ។ បេ ។ យាវជីវំ អរហន្តោ មុសាវាទំ បហាយ មុសាវាទា បដិវិរតា សច្ចវាទិនោ សច្ចសន្ធា ថេតា បច្ចយិកា អវិសំវាទកា លោកស្ស អហំបជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ មុសាវាទំ បហាយ មុសាវាទា បដិវិរតោ សច្ចវាទី សច្ចសន្ធោ ថេតោ បច្ចយិកោ អវិសំវាទកោ លោកស្ស ឥមិនាបង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា ចតុត្ថេន អង្គេន សមន្នាគតោ ហោតិ ។ បេ ។ យាវជីវំ អរហន្តោ សុរាមេរយមជ្ជប្បមាទដ្ឋានំ បហាយ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតា

ក្នុងថ្ងៃនេះ ចំណែកខ្ញុំនអញលះបង់អព្រហ្មចរិយៈ ជាអ្នកមានព្រហ្មចារ្យ ប្រព្រឹត្តឆ្ងាយ វៀរចាកមេថុន ដែលជាធម៌របស់អ្នកស្រុក អស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំនអញនឹងចាំរក្សា ឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ៣ នេះឯង ។ បេ ។ ព្រះអរហន្តទាំងឡាយ លះបង់មុសាវាទ វៀរចាកមុសាវាទ អ្នកពោលពាក្យពិត ទ្រទ្រង់ពាក្យពិត ពោលពាក្យខ្ជាប់ខ្ជួន គួរឲ្យគេជឿបាន មិនបានពោលពាក្យបង្កាច់លោក ក្នុងថ្ងៃនេះ ចំណែកខ្ញុំនអញលះបង់មុសាវាទ វៀរចាកមុសាវាទ ជាអ្នកពោលពាក្យពិត ទ្រទ្រង់ពាក្យពិត ពោលពាក្យខ្ជាប់ខ្ជួន គួរឲ្យគេជឿបាន មិនបានពោលពាក្យបង្កាច់លោក អស់យប់នេះ និងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ៤ នេះឯង ។ បេ ។ ព្រះអរហន្តទាំងឡាយ លះបង់ហេតុជាទីតាំងនៃសេចក្តីប្រមាទគឺផឹកគ្រឿងស្រវឹងគឺសុរានិងមេរ័យ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកគ្រឿងស្រវឹងគឺសុរានិងមេរ័យ ដរាបអស់ជីវិត

អហំបជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ សុរាមេរយមជ្ជប្ប-មាទដ្ឋានំ បហាយ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ឥមិនាបង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា បញ្ចមេន អង្គេន សមន្នា-គតោ ហោតិ ។ បេ ។ យាវជីវំ អរហន្តោ ឯកភត្តិកា រត្តូបរតា វិរតា វិកាលភោជនា អហំបជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឯកភត្តិកោ រត្តូបរតោ វិរតោ វិកាល-ភោជនា ឥមិនាបង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា ឆដ្ឋេន អង្គេន សមន្នាគតោ ហោតិ ។ បេ ។ យាវជីវំ អរហន្តោ នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌន-វិភូសនដ្ឋានំ បហាយ នច្ចគីតវាទិតវិសូកទស្សន-មាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតា

ក្នុងថ្ងៃនេះ ចំណែកខ្ញុំនអញ លះបង់ហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកគ្រឿងស្រវឹង គឺសុរានិងមេរ័យ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទគឺផឹកគ្រឿងស្រវឹង គឺសុរានិងមេរ័យ អស់យប់នេះនិងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថ ប្រកបដោយអង្គទី ៥ នេះឯង ។ បេ ។ ព្រះអរហន្តទាំងឡាយ បរិភោគបាយតែម្តង វៀរបរិភោគ ក្នុងវេលាយប់ វៀរចាកភោជន ក្នុងវេលាវិកាល ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្ញុំនអញ បរិភោគបាយតែម្តង វៀរបរិភោគ ក្នុងវេលាយប់ វៀរចាកភោជន ក្នុងវេលាវិកាល អស់យប់នេះនិងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថ ប្រកបដោយអង្គទី ៦ នេះឯង ។ បេ ។ ព្រះអរហន្តទាំងឡាយ លះបង់ការរាំ ច្រៀង ប្រគំ មើលល្បែង ដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ ប្រដាប់តាក់តែង ស្អិតស្អាងរាងកាយ ដោយផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ វៀរចាកការរាំ ច្រៀង ប្រគំ មើលល្បែងដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ប្រដាប់តាក់តែង ស្អិតស្អាង រាងកាយ ដោយផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ ដរាបអស់ជីវិត

បណ្ណាសកេ ឧបោសថវគ្គោ

អហំបជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានំ បហាយ នច្ចគីតវាទិតវិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូសនដ្ឋានា បដិវិរតោ ឥមិនាបង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា សត្តមេន អង្គេន សមន្នាគតោ ហោតិ ។ បេ ។ យាវជីវំ អរហន្តោ ឧច្ចាសយនមហាសយនំ បហាយ ឧច្ចាសយនមហាសយនា បដិវិរតា នីចសេយ្យំ កប្បេន្តិ មញ្ចកេ វា តិណសន្ថរកេ វា អហំបជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឧច្ចាសយនមហាសយនំ បហាយ ឧច្ចាសយនមហាសយនា បដិវិរតោ នីចសេយ្យំ កប្បេមិ មញ្ចកេ វា តិណសន្ថរកេ វា ឥមិនាបង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។

ក្នុងថ្ងៃនេះ ចំណែកខ្លួនអញ លះបង់ការរាំ ច្រៀង ប្រគំ មើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ និងការទ្រទ្រង់ប្រដាប់តាក់តែង ស្អិតស្អាង រាងកាយ ដោយផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាបផ្សេងៗ វៀរចាក ការរាំ ច្រៀង ប្រគំ មើលនូវល្បែង ដែលជាសត្រូវដល់កុសលធម៌ និងការ ទ្រទ្រង់ប្រដាប់តាក់តែង ស្អិតស្អាង រាងកាយដោយផ្កាកម្រងគ្រឿងក្រអូប គ្រឿងលាបផ្សេងៗ អស់យប់នេះនិងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្ត ទាំងឡាយផង ខ្លួនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោ-សថប្រកបដោយអង្គទី ៧ នេះឯង ។ បេ ។ ព្រះអរហន្តទាំងឡាយ លះ បង់សេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងសេនាសនៈដ៏ប្រសើរ វៀរចាក សេនាសនៈដ៏ខ្ពស់ហួសប្រមាណនិងសេនាសនៈដ៏ប្រសើរ សម្រេចនូវ ទីដេកដ៏ទាប លើគ្រែតូច លើកម្រាល ដែលគេធ្វើដោយស្មៅក្តី ដរាបអស់ ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្លួនអញ លះបង់សេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងសេនាសនៈដ៏ប្រសើរ វៀរចាកសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និង សេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើគ្រែតូច លើកម្រាលដែល គេធ្វើដោយស្មៅក្តី អស់យប់នេះនិងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្ត ទាំងឡាយផង ខ្លួនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។

ឥមិនា អដ្ឋមេន អង្គេន សមន្នាគតោ ហោតិ ។ ឯវំ ឧបវុត្ថោ ខោ ភិក្ខវេ អដ្ឋង្គសមន្នាគតោ ឧបោសថោ មហប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោតិ ។

[៤២] អដ្ឋង្គសមន្នាគតោ ភិក្ខវេ ឧបោសថោ ឧបវុត្ថោ មហប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោ ។ កថំ ឧបវុត្ថោ ច ភិក្ខវេ អដ្ឋង្គសមន្នាគតោ ឧបោសថោ មហប្ផលោ ហោតិ មហានិសំសោ មហា-ជុតិកោ មហាវិប្ផារោ ។ ឥធ ភិក្ខវេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យាវជីវំ អរហន្តោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតា និហិតទណ្ឌា និហិតសត្ថា លជ្ជី ទយាបន្នា សព្វបាណភូតហិតានុកម្បិនោ វិហរន្តិ អហំ-បជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតោ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរាមិ

ឧបោសថប្រកបដោយអង្គទី ៨ នេះឯង ។ ម្នាលភិក្ខុទាំងឡាយឧបោសថ ប្រកបដោយអង្គ ៨ ដែលបុគ្គលចាំរក្សាយ៉ាងនេះឯង រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយច្រើន ។

[៤២] ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ។ ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន តើដោយប្រការដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ អរិយសាវ័កក្នុងសាសនានេះ ពិចារណាថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដល់សព្វសត្វ ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្លួនអញលះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ដល់សព្វសត្វ អស់យប់នេះនិងថ្ងៃនេះ

ឥមិនាបង្គេន អរហតំ អនុករោមិ ឧចោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា បឋមេន អង្គេន សមន្នាគតោ ហោតិ ។ (បឋមេន យថា វិត្ថារោ) យាវជីវំ អរហន្តោ ឧច្ចាសយនមហាសយនំ បហាយ ឧច្ចាសយនមហាសយនា បដិវិរតា នីចសេយ្យំ កប្បេន្តិ មញ្ចកេ វា តិណសន្ថរកេ វា អហំបជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឧច្ចាសយនមហាសយនំ បហាយ ឧច្ចាសយនមហាសយនា បដិវិរតោ នីចសេយ្យំ កប្បេមិ មញ្ចកេ វា តិណសន្ថរកេ វា ឥមិនាបង្គេន អរហតំ អនុករោមិ ឧចោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា អដ្ឋមេន អង្គេន សមន្នាគតោ ហោតិ ។ ឯវំ ឧបវុត្ថោ ខោ ភិក្ខវេ អដ្ឋង្គសមន្នាគតោ ឧចោសថោ មហប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោ ។

កីវមហប្ផលោ ហោតិ កីវមហានិសំសោ កីវមហាជុតិកោ កីវមហាវិប្ផារោ ។ សេយ្យថាបិ ភិក្ខវេ យោ

យកតម្រាប់ព្រះអរហន្តទាំងឡាយ ខ្ញុំនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ១ នេះឯង ។ (សេចក្ដីពិស្ដារដូចអង្គទី ១) ព្រះអរហន្តទាំងឡាយ លះបង់សេនាសនៈដ៏ខ្ពស់ហួសប្រមាណនិងសេនាសនៈដ៏ប្រសើរ វៀរចាកសេនាសនៈដ៏ខ្ពស់ហួសប្រមាណនិងសេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើគ្រែក្ដី លើកម្រាល ដែលគេធ្វើដោយស្មៅក្ដី ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្ញុំនអញ លះបង់សេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងសេនាសនៈដ៏ប្រសើរ វៀរចាកសេនាសនៈដ៏ខ្ពស់ហួសប្រមាណ និងសេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើគ្រែក្ដី លើកម្រាល ដែលធ្វើដោយស្មៅក្ដី អស់យប់នេះនិងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង អញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ៨ នេះឯង ។ ម្នាលភិក្ខុទាំងឡាយ ឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាយ៉ាងនេះឯង រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្ដីរុងរឿងច្រើន មានសេចក្ដីផ្សាយទៅច្រើន ។

ឧបោសថ មានផលច្រើន ដូចម្ដេច មានអានិសង្សច្រើន ដូចម្ដេច មានសេចក្ដីរុងរឿងច្រើន ដូចម្ដេច មានសេចក្ដីផ្សាយទៅច្រើន ដូចម្ដេច ។ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចបុគ្គល

ឥមេសំ សោឡសន្នំ មហាជនបទានំ បហូតសត្ត-
រតនានំ ឥស្សរាធិបច្ចំ រជ្ជំ ការេយ្យ សេយ្យថីទំ អង្គានំ
មគធានំ កាសីនំ កោសលានំ វជ្ជីនំ មល្លានំ ចេតីនំ
វំសានំ កុរូនំ បញ្ចាលានំ មច្ឆានំ សូរសេនានំ អស្ស-
កានំ អវន្តីនំ គន្ធារានំ កម្ពោជានំ អដ្ឋង្គសមន្នាគតស្ស
ឧបោសថស្ស ឯតំ កលំ នាគ្ឃតិ សោឡសឹ ។ តំ
កិស្ស ហេតុ ។ កបណំ ភិក្ខវេ មានុសកំ រជ្ជំ
ទិព្វំ សុខំ ឧបនិធាយ ។ យានិ ភិក្ខវេ មានុសកានិ
បញ្ញាសំ វស្សានិ ចាតុម្មហារាជិកានំ ទេវានំ ឯសោ
ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹសរត្តិយោ មាសោ តេន
មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន
ទិព្វានិ បញ្ច វស្សសតានិ ចាតុម្មហារាជិកានំ ទេវានំ
អាយុប្បមាណំ ។ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ
យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ
ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា
ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។

សោយរាជ្យ ជាឥស្សរាធិបតីនៃមហាជនបទទាំង ១៦ នេះ ដែលជាជនបទ សម្បូរដោយកែវ ៧ ប្រការ គឺមហាជនបទ ឈ្មោះ អង្គៈ ១ មគធៈ ១ កាសី ១ កោសលៈ ១ វជ្ជី ១ មល្លៈ ១ ចេតី ១ វំស្សៈ ១ កុរុ ១ បញ្ចាលៈ ១ មច្ឆៈ ១ សូរសេនៈ ១ អស្សកៈ ១ អវន្តី ១ គន្ធារៈ ១ កម្ពោជៈ ១ រាជសម្បត្តិនៃមហាជនបទទាំងនុ៎ះ មិនដល់នូវចំណិត ១ ក្នុងចំណិតទី ១៦ៗ លើកនៃឧបោសថប្រកបដោយអង្គ ៨ ប្រការឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលភិក្ខុទាំងឡាយ រាជ-សម្បត្តិរបស់មនុស្ស ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខជារបស់ទិព្យ ។ ម្នាលភិក្ខុទាំងឡាយ ៥០ ឆ្នាំរបស់មនុស្សត្រូវជា ១ យប់ ១ ថ្ងៃ របស់ចាតុម្មហារាជិកទេវតា រាប់រាត្រីនោះបាន ៣០ រាត្រីត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ៥០០ ឆ្នាំទិព្យ ត្រូវជាប្រមាណនៃអាយុរបស់ចាតុម្មហារាជិកទេវតា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថដែលប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកចាតុម្មហារាជិកទេវតា ។

ឥទំ ខោ បន មេតំ ភិក្ខវេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។ យំ ភិក្ខវេ មានុសកំ វស្សសតំ តាវត្តឹសានំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន ទិព្វំ វស្ស-សហស្សំ តាវត្តឹសានំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា តាវត្តឹសានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥទំ ខោ បន មេតំ ភិក្ខវេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។ យានិ ភិក្ខវេ មានុសកានិ ទ្វេ វស្សសតានិ យាមានំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ

ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្ស ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្យ ដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ១០០ ឆ្នាំរបស់មនុស្សត្រូវជា ១ យប់ ១ ថ្ងៃ របស់តាវត្តិង្សទេវតា រាប់រាត្រីនោះបាន ៣០ ត្រូវជា ១ ខែ រាប់ខែនោះ បាន ១២ ខែត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ១០០០ ឆ្នាំទិព្យ ត្រូវជាប្រមាណនៃអាយុរបស់តាវត្តិង្សទេវតា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថ ប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកតាវត្តិង្សទេវតា ។ ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្យ ដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ២០០ ឆ្នាំរបស់មនុស្សត្រូវជា ១ យប់ ១ ថ្ងៃ របស់ពួកយាមទេវតា រាប់រាត្រីនោះបាន ៣០ រាត្រីត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែត្រូវជា ១ ឆ្នាំ

តេន សំវច្ឆរេន ទិព្វានិ ទ្វេ វស្សសហស្សានិ យាមានំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា យាមានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥទំ ខោ បន មេតំ ភិក្ខវេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។ យានិ ភិក្ខវេ មានុសកានិ ចត្តារិ វស្សសតានិ តុសិតានំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន ទិព្វានិ ចត្តារិ វស្សសហស្សានិ តុសិតានំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា តុសិតានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។

រាប់ឆ្នាំនោះបាន ២០០០ ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុរបស់យាមទេ-វតា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកយាមទេវតា ។ ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្វ ដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ៤០០ ឆ្នាំរបស់មនុស្ស ត្រូវជា ១ យប់ ១ ថ្ងៃ របស់ពួកតុសិតទេវតា រាប់រាត្រីនោះបាន ៣០ រាត្រីត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ៤០០០ ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុរបស់ពួកតុសិត-ទេវតា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមានត្រង់ដែលស្ត្រី ឬ បុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សាឧបោសថ ប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកតុសិតទេវតា ។

ឥទំ ខោ បន មេតំ ភិក្ខវេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។ យានិ ភិក្ខវេ មានុសកានិ អដ្ឋ វស្សសតានិ និម្មានរតីនំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន ទិព្វានិ អដ្ឋ វស្សសហស្សានិ និម្មានរតីនំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា និម្មានរតីនំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥទំ ខោ បន មេតំ ភិក្ខវេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។ យានិ ភិក្ខវេ មានុសកានិ សោឡស វស្សសតានិ បរនិម្មិតវសវត្តីនំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ

ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្វ ដែលតថាគត សម្តែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ៨០០ ឆ្នាំរបស់មនុស្ស ត្រូវជា ១ យប់ ១ ថ្ងៃ របស់ពួកនិម្មានរតីទេវតា រាប់រាត្រីនោះបាន ៣០ ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ៨០០០ ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុរបស់ពួកនិម្មានរតីទេវតា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមានត្រង់ដែលស្ត្រី ឬ បុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកនិម្មានរតីទេវតា ។ ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្វ ដែលតថាគត សម្តែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ១៦០០ ឆ្នាំរបស់មនុស្ស ត្រូវជា ១ យប់ ១ ថ្ងៃ របស់ពួកបរនិម្មិតវសវត្តីទេវតា រាប់រាត្រីនោះបាន ៣០ ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ ឆ្នាំ

តេន សំវច្ឆរេន និដ្ឋានិ សោឡស វស្សសហស្សានិ បរនិម្មិតវសវត្តីនំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា បរនិម្មិតវសវត្តីនំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥទំ ខោ បន មេតំ ភិក្ខវេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយាតិ ។

បាណំ ន ហញ្ញេ ន ចាទិន្នមាទិយេ
មុសា ន ភាសេ ន ច មជ្ជបោ សិយា
អព្រហ្មចរិយា វិរមេយ្យ មេថុនា
រត្តឹ ន ភុញ្ជេយ្យ វិកាលភោជនំ
មាលំ ន ធារយេ ន ច គន្ធមាចរេ
មញ្ចេ ឆមាយំវ សយេថ សន្ថតេ
ឯតញ្ហិ អដ្ឋង្គិកមាហុបោសថំ
ពុទ្ធេន ទុក្ខន្តគុនា បកាសិតំ

រាប់ឆ្នាំនោះបាន ១៦០០០ ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុរបស់ពួកបរនិម្មិតវសវត្តីទេវតា ។ ម្នាលភិក្ខុទាំងឡាយ ហេតុនេះ រមែងមានត្រង់ដែលស្រ្តី ឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកបរនិម្មិតវសវត្តីទេវតា ។ ម្នាលភិក្ខុទាំងឡាយ រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខជារបស់ទិព្វ ដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះឯង ។

បុគ្គលមិនគប្បីសម្លាប់សត្វ ១ មិនគប្បីកាន់យកវត្ថុដែលគេមិនបានឲ្យ ១ មិនគប្បីពោលពាក្យកុហក ១ មិនគប្បីផឹកទឹកស្រវឹង ១ គប្បីវៀរចាកការប្រព្រឹត្តមិនប្រសើរ គឺមេថុន ១ មិនគប្បីបរិភោគភោជន ក្នុងវេលារាត្រី និងក្នុងវេលាវិកាល ១ មិនគប្បីទ្រទ្រង់ផ្កាកម្រង មិនគប្បីប្រស់ព្រំដោយគ្រឿងក្រអូប ១ គប្បីដេកលើគ្រែ លើផែនដី ឬ លើកម្រាល ១ ព្រះពុទ្ធព្រះអង្គ ដល់នូវទីបំផុតនៃទុក្ខ ទ្រង់ប្រកាសហើយ នូវឧបោសថដែលប្រកបដោយអង្គ ៨ ប្រការនេះឯង

បណ្ណាសកេ ឧបោសថវគ្គោ

ចន្ទោ ច សុរិយោ ច ឧភោ សុទស្សនា
ឱភាសយន្តា អនុយន្តិ[១] យាវតា
តមោនុទា តេ បន អន្តលិក្ខគា
នភេ បភាសន្តិ ទិសា វិរោចនា
ឯតស្មិំ យំ វិជ្ជតិ អន្តរេ ធនំ
មុត្តា មណី វេឡុរិយញ្ច ភទ្ទកំ
សិង្គី សុវណ្ណំ អថវាបិ កាញ្ចនំ
យំ ជាតរូបំ ហដកន្តិ វុច្ចតិ
អដ្ឋង្គុបេតស្ស ឧបោសថស្ស
កលម្បិ តេ នានុភវន្តិ សោឡសឹ
ចន្ទប្បភា តារគណាវ សព្វេ
តស្មា ហិ នារី ច នរោ ច សីលវា
អដ្ឋង្គុបេតំ ឧបវស្សុបោសថំ
បុញ្ញានិ កត្វាន សុខុទ្រយានិ
អនិន្ទិតា សគ្គមុបេន្តិ ឋានន្តិ ។

១ ឱ. ឱភាសយំ អនុបរិយន្តិ ។

សភាវៈទាំងឡាយពីរ គឺព្រះចន្ទ ១ ព្រះអាទិត្យ ១ ជាសភាវៈល្អមើល កាលបំភ្លឺលោក រមែងចរទៅអស់ទីត្រឹមណា ព្រះច័ន្ទនិងព្រះអាទិត្យទាំងនោះ ដែលកម្ចាត់បង់នូវងងឹត ចរទៅក្នុងអាកាស ញ៉ាំងទិសឲ្យរុងរឿងភ្លឺច្បាស់ ក្នុងអាកាសអស់ទីត្រឹមនោះ ទ្រព្យណា មានក្នុងចន្លោះនេះ គឺកែវមុក្តាក្តី កែវមណីក្តី កែវពិទូរ្យដ៏ល្អក្តី មាសឈ្មោះសិង្គីក្តី ឈ្មោះសុវណ្ណក្តី ឬមាសឈ្មោះកាញ្ចនៈក្តី ឈ្មោះជាតរូបក្តី ឈ្មោះហាដកៈក្តី ទ្រព្យទាំងអម្បាលនោះ មិនដល់នូវចំណិតមួយក្នុងចំណែក ១៦ ៗ លើកនៃឧបោសថដែលប្រកបដោយអង្គ ៨ ប្រការឡើយ ដូចជាពួកផ្កាយទាំងអស់ មិនដល់នូវពន្លឺនៃព្រះចន្ទ ហេតុដូច្នោះ ស្ត្រីក្តី បុរសក្តី ជាអ្នកមានសីល គួរចាំរក្សានូវឧបោសថប្រកបដោយអង្គ ៨ ប្រការ ពួកជនដែលមិនមានគេនិន្ទា បំពេញនូវបុណ្យទាំងឡាយ ដែលមានសេចក្តីសុខជាកម្រៃ រមែងចូលទៅកាន់ឋានសួគ៌បាន ។

[៤៣] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុប្បាសាទេ ។ អថខោ វិសាខា មិគារមាតា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ វិសាខំ មិគារមាតរំ ភគវា ឯតទវោច អដ្ឋង្គសមន្នា-គតោ វិសាខេ ឧបោសថោ ឧបវុត្ថោ មហប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោ ។ កថំ ឧបវុត្ថោ ច វិសាខេ អដ្ឋង្គសមន្នាគតោ ឧបោសថោ មហប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោ ។ ឥធ វិសាខេ អរិយសាវកោ ឥតិ បដិសញ្ចិក្ខតិ យាវជីវំ អរហន្តោ បាណាតិបាតំ បហាយ បាណាតិបាតា បដិវិរតា និហិតទណ្ឌា និហិតសត្ថា លជ្ជី ទយាបន្នា សព្វបាណភូតហិតានុកម្បិនោ វិហរន្តិ

[៤៣] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅនាប្រាសាទមិគារមាតា ក្នុងបុព្វារាម ជិតក្រុងសាវត្ថី ។ គ្រានោះ នាងវិសាខា ជាមិគារមាតា ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះវិសាខា ជាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ទើបព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូចនេះថា ម្នាលវិសាខា ឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ។ ម្នាលវិសាខា ចុះឧបោសថប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន តើដោយប្រការដូចម្តេច ។ ម្នាលវិសាខា អរិយសាវ័កក្នុងសាសនានេះ ពិចារណាថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះ ដោយប្រយោជន៍ ដល់សព្វសត្វ ដរាបអស់ជីវិត

អហំបជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ បាណាតិបាតំ បហាយ
បាណាតិបាតា បដិវិរតោ និហិតទណ្ឌោ និហិតសត្ថោ
លជ្ជី ទយាបន្នោ សព្វបាណភូតហិតានុកម្បី វិហរាមិ
ឥមិនាបង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ
ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា បឋមេន អង្គេន សមន្នា-
គតោ ហោតិ ។ បេ ។ យាវជីវំ អរហន្តោ ឧច្ចាសយន-
មហាសយនំ បហាយ ឧច្ចាសយនមហាសយនា
បដិវិរតា នីចសេយ្យំ កប្បេន្តិ មញ្ចកេ វា តិណសន្ថរកេ
វា អហំបជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឧច្ចាសយន-
មហាសយនំ បហាយ ឧច្ចាសយនមហាសយនា
បដិវិរតោ នីចសេយ្យំ កប្បេមិ មញ្ចកេ វា តិណ-
សន្ថរកេ វា ឥមិនាបង្គេន អរហតំ អនុករោមិ
ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា
អដ្ឋមេន អង្គេន សមន្នាគតោ ហោតិ ។ ឯវំ ឧបវុត្ថោ
ខោ វិសាខេ អដ្ឋង្គសមន្នាគតោ ឧបោសថោ មហប្ផលោ
ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោ ។

ក្នុងថ្ងៃនេះ ចំណែកខ្ញុំនអញលះបង់បាណាតិបាត វៀរចាកបាណាតិបាត មានអាជ្ញាដាក់ចុះហើយ មានគ្រឿងសស្ត្រាដាក់ចុះហើយ មានសេចក្តីខ្មាសបាប មានសេចក្តីអាណិត មានសេចក្តីអនុគ្រោះដោយប្រយោជន៍ដល់សព្វសត្វ អស់យប់នេះនិងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ១ នេះឯង ។ បេ ។ ព្រះអរហន្តទាំងឡាយ លះបង់នូវសេនាសនៈដ៏ខ្ពស់ និងសេនាសនៈ ដ៏ប្រសើរ វៀរចាកសេនាសនៈដ៏ខ្ពស់ និងសេនាសនៈ ដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើគ្រែតូច លើកម្រាលដែលគេធ្វើដោយស្មៅក្តី ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកខ្ញុំនអញ លះបង់សេនាសនៈដ៏ខ្ពស់ និងសេនាសនៈដ៏ប្រសើរ វៀរចាកសេនាសនៈដ៏ខ្ពស់និងសេនាសនៈដ៏ប្រសើរ សម្រេចនូវទីដេកដ៏ទាប លើគ្រែតូច លើកម្រាលដែលគេធ្វើដោយស្មៅក្តី អស់យប់នេះនិងថ្ងៃនេះដែរ យកតម្រាប់ព្រះអរហន្តទាំងឡាយផង ខ្ញុំនអញនឹងចាំរក្សាឧបោសថផង ដោយអង្គនេះឯង ។ ឧបោសថប្រកបដោយអង្គទី ៨ នេះឯង ។ ម្នាលវិសាខា ឧបោសថ ប្រកបដោយអង្គ ៨ ប្រការ ដែលបុគ្គលចាំរក្សាយ៉ាងនេះហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានសេចក្តីរុងរឿងច្រើន មានសេចក្តីផ្សាយទៅច្រើន ។

កីវមហាប្ផលោ ហោតិ កីវមហានិសំសោ កីវមហា-
ជុតិកោ កីវមហាវិប្ផារោ ។ សេយ្យថាបិ វិសាខេ យោ
ឥមេសំ សោឡសន្នំ មហាជនបទានំ បហូតសត្តរតនានំ
ឥស្សរាធិបច្ចំ រជ្ជំ ការេយ្យ សេយ្យថីទំ អង្គានំ មគធានំ
កាសីនំ កោសលានំ វជ្ជីនំ មល្លានំ ចេតីនំ វំសានំ
កុរូនំ បញ្ចាលានំ មច្ឆានំ សូរសេនានំ អស្សកានំ អវន្តីនំ
គន្ធារានំ កម្ពោជានំ អដ្ឋង្គសមន្នាគតស្ស ឧបោសថស្ស
ឯតំ កលំ នាគ្ឃតិ សោឡសឹ ។ តំ កិស្ស ហេតុ ។
កបណំ វិសាខេ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។
យានិ វិសាខេ មានុសកានិ បញ្ញាសំ វស្សានិ ចាតុម្ម-
ហារាជិកានំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា
តឹសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ
សំវច្ឆរោ តេន សំវច្ឆរេន ទិព្វានិ បញ្ច វស្សសតានិ
ចាតុម្មហារាជិកានំ ទេវានំ អាយុប្បមាណំ ។

ឧបោសថ មានផលច្រើន ដូចម្តេច មានអានិសង្សច្រើន ដូចម្តេច មានសេចក្តីរុងរឿងច្រើន ដូចម្តេច មានសេចក្តីផ្សាយទៅច្រើន ដូចម្តេច ។ ម្នាលវិសាខា ប្រៀបដូចបុគ្គល សោយរាជ្យ ជាឥស្សរាធិបតីនៃមហាជនបទទាំង ១៦ នេះ ដែលជាជនបទ សម្បូរដោយកែវ ៧ ប្រការ គឺមហាជនបទឈ្មោះអង្គៈ ១ មគធៈ ១ កាសី ១ កោសលៈ ១ វជ្ជី ១ មល្លៈ ១ ចេតី ១ វំសៈ ១ កុរុ ១ បញ្ចាលៈ ១ មច្ឆៈ ១ សូរសេនៈ ១ អស្សកៈ ១ អវន្តី ១ គន្ធារៈ ១ កម្ពោជៈ ១ រាជសម្បត្តិ នៃមហាជនបទទាំងនុ៎ះ មិនដល់នូវចំណិត ១ ក្នុងចំណិតទី ១៦ៗ លើកនៃឧបោសថ ដែលប្រកបដោយអង្គ ៨ ប្រការឡើយ ។ ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលវិសាខា រាជសម្បត្តិ របស់មនុស្ស ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្វ ។ ម្នាលវិសាខា ៥០ ឆ្នាំរបស់មនុស្ស ត្រូវជា ១ យប់ ១ ថ្ងៃ របស់ចាតុម្មហារាជិកទេវតា រាប់រាត្រីនោះបាន ៣០ រាត្រី ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ៥០០ ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុរបស់ពួកចាតុម្មហារាជិកទេវតា ។

ឋានំ ខោ បនេតំ វិសាខេ វិជ្ជតិ យំ ឯកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា ចាតុម្មហារាជិកានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥទំ ខោ បន មេតំ វិសាខេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។ យំ វិសាខេ មានុសកំ វស្សសតំ តាវត្តឹសានំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន ទិព្វំ វស្សសហស្សំ តាវត្តឹសានំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ វិសាខេ វិជ្ជតិ យំ ឯកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា តាវត្តឹសានំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥទំ ខោ បន មេតំ វិសាខេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។

ម្នាលវិសាខា ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សានូវឧបោសថប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកចាតុម្មហារាជិកទេវតា ។ ម្នាលវិសាខា រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្យ ដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។ ម្នាលវិសាខា ១០០ ឆ្នាំរបស់មនុស្សត្រូវជា ១ យប់ ១ ថ្ងៃ របស់ពួកតាវត្តិង្សទេវតា រាប់រាត្រីនោះបាន ៣០ រាត្រីត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ១០០០ ឆ្នាំទិព្យ ត្រូវជាប្រមាណនៃអាយុ របស់តាវត្តិង្សទេវតា ។ ម្នាលវិសាខា ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សាឧបោសថប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងចូលទៅកើតជាមួយនឹងពួកតាវត្តិង្សទេវតា ។ ម្នាលវិសាខា រាជសម្បត្តិរបស់មនុស្សនេះឯង ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្យ ដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។

យានិ វិសាខេ មានុសកានិ ទ្វេ វស្សសតានិ ។ បេ ។ ចត្តារិ វស្សសតានិ ។ បេ ។ អដ្ឋ វស្សសតានិ ។ បេ ។ សោឡស វស្សសតានិ បរនិម្មិតវសវត្តីនំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន ទិព្វានិ សោឡស វស្សសហស្សានិ បរនិម្មិតវសវត្តីនំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ វិសាខេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា បរនិម្មិតវសវត្តីនំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥទំ ខោ បន មេតំ វិសាខេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយាតិ ។

បាណំ ន ហញ្ញេ ន ចាទិន្នមាទិយេ
មុសា ន ភាសេ ន ច មជ្ជបោ សិយា
អព្រហ្មចរិយា វិរមេយ្យ មេថុនា
រត្តឹ ន ភុញ្ជេយ្យ វិកាលភោជនំ

ម្នាលវិសាខា ២០០ ឆ្នាំរបស់មនុស្ស ។ បេ ។ ៤០០ ឆ្នាំ ។ បេ ។ ៨០០ ឆ្នាំ ។ បេ ។ ១៦០០ ឆ្នាំត្រូវជា ១ យប់ ១ ថ្ងៃរបស់ពួកបរនិម្មិតវសវត្តីទេវតា រាប់រាត្រីនោះបាន ៣០ រាត្រី ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ១៦០០០ (មួយហ្មឺនប្រាំមួយពាន់) ឆ្នាំទិព្យ ត្រូវជាប្រមាណនៃអាយុ របស់ពួកបរនិម្មិតវសវត្តីទេវតា ។ ម្នាលវិសាខា ហេតុនេះ រមែងមាន ត្រង់ដែលស្ត្រីឬបុរសពួកខ្លះ ក្នុងលោកនេះ ចាំរក្សាឧបោសថប្រកបដោយអង្គ ៨ ប្រការ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកបរនិម្មិតវសវត្តីទេវតា ។ ម្នាលវិសាខា រាជសម្បត្តិរបស់មនុស្សនេះឯង ជារបស់ស្តួចស្តើង ហើយយកទៅប្រៀបធៀបនឹងសេចក្តីសុខ ជារបស់ទិព្យ ដែលតថាគតសម្តែងហើយ ព្រោះអាស្រ័យហេតុនេះ ។

បុគ្គលមិនគប្បីសម្លាប់សត្វ ១ មិនគប្បីកាន់យកវត្ថុ ដែលគេមិនបានឲ្យ ១ មិនគប្បីពោលពាក្យកុហក ១ មិនគប្បីផឹកទឹកស្រវឹង ១ គប្បីវៀរចាកការប្រព្រឹត្តធម៌មិនប្រសើរ គឺមេថុន ១ មិនគប្បី បរិភោគភោជន ក្នុងវេលារាត្រី និងក្នុងវេលាវិកាល ១

២០១

បណ្ណាសកេ ឧបោសថវគ្គោ

មាលំ ន ធារយេ ន ច គន្ធមាចរេ
មញ្ចេ ឆមាយំវ សយេថ សន្ថតេ
ឯតញ្ហិ អដ្ឋង្គិកមាហុចោសថំ
ពុទ្ធេន ទុក្ខន្តគុនា បកាសិតំ
ចន្ទោ ច សូរោ ច ឧភោ សុទស្សនា
ឱភាសយន្តា អនុយន្តិ យាវតា
តមោនុទា តេ បន អន្តលិក្ខគា
នភេ បភាសន្តិ ទិសា វិរោចនា
ឯតស្មិំ យំ វិជ្ជតិ អន្តរេ ធនំ
មុត្តា មណី វេឡុរិយញ្ច ភទ្ទកំ
សិង្គី សុវណ្ណំ អថវាបិ កាញ្ចនំ
យំ ជាតរូបំ ហដកន្តិ វុច្ចតិ
អដ្ឋង្គុបេតស្ស ឧចោសថស្ស
កលម្បិ តេ នានុភវន្តិ សោឡសឹ
ចន្ទប្បភា តារគណាវ សព្វេ

មិនគប្បីទ្រទ្រង់នូវផ្កាកម្រង មិនគប្បីប្រស់ព្រំ ដោយគ្រឿងក្រអូប ១ គប្បីដេកលើគ្រែ លើផែនដី ឬ លើកម្រាល ១ ព្រះពុទ្ធ ព្រះអង្គដល់នូវទីបំផុតនៃទុក្ខ ទ្រង់ប្រកាសហើយ នូវឧបោសថប្រកបដោយអង្គ ៨ ប្រការនេះឯង សភាវៈទាំងឡាយពីរគឺ ព្រះចន្ទ ១ ព្រះអាទិត្យ ១ ជាសភាវៈល្អមើល កាលបំភ្លឺលោក រមែងចរទៅ អស់ទីត្រឹមណា ព្រះចន្ទនិងព្រះអាទិត្យទាំងនោះ ដែលកម្ចាត់បង់នូវងងឹត ចរទៅក្នុងអាកាស ញុាំងទិសឲ្យរុងរឿងភ្លឺច្បាស់ ក្នុងអាកាស អស់ទីត្រឹមនោះ ទ្រព្យណា មានក្នុងចន្លោះនេះ គឺកែវមុក្តាក្តី កែវមណីក្តី កែវពិទូរ្យដ៏ល្អក្តី មាសឈ្មោះសិង្គីក្តី ឈ្មោះសុវណ្ណក្តី ឬ មាសឈ្មោះកាញ្ចនៈក្តី ឈ្មោះជាតរូបក្តី ឈ្មោះហដកៈក្តី ទ្រព្យទាំងអម្បាលនោះ មិនដល់នូវចំណិត ១ ក្នុងចំណែក ១៦ ៗ លើក នៃឧបោសថ ដែលប្រកបដោយអង្គ ៨ ប្រការឡើយ ដូចជាពួកផ្កាយ ទាំងអស់ មិនដល់នូវពន្លឺ នៃព្រះចន្ទ

តស្មា ហិ នារី ច នរោ ច សីលវា
អដ្ឋង្គុបេតំ ឧបវស្សុបោសថំ
បុញ្ញានិ កត្វាន សុខុទ្រយានិ
អនិន្ទិតា សគ្គមុបេន្តិ ឋានន្តិ ។

[៤៤] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ វាសេដ្ឋោ ឧបាសកោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯក-មន្តំ និសិន្នំ ខោ វាសេដ្ឋំ ឧបាសកំ ភគវា ឯតទវោច អដ្ឋង្គសមន្នាគតោ វាសេដ្ឋ ឧបោសថោ ឧបវុត្ថោ មហប្ផលោ ហោតិ ។ បេ ។ អនិន្ទិតា សគ្គមុបេន្តិ ឋានន្តិ ។ ឯវំ វុត្តេ វាសេដ្ឋោ ឧបាសកោ ភគវន្តំ ឯតទវោច បិយា មេ ភន្តេ ញាតិសាលោហិតា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសេយ្យុំ បិយានម្បិ មេ អស្ស ញាតិសា-លោហិតានំ ទីឃរត្តំ ហិតាយ សុខាយ ។

ហេតុដូច្នោះ ស្ត្រីក្តី បុរសក្តី ជាអ្នកមានសីល គួរចាំរក្សា នូវឧបោសថប្រកបដោយអង្គ ៨ ប្រការ ពួកជនដែលមិនមានគេនិន្ទា បំពេញនូវបុណ្យដែលមានសេចក្តីសុខជាកម្រៃ រមែងចូលទៅកាន់ឋានសួគ៌បាន ។

[៤៤] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងកូដាគារសាលា នាព្រៃមហាវ័ន ជិតក្រុងវេសាលី ។ គ្រានោះ វាសេដ្ឋឧបាសក (ឧបាសកឈ្មោះវាសេដ្ឋ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយក៏អង្គុយក្នុងទីសមគួរ ។ លុះវាសេដ្ឋឧបាសក អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលវាសេដ្ឋ ឧបោសថប្រកបដោយអង្គ ៨ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន ។ បេ ។ ពួកជនដែលគេមិននិន្ទា តែងទៅកាន់ឋានសួគ៌ ។ កាលដែលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ វាសេដ្ឋឧបាសក បានក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ពួកញាតិសាលោហិត ជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គ គប្បីរក្សាឧបោសថប្រកបដោយអង្គ ៨ ការរក្សាឧបោសថនោះ គប្បីប្រព្រឹត្តទៅ ដើម្បីជាប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ពួកញាតិសាលោហិត ជាទីស្រឡាញ់របស់ខ្ញុំព្រះអង្គ អស់កាលយូរ ។

២០៣



សព្វេ ចេបិ ភន្តេ ខត្តិយា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសេយ្យុំ សព្វេសម្បិស្ស ខត្តិយានំ ទីឃរត្តំ ហិតាយ សុខាយ ។ សព្វេ ចេបិ ភន្តេ ព្រាហ្មណា ។ បេ ។ វេស្សា សុទ្ទា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសេយ្យុំ សព្វេសម្បិស្ស សុទ្ទានំ ទីឃរត្តំ ហិតាយ សុខាយាតិ ។ សព្វេ ចេបិ វាសេដ្ឋ[១] ខត្តិយា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសេយ្យុំ សព្វេសម្បិស្ស ខត្តិយានំ ទីឃរត្តំ ហិតាយ សុខាយ ។ សព្វេ ចេបិ វាសេដ្ឋ ព្រាហ្មណា ។ បេ ។ វេស្សា សុទ្ទា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសេយ្យុំ សព្វេសម្បិស្ស សុទ្ទានំ ទីឃរត្តំ ហិតាយ សុខាយ ។ សទេវកោ ចេបិ វាសេដ្ឋ លោកោ សមារកោ សព្រហ្មកោ សស្សមណព្រាហ្មណី បជា សទេវមនុស្សា[២] អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសេយ្យុំ

---

១ ឱ. ឯវមេតំ វាសេដ្ឋ ។ សព្វេ ចេបិ វាសេដ្ឋាតិ ទិស្សន្តិ ។ ២ ឱ. ម. សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ។

បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកក្សត្រិយ៍ទាំងពួង គប្បីចាំរក្សាឧបោសថប្រកបដោយអង្គ ៨ ការរក្សាឧបោសថនោះ គប្បីប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ពួកក្សត្រិយ៍ទាំងពួង អស់កាលយូរ ។ បពិត្រព្រះអង្គដ៏ចម្រើន ប្រសិនបើពួកព្រាហ្មណ៍ទាំងពួង ។ បេ ។ ពួកវេស្សៈ សុទ្ទៈ គប្បីចាំរក្សាឧបោសថប្រកបដោយអង្គ ៨ ការរក្សាឧបោសថនោះ គប្បីប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ពួកសុទ្ទៈទាំងពួង អស់កាលយូរ ។ ម្នាលវាសេដ្ឋ ប្រសិនបើពួកក្សត្រិយ៍ទាំងពួង គប្បីចាំរក្សាឧបោសថប្រកបដោយអង្គ ៨ ការរក្សាឧបោសថនោះ គប្បីប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ពួកក្សត្រិយ៍ទាំងពួង អស់កាលយូរ ។ ម្នាលវាសេដ្ឋ ប្រសិនបើពួកព្រាហ្មណ៍ទាំងពួង ។ បេ ។ ពួកវេស្សៈ សុទ្ទៈ គប្បីចាំរក្សាឧបោសថប្រកបដោយអង្គ ៨ ហើយ ការរក្សាឧបោសថនោះគប្បីប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្ដីសុខ ដល់ពួកសុទ្ទៈទាំងពួង អស់កាលយូរ ។ ម្នាលវាសេដ្ឋ ប្រសិនបើលោក (នេះ) ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ទាំងមនុស្ស ជាសម្មតិទេព និងមនុស្សដ៏សេស គប្បីចាំរក្សាឧបោសថប្រកបដោយអង្គ ៨

សទេវកស្ស លោកស្ស សមារកស្ស សព្រហ្មកស្ស សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ ទីឃរត្តំ ហិតាយ សុខាយ ។ ឥមេ ចេបិ វាសេដ្ឋ មហាសាលា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសេយ្យុំ ឥមេសម្បិស្ស មហាសាលានំ ទីឃរត្តំ ហិតាយ សុខាយ សចេ ចេតេយ្យុំ(១) កោ បន វាទោ មនុស្សភូតស្សាតិ ។

[៤៩] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ ជេតវនេ អនាថបិណ្ឌិកស្ស អារាមេ ។ អថខោ វិសាខា ឧបា-សិកា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ វិសាខំ ឧបាសិកំ ភគវា ឯតទវោច អដ្ឋង្គស-មន្នាគតោ វិសាខេ ឧបោសថោ ឧបវុត្ថោ មហប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោ ។

---

១- សចេ ចេតេយ្យុន្តិ ឥមេ បាឋា មរម្មបោត្ថកេ នត្ថិ ។ អយំ នយោ យុត្តតរោ ។ តេ ហិ និរត្ថកា ហោន្តិ ។

ការរក្សាឧបោសថនោះ គប្បីប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់លោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ដល់ពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទាំងមនុស្ស ជាសម្មតិទេព និងមនុស្សដ៏សេស អស់កាលយូរ ។ ម្នាលវាសេដ្ឋ ប្រសិនបើ ដើមមហាសាលព្រឹក្សទាំងនេះ គប្បីចាំរក្សាឧបោសថ ប្រកបដោយអង្គ ៨ ការរក្សាឧបោសថនោះគប្បីប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ដើមមហាសាលព្រឹក្សទាំងនេះ អស់កាលយូរ ប្រសិនបើ ឈើទាំងនេះចេះគិត ចាំបាច់ទៅនិយាយថ្វី ដល់មនុស្ស ។

[៤៩] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ជិតក្រុងសាវត្ថី ។ គ្រានោះ នាងពោជ្ឈាឧបាសិកា (ឧបាសិកាឈ្មោះពោជ្ឈា) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ អង្គុយក្នុងទីសមគួរ ។ លុះនាងពោជ្ឈាឧបាសិកា អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលនាងពោជ្ឈា ឧបោសថប្រកបដោយអង្គ ៨ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានការរុងរឿងច្រើន មានគុណផ្សាយទៅច្រើន ។

កថំ ឧបវុត្ថោ ច ពោជ្ឈ អដ្ឋង្គសមន្នាគតោ ឧចោសថោ មហប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហា-វិប្ផារោ ។ ឥធ ពោជ្ឈ អរិយស្សាវកោ ឥតិ បជិសញ្ចិ-ក្ខតិ យាវជីវំ អរហន្តោ ចាណាតិចាតំ បហាយ ចាណា-តិចាតា បជិវិរតា និហិតទណ្ឌា និហិតសត្ថា លជ្ជី ទយា-បន្នា សព្វប្បាណភូតហិតានុកម្បិនោ វិហរន្តិ អហំបជ្ជ ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ចាណាតិចាតំ បហាយ ចា-ណាតិចាតា បជិវិរតោ និហិតទណ្ឌោ និហិតសត្ថោ លជ្ជី ទយាបន្នោ សព្វប្បាណភូតហិតានុកម្បី វិហរាមិ ឥមិនា-បង្គេន អរហតំ អនុករោមិ ឧចោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា បឋមេន អង្គេន សមន្នាគតោ ហោតិ ។ បេ ។ យាវជីវំ អរហន្តោ ឧច្ចាសយនមហាសយនំ បហាយ ឧច្ចាសយនមហាសយនា បជិវិរតា នីចសេយ្យំ កប្បេន្តិ មញ្ចកេ វា តិណសន្ថរកេ វា អហំបជ្ជ

ម្នាលនាងពោដ្ឋា ចុះឧបោសថប្រកបដោយអង្គ ៨ ដែលបុគ្គលចាំរក្សាហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានការរុងរឿងច្រើន មានការផ្សាយទៅច្រើន តើដូចម្តេច ។ ម្នាលនាងពោដ្ឋា អរិយសាវ័ក ក្នុងសាសនានេះ ពិចារណាថា ព្រះអរហន្តទាំងឡាយ លះបង់បាណាតិបាត វៀរចាកបាណាតិបាត ដាក់ចុះនូវអាជ្ញា ដាក់ចុះនូវគ្រឿងសស្ត្រា មានសេចក្តីអៀនខ្មាស ដល់នូវការអាណិត អនុគ្រោះដោយប្រយោជន៍ ដល់សត្វទាំងអស់ ដរាបដល់អស់ជីវិត ក្នុងថ្ងៃនេះ ចំណែកអាត្មាអញបានលះបង់បាណាតិបាត វៀរចាកបាណាតិបាត ដាក់ចុះនូវអាជ្ញា ដាក់ចុះនូវគ្រឿងសស្ត្រា មានសេចក្តីអៀនខ្មាស ដល់នូវការអាណិត អនុគ្រោះដោយប្រយោជន៍ ដល់សត្វទាំងអស់ អស់យប់នេះនិងថ្ងៃនេះដែរ ធ្វើតាមព្រះអរហន្តទាំងឡាយផង ឧបោសថអាត្មាអញនឹងចាំរក្សាហើយផង ដោយអង្គនេះ ។ អរិយសាវ័កប្រកបដោយអង្គទី ១ នេះ ។ បេ ។ ព្រះអរហន្តទាំងឡាយ លះបង់ទីដេក ទីអង្គុយដ៏ខ្ពស់ហួសប្រមាណនិងទីដេកទីអង្គុយដ៏ប្រសើរ វៀរចាកទីដេក ទីអង្គុយដ៏ខ្ពស់ហួសប្រមាណនិងទីដេកទីអង្គុយដ៏ប្រសើរ សម្រេចការដេកលើអាសនៈ គឺលើគ្រែ ឬ លើកម្រាលស្មៅ ដរាបអស់ជីវិត ក្នុងថ្ងៃនេះ ចំណែកអាត្មាអញ

ឥមញ្ច រត្តឹ ឥមញ្ច ទិវសំ ឧច្ចាសយនមហាសយនំ បហាយ ឧច្ចាសយនមហាសយនា បដិវិរតោ នីចសេយ្យំ កប្បេមិ មញ្ចកេ វា តិណសន្ថរកេ វា ឥមិនាបង្គេន អរហតំ អនុករោមិ ឧបោសថោ ច មេ ឧបវុត្ថោ ភវិស្សតីតិ ។ ឥមិនា អដ្ឋមេន អង្គេន សមន្នាគតោ ហោតិ ។ ឯវំ ឧបវុត្ថោ ខោ ពោជ្ឈេ អដ្ឋង្គសមន្នា-គតោ ឧបោសថោ មហប្ផលោ ហោតិ មហានិសំសោ មហាជុតិកោ មហាវិប្ផារោ ។ កីវមហប្ផលោ ហោតិ កីវមហានិសំសោ កីវមហាជុតិកោ កីវមហាវិប្ផា-រោ ។ សេយ្យថាបិ ពោជ្ឈេ យោ ឥមេសំ សោឡ-សន្នំ មហាជនបទានំ បហូតសត្តរតនានំ ឥស្សរាធិ-បច្ចំ រជ្ជំ ការេយ្យ សេយ្យថីទំ អង្គានំ មគធានំ កាសីនំ កោសលានំ វជ្ជីនំ មល្លានំ ចេតីនំ វំសានំ កុរូនំ បញ្ចាលានំ មច្ឆានំ សូរសេនានំ អស្សកានំ អវន្តីនំ គន្ធារានំ កម្ពោជានំ អដ្ឋង្គសមន្នាគតស្ស ឧបោសថស្ស ឯតំ កលំ នាគ្ឃតិ សោឡសឹ ។

បានលះបង់ទីដេក ទីអង្គុយដ៏ខ្ពស់ហួសប្រមាណ និងទីដេក ទីអង្គុយដ៏ប្រសើរ វៀរចាកទីដេកទីអង្គុយខ្ពស់ហួសប្រមាណនិងទីដេកទីអង្គុយដ៏ប្រសើរ សម្រេចការដេកលើអាសនៈទាប គឺ លើគ្រែ ឬ លើកម្រាលស្មៅ អស់យប់នេះ និងថ្ងៃនេះដែរ ធ្វើតាមព្រះអរហន្តទាំងឡាយនេះផង ឧបោសថ អាត្មាអញ នឹងចាំរក្សាហើយផង ដោយអង្គនេះឯង ។ អរិយសាវ័កប្រកបដោយអង្គទី ៨ នេះ ។ ម្នាលនាងពោដ្ឋា ឧបោសថប្រកបដោយអង្គ ៨ ដែលបុគ្គលចាំរក្សាយ៉ាងនេះហើយ រមែងមានផលច្រើន មានអានិសង្សច្រើន មានការរុងរឿងច្រើន មានគុណផ្សាយទៅច្រើន ។ ឧបោសថមានផលច្រើនប៉ុនណា មានអានិសង្សច្រើនប៉ុនណា មានការរុងរឿងច្រើនប៉ុនណា មានគុណផ្សាយទៅច្រើនប៉ុនណា ។ ម្នាលនាងពោដ្ឋា ប្រៀបដូចជាបុគ្គលណាសោយរាជ្យ ជាឥស្សរាធិបតីលើមហាជនបទទាំង ១៦ នេះ ដែលសម្បូណ៌ដោយរតនៈ (ទ្រព្យជាគ្រឿងរីករាយ) ទាំង ៧ ប្រការ គឺមហាជនបទឈ្មោះអង្គៈ ១ មគធៈ ១ កាសី ១ កោសលៈ ១ វជ្ជី ១ មល្លៈ ១ ចេតី ១ វង្សៈ ១ កុរុ ១ បញ្ចាលៈ ១ មច្ឆៈ ១ សូរសេនៈ ១ អស្សកៈ ១ អវន្តី ១ គន្ធារៈ ១ កម្ពោជៈ ១ ឯភោគសម្បទ័ទាំងនុ៎ះ មិនដល់នូវចំណិតនៃចំណែក ១៦ ៗ លើកនៃឧបោសថ ដែលប្រកបដោយអង្គ ៨ ឡើយ ។

២០៧



តំ កិស្ស ហេតុ ។ កបណំ ភិក្ខវេ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។ យានិ ភិក្ខវេ មានុសកានិ បញ្ញាសំ វស្សានិ ចាតុម្មហារាជិកានំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តឹសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន ទិព្វានិ បញ្ច វស្សសតានិ ចាតុម្មហារាជិ-កានំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ ភិក្ខវេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា ចាតុម្មហារាជិកានំ ទេវានំ សហាព្យតំ ឧបបជ្ជេយ្យ ។ ឥទំ ខោ បនេតំ ភិក្ខវេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយ ។ យំ ភិក្ខវេ មានុសកំ វស្សសតំ ។ បេ ។ យានិ ភិក្ខវេ មានុសកានិ ទ្វេ វស្សសតានិ ។ បេ ។ ចត្តារិ វស្សសតានិ ។ បេ ។ អដ្ឋ វស្សសតានិ ។ បេ ។ សោឡស វស្សសតានិ

ដំណើរនោះ ព្រោះហេតុអ្វី ។ ម្នាលនាងពោដ្ឋា (ព្រោះថា) រាជ-សម្បត្តិរបស់មនុស្ស ជារបស់ស្តួចស្តើង ហើយប្រៀបផ្ទឹមនឹងសុខជាទិព្វ ។ ម្នាលនាងពោដ្ឋា ព្រោះថា ៥០ ឆ្នាំរបស់មនុស្ស ជា ១ យប់ ១ ថ្ងៃរបស់ពួកទេវតាជាន់ចាតុម្មហារាជិកៈ រាប់រាត្រីនោះបាន ៣០ រាត្រី ត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ខែត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះ បាន ៥០០ ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុ របស់ពួកទេវតាជាន់ចាតុម្មហារាជិកៈ ។ ម្នាលនាងពោដ្ឋា ហេតុនេះរមែងមានប្រាកដ ត្រង់ដែលស្ត្រីឬបុរសពួកខ្លះក្នុងលោកនេះ ចាំរក្សាឧបោសថប្រកបដោយអង្គ ៨ ហើយ លុះទម្លាយរាងកាយស្លាប់ទៅ គប្បីទៅកើត ជាមួយនឹងពួកទេវតាជាន់ចាតុម្មហា-រាជិកៈ ។ ម្នាលនាងពោដ្ឋា ពាក្យដែលតថាគត សម្តែងហើយថា រាជសម្បត្តិរបស់មនុស្ស ជារបស់ស្តួចស្តើង ប្រៀងផ្ទឹមដោយសុខ ជាទិព្វនេះ ព្រោះសំដៅនូវហេតុនុ៎ះ ។ ម្នាលនាងពោដ្ឋា ១០០ ឆ្នាំរបស់មនុស្ស ។ បេ ។ ម្នាលនាងពោដ្ឋា ២០០ ឆ្នាំរបស់មនុស្ស ។ បេ ។ ៤០០ ឆ្នាំ ។ បេ ។ ៨០០ ឆ្នាំ ។ បេ ។ ១៦០០ ឆ្នាំ (របស់មនុស្ស)

បរនិម្មិតវសវត្តីនំ ទេវានំ ឯសោ ឯកោ រត្តិន្ទិវោ តាយ រត្តិយា តីសរត្តិយោ មាសោ តេន មាសេន ទ្វាទសមាសិយោ សំវច្ឆរោ តេន សំវច្ឆរេន ទិព្វានិ សោឡស វស្សសហស្សានិ បរនិម្មិតវសវត្តីនំ ទេវានំ អាយុប្បមាណំ ។ ឋានំ ខោ បនេតំ ពោជ្ឈេ វិជ្ជតិ យំ ឥធេកច្ចោ ឥត្ថី វា បុរិសោ វា អដ្ឋង្គសមន្នាគតំ ឧបោសថំ ឧបវសិត្វា កាយស្ស ភេទា បរម្មរណា បរនិម្មិតវសវត្តីនំ ទេវានំ សហព្យតំ ឧបបជ្ជេយ្យ ។ ឥទំ ខោ បន មេតំ ពោជ្ឈេ សន្ធាយ ភាសិតំ កបណំ មានុសកំ រជ្ជំ ទិព្វំ សុខំ ឧបនិធាយាតិ

បាណំ ន ហានេ ន ចាទិន្នមាទិយេ
មុសា ន ភាសេ ន ច មជ្ជបោ សិយា
អព្រហ្មចរិយា វិរមេយ្យ មេថុនា
រត្តឹ ន ភុញ្ជេយ្យ វិកាលភោជនំ
មាលំ ន ធារយេ ន ច គន្ធមាចរេ
មញ្ចេ ឆមាយំវ សយេថ សន្ថតេ

ត្រូវជា ១ យប់ ១ ថ្ងៃរបស់ពួកទេវតាជាន់បរនិម្មិតវសវត្តី រាប់រាត្រីនោះបាន ៣០ រាត្រីត្រូវជា ១ ខែ រាប់ខែនោះបាន ១២ ត្រូវជា ១ ឆ្នាំ រាប់ឆ្នាំនោះបាន ១៦០០០ ឆ្នាំទិព្វ ត្រូវជាប្រមាណនៃអាយុរបស់ពួកទេវតាជាន់បរ-និម្មិតវសវត្តី ។ ម្នាលនាងពោដ្ឋា ហេតុនេះ រមែងមានពិតប្រាកដ ត្រង់ដែលស្ត្រីឬបុរសពួកខ្លះក្នុងលោកនេះ ចាំរក្សាឧបោសថប្រកបដោយអង្គ ៨ ហើយ លុះទម្លាយរាងកាយស្លាប់ទៅ គប្បីទៅកើត ជាមួយនឹងពួកទេវតាជាន់បរនិម្មិតវសវត្តី ។ ម្នាលនាងពោដ្ឋា ពាក្យដែលតថាគត សម្តែងហើយថា រាជសម្បត្តិរបស់មនុស្ស ជារបស់ស្តួចស្តើង ប្រៀបផ្ទឹមដោយសុខ ជាទិព្យនេះ ព្រោះសំដៅនូវហេតុនុ៎ះ ។

បុគ្គលកុំគប្បីសម្លាប់សត្វ ១ កុំគប្បីកាន់យកទ្រព្យដែលគេមិនបានឲ្យ ១ កុំគប្បីពោលពាក្យកុហក ១ កុំគប្បីផឹកទឹកស្រវឹង ១ គប្បីវៀរចាកអព្រហ្មចរិយៈគឺមេថុន ១ កុំគប្បីបរិភោគភោជនក្នុងវេលារាត្រីនិងវេលាវិកាល ១ កុំគប្បីទ្រទ្រង់ផ្កាកម្រង កុំគប្បីលាបគ្រឿងក្រអូប ១ គប្បីដេកលើគ្រែ លើផែនដី ឬ លើកម្រាល ១

ឯតញ្ហិ អដ្ឋង្គិកមាហុបោសថំ
ពុទ្ធេន ទុក្ខន្តគុនា បកាសិតំ
ចន្ទោ ច សូរោ[១] ច ឧភោ សុទស្សនា
ឱភាសយន្តា អនុយន្តិ[២] យាវតា
តមោនុទា តេ បន អន្តលិក្ខគា
នភេ បភាសន្តិ ទិសា វិរោចនា
ឯតស្មិំ យំ វិជ្ជតិ អន្តរេ ធនំ
មុត្តា មណី វេឡុរិយញ្ច ភទ្ទកំ
សិង្គី សុវណ្ណំ អថវាបិ កាញ្ចនំ
យំ ជាតរូបំ ហដកន្តិ វុច្ចតិ
អដ្ឋង្គុបេតស្ស ឧបោសថស្ស
កលម្បិ តេ នានុភវន្តិ សោឡសឹ
ចន្ទប្បភា តារគណាវ សព្វេ
តស្មា ហិ នារី ច នរោ ច សីលវា
អដ្ឋង្គុបេតំ ឧបវស្សុបោសថំ
បុញ្ញានិ កត្វាន សុខុទ្រយានិ
អនិន្ទិតា សគ្គមុបេន្តិ ឋានន្តិ ។

១ ឱ. សុរិយោ ។ ២ ឱ. ឱភាសយំ អនុបរិយន្តិ ។

ព្រោះថា ឧបោសថប្រកបដោយអង្គ ៨ នេះ ព្រះពុទ្ធទ្រង់ដល់នូវទីបំផុតនៃទុក្ខ ទ្រង់ប្រកាសហើយ ព្រះចន្ទនិងព្រះអាទិត្យទាំង ២ ជារបស់ល្អហើយ កាលចរទៅបំភ្លឺត្រឹមណា ព្រះចន្ទ និងព្រះអាទិត្យទាំង ២ នោះ តែងកម្ចាត់បង់នូវងងឹតត្រាច់ទៅក្នុងអាកាស ភ្លឺក្នុងអាកាស រុងរឿងសព្វទិស ទ្រព្យណា ដែលមាន ក្នុងចន្លោះនុ៎ះ គឺកែវមុក្តា កែវមណី កែវពិទូរ្យដ៏ល្អ មួយ៉ាងទៀត មាសឈ្មោះសិង្គី ឈ្មោះសុវណ្ណ ឬមាសឈ្មោះកាញ្ចនៈ ឈ្មោះជាតរូប ឈ្មោះហដកៈ របស់ទាំងអស់នោះ ក៏មិនដល់នូវ ១ ចំណិតនៃចំណែក ១៦ៗ លើកនៃឧបោសថ ប្រកបដោយអង្គ ៨ ដូចជាពួកផ្កាយទាំងអស់មិនដល់នូវពន្លឺនៃព្រះចន្ទ ព្រោះហេតុនោះ ជនស្រីប្រុសអ្នកមានសីល គួររក្សាឧបោសថ ប្រកបដោយអង្គ ៨ ពួកជនដែលគេមិននិន្ទាហើយ បំពេញបុណ្យដែលជាកម្រៃនៃសេចក្តីសុខរមែងចូលទៅកាន់ឋានសួគ៌បាន ។

[៨៦] ឯកំ សមយំ ភគវា កោសម្ពិយំ វិហរតិ ឃោសិតារាមេ ។ តេន ខោ បន សមយេន អាយស្មា អនុរុទ្ធោ ទិវាវិហារំ គតោ ហោតិ បដិសល្លីនោ ។ អថខោ សម្ពហុលា មនាបកាយិកា ទេវតា យេនាយស្មា អនុរុទ្ធោ តេនុបសង្កមឹសុ ឧបសង្កមិត្វា អាយស្មន្តំ អនុរុទ្ធំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ តា ទេវតា អាយស្មន្តំ អនុរុទ្ធំ ឯតទវោចុំ មយំ ភន្តេ អនុរុទ្ធ មនាបកាយិកា នាម ទេវតា តីសុ ឋានេសុ ឥស្សរិយំ ការេម វសំ វត្តេម មយំ ភន្តេ អនុរុទ្ធ យាទិសកំ វណ្ណំ អាកង្ខាម តាទិសកំ វណ្ណំ ឋានសោ បដិលភាម យាទិសកំ សទ្ទំ[១] អាកង្ខាម តាទិសកំ សទ្ទំ[២] ឋានសោ បដិលភាម យាទិសកំ សុខំ អាកង្ខាម តាទិសកំ សុខំ ឋានសោ បដិលភាម មយំ ភន្តេ អនុរុទ្ធ មនាបកាយិកា នាម ទេវតា ឥមេសុ តីសុ ឋានេសុ ឥស្សរិយំ ការេម វសំ វត្តេមាតិ ។

១. ២ ឱ. ម. សរំ ។

[៤៦] សម័យមួយ ព្រះដ៏មានព្រះភាគកាលគង់នៅឃោសិតារាម ទៀបក្រុងកោសម្ពី ។ សម័យនោះឯង ព្រះអនុរុទ្ធដ៏មានអាយុ ចូលទៅកាន់ទីនៅក្នុងវេលាថ្ងៃ សម្ងំនៅ ។ គ្រានោះ ពួកទេវតាឈ្មោះមនាបកាយិកា ជាច្រើនអង្គនាំគ្នាចូលទៅរកព្រះអនុរុទ្ធ លុះចូលទៅដល់ ថ្វាយបង្គំព្រះអនុរុទ្ធ ហើយឋិតនៅក្នុងទីសមគួរ ។ លុះទេវតាទាំងនោះ ឋិតនៅក្នុងទីសមគួរហើយ ក៏ពោលទៅនឹងព្រះអនុរុទ្ធដ៏មានអាយុ ដូច្នេះថា បពិត្រព្រះអនុរុទ្ធដ៏ចម្រើន យើងខ្ញុំជាពួកទេវតា ឈ្មោះមនាបកាយិកា ធ្វើឥស្សរិយភាព ញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅ ក្នុងហេតុទាំង ៣ បពិត្រព្រះអនុរុទ្ធដ៏ចម្រើន យើងខ្ញុំប្រាថ្នានូវវណ្ណៈបែបណា ក៏បាននូវវណ្ណៈបែបនោះមួយរំពេច ១ ប្រាថ្នានូវសំឡេងបែបណា ក៏បាននូវសំឡេងបែបនោះមួយរំពេច ១ ប្រាថ្នានូវសុខបែបណា ក៏បាននូវសុខបែបនោះមួយរំពេច ១ បពិត្រព្រះអនុរុទ្ធដ៏ចម្រើន យើងខ្ញុំជាពួកទេវតាឈ្មោះមនាបកាយិកា ធ្វើនូវឥស្សរិយភាព ញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅ ក្នុងហេតុទាំង ៣ នេះ ។

អថខោ អាយស្មតោ អនុរុទ្ធស្ស ឯតទហោសិ អហោ វតិមា ទេវតា សព្វាវ នីលា អស្សុ នីលវណ្ណា នីលវត្ថា នីលាលង្ការាតិ ។ អថខោ តា ទេវតា អាយស្មតោ អនុរុទ្ធស្ស ចិត្តមញ្ញាយ សព្វាវ នីលា អហេសុំ នីលវណ្ណា នីលវត្ថា នីលាលង្ការា ។ អថខោ អាយស្មតោ អនុរុទ្ធស្ស ឯតទហោសិ អហោ វតិមា ទេវតា សព្វាវ បីតា អស្សុ ។ បេ ។ សព្វាវ លោហិតកា អស្សុ សព្វាវ ឱទាតា អស្សុ ឱទាតវណ្ណា ឱទាតវត្ថា ឱទាតាលង្ការាតិ ។ អថខោ តា ទេវតា អាយស្មតោ អនុរុទ្ធស្ស ចិត្តមញ្ញាយ សព្វាវ ឱទាតា អហេសុំ ឱទាតវណ្ណា ឱទាតវត្ថា ឱទាតាលង្ការា ។ អថខោ តា ទេវតា ឯកាវ គាយិ ឯកាវ នច្ចិ ឯកាវ អច្ឆរិកំ វាទេសិ ។ សេយ្យថាបិ នាម បញ្ចង្គិកស្ស តុរិយស្ស សុវិនីតស្ស សុប្បដិប្បតាឡិតស្ស កុសលេហិ សុសមន្នាហតស្ស សទ្ទោ ហោតិ វគ្គុ ច រជនីយោ ច កមនីយោ[១] ច បេមនីយោ ច រមណីយោ[២] ច

១ ឱ. ខមនីយោតិបិ បាឋោ ។ ២ ឱ. ម. មទនិយោ ច ។

លំដាប់នោះ ព្រះអនុរុទ្ធដ៏មានអាយុ មានសេចក្ដីត្រិះរិះថា ធ្វើដូចម្ដេចហ្ន៎ នឹងបានទេវតាទាំងនោះ ទៅជាខៀវទាំងអស់ គឺមានសម្បុរ ក៏ខៀវ មានសំពត់ ក៏ខៀវ មានគ្រឿងអលង្ការ ក៏ខៀវ ។ វេលានោះ ទេវតាទាំងនោះ បានដឹងចិត្តនៃព្រះអនុរុទ្ធដ៏មានអាយុ ហើយក៏ទៅជាខៀវទាំងអស់ គឺមានសម្បុរ ក៏ខៀវ មានសំពត់ ក៏ខៀវ មានគ្រឿងអលង្ការ ក៏ខៀវ ។ លំដាប់នោះ ព្រះអនុរុទ្ធដ៏មានអាយុ មានសេចក្ដីត្រិះរិះដូច្នេះថា ធ្វើដូចម្ដេចហ្ន៎ នឹងបានទេវតាទាំងនោះ ទៅជាលឿងទាំងអស់ ។ បេ ។ ទៅជាក្រហមទាំងអស់ ទៅជាសទាំងអស់ គឺមានសម្បុរ ក៏ស មានសំពត់ ក៏ស មានគ្រឿងអលង្ការ ក៏ស ។ វេលានោះ ទេវតាទាំងនោះ បានដឹងចិត្តនៃព្រះអនុរុទ្ធដ៏មានអាយុហើយ ក៏ទៅជាស ទាំងអស់ គឺមានសម្បុរ ក៏ស មានសំពត់ ក៏ស មានគ្រឿងអលង្ការ ក៏ស ។ លំដាប់នោះ ទេវតាទាំងនោះ ១ អង្គច្រៀង ១ អង្គរាំ ១ អង្គទះដៃ ។ ប្រៀបដូចតូរ្យតន្ត្រីប្រកបដោយអង្គ ៥ ដែលបុគ្គលអ្នកឈ្លាសវៃ បានសិក្សាស្ទាត់ ប្រគំដោយប្រពៃ ដេញដំដោយប្រពៃ មានសំឡេងពីរោះផង គួរត្រេកអរផង គួរប្រាថ្នាផង គួរស្រឡាញ់ផង គួររីករាយផង យ៉ាងណាមិញ

ឯវមេវ តាសំ ទេវតានំ អលង្ការានំ សទ្ទោ ហោតិ វគ្គុ ច រជនីយោ ច កាមនីយោ ច បេមនីយោ ច រមណីយោ ច ។ អថខោ អាយស្មា អនុរុទ្ធោ ឥន្ទ្រិយានិ ឱក្ខិបិ ។ អថខោ តា ទេវតា ន ខ្វយ្យោ អនុរុទ្ធោ សាទិយតីតិ តត្ថេវ អន្តរធាយឹសុ ។ អថខោ អាយស្មា អនុរុទ្ធោ សាយណ្ហសមយំ បដិសល្លានា វុដ្ឋិតោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អនុរុទ្ធោ ភគវន្តំ ឯតទវោច ឥធាហំ ភន្តេ ទិវាវិហារំ គតោ ហោមិ បដិសល្លីនោ ។ អថខោ ភន្តេ សម្ពហុលា មនាបកាយិកា ទេវតា យេនាហំ តេនុបសង្កមឹសុ ឧបសង្កមិត្វា មំ អភិវាទេត្វា ឯកមន្តំ អដ្ឋំសុ ។ ឯកមន្តំ ឋិតា ខោ ភន្តេ តា ទេវតា មំ ឯតទវោចុំ មយំ ភន្តេ អនុរុទ្ធ មនាបកាយិកា នាម ទេវតា តីសុ ឋានេសុ ឥស្សរិយំ ការេម វសំ វត្តេម

សំឡេងនៃគ្រឿងអលង្ការ របស់ពួកទេវតាទាំងនោះ ពីរោះផង គួរត្រេកអរផង គួរប្រាថ្នាផង គួរស្រឡាញ់ផង គួររីករាយផង ក៏យ៉ាងនោះដែរ ។ គ្រានោះ ព្រះអនុរុទ្ធដ៏មានអាយុ ដាក់ចុះនូវឥន្ទ្រិយទាំងឡាយ គឺធ្វើព្រងើយ ។ លំដាប់នោះ ទេវតាទាំងនោះដឹងថា ព្រះអនុរុទ្ធជាម្ចាស់មិនត្រេកអរហើយបាត់ក្នុងទីនោះទៅ ។ គ្រានោះ ព្រះអនុរុទ្ធដ៏មានអាយុចេញចាកទីសម្ងំនៅ ក្នុងសាយណ្ហសម័យ ហើយចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអនុរុទ្ធដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងទីឯណោះ ខ្ញុំព្រះអង្គចូលទៅកាន់ទីនៅ ក្នុងវេលាថ្ងៃ ហើយសម្ងំនៅ ។ បពិត្រព្រះអង្គដ៏ចម្រើន លំដាប់នោះ ពួកទេវតា ឈ្មោះ មនាបកាយិកាជាច្រើនអង្គ ចូលទៅរកខ្ញុំព្រះអង្គ លុះចូលទៅដល់ ថ្វាយបង្គំខ្ញុំព្រះអង្គ ហើយឋិតនៅក្នុងទីសមគួរ ។ បពិត្រព្រះអង្គដ៏ចម្រើន លុះទេវតាទាំងនោះ ឋិតនៅក្នុងទីសមគួរហើយ ក៏ពោលទៅនឹងខ្ញុំព្រះអង្គដូច្នេះថា បពិត្រព្រះអង្គដ៏ច្រើន យើងខ្ញុំជាពួកទេវតាឈ្មោះមនាបកា-យិកា ធ្វើនូវឥស្សរិយភាពញុំាំងអំណាចឲ្យប្រព្រឹត្តទៅក្នុងហេតុ ៣ យ៉ាង

២១៣

បណ្ណាសកេ ឧបោសថវគ្គោ

មយំ ភន្តេ អនុរុទ្ធ យាវតិសកំ វណ្ណំ អាកង្ខាម តាវតិសកំ វណ្ណំ ឋានសោ បដិលភាម យាវតិសកំ សទ្ទំ អាកង្ខាម តាវតិសកំ សទ្ទំ ឋានសោ បដិលភាម យាវតិសកំ សុខំ អាកង្ខាម តាវតិសកំ សុខំ ឋានសោ បដិលភាម មយំ ភន្តេ អនុរុទ្ធ មនាបកាយិកា នាម ទេវតា ឥមេសុ តីសុ ឋានេសុ ឥស្សរិយំ ការេម វសំ វត្តេមាតិ ។ តស្ស មយ្ហំ ភន្តេ ឯតទហោសិ អហោ វតិមា ទេវតា សព្វាវ នីលា អស្សុ នីលវណ្ណា នីលវត្ថា នីលាលង្ការាតិ ។ អថខោ ភន្តេ តា ទេវតា មម ចិត្តមញ្ញាយ សព្វាវ នីលា អហេសុំ នីលវណ្ណា នីលវត្ថា នីលាលង្ការា តស្ស មយ្ហំ ភន្តេ ឯតទហោសិ អហោ វតិមា ទេវតា សព្វាវ បីតា អស្សុ ។ បេ ។ សព្វាវ លោហិតកា អស្សុ ។ បេ ។ សព្វាវ ឱទាតា អស្សុ ឱទាតវណ្ណា ឱទាតវត្ថា ឱទាតាលង្ការាតិ ។

បពិត្រព្រះអនុរុទ្ធដ៏ចម្រើន យើងខ្ញុំប្រាថ្នានូវវណ្ណៈបែបណា ក៏បាននូវវណ្ណៈបែបនោះមួយរំពេច ១ ប្រាថ្នានូវសំឡេងបែបណា ក៏បាននូវសំឡេងបែបនោះមួយរំពេច ១ ប្រាថ្នានូវសុខបែបណា ក៏បាននូវសុខបែបនោះមួយរំពេច ១ បពិត្រព្រះអនុរុទ្ធដ៏ចម្រើន យើងខ្ញុំជាពួកទេវតា ឈ្មោះមនាបកាយិកា ធ្វើនូវឥស្សរិយភាព ញុំាងអំណាចឲ្យប្រព្រឹត្តទៅក្នុងហេតុទាំង ៣ នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះដូច្នេះថា ធ្វើដូចម្តេចហ្ន៎ នឹងបានទេវតាទាំងនេះ ទៅជាខៀវទាំងអស់ គឺមានសម្បុរ ក៏ខៀវ មានសំពត់ ក៏ខៀវ មានគ្រឿងអលង្ការ ក៏ខៀវ ។ បពិត្រព្រះអង្គដ៏ចម្រើន វេលានោះ ទេវតាទាំងនោះ បានដឹងចិត្តខ្ញុំព្រះអង្គហើយ ក៏ទៅជាខៀវទាំងអស់គឺ មានសម្បុរ ក៏ខៀវ មានសំពត់ ក៏ខៀវ មានគ្រឿងអលង្ការ ក៏ខៀវ បពិត្រព្រះអង្គដ៏ច្រើន ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះដូច្នេះថា ធ្វើដូចម្តេចហ្ន៎ នឹងបានទេវតាទាំងនេះ ទៅជាលឿងទាំងអស់ ។ បេ ។ ទៅជាក្រហមទាំងអស់ ។ បេ ។ ទៅជាសទាំងអស់ គឺមានសម្បុរ ក៏ស មានសំពត់ ក៏ស មានគ្រឿងអលង្ការ ក៏ស ។

អថខោ ភន្តេ តា ទេវតា មម ចិត្តមញ្ញាយ សព្វាវ ឱទាតា អហេសុំ ឱទាតវណ្ណា ឱទាតវត្ថា ឱទាតាលង្ការា ។ អថខោ ភន្តេ តា ទេវតា ឯកាវ គាយិ ឯកាវ នច្ចិ ឯកាវ អច្ឆរិកំ វាទេសិ ។ សេយ្យថាបិ នាម បញ្ចង្គិកស្ស តុរិយស្ស សុវិនីតស្ស សុប្បដិប្បតាឡិតស្ស កុសលេហិ សុសមន្នាហតស្ស សទ្ទោ ហោតិ វគ្គុ ច រជនីយោ ច កមនីយោ ច បេមនីយោ ច រមណីយោ ច ឯវមេវ តាសំ ទេវតានំ អលង្ការានំ សទ្ទោ ហោតិ វគ្គុ ច រជនីយោ ច កមនីយោ ច បេមនីយោ ច រមណីយោ ច ។ អថខោហំ ភន្តេ ឥន្ទ្រិយានិ ឱក្ខិបឹ ។ អថខោ ភន្តេ តា ទេវតា ន ខ្វយ្យោ អនុរុទ្ធោ សាទិយតីតិ តត្ថេវ អន្តរធាយឹសុ ។ កតីហិ នុ ខោ ភន្តេ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរម្មរណា មនាបកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។

បពិត្រព្រះអង្គដ៏ចម្រើន លុះទេវតាទាំងនោះ បានដឹងចិត្តខ្ញុំព្រះអង្គហើយ ក៏ទៅជាសទាំងអស់ គឺមានសម្បុរ ក៏ស មានសំពត់ ក៏ស មានគ្រឿងអលង្ការ ក៏ស ។ បពិត្រព្រះអង្គដ៏ចម្រើន វេលានោះ ទេវតាទាំងនោះ ១ អង្គច្រៀង ១ អង្គរាំ ១ អង្គទះដៃ ។ ប្រៀបដូចតូរ្យតន្ត្រី ប្រកបដោយអង្គ ៥ ដែលគេរៀបចំល្អហើយ បុគ្គលឈ្លាសវៃ បានប្រគំដោយប្រពៃ បានដេញដំដោយប្រពៃ មានសំឡេងពីរោះផង គួរត្រេកអរផង គួរប្រាថ្នាផង គួរស្រឡាញ់ផង គួររីករាយផង យ៉ាងណាមិញ សំឡេងគ្រឿងអលង្ការ របស់ទេវតាទាំងនោះ ក៏ពីរោះផង គួរត្រេកអរផង គួរប្រាថ្នាផង គួរស្រឡាញ់ផង គួររីករាយផង ក៏យ៉ាងនោះដែរ ។ បពិត្រព្រះអង្គដ៏ចម្រើន ឯខ្ញុំព្រះអង្គ ក៏ដាក់ចុះនូវឥន្ទ្រិយទាំងឡាយ គឺធ្វើព្រងើយ ។ បពិត្រព្រះអង្គដ៏ចម្រើន វេលានោះ ទេវតាទាំងនោះ គិតគ្នាថា ព្រះអនុរុទ្ធជាម្ចាស់ មិនត្រេកអរហើយ ក៏បាត់ក្នុងទីនោះទៅ បពិត្រព្រះអង្គដ៏ចម្រើន ចុះមាតុគ្រាម ប្រកបដោយធម៌ប៉ុន្មានយ៉ាង លុះបែកធ្លាយរាងកាយស្លាប់ទៅ បានទៅកើតជាមួយនឹងពួកទេវតាឈ្មោះមនាបកាយិកា ។

អដ្ឋហិ ខោ អនុរុទ្ធ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរម្មរណា មនាបកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ កតមេហិ អដ្ឋហិ ។ ឥធ អនុរុទ្ធ មាតុគ្គាមោ យស្ស មាតាបិតរោ ភត្តុនោ ទេន្តិ អត្ថកាមា ហិតេសិនោ អនុកម្បកា អនុកម្បំ ឧបាទាយ តស្ស ហោតិ បុព្វុដ្ឋាយិនី បច្ឆានិបាតិនី កឹការប្បដិស្សាវិនី មនាបចារិនី បិយវាទិនី យេ ភត្តុ គរុនោ ហោន្តិ មាតាតិ វា បិតាតិ វា សមណព្រាហ្មណាតិ វា តេ សក្ករោតិ គរុករោតិ មានេតិ បូជេតិ អព្ភាគតេ ច អាសនោទកេន បដិបូជេតិ យេ តេ ភត្តុ អព្ភន្តរា កម្មន្តា ឧណ្ណាតិ វា កប្បាសាតិ វា តត្ថ ទក្ខា ហោតិ អនលសា តត្រុបាយាយ វីមំសាយ សមន្នាគតា អលំ កាតុំ អលំ សំវិធាតុំ យេ តេ ភត្តុ អព្ភន្តរា អន្តោជនា ទាសាតិ វា បេស្សាតិ វា កម្មករាតិ វា តេសំ កតញ្ច កតតោ ជានាតិ អកតញ្ច អកតតោ ជានាតិ

ព្រះអង្គត្រាស់ថា ម្នាលអនុរុទ្ធ មាតុគ្រាមប្រកបដោយធម៌ ៨ ប្រការ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកទេវតាឈ្មោះមនាបកាយិកា ។ ប្រកបដោយធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលអនុរុទ្ធ មាតុគ្រាម ក្នុងលោកនេះ ដែលមាតាបិតា ប្រាថ្នាសេចក្តីចម្រើន ស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវសេចក្តីអនុគ្រោះ បានរៀបចំឲ្យដល់ស្វាមីណាហើយ ជាស្រីក្រោកមុន ដេកក្រោយ ទទួលស្តាប់កិច្ចការអ្វីៗ ប្រព្រឹត្តនូវអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ចំពោះស្វាមីនោះ ១ ពួកជនណាជាទីគោរព របស់ស្វាមី ទោះមាតាក្តី បិតាក្តី សមណព្រាហ្មណ៍ក្តី មាតុគ្រាម តែងធ្វើសក្ការៈ គោរព រាប់អាន បូជាចំពោះជនទាំងនោះផង តែងបូជាពួកជន ដែលទើបមកដល់ថ្មី ដោយអាសនៈនិងទឹកផង ១ ការងារទាំងឡាយណា ជាបន្ទុករបស់ស្វាមី ទោះជារោមសត្វក្តី កប្បាសក្តី ជាស្រីប៉ិនប្រសប់ក្នុងការងារទាំងនោះ មិនខ្ជិលច្រអូសប្រកបដោយការពិចារណា ដោយឧបាយក្នុងកិច្ចទាំងនោះ ថា គួរធ្វើ គួរចាត់ចែង ១ ពួកជនណានៅខាងក្នុង ជាបន្ទុករបស់ស្វាមី ទោះជាខ្ញុំក្តី ជាអ្នកបម្រើក្តី ជាកម្មករក្តី មាតុគ្រាម តែងដឹងនូវអំពើដែលជនទាំងនោះធ្វើថា ធ្វើ ដឹងនូវអំពើដែលជនទាំងនោះមិនបានធ្វើថា មិនបានធ្វើ

គិលានកានញ្ច ពលាពលំ ជានាតិ ខាទនីយភោជនីយញ្ចស្ស បច្ចយំសេន សំវិភជតិ យំ ភត្តា អាហរតិ ធនំ វា ធញ្ញំ វា រជតំ វា ជាតរូបំ វា តំ អារក្ខេន គុត្តិយា សម្បាទេតិ តត្ថ ច ហោតិ អធុត្តី អថេនី អសោណ្ឌី អវិនាសិកា ឧបាសិកា ខោ បន ហោតិ ពុទ្ធំ សរណំ គតា ធម្មំ សរណំ គតា សង្ឃំ សរណំ គតា សីលវតី ខោ បន ហោតិ បាណាតិបាតា បដិវិរតា អទិន្នាទានា បដិវិរតា កាមេសុ មិច្ឆាចារា បដិវិរតា មុសាវាទា បដិវិរតា សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតា ចាគវតី ខោ បន ហោតិ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ មុត្តចាគី បយតបាណី វោស្សគ្គរតា យាចយោគា ទានសំវិភាគរតា ។ ឥមេហិ ខោ អនុរុទ្ធ អដ្ឋហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរម្មរណា មនាបកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។

ដឹងនូវកម្លាំងតិចនិងកម្លាំងច្រើនរបស់អ្នកឈឺ ទាំងចេះចាត់ចែងនូវខាទ-នីយភោជនីយាហារ តាមចំណែកដែលគួរដល់ជនជាខាងក្នុងបន្ទុកនោះ ១ ស្វាមីបាននាំមក នូវទ្រព្យណាក្តី ស្រូវណាក្តី ប្រាក់ណាក្តី មាសណាក្តី មាតុគ្រាមនោះ តែងសម្រេចដោយការរក្សា គ្រប់គ្រងនូវទ្រព្យជាដើមនោះ និងជាអ្នកមិនលេង មិនលួច មិនខិលខូច មិនធ្វើសម្បត្តិទាំងនោះឲ្យវិនាស ១ ជាឧបាសិកាដល់នូវព្រះពុទ្ធជាទីពឹង ដល់នូវព្រះធម៌ជាទីពឹង ដល់នូវព្រះសង្ឃជាទីពឹង ១ ជាស្ត្រីមានសីល វៀរចាកបាណាតិបាត វៀរចាកអទិន្នាទាន វៀរចាកកាមេសុមិច្ឆាចារ វៀរចាកមុសាវាទ វៀរចាកការផឹកទឹកស្រវឹងគឺសុរានិងមេរ័យ ដែលជាទីតាំងនៃសេចក្តីប្រមាទ ១ ជាស្ត្រីមានចាគៈ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ គួរដល់ពួកស្មូម ត្រេកអរក្នុងការចែករលែកនូវទាន ១ ។ ម្នាលអនុរុទ្ធ មាតុគ្រាម ប្រកបដោយធម៌ទាំង ៨ នេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅតែងទៅកើតជាមួយនឹងពួកទេវតាឈ្មោះមនាបកាយិកា ។

យោ នំ ភរតិ សព្វទា និច្ចំ អាតាបិ ឧស្សុកោ
តំ សព្វកាមហរំ ចោសំ ភត្តារំ នាតិមញ្ញតិ
ន ចាបិ សោត្ថិ ភត្តារំ ឥស្សាវាទេន រោសយេ
ភត្តុញ្ច គរុនោ សព្វេ បដិបូជេតិ បណ្ឌិតា
ឧដ្ឋាហិកា អនលសា សង្គហិតបរិជ្ជនា
ភត្តុ មនាបញ្ចរតិ សម្ភតំ អនុរក្ខតិ
យា ឯវំ វត្តតិ នារី ភត្តុ ឆន្ទវសានុគា
មនាបា នាម តេ ទេវា យត្ថ សា ឧបបជ្ជតីតិ ។

[៤៧] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុប្បាសាទេ ។ អថខោ វិសាខា មិគារមាតា ។ បេ ។ ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ វិសាខំ មិគារមាតរំ ភគវា ឯតទវោច អដ្ឋហិ ខោ វិសាខេ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរម្មរណា មនាបកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។

មាតុគ្រាមណា មានព្យាយាម ខ្វល់ខ្វាយចិញ្ចឹមស្វាមីនោះ សព្វកាលជានិច្ច មិនមើលងាយបុរសជាស្វាមី ដែលនាំមកនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងនោះ ជាស្រ្តីល្អមិនធ្វើស្វាមីឲ្យក្តៅក្រហាយ ដោយពាក្យប្រចណ្ឌ ជាស្រ្តីមានបញ្ញា តែងបូជាស្វាមីនិងបុគ្គល ដែលជាទីគោរពទាំងអស់ ជាស្រ្តីមានសេចក្តីខ្នះខ្នែង មិនខ្ជិលច្រអូស សង្គ្រោះជនជាបរិសទ្យ តែងប្រព្រឹត្តនូវអំពើ ជាទីគាប់ចិត្តនៃស្វាមី ថែទាំសម្បត្តិដែលស្វាមីរកបានមក នារីណា ជាស្រ្តីលុះ ក្នុងអំណាចសេចក្តីប្រាថ្នារបស់ស្វាមី ហើយប្រព្រឹត្តយ៉ាងនេះ នារីនោះ រមែងទៅកើតក្នុងពួកទេវតាឈ្មោះមនាបកាយិកា ។

[៤៧] សម័យមួយ ព្រះដ៏មានព្រះភាគកាលគង់នៅក្នុងមិគារមាតុ-ប្រាសាទ ក្នុងវត្តបុព្វារាម ជិតក្រុងសាវត្ថី ។ គ្រានោះ នាងវិសាខាមិគារមាតា ។ បេ ។ អង្គុយក្នុងទីសមគួរ ។ លុះនាងវិសាខាមិគារមាតាអង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលនាងវិសាខា មាតុគ្រាមប្រកបដោយធម៌ ៨ ប្រការ លុះបែកធ្លាយរាងកាយ ស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកទេវតាមនាបកាយិកា ។

កតមេហិ អដ្ឋហិ ។ ឥធ វិសាខេ មាតុគ្គាមោ យស្ស មាតាបិតរោ ភត្តុនោ ទេន្តិ អត្ថកាមា ហិតេសិនោ អនុកម្បកា អនុកម្បំ ឧបាទាយ តស្ស ហោតិ បុព្វុដ្ឋាយិនី បច្ឆានិបាតិនី កឹការបដិស្សាវិនី មនាបចារិនី បិយវាទិនី ។ បេ ។ ចាគវតី ខោ បន ហោតិ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ មុត្តចាគី បយតបាណី វោស្សគ្គរតា យាចយោគា ទានសំវិភាគរតា ។ ឥមេហិ ខោ វិសាខេ អដ្ឋហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរម្មរណា មនាបកាយិកានំ ទេវានំ សហាព្យតំ ឧបបជ្ជតីតិ ។

យោ នំ ភរតិ សព្វទា និច្ចំ អាតាបិ ឧស្សុកោ
តំ សព្វកាមហរំ បោសំ ភត្តារំ នាតិមញ្ញតិ
ន ចាបិ សោត្ថិ ភត្តារំ ឥស្សាវាទេន រោសយេ
ភត្តុញ្ច គរុនោ សព្វេ បដិបូជេតិ បណ្ឌិតា
ឧដ្ឋាហិកា អនលសា សង្គហិតបរិជ្ជនា

ប្រកបដោយធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលនាងវិសាខា មាតុគ្រាម ក្នុងលោកនេះ ដែលមាតាបិតា មានប្រាថ្នាសេចក្តីចម្រើន ស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវសេចក្តីអនុគ្រោះ បានរៀបចំឲ្យដល់ស្វាមីណាហើយ ជាស្ត្រីក្រោកមុន ដេកក្រោយ ទទួលស្តាប់កិច្ចការអ្វីៗ ប្រព្រឹត្តនូវអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ ចំពោះស្វាមីនោះ ១ ។ បេ ។ ជាស្ត្រីមានចាគៈ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ គួរដល់ពួកស្មូម ត្រេកអរក្នុងការចែករំលែកនូវទាន ១ ។ ម្នាលនាងវិសាខា មាតុគ្រាមប្រកបដោយធម៌ ៨ ប្រការនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ រមែងទៅកើតជាមួយនឹងពួកទេវតាមនាបកាយិកា ។

មាតុគ្រាមណា មានព្យាយាម ខ្វល់ខ្វាយចិញ្ចឹមស្វាមីនោះ
សព្វកាល ជានិច្ច មិនមើលងាយបុរស ជាស្វាមី ដែលនាំ
មកនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងនោះ ជាស្ត្រីល្អ មិនបានធ្វើ
ស្វាមីឲ្យក្តៅក្រហាយ ដោយពាក្យច្រណែន ជាស្ត្រីមានបញ្ញា
តែងបូជាស្វាមីនិងបុគ្គល ដែលជាទីគោរពទាំងអស់ ជាស្ត្រី
មានសេចក្តីខ្នះខ្នែង មិនខ្ជិលច្រអូស សង្គ្រោះជនជាបរិសទ្យ

ភត្តុ មនាបញ្ចរតិ សម្ភតំ អនុរក្ខតិ
យា ឯវំ វត្តតិ នារី ភត្តុ ឆន្ទវសានុគា
មនាបា នាម តេ ទេវា យត្ថ សា ឧបបជ្ជតីតិ ។

[៤៨] ឯកំ សមយំ ភគវា ភគ្គេសុ វិហរតិ សុំសុមារគិរេ ភេសកឡាវនេ មិគទាយេ ។ អថខោ នកុលមាតា គហបតានី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ។ បេ ។ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ នកុលមាតរំ គហបតានឹ ភគវា ឯតទវោច អដ្ឋហិ ខោ នកុលមាតេ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរម្មរណា មនាបកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជតិ ។ កតមេហិ អដ្ឋហិ ។ ឥធ នកុលមាតេ មាតុគ្គាមោ យស្ស មាតាបិតរោ ភត្តុនោ ទេន្តិ អត្ថកាមា ហិតេសិនោ អនុកម្បកា អនុកម្បំ ឧបាទាយ តស្ស ហោតិ បុព្វុដ្ឋាយិនី បច្ឆានិបាតិនី កឹការប្បដិស្សាវិនី មនាបចារិនី បិយវាទិនី ។ បេ ។ ចាគវតី

តែងប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តនៃស្វាមី ថែទាំសម្បត្តិ ដែលស្វាមីរកបានមក នារីណា ជាស្ត្រី លុះក្នុងអំណាចសេចក្តីប្រាថ្នារបស់ស្វាមី ប្រព្រឹត្តយ៉ាងនេះ នារីនោះ រមែងទៅកើតក្នុងពួកទេវតា ឈ្មោះមនាបកាយិកា ។

[៤៨] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងភេសកឡាវ័ន ជាទីឲ្យអភ័យដល់សត្វម្រឹគ ទៀបក្រុងសុំសុមារគិរៈ ក្នុងដែនភគ្គៈ ។ គ្រានោះ នកុលមាតាគហបតានី (នាងគហបតានីឈ្មោះនកុលមាតា) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ។ បេ ។ ក៏អង្គុយនៅ ។ លុះនកុលមាតាគហបតានី អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ដូច្នេះថា ម្នាលនកុលមាតា មាតុគ្រាមប្រកបដោយធម៌ ៨ ប្រការ លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាមួយនឹងពួកទេវតាមនាបកាយិកា ។ ប្រកបដោយធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលនកុលមាតា មាតុគ្រាមក្នុងលោកនេះ ដែលមាតាបិតា មានប្រាថ្នាសេចក្តីចម្រើន ស្វែងរកប្រយោជន៍ ជាអ្នកអនុគ្រោះ អាស្រ័យនូវសេចក្តីអនុគ្រោះ បានរៀបចំឲ្យដល់ស្វាមីណាហើយ ជាស្ត្រីក្រោកមុន ដេកក្រោយ ទទួលស្តាប់កិច្ចការអ្វីៗ ប្រព្រឹត្តនូវអំពើជាទីគាប់ចិត្ត ពោលពាក្យជាទីស្រឡាញ់ ចំពោះស្វាមីនោះ ១ ។ បេ ។ ជាស្ត្រីមានចាគៈ

ខោ បន ហោតិ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ មុត្តចាគី បយតបាណី វោស្សគ្គរតា យាចយោគា ទានសំវិភាគរតា ។ ឥមេហិ ខោ នកុលមាតេ អដ្ឋហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ កាយស្ស ភេទា បរម្មរណា មនាបកាយិកានំ ទេវានំ សហព្យតំ ឧបបជ្ជតីតិ ។

យោ នំ ភរតិ សព្វទា និច្ចំ អាតាបិ ឧស្សុកោ
តំ សព្វកាមហរំ បោសំ ភត្តារំ នាតិមញ្ញតិ
ន ចាបិ សោត្ថិ ភត្តារំ ឥស្សាវាទេន រោសយេ
ភត្តុញ្ច គរុនោ សព្វេ បដិបូជេតិ បណ្ឌិតា
ឧដ្ឋាហិកា អនលសា សង្គហិតបរិជ្ជនា
ភត្តុ មនាបញ្ចរតិ សម្ភតំ អនុរក្ខតិ
យា ឯវំ វត្តតិ នារី ភត្តុ ឆន្ទវសានុគា
មនាបា នាម តេ ទេវា យត្ថ សា ឧបបជ្ជតីតិ ។

[៤៩] ឯកំ សមយំ ភគវា សាវត្ថិយំ វិហរតិ បុព្វារាមេ មិគារមាតុបាសាទេ ។ អថខោ វិសាខា

មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មានទាន បរិច្ចាគស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ គួរដល់ពួកស្មូម ត្រេកអរក្នុងការចែករលែកនូវទាន ១ ។ ម្នាលនកុលមាតា មាតុគ្រាម ប្រកបដោយធម៌ ៨ ប្រការនេះឯង លុះបែកធ្លាយរាងកាយស្លាប់ទៅ តែងទៅកើតជាមួយនឹងពួកទេវតាមនាបកាយិកា ។

មាតុគ្រាមណា មានព្យាយាម ខ្វល់ខ្វាយចិញ្ចឹមស្វាមីនោះ
សព្វកាលជានិច្ច មិនមើលងាយបុរសជាស្វាមី ដែលនាំមកនូវ
សេចក្តីប្រាថ្នាគ្រប់យ៉ាងនោះ ជាស្ត្រីល្អ មិនបានធ្វើស្វាមីឲ្យ
ក្តៅក្រហាយ ដោយពាក្យច្រណែន ជាស្ត្រីមានបញ្ញា តែង
បូជាស្វាមីនិងបុគ្គល ដែលជាទីគោរពទាំងអស់ ជាស្ត្រីមាន
សេចក្តីខ្នះខ្នែង មិនខ្ជិលច្រអូស សង្គ្រោះជនជាបរិសទ្យ
ប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តនៃស្វាមី ថែទាំសម្បត្តិដែលស្វាមី
រកបានមក នារីណា ជាស្ត្រីលុះ ក្នុងអំណាចសេចក្តីប្រាថ្នា
របស់ស្វាមី ប្រព្រឹត្តយ៉ាងនេះ នារីនោះ រមែងទៅកើតក្នុងពួក
ទេវតាឈ្មោះមនាបកាយិកា ។

[៤៩] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងវត្តបុព្វារាម ជាប្រាសាទរបស់មិគារមាតា ជិតក្រុងសាវត្ថី ។ គ្រានោះ នាងវិសាខា

២២១



មិគារមាតា យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ។ បេ ។ និសីទិ ។ ឯកមន្តំ និសិន្នំ ខោ វិសាខំ មិគារមាតរំ ភគវា ឯតទវោច ចតូហិ ខោ វិសាខេ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ ឥធលោកវិជយាយ បដិបន្នោ ហោតិ អយំស លោកោ អារទ្ធោ ហោតិ ។ កតមេហិ ចតូហិ ។ ឥធ វិសាខេ មាតុគ្គាមោ សុសំវិហិតកម្មន្តោ ហោតិ សង្គហិតបរិជនោ ភត្តុ មនាបំ ចរតិ សម្ភតំ អនុរក្ខតិ ។ កថញ្ច វិសាខេ មាតុគ្គាមោ សុសំវិហិតកម្មន្តោ ហោតិ ។ ឥធ វិសាខេ មាតុគ្គាមោ យេ តេ ភត្តុ អព្ភន្តរា កម្មន្តា ឧណ្ណាតិ វា កប្បាសាតិ វា តត្ថ ទក្ខា ហោតិ អនលសា តត្រុបាយាយ វីមំសាយ សមន្នាគតា អលំ កាតុំ អលំ សំវិធាតុំ ។ ឯវំ ខោ វិសាខេ មាតុគ្គាមោ សុសំវិហិតកម្មន្តោ ហោតិ ។ កថញ្ច វិសាខេ មាតុគ្គាមោ សង្គហិតបរិជនោ ហោតិ ។ ឥធ វិសាខេ មាតុគ្គាមោ យេ តេ ភត្តុ អព្ភន្តរា អន្តោជនា ទាសាតិ វា

មិគារមាតា ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ។ បេ ។ ក៏អង្គុយនៅ ។ លុះនាងវិសាខាមិគារមាតា អង្គុយក្នុងទីសមគួរហើយ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ដូច្នេះថា ម្នាលវិសាខា មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការ ឈ្មោះថាប្រតិបត្តិ ដើម្បីឈ្នះនូវលោកនេះ លោកនេះ ក៏ឈ្មោះថា មាតុគ្រាមនោះ ប្រារព្ធហើយ ។ ប្រកបដោយធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលវិសាខា មាតុគ្រាម ក្នុងលោកនេះ ជាស្ត្រីចេះចាត់ចែងការងារ ដោយប្រពៃ ១ ចេះសង្គ្រោះពួកជនជាបរិសទ្យ ១ ចេះប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តរបស់ស្វាមី ១ ចេះថែទាំសម្បត្តិដែលស្វាមីរកបានមក ១ ។ ម្នាលវិសាខា ចុះមាតុគ្រាម ជាស្ត្រីចេះចាត់ចែងការងារដោយប្រពៃ តើដូចម្តេច ។ ម្នាលវិសាខា មាតុគ្រាមក្នុងលោកនេះ ការទាំងឡាយណា ជាបន្ទុករបស់ស្វាមី ទោះរោមសត្វក្តី កប្បាសក្តី ជាស្ត្រីឆ្លៀវឆ្លាស មិនខ្ជិលច្រអូស ក្នុងការងារទាំងនោះ ប្រកបដោយការពិចារណា ដោយឧបាយក្នុងការងារនោះថា គួរធ្វើ គួរចាត់ចែង ។ ម្នាលវិសាខា មាតុគ្រាម ជាស្ត្រីចេះចាត់ចែងការងារ ដោយប្រពៃយ៉ាងនេះឯង ។ ម្នាលវិសាខា ចុះមាតុគ្រាម ជាស្ត្រីចេះសង្គ្រោះពួកជនជាបរិសទ្យ តើដូចម្តេច ។ ម្នាលវិសាខា មាតុគ្រាម ក្នុងលោកនេះ ពួកជនណា ជាខាងក្នុង ជាបន្ទុករបស់ស្វាមី ទោះខ្ញុំក្តី

បេស្សាតិ វា កម្មការាតិ វា តេសំ កតញ្ច កតតោ ជានាតិ អកតញ្ច អកតតោ ជានាតិ គិលានកានញ្ច ពលាពលំ ជានាតិ ខាទនីយភោជនីយញ្ចស្ស បច្ចយំសេន សំវិភជតិ ។ ឯវំ ខោ វិសាខេ មាតុគ្គាមោ សង្គហិតបរិជនោ ហោតិ ។ កថញ្ច វិសាខេ មាតុគ្គាមោ ភត្តុ មនាបំ ចរតិ ។ ឥធ វិសាខេ មាតុគ្គាមោ យំ ភត្តុ អមនាបសង្ខាតំ តំ ជីវិតហេតុបិ ន អជ្ឈាចរតិ ។ ឯវំ ខោ វិសាខេ មាតុគ្គាមោ ភត្តុ មនាបំ ចរតិ ។ កថញ្ច វិសាខេ មាតុគ្គាមោ សម្ភតំ អនុរក្ខតិ ។ ឥធ វិសាខេ មាតុគ្គាមោ យំ ភត្តា អាហរតិ ធនំ វា ធញ្ញំ វា រជតំ វា ជាតរូបំ វា តំ អារក្ខេន គុត្តិយា សម្បាទេតិ តត្ថ ច ហោតិ អធុត្តី អត្ថេនី អសោណ្ឌី អវិនាសិកា ។ ឯវំ ខោ វិសាខេ មាតុគ្គាមោ សម្ភតំ អនុរក្ខតិ ។ ឥមេហិ ខោ វិសាខេ ចតូហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ

អ្នកបម្រើក្តី កម្មករក្តី តែងដឹងនូវអំពើដែលជនទាំងនោះធ្វើថា ធ្វើ ដឹងនូវអំពើដែលជនទាំងនោះ មិនបានធ្វើថា មិនបានធ្វើ ដឹងនូវកម្លាំងតិចនិងកម្លាំងច្រើននៃពួកជនអ្នកឈឺ ចេះចាត់ចែងខាទនីយភោជនីយាហារ តាមចំណែកដែលគួរដល់ពួកជនខាងក្នុងបន្ទុកនោះ ។ ម្នាលវិសាខា មាតុគ្រាមជាស្ត្រីចេះសង្គ្រោះពួកជន ជាបរិសទ្យយ៉ាងនេះឯង ។ ម្នាលវិសាខា ចុះមាតុគ្រាម ចេះប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តនៃស្វាមី តើដូចម្តេច ។ ម្នាលវិសាខា មាតុគ្រាម ក្នុងលោកនេះ អំពើណា មិនជាទីគាប់ចិត្តរបស់ស្វាមី បើទុកជា មានហេតុដល់ជីវិត ក៏មិនប្រព្រឹត្តកន្លងនូវអំពើនោះ ។ ម្នាលវិសាខា មាតុគ្រាម ចេះប្រព្រឹត្តអំពើ ជាទីគាប់ចិត្តនៃស្វាមីយ៉ាងនេះឯង ។ ម្នាលវិសាខា ចុះមាតុគ្រាម ចេះថែទាំសម្បត្តិ ដែលស្វាមីរកបានមក តើដូចម្តេច ។ ម្នាលវិសាខា ទ្រព្យណាក្តី ស្រូវណាក្តី ប្រាក់ណាក្តី មាសណាក្តី ដែលស្វាមីរកបានមក មាតុគ្រាម ក្នុងលោកនេះតែងសម្រេច ដោយការរក្សា គ្រប់គ្រងនូវទ្រព្យជាដើមនោះ ទាំងជាស្ត្រីអ្នកមិនលេង មិនលួច មិនខិលខូច មិនធ្វើសម្បត្តិទាំងនោះ ឲ្យវិនាស ។ ម្នាលវិសាខា មាតុគ្រាម ចេះថែទាំសម្បត្តិ ដែលស្វាមី រកបានមកយ៉ាងនេះឯង ។ ម្នាលវិសាខា មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការនេះឯង

ឥធលោកវិជយាយ បដិបន្នោ ហោតិ អយំស លោកោ អារទ្ធោ ហោតិ ។ ចតូហិ ខោ វិសាខេ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ បរលោកវិជយាយ បដិបន្នោ ហោតិ បរស្ស លោកោ អារទ្ធោ ហោតិ ។ កតមេហិ ចតូហិ ។ ឥធ វិសាខេ មាតុគ្គាមោ សទ្ធាសម្បន្នោ ហោតិ សីលសម្បន្នោ ហោតិ ចាគសម្បន្នោ ហោតិ បញ្ញាសម្បន្នោ ហោតិ ។ កថញ្ច វិសាខេ មាតុគ្គាមោ សទ្ធាសម្បន្នោ ហោតិ ។ ឥធ វិសាខេ មាតុគ្គាមោ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ វិជ្ជាចរណសម្បន្នោ សុគតោ លោកវិទូ អនុត្តរោ បុរិសទម្មសារថិ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ ។ ឯវំ ខោ វិសាខេ មាតុគ្គាមោ សទ្ធាសម្បន្នោ ហោតិ ។ កថញ្ច វិសាខេ មាតុគ្គាមោ សីសលម្បន្នោ ហោតិ ។ ឥធ វិសាខេ មាតុគ្គាមោ ចាណាតិចាតា បដិវិរតោ ហោតិ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ។

ឈ្មោះថាប្រតិបត្តិ ដើម្បីឈ្នះនូវលោកនេះ លោកនេះក៏ឈ្មោះថាមាតុគ្រាមនោះ បានប្រារព្ធហើយ ។ ម្នាលវិសាខា មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការ ឈ្មោះថាប្រតិបត្តិ ដើម្បីឈ្នះនូវលោកខាងមុខ លោកខាងមុខក៏ឈ្មោះថាមាតុគ្រាមនោះ បានប្រារព្ធហើយ ។ ប្រកបដោយធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលវិសាខា មាតុគ្រាម ក្នុងលោកនេះ បរិបូណ៌ដោយសទ្ធា ១ បរិបូណ៌ដោយសីល ១ បរិបូណ៌ដោយចាគៈ ១ បរិបូណ៌ដោយបញ្ញា ១ ។ ម្នាលវិសាខា ចុះមាតុគ្រាម បរិបូណ៌ដោយសទ្ធា តើដូចម្តេច ។ ម្នាលវិសាខា មាតុគ្រាម ក្នុងលោកនេះ ជាស្ត្រីមានសទ្ធា ជឿការត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ទ្រង់បរិបូណ៌ដោយវិជ្ជានិងចរណៈ ជាព្រះសុគត ជ្រាបច្បាស់នូវត្រៃលោក ទ្រង់ប្រសើរបំផុត ទ្រង់ទូន្មាននូវបុរស ដែលគួរទូន្មានបាន ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវអរិយសច្ច ៤ ទ្រង់ខ្ជាក់ចោលនូវត្រៃភព គឺលែងវិលត្រឡប់មកកើតទៀតហើយ ។ ម្នាលវិសាខា មាតុគ្រាម បរិបូណ៌ដោយសទ្ធាយ៉ាងនេះឯង ។ ម្នាលវិសាខា ចុះមាតុគ្រាម បរិបូណ៌ដោយសីល តើដូចម្តេច ។ ម្នាលវិសាខា មាតុ-គ្រាម ក្នុងលោកនេះ ជាស្ត្រីវៀរចាកបាណាតិបាត ។ បេ ។ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺ ផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ។

ឯវំ ខោ វិសាខេ មាតុគ្គាមោ សីលសម្បន្នោ ហោតិ ។ កថញ្ច វិសាខេ មាតុគ្គាមោ ចាគសម្បន្នោ ហោតិ ។ ឥធ វិសាខេ មាតុគ្គាមោ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ មុត្តច្ចាគី បយតបាណី វោស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោ ។ ឯវំ ខោ វិសាខេ មាតុគ្គាមោ ចាគសម្បន្នោ ហោតិ ។ កថញ្ច វិសាខេ មាតុគ្គាមោ បញ្ញាសម្បន្នោ ហោតិ ។ ឥធ វិសាខេ មាតុគ្គាមោ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយ-គាមិនិយា ។ ឯវំ ខោ វិសាខេ មាតុគ្គាមោ បញ្ញាស-ម្បន្នោ ហោតិ ។ ឥមេហិ ខោ វិសាខេ ចតូហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ បរលោកវិជយាយ បដិបន្នោ ហោតិ បរស្ស លោកោ អារទ្ធោ ហោតីតិ ។

សុសំវិហិតកម្មន្តោ សង្គហិតបរិជ្ជនោ
ភត្តុ មនាបំ ចរតិ សម្ភតំ អនុរក្ខតិ
សទ្ធាសីលេន សម្បន្នោ វទញ្ញូ វីតមច្ឆរោ

ម្នាលវិសាខា មាតុគ្រាម បរិបូណ៌ដោយសីលយ៉ាងនេះឯង ។ ម្នាលវិសាខា ចុះមាតុគ្រាម បរិបូណ៌ដោយចាគៈ តើដូចម្តេច ។ ម្នាលវិសាខា មាតុគ្រាម ក្នុងលោកនេះ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគរួចស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ គួរដល់ពួកស្មូម ត្រេកអរក្នុងការចែករំលែកនូវទាន ។ ម្នាលវិសាខា មាតុគ្រាម បរិបូណ៌ដោយចាគៈ យ៉ាងនេះឯង ។ ម្នាលវិសាខា ចុះមាតុគ្រាម បរិបូណ៌ដោយបញ្ញា តើដូចម្តេច ។ ម្នាលវិសាខា មាតុគ្រាមក្នុងលោកនេះ ជាស្ត្រីមានបញ្ញា ប្រកបដោយបញ្ញាជាដំណើរទៅកាន់សេចក្តីចម្រើន និងសេចក្តីវិនាស ជាបញ្ញាដ៏ប្រសើរមោះមុតដល់នូវការអស់ទៅនៃទុក្ខដោយប្រពៃ ។ ម្នាលវិសាខា មាតុគ្រាមបរិបូណ៌ដោយបញ្ញាយ៉ាងនេះឯង ។ ម្នាលវិសាខា មាតុគ្រាម បរិបូណ៌ដោយធម៌ ៨ ប្រការនេះ ឈ្មោះថាប្រតិបត្តិ ដើម្បីឈ្នះនូវលោកខាងមុខ លោកខាងមុខក៏ឈ្មោះថា មាតុគ្រាមនោះ បានប្រារព្ធហើយ ។

មាតុគ្រាមចាត់ចែងការងារដោយប្រពៃ ១ សង្គ្រោះពួកជនជាបរិសទ្យ ១ ប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តនៃស្វាមី ១ ថែទាំសម្បត្តិដែលស្វាមីរកបានមក ១ បរិបូណ៌ដោយសទ្ធា ១ សីល ១ ដឹងនូវពាក្យពោល ១ ប្រាសចាកសេចក្តីកំណាញ់ ១

និច្ចំ មគ្គំ វិសោធេតិ សោត្ថានំ សម្បរាយិកំ
ឥច្ចេតេ អដ្ឋ ធម្មា ច យស្សា វិជ្ជន្តិ នារិយា
តម្បិ សីលវតឹ អាហុ ធម្មដ្ឋំ សច្ចវាទិនឹ
សោឡសាការសម្បន្នា អដ្ឋង្គសុសមាគតា
តាទិសី សីលវតី ឧបាសិកា ឧបបជ្ជតិ
ទេវលោកំ មនាបន្តិ ។

[៥០] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ ឥធ លោកវិជយាយ បដិបន្នោ ហោតិ អយំស លោកោ អារទ្ធោ ហោតិ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ មាតុគ្គាមោ សុសំវិហិតកម្មន្តោ ហោតិ សង្គហិតបរិជនោ ភត្តុ មនាបំ ចរតិ សម្ភតំ អនុរក្ខតិ ។ កថញ្ច ភិក្ខវេ មាតុគ្គាមោ សុសំវិហិតកម្មន្តោ ហោតិ ។ ឥធ ភិក្ខវេ មាតុគ្គាមោ យេ តេ ភត្តុ អព្ភន្តរា កម្មន្តា ។ បេ ។ ឯវំ ខោ ភិក្ខវេ មាតុគ្គាមោ សុសំវិហិតកម្មន្តោ ហោតិ ។

ជម្រះផ្លូវជាទីទៅកាន់បរលោក ឲ្យស្អាតជានិច្ច ១ ធម៌ទាំង ៨ នេះ មានដល់នារីណា អ្នកប្រាជ្ញពោលថា នារីនោះមានសីល ឋិតនៅក្នុងធម៌ ពោលនូវពាក្យពិត ជាឧបាសិកាដែលបរិបូណ៌ដោយអាការ ១៦[១] ប្រកបដោយអង្គទាំង ៨ ប្រការ មានសីលបែបនោះ រមែងទៅកើត ក្នុងទេវលោកឈ្មោះមនាបកាយិកា ។

[៥០] ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការ ឈ្មោះថាប្រតិបត្តិ ដើម្បីឈ្នះនូវលោកនេះ លោកនេះ ក៏ឈ្មោះថាមាតុគ្រាមនោះ បានប្រារព្ធហើយ ។ ប្រកបដោយធម៌ ៤ ប្រការ តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ក្នុងលោកនេះ ជាស្ត្រីចេះចាត់ចែងការងារដោយប្រពៃ ១ ចេះសង្គ្រោះពួកជនជាបរិសទ្យ ១ ចេះប្រព្រឹត្តនូវអំពើជាទីគាប់ចិត្តនៃស្វាមី ១ ចេះថែទាំសម្បត្តិដែលស្វាមីរកបានមក ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម ជាស្ត្រីចេះចាត់ចែងការងារដោយប្រពៃ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ក្នុងលោកនេះ ការងារទាំងឡាយណា ជាបន្ទុករបស់ស្វាមី ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ជាស្ត្រីចេះចាត់ចែង ការងារដោយប្រពៃ យ៉ាងនេះឯង ។

---

១ អាការ ១៦ នោះ សំដៅយកបបួលអ្នកដទៃ ៨ ចូលមកទៀតផង ។ អដ្ឋកថា ។

កថញ្ច ភិក្ខវេ មាតុគ្គាមោ សង្គហិតបរិជនោ ហោតិ ។ ឥធ ភិក្ខវេ មាតុគ្គាមោ យេ តេ ភត្តុ អព្ភន្តរា អន្តោជនា ។ បេ ។ ឯវំ ខោ ភិក្ខវេ មាតុគ្គាមោ សង្គហិតបរិជនោ ហោតិ ។ កថញ្ច ភិក្ខវេ មាតុគ្គាមោ ភត្តុ មនាបំ ចរតិ ។ ឥធ ភិក្ខវេ មាតុគ្គាមោ យំ ភត្តុ អមនាបសង្ខាតំ តំ ជីវិតហេតុបិ ន អជ្ឈាចរតិ ។ ឯវំ ខោ ភិក្ខវេ មាតុគ្គាមោ ភត្តុ មនាបំ ចរតិ ។ កថញ្ច ភិក្ខវេ មាតុគ្គាមោ សម្ភតំ អនុរក្ខតិ ។ ឥធ ភិក្ខវេ មាតុគ្គាមោ យំ ភត្តា អាហរតិ ។ បេ ។ ឯវំ ខោ ភិក្ខវេ មាតុគ្គាមោ សម្ភតំ អនុរក្ខតិ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ ឥធលោកវិជយាយ បដិបន្នោ ហោតិ អយសំ លោកោ អារទ្ធោ ហោតិ ។ ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ មាតុគ្គាមោ បរលោកវិជយាយ បដិបន្នោ ហោតិ បរស្ស លោកោ អារទ្ធោ ហោតិ ។

ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម ចេះសង្គ្រោះពួកជនជាបរិសទ្យ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ក្នុងលោកនេះ ពួកជនណាជាខាងក្នុង ជាបន្ទុករបស់ស្វាមី ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ចេះសង្គ្រោះពួកជនជាបរិសទ្យយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម ចេះប្រព្រឹត្តអំពើជាទីគាប់ចិត្តរបស់ស្វាមី តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ក្នុងលោកនេះ អំពើណាដែលមិនជាទីគាប់ចិត្តនៃស្វាមី បើទុកជាមានហេតុដល់ជីវិត ក៏មិនប្រព្រឹត្តកន្លងនូវអំពើនោះ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រព្រឹត្តអំពើជាទីគាប់ចិត្តនៃស្វាមីយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម ចេះថែទាំសម្បត្តិ ដែលស្វាមីរកបានមក តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ ស្វាមីនាំមកនូវទ្រព្យណា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម ចេះថែទាំសម្បត្តិដែលស្វាមីរកបានមកយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការនេះឯង ឈ្មោះថាប្រតិបត្តិ ដើម្បីឈ្នះលោកនេះ លោកនេះក៏ឈ្មោះថា មាតុគ្រាមនោះ បានប្រារព្ធហើយ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការ ឈ្មោះថាប្រតិបត្តិ ដើម្បីឈ្នះលោកខាងមុខ លោកខាងមុខ ក៏ឈ្មោះថាមាតុគ្រាមនោះ បានប្រារព្ធហើយ ។

២២៧



កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ មាតុគ្គាមោ សទ្ធា-
សម្បន្នោ ហោតិ សីលសម្បន្នោ ហោតិ ចាគសម្បន្នោ
ហោតិ បញ្ញាសម្បន្នោ ហោតិ ។ កថញ្ច ភិក្ខវេ
មាតុគ្គាមោ សទ្ធាសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ
មាតុគ្គាមោ សទ្ធោ ហោតិ ។ បេ ។ ឯវំ ខោ ភិក្ខវេ
មាតុគ្គាមោ សទ្ធាសម្បន្នោ ហោតិ ។ កថញ្ច ភិក្ខវេ
មាតុគ្គាមោ សីលសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ
មាតុគ្គាមោ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។
សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ ។ ឯវំ ខោ
ភិក្ខវេ មាតុគ្គាមោ សីលសម្បន្នោ ហោតិ ។ កថញ្ច
ភិក្ខវេ មាតុគ្គាមោ ចាគសម្បន្នោ ហោតិ ។ ឥធ ភិក្ខវេ
មាតុគ្គាមោ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ
។ បេ ។ ឯវំ ខោ ភិក្ខវេ មាតុគ្គាមោ ចាគសម្បន្នោ
ហោតិ ។ កថញ្ច ភិក្ខវេ មាតុគ្គាមោ បញ្ញាសម្បន្នោ
ហោតិ ។ ឥធ ភិក្ខវេ មាតុគ្គាមោ បញ្ញវា ហោតិ ។ បេ ។
ឯវំ ខោ ភិក្ខវេ មាតុគ្គាមោ បញ្ញាសម្បន្នោ ហោតិ ។
ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ

ប្រកបដោយធម៌ ៤ ប្រការ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ បរិបូណ៌ដោយសទ្ធា ១ បរិបូណ៌ដោយសីល ១ បរិបូណ៌ដោយចាគៈ ១ បរិបូណ៌ដោយបញ្ញា ១ ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាមបរិបូណ៌ដោយសទ្ធា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ មានសទ្ធា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម បរិបូណ៌ដោយសទ្ធាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម បរិបូណ៌ដោយសីល តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ វៀរចាកបាណាតិបាត ។ បេ ។ វៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺផឹកនូវទឹកស្រវឹងគឺសុរានិងមេរ័យ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមបរិបូណ៌ដោយសីលយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាមបរិបូណ៌ដោយចាគៈ តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម បរិបូណ៌ដោយចាគៈយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ ចុះមាតុគ្រាម បរិបូណ៌ដោយបញ្ញា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមក្នុងលោកនេះ ជាស្ត្រីមានបញ្ញា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាម បរិបូណ៌ដោយបញ្ញាយ៉ាងនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មាតុគ្រាមប្រកបដោយធម៌ ៤ ប្រការនេះឯង

មាតុគ្គាមោ បរលោកវិជយាយ បដិបន្នោ ហោតិ បរស្ស លោកោ អារទ្ធោ ហោតីតិ ។

សុសំវិហិតកម្មន្តោ សង្គហិតបរិជ្ជនោ
ភត្តុ មនាបំ ចរតិ សម្ភតំ អនុរក្ខតិ
សទ្ធាសីលេន សម្បន្នោ វទញ្ញូ វីតមច្ឆរោ
និច្ចំ មគ្គំ វិសោធេតិ សោត្ថានំ សម្បរាយិកំ
ឥច្ចេតេ អដ្ឋ ធម្មា ច យស្សា វិជ្ជន្តិ នារិយា
តម្បិ សីលវតឹ អាហុ ធម្មដ្ឋំ សច្ចវាទិនឹ
សោឡសាការសម្បន្នា អដ្ឋង្គសុសមាគតា
តាទិសី សីលវតី ឧបាសិកា ឧបបជ្ជតិ
ទេវលោកំ មនាបន្តិ ។

ឧបោសថវគ្គោ បញ្ចមោ ។

# តត្រុទ្ទានំ

សង្ខិត្តេ វិត្ថតេ វិសាខេ វាសេដ្ឋោ ពោជ្ឈាយ បញ្ចមំ អនុរុទ្ធំ បុន វិសាខេ នកុលា ឥធលោកិកា ទ្វេតិ ។

បណ្ណាសកោ សមត្តោ ។

ឈ្មោះថាប្រតិបត្តិ ដើម្បីឈ្នះលោកខាងមុខ លោកខាងមុខ ក៏ឈ្មោះថា មាតុគ្រាមនោះ បានប្រារព្ធហើយ ។

មាតុគ្រាមចាត់ចែងការងារដោយប្រពៃ ១ សង្គ្រោះពួកជនជាបរិសទ្យ ១ ប្រព្រឹត្តអំពើ ជាទីគាប់ចិត្តនៃស្វាមី ១ ថែទាំសម្បត្តិដែលស្វាមីរកបានមក ១ បរិបូណ៌ដោយសទ្ធា ១ សីល ១ ដឹងនូវពាក្យពោល ១ ប្រាសចាកសេចក្តីកំណាញ់ ជម្រះផ្លូវជាទីទៅកាន់បរលោកឲ្យស្អាតជានិច្ច ១ ធម៌ទាំង ៨ នេះ មានដល់នារីណា អ្នកប្រាជ្ញពោលថា នារីនោះ មានសីល ឋិតនៅក្នុងធម៌ ពោលនូវពាក្យពិត ឧបាសិកាដែលបរិបូណ៌ដោយអាការ ១៦ ប្រកបដោយអង្គទាំង ៨ មានសីលបែបនោះ រមែងទៅកើតក្នុងទេវលោកឈ្មោះមនាបកាយិកា ។

ចប់ ឧបោសថវគ្គ ទី ៥ ។

# ឧទ្ទានក្នុងឧបោសថវគ្គនោះគឺ

និយាយអំពីការរក្សាឧបោសថយ៉ាងសង្ខេប ១ ពិស្តារ ១ អំពីនាងវិសាខា ១ អំពីវាសេដ្ឋព្រាហ្មណ៍ ១ ជាគម្រប់ ៥ នឹងនាងពោជ្ឈា អំពីព្រះអនុរុទ្ធ ១ អំពីនាងវិសាខា ១ អំពីនកុលមាតា ១ អំពីការឈ្នះលោកនេះ មានពីរលើក ។

ចប់ បណ្ណាសក ។

# បណ្ណាសកាសង្គហិតា វគ្គា

## សន្ទានវគ្គោ

[៥១] ឯកំ សមយំ ភគវា សក្កេសុ វិហរតិ កបិលវត្ថុស្មឹ និគ្រោធារាមេ ។ អថខោ មហាបជាបតី គោតមី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អលំ គោតមិ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។ ទុតិយម្បិ ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេ-ទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។

# បណ្ណាសកាសង្គហិតវគ្គ

## សន្ធានវគ្គ

[៥១] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងនិគ្រោធារាម ក្បែរក្រុងកបិលពស្តុ ក្នុងដែនសក្កៈ ។ គ្រានោះ ព្រះនាងមហាបជា-បតិគោតមី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយឋិតនៅ ក្នុងទីសមគួរ ។ លុះព្រះនាងមហាបជាបតិគោតមី ឋិតនៅ ក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់សូមអង្វរ មាតុគ្រាម គួរចេញចាកផ្ទះ បានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគត ទ្រង់សម្តែងហើយ ។ ព្រះសម្ពុទ្ធទ្រង់ត្រាស់ឃាត់ថា ម្នាលនាងគោតមី ណ្ហើយនាង កុំគាប់ចិត្តឲ្យមាតុគ្រាមចេញចាកផ្ទះ ហើយបព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតបានសម្តែងឡើយ ។ ព្រះនាងមហាបជាបតិគោតមី ក្រាបថ្វាយបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះ ជាគម្រប់ពីរដងថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់សូមអង្វរ មាតុគ្រាម គួរចេញចាកផ្ទះ បានបព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សម្តែងហើយ ។

អលំ គោតមិ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។ តតិយម្បិ ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អលំ គោតមិ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។ អថខោ មហាបជាបតី គោតមី ន ភគវា អនុជានាតិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ទុក្ខី ទុម្មនា អស្សុមុខី រុទមានា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ ភគវា កបិលវត្ថុស្មឹ យថាភិរន្តំ វិហរិត្វា យេន វេសាលី តេន ចារិកំ បក្កាមិ អនុបុព្វេន ចារិកំ ចរមានោ យេន វេសាលី តទវសរិ តត្រ សុទំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។

ម្នាលនាងគោតមី ណ្ហើយនាង កុំគាប់ចិត្តឲ្យមាតុគ្រាម ចេញចាកផ្ទះ បព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះក្នុងធម្មវិន័យដែលតថាគតបានសម្តែងឡើយ ។ ព្រះនាងមហាបជាបតិគោតមី ក្រាបបង្គំទូលព្រះមានព្រះភាគដូច្នេះជាគម្រប់ បីដងថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំម្ចាស់សូមអង្វរ មាតុគ្រាមគួរចេញចាកផ្ទះ បានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគត សម្តែងហើយ ។ ម្នាលនាងគោតមី ណ្ហើយនាងកុំគាប់ចិត្តឲ្យមាតុគ្រាមចេញ ចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតបាន សម្តែងឡើយ ។ លំដាប់នោះឯង ព្រះនាងមហាបជាបតិគោតមី បានជ្រាបថា ព្រះដ៏មានព្រះភាគ មិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិន មានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតសម្តែងហើយ ក៏កើតទុក្ខតូចព្រះទ័យ ស្រក់ទឹកព្រះនេត្រទ្រង់ព្រះកន្សែងហើយ ថ្វាយបង្គំ ព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណរួចចៀសចេញទៅ ។ គ្រានោះឯង ព្រះ ដ៏មានព្រះភាគ ទ្រង់គង់សម្រេចសម្រាន្ត ក្នុងក្រុងកបិលពស្តុ តាមគួរ ដល់ពុទ្ធអធ្យាស្រ័យ ហើយស្តេចចៀសចេញទៅកាន់ចារិក ក្រុងវេសាលី កាលទ្រង់ស្តេចទៅកាន់ចារិក តាមលំដាប់ ក៏បានទៅដល់ក្រុងវេសាលី នោះឯង ។ មានសេចក្តីដំណាលថា ព្រះដ៏មានព្រះភាគ ទ្រង់គង់សម្រេច សម្រាន្ត ក្នុងកូដាគារសាលា នាមហាវ័ន ទៀបក្រុងវេសាលីនោះ ។

អថខោ មហាបជាបតី គោតមី កេសេ ឆេទាបេត្វា កាសាយានិ វត្ថានិ អច្ឆាទេត្វា សម្ពហុលាហិ សាកិយាហិ[១] សទ្ធឹ យេន វេសាលី តេន បក្កាមិ អនុបុព្វេន យេន វេសាលី មហាវនំ កូដាគារសាលា តេនុបសង្កមិ ។ អថខោ មហាបជាបតី គោតមី សុនេហិ បាទេហិ រជោកិណ្ណេន គត្តេន ទុក្ខី ទុម្មនា អស្សុមុខី រុទមានា ពហិទ្វារកោដ្ឋកេ អដ្ឋាសិ ។ អទ្ទសា ខោ អាយស្មា អានន្ទោ មហាបជាបតឹ គោតមឹ សុនេហិ បាទេហិ រជោកិណ្ណេន គត្តេន ទុក្ខឹ ទុម្មនំ អស្សុមុខឹ រុទមានំ ពហិទ្វារកោដ្ឋកេ ឋិតំ ទិស្វាន មហាបជាបតឹ គោតមឹ ឯតទវោច កឹ នុ ត្វំ គោតមិ សុនេហិ បាទេហិ រជោកិណ្ណេន គត្តេន ទុក្ខី ទុម្មនា អស្សុមុខី រុទមានា ពហិទ្វារកោដ្ឋកេ ឋិតាតិ ។ តថា ហិ បន ភន្តេ អានន្ទ ន ភគវា អនុជានាតិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ តេនហិ គោតមិ

១ ឱ. ម. សាកិយានីហិ ។

លំដាប់នោះឯង ព្រះនាងមហាបជាបតិគោតមី ឲ្យគេកោរព្រះកេសា ហើយស្លៀកសំពត់ជ្រលក់ ដោយទឹកអម្ចត់ ទ្រង់យាងសំដៅទៅក្រុងវេសាលី ជាមួយនឹងពួកនាងសាកិយានីជាច្រើន យាងចូលទៅកាន់កូដាគារសាលា នាមហាវ័ន ទៀបក្រុងវេសាលីនោះ តាមលំដាប់ ។ វេលានោះ ព្រះនាងមហាបជាបតិគោតមី មានព្រះបាទទាំងគូ ពុរពង មានព្រះអង្គប្រឡាក់ដោយធូលី កើតទុក្ខតូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្សែង ទៀបក្លោងទ្វារខាងក្រៅ ។ ព្រះអានន្ទដ៏មានអាយុ បានឃើញព្រះនាងមហាបជាបតិគោតមី មានព្រះបាទទាំងគូ ពុរពង មានព្រះអង្គប្រឡាក់ដោយធូលី កើតទុក្ខតូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ កំពុងតែឈរទ្រង់ព្រះកន្សែង ទៀបក្លោងទ្វារខាងក្រៅ លុះបានឃើញហើយ ក៏ពោលទៅនឹងព្រះនាងមហាបជាបតិគោតមីដូច្នេះថា បពិត្រព្រះនាងគោតមី ហេតុអ្វីបានជាព្រះនាងមានព្រះបាទទាំងគូពុរពង មានព្រះអង្គព្រះឡាក់ដោយធូលី កើតទុក្ខតូចព្រះទ័យ ស្រក់ទឹកព្រះនេត្រឈរទ្រង់ព្រះកន្សែងទៀបក្លោងទ្វារខាងក្រៅដូច្នេះ ។ បពិត្រព្រះអានន្ទដ៏ចម្រើន បានជាដូច្នោះ ព្រោះតែព្រះដ៏មានព្រះភាគ មិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សម្ដែងហើយផងសោះ ។ បពិត្រព្រះនាងគោតមី បើដូច្នោះ

ឥធេវ តាវ ហោហិ យាវាហំ ភគវន្តំ យាចាមិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ឯសា ភន្តេ មហាបជាបតី គោតមី សុនេហិ ចាទេហិ រជោកិណ្ណេន គត្តេន ទុក្ខី ទុម្មនា អស្សុមុខី រុទមានា ពហិទ្វារកោដ្ឋកេ ឋិតា ន ភគវា អនុជានាតិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អលំ អានន្ទ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។

សូមព្រះនាងទ្រង់រង់ចាំក្នុងទីនេះសិនចុះ ទម្រាំអាត្មាភាព ទៅក្រាបបង្គំទូលសុំព្រះដ៏មានព្រះភាគ ឲ្យមាតុគ្រាម បានចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សម្តែងហើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមីនុ៎ះ មានព្រះបាទទាំងគូ ពុរពង មានព្រះអង្គប្រឡាក់ធូលី កើតទុក្ខតូចព្រះទ័យ ស្រក់ទឹកព្រះនេត្រ ឈរទ្រង់ព្រះកន្សែងទៀបក្លោងទ្វារខាងក្រៅ ដោយជ្រាបថា ព្រះដ៏មានព្រះភាគមិនទ្រង់អនុញ្ញាតឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សម្តែងហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមចេញចាកផ្ទះ បានបព្វជ្ជា មិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សម្តែងហើយ ។ ម្នាលអានន្ទ ណ្ហើយអ្នក កុំគាប់ចិត្តឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតសម្តែងឡើយ ។

ទុតិយម្បិ ខោ ។ បេ ។ តតិយម្បិ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អលំ អានន្ទ មា តេ រុច្ចិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជាតិ ។ អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ ន ភគវា អនុជានាតិ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជំ យន្នូនាហំ អញ្ញេនបិ បរិយាយេន ភគវន្តំ យាចេយ្យំ មាតុគ្គាមស្ស តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ អថខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច ភព្វោ នុ ខោ ភន្តេ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិត្វា សោតាបត្តិផលំ វា សកទាគាមិផលំ វា អនាគាមិផលំ វា អរហត្តផលំ វា សច្ឆិកាតុន្តិ ។

ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូល ជាគម្រប់ពីរដងផង ។ បេ ។ ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះ ជាគម្រប់ ៣ ដងផងថា បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាមចេញចាកផ្ទះ បានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សម្តែងហើយផង ។ ម្នាលអានន្ទ ណ្ហើយអ្នកកុំគាប់ចិត្ត ឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតសម្តែងឡើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្តីត្រិះរិះដូច្នេះថា ឥឡូវនេះ ព្រះដ៏មានព្រះភាគ មិនទ្រង់អនុញ្ញាត ឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សម្តែងហើយទេ បើដូច្នោះ គួរតែអាត្មាអញក្រាបបង្គំទូលសុំព្រះដ៏មានព្រះភាគ ដោយបរិយាយដទៃទៀត ដើម្បីឲ្យមាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សម្តែងហើយ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន មាតុគ្រាម បើចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សម្តែងហើយ គួរធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលក្តី សកទាគាមិផលក្តី អនាគាមិផលក្តី អរហត្តផលក្តី បានដែរ ឬ ។

ភព្វោ អានន្ទ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិត្វា សោតាបត្តិផលម្បិ សកទាគាមិផលម្បិ អនាគាមិផលម្បិ អរហត្តផលម្បិ សច្ឆិកាតុន្តិ ។ សចេ ភន្តេ ភព្វោ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិត្វា សោតាបត្តិផលម្បិ ។ បេ ។ អរហត្តផលម្បិ សច្ឆិកាតុំ ពហុការា ភន្តេ មហាបជាបតី គោតមី ភគវតោ មាតុច្ឆា អាចាទិកា ចោសិកា ភគវន្តំ ជនេត្តិយា កាលកតាយ ថញ្ញំ ចាយេសិ ។ សាធុ ភន្តេ លភេយ្យ មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជន្តិ ។ សចេ អានន្ទ មហាបជាបតី គោតមី អដ្ឋ គរុធម្មេ បដិគ្គណ្ហាតិ សា វស្សា ហោតុ ឧបសម្បទា ។ វស្សសតូបសម្បន្នាយ ភិក្ខុនិយា តទហុបសម្បន្នស្ស ភិក្ខុនោ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ កត្តព្វំ

ម្នាលអានន្ទ មាតុគ្រាម បើចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតសម្តែងហើយ ក៏គួរធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលផង សកទាគាមិផលផង អនាគាមិផលផង អរហត្តផលផង ។ បពិត្រព្រះអង្គដ៏ចម្រើន បើមាតុគ្រាម ចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតសម្តែងហើយ គួរធ្វើឲ្យជាក់ច្បាស់នូវសោតាបត្តិផលផង ។ បេ ។ អរហត្តផលផង បពិត្រព្រះអង្គដ៏ចម្រើន ព្រះនាងមហាបជាបតិគោតមីមានឧបការៈច្រើន ជាព្រះមាតុច្ឆារបស់ព្រះដ៏មានព្រះភាគ បានបីបាច់ចិញ្ចឹម កាលព្រះមាតាទ្រង់ទិវង្គតទៅ បានបំបៅព្រះដ៏មានព្រះភាគ តរៀងមក ។ បពិត្រព្រះអង្គដ៏ចម្រើន សូមទ្រង់ព្រះមេត្តាប្រោស ឲ្យមាតុគ្រាម ចេញចាកផ្ទះ បានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលព្រះតថាគតទ្រង់សម្តែងហើយផង ។ ម្នាលអានន្ទ បើព្រះនាងមហាបជាបតិគោតមីទទួលប្រតិបត្តិតាមគរុធម៌ ៨ ប្រការបាន ឧបសម្បទានោះ ចូរសម្រេចដល់ព្រះនាងចុះ ។ (ឯគរុធម៌ ៨ ប្រការនោះគឺ) ភិក្ខុនីសូម្បីឧបសម្បទាបានមួយរយវស្សាហើយ ក៏ត្រូវតែថ្វាយបង្គំ ក្រោកទទួល ធ្វើអញ្ជលិកម្ម សាមីចិកម្ម ចំពោះភិក្ខុ ដែលទើបនឹងឧបសម្បទាក្នុងថ្ងៃនោះ

អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ ន ភិក្ខុនិយា អភិក្ខុកេ អាវាសេ វស្សំ ឧបគន្តព្វំ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ អន្វឌ្ឍមាសំ ភិក្ខុនិយា ភិក្ខុសង្ឃតោ ឧបោសថបុច្ឆកញ្ច ឱវាទូបសង្កមនញ្ច បរិយេសិតព្វំ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ វស្សំ វុត្ថាយ ភិក្ខុនិយា ឧភតោសង្ឃេ តីហិ ឋានេហិ បវារេតព្វំ ទិដ្ឋេន សុតេន បរិសង្កាយ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ គរុធម្មំ អជ្ឈាបន្នាយ ភិក្ខុនិយា ឧភតោសង្ឃេ បក្ខមានត្តំ ចរិតព្វំ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ ទ្វេ វស្សានិ ឆសុ ធម្មេសុ សិក្ខិតសិក្ខាយ សិក្ខមានាយ ឧភតោសង្ឃេ ឧបសម្បទា បរិយេសិតព្វា

នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ។ ភិក្ខុនី មិនត្រូវនៅចាំវស្សាក្នុងអាវាសដែលគ្មានភិក្ខុឡើយ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លងដរាបអស់ជីវិត ១ ។ ភិក្ខុនីត្រូវស្វែងរកសួរឧបោសថផង ចូលទៅស្តាប់ឱវាទផង អំពីសំណាក់ភិក្ខុសង្ឃរាល់កន្លះខែ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លង ដរាបអស់ជីវិត ១ ។ ភិក្ខុនីនៅចាំវស្សារួចហើយ ត្រូវបវារណាក្នុងសំណាក់សង្ឃទាំង ២ ពួក (គឺភិក្ខុសង្ឃ ១ ភិក្ខុនីសង្ឃ ១) ដោយឋាន ៣ យ៉ាងគឺ ឃើញ ឮ រង្កៀស នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លង ដរាបអស់ជីវិត ១ ។ ភិក្ខុនីត្រូវគរុកាបត្តិហើយ គប្បីប្រព្រឹត្តបក្ខមានត្តក្នុងសំណាក់សង្ឃទាំង ២ ពួក នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លង ដរាបអស់ជីវិត ១ ។ ភិក្ខុនីត្រូវជួយស្វែងរកឧបសម្បទា ក្នុងសំណាក់សង្ឃទាំង ២ ពួក ដល់សិក្ខមានាដែលបានសិក្សាសិក្ខាក្នុងធម៌ ៦[១] ប្រការគ្រប់ ២ ឆ្នាំហើយ

---

១ សំដៅយកសិក្ខាបទ ៦ ពីបាណាតិបាត ដល់វិកាលភោជនៈ ។

អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ ន កេនចិ បរិយាយេន ភិក្ខុនិយា ភិក្ខុ អក្កោសិតព្វោ បរិភាសិតព្វោ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ អជ្ជតគ្គេ ឱវដោ ភិក្ខុនីនំ ភិក្ខូសុ វចនបថោ អនោវដោ ភិក្ខូនំ ភិក្ខុនីសុ វចនបថោ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ សចេ អានន្ទ មហាបជាបតី គោតមី ឥមេ អដ្ឋ គរុធម្មេ បដិគ្គណ្ហាតិ សា វស្សា ហោតុ ឧបសម្បទាតិ ។ អថខោ អាយស្មា អានន្ទោ ភគវតោ សន្តិកេ ឥមេ អដ្ឋ គរុធម្មេ ឧគ្គហេត្វា យេន មហាបជាបតី គោតមី តេនុបសង្កមិ ឧបសង្កមិត្វា មហាបជាបតឹ គោតមឹ ឯតទវោច សចេ ខោ ត្វំ គោតមិ អដ្ឋ គរុធម្មេ បដិគ្គណ្ហេយ្យាសិ សាវ តេ ភវិស្សតិ ឧបសម្បទា ។

នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លង ដរាបអស់ជីវិត ១ ។ ភិក្ខុនីមិនត្រូវជេរ មិនត្រូវប្រទេចភិក្ខុ ដោយបរិយាយណាមួយឡើយ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លង ដរាបអស់ជីវិត ១ ។ តាំងពីថ្ងៃ ដែលបានឧបសម្បទានេះទៅ ភិក្ខុនីត្រូវតែស្តាប់បង្គាប់ភិក្ខុ ឯភិក្ខុមិនត្រូវស្តាប់បង្គាប់ភិក្ខុនីវិញឡើយ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់-អាន បូជា កុំគប្បីប្រព្រឹត្តកន្លង ដរាបអស់ជីវិត ១ ។ ម្នាលអានន្ទ បើព្រះនាងមហាបជាបតិគោតមី ទទួលប្រព្រឹត្តតាមគរុធម៌ទាំង ៨ នេះបាន ឧបសម្បទានោះ ចូរសម្រេចដល់ព្រះនាងចុះ ។ លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ បានរៀនគរុធម៌ ៨ ប្រការ ក្នុងសំណាក់ព្រះដ៏មានព្រះភាគ (ចាំស្ទាត់ហើយ) ក៏ចូលទៅរកព្រះនាងមហាបជាបតិ-គោតមី លុះចូលទៅដល់ហើយ ក៏ពោលទៅនឹងព្រះនាងមហាបជាបតិ-គោតមីដូច្នេះថា បពិត្រព្រះនាងគោតមី បើព្រះនាងទទួលប្រតិបត្តិតាមគរុធម៌ ៨ ប្រការបាន ឧបសម្បទានោះ នឹងសម្រេចដល់ព្រះនាង ។

២៣៧



វស្សសតូបសម្បន្នាយ ភិក្ខុនិយា តទហុបសម្បន្នស្ស ភិក្ខុនោ អភិវាទនំ បច្ចុដ្ឋានំ អញ្ជលិកម្មំ សាមីចិកម្មំ កាតព្វំ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ បេ ។ អជ្ជតគ្គេ ឱវដោ ភិក្ខុនីនំ ភិក្ខូសុ វចនបថោ អនោវដោ ភិក្ខូនំ ភិក្ខុនីសុ វចនបថោ អយម្បិ ធម្មោ សក្កត្វា គរុកត្វា មានេត្វា បូជេត្វា យាវជីវំ អនតិក្កមនីយោ ។ សចេ ខោ ត្វំ គោតមិ ឥមេ អដ្ឋ គរុធម្មេ បដិគ្គណ្ហេយ្យាសិ សាវ តេ ភវិស្សតិ ឧបសម្បទាតិ ។ សេយ្យថាបិ ភន្តេ អានន្ទ ឥត្ថី វា បុរិសោ វា ទហរោ យុវា មណ្ឌនកជាតិកោ សីសន្ហាតោ ឧប្បលមាលំ វា វស្សិកមាលំ វា អតិមុត្តកមាលំ វា លភិត្វា ឧភោហិ ហត្ថេហិ បដិគ្គហេត្វា ឧត្តមង្គេ សិរស្មឹ បតិដ្ឋាបេយ្យ ឯវមេវ ខោ អហំ ភន្តេ ឥមេ អដ្ឋ គរុធម្មេ បដិគ្គណ្ហាមិ យាវជីវំ អនតិក្កមនីយេតិ ។

(ឯគរុធម៌ ៨ ប្រការនោះគឺ) ភិក្ខុនីសូម្បីឧបសម្បទា បានមួយរយវស្សាហើយ ក៏ត្រូវតែថ្វាយបង្គំ ក្រោកទទួល ធ្វើអញ្ជលិកម្ម សាមីចិកម្ម ចំពោះភិក្ខុ ដែលទើបនឹងបួសហើយក្នុងថ្ងៃនោះ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លង ដរាបអស់ជីវិត ១ ។ បេ ។ ចាប់ដើមតាំងពីថ្ងៃ (ដែលបានឧបសម្បទា) នេះទៅ ភិក្ខុនីត្រូវតែស្តាប់បង្គាប់ភិក្ខុ ឯភិក្ខុមិនត្រូវស្តាប់បង្គាប់ភិក្ខុនីវិញទេ្បីយ នេះជាធម៌ដែលភិក្ខុនីត្រូវធ្វើសក្ការៈ គោរព រាប់អាន បូជា កុំគប្បីប្រព្រឹត្តកន្លង ដរាបអស់ជីវិត ១ ។ បពិត្រព្រះនាងគោតមី បើព្រះនាងទទួលប្រតិបត្តិគរុធម៌ ៨ ប្រការនេះបាន ឧបសម្បទានោះ នឹងសម្រេចដល់ព្រះនាងបាន ។ ព្រះនាងមហាបជាបតិគោតមី ឆ្លើយតបថា បពិត្រព្រះអានន្ទដ៏ចម្រើន ស្ត្រីឬបុរសនៅក្រមុំកំឡោះប្រកបដោយជាតិជាអ្នកស្អិតស្អាងខ្លួន មានក្បាលលប់លាងហើយបានកម្រងផ្កាឧប្បលក្តី កម្រងផ្កាម្លិះក្តី កម្រងផ្កាដែលមានក្លិនក្រអូបណាស់ក្តី ហើយទទួលយកដោយដៃទាំងពីរ តម្កល់ទុកលើអវយវៈដ៏ឧត្តមគឺក្បាល យ៉ាងណាមិញ បពិត្រព្រះអានន្ទដ៏ចម្រើន ខ្ញុំនឹងទទួលប្រតិបត្តិតាមគរុធម៌ ៨ ប្រការនេះ មិនប្រព្រឹត្តកន្លង ដរាបអស់ជីវិត ក៏យ៉ាងនោះដែរ ។

អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច បដិគ្គហិតា ភន្តេ មហាបជាបតិយា គោត-មិយា អដ្ឋ គរុធម្មា យាវជីវំ អនតិក្កមនីយាតិ ។ សចេ អានន្ទ នាលភិស្ស មាតុគ្គាមោ តថាគតប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជ្ជំ ចិរដ្ឋិតិកំ អានន្ទ ព្រហ្មចរិយំ អភវិស្ស វស្សសហស្សមេវ សទ្ធម្មោ តិដ្ឋេយ្យ ។ យតោ ច ខោ អានន្ទ មាតុគ្គាមោ តថាគត-ប្បវេទិតេ ធម្មវិនយេ អគារស្មា អនគារិយំ បព្វជិតោ ឥទានិ អានន្ទ ព្រហ្មចរិយំ ចិរដ្ឋិតិកំ ភវិស្សតិ បញ្ចេវទានិ អានន្ទ វស្សសតានិ សទ្ធម្មោ ឋស្សតិ សេយ្យថាបិ អានន្ទ យានិ កានិចិ កុលានិ ពហុឥត្ថិកានិ អប្បបុរិសកានិ តានិ សុប្បធំសិយានិ ហោន្តិ ចោរេហិ កុម្ភត្ថេនកេហិ

លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន គរុធម៌ទាំង ៨ ប្រការ ព្រះនាងមហាបជាបតិគោតមីព្រមទទួលហើយ មិនប្រព្រឹត្តឲ្យកន្លងដរាបអស់ជីវិតទេ ។ ម្នាលអានន្ទ ប្រសិនបើ មាតុគ្រាម មិនបានចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតសម្ដែងហើយទេ ម្នាលអានន្ទ ព្រហ្មចរិយធម៌នឹងបានតាំងនៅជាអង្វែងព្រះសទ្ធម្មគឺអរហត្តផលនឹងបានតាំងនៅអស់ ១ ពាន់ឆ្នាំ ។ ម្នាលអានន្ទ តែកាលណា មាតុគ្រាមចេញចាកផ្ទះ បព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ ដែលតថាគតសម្ដែងហើយ ម្នាលអានន្ទ ឥឡូវនេះ ព្រហ្មចរិយធម៌នឹងមិនតាំងនៅយូរអង្វែងទេ ម្នាលអានន្ទ ឥឡូវនេះ ព្រះសទ្ធម្មនឹងឋិតនៅ បានត្រឹមតែប្រាំរយឆ្នាំវិញ ម្នាលអានន្ទ ត្រកូលទាំងឡាយណាមួយ ដែលមានស្រីច្រើន មានប្រុសតិច ត្រកូលទាំងនោះ ពួកចោរលួចឧជប្រទីបក្នុងក្អមឆ្នាំង ហើយគន់មើលទ្រព្យក្នុងផ្ទះអ្នកដទៃដោយពន្លឺនោះអាចចូលមកបំផ្លាញបានដោយងាយ យ៉ាងណាមិញ

២៣៩

## បណ្ណាសកាសង្គហិតោ  សន្ទានវគ្គោ

ឯវមេវ ខោ អានន្ទ យស្មឹ ធម្មវិនយេ លភតិ មាតុគ្គាមោ អគារស្មា អនគារិយំ បព្វជ្ជំ ន តំ ព្រហ្មចរិយំ ចិរដ្ឋិតិកំ ហោតិ ។ សេយ្យថាបិ អានន្ទ សម្បន្នេ សាលិក្ខេត្តេ សេតដ្ឋិកា នាម រោគជាតិ និបតតិ ឯវំ តំ សាលិក្ខេត្តំ ន ចិរដ្ឋិតិកំ ហោតិ ឯវមេវ ខោ អានន្ទ យស្មឹ ធម្មវិនយេ លភតិ មាតុគ្គាមោ អគារស្មា អនគារិយំ បព្វជ្ជំ ន តំ ព្រហ្មចរិយំ ចិរដ្ឋិតិកំ ហោតិ ។ សេយ្យថាបិ អានន្ទ សម្បន្នេ ឧច្ឆុក្ខេត្តេ មញ្ជេដ្ឋិកា នាម រោគជាតិ និបតតិ ឯវំ តំ ឧច្ឆុក្ខេត្តំ ន ចិរដ្ឋិតិកំ ហោតិ ឯវមេវ ខោ អានន្ទ យស្មឹ ធម្មវិនយេ លភតិ មាតុគ្គាមោ អគារស្មា អនគារិយំ បព្វជ្ជំ ន តំ ព្រហ្មចរិយំ ចិរដ្ឋិតិកំ ហោតិ ។ សេយ្យថាបិ អានន្ទ បុរិសោ មហតោ តឡាកស្ស បដិកច្ចេវ អាឡឹ ពន្ធេយ្យ យាវទេវ ឧទកស្ស អនតិក្កមនាយ ឯវមេវ ខោ អានន្ទ មយា បដិកច្ចេវ ភិក្ខុនីនំ អដ្ឋ គរុធម្មា បញ្ញត្តា យាវជីវំ អនតិក្កមនីយាតិ ។

ម្នាលអានន្ទ មាតុគ្រាមចេញចាកផ្ទះ បានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ គឺព្រហ្មចរិយធម៌ណា ព្រហ្មចរិយធម៌នោះ មិនបានតាំងនៅយូរអង្វែងទេ ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ រោគជាតិឈ្មោះសេតដ្ឋិកា (គ្រា-ស) ធ្លាក់ចុះក្នុងស្រែស្រូវណា ដែលកំពុងតែលូតលាស់ល្អ ស្រែស្រូវនោះមិនបានតាំងនៅយូរអង្វែង ដោយប្រការយ៉ាងនេះ យ៉ាងណាមិញ ម្នាលអានន្ទ មាតុគ្រាម ចេញចាកផ្ទះ បានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ គឺព្រហ្មចរិយធម៌ណា ព្រហ្មចរិយធម៌នោះ មិនបានតាំងនៅយូរអង្វែងទេ ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ រោគជាតិឈ្មោះមញ្ជេដ្ឋិកា (គ្រាក្រហម) ធ្លាក់ចុះក្នុងច្បារអំ-ពៅណា ដែលកំពុងលូតលាស់ល្អ ច្បារអំពៅនោះ មិនបានតាំងនៅយូរអង្វែង ដោយប្រការយ៉ាងនេះ យ៉ាងណាមិញ ម្នាលអានន្ទ មាតុគ្រាមចេញចាកផ្ទះ បានបព្វជ្ជាមិនមានប្រយោជន៍ដោយផ្ទះ ក្នុងធម្មវិន័យ គឺព្រហ្ម-ចរិយធម៌ណា ព្រហ្មចរិយធម៌នោះ មិនបានតាំងនៅយូរអង្វែងទេ ក៏យ៉ាងនោះដែរ ។ ម្នាលអានន្ទ បុរសប្រញាប់លើកទំនប់ទប់ទឹកស្រះដ៏ធំជាមុន ដើម្បីមិនឲ្យទឹកហូរចេញទៅជាកំណាត់ យ៉ាងណាមិញ ម្នាលអានន្ទ គរុ-ធម៌ ៨ ប្រការ ដែលតថាគត បានបញ្ញត្តហើយ ចំពោះភិក្ខុនីជាដំបូង ដើម្បីមិនឲ្យ (ភិក្ខុនី) ប្រព្រឹត្តកន្លង ដរាបដល់អស់ជីវិត ក៏យ៉ាងនោះដែរ ។

[៥២] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច កតីហិ នុ ខោ ភន្តេ ធម្មេហិ សមន្នាគតោ ភិក្ខុ ភិក្ខុនោវាទកោ សម្មន្និតព្វោតិ ។ អដ្ឋហិ ខោ អានន្ទ ធម្មេហិ សមន្នាគតោ ភិក្ខុ ភិក្ខុនោវាទកោ សម្មន្និតព្វោ ។ កតមេហិ អដ្ឋហិ ។ ឥធានន្ទ ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ ។ បេ ។ ទិដ្ឋិយា សុប្បដិវិទ្ធា ឧភយានិ ខោ បនស្ស ចាតិមោក្ខានិ វិត្ថារេន ស្វាគតានិ ហោន្តិ សុវិភត្តានិ សុប្បវត្តិតានិ សុវិនិច្ឆិតានិ សុត្តសោ អនុព្យញ្ជនសោ កល្យាណវាចោ ហោតិ កល្យាណវាក្ករណោ ចោរិយា

[៩២] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងកូដាគារ-សាលា នាមហាវ័ន ក្បែរក្រុងវេសាលី ។ គ្រានោះ ព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយអង្គុយក្នុងទីសមគួរ ។ លុះព្រះអានន្ទដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ភិក្ខុប្រកបដោយធម៌ប៉ុន្មាន ដែលសង្ឃគួរសន្មត ជាអ្នកឲ្យឱវាទដល់នាងភិក្ខុនីបាន ។ ម្នាលអានន្ទ ភិក្ខុប្រកបដោយធម៌ ៨ ប្រការ ទើបសង្ឃគួរសន្មត ជាអ្នកឲ្យឱវាទដល់នាងភិក្ខុនីបាន ។ ប្រកបដោយធម៌ទាំង ៨ ប្រការ តើដូចម្ដេច ។ ម្នាលអានន្ទ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។ បេ ។ សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ១ ជាអ្នកចេះចាំច្រើន ។ បេ ។ យល់ត្រឹមត្រូវដោយទិដ្ឋិ ១ បាតិមោក្ខទាំងពីរភិក្ខុនោះ ក៏ចេះចាំដោយសេចក្ដីពិស្ដារ ចែកចេញដោយប្រពៃ ចាំស្ទាត់រត់មាត់ កាត់សេចក្ដីបានដោយល្អ តាមសូត្រ តាមអនុព្យញ្ជនៈ ១ ជាអ្នកមានវាចាពីរោះ ពោលពាក្យពីរោះ ប្រកបដោយវាចាអ្នកក្រុង

វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា បដិពលោ ហោតិ ភិក្ខុនីសង្ឃស្ស ធម្មិយា កថាយ សន្ទស្សេតុំ សមាទបេតុំ សមុត្តេជេតុំ សម្បហំសេតុំ យេភុយ្យេន ភិក្ខុនីនំ បិយោ ហោតិ មនាបោ ន ខោ បនេតំ ភគវន្តំ ឧទ្ទិស្ស បព្វជិតាយ កាសាយវត្ថនិវសនាយ គរុធម្មមជ្ឈាបន្នបុព្វោ ហោតិ វីសតិវស្សោ វា ហោតិ អតិរេកវីសតិវស្សោ វា ។ ឥមេហិ ខោ អានន្ទ អដ្ឋហិ ធម្មេហិ សមន្នាគតោ ភិក្ខុ ភិក្ខុនោវាទកោ សម្មន្និតព្វោតិ ។

[៤៣] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ មហាបជាបតី គោតមី យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ អដ្ឋាសិ ។ ឯកមន្តំ ឋិតា ខោ មហាបជាបតី គោតមី ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកា វូបកដ្ឋា

ជាវាចាក្បោះក្បាយមិនមានទោស អាចញ៉ាំងអ្នកផងឲ្យដឹងច្បាស់សេចក្តី ១ ជាអ្នកអង់អាច ដើម្បីញ៉ាំងភិក្ខុនីសង្ឃ ឲ្យយល់ ឲ្យប្រតិបត្តិតាម ឲ្យក្លាហាន ឲ្យជ្រះថ្លាដោយធម្មីកថា ១ ជាទីស្រឡាញ់ ជាទីគាប់ចិត្តនៃនាងភិក្ខុនីទាំងឡាយដោយច្រើន ១ ជាអ្នកមិនធ្លាប់ត្រូវគរុកាបត្តិ[១] ដោយនាងភិក្ខុនី ដែលស្លៀកសំពត់ជ្រលក់ដោយទឹកអម្ចត់ បួសចំពោះព្រះដ៏មានព្រះភាគអង្គនុ៎ះ ១ ជាអ្នកមានវស្សា ២០ ឬមានវស្សាច្រើនជាង ២០ ឡើងទៅ ១ ។ ម្នាលអានន្ទ ភិក្ខុប្រកបដោយធម៌ទាំង ៨ ប្រការនេះឯង ទើបសង្ឃគួរសន្មតជាអ្នកឲ្យឱវាទដល់នាងភិក្ខុនីបាន ។

[៥៣] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងកូដាគារសាលា នាមហាវ័ន ក្បែរក្រុងវេសាលី ។ គ្រានោះ ព្រះនាងមហាបជាបតិគោតមី ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ រួចហើយក៏ឋិតនៅ ក្នុងទីសមគួរ ។ លុះព្រះនាងមហាបជាបតិគោតមី ឋិតនៅក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ សម្តែងធម៌ដោយសង្ខេបដល់ខ្ញុំព្រះអង្គ ព្រោះថា ខ្ញុំព្រះអង្គបានស្តាប់ធម៌ព្រះដ៏មានព្រះភាគហើយ គប្បីចៀសចេញទៅតែម្នាក់ឯង

១ សំដៅយកកាយសំសគ្គៈ ការចាប់ពាល់ត្រូវកាយភិក្ខុនី ។ អដ្ឋកថា ។

អប្បមត្តា អាតាបិនី បហិតត្តា វិហរេយ្យន្តិ ។ យេ ខោ ត្វំ គោតមិ ធម្មេ ជានេយ្យាសិ ឥមេ ធម្មា សរាគាយ សំវត្តន្តិ នោ វិរាគាយ សំយោគាយ សំវត្តន្តិ នោ វិសំយោគាយ អាចយាយ សំវត្តន្តិ នោ អបចយាយ មហិច្ឆតាយ សំវត្តន្តិ នោ អប្បិច្ឆតាយ អសន្តុដ្ឋិយា សំវត្តន្តិ នោ សន្តុដ្ឋិយា សង្គណិកាយ សំវត្តន្តិ នោ បវិវេកាយ កោសជ្ជាយ សំវត្តន្តិ នោ វីរិយារម្ភាយ ទុព្ភរតាយ សំវត្តន្តិ នោ សុភរតាយាតិ ។ ឯកំសេន គោតមិ ធារេយ្យាសិ នេសោ ធម្មោ នេសោ វិនយោ នេតំ សត្ថុសាសនន្តិ ។ យេ ច ខោ ត្វំ គោតមិ ធម្មេ ជានេយ្យាសិ ឥមេ ធម្មា វិរាគាយ សំវត្តន្តិ នោ សរាគាយ វិសំយោគាយ សំវត្តន្តិ នោ សំយោគាយ

មិនប្រមាទ មានសេចក្តីព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន (មិនខាន) ។ ម្នាលនាងគោតមី នាងគប្បីដឹងនូវធម៌ទាំងឡាយណា ធម៌ទាំងនេះ រមែងប្រព្រឹត្តទៅ ដើម្បីប្រកបដោយតម្រេក មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក ប្រព្រឹត្តទៅ ដើម្បីប្រកបក្នុងវដ្តៈ មិនប្រព្រឹត្តទៅ ដើម្បីប្រាសចាកការប្រកបក្នុងវដ្តៈ ប្រព្រឹត្តទៅ ដើម្បីការសន្សំកិលេសវដ្តៈ មិនប្រព្រឹត្តទៅ ដើម្បីមិនមានការសន្សំកិលេសវដ្តៈ ប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាច្រើន មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីប្រាថ្នាតិច ប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសន្តោស មិនប្រព្រឹត្តទៅ ដើម្បីសេចក្តីសន្តោស ប្រព្រឹត្តទៅ ដើម្បីច្រឡូកច្រឡំដោយពួក មិនប្រព្រឹត្តទៅ ដើម្បីស្ងាត់ចាកពួក ប្រព្រឹត្តទៅ ដើម្បីសេចក្តីខ្ជិលច្រអូស មិនប្រព្រឹត្តទៅ ដើម្បីប្រារព្ធសេចក្តីព្យាយាម ប្រព្រឹត្តទៅ ដើម្បីឲ្យគេចិញ្ចឹមក្រ មិនប្រព្រឹត្តទៅ ដើម្បីឲ្យគេចិញ្ចឹមងាយ ។ ម្នាលនាងគោតមី នាងគប្បីចាំទុកដោយពិតចុះថា នេះមិនមែនជាធម៌ នេះមិនមែនជាវិន័យ នេះមិនមែនជាពាក្យប្រៀនប្រដៅរបស់ព្រះសាស្តាទេ ។ ម្នាលនាងគោតមី មួយទៀត នាងគប្បីដឹងនូវធម៌ទាំងឡាយណា ធម៌ទាំងនេះ រមែងប្រព្រឹត្តទៅ ដើម្បីប្រាសចាកតម្រេក មិនប្រព្រឹត្តទៅ ដើម្បីប្រកបដោយតម្រេក ប្រព្រឹត្តទៅ ដើម្បីប្រាសចាកការប្រកបក្នុងវដ្តៈ មិនប្រព្រឹត្តទៅ ដើម្បីការប្រកបក្នុងវដ្តៈ

អបចយាយ សំវត្តន្តិ នោ អាចយាយ អប្បិច្ឆតាយ សំវត្តន្តិ នោ មហិច្ឆតាយ សន្តុដ្ឋិយា សំវត្តន្តិ នោ អសន្តុដ្ឋិយា បវិវេកាយ សំវត្តន្តិ នោ សង្គណិកាយ វីរិយារម្ភាយ សំវត្តន្តិ នោ កោសជ្ជាយ សុភរតាយ សំវត្តន្តិ នោ ទុព្ភរតាយាតិ ។ ឯកំសេន គោតមិ ធារេយ្យាសិ ឯសោ ធម្មោ ឯសោ វិនយោ ឯតំ សត្ថុសាសនន្តិ ។

[៥៤] ឯកំ សមយំ ភគវា កោលិយេសុ វិហរតិ កក្ករបត្តំ នាម កោលិយានំ និគមោ ។ អថខោ ទីឃជាណុ កោលិយបុត្តោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ទីឃជាណុ កោលិយបុត្តោ ភគវន្តំ ឯតទវោច មយំ ភន្តេ គិហី កាមភោគី បុត្ត-សម្ពាធសយនំ អជ្ឈាវសាម កាសិកចន្ទនំ បច្ចនុភោម

ប្រព្រឹត្តទៅ ដើម្បីមិនមានការសន្សំកិលេសវដ្ដៈ មិនប្រព្រឹត្តទៅ ដើម្បីការសន្សំកិលេសវដ្ដៈ ប្រព្រឹត្តទៅ ដើម្បីសេចក្ដីប្រាថ្នាតិច មិនប្រព្រឹត្តទៅ ដើម្បីប្រាថ្នាច្រើន ប្រព្រឹត្តទៅ ដើម្បីសេចក្ដីសន្តោស មិនប្រព្រឹត្តទៅ ដើម្បីមិនសន្តោស ប្រព្រឹត្តទៅ ដើម្បីសេចក្ដីស្ងាត់ចាកពួក មិនប្រព្រឹត្តទៅ ដើម្បីច្រឡូកច្រឡំដោយពួក ប្រព្រឹត្តទៅ ដើម្បីប្រារព្ធសេចក្ដីព្យាយាម មិនប្រព្រឹត្តទៅ ដើម្បីសេចក្ដីខ្ជិលច្រអូស ប្រព្រឹត្តទៅ ដើម្បីឲ្យគេចិញ្ចឹមងាយ មិនប្រព្រឹត្តទៅ ដើម្បីឲ្យគេចិញ្ចឹមក្រ ។ ម្នាលនាងគោតមី នាងគប្បីចាំទុក ដោយពិតចុះថា នេះជាធម៌ នេះជាវិន័យ នេះជាពាក្យប្រៀនប្រដៅ របស់ព្រះសាស្ដាហើយ ។

[៥៤] សម័យមួយ ព្រះដ៏មានព្រះភាគ ទ្រង់គង់ក្នុងនិគមឈ្មោះកក្ករបត្តៈ របស់កោឡិយក្សត្រក្នុងដែនកោឡិយៈ ។ គ្រានោះ ទីឃជាណុកោឡិយបុត្រ (កោឡិយបុត្រឈ្មោះទីឃជាណុ) ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ក្រាបថ្វាយបង្គំ ព្រះដ៏មានព្រះភាគរួចហើយអង្គុយក្នុងទីសមគួរ ។ លុះទីឃជាណុកោឡិយបុត្រ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន យើងខ្ញុំព្រះអង្គជាគ្រហស្ថ បរិភោគកាម តែងគ្រប់គ្រងទីដំណេកចង្អៀតចង្អល់ដោយកូន ប្រស់ព្រំនូវលម្អិតនៃខ្លឹមចន្ទន៍ ពីដែនកាសី

មាលាគន្ធវិលេបនំ ធារយាម ជាតរូបរជតំ សាទិយាម តេសំ នោ ភន្តេ ភគវា អម្ហាកំ តថា ធម្មំ ទេសេតុ យេ អម្ហាកំ អស្សុ ធម្មា ទិដ្ឋធម្មហិតាយ ទិដ្ឋធម្មសុខាយ សម្បរាយហិតាយ សម្បរាយសុខាយាតិ ។ ចត្តារោមេ ព្យគ្ឃបជ្ជ ធម្មា កុលបុត្តស្ស ទិដ្ឋធម្មហិតាយ សំវត្តន្តិ ទិដ្ឋធម្មសុខាយ ។ កតមេ ចត្តារោ ។ ឧដ្ឋានសម្បទា អារក្ខសម្បទា កល្យាណមិត្តតា សមជីវិតា ។ កតមា ច ព្យគ្ឃបជ្ជ ឧដ្ឋានសម្បទា ។ ឥធ ព្យគ្ឃបជ្ជ កុលបុត្តោ យេន កម្មុដ្ឋានេន[១] ជីវិកំ កប្បេតិ យទិ កសិយា យទិ វណិជ្ជាយ យទិ គោរក្ខេន យទិ ឥស្សត្ថេន យទិ រាជបោរិសេន យទិ សិប្បញ្ញតរេន តត្ថ ទក្ខោ ហោតិ អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ កាតុំ អលំ សំវិធាតុំ អយំ វុច្ចតិ ព្យគ្ឃបជ្ជ ឧដ្ឋានសម្បទា ។ កតមា ច ព្យគ្ឃបជ្ជ អារក្ខសម្បទា ។

១ ម. កម្មដ្ឋានេន ។

ទ្រទ្រង់នូវផ្កាកម្រង គ្រឿងក្រអូប គ្រឿងលាប ត្រេកអរនូវមាសនិងប្រាក់ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់សម្តែងធម៌ បែបនោះ ដល់យើងខ្ញុំទាំងឡាយនោះ ជាធម៌ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ន ដើម្បីសេចក្តីសុខក្នុងបច្ចុប្បន្ន ដើម្បីប្រយោជន៍ក្នុងបរលោក ដើម្បីសេចក្តីសុខក្នុងបរលោក ដល់យើងខ្ញុំព្រះអង្គ ។ ម្នាលព្យគ្ឃបជ្ជៈ[១] ធម៌ទាំងឡាយ ៤ ប្រការនេះ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ន ដើម្បីសេចក្តីសុខក្នុងបច្ចុប្បន្ន ដល់កុលបុត្រ ។ ធម៌ ៤ ប្រការ តើដូចម្តេច ។ គឺ ឧដ្ឋានសម្បទា ១ អារក្ខសម្បទា ១ កល្យាណមិត្តតា ១ សមជីវិតា ១ ។ ម្នាលព្យគ្ឃបជ្ជៈ ចុះឧដ្ឋានសម្បទា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រ ក្នុងលោកនេះ ចិញ្ចឹមជីវិត ដោយការប្រឹងប្រែង ក្នុងការងារណា ទោះភ្ជួររាស់ក្តី ជួញប្រែក្តី រក្សាគោក្តី ការងាររបស់ខ្មាន់ធ្នូក្តី ការងាររបស់រាជបុរសក្តី សិល្បៈណាមួយក្តី ជាអ្នកប៉ិនប្រសប់ ក្នុងការងារទាំងនោះ មិនខ្ជិលច្រអូស ប្រកបដោយឧបាយ ជាគ្រឿងពិចារណាក្នុងការងារទាំងនោះថា គួរធ្វើ គួរចាត់ចែង ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា ឧដ្ឋានសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះអារក្ខសម្បទា តើដូចម្តេច ។

---

១ ហៅតាមបវេណី ព្រោះបុព្វបុរស គឺត្រកូលរបស់បុរសនោះ កើតក្បែរផ្លូវខ្លាធំ ។ អដ្ឋកថា ។

ឥធ ព្យគ្ឃបជ្ជ កុលបុត្តស្ស ភោគា ហោន្តិ ឧដ្ឋានវីរិ-
យាធិគតា ពាហាពលបរិចិតា សេទាវក្ខិត្តា ធម្មិកា
ធម្មលទ្ធា តេ អារក្ខេន គុត្តិយា សម្បាទេតិ កិន្តិ
មេ ឥមេ ភោគេ នេវ រាជានោ ហរេយ្យុំ ន ចោរា
ហរេយ្យុំ ន អគ្គិ ឌហេយ្យ ន ឧទកំ វហេយ្យ ន
អប្បិយា ទាយាទា ហរេយ្យុន្តិ អយំ វុច្ចតិ ព្យគ្ឃបជ្ជ
អារក្ខសម្បទា ។ កតមា ច ព្យគ្ឃបជ្ជ កល្យា-
ណមិត្តតា ។ ឥធ ព្យគ្ឃបជ្ជ កុលបុត្តោ យស្មឹ
គាមេ វា និគមេ វា បដិវសតិ តត្រ យេ តេ
ហោន្តិ គហបតិ វា គហបតិបុត្តា វា ទហរា វា
វុឌ្ឍសីលិនោ វុឌ្ឍា វា វុឌ្ឍសីលិនោ សទ្ធាសម្បន្នា
សីលសម្បន្នា ចាគសម្បន្នា បញ្ញាសម្បន្នា តេហិ
សទ្ធឹ សន្តិដ្ឋតិ សល្លបតិ សាកច្ឆំ សមាបជ្ជតិ
យថារូបានំ សទ្ធាសម្បន្នានំ សទ្ធាសម្បទំ អនុសិក្ខតិ
យថារូបានំ សីលសម្បន្នានំ សីលសម្បទំ អនុសិក្ខតិ

ម្នាលព្យគ្ឃបជ្ជៈ ភោគៈទាំងឡាយ ដែលកុលបុត្រក្នុងលោកនេះ បានមកដោយកម្លាំងព្យាយាម ប្រឹងប្រែង សន្សំដោយកម្លាំងដៃ បែកញើសហូរញើស ជាភោគៈប្រកបដោយធម៌ បានមកដោយធម៌ កុលបុត្រនោះបានញ៉ាំងភោគៈទាំងនោះ ឲ្យសម្រេចដោយការរក្សាគ្រប់គ្រង ដោយគិតថា ធ្វើដូចម្តេច កុំឲ្យស្តេចទាំងឡាយ នាំយកភោគៈទាំងនេះ របស់អាត្មាអញទៅបាន កុំឲ្យពួកចោរលួចទៅបាន កុំឲ្យភ្លើងឆេះបាន កុំឲ្យទឹកបន្សាត់ទៅបាន កុំឲ្យពួកទាយាទ មិនជាទីស្រឡាញ់ ដណ្តើមយកទៅបាន ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា អារក្ខសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះកល្យាណមិត្តតា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ នៅអាស្រ័យក្នុងស្រុក ឬ និគមណា ពួកជនណា ទោះគហបតីក្តី គហបតិបុត្រក្តី ក្មេងតែចម្រើនដោយសីលក្តី ចាស់ហើយតែចម្រើនដោយសីលក្តី បរិបូណ៌ដោយសទ្ធា បរិបូណ៌ដោយសីល បរិបូណ៌ដោយចាគៈ បរិបូណ៌ដោយបញ្ញា ដែលនៅក្នុងស្រុក ឬ និគមនោះ កុលបុត្រនោះតែងឈរ ចរចា សាកច្ឆាជាមួយនឹងពួកជនទាំងនោះ តែងសិក្សានូវសទ្ធាសម្បទា នឹងពួកជនអ្នកបរិបូណ៌ ដោយសទ្ធា តាមសមគួរ សិក្សានូវសីលសម្បទា នឹងពួកជនអ្នកបរិបូណ៌ ដោយសីល តាមសមគួរ

យថារូបានំ ចាគសម្បន្នានំ ចាគសម្បទំ អនុសិក្ខតិ យថារូបានំ បញ្ញាសម្បន្នានំ បញ្ញាសម្បទំ អនុសិក្ខតិ អយំ វុច្ចតិ ព្យគ្ឃបជ្ជ កល្យាណមិត្តតា ។ កតមា ច ព្យគ្ឃបជ្ជ សមជីវិតា ។ ឥធ ព្យគ្ឃបជ្ជ កុលបុត្តោ អាយញ្ច ភោគានំ វិទិត្វា វយញ្ច ភោគានំ វិទិត្វា សមជីវិកំ កប្បេតិ នាច្ចោគាឡ្ហំ នាតិហីនំ ឯវំ មេ អាយោ វយំ បរិយាទាយ ឋស្សតិ ន ច មេ វយោ អាយំ បរិយាទាយ ឋស្សតីតិ ។ សេយ្យថាបិ ព្យគ្ឃបជ្ជ តុលាធារោ វា តុលាធារន្តេវាសី វា តុលំ បគ្គហេត្វា ជានាតិ ឯត្តកេន វា ឱនតំ ឯត្តកេន វា ឧន្នតន្តិ ឯវមេវ ខោ ព្យគ្ឃបជ្ជ កុលបុត្តោ អាយញ្ច ភោគានំ វិទិត្វា វយញ្ច ភោគានំ វិទិត្វា សមជីវិកំ កប្បេតិ នាច្ចោគាឡ្ហំ នាតិហីនំ ឯវំ មេ អាយោ វយំ បរិយាទាយ ឋស្សតិ ន ច មេ វយោ អាយំ បរិយាទាយ ឋស្សតីតិ ។

សិក្សានូវចាគសម្បទា នឹងពួកជនអ្នកបរិបូណ៌ ដោយចាគៈ តាមសមគួរ សិក្សានូវបញ្ញាសម្បទា នឹងពួកជនអ្នកបរិបូណ៌ ដោយបញ្ញាតាមសមគួរ ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា កល្យាណមិត្តតា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះសមជីវិតា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ ដឹងច្បាស់នូវការចម្រើននៃភោគៈទាំងឡាយផង ដឹងច្បាស់នូវការវិនាសទៅ នៃភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ជះ-ខ្ជាយពេក មិនក្បិតក្បៀតពេក ដោយគិតថា សេចក្តីចម្រើនរបស់អាត្មាអញ នឹងគ្របសង្កត់សេចក្តីវិនាសយ៉ាងនេះ ឯសេចក្តីវិនាសរបស់អាត្មាអញ នឹងកុំគ្របសង្កត់សេចក្តីចម្រើនបានឡើយ ។ ម្នាលព្យគ្ឃបជ្ជៈ ប្រៀបដូចជនអ្នកថ្លឹងជញ្ជីងក្តី កូនសិស្សនៃជនអ្នកថ្លឹងជញ្ជីងក្តី លើកនូវជញ្ជីង ថ្លឹង ហើយក៏ដឹងថា ទន់ទៅខាងម្ខាងផង បះឡើងខាងម្ខាងផង យ៉ាងណាមិញ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រអ្នកដឹងច្បាស់នូវការចម្រើន នៃភោគៈទាំងឡាយផង ដឹងច្បាស់នូវការវិនាសទៅ នៃភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ជះខ្ជាយពេក មិនក្បិតក្បៀតពេក ដោយគិតថា សេចក្តីចម្រើនរបស់អាត្មាអញនឹងគ្របសង្កត់សេចក្តីវិនាសយ៉ាងនេះ ឯសេចក្តីវិនាសរបស់អាត្មាអញ នឹងកុំគ្របសង្កត់សេចក្តីចម្រើនបានឡើយ ក៏យ៉ាងនោះដែរ ។

សចាយំ ព្យគ្ឃបជ្ជ កុលបុត្តោ អប្បាយោ សមានោ ឧឡារំ ជីវិកំ កប្បេតិ តស្ស ភវន្តិ វត្តារោ ឧទុម្ពរខាទកញ្ញាយំ កុលបុត្តោ ភោគេ ខាទតីតិ ។ សចេ បនាយំ ព្យគ្ឃបជ្ជ កុលបុត្តោ មហាយោ សមានោ កសិរំ ជីវិកំ កប្បេតិ តស្ស ភវន្តិ វត្តារោ អទ្ធមារកញ្ញាយំ កុលបុត្តោ មរិស្សតីតិ[1] ។ យតោ ច ខោយំ ព្យគ្ឃបជ្ជ កុលបុត្តោ អាយញ្ច ភោគានំ វិទិត្វា វយញ្ច ភោគានំ វិទិត្វា សមជីវិកំ កប្បេតិ នាច្ចោគាឡ្ហំ នាតិហីនំ ឯវំ មេ អាយោ វយំ បរិយាទាយ ឋស្សតិ ន ច មេ វយោ អាយំ បរិយាទាយ ឋស្សតីតិ អយំ វុច្ចតិ ព្យគ្ឃបជ្ជ សមជីវិតា ។ ឯវំ សមុប្បន្នានំ ព្យគ្ឃបជ្ជ ភោគានំ ចត្តារិ អបាយមុខានិ ហោន្តិ ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ បាបមិត្តោ បាបសហាយោ បាបសម្បវង្កោ ។

---

១ ឱ. អជទ្ធុមារិកំ វាយំ កុលបុត្តោ មរិស្សតីតិ ។ ម. អជេដ្ឋមរណំ វាយំ កុល-បុត្តោ មរិស្សតីតិ ។

ម្នាលព្យគ្ឃបជ្ជៈ ប្រសិនបើ កុលបុត្រនេះមានសេចក្ដីចម្រើនតិច ហើយចិញ្ចឹមជីវិតច្រើនលើសលុប អ្នកផងតែងនិយាយ ដល់កុលបុត្រនោះថា កុលបុត្រនេះ បរិភោគនូវភោគៈទាំងឡាយ ដូចជាគេស៊ីផ្លែល្វា[១] ។ ម្នាលព្យគ្ឃបជ្ជៈ ប្រសិនបើ កុលបុត្រនេះ មានសេចក្ដីចម្រើនធំ ហើយចិញ្ចឹមជីវិតដោយក្បិតក្បៀត អ្នកផងទាំងឡាយ រមែងនិយាយដល់កុលបុត្រនោះថា កុលបុត្រនេះមុខជានឹងស្លាប់ៗ ដោយឥតទីពឹង ។ ម្នាលព្យគ្ឃបជ្ជៈ កាលណាកុលបុត្រនេះ ដឹងច្បាស់នូវសេចក្ដីចម្រើន នៃភោគៈទាំង-ឡាយផង ដឹងច្បាស់នូវសេចក្ដីវិនាសនៃភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ជះខ្ជាយពេក មិនក្បិតក្បៀតពេក ដោយគិតថា សេចក្ដីចម្រើនរបស់អាត្មាអញ នឹងគ្របសង្កត់នូវសេចក្ដីវិនាសយ៉ាងនេះ ឯសេចក្ដីវិនាសរបស់អាត្មាអញ នឹងកុំគ្របសង្កត់សេចក្ដីចម្រើនបានឡើយ ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា សមជីវិតា ។ ម្នាលព្យគ្ឃបជ្ជៈ កាលដែលភោគៈទាំងឡាយ ចម្រើនឡើងយ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្ដីវិនាស ៤ យ៉ាងគឺ ជាអ្នកលេងស្រី ១ លេងសុរា ១ លេងល្បែងភ្នាល់ ១ មានមិត្រដ៏លាមក មានសំឡាញ់ដ៏លាមក សមគប់នឹងបុគ្គលដ៏លាមក ១ ។

---

១ អ្នកចង់ស៊ីផ្លែល្វា មិនបេះឲ្យល្មមតែបរិភោគឆ្អែត ទៅចាប់ដើមអង្រួន ឲ្យជ្រុះផ្លែទាំងអស់នោះតែម្ដង ហើយរើសយកតែផ្លែណាដែលគួរស៊ីបាន ផ្លែក្រៅពីនោះ នៅសល់ចោលជាច្រើន ។ អដ្ឋកថា ។

សេយ្យថាបិ ព្យគ្ឃបជ្ជ មហតោ តឡាកស្ស ចត្តារិ ចេវ អាយមុខានិ ចត្តារិ ច អបាយមុខានិ តស្ស បុរិសោ យានិ ចេវ អាយមុខានិ តានិ បិទហេយ្យ យានិ ច អបាយមុខានិ តានិ វិវរេយ្យ ទេវោ ច ន សម្មា ធារំ អនុប្បវេច្ឆេយ្យ ឯវញ្ហិ តស្ស ព្យគ្ឃបជ្ជ មហតោ តឡាកស្ស បរិហានិយេវ បាដិកង្ខា នោ វុឌ្ឍិ ឯវមេវ ខោ ព្យគ្ឃបជ្ជ ឯវំ សមុប្បន្នានំ ភោគានំ ចត្តារិ អបាយមុខានិ ហោន្តិ ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ បាបមិត្តោ បាបសហាយោ បាបសម្បវង្កោ ។ ឯវំ សមុប្បន្នានំ ព្យគ្ឃបជ្ជ ភោគានំ ចត្តារិ អាយមុខានិ ហោន្តិ ន ឥត្ថីធុត្តោ ន សុរាធុត្តោ ន អក្ខធុត្តោ កល្យាណមិត្តោ កល្យាណសហាយោ កល្យាណសម្បវង្កោ ។

ម្នាលព្យគ្ឃបជ្ជៈ ដូចស្រះទឹកដ៏ធំ មានផ្លូវនៃសេចក្តីចម្រើន ៤ យ៉ាងផង មានប្រធាននៃសេចក្តីវិនាស ៤ យ៉ាងផង បុរសគប្បីបិទខ្ទប់នូវផ្លូវនៃសេចក្តីវិនាសទាំងនោះ របស់ស្រះនោះក្តី គប្បីបើកបង្ហូរនូវផ្លូវនៃសេចក្តីវិនាសទាំងនោះ របស់ស្រះនោះក្តី ទាំងភ្លៀង ក៏មិនបង្អុរនូវជារទឹកដោយប្រពៃក្តី ម្នាលព្យគ្ឃបជ្ជៈ កាលបើយ៉ាងនេះហើយ ស្រះដ៏ធំនោះនឹងមានសេចក្តីសាបសូន្យជាប្រាកដ មិនមានសេចក្តីចម្រើនឡើយ យ៉ាងណាមិញ ម្នាលព្យគ្ឃបជ្ជៈ កាលភោគៈទាំងឡាយ ចម្រើនឡើងយ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្តីវិនាស ៤ យ៉ាងគឺ ជាអ្នកលេងស្រី ១ លេងសុរា ១ លេងល្បែងភ្នាល់ ១ មានមិត្រដ៏លាមក មានសំឡាញ់ដ៏លាមក សមគប់នឹងបុគ្គលដ៏លាមក ១ ក៏យ៉ាងនោះដែរ ។ ម្នាលព្យគ្ឃបជ្ជៈ កាលបើភោគៈទាំងឡាយ ចម្រើនឡើងយ៉ាងនេះហើយ ប្រធាននៃសេចក្តីចម្រើន ៤ យ៉ាងគឺ ជាអ្នកមិនលេងស្រី ១ មិនលេងសុរា ១ មិនលេងល្បែងភ្នាល់ ១ មានមិត្រល្អ មានសំឡាញ់ល្អ សមគប់នឹងបុគ្គលល្អ ១ ក៏មានឡើង ។

សេយ្យថាបិ ព្យគ្ឃបជ្ជ មហាតោ តឡាកស្ស ចត្តារិ ចេវ អាយមុខានិ ចត្តារិ ច អបាយមុខានិ តស្ស បុរិសោ យានិ ចេវ អាយមុខានិ តានិ វិវរេយ្យ យានិ ច អបាយមុខានិ តានិ បិទហេយ្យ ទេវោ ច សម្មា ធារំ អនុប្បវេច្ឆេយ្យ ឯវញ្ហិ តស្ស ព្យគ្ឃបជ្ជ មហាតោ តឡាកស្ស វុឌ្ឍិយេវ បាដិកង្ខា នោ បរិហានិ ឯវមេវ ខោ ព្យគ្ឃបជ្ជ ឯវំ សមុប្បន្នានំ ភោគានំ ចត្តារិ អាយមុខានិ ហោន្តិ ន ឥត្ថីធុត្តោ ន សុរាធុត្តោ ន អក្ខធុត្តោ កល្យាណមិត្តោ កល្យាណសហាយោ កល្យាណសម្បវង្កោ ។ ឥមេ ខោ ព្យគ្ឃបជ្ជ ចត្តារោ ធម្មា កុលបុត្តស្ស ទិដ្ឋធម្មហិតាយ សំវត្តន្តិ ទិដ្ឋធម្មសុខាយ ។ ចត្តារោមេ ព្យគ្ឃបជ្ជ ធម្មា កុលបុត្តស្ស សម្បរាយហិតាយ សំវត្តន្តិ សម្បរាយសុខាយ ។ កតមេ ចត្តារោ ។ សទ្ធាសម្បទា សីលសម្បទា ចាគសម្បទា បញ្ញាសម្បទា ។ កតមា ច ព្យគ្ឃបជ្ជ សទ្ធាសម្បទា ។ ឥធ ព្យគ្ឃបជ្ជ កុលបុត្តោ សទ្ធោ ហោតិ សទ្ទហតិ

ម្នាលព្យគ្ឃបជ្ជៈ ដូចស្រះដ៏ធំ មានផ្លូវនៃសេចក្ដីចម្រើន ៤ យ៉ាងផង មានប្រធាននៃសេចក្ដីវិនាស ៤ យ៉ាងផង បុរសគប្បីបើកបង្ហូរនូវផ្លូវនៃសេចក្ដីចម្រើនទាំងនោះ របស់ស្រះនោះផង គប្បីបិទនូវផ្លូវនៃសេចក្ដីវិនាសទាំងនោះ របស់ស្រះនោះផង ទាំងភ្លៀង ក៏បង្អុរចុះនូវធារទឹក ដោយប្រពៃផង ម្នាលព្យគ្ឃបជ្ជៈ កាលបើយ៉ាងនេះហើយ សេចក្ដីចម្រើនរបស់ស្រះនោះនឹងមានប្រាកដ មិនមានសេចក្ដីសាបសូន្យឡើយ យ៉ាងណាមិញ ម្នាលព្យគ្ឃបជ្ជៈ កាលបើភោគៈទាំងឡាយ ចម្រើនឡើងយ៉ាងនេះហើយ រមែងមានផ្លូវ នៃសេចក្ដីចម្រើន ៤ យ៉ាងគឺ អ្នកមិនលេងស្រី ១ មិនលេងសុរា ១ មិនលេងល្បែងភ្នាល់ ១ មានមិត្រល្អ មានសំឡាញ់ល្អ សមគប់នឹងបុគ្គលដ៏ល្អ ១ ក៏យ៉ាងនោះដែរ ។ ម្នាលព្យគ្ឃបជ្ជៈ ធម៌ទាំងឡាយ ៤ ប្រការនេះឯង ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ន ដើម្បីសេចក្ដីសុខក្នុងបច្ចុប្បន្ន ដល់កុលបុត្រ ។ ម្នាលព្យគ្ឃបជ្ជៈ ធម៌ទាំងឡាយ ៤ ប្រការនេះ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ក្នុងបរលោក ដើម្បីសេចក្ដីសុខក្នុងបរលោក ដល់កុលបុត្រ ។ ធម៌ ៤ ប្រការ តើដូចម្ដេច ។ គឺសទ្ធាសម្បទា ១ សីលសម្បទា ១ ចាគសម្បទា ១ បញ្ញាសម្បទា ១ ។ ម្នាលព្យគ្ឃបជ្ជៈ ចុះសទ្ធាសម្បទា តើដូចម្ដេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ ជាអ្នកមានសទ្ធា ជឿការត្រាស់ដឹងនៃព្រះតថាគតថា

តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ អយំ វុច្ចតិ ព្យគ្ឃបជ្ជ សទ្ធាសម្បទា ។ កតមា ច ព្យគ្ឃបជ្ជ សីលសម្បទា ។ ឥធ ព្យគ្ឃបជ្ជ កុលបុត្តោ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ អយំ វុច្ចតិ ព្យគ្ឃបជ្ជ សីលសម្បទា ។ កតមា ច ព្យគ្ឃបជ្ជ ចាគសម្បទា ។ ឥធ ព្យគ្ឃបជ្ជ កុលបុត្តោ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ មុត្តចាគោ បយតបាណី វោស្សគ្គរតោ យាចយោគោ ទានសំវិភាគ-រតោ អយំ វុច្ចតិ ព្យគ្ឃបជ្ជ ចាគសម្បទា ។ កតមា ច ព្យគ្ឃបជ្ជ បញ្ញាសម្បទា ។ ឥធ ព្យគ្ឃបជ្ជ កុលបុត្តោ បញ្ញវា ហោតិ ឧទយត្ថគាមិនិយា បញ្ញាយ សមន្នាគតោ អរិយាយ និព្វេធិកាយ សម្មាទុក្ខក្ខយគាមិនិយា អយំ វុច្ចតិ ព្យគ្ឃបជ្ជ បញ្ញាសម្បទា ។ ឥមេ ខោ ព្យគ្ឃបជ្ជ ចត្តារោ ធម្មា កុលបុត្តស្ស សម្បរាយហិតាយ សំវត្តន្តិ សម្បរាយសុខាយាតិ ។

ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ជាសាស្តានៃទេវតានិងមនុស្សទាំង-ឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀតហើយ ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា សទ្ធាសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះសីលសម្បទា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុល-បុត្រក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត ។ បេ ។ វៀរចាកសុរា-មេរយមជ្ជប្បមាទដ្ឋាន ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា សីលសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះចាគសម្បទា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគរួចស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ គួរដល់ស្មូម ត្រេកអរ ក្នុងការចែករលែកនូវទាន ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា ចាគសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ចុះបញ្ញា-សម្បទា តើដូចម្តេច ។ ម្នាលព្យគ្ឃបជ្ជៈ កុលបុត្រក្នុងលោកនេះ មានប្រាជ្ញា ប្រកបដោយប្រាជ្ញា ជាដំណើរយល់ការសេចក្តីចម្រើន និងសេចក្តីវិនាស ជាប្រាជ្ញាដ៏ប្រសើរ មោះមុត ជាដំណើរយល់ការដែលអស់ទៅនៃទុក្ខដោយប្រពៃ ម្នាលព្យគ្ឃបជ្ជៈ នេះហៅថា បញ្ញាសម្បទា ។ ម្នាលព្យគ្ឃបជ្ជៈ ធម៌ទាំង ៨ យ៉ាងនេះឯង រមែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ក្នុងបរលោក ដើម្បីសេចក្តីសុខក្នុងបរលោក ដល់កុលបុត្រ ។

ឧដ្ឋាតា កម្មធេយ្យេសុ  អប្បមត្តោ វិធានវា
សមំ កប្បេតិ ជីវិតំ  សម្ភតំ អនុរក្ខតិ
សទ្ធោ សីលេន សម្បន្នោ វទញ្ញូ វីតមច្ឆរោ
និច្ចំ មគ្គំ វិសោធេតិ  សោត្ថានំ សម្បរាយិកំ
ឥច្ចេតេ អដ្ឋ ធម្មា ច  សទ្ធស្ស ឃរមេសិនោ
អក្ខាតា សច្ចនាមេន  ឧភយត្ថ សុខាវហា
ទិដ្ឋធម្មហិតត្ថាយ  សម្បរាយសុខាយ ច
ឯវមេតំ គហដ្ឋានំ  ចាគោ បុញ្ញំ បវឌ្ឍតីតិ ។

[៥៥] អថខោ ឧជ្ជយោ ព្រាហ្មណោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវតា សទ្ធឹ សម្មោទិ សម្មោទនីយំ កថំ សារាណីយំ វីតិសារេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ ឧជ្ជយោ ព្រាហ្មណោ ភគវន្តំ ឯតទវោច មយំ ភោ គោតម[១] បវាសំ គន្តុកាមា

១ ឱ. មយំ អស្សុ ភោ គោតម ។

កុលបុត្រ អ្នកមានព្យាយាមប្រឹងប្រែង ក្នុងទីនៃការងារទាំង-ឡាយ ១ មិនប្រហែសធ្វេសមានការចាត់ចែង ១ ចិញ្ចឹមជីវិតស្មើ ១ ចេះថែរក្សាទ្រព្យ ដែលរកបានមក ១ មានសទ្ធា ១ បរិបូណ៌ ដោយសីល ១ ដឹងនូវពាក្យពេចន៍ ១ ប្រាសចាកសេចក្តីកំណាញ់ រមែងជម្រះនូវផ្លូវមានសួស្តី ជាផ្លូវទៅកាន់បរ-លោកជានិច្ច ១ ធម៌ទាំង ៨ ប្រការនេះ តែងនាំមកនូវសេចក្តីសុខក្នុងលោកទាំងពីរដែលព្រះដ៏មានព្រះភាគព្រះអង្គជាសច្ច-នាម ទ្រង់សម្តែងហើយ ដល់កុលបុត្រអ្នកមានសទ្ធា ស្វែងរកផ្ទះ ដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខក្នុងបរលោកផង ដោយប្រការដូច្នេះ ការបរិច្ចាគនិងបុណ្យនេះតែងចម្រើន ដល់គ្រហស្ថទាំងឡាយយ៉ាងនេះឯង ។

[៥៥] លំដាប់នោះ ឧជ្ជយព្រាហ្មណ៍ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏និយាយរីករាយជាមួយនឹងព្រះដ៏មានព្រះភាគ លុះបញ្ចប់ពាក្យ ដែលគួររីករាយ និងពាក្យដែលគួររលឹកហើយ ក៏អង្គុយក្នុងទីសមគួរ ។ លុះឧជ្ជយព្រាហ្មណ៍ អង្គុយក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគ ដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន យើងខ្ញុំមានប្រាថ្នា ដើម្បីទៅឃ្លាតចេញអំពីស្រុក

តេសន្នោ ភវំ គោតមោ អម្ហាកំ តថា ធម្មំ ទេសេតុ យេ អម្ហាកំ អស្ស ធម្មា ទិដ្ឋធម្មហិតាយ ទិដ្ឋធម្មសុខាយ សម្បរាយហិតាយ សម្បរាយសុខាយាតិ ។ ចត្តារោមេ ព្រាហ្មណ ធម្មា កុលបុត្តស្ស ទិដ្ឋធម្មហិតាយ សំវត្តន្តិ ទិដ្ឋធម្មសុខាយ ។ កតមេ ចត្តារោ ។ ឧដ្ឋានសម្បទា អារក្ខសម្បទា កល្យាណមិត្តតា សមជីវិតា ។ កតមា ច ព្រាហ្មណ ឧដ្ឋានសម្បទា ។ ឥធ ព្រាហ្មណ កុល-បុត្តោ យេន កម្មដ្ឋានេន ជីវិកំ កប្បេតិ យទិ កសិយា យទិ វណិជ្ជាយ យទិ គោរក្ខេន យទិ ឥស្សត្ថេន យទិ រាជបោរិសេន យទិ សិប្បញ្ញតរេន តត្ថ ទក្ខោ ហោតិ អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ កាតុំ អលំ សំវិធាតុំ អយំ វុច្ចតិ ព្រាហ្មណ ឧដ្ឋាន-សម្បទា ។ កតមា ច ព្រាហ្មណ អារក្ខសម្បទា ។ ឥធ ព្រាហ្មណ កុលបុត្តស្ស ភោគា ហោន្តិ ឧដ្ឋានវីរិ-យាធិគតា ពាហាពលបរិចិតា សេទាវក្ខិត្តា ធម្មិកា

ធម៌ទាំងឡាយណា ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្ន ដើម្បីសេចក្តីសុខ ក្នុងបច្ចុប្បន្ន ដើម្បីប្រយោជន៍ ក្នុងបរលោក ដើម្បីសេចក្តីសុខ ក្នុងបរលោក គប្បីមានដល់ពួកយើងខ្ញុំ សូមព្រះគោតមដ៏ចម្រើន ទ្រង់សម្តែងនូវធម៌នោះដល់យើងខ្ញុំ ។ ព្រះអង្គទ្រង់ត្រាស់ថា ម្នាលព្រាហ្មណ៍ ធម៌ទាំងឡាយ ៤ ប្រការនេះ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្ន ដើម្បីសេចក្តីសុខ ក្នុងបច្ចុប្បន្ន ដល់កុលបុត្រ ។ ធម៌ ៤ ប្រការ តើដូចម្តេច ។ គឺ ឧដ្ឋានសម្បទា ១ អារក្ខសម្បទា ១ កល្យាណមិត្តតា ១ សមជីវិតា ១ ។ ម្នាលព្រាហ្មណ៍ ចុះឧដ្ឋានសម្បទា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កុលបុត្រក្នុងលោកនេះ ចិញ្ចឹមជីវិតដោយការប្រឹងប្រែងក្នុងការងារណា ទោះភ្ជួរក្តី ជួញប្រែក្តី រក្សាគោក្តី ការងាររបស់ខ្មាន់ធ្នូក្តី ការងាររបស់រាជបុរសក្តី សិល្បៈណាមួយក្តី ជាអ្នកប៉ិនប្រសប់ក្នុងការងារទាំងនោះ មិនខ្ជិលច្រអូស ប្រកបដោយឧបាយជាគ្រឿងពិចារណា ក្នុងការងារទាំងនោះថា គួរធ្វើ គួរចាត់ចែង ម្នាលព្រាហ្មណ៍ នេះហៅថា ឧដ្ឋានសម្បទា ។ ម្នាលព្រាហ្មណ៍ ចុះអារក្ខសម្បទា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ ភោគៈទាំងឡាយ ដែលកុលបុត្រក្នុងលោកនេះ បានមកដោយកម្លាំងព្យាយាម ប្រឹងប្រែង សន្សំដោយកម្លាំងដៃ បែកញើស ហូរញើស ជាភោគៈ ប្រកបដោយធម៌

ធម្មលទ្ធា តេ អារក្ខេន គុត្តិយា សម្បាទេតិ កិន្តិ មេ ឥមេ ភោគេ នេវ រាជានោ ហរេយ្យុំ ន ចោរា ហរេយ្យុំ ន អគ្គិ ឌហេយ្យ ន ឧទកំ វហេយ្យ ន អប្បិយា ទាយាទា ហរេយ្យុន្តិ អយំ វុច្ចតិ ព្រាហ្មណ អារក្ខសម្បទា ។ កតមា ច ព្រាហ្មណ កល្យាណមិត្តតា ។ ឥធ ព្រាហ្មណ កុលបុត្តោ យស្មឹ គាមេ វា និគមេ វា បដិវសតិ តត្រ យេ តេ ហោន្តិ គហបតិ វា គហបតិបុត្តា វា ទហរា វា វុឌ្ឍសីលិនោ វុឌ្ឍា វា វុឌ្ឍសីលិនោ សទ្ធាសម្បន្នា សីលសម្បន្នា ចាគសម្បន្នា បញ្ញាសម្បន្នា តេហិ សទ្ធឹ សន្តិដ្ឋតិ សល្លបតិ សាកច្ឆំ សមាបជ្ជតិ យថារូបានំ សទ្ធាសម្បន្នានំ សទ្ធាសម្បទំ អនុសិក្ខតិ យថារូបានំ សីលសម្បន្នានំ សីលសម្បទំ អនុសិក្ខតិ យថារូបានំ ចាគសម្បន្នានំ ចាគសម្បទំ អនុសិក្ខតិ យថារូបានំ បញ្ញាសម្បន្នានំ បញ្ញាសម្បទំ អនុសិក្ខតិ អយំ វុច្ចតិ ព្រាហ្មណ កល្យាណមិត្តតា ។

កុលបុត្រនោះ រមែងញ៉ាំងភោគៈទាំងនោះ ឲ្យសម្រេចដោយការរក្សាគ្រប់-គ្រងដោយគិតថាធ្វើដូចម្តេច កុំឲ្យស្តេចទាំងឡាយ នាំយកភោគៈទាំងនេះរបស់អាត្មាអញទៅបាន កុំឲ្យពួកចោរលួចយកទៅបាន កុំឲ្យភ្លើងឆេះបាន កុំឲ្យទឹកបន្សាត់ទៅបាន កុំឲ្យពួកទាយាទ មិនជាទីស្រឡាញ់ ដណ្តើមយកទៅបាន ម្នាលព្រាហ្មណ៍ នេះហៅថាអារក្ខសម្បទា ។ ម្នាលព្រាហ្មណ៍ ចុះកល្យាណមិត្តតាតើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កុលបុត្រក្នុងលោកនេះ នៅអាស្រ័យក្នុងស្រុកឬនិគមណា ពួកជនណា ទោះគហបតីក្តី គហបតិ-បុត្រក្តី ក្មេងតែចម្រើនដោយសីល ចាស់ហើយតែចម្រើនដោយសីល បរិបូណ៌ដោយសទ្ធា បរិបូណ៌ដោយសីល បរិបូណ៌ដោយចាគៈ បរិបូណ៌ដោយបញ្ញា មាននៅក្នុងស្រុក ឬនិគមនោះ (កុលបុត្រនោះ) រមែងឈរ ចរចា សាកច្ឆាជាមួយនឹងពួកជនទាំងនោះ តែងសិក្សានូវសទ្ធាសម្បទា នឹងពួកជនអ្នកបរិបូណ៌ ដោយសទ្ធា តាមសមគួរ សិក្សានូវសីល-សម្បទា នឹងពួកជនអ្នកបរិបូណ៌ ដោយសីល តាមសមគួរ សិក្សានូវចាគសម្បទា នឹងពួកជន អ្នកបរិបូណ៌ ដោយចាគៈ តាមសមគួរ សិក្សានូវបញ្ញាសម្បទា នឹងពួកជន អ្នកបរិបូណ៌ ដោយបញ្ញា តាមសមគួរ ម្នាលព្រាហ្មណ៍ នេះហៅថា កល្យាណមិត្តតា ។

កតមា ច ព្រាហ្មណា សមជីវិតា ។ ឥធ ព្រាហ្មណា កុលបុត្តោ អាយញ្ច ភោគានំ វិទិត្វា វយញ្ច ភោគានំ វិទិត្វា សមជីវិកំ កប្បេតិ ឆាច្ចាគាឡ្ហំ ឆាតិហីនំ ឯវំ មេ អាយោ វយំ បរិយាទាយ ឋស្សតិ ន ច មេ វយោ អាយំ បរិយាទាយ ឋស្សតីតិ ។ សេយ្យថាបិ ព្រាហ្មណា តុលាធារោ វា តុលាធារន្តេវាសី វា តុលំ បគ្គហេត្វា ជានាតិ ឯត្តកេន វា ឱនតំ ឯត្តកេន វា ឧន្នតន្តិ ឯវមេវ ខោ ព្រាហ្មណា កុលបុត្តោ អាយញ្ច ភោគានំ វិទិត្វា វយញ្ច ភោគានំ វិទិត្វា សមជីវិកំ កប្បេតិ ឆាច្ចាគាឡ្ហំ ឆាតិហីនំ ឯវំ មេ អាយោ វយំ បរិយាទាយ ឋស្សតិ ន ច មេ វយោ អាយំ បរិយាទាយ ឋស្សតីតិ ។ សចាយំ ព្រាហ្មណា កុលបុត្តោ អប្បាយោ សមានោ ឧឡារំ ជីវិកំ កប្បេតិ តស្ស ភវន្តិ វត្តារោ ឧទុម្ពរខាទកញ្ចាយំ កុលបុត្តោ ភោគេ ខាទតីតិ ។ សចេ បនាយំ ព្រាហ្មណា កុលបុត្តោ មហាយោ សមានោ

ម្នាលព្រាហ្មណ៍ ចុះសមជីវិតា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កុលបុត្រ ក្នុងលោកនេះ ដឹងច្បាស់នូវការចម្រើន នៃភោគៈទាំងឡាយផង ដឹងច្បាស់ នូវការវិនាសទៅ នៃភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ជះ-ខ្ជាយពេក មិនក្បិតក្បៀតពេក ដោយគិតថា សេចក្តីចម្រើនរបស់អាត្មាអញ នឹងគ្របសង្កត់សេចក្តីវិនាសយ៉ាងនេះ ឯសេចក្តីវិនាស របស់អាត្មាអញ នឹងកុំគ្របសង្កត់សេចក្តីចម្រើនបានឡើយ ។ ម្នាលព្រាហ្មណ៍ ប្រៀបដូចជន អ្នកថ្លឹងជញ្ជីងក្តី កូនសិស្សនៃជនអ្នកថ្លឹងជញ្ជីងក្តី លើកនូវជញ្ជីងថ្លឹងហើយ ក៏ដឹងថា ទន់ទៅខាងម្ខាង បះឡើងខាងម្ខាងផង យ៉ាងណាមិញ ម្នាល ព្រាហ្មណ៍ កុលបុត្រអ្នកដឹងច្បាស់នូវការចម្រើន នៃភោគៈទាំងឡាយផង ដឹងច្បាស់នូវការវិនាសទៅ នៃភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ជះខ្ជាយពេក មិនក្បិតក្បៀតពេក ដោយគិតថា សេចក្តីចម្រើនរបស់ អាត្មាអញ នឹងគ្របសង្កត់សេចក្តីវិនាសយ៉ាងនេះ ឯសេចក្តីវិនាសរបស់ អាត្មាអញ នឹងកុំគ្របសង្កត់សេចក្តីចម្រើនបានឡើយ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ ប្រសិនបើ កុលបុត្រនេះមានសេចក្តីចម្រើនតិច តែចិញ្ចឹម ជីវិតច្រើនលើសលុប អ្នកផងទាំងឡាយ តែងនិយាយដល់កុលបុត្រ នោះថា កុលបុត្រនេះ បរិភោគនូវភោគៈទាំងឡាយ ដូចជាគេស៊ីផ្លែល្វា ។ ម្នាលព្រាហ្មណ៍ ប្រសិនបើ កុលបុត្រនេះ មានសេចក្តីចម្រើនធំ

កសិំ ជីវិកំ កប្បេតិ តស្ស ភវន្តិ វត្តារោ អជ្ឈមារ-កញ្ញាយំ កុលបុត្តោ មរិស្សតីតិ ។ យតោ ច ខោយំ ព្រាហ្មណ កុលបុត្តោ អាយញ្ច ភោគានំ វិទិត្វា វយញ្ច ភោគានំ វិទិត្វា សមជីវិកំ កប្បេតិ នាច្ចោគាឡ្ហំ នាតិហីនំ ឯវំ មេ អាយោ វយំ បរិយាទាយ ឋស្សតិ ន ច មេ វយោ អាយំ បរិយាទាយ ឋស្សតីតិ អយំ វុច្ចតិ ព្រាហ្មណ សមជីវិតា ។ ឯវំ សមុប្បន្នានំ ព្រាហ្មណ ភោគានំ ចត្តារិ អបាយមុខានិ ហោន្តិ ឥត្ថីធុត្តោ សុរា-ធុត្តោ អក្ខធុត្តោ បាបមិត្តោ បាបសហាយោ បាបសម្ប-វង្កោ ។ សេយ្យថាបិ ព្រាហ្មណ មហតោ តឡាកស្ស ចត្តារិ ចេវ អាយមុខានិ ចត្តារិ ច អបាយមុខានិ តស្ស បុរិសោ យានិ ចេវ អាយមុខានិ តានិ បិទហេយ្យ យានិ ច អបាយមុខានិ តានិ វិវរេយ្យ ទេវោ ច ន សម្មា ធារំ អនុប្បវេច្ឆេយ្យ ឯវញ្ហិ តស្ស ព្រាហ្មណ មហតោ តឡាកស្ស បរិហានិយេវ បាដិកង្ខា នោ វុឌ្ឍិ

តែចិញ្ចឹមជីវិត ដោយក្បិតក្បៀត អ្នកផងទាំងឡាយ រមែងនិយាយដល់កុលបុត្រនោះថា កុលបុត្រនេះ មុខជានឹងស្លាប់ៗ ដោយឥតទីពឹង ។ ម្នាលព្រាហ្មណ៍ កាលណាកុលបុត្រនេះ ដឹងច្បាស់នូវការចម្រើន នៃភោគៈទាំង-ឡាយផង ដឹងច្បាស់នូវការវិនាសទៅ នៃភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនខ្ជះខ្ជាយពេក មិនក្បិតក្បៀតពេក ដោយគិតថាសេចក្តីចម្រើនរបស់អាត្មាអញ នឹងគ្របសង្កត់នូវសេចក្តីវិនាស យ៉ាងនេះឯសេចក្តីវិនាសរបស់អាត្មាអញ នឹងកុំគ្របសង្កត់សេចក្តីចម្រើន បានឡើយម្នាលព្រាហ្មណ៍ នេះហៅថា សមជីវិតា ។ ម្នាលព្រាហ្មណ៍ កាលដែលភោគៈទាំងឡាយ ចម្រើនឡើងយ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្តីវិនាស ៤ ប្រការ គឺជាអ្នកលេងស្រី ១ លេងសុរា ១ លេងល្បែងភ្នាល់ ១ មានមិត្រលាមក មានសំឡាញ់លាមក សមគប់នឹងបុគ្គលលាមក ១ ។ ម្នាលព្រាហ្មណ៍ ដូចស្រះធំមានផ្លូវនៃសេចក្តីចម្រើន ៤ ផង មានផ្លូវនៃសេចក្តីវិនាស ៤ ផង បុរសគប្បីបិទខ្ទប់នូវផ្លូវនៃសេចក្តីចម្រើនទាំងនោះរបស់ស្រះនោះផង គប្បីបើកបង្ហូរ នូវផ្លូវនៃសេចក្តីវិនាស ទាំងនោះរបស់ស្រះនោះផង ទាំងភ្លៀងសោត ក៏មិនបង្អុរនូវធារទឹក ដោយប្រពៃផង ម្នាលព្រាហ្មណ៍ កាលបើយ៉ាងនេះ ស្រះដ៏ធំនោះ នឹងមានសេចក្តីសាបសូន្យ ជាប្រាកដ មិនមានសេចក្តីចម្រើនឡើយ យ៉ាងណាមិញ

ឯវមេវ ខោ ព្រាហ្មណ ឯវំ សមុប្បន្នានំ ភោគានំ ចត្តារិ អបាយមុខានិ ហោន្តិ ឥត្ថីធុត្តោ សុរាធុត្តោ អក្ខធុត្តោ បាបមិត្តោ បាបសហាយោ បាបសម្បវង្កោ ។ ឯវំ សមុប្បន្នានំ ព្រាហ្មណ ភោគានំ ចត្តារិ អាយមុខានិ ហោន្តិ ន ឥត្ថីធុត្តោ ន សុរាធុត្តោ ន អក្ខធុត្តោ កល្យាណមិត្តោ កល្យាណសហាយោ កល្យាណសម្បវង្កោ ។ សេយ្យថាបិ ព្រាហ្មណ មហតោ តឡាកស្ស ចត្តារិ ចេវ អាយមុខានិ ចត្តារិ ច អបាយមុខានិ តស្ស បុរិសោ យានិ ចេវ អាយមុខានិ តានិ វិវរេយ្យ យានិ ច អបាយមុខានិ តានិ បិទហេយ្យ ទេវោ ច សម្មា ធារំ អនុប្បវេច្ឆេយ្យ ឯវញ្ហិ តស្ស ព្រាហ្មណ មហតោ តឡាកស្ស វុឌ្ឍិយេវ បាដិកង្ខា នោ បរិហានិ

ម្នាលព្រាហ្មណ៍ កាលដែលភោគៈទាំងឡាយ ចម្រើនឡើង យ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្តីវិនាស ៤ យ៉ាង គឺ ជាអ្នកលេងស្រី ១ លេងសុរា ១ លេងល្បែងភ្នាល់ ១ មានមិត្រលាមក មានសំឡាញ់លាមក សមគប់នឹងបុគ្គលលាមក ១ ក៏យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ កាលដែលភោគៈទាំងឡាយ ចម្រើនឡើង យ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្តីចម្រើន ៤ ប្រការ គឺជាអ្នកមិនលេងស្រី ១ មិនលេងសុរា ១ មិនលេងល្បែងភ្នាល់ ១ មានមិត្រល្អ មានសំឡាញ់ល្អ សមគប់នឹងបុគ្គលល្អ ១ ។ ម្នាលព្រាហ្មណ៍ ស្រះធំមានផ្លូវនៃសេចក្តីចម្រើន ៤ ផង មានផ្លូវនៃសេចក្តីវិនាស ៤ ផង បុរសគប្បីបើកបង្ហូរនូវផ្លូវនៃសេចក្តីចម្រើនទាំងនោះ របស់ស្រះនោះផង គប្បីបិទនូវផ្លូវនៃសេចក្តីវិនាសទាំងនោះ របស់ស្រះនោះផង ទាំងភ្លៀងសោត ក៏បង្អុរចុះនូវធារទឹកដោយប្រពៃផង ម្នាលព្រាហ្មណ៍ កាលបើយ៉ាងនេះហើយ សេចក្តីចម្រើនរបស់ស្រះនោះនឹងមានប្រាកដ មិនមានសេចក្តីសាបសូន្យឡើយ យ៉ាងណាមិញ

២៤៧



ឯវមេវ ខោ ព្រាហ្មណ ឯវំ សមុប្បន្នានំ ភោគានំ ចត្តារិ អាយមុខានិ ហោន្តិ ន ឥត្ថីធុត្តោ ។ បេ ។ កល្យាណសម្បវង្កោ ។ ឥមេ ខោ ព្រាហ្មណ ចត្តារោ ធម្មា កុលបុត្តស្ស ទិដ្ឋធម្មហិតាយ សំវត្តន្តិ ទិដ្ឋធម្ម-សុខាយ ។ ចត្តារោមេ ព្រាហ្មណ ធម្មា កុលបុត្តស្ស សម្បរាយហិតាយ សំវត្តន្តិ សម្បរាយសុខាយ ។ កតមេ ចត្តារោ ។ សទ្ធាសម្បទា សីលសម្បទា ចាគសម្បទា បញ្ញាសម្បទា ។ កតមា ច ព្រាហ្មណ សទ្ធាសម្បទា ។ ឥធ ព្រាហ្មណ កុលបុត្តោ សទ្ធោ ហោតិ សទ្ទហតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ អយំ វុច្ចតិ ព្រាហ្មណ សទ្ធាសម្បទា ។ កតមា ច ព្រាហ្មណ សីលសម្បទា ។ ឥធ ព្រាហ្មណ កុលបុត្តោ បាណាតិ-បាតា បដិវិរតោ ហោតិ ។ បេ ។ សុរាមេរយមជ្ជប្បមាទ-ដ្ឋានា បដិវិរតោ ហោតិ អយំ វុច្ចតិ ព្រាហ្មណ សីល-សម្បទា ។ កតមា ច ព្រាហ្មណ ចាគសម្បទា ។

ម្នាលព្រាហ្មណ៍ កាលបើភោគៈទាំងឡាយ ចម្រើនឡើង យ៉ាងនេះហើយ រមែងមានផ្លូវនៃសេចក្តីចម្រើន ៤ ប្រការ គឺជាអ្នកមិនលេងស្ត្រី ១ ។ បេ ។ សមគប់នឹងបុគ្គលល្អ ១ យ៉ាងនោះដែរ ។ ម្នាលព្រាហ្មណ៍ ធម៌ទាំងឡាយ ៤ ប្រការនេះឯង តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្ន ដើម្បីសេចក្តីសុខ ក្នុងបច្ចុប្បន្ន ដល់កុលបុត្រ ។ ម្នាលព្រាហ្មណ៍ ធម៌ទាំង-ឡាយ ៤ ប្រការនេះ ប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ក្នុងបរលោក ដើម្បីសេចក្តីសុខ ក្នុងបរលោក ដល់កុលបុត្រ ។ ធម៌ ៤ ប្រការ តើដូចម្តេច ។ គឺសទ្ធាសម្បទា ១ សីលសម្បទា ១ ចាគសម្បទា ១ បញ្ញា-សម្បទា ១ ។ ម្នាលព្រាហ្មណ៍ ចុះសទ្ធាសម្បទា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កុលបុត្រក្នុងលោកនេះ ជាអ្នកមានសទ្ធា ជឿនូវការត្រាស់ដឹងនៃព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ជាសាស្តានៃទេវតានិងមនុស្សទាំងឡាយ ទ្រង់ត្រាស់ដឹងនូវចតុរារិយសច្ច ទ្រង់លែងវិលត្រឡប់មកកាន់ភពថ្មីទៀតហើយ ម្នាលព្រាហ្មណ៍ នេះហៅថា សទ្ធាសម្បទា ។ ម្នាលព្រាហ្មណ៍ ចុះសីលសម្បទា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កុលបុត្រក្នុងលោកនេះ ជាអ្នកវៀរចាកបាណាតិបាត ។ បេ ។ វៀរចាកសុរាមេរយមជ្ជប្បមាទដ្ឋាន ម្នាលព្រាហ្មណ៍ នេះហៅថា សីលសម្បទា ។ ម្នាលព្រាហ្មណ៍ ចុះចាគសម្បទា តើដូចម្តេច ។

ឥធ ព្រាហ្មណ កុលបុត្តោ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ មុត្តចាគោ បយតបាណិ វោ-ស្សគ្គរតោ យាចយោគោ ទានសំវិភាគរតោ អយំ វុច្ចតិ ព្រាហ្មណ ចាគសម្បទា ។ កតមា ច ព្រាហ្មណ បញ្ញាសម្បទា ។ ឥធ ព្រាហ្មណ កុលបុត្តោ បញ្ញវា ហោតិ ។ បេ ។ សម្មាទុក្ខក្ខយគាមិនិយា អយំ វុច្ចតិ ព្រាហ្មណ បញ្ញាសម្បទា ។ ឥមេ ខោ ព្រាហ្មណ ចត្តារោ ធម្មា កុលបុត្តស្ស សម្បរាយហិតាយ សំវត្តន្តិ សម្បរាយសុខាយាតិ ។

ឧដ្ឋាតា កម្មធេយ្យេសុ អប្បមត្តោ វិធានវា
សមំ កប្បេតិ ជីវិតំ សម្ភតំ អនុរក្ខតិ
សទ្ធោ សីលេន សម្បន្នោ វទញ្ញូ វីតមច្ឆរោ
និច្ចំ មគ្គំ វិសោធេតិ សោត្ថានំ សម្បរាយិកំ
ឥច្ចេតេ អដ្ឋ ធម្មា ច សទ្ធស្ស ឃរមេសិនោ
អក្ខាតា សច្ចនាមេន ឧភយត្ថ សុខាវហា

ម្នាលព្រាហ្មណ៍ កុលបុត្រក្នុងលោកនេះ មានចិត្តប្រាសចាកមន្ទិលគឺសេចក្តីកំណាញ់ នៅគ្រប់គ្រងផ្ទះ មានទានបរិច្ចាគរួចស្រឡះហើយ មានដៃលាងហើយ ត្រេកអរក្នុងការលះបង់ ជាអ្នកគួរដល់ស្នូម ត្រេកអរក្នុងការចែករំលែកនូវទាន ម្នាលព្រាហ្មណ៍ នេះហៅថា ចាគសម្បទា ។ ម្នាលព្រាហ្មណ៍ ចុះបញ្ញាសម្បទា តើដូចម្តេច ។ ម្នាលព្រាហ្មណ៍ កុលបុត្រក្នុងលោកនេះ ជាអ្នកមានប្រាជ្ញា ។ បេ ។ ជាដំណើរយល់ការដែលអស់ទៅនៃទុក្ខដោយប្រពៃ ម្នាលព្រាហ្មណ៍ នេះហៅថា បញ្ញាសម្បទា ។ ម្នាលព្រាហ្មណ៍ ធម៌ទាំងឡាយ ៤ ប្រការនេះឯង តែងប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ ក្នុងបរលោក ដើម្បីសេចក្តីសុខ ក្នុងបរលោកដល់កុលបុត្រ ។

កុលបុត្រអ្នកមានព្យាយាម ប្រឹងប្រែង ក្នុងទីនៃការងារទាំងឡាយ ១ មិនប្រហែសធ្វេសមានការចាត់ចែង ១ ចិញ្ចឹមជីវិតស្មើ ១ ចេះថែរក្សាទ្រព្យដែលរកបានមក ១ មានសទ្ធា ១ បរិបូណ៌ដោយសីល ១ ដឹងនូវពាក្យពេចន៍ ១ ប្រាសចាកសេចក្តីកំណាញ់ ជម្រះនូវផ្លូវមានសួស្តី ជាផ្លូវទៅកាន់បរលោកជានិច្ច ១ ធម៌ទាំង ៨ ប្រការនេះ តែងនាំមកនូវសេចក្តីសុខក្នុងលោកទាំងពីរ ដែលព្រះដ៏មានព្រះភាគ ព្រះអង្គជាសច្ចនាម ទ្រង់សម្តែងដល់កុលបុត្រអ្នកមានសទ្ធា ស្វែងរកផ្ទះ

និជ្ជជម្មហិតត្ថាយ សម្បរាយសុខាយ ច
ឯវមេតំ គហដ្ឋានំ ចាគោ បុញ្ញំ បវឌ្ឍតីតិ ។

[៤៦] ភយន្តិ ភិក្ខវេ កាមានមេតំ អធិវចនំ ទុក្ខន្តិ ភិក្ខវេ កាមានមេតំ អធិវចនំ រោគោតិ ភិក្ខវេ កាមានមេតំ អធិវចនំ គណ្ឌោតិ ភិក្ខវេ កាមានមេតំ អធិវចនំ សល្លន្តិ ភិក្ខវេ កាមានមេតំ អធិវចនំ សង្គោតិ ភិក្ខវេ កាមានមេតំ អធិវចនំ បង្កោតិ ភិក្ខវេ កាមានមេតំ អធិវចនំ គព្ភោតិ ភិក្ខវេ កាមានមេតំ អធិវចនំ ។ កស្មា ច ភិក្ខវេ ភយន្តិ កាមានមេតំ អធិវចនំ ។ យស្មា ច កាមរាគរត្តាយំ ភិក្ខវេ ឆន្ទរាគវិនិពទ្ធោ និជ្ជជម្មិកាបិ ភយា ន បរិមុច្ចតិ សម្បរាយិកាបិ ភយា ន បរិមុច្ចតិ តស្មា ភយន្តិ កាមានមេតំ អធិវចនំ ។ កស្មា ច ភិក្ខវេ ទុក្ខន្តិ ។ បេ ។ រោគោតិ គណ្ឌោតិ សល្លន្តិ សង្គោតិ បង្កោតិ ។

ដើម្បីប្រយោជន៍ ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខ ក្នុងបរលោកផង ដោយប្រការដូច្នេះ ការបរិច្ចាគនិងបុណ្យនេះ តែងចម្រើន ដល់គ្រហស្ថទាំងឡាយ យ៉ាងនេះឯង ។

[៥៦] ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភ័យនេះ ជាឈ្មោះរបស់កាម ម្នាលភិក្ខុទាំងឡាយ ពាក្យថា ទុក្ខនេះ ជាឈ្មោះរបស់កាម ម្នាលភិក្ខុទាំង-ឡាយ ពាក្យថា រោគនេះ ជាឈ្មោះរបស់កាម ម្នាលភិក្ខុទាំងឡាយ ពាក្យថា ពកនេះ ជាឈ្មោះរបស់កាម ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រួញនេះ ជាឈ្មោះរបស់កាម ម្នាលភិក្ខុទាំងឡាយ ពាក្យថា ជាប់ជំពាក់នេះ ជាឈ្មោះរបស់កាម ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភក់នេះ ជាឈ្មោះរបស់កាម ម្នាលភិក្ខុទាំងឡាយ ពាក្យថា គភ៌នេះ ជាឈ្មោះរបស់កាម ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូចម្តេច បានជាពាក្យថា ភ័យនេះ ជាឈ្មោះរបស់កាម ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រនេះត្រេកអរដោយអំណាចកាមរាគ ជាប់ជំពាក់ដោយឆន្ទរាគ រមែងមិនរួចចាកភ័យក្នុងបច្ចុប្បន្នផង មិនរួចចាកភ័យក្នុងបរលោកផង ហេតុនោះបានជាពាក្យថា ភ័យនេះ ជាឈ្មោះរបស់កាម ។ ម្នាលភិក្ខុទាំងឡាយ ហេតុដូចម្តេច បានជាពាក្យថាទុក្ខ ។ បេ ។ ថារោគ ថាពក ថាព្រួញ ថាជាប់ជំពាក់ ថាភក់ (នេះជាឈ្មោះរបស់កាម) ។

កស្មា ច ភិក្ខវេ គព្ភោតិ កាមានមេតំ អធិវចនំ ។ យស្មា ច កាមរាគរត្តាយំ ភិក្ខវេ ឆន្ទរាគវិនិពទ្ធោ ទិដ្ឋធម្មិកាបិ គព្ភា ន បរិមុច្ចតិ សម្បរាយិកាបិ គព្ភា ន បរិមុច្ចតិ តស្មា គព្ភោតិ កាមានមេតំ អធិវចនន្តិ ។

ភយំ ទុក្ខញ្ច រោគោ ច គណ្ឌោ សល្លញ្ច សង្គោ ច
បង្កោ គព្ភោ ច ឧភយំ
ឯតេ កាមា បវុច្ចន្តិ យត្ថ សត្តោ បុថុជ្ជនោ
ឱតិណ្ណោ សាតរូបេន បុន គព្ភាយ គច្ឆតិ
យតោ ច ភិក្ខុ អាតាបី សម្បជញ្ញេន រិញ្ចតិ
សោមំ បលិបថំ ទុគ្គំ អតិក្កម្ម តថាវិធោ
បជំ ជាតិជរូបេតំ ផន្ទមានំ អវេក្ខតីតិ ។

[៩៧] អដ្ឋហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ បាហុនេយ្យោ ទក្ខិណេយ្យោ អញ្ជលិករណីយោ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។

ម្នាលភិក្ខុទាំងឡាយ ហេតុដូចម្តេច បានជាពាក្យថា គក់នេះ ជាឈ្មោះរបស់កាម ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្រនេះ ត្រេកអរដោយអំណាចកាម-រាគ ជាប់ជំពាក់ដោយឆន្ទរាគ រមែងមិនរួចចាកគក់ ក្នុងបច្ចុប្បន្នផង មិនរួចចាកគក់ ក្នុងបរលោកផង ហេតុនោះបានជា ពាក្យថា គក់នេះ ជាឈ្មោះរបស់កាម ។

បុថុជ្ជនជាប់ជំពាក់ក្នុងកាមណា កាមទាំងពីរនុ៎ះ លោកហៅថា ភ័យ ថាទុក្ខ ថារោគ ថាពក ថាព្រួញ ថាការជាប់ជំពាក់ ថាភក់ ថាគក់ បុថុជ្ជនត្រូវសេចក្តីសុខ ក្នុងកាមគ្របសង្កត់ហើយ រមែងទៅកាន់គក់ទៀត លុះតែភិក្ខុ មានព្យាយាមដុតកម្តៅកិលេស ត្រេកអរដោយសម្បជញ្ញៈក្នុងវេលាណា ភិក្ខុនោះបែបនោះ កន្លងនូវផ្លូវវាងគឺវដ្តៈនេះ ដែលគេឆ្លងបានដោយក្រ រមែងមើលឃើញនូវពួកសត្វ ដែលចូលទៅកាន់ជាតិនិងជរា កំពុងតែញាប់ញ័រ (ក្នុងភពទាំង ៣ ក្នុងវេលានោះ) ។

[៥៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាង ជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា គួរទទួលនូវចតុប្បច្ច័យដែលគេតាក់តែង ដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្ម ដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន។

កតមេហិ អដ្ឋហិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ ។ បេ ។ ទិដ្ឋិយា សុប្បដិវិទ្ធា កល្យាណមិត្តោ ហោតិ កល្យាណសហាយោ កល្យាណសម្បវង្កោ សម្មាទិដ្ឋិកោ ហោតិ សម្មាទស្សនេន សមន្នាគតោ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ សេយ្យថីទំ ឯកម្បិ ជាតឹ ទ្វេបិ ជាតិយោ ។ បេ ។ ឥតិ សាការំ សឧទ្ទេសំ អនេកវិហិតំ បុព្វេនិវាសំ អនុស្សរតិ ទិព្វេន ចក្ខុនា វិសុទ្ធេន អតិក្កន្តមានុសកេន ។ បេ ។ យថា-កម្មូបគេ សត្តេ បជានាតិ អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

ប្រកបដោយធម៌ទាំង ៨ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។ បេ ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ១ ជាអ្នកចេះចាំច្រើន ១ ។ បេ ។ យល់ត្រឹមត្រូវដោយទិដ្ឋិ ១ ជាអ្នកមានមិត្រល្អ មានសំឡាញ់ល្អ សមគប់នឹងបុគ្គលល្អ ១ ជាអ្នកសម្មាទិដ្ឋិ ប្រកបដោយសម្មាទស្សនៈ ១ ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយទូលាយនូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ប្រសើរ ជាគ្រឿងនៅសប្បាយ ក្នុងបច្ចុប្បន្ន ១ តែងរឭកឃើញនូវបុព្វេនិវាសគឺ ការនៅក្នុងភពមុន មានប្រការដ៏ច្រើនគឺ រឭកឃើញ ១ ជាតិខ្លះ ២ ជាតិខ្លះ ។ បេ ។ រលឹកឃើញនូវបុព្វេនិវាស ព្រមទាំងអាការៈ ព្រមទាំងឧទ្ទេស មានប្រការដ៏ច្រើន ដោយប្រការដូច្នេះ ១ បានដឹងច្បាស់នូវពួកសត្វដែលអន្ទោលទៅតាមកកម្ម ។ ល ។ ទិព្វចក្ខុដ៏ស្អាតកន្លងបង់នូវចក្ខុរបស់មនុស្សធម្មតា ។ បេ ។ ដឹងច្បាស់នូវពួកសត្វ ដែលអន្ទោលទៅតាមកម្ម ១ បានធ្វើឲ្យជាក់ច្បាស់ បានដល់ ។ បេ ។ ព្រោះអស់ទៅនៃអាសវៈ ទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៨ យ៉ាងនេះឯង ជាអ្នកគួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃ ក្រៃលែងជាងគ្មាន ។

[៥៨] អដ្ឋហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេហិ អដ្ឋហិ ។ ឥធ ភិក្ខវេ ភិក្ខុ សីលវា ហោតិ ។ បេ ។ សមាទាយ សិក្ខតិ សិក្ខាបទេសុ ពហុស្សុតោ ហោតិ ។ បេ ។ ទិដ្ឋិយា សុប្បដិវិទ្ធា អារទ្ធវិរិយោ ហោតិ ថាមវា ទឡ្ហបរក្កមោ អនិក្ខិត្តធុរោ កុសលេសុ ធម្មេសុ អារញ្ញកោ ហោតិ បន្តសេនាសនោ អរតិរតិសហោ ហោតិ ឧប្បន្នំ អរតឹ អភិភុយ្យ វិហរតិ ភយភេរវសហោ ហោតិ ឧប្បន្នំ ភយភេរវំ អភិភុយ្យ វិហរតិ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អាហុនេយ្យោ ហោតិ ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

[៩៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ យ៉ាង ជាអ្នកគួរទទួលចតុប្បច្ច័យដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ ប្រកបដោយធម៌ទាំង ៨ យ៉ាង តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល ។ បេ ។ សមាទានសិក្សា ក្នុងសិក្ខាបទទាំងឡាយ ១ ជាអ្នកចេះចាំច្រើន ១ ។ បេ ។ យល់ត្រឹមត្រូវដោយទិដ្ឋិ ១ ជាអ្នកប្រារព្ធសេចក្តីព្យាយាម មានកម្លាំងប្រឹងប្រែងដ៏មាំ មិនដាក់ធុរៈចោលក្នុងកុសលធម៌ទាំងឡាយ ១ ជាអ្នកនៅក្នុងព្រៃ មានទីសេនាសនៈស្ងាត់ ១ អត់ទ្រាំនូវសេចក្តីអផ្សុកនិងសេចក្តីត្រេកអរ តែងគ្របសង្កត់នូវសេចក្តីអផ្សុកដែលកើតឡើងហើយ ១ ជាអ្នកអត់ទ្រាំនូវភ័យគួរស្ញប់ស្ញែង តែងគ្របសង្កត់នូវភ័យ គួរស្ញប់ស្ញែងដែលកើតឡើងហើយ ១ ជាអ្នកបានតាមប្រាថ្នា បានដោយមិនលំបាក បានដោយទូលាយ នូវឈានទាំង ៤ ដែលអាស្រ័យនូវចិត្តដ៏ប្រសើរ ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្ន ១ បានធ្វើឲ្យជាក់ច្បាស់ បានដល់ ។ បេ ។ ព្រោះអស់ទៅនៃអាសវៈទាំងឡាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៨ យ៉ាងនេះឯង ជាអ្នកគួរទទួលនូវចតុប្បច្ច័យដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

[៤៩] អដ្ឋិមេ ភិក្ខវេ បុគ្គលា អាហុនេយ្យា ចាហុនេយ្យា ទក្ខិណេយ្យា អញ្ជលិករណីយា អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេ អដ្ឋ ។ សោតាបន្នោ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ សកទាគាមី សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ អនាគាមី អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ អរហា អរហត្តាយ បដិបន្នោ ។ ឥមេ ខោ ភិក្ខវេ អដ្ឋ បុគ្គលា អាហុនេយ្យា ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

ចត្តារោ ច បដិបន្នា ចត្តារោ ច ផលេ ឋិតា
ឯស សង្ឃោ ឧជុភូតោ បញ្ញាសីលសមាហិតោ

[៩៩] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៨ ពួកនេះ ជាអ្នកគួរទទួលនូវចតុប្បច្ច័យ ដែលគេនាំមកបូជា គួរទទួលនូវចតុប្បច្ច័យដែលគេតាក់តែងដើម្បីភ្ញៀវ គួរទទួលនូវទក្ខិណាទាន គួរដល់អញ្ជលិកម្មដែលសត្វលោកគប្បីធ្វើ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃ ក្រៃលែងជាងគ្មាន ។ បុគ្គលទាំង ៨ ពួក តើដូចម្តេច ។ គឺបុគ្គលជាសោតាបន្ន ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់សោតាបត្តិផល ១ បុគ្គលជាសកទាគាមី ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់សកទាគាមិផល ១ បុគ្គលជាអនាគាមី ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់អនាគាមិផល ១ បុគ្គលជាអរហន្ត ១ បុគ្គលជាអ្នកប្រតិបត្តិ ដើម្បីអរហត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៨ ពួកនេះឯង ជាអ្នកគួរទទួលនូវចតុបច្ច័យដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃ ក្រៃលែងជាងគ្មាន ។

បុគ្គល ៤ ពួក ជាអ្នកប្រតិបត្តិផង ៤ ពួកតាំងនៅក្នុងផលផង
នេះ ជាសង្ឃមានសភាពដ៏ត្រង់ ប្រកបដោយបញ្ញានិងសីល

យជមានានំ មនុស្សានំ បុញ្ញបេក្ខាន បាណិនំ
ករោតំ ឱបធិកំ បុញ្ញំ[១] សង្ឃេ ទិន្នំ មហប្ផលន្តិ ។

[៦០] អដ្ឋិមេ ភិក្ខវេ បុគ្គលា អាហុនេយ្យា ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្ស ។ កតមេ អដ្ឋ ។ សោតាបន្នោ សោតាបត្តិផលសច្ឆិកិរិយាយ បដិបន្នោ សកទាគាមី សកទាគាមិផលសច្ឆិកិរិយាយ បដិបន្នោ អនាគាមី អនាគាមិផលសច្ឆិកិរិយាយ បដិបន្នោ អរហា អរហត្តាយ បដិបន្នោ ។ ឥមេ ខោ ភិក្ខវេ អដ្ឋ បុគ្គលា អាហុនេយ្យា ។ បេ ។ អនុត្តរំ បុញ្ញក្ខេត្តំ លោកស្សាតិ ។

---

១ ឱ. ម. ករោតំ ឱបធិកំ បុញ្ញំ ។

រមែងធ្វើនូវបុណ្យដ៏ក្រៃលែង ដល់ពួកសត្វគឺ មនុស្សកាល
ស្វែងរកនូវបុណ្យហើយបូជា ព្រោះទានដែលបុគ្គលឲ្យហើយ
ចំពោះសង្ឃ រមែងមានផលច្រើន ។

[៦០] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៨ ពួកនេះ ជាអ្នកគួរទទួលនូវចតុបច្ច័យ ដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។ បុគ្គលទាំង ៨ ពួក តើដូចម្តេច ។ គឺបុគ្គលជាសោតាបន្ន ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់ សោតាបត្តិ-ផល ១ បុគ្គលជាសកទាគាមី ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់សកទាគាមិផល ១ បុគ្គលជាអនាគាមី ១ បុគ្គលអ្នកប្រតិបត្តិ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវអនាគាមិផល ១ បុគ្គលជាអរហន្ត ១ បុគ្គលអ្នកប្រតិបត្តិដើម្បីអរហត្ត ១ ។ ម្នាលភិក្ខុទាំងឡាយ បុគ្គលទាំង ៨ ពួកនេះឯង ជាអ្នកគួរទទួលនូវចតុបច្ច័យ ដែលគេនាំមកបូជា ។ បេ ។ ជាបុញ្ញក្ខេត្តនៃសត្វលោក រកខេត្តដទៃក្រៃលែងជាងគ្មាន ។

២៦៨

បណ្ណាសកាសង្គហិតោ   សន្ទានវគ្គោ

ចត្តារោ   ច   បដិបន្នា   ចត្តារោ   ច   ផលេ   ឋិតា
ឯស   សង្ឃោ   សមុក្កដ្ឋោ   សត្តានំ   អដ្ឋ   បុគ្គលា
យជមានានំ   មនុស្សានំ   បុញ្ញបេក្ខាន   បាណិនំ
ករោតិ   ឱបធិកំ   បុញ្ញំ   ឯត្ថ   ទិន្នំ   មហប្ផលន្តិ ។

សន្ទានវគ្គោ   បឋមោ ។

## តត្រុទ្ទានំ

គោតមី   ឱវាទំ   សំខិត្តំ   ទីឃជាណុញ្ច   ឧជ្ជយោ
ភយា   ទ្វេ   អាហុនេយ្យា   ទ្វេ   ច   អដ្ឋបុគ្គលាតិ ។

បុគ្គល ៤ ពួក ជាអ្នកប្រតិបត្តិផង ៤ ពួកជាអ្នកតាំងនៅក្នុងផលផង នេះជាសង្ឃដ៏ឧត្តម ជាងសត្វទាំងឡាយ បុគ្គល ៨ ពួក រមែងធ្វើបុណ្យដ៏ក្រៃលែង ដល់ពួកសត្វគឺ មនុស្សកាលស្វែងរកនូវបុណ្យហើយបូជា ព្រោះទានដែលបុគ្គលឲ្យហើយចំពោះសង្ឃនុ៎ះ រមែងមានផលច្រើន ។

ចប់ សន្ទានវគ្គ ទី ១ ។

## ឧទ្ទាននៃសន្ទានវគ្គនោះ គឺ

និយាយអំពីរឿងនាងមហាបជាបតិគោតមី ១ អំពីភិក្ខុគួរឲ្យឱវាទដល់ភិក្ខុនី ១ អំពីធម៌ដ៏សង្ខេប ១ អំពីទីឃជាណុកោឡិយបុត្ត ១ អំពីឧជ្ជយព្រាហ្មណ៍ ១ អំពីភ័យ ១ អំពីអាហុនេយ្យបុគ្គលមាន ២ លើក អំពីបុគ្គល ៨ ពួកមាន ២ លើក ។

# ចាលវគ្គោ

[៦១] អដ្ឋិមេ ភិក្ខវេ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ អដ្ឋ ។ ឥធ ភិក្ខវេ ភិក្ខុនោ បវិវិត្តស្ស វិហរតោ និរាយត្តវុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ ។ សោ ឧដ្ឋហតិ ឃដតិ វាយមតិ លាភាយ ។ តស្ស ឧដ្ឋហតោ ឃដតោ វាយមតោ លាភាយ លាភោ នុប្បជ្ជតិ ។ សោ តេន អលាភេន សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡី[១] កន្ទតិ សម្មោហំ អាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ឥច្ឆោ វិហរតិ លាភាយ ឧដ្ឋហតិ ឃដតិ វាយមតិ លាភាយ ន ច លាភី សោចិ ច បរិទេវិ ច ចុតោ ច សទ្ធម្មា ។ ឥធ បន ភិក្ខវេ ភិក្ខុនោ បវិវិត្តស្ស វិហរតោ និរាយត្តវុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ ។ សោ ឧដ្ឋហតិ ឃដតិ វាយមតិ លាភាយ ។ តស្ស ឧដ្ឋហតោ ឃដតោ វាយមតោ លាភាយ លាភោ ឧប្បជ្ជតិ ។ សោ តេន លាភេន មជ្ជតិ បមជ្ជតិ បមាទមាបជ្ជតិ ។

១ ឱ. ម. ឧរត្តាឡឹ ។

# ចាលវគ្គ

[៦១] ម្នាលភិក្ខុទាំងឡាយ បុគ្គល ៨ ពួកនេះ រមែងមានប្រាកដក្នុងលោក ។ បុគ្គល ៨ ពួក តើដូចម្ដេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ តែប្រព្រឹត្តមិនជាប់លាប់ សេចក្ដីប្រាថ្នាដើម្បីលាភ ក៏កើតឡើង ។ ភិក្ខុនោះ ខំសង្វាត ខ្មីឃ្មាត ព្យាយាម ដើម្បីលាភ ។ កាលភិក្ខុនោះ ខំសង្វាត ខ្មីឃ្មាត ព្យាយាម ដើម្បីលាភ លាភក៏មិនកើតឡើង ។ ភិក្ខុនោះ រមែងសោកស្ដាយ លំបាក ខ្សឹកខ្សួល គក់ទ្រូងកន្ទក់កន្ទេញ ដល់នូវសេចក្ដីវង្វេង ព្រោះមិនមានលាភនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកប្រាថ្នា ដើម្បីលាភ ខំសង្វាត ខ្មីឃ្មាត ព្យាយាម ដើម្បីលាភ ប៉ុន្តែជាអ្នកមិនមានលាភផង សោកស្ដាយផង ខ្សឹកខ្សួលផង ឃ្លាតចាកព្រះសទ្ធម្មផង (១) ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ ប្រព្រឹត្តមិនជាប់លាប់ សេចក្ដីប្រាថ្នាដើម្បីលាភ ក៏កើតឡើង ។ ភិក្ខុនេះខំសង្វាត ខ្មីឃ្មាតព្យាយាមដើម្បីលាភ ។ កាលភិក្ខុនោះ ខំសង្វាត ខ្មីឃ្មាត ព្យាយាម ដើម្បីលាភ លាភក៏កើតឡើង ។ ភិក្ខុនោះ ស្រវឹងជ្រុលជ្រប់ ដល់នូវសេចក្ដីប្រមាទ ព្រោះលាភនោះ ។

២៦៧



អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ឥច្ឆោ វិហរតិ លាភាយ ឧដ្ឋហតិ ឃដតិ វាយមតិ លាភាយ លាភី ច មទី ច បមាទី ច ចុតោ ច សទ្ធម្មា ។ ឥធ បន ភិក្ខវេ ភិក្ខុនោ បវិវិត្តស្ស វិហរតោ និរាយត្តវុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ ។ សោ ន ឧដ្ឋហតិ ន ឃដតិ ន វាយមតិ លាភាយ ។ តស្ស អនុដ្ឋហតោ អឃដតោ អវាយមតោ លាភាយ លាភោ នុប្បជ្ជតិ ។ សោ តេន អលាភេន សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ឥច្ឆោ វិហរតិ លាភាយ ន ឧដ្ឋហតិ ន ឃដតិ ន វាយមតិ លាភាយ ន ច លាភី សោចិ ច បរិទេវិ ច ចុតោ ច សទ្ធម្មា ។ ឥធ បន ភិក្ខវេ ភិក្ខុនោ បវិវិត្តស្ស វិហរតោ និរាយត្តវុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ ។ សោ ន ឧដ្ឋហតិ ន ឃដតិ ន វាយមតិ លាភាយ ។ តស្ស អនុដ្ឋហតោ អឃដតោ អវាយមតោ លាភាយ លាភោ ឧប្បជ្ជតិ ។

ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកប្រាថ្នាដើម្បីលាភ ខំសង្វាត ខ្មីឃ្មាត ព្យាយាម ដើម្បីលាភ ជាអ្នកមានលាភផង ស្រវឹងផង ប្រមាទផង ឃ្លាតចាកព្រះសទ្ធម្មផង(២) ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ ប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នា ដើម្បីលាភក៏កើតឡើង ។ ភិក្ខុនោះ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភទេ ។ កាលភិក្ខុនោះ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភទេ លាភក៏មិនកើតដែរ ។ ភិក្ខុនោះ រមែងសោកស្តាយ លំបាក ខ្សឹកខ្សួល គក់ទ្រូង កន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេង ព្រោះមិនមានលាភនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកប្រាថ្នាដើម្បីលាភ តែមិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភ ប៉ុន្តែជាអ្នកមិនមានលាភផង សោកស្តាយផង ខ្សឹកខ្សួលផង ឃ្លាតចាកព្រះសទ្ធម្មផង (៣) ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ ប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នាដើម្បីលាភ ក៏កើតឡើង ។ ភិក្ខុនោះ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភទេ ។ កាលភិក្ខុនោះ មិនសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភទេ ប៉ុន្តែលាភក៏កើតឡើងបាន ។

សោ តេន លាភេន មជ្ជតិ បមជ្ជតិ បមាទមាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ឥច្ឆោ វិហរតិ លាភាយ ន ឧដ្ឋហតិ ន ឃដតិ ន វាយមតិ លាភាយ លាភី ច មទី ច បមាទី ច ចុតោ ច សទ្ធម្មា ។ ឥធ បន ភិក្ខវេ ភិក្ខុនោ បវិវិត្តស្ស វិហរតោ និរាយត្តវុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ ។ សោ ឧដ្ឋហតិ ឃដតិ វាយមតិ លាភាយ ។ តស្ស ឧដ្ឋហតោ ឃដតោ វាយមតោ លាភាយ លាភោ នុប្បជ្ជតិ ។ សោ តេន អលាភេន ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ឥច្ឆោ វិហរតិ លាភាយ ឧដ្ឋហតិ ឃដតិ វាយមតិ លាភាយ ន ច លាភី ន ច សោចិ ន ច បរិទេវិ អច្ចុតោ ច សទ្ធម្មា ។ ឥធ បន ភិក្ខវេ ភិក្ខុនោ បវិវិត្តស្ស វិហរតោ និរាយត្តវុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ ។ សោ ឧដ្ឋហតិ ឃដតិ វាយមតិ លាភាយ ។

ភិក្ខុនោះ ស្រវឹងជ្រុលជ្រប់ ដល់នូវសេចក្ដីប្រមាទ ព្រោះលាភនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកប្រាថ្នា ដើម្បីលាភ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភទេ ប៉ុន្តែជាអ្នកមានលាភផង ស្រវឹងផង ប្រមាទផង ឃ្លាតចាកព្រះសទ្ធម្មផង (២) ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ ប្រព្រឹត្តមិនជាប់លាប់ សេចក្ដីប្រាថ្នា ដើម្បីលាភ ក៏កើតឡើង ។ ភិក្ខុនោះ ខំសង្វាត ខ្មីឃ្មាត ព្យាយាម ដើម្បីលាភ ប៉ុន្តែលាភមិនកើតឡើង ។ ភិក្ខុនោះ មិនសោកស្ដាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង កន្ទក់កន្ទេញ មិនដល់នូវសេចក្ដីវង្វេង ព្រោះមិនមានលាភនោះទេ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកប្រាថ្នា ដើម្បីលាភ ខំសង្វាត ខ្មីឃ្មាត ព្យាយាម ដើម្បីលាភ ប៉ុន្តែជាអ្នកមិនមានលាភផង មិនសោកស្ដាយផង មិនខ្សឹកខ្សួលផង មិនឃ្លាតចាកព្រះសទ្ធម្មផង (៥) ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ ប្រព្រឹត្តមិនជាប់លាប់ សេចក្ដីប្រាថ្នា ដើម្បីលាភ ក៏កើតឡើង ។ ភិក្ខុនោះខំសង្វាត ខ្មីឃ្មាត ព្យាយាម ដើម្បីលាភ ។

តស្ស ឧជ្ជហតោ ឃជតោ វាយមតោ លាភាយ លាភោ ឧប្បជ្ជតិ ។ សោ តេន លាភេន ន មជ្ជតិ ន បមជ្ជតិ ន បមាទមាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ឥច្ឆោ វិហរតិ លាភាយ ឧជ្ជហតិ ឃជតិ វាយមតិ លាភាយ លាភី ច ន ច មទី ន ច បមាទី អច្ចុតោ ច សទ្ធម្មា ។ ឥធ បន ភិក្ខវេ ភិក្ខុនោ បវិវិត្តស្ស វិហរតោ និរាយត្តវុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ ។ សោ ន ឧជ្ជហតិ ន ឃជតិ ន វាយមតិ លាភាយ ។ តស្ស អនុជ្ជ-ហតោ អឃជតោ អវាយមតោ លាភាយ លាភោ នុប្ប-ជ្ជតិ ។ សោ តេន អលាភេន ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ឥច្ឆោ វិហរតិ លាភាយ ន ឧជ្ជហតិ ន ឃជតិ ន វាយមតិ លាភាយ ន ច លាភី ន ច សោចិ ន ច បរិទេវិ អច្ចុតោ ច សទ្ធម្មា ។

កាលភិក្ខុនោះ ខំសង្វាត ព្យាយាម ដើម្បីលាភ លាភក៏កើតឡើង ។ ភិក្ខុនោះមិនស្រវឹង មិនជ្រុលជ្រប់ មិនដល់នូវសេចក្ដីប្រមាទ ព្រោះលាភនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកប្រាថ្នា ដើម្បីលាភ ខំសង្វាត ខ្មីឃ្មាត ព្យាយាម ដើម្បីលាភ ជាអ្នកមានលាភផង មិនស្រវឹងផង មិនប្រមាទផង មិនឃ្លាតចាកព្រះសទ្ធម្មផង (៦) ។ ម្នាលភិក្ខុទាំង-ឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ ប្រព្រឹត្តមិនជាប់លាប់ សេចក្ដីប្រាថ្នា ដើម្បីលាភ ក៏កើតឡើង ។ ភិក្ខុនោះមិនខំសង្វាត មិនខ្មី-ឃ្មាត មិនព្យាយាម ដើម្បីលាភទេ ។ កាលភិក្ខុនោះ មិនខំសង្វាត មិនខ្មី-ឃ្មាត មិនព្យាយាម ដើម្បីលាភទេ លាភក៏មិនកើតឡើងដែរ ។ ភិក្ខុនោះរមែងមិនសោកស្ដាយ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូង កន្ទក់កន្ទេញ មិនដល់នូវសេចក្ដីវង្វេង ព្រោះមិនមានលាភនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកប្រាថ្នាដើម្បីលាភ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភ ទាំងជាអ្នកមិនមានលាភផង មិនសោកស្ដាយផង មិនខ្សឹកខ្សួលផង មិនឃ្លាតចាកព្រះសទ្ធម្មផង (៧) ។

ឥធ បន ភិក្ខវេ ភិក្ខុនោ បរិត្តស្ស វិហរតោ និរាយត្តវុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ ។ សោ ន ឧដ្ឋហតិ ន ឃដតិ ន វាយមតិ លាភាយ ។ តស្ស អនុដ្ឋហតោ អឃដតោ អវាយមតោ លាភាយ លាភោ ឧប្បជ្ជតិ ។ សោ តេន លាភេន ន មជ្ជតិ ន បមជ្ជតិ ន បមាទមាបជ្ជតិ ។ អយំ វុច្ចតិ ភិក្ខវេ ភិក្ខុ ឥច្ឆោ វិហរតិ លាភាយ ន ឧដ្ឋហតិ ន ឃដតិ ន វាយមតិ លាភាយ លាភី ច ន ច មទី ន ច បមាទី អចុតោ ច សទ្ធម្មា ។ ឥមេ ខោ ភិក្ខវេ អដ្ឋ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

[៦២] ឆហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ អលំ បរេសំ ។ កតមេហិ ឆហិ ។ ឥធ ភិក្ខវេ ភិក្ខុ ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុតានញ្ច ធម្មានំ ធារកជាតិកោ ហោតិ

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុក្នុងសាសនានេះ ជាអ្នកស្ងាត់ ប្រព្រឹត្ត មិនជាប់លាប់ សេចក្តីប្រាថ្នា ដើម្បីលាភ ក៏កើតឡើង ។ ភិក្ខុនោះ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភទេ ។ កាលភិក្ខុនោះ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភទេ ប៉ុន្តែលាភកើតឡើងបាន ។ ភិក្ខុនោះ មិនស្រវឹង មិនជ្រុលជ្រប់ មិនដល់នូវសេចក្តីប្រមាទ ព្រោះលាភនោះ ។ ម្នាលភិក្ខុទាំងឡាយ នេះហៅថា ភិក្ខុអ្នកប្រាថ្នា ដើម្បីលាភ មិនខំសង្វាត មិនខ្មីឃ្មាត មិនព្យាយាម ដើម្បីលាភ ក៏ជាអ្នកមានលាភផង មិនស្រវឹងផង មិនប្រមាទផង មិនឃ្លាតចាកព្រះសទ្ធម្មផង (៨) ។ ម្នាលភិក្ខុទាំងឡាយ បុគ្គល ៨ ពួកនេះឯង រមែងមានប្រាកដ ក្នុងលោក ។

[៦២] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាង ទើបគួរដល់ខ្លួន គួរដល់ពួកជនដទៃ ។ ៦ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកចេះដឹងឆាប់ ក្នុងកុសលធម៌ទាំងឡាយ ១ ជាអ្នកទ្រទ្រង់ធម៌ទាំងឡាយ ដែលខ្លួនស្តាប់ហើយ ១

ឯតានញ្ច ធម្មានំ អត្ថុបបរិក្ខី ហោតិ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ច ហោតិ កល្យាណវាចោ ច ហោតិ កល្យាណវាក្ករណោ ពោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា សន្ទស្សកោ ច ហោតិ សមាទបកោ សមុត្តេជកោ សម្បហំសកោ សព្រហ្មចារីនំ ។ ឥមេហិ ខោ ភិក្ខវេ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ អលំ បរេសំ ។

[៦៣] បញ្ចហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ អលំ បរេសំ ។ កតមេហិ បញ្ចហិ ។ ឥធ ភិក្ខវេ ភិក្ខុ ន ហេវ ខោ ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុតានញ្ច ធម្មានំ ធារកជាតិកោ ហោតិ ឯតានញ្ច ធម្មានំ អត្ថុបបរិក្ខី ហោតិ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ច ហោតិ កល្យាណវាចោ ច ហោតិ ។ បេ ។ អត្ថស្ស វិញ្ញាបនិយា សន្ទស្សកោ ច ហោតិ សមាទបកោ សមុត្តេជកោ សម្បហំសកោ សព្រហ្មចារីនំ ។ ឥមេហិ ខោ ភិក្ខវេ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ អលំ បរេសំ ។

ជាអ្នកពិចារណា នូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ ១ ជាអ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ ១ ជាអ្នកមានវាចាល្អ មានពាក្យពីរោះ ប្រកបដោយវាចាអ្នកក្រុង ជាវាចាច្បាស់លាស់ ជាវាចាឥតទោស ជាគ្រឿងញុំាងជនឲ្យដឹងច្បាស់នូវសេចក្តី ១ ជាអ្នកញុំាងពួកសព្រហ្មចារីឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ យ៉ាងនេះឯង ទើបគួរដល់ខ្លួន គួរដល់ពួកជនដទៃ ។

[៦៣] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាង ទើបគួរដល់ខ្លួន គួរដល់ពួកជនដទៃ ។ ៥ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំង-ឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនចេះដឹងឆាប់ ក្នុងកុសលធម៌ទាំង-ឡាយទេ តែជាអ្នកទ្រទ្រង់ធម៌ទាំងឡាយ ដែលខ្លួនស្តាប់ ១ ជាអ្នកពិចារណានូវអត្ថនៃធម៌ដែលខ្លួនទ្រទ្រង់ ១ ជាអ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិធម៌ ដ៏សមគួរដល់ធម៌ ១ ជាអ្នកមានវាចាល្អ ។ បេ ។ ជាគ្រឿងញុំាងជនឲ្យដឹងច្បាស់នូវសេចក្តី ១ ជាអ្នកញុំាងពួកសព្រហ្មចារីឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៥ យ៉ាងនេះឯង ទើបគួរដល់ខ្លួន គួរដល់ពួកជនដទៃ ។

[៦៤] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ នោ បរេសំ ។ កតមេហិ ចតូហិ ។ ឥធ ភិក្ខវេ ភិក្ខុ ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុតានញ្ច ធម្មានំ ធារកជាតិកោ ហោតិ ធាតានញ្ច ធម្មានំ អត្ថុបបរិក្ខី ហោតិ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ច ហោតិ នោ ច កល្យាណវាចោ ហោតិ កល្យាណវាក្ករណោ ចោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា នោ ច សន្ទស្សកោ ហោតិ សមាទបកោ សមុត្តេជកោ សម្បហំសកោ សព្រហ្មចារីនំ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ នោ បរេសំ ។

[៦៥] ចតូហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ បរេសំ នោ អត្តនោ ។ កតមេហិ ចតូហិ ឥធ ភិក្ខវេ ភិក្ខុ ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុតានញ្ច ធម្មានំ ធារកជាតិកោ ហោតិ នោ ច ធាតានំ ធម្មានំ អត្ថុបបរិក្ខី ហោតិ នោ ច

[៦៤] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាង រមែងគួរដល់ខ្លួន តែមិនគួរដល់ពួកជនដទៃទេ ។ ៤ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកចេះដឹងឆាប់ក្នុងកុសលធម៌ទាំងឡាយ ១ ជាអ្នកទ្រទ្រង់ធម៌ទាំងឡាយ ដែលខ្លួនបានស្តាប់ហើយ ១ ជាអ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ ១ ជាអ្នកដឹងនូវអត្ថ ដឹងនូវធម៌ហើយ ប្រតិបត្តិដ៏សមគួរដល់ធម៌ តែជាអ្នកមានវាចាមិនល្អ ជាអ្នកមានពាក្យមិនពីរោះ ជាអ្នកមិនប្រកបដោយវាចាអ្នកក្រុង ដែលជាវាចាច្បាស់លាស់ ជាវាចាឥតទោស ជាគ្រឿងញុំាងជនឲ្យដឹងច្បាស់នូវសេចក្តី ទាំងជាអ្នកមិនញុំាងពួកសព្រហ្មចារី ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះឯង រមែងគួរដល់ខ្លួន តែមិនគួរដល់ពួកជនដទៃឡើយ ។

[៦៥] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាង រមែងគួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនទេ ។ ៤ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកចេះដឹងឆាប់ ក្នុងកុសលធម៌ទាំងឡាយ ១ ជាអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ដែលខ្លួនស្តាប់ហើយ តែជាអ្នកមិនពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ

អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ កល្យាណវាចោ ច ហោតិ កល្យាណវាក្ករណោ ។ បេ ។ អត្ថស្ស វិញ្ញាបនិយា សន្ទស្សកោ ច ហោតិ ។ បេ ។ សព្រហ្មចារីនំ ។ ឥមេហិ ខោ ភិក្ខវេ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ បរេសំ នោ អត្តនោ ។

[៦៦] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ នោ បរេសំ ។ កតមេហិ តីហិ ។ ឥធ ភិក្ខវេ ភិក្ខុ ន ហេវ ខោ ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុតានញ្ច ធម្មានំ ធារកជាតិកោ ហោតិ ធតានញ្ច ធម្មានំ អត្ថុបបរិក្ខី ហោតិ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ច ហោតិ នោ ច កល្យាណវាចោ ហោតិ កល្យាណវាក្ករណោ ចោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា នោ ច សន្ទស្សកោ ហោតិ សមាទបកោ សមុត្តេជកោ សម្បហំសកោ សព្រហ្មចារីនំ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ នោ បរេសំ ។

ទាំងជាអ្នកមិនដឹងនូវអត្ថ មិនដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ ១ ជាអ្នកមានវាចាល្អ ជាអ្នកមានពាក្យពីរោះ ។ បេ ។ ជាគ្រឿងញ៉ាំងជនឲ្យដឹងច្បាស់នូវសេចក្តី ១ ជាអ្នកញ៉ាំងពួកសព្រហ្មចារី ឲ្យឃើញច្បាស់ ១ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៤ យ៉ាងនេះឯង រមែងគួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឡើយ ។

[៦៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាង រមែងគួរដល់ខ្លួន តែមិនគួរដល់ពួកជនដទៃទេ ។ ៣ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនចេះដឹងឆាប់ ក្នុងកុសលធម៌ទាំងឡាយទេ តែជាអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ដែលខ្លួនស្តាប់ហើយ ១ ជាអ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ ១ ជាអ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ តែជាអ្នកមានវាចាមិនល្អ ជាអ្នកមានពាក្យមិនពីរោះ ជាអ្នកមិនប្រកបដោយវាចាអ្នកក្រុង ដែលជាវាចាច្បាស់លាស់ ជាវាចាឥតទោស ជាគ្រឿងញ៉ាំងជន ឲ្យដឹងច្បាស់នូវសេចក្តី ទាំងមិនញ៉ាំងពួកសព្រហ្មចារី ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះ រមែងគួរដល់ខ្លួន តែមិនគួរដល់ពួកជនដទៃឡើយ ។

[៦៧] តីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ បរេសំ ធោ អត្តធោ ។ កាតមេហិ តីហិ ។ ឥធ ភិក្ខវេ ភិក្ខុ ន ហេវ ខោ ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុតានញ្ច ធម្មានំ ធារកជាតិកោ ហោតិ ធោ ច ធតានំ ធម្មានំ អត្ថុបបរិក្ខី ហោតិ ធោ ច អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ កល្យាណវាចោ ច ហោតិ ។ បេ ។ អត្ថស្ស វិញ្ញាបនិយា សន្ទស្សកោ ច ហោតិ សមាទបកោ សមុត្តេជកោ សម្បហំសកោ សព្រហ្មចារីនំ ។ ឥមេហិ ខោ ភិក្ខវេ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ បរេសំ ធោ អត្តធោ ។

[៦៨] ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តធោ ធោ បរេសំ ។ កាតមេហិ ទ្វីហិ ។ ឥធ ភិក្ខវេ ភិក្ខុ ន ហេវ ខោ ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ ធោ ច សុតានំ ធម្មានំ ធារក-ជាតិកោ ហោតិ ធតានញ្ច ធម្មានំ អត្ថុបបរិក្ខី ហោតិ

[៦៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាង រមែងគួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនទេ ។ ៣ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនចេះដឹងឆាប់ ក្នុងកុសលធម៌ទាំងឡាយទេតែជាអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ដែលខ្លួនស្តាប់ហើយ ១ ជាអ្នកមិនពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ ទាំងជាអ្នកមិនដឹងនូវអត្ថ មិនដឹងនូវធម៌ ហើយប្រតិបត្តិ នូវធម៌ដ៏សមគួរដល់ធម៌ តែជាអ្នកមានវាចាល្អ ។ បេ ។ ជាគ្រឿងញ៉ាំងជនឲ្យដឹងច្បាស់នូវសេចក្តី ១ ជាអ្នកញ៉ាំងពួកសព្រហ្មចារី ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៣ យ៉ាងនេះ រមែងគួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឡើយ ។

[៦៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ យ៉ាង រមែងគួរដល់ខ្លួន តែមិនគួរដល់ពួកជនដទៃទេ ។ ២ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនចេះដឹងឆាប់ ក្នុងកុសលធម៌ទាំង-ឡាយ ថែមទាំងមិនជាអ្នកទ្រទ្រង់នូវធម៌ទាំងឡាយ ដែលខ្លួនស្តាប់ហើយផង តែជាអ្នកពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ ១

អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ច ហោតិ នោ ច កល្យាណវាចោ ហោតិ ។ បេ ។ អត្ថស្ស វិញ្ញាបនិយា នោ ច សន្ទស្សកោ ហោតិ ។ បេ ។ សព្រហ្មចារីនំ ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ នោ បរេសំ ។

[៦៩] ទ្វីហិ ភិក្ខវេ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ បរេសំ នោ អត្តនោ ។ កតមេហិ ទ្វីហិ ។ ឥធ ភិក្ខវេ ភិក្ខុ ន ហេវ ខោ ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ នោ ច សុតានំ ធម្មានំ ធារកជាតិកោ ហោតិ នោ ច ធតានំ ធម្មានំ អត្ថុបបរិក្ខី ហោតិ នោ ច អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ កល្យាណវាចោ ច ហោតិ កល្យាណវាក្ករណោ ចោ-រិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា សន្ទស្សកោ ច ហោតិ សមាទ-បកោ សមុត្តេជកោ សម្បហំសកោ សព្រហ្មចារីនំ ។ ឥមេហិ ខោ ភិក្ខវេ ទ្វីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ បរេសំ នោ អត្តនោតិ ។

ជាអ្នកដឹងនូវអត្ថ ដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ តែជាអ្នកមានវាចាមិនល្អ ។ បេ ។ ជាគ្រឿងញុំាងជនឲ្យដឹងច្បាស់នូវសេចក្តី ជាអ្នកមិនញុំាងពួកសព្រហ្មចារី ឲ្យឃើញច្បាស់ ១ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ យ៉ាងនេះឯង រមែងគួរដល់ខ្លួន តែមិនគួរដល់ពួកជនដទៃឡើយ ។

[៦៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ យ៉ាង រមែងគួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនទេ ។ ២ យ៉ាង តើអ្វីខ្លះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនចេះដឹងឆាប់ ក្នុងកុសលធម៌ទាំងឡាយ ថែមទាំងជាអ្នកមិនទ្រទ្រង់នូវធម៌ទាំងឡាយ ដែលខ្លួនស្តាប់ហើយ ទាំងជាអ្នកមិនពិចារណានូវអត្ថនៃធម៌ទាំងឡាយ ដែលខ្លួនទ្រទ្រង់ហើយ ជាអ្នកមិនដឹងនូវអត្ថ មិនដឹងនូវធម៌ ហើយមិនប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ផង តែជាអ្នកមានវាចាល្អ ជាអ្នកមានពាក្យពីរោះប្រកបដោយវាចាអ្នកក្រុង ដែលជាវាចាច្បាស់លាស់ ជាវាចាឥតទោស ជាគ្រឿងញុំាងជនឲ្យដឹងច្បាស់នូវសេចក្តី ១ ជាអ្នកញុំាងពួកសព្រហ្មចារីឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យក្លាហាន ឲ្យរីករាយ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ២ យ៉ាងនេះឯង រមែងគួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឡើយ ។

[៧០] អថខោ អញ្ញតរោ ភិក្ខុ យេន ភគវា តេនុបសង្កមិ ។ បេ ។ ឯកមន្តំ និសិន្នោ ខោ សោ ភិក្ខុ ភគវន្តំ ឯតទវោច សាធុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ យមហំ ភគវតោ ធម្មំ សុត្វា ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរេយ្យន្តិ ។ ឯវមេវ បនិធេកច្ចេ មោឃបុរិសា មមញ្ញេវ[១] អជ្ឈេសន្តិ ធម្មេ ច ភាសិតេ មមញ្ញេវ អនុពន្ធិតព្វំ មញ្ញន្តីតិ ។ ទេសេតុ មេ ភន្តេ ភគវា សង្ខិត្តេន ធម្មំ ទេសេតុ សុគតោ សង្ខិត្តេន ធម្មំ អប្បេវនាមាហំ ភគវតោ ភាសិតស្ស អត្ថំ អាជានេយ្យំ អប្បេវនាមាហំ ភគវតោ ភាសិតស្ស ទាយាទោ អស្សន្តិ ។ តស្មាតិហ តេ ភិក្ខុ ឯវំ សិក្ខិតព្វំ អជ្ឈត្តំ មេ ចិត្តំ ឋិតំ ភវិស្សតិ សុសណ្ឋិតំ ន ចុប្បន្នា បាបកា អកុសលា ធម្មា ចិត្តំ បរិយាទាយ ឋស្សន្តីតិ ។ ឯវញ្ហិ តេ ភិក្ខុ សិក្ខិតព្វំ ។

---

១ ឱ. ម. មមញ្ញេវ ។

[៧០] គ្រានោះ ភិក្ខុមួយរូប បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ។ បេ ។ លុះភិក្ខុនោះ អង្គុយក្នុងទីដ៏សមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់សម្តែងធម៌ដល់ខ្ញុំព្រះអង្គ ដោយសេចក្តីបំប្រួញឲ្យទានដែលខ្ញុំព្រះអង្គបានស្តាប់ធម៌ របស់ព្រះដ៏មានព្រះភាគហើយ ជាបុគ្គលម្នាក់ឯងចៀសចេញទៅ ជាអ្នកមិនធ្វេសប្រហែស មានព្យាយាមដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ។ មោឃបុរសពួកខ្លះ ក្នុងលោកនេះ គ្រាន់តែអារាធនាតថាគតយ៉ាងនេះ កាលធម៌ដែលតថាគតសម្តែងហើយ សម្គាល់តែត្រង់ដើមតាមតថាគតប៉ុណ្ណោះ ។ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ទ្រង់សម្តែងធម៌ដល់ខ្ញុំព្រះអង្គ ដោយសេចក្តីបំប្រួញឲ្យទាន សូមព្រះសុគតទ្រង់សម្តែងធម៌ ដោយសេចក្តីបំប្រួញឲ្យទាន គិតធ្វើដូចម្តេច សូមឲ្យខ្ញុំព្រះអង្គ បានយល់នូវអត្ថនៃភាសិតរបស់ព្រះដ៏មានព្រះភាគ គិតធ្វើដូចម្តេច សូមឲ្យខ្ញុំព្រះអង្គបានទទួលនូវភាសិតរបស់ព្រះដ៏មានព្រះភាគ ។ ម្នាលភិក្ខុ ហេតុដូច្នោះ ក្នុងសាសនានេះ អ្នកគប្បីសិក្សាយ៉ាងនេះថា ចិត្តរបស់អាត្មាអញ នឹងតាំងនៅក្នុងសន្តាន តាំងនៅដោយល្អ ទាំងពួកអកុសលធម៌ដ៏លាមក ក៏មិនកើតឡើងគ្របសង្កត់ចិត្តបានឡើយ ។ ម្នាលភិក្ខុ អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។

២៧៧



យតោ ខោ តេ ភិក្ខុ អជ្ឈត្តំ ចិត្តំ ឋិតំ ហោតិ សុស-ណ្ឋិតំ ន ចុប្បន្នា បាបកា អកុសលា ធម្មា ចិត្តំ បរិយាទាយ តិដ្ឋន្តិ តតោ តេ ភិក្ខុ ឯវំ សិក្ខិតព្វំ មេត្តា មេ ចេតោវិមុត្តិ ភាវិតា ភវិស្សតិ ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធាតិ ។ ឯវញ្ហិ តេ ភិក្ខុ សិក្ខិតព្វំ ។ យតោ ខោ តេ ភិក្ខុ អយំ សមាធិ ឯវំ ភាវិតោ ហោតិ ពហុលីកតោ តតោ ត្វំ ភិក្ខុ ឥមំ សមាធឹ សវិតក្កម្បិ សវិចារំ ភាវេយ្យាសិ អវិតក្កម្បិ វិចារមត្តំ ភាវេយ្យាសិ អវិតក្កម្បិ អវិចារំ ភាវេយ្យាសិ សប្បីតិកម្បិ ភាវេយ្យាសិ និប្បីតិកម្បិ ភាវេយ្យាសិ សាតសហគតម្បិ ភាវេយ្យាសិ ឧបេក្ខាសហគតម្បិ ភាវេយ្យាសិ ។ យតោ ខោ តេ ភិក្ខុ អយំ សមាធិ ឯវំ ភាវិតោ ហោតិ សុភាវិតោ តតោ តេ ភិក្ខុ ឯវំ សិក្ខិតព្វំ ករុណា មេ ចេតោវិមុត្តិ ។ បេ ។ មុទិតា មេ ចេតោវិមុត្តិ ។ បេ ។ ឧបេក្ខា មេ ចេតោវិមុត្តិ

ម្នាលភិក្ខុ កាលណា ចិត្តរបស់អ្នកតាំងនៅក្នុងសន្តាន តាំងនៅល្អហើយ ទាំងពួកអកុសលធម៌ដ៏លាមក ក៏មិនកើតឡើង គ្របសង្កត់ចិត្តបាន ម្នាលភិក្ខុ កាលនោះអ្នកគប្បីសិក្សាយ៉ាងនេះថា ចេតោវិមុត្តិ ប្រកបដោយមេត្តា អាត្មាអញ បានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយ ។ ម្នាលភិក្ខុ អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។ ម្នាលភិក្ខុ កាលណា សមាធិនេះ អ្នកបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយយ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នកគួរចម្រើននូវសមាធិនេះ ដែលប្រកបដោយវិតក្កៈនិងវិចារៈផង គួរចម្រើននូវសមាធិដែលមិនមានវិតក្កៈផង មានតែវិចារៈប៉ុណ្ណោះ គួរចម្រើននូវសមាធិ ដែលមិនមានវិតក្កៈ មិនមានវិចារៈផង គួរចម្រើននូវសមាធិ ដែលប្រកបដោយបីតិផង គួរចម្រើននូវសមាធិ ដែលមិនមានបីតិផង គួរចម្រើននូវសមាធិ ដែលប្រកបដោយសេចក្ដីសប្បាយផង គួរចម្រើននូវសមាធិដែលប្រកបដោយឧបេក្ខាផង ។ ម្នាលភិក្ខុ កាលណា សមាធិនេះ អ្នកបានចម្រើនហើយ បានចម្រើនល្អហើយ យ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នកគប្បីសិក្សាយ៉ាងនេះថា ចេតោវិមុត្តិប្រកបដោយករុណា អាត្មាអញ ។ បេ ។ ចេតោវិមុត្តិប្រកបដោយមុទិតា អាត្មាអញ ។ បេ ។ ចេតោវិមុត្តិ ប្រកបដោយឧបេក្ខា

ភាវិតា ភវិស្សតិ ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធាតិ ។ ឯវញ្ហិ តេ ភិក្ខុ សិក្ខិតព្វំ ។ យតោ ខោ តេ ភិក្ខុ អយំ សមាធិ ឯវំ ភាវិតោ ហោតិ ពហុលីកតោ តតោ ត្វំ ភិក្ខុ ឥមំ សមាធឹ សវិតក្កម្បិ សវិចារំ ភាវេយ្យាសិ អវិតក្កម្បិ វិចារមត្តំ ភាវេយ្យាសិ អវិតក្កម្បិ អវិចារំ ភាវេយ្យាសិ សប្បីតិកម្បិ ភាវេយ្យាសិ និប្បីតិកម្បិ ភាវេយ្យាសិ សាតសហគតម្បិ ភាវេយ្យាសិ ឧបេក្ខាសហគតម្បិ ភាវេយ្យាសិ ។ យតោ ខោ តេ ភិក្ខុ អយំ សមាធិ ឯវំ ភាវិតោ ហោតិ សុភាវិតោ តតោ តេ ភិក្ខុ ឯវំ សិក្ខិតព្វំ កាយេ កាយានុបស្សី វិហរិស្សាមិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមន-ស្សន្តិ ។ ឯវញ្ហិ តេ ភិក្ខុ សិក្ខិតព្វំ ។ យតោ ខោ តេ ភិក្ខុ អយំ សមាធិ ឯវំ ភាវិតោ ហោតិ ពហុលីកតោ

អាត្មាអញបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយ ។ ម្នាលភិក្ខុ អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។ ម្នាលភិក្ខុ កាលណា សមាធិនេះ អ្នកបានចម្រើនហើយ ធ្វើឲ្យច្រើនហើយយ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នកគួរចម្រើននូវសមាធិនេះ ដែលប្រកបដោយវិតក្កវិចារៈផង អ្នកគួរចម្រើនសមាធិ ដែលមិនមានវិតក្កៈមានតែវិចារៈផង អ្នកគួរចម្រើនសមាធិ ដែលមិនមានវិតក្កៈមិនមានវិចារៈផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយបីតិផង អ្នកគួរចម្រើនសមាធិ ដែលមិនមានបីតិផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយសេចក្តីសប្បាយផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយឧបេក្ខាផង ។ ម្នាលភិក្ខុ កាលណា សមាធិនេះ អ្នកបានចម្រើនហើយ បានចម្រើនល្អហើយយ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នកគប្បីសិក្សាយ៉ាងនេះថា អាត្មាអញនឹងពិចារណា នូវកាយក្នុងកាយជាប្រក្រតី មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្សក្នុងលោកចេញ ។ ម្នាលភិក្ខុ អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។ ម្នាលភិក្ខុ កាលណា សមាធិនេះ អ្នកបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយ យ៉ាងនេះ

តតោ ត្វំ ភិក្ខុ ឥមំ សមាធឹ សវិតក្កម្បិ សវិចារំ ភាវេយ្យាសិ អវិតក្កម្បិ វិចារមត្តំ ភាវេយ្យាសិ អវិតក្កម្បិ អវិចារំ ភាវេយ្យាសិ សប្បីតិកម្បិ ភាវេ-យ្យាសិ និប្បីតិកម្បិ ភាវេយ្យាសិ សាតសហគតម្បិ ភាវេយ្យាសិ ឧបេក្ខាសហគតម្បិ ភាវេយ្យាសិ ។ យតោ ខោ តេ ភិក្ខុ អយំ សមាធិ ឯវំ ភាវិតោ ហោតិ សុភាវិតោ តតោ តេ ភិក្ខុ ឯវំ សិក្ខិតព្វំ វេទនាសុ ។ បេ ។ ចិត្តេ ។ បេ ។ ធម្មេសុ ធម្មា-នុបស្សី វិហរិស្សាមិ អាតាបី សម្បជានោ សតិមា វិនេយ្យ លោកេ អភិជ្ឈាទោមនស្សន្តិ ។ ឯវញ្ហិ តេ ភិក្ខុ សិក្ខិតព្វំ ។ យតោ ខោ តេ ភិក្ខុ អយំ សមាធិ ឯវំ ភាវិតោ ហោតិ ពហុលីកតោ តតោ ត្វំ ភិក្ខុ ឥមំ សមាធឹ សវិតក្កម្បិ សវិចារំ ភាវេយ្យាសិ អវិតក្កម្បិ វិចារមត្តំ ភាវេយ្យាសិ អវិតក្កម្បិ អវិចារំ ភាវេយ្យាសិ សប្បីតិកម្បិ ភាវេយ្យាសិ

ម្នាលភិក្ខុ កាលនោះ អ្នកគួរចម្រើនសមាធិនេះ ដែលប្រកបដោយវិតក្ក-វិចារៈផង អ្នកគួរចម្រើនសមាធិ ដែលមិនមានវិតក្កៈ មានតែវិចារៈផង អ្នកគួរចម្រើនសមាធិ ដែលមិនមានវិតក្កៈ មិនមានវិចារៈផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយបីតិផង អ្នកគួរចម្រើនសមាធិ ដែលមិនមានបីតិផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយសេចក្ដីសប្បាយផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយឧបេក្ខាផង ។ ម្នាលភិក្ខុ កាលណា សមាធិនេះ អ្នកបានចម្រើនហើយ បានចម្រើនល្អហើយ យ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នកគប្បីសិក្សាយ៉ាងនេះថា ក្នុងវេទនាទាំងឡាយ ។ បេ ។ ក្នុងចិត្ត ។ បេ ។ អាត្មាអញនឹងពិចារណាឃើញ នូវធម៌ក្នុងធម៌ទាំងឡាយជាប្រក្រតី មានព្យាយាមជាគ្រឿងដុតកម្ដៅកិលេស ជាអ្នកដឹងខ្លួន មានស្មារតី កម្ចាត់បង់នូវអភិជ្ឈានិងទោមនស្ស ក្នុងលោកចេញ ។ ម្នាលភិក្ខុ អ្នកគប្បីសិក្សាយ៉ាងនេះចុះ ។ ម្នាលភិក្ខុ កាលណា សមាធិនេះ អ្នកបានចម្រើនហើយ បានធ្វើឲ្យច្រើនហើយយ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នកគួរចម្រើនសមាធិនេះ ដែលប្រកបដោយវិតក្កវិចារៈផង អ្នកគួរចម្រើនសមាធិ ដែលមិនមានវិតក្កៈ មានតែវិចារៈផង អ្នកគួរចម្រើនសមាធិ ដែលមិនមានវិតក្កៈ មិនមានវិចារៈផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយបីតិផង

និប្បីតិកម្បិ ភាវេយ្យាសិ សាតសហគតម្បិ ភាវេយ្យាសិ ឧបេក្ខាសហគតម្បិ ភាវេយ្យាសិ ។ យតោ ខោ តេ ភិក្ខុ អយំ សមាធិ ឯវំ ភាវិតោ ហោតិ សុភាវិតោ តតោ ត្វំ ភិក្ខុ យេន យេនេវ គគ្ឃសិ[១] ផាសុយេវ គគ្ឃសិ[២] យត្ថ យត្ថ ឋស្សសិ ផាសុយេវ ឋស្សសិ យត្ថ យត្ថ និសីទិស្សសិ យត្ថ យត្ថ សេយ្យំ កប្បិស្សសិ ផាសុយេវ សេយ្យំ កប្បិស្សសីតិ ។

អថខោ សោ ភិក្ខុ ភគវតា ឥមិនា ឱវាទេន ឱវទិតោ ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា បក្កាមិ ។ អថខោ សោ ភិក្ខុ ឯកោ វូបកដ្ឋោ អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ន ចិរស្សេវ យស្សត្ថាយ កុលបុត្តា សម្មទេវ អគារស្មា អនគារិយំ បព្វជន្តិ តទនុត្តរំ ព្រហ្មចរិយបរិយោសានំ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហាសិ

១-២ ឱ. គច្ឆសិ ។ ម. គគ្ឃសិ ។

អ្នកគួរចម្រើនសមាធិ ដែលមិនមានបីតិផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយសេចក្តីសប្បាយផង អ្នកគួរចម្រើនសមាធិ ដែលប្រកបដោយឧបេក្ខាផង ។ ម្នាលភិក្ខុ កាលណា សមាធិនេះ អ្នកបានចម្រើនហើយ បានចម្រើនល្អហើយយ៉ាងនេះ ម្នាលភិក្ខុ កាលនោះ អ្នកនឹងទៅក្នុងទីណាៗ អ្នកនឹងនៅសប្បាយ ក្នុងទីនោះៗ អ្នកនឹងឈរនៅ ក្នុងទីណាៗ អ្នកនឹងឈរនៅសប្បាយ ក្នុងទីនោះៗ អ្នកនឹងអង្គុយ ក្នុងទីណាៗ អ្នកនឹងអង្គុយសប្បាយ ក្នុងទីនោះៗ អ្នកនឹងសម្រេចការដេក ក្នុងទីណាៗ អ្នកនឹងសម្រេចការដេកសប្បាយ ក្នុងទីនោះ ។

គ្រានោះ ភិក្ខុនោះ ដែលព្រះដ៏មានព្រះភាគ ទូន្មានដោយឱវាទនេះហើយ ក៏ក្រោកចាកអាសនៈ ហើយក្រាបថ្វាយបង្គំលាព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណាចៀសចេញទៅ ។ លំដាប់នោះ ភិក្ខុនោះ តែម្នាក់ឯងចៀសចេញទៅ មិនធ្វេសប្រហែស មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន កុលបុត្តចេញចាកផ្ទះ ចូលទៅកាន់ផ្នួសដោយប្រពៃ ដើម្បីប្រយោជន៍ដល់អនុត្តរធម៌ណា មិនយូរប៉ុន្មាន លោកក៏ធ្វើឲ្យជាក់ច្បាស់នូវអនុត្តរធម៌ ដែលមានព្រហ្មចរិយៈជាទីបំផុតនោះ ដោយប្រាជ្ញាដ៏ប្រសើររបស់ខ្លួនក្នុងបច្ចុប្បន្ននេះ

ខីណា ជាតិ វុសិតំ ព្រហ្មចរិយំ កតំ ករណីយំ នាបរំ ឥត្ថត្តាយាតិ អព្ភញ្ញាសិ ។ អញ្ញតរោ ច បន សោ ភិក្ខុ អរហតំ អហោសីតិ ។

[៧១] ឯកំ សមយំ ភគវា គយាយំ វិហរតិ គយា-សីសេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ បេ ។ ភគវា ឯតទវោច បុព្វាហំ ភិក្ខវេ សម្ពោធា អនភិសម្ពុទ្ធោ ពោធិសត្តោ វ សមានោ ឱភាសំបិ ខោ សញ្ជានាមិ នោ ច រូបានិ បស្សាមិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ សចេ ខោ អហំ ឱភាសញ្ចេវ សញ្ជានេយ្យំ រូបានិ ច បស្សេយ្យំ ឯវម្មេ ឥទំ ញាណទស្សនំ បរិសុទ្ធតរំ អស្សាតិ ។ សោ ខោ អហំ ភិក្ខវេ អបរេន សមយេន អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ឱភាសញ្ចេវ សញ្ជានាមិ

ដឹងច្បាស់ថា ជាតិរបស់អាត្មាអញអស់ហើយ ព្រហ្មចរិយធម៌អាត្មាអញបានប្រព្រឹត្តគ្រប់គ្រាន់ហើយ សោឡសកិច្ច អាត្មាអញបានធ្វើរួចហើយ មគ្គភាវនាកិច្ចដទៃទៀត ប្រព្រឹត្តទៅ ដើម្បីសោឡសកិច្ចនេះមិនមានឡើយ ។ មានសេចក្តីសរសើរថា បណ្តាព្រះអរហន្តទាំងឡាយភិក្ខុនោះ ក៏ជាព្រះអរហន្ត មួយអង្គដែរ ។

[៧១] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងគយាសីសប្រទេស ទៀបស្រុកគយា ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ។ បេ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ពាក្យនេះថា ម្នាលភិក្ខុទាំងឡាយ កាលមុនអំពីការត្រាស់ដឹង តថាគតនៅជាពោធិសត្វ មិនទាន់ត្រាស់ដឹងនៅឡើយ ស្គាល់នូវពន្លឺដោយច្បាស់លាស់ តែមិនឃើញនូវរូបទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយតថាគតនោះ ក៏មានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រសិនបើតថាគតស្គាល់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង ញាណទស្សនៈរបស់តថាគតនេះ គប្បីបរិសុទ្ធយ៉ាងក្រៃលែង យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយសម័យដទៃទៀត តថាគតនោះ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ស្គាល់ច្បាស់នូវពន្លឺផង

រូបានិ ច បស្សាមិ ញោ ច ខោ តាហិ ទេវតាហិ សទ្ធឹ សន្តិដ្ឋាមិ សល្លបាមិ សាកច្ឆំ សមាបជ្ជាមិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ សចេ ខោ អហំ ឱភាសញ្ចេវ សញ្ជានេយ្យំ រូបានិ ច បស្សេយ្យំ តាហិ ច ទេវតាហិ សទ្ធឹ សន្តិដ្ឋេយ្យំ សល្លបេយ្យំ សាកច្ឆំ សមាបជ្ជេយ្យំ ឯវម្មេ ឥទំ ញាណទស្សនំ បរិសុទ្ធតរំ អស្សាតិ ។ សោ ខោ អហំ ភិក្ខវេ អបរេន សមយេន អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ឱភាសញ្ចេវ សញ្ជានាមិ រូបានិ ច បស្សាមិ តាហិ ច ទេវតាហិ សទ្ធឹ សន្តិដ្ឋាមិ សល្លបាមិ សាកច្ឆំ សមាបជ្ជាមិ ញោ ច ខោ តា ទេវតា ជានាមិ ឥមា ទេវតា អមុកម្ហា វា អមុកម្ហា វា ទេវនិកាយាតិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ សចេ ខោ អហំ ឱភាសញ្ចេវ សញ្ជានេយ្យំ រូបានិ ច បស្សេយ្យំ តាហិ ច ទេវតាហិ សទ្ធឹ សន្តិដ្ឋេយ្យំ សល្ល-បេយ្យំ សាកច្ឆំ សមាបជ្ជេយ្យំ តា ច ទេវតា ជានេយ្យំ

ឃើញច្បាស់នូវរូបទាំងឡាយផង តែមិនឋិតនៅជាមួយ មិនចរចាជាមួយ មិនដល់នូវការសាកច្ឆា ជាមួយនឹងទេវតាទាំងឡាយនោះ ។ ម្នាលភិក្ខុទាំង-ឡាយ តថាគតនោះ មានសេចក្តីត្រិះរិះ យ៉ាងនេះថា ប្រសិនបើ តថាគត ស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង គប្បីឋិតនៅ ជាមួយ គប្បីចរចាជាមួយ គប្បីដល់នូវការសាកច្ឆា ជាមួយនឹង ទេវតាទាំងឡាយផង ញាណទស្សនៈរបស់តថាគតនេះ គប្បីបរិសុទ្ធ ក្រៃលែង យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ សម័យមួយទៀត តថាគតនោះ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់ នូវរូបទាំងឡាយផង ក៏ឋិតនៅជាមួយ ចរចាជាមួយ ដល់នូវការសាកច្ឆា ជាមួយនឹងទេវតាទាំងឡាយនោះផង តែមិនស្គាល់នូវទេវតាទាំងឡាយ នោះថា ទេវតាទាំងឡាយនេះ មកអំពីទេវនិកាយឯណោះៗ ដូច្នេះ ផង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រសិនបើតថាគត ស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយ ផង ក៏ឋិតនៅជាមួយ ចរចាជាមួយ ដល់នូវការសាកច្ឆា ជាមួយនឹង ទេវតាទាំងឡាយនោះផង តថាគតស្គាល់នូវទេវតាទាំងឡាយនោះថា

២៨៣

## បណ្ណាសកាសង្គហិតោ ចាលវគ្គោ

ឥមា ទេវតា អមុកម្ហា វា អមុកម្ហា វា ទេវនិកាយាតិ ឯវម្មេ ឥទំ ញាណទស្សនំ បរិសុទ្ធតរំ អស្សាតិ ។ សោ ខោ អហំ ភិក្ខវេ អបរេន សមយេន អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ឱភាសញ្ចេវ សញ្ជានាមិ រូបានិ ច បស្សាមិ តាហិ ច ទេវតាហិ សទ្ធឹ សន្តិដ្ឋាមិ សល្លបាមិ សាកច្ឆំ សមាបជ្ជាមិ តា ច ទេវតា ជានាមិ ឥមា ទេវតា អមុកម្ហា វា អមុកម្ហា វា ទេវនិកាយាតិ នោ ច ខោ តា ទេវតា ជានាមិ ឥមា ទេវតា ឥមស្ស កម្មស្ស វិបាកេន ឥតោ ចុតា តត្ថ ឧបបន្នាតិ តា ច ទេវតា ជានាមិ ឥមា ទេវតា ឥមស្ស កម្មស្ស វិបាកេន ឥតោ ចុតា តត្ថ ឧបបន្នាតិ នោ ច ខោ តា ទេវតា ជានាមិ ឥមា ទេវតា ឯវមាហារា ឯវំសុខទុក្ខប្បដិសំវេទិ-និយោតិ តា ច ទេវតា ជានាមិ ឥមា ទេវតា ឯវមាហារា ឯវំសុខទុក្ខប្បដិសំវេទិនិយោតិ នោ ច ខោ តា ទេវតា ជានាមិ ឥមា ទេវតា ឯវំទីឃាយុកា ឯវំចិរដ្ឋិតិកាតិ

ទេវតាទាំងឡាយនេះ មកអំពីទេវនិកាយឯណោះៗ ដូច្នេះផង ញាណ-ទស្សនៈរបស់តថាគតនោះ គប្បីបរិសុទ្ធក្រៃលែងយ៉ាងនេះ ។ ម្នាលភិក្ខុទាំង-ឡាយ សម័យខាងក្រោយមក តថាគតនោះឯង ជាអ្នកមិនមានសេចក្តីប្រមាទ មានព្យាយាម ជាគ្រឿងដុតកម្តៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង ក៏ឋិតនៅជាមួយ ចរចាជាមួយ ដល់នូវការសាកច្ឆា ជាមួយនឹងទេវតាទាំងនោះផង ស្គាល់នូវទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មកអំពីទេវនិ-កាយឯណោះៗ ដូច្នេះផង តែមិនស្គាល់នូវទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ ដោយផលកម្មនេះ ដូច្នេះផង ស្គាល់នូវទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ ដោយផលកម្មនេះដូច្នេះផង តែមិនស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះ ដូច្នេះផង ស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះ ដូច្នេះផង តែមិនស្គាល់ទេវតាទាំងនោះថា ទេវតាទាំងនេះ មានអាយុវែងយ៉ាងនេះ ឋិតនៅអស់កាលយូរយ៉ាងនេះ ដូច្នេះផង

តា ច ទេវតា ជានាមិ ឥមា ទេវតា ឯវំទីឃាយុកា ឯវំចិរដ្ឋិតិកាតិ នោ ច ខោ តា ទេវតា ជានាមិ យទិ វា មេ ឥមាហិ ទេវតាហិ សទ្ធឹ សន្និវុត្ថបុព្វំ យទិ វា ន សន្និវុត្ថបុព្វន្តិ ។ តស្ស មយ្ហំ ភិក្ខវេ ឯតទហោសិ សចេ ខោ អហំ ឱភាសញ្ចេវ សញ្ជានេយ្យំ រូបានិ ច បស្សេយ្យំ តាហិ ច ទេវតាហិ សទ្ធឹ សន្តិដ្ឋេយ្យំ សល្លបេយ្យំ សាកច្ឆំ សមាបជ្ជេយ្យំ តា ច ទេវតា ជានេយ្យំ ឥមា ទេវតា អមុកម្ហា វា អមុកម្ហា វា ទេវនិកាយាតិ តា ច ទេវតា ជានេយ្យំ ឥមា ទេវតា ឥមស្ស កម្មស្ស វិបាកេន ឥតោ ចុតា តត្ថ ឧបបន្នាតិ តា ច ទេវតា ជានេយ្យំ ឥមា ទេវតា ឯវមាហារា ឯវំសុខទុក្ខប្បដិសំវេទិនិយោតិ តា ច ទេវតា ជានេយ្យំ ឥមា ទេវតា ឯវំទីឃាយុកា ឯវំចិរដ្ឋិតិកាតិ តា ច ទេវតា ជានេយ្យំ យទិ វា មេ ឥមាហិ ទេវតាហិ សទ្ធឹ សន្និវុត្ថបុព្វំ យទិ វា ន សន្និវុត្ថបុព្វន្តិ ឯវម្មេ ឥទំ ញាណទស្សនំ បរិសុទ្ធតរំ អស្សាតិ ។

ស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាយុវែងយ៉ាងនេះ ឋិតនៅអស់កាលយូរយ៉ាងនេះ ដូច្នេះផង តែមិនស្គាល់ទេវតាទាំងនោះថា អាត្មាអញ ធ្លាប់នៅជាមួយនឹងទេវតាទាំងឡាយនេះ ឬថា មិនធ្លាប់នៅជាមួយ ដូច្នេះផង ។ ម្នាលភិក្ខុទាំងឡាយ តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ប្រសិនបើ អាត្មាស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង ឋិតនៅជាមួយ ចរចាជាមួយ ដល់នូវការសាកច្ឆា ជាមួយនឹងទេវតាទាំងនោះផងគប្បីស្គាល់នូវទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មកអំពីទេវនិកាយឯណោះៗ ដូច្នេះផង គប្បីស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ ដោយផលកម្មនេះដូច្នេះផង គប្បីស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះ ដូច្នេះផង គប្បីស្គាល់នូវទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាយុវែងយ៉ាងនេះ ឋិតនៅអស់កាលយូរយ៉ាងនេះ ដូច្នេះផង គប្បីស្គាល់នូវទេវតាទាំងនោះថា អាត្មាអញធ្លាប់នៅជាមួយនឹងទេវតាទាំងឡាយ ឬថា មិនធ្លាប់នៅជាមួយទេ ដូច្នេះផង ញាណទស្សនៈរបស់តថាគតនេះ គប្បីបរិសុទ្ធក្រៃលែងយ៉ាងនេះ ។

សោ ខោ អហំ ភិក្ខវេ អបរេន សមយេន អប្បមត្តោ អាតាបី បហិតត្តោ វិហរន្តោ ឱភាសញ្ចេវ សញ្ជានាមិ រូបានិ ច បស្សាមិ តាហិ ច ទេវតាហិ សទ្ធឹ សន្តិដ្ឋាមិ សល្លបាមិ សាកច្ឆំ សមាបជ្ជាមិ តា ច ទេវតា ជានាមិ ឥមា ទេវតា អមុកម្ហា វា អមុកម្ហា វា ទេវនិកាយាតិ តា ច ទេវតា ជានាមិ ឥមា ទេវតា ឥមស្ស កម្មស្ស វិបាកេន ឥតោ ចុតា តត្ថ ឧបបន្នាតិ តា ច ទេវតា ជានាមិ ឥមា ទេវតា ឯវមាហារា ឯវំសុខទុក្ខប្បដិសំវេ-ទិនិយោតិ តា ច ទេវតា ជានាមិ ឥមា ទេវតា ឯវំទី-ឃាយុកា ឯវំចិរដ្ឋិតិកាតិ តា ច ទេវតា ជានាមិ យទិ វា មេ តាហិ ទេវតាហិ សទ្ធឹ សន្និវុត្ថបុព្វំ យទិ វា ន សន្និវុត្ថបុព្វន្តិ ។ យាវកីវញ្ច មេ ភិក្ខវេ ឯវំ អដ្ឋបរិវដ្ដំ អធិទេវញ្ញាណទស្សនំ ន សុវិសុទ្ធំ អហោសិ

ម្នាលភិក្ខុទាំងឡាយ សម័យដទៃទៀត តថាគតនោះ ជាអ្នកមិនប្រមាទ មានព្យាយាមជាគ្រឿងកម្ដៅកិលេស មានចិត្តបញ្ជូនទៅកាន់ព្រះនិព្វាន ស្គាល់ច្បាស់នូវពន្លឺផង ឃើញច្បាស់នូវរូបទាំងឡាយផង ឋិតនៅជាមួយ ចរចាជាមួយ ដល់នូវការសាកច្ឆា ជាមួយនឹងទេវតាទាំងឡាយនោះផង ស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មកអំពីទេវនិកាយឯណោះៗ ដូច្នេះផង ស្គាល់ទេវតាទាំងឡាយនោះថា ទេវតាទាំងឡាយនេះ ច្យុតអំពីទីនេះ ទៅកើតក្នុងទីនោះ ដោយផលកម្មនេះ ដូច្នេះផង ស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាហារយ៉ាងនេះ សោយសុខទុក្ខយ៉ាងនេះ ដូច្នេះផង ស្គាល់ទេវតាទាំងនោះថា ទេវតាទាំងឡាយនេះ មានអាយុវែងយ៉ាងនេះ ឋិតនៅអស់កាលយូរយ៉ាងនេះ ដូច្នេះផង ស្គាល់ទេវតាទាំងនោះថា អាត្មាអញធ្លាប់នៅជាមួយនឹងទេវតាទាំងឡាយនោះ ឬថា មិនធ្លាប់នៅជាមួយទេ ដូច្នេះផង ។ ម្នាលភិក្ខុទាំងឡាយ អធិទេវញ្ញាណទស្សនៈ (ការដឹងនិងការឃើញនូវទេវតាដ៏ក្រៃលែង) របស់តថាគតមានបរិវដ្ដ ៨ ប្រការយ៉ាងនេះ មិនបរិសុទ្ធដរាបណា

នេវ តាវាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវ-មនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ច-ញ្ញាសឹ ។ យតោ ច ខោ មេ ភិក្ខវេ ឯវំ អដ្ឋបរិវដ្តំ អធិទេវញ្ញាណទស្សនំ សុវិសុទ្ធំ អហោសិ អថាហំ ភិក្ខវេ សទេវកេ លោកេ សមារកេ សព្រហ្មកេ សស្សមណព្រាហ្មណិយា បជាយ សទេវមនុស្សាយ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុទ្ធោ បច្ចញ្ញាសឹ ។ ញាណញ្ច បន មេ ទស្សនំ ឧទបាទិ អកុប្បា មេ ចេតោវិមុត្តិ អយមន្តិមា ជាតិ នត្ថិទានិ បុនព្ភវោតិ ។

[៧២] អដ្ឋិមានិ ភិក្ខវេ អភិភាយតនានិ ។ កតមានិ អដ្ឋ ។ អជ្ឈត្តំ រូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ

ម្នាលភិក្ខុទាំងឡាយ តថាគត ក៏មិនទាន់ប្តេជ្ញាខ្លួនថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងលោក ព្រមទាំងទេវលោក មារលោក និងព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទេវតានិងមនុស្សដរាបនោះ ។ ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលណា អធិទេវញ្ញាណទស្សនៈ របស់តថាគតមានបរិវដ្ដ ៨ ប្រការយ៉ាងនេះ បរិសុទ្ធហើយ ម្នាលភិក្ខុទាំងឡាយ កាលនោះ តថាគតប្តេជ្ញាខ្លួន ថាជាអ្នកត្រាស់ដឹងនូវអនុត្តរសម្មាសម្ពោធិញ្ញាណ ក្នុងលោក ព្រមទាំងទេវលោក មារលោក ព្រហ្មលោក ក្នុងពពួកសត្វ ព្រមទាំងសមណព្រាហ្មណ៍ ទេវតានិងមនុស្ស ។ មិនតែប៉ុណ្ណោះសោត ញាណទស្សនៈក៏កើតឡើងដល់តថាគតថា ចេតោវិមុត្តិរបស់តថាគតមិនកម្រើក ជាតិនេះជាជាតិទីបំផុតក្នុងកាលឥឡូវនេះ ភពថ្មីមិនមានទៀតឡើយ ។

[៧២] ម្នាលភិក្ខុទាំងឡាយ អភិភាយតនៈ (ហេតុជាគ្រឿងគ្របសង្កត់នូវធម៌ជាសត្រូវផង នូវអារម្មណ៍ផង) នេះមាន ៨ យ៉ាង ។ ៨ យ៉ាងតើអ្វីខ្លះ ។ គឺបុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណតិច មានសម្បុរល្អ ឬ សម្បុរអាក្រក់

តានិ អភិកុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ បឋមំ អភិភាយតនំ ។ អជ្ឈត្តំ រូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិកុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ទុតិយំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ តានិ អភិកុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ តតិយំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិកុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ចតុត្ថំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ នីលានិ នីលវណ្ណានិ នីលនិទស្សនានិ នីលនិភាសានិ តានិ អភិកុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ បញ្ចមំ អភិភាយតនំ ។

គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ១ ។ បុគ្គលពួកមួយ មានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណច្រើន មានសម្បុរល្អ ឬ សម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ២ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណតិច មានសម្បុរល្អ ឬ សម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិ-ភាយតនៈទី ៣ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណច្រើន មានសម្បុរល្អ ឬ សម្បុរអាក្រក់ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៤ ។ បុគ្គលពួកមួយ មិនមានសេចក្តីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបខៀវ មានសម្បុរខៀវ ជាទីចង្អុលប្រាប់ថា នេះមានសម្បុរខៀវ មានពន្លឺខៀវ គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៥ ។

អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ បីតានិ បីតវណ្ណានិ បីតនិទស្សនានិ បីតនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ ឆដ្ឋំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ លោហិតកានិ លោហិតកវណ្ណានិ លោហិតកនិទស្សនានិ លោហិតកនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ សត្តមំ អភិភាយតនំ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ ឱទាតានិ ឱទាតវណ្ណានិ ឱទាតនិទស្សនានិ ឱទាតនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ឥទំ អដ្ឋមំ អភិភាយតនំ ។ ឥមានិ ខោ ភិក្ខវេ អដ្ឋ អភិភាយតនានីតិ ។

បុគ្គលពួកមួយ មិនមានសេចក្ដីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបលឿង មានសម្បុរលឿង ជាទីចង្អុលប្រាប់ថា នេះមានសម្បុរលឿង មានពន្លឺលឿង គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈទី ៦ ។ បុគ្គលពួកមួយ មិនមានសេចក្ដីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបក្រហម មានសម្បុរក្រហម ជាទីចង្អុលប្រាប់ថា នេះមានសម្បុរក្រហម មានពន្លឺក្រហម គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភា-យតនៈ ទី ៧ ។ បុគ្គលពួកមួយ មិនមានសេចក្ដីសម្គាល់នូវរូបខាងក្នុង ឃើញនូវរូបខាងក្រៅ ជារូបស មានសម្បុរស ជាទីចង្អុលប្រាប់ថា នេះមានសម្បុរស មានពន្លឺស គ្របសង្កត់នូវរូបទាំងនោះហើយមានសេចក្ដីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញដូច្នេះ នេះជាអភិភាយតនៈ ទី ៨ ។ ម្នាលភិក្ខុទាំងឡាយ អភិភាយតនៈមាន ៨ យ៉ាងនេះឯង ។

[៧៣] អដ្ឋិមេ ភិក្ខវេ វិមោក្ខា ។ កតមេ អដ្ឋ ។ រូបី រូបានិ បស្សតិ អយំ បឋមោ វិមោក្ខោ ។ អជ្ឈត្តំ អរូបសញ្ញី ឯកោ ពហិទ្ធា រូបានិ បស្សតិ អយំ ទុតិយោ វិមោក្ខោ ។ សុភន្តេវ អធិមុត្តោ ហោតិ អយំ តតិយោ វិមោក្ខោ ។ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ចតុត្ថោ វិមោក្ខោ ។ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ អយំ បញ្ចមោ វិមោក្ខោ ។ សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ ឆដ្ឋោ វិមោក្ខោ ។ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ អយំ សត្តមោ វិមោក្ខោ ។

[៧៣] ម្នាលភិក្ខុទាំងឡាយ វិមោក្ខនេះមាន ៨ យ៉ាង ។ ៨ យ៉ាង តើអ្វីខ្លះ ។ គឺបុគ្គលមានរូបជ្ឈាន រមែងឃើញនូវរូបគឺកសិណទាំងឡាយ (មាននីលកសិណជាដើម) នេះជាវិមោក្ខទី ១ ។ បុគ្គលពួកមួយ មិនមានសេចក្ដីសម្គាល់នូវរូបខាងក្នុង (មានសក់ជាដើម) រមែងឃើញនូវរូបខាងក្រៅទាំងឡាយគឺកសិណ (មាននីលកសិណជាដើម) នេះជាវិមោក្ខទី ២ ។ បុគ្គលមានចិត្តចុះស៊ប់ថា វណ្ណកសិណដ៏បរិសុទ្ធ នេះជាវិមោក្ខទី ៣ ។ ព្រោះកន្លងនូវរូបសញ្ញា ដោយប្រការទាំងពួង ដល់នូវសេចក្ដីវិនាសនៃបដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា បានដល់នូវអាកាសានញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អាកាសមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៤ ។ ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា វិញ្ញាណមិនមានទីបំផុតដូច្នេះ នេះជាវិមោក្ខទី ៥ ។ ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចក៏មិនមានដូច្នេះ នេះជាវិមោក្ខទី ៦ ។ ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង បានដល់នូវនេវសញ្ញានាសញ្ញាយតនជ្ឈាន នេះជាវិមោក្ខទី ៧ ។

សព្វសោ នេវសញ្ញានាសញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ អយំ អដ្ឋមោ វិមោក្ខោ ។ ឥមេ ខោ ភិក្ខវេ អដ្ឋ វិមោក្ខាតិ ។

[៧៤] អដ្ឋិមេ ភិក្ខវេ អនរិយវោហារា ។ កាតមេ អដ្ឋ ។ អទិដ្ឋេ ទិដ្ឋវាទិតា អស្សុតេ សុតវាទិតា អមុតេ មុតវាទិតា អវិញ្ញាតេ វិញ្ញាតវាទិតា ទិដ្ឋេ អទិដ្ឋវាទិតា សុតេ អស្សុតវាទិតា មុតេ អមុតវាទិតា វិញ្ញាតេ អវិញ្ញា-តវាទិតា ។ ឥមេ ខោ ភិក្ខវេ អដ្ឋ អនរិយវោហារាតិ ។

[៧៥] អដ្ឋិមេ ភិក្ខវេ អរិយវោហារា ។ កាតមេ អដ្ឋ ។ អទិដ្ឋេ អទិដ្ឋវាទិតា អស្សុតេ អស្សុតវាទិតា អមុតេ អមុតវាទិតា អវិញ្ញាតេ អវិញ្ញាតវាទិតា ទិដ្ឋេ ទិដ្ឋវាទិតា សុតេ សុតវាទិតា មុតេ មុតវាទិតា វិញ្ញាតេ វិញ្ញាតវា-ទិតា ។ ឥមេ ខោ ភិក្ខវេ អដ្ឋ អរិយវោហារាតិ ។

ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង បាន ដល់នូវសញ្ញាវេទយិតនិរោធ (សេចក្តីរលត់នៃសញ្ញានិងវេទនា) នេះជា វិមោក្ខទី ៨ ។ ម្នាលភិក្ខុទាំងឡាយ វិមោក្ខមាន ៨ យ៉ាងនេះឯង ។

[៧៤] ម្នាលភិក្ខុទាំងឡាយ អនរិយវោហារ (វោហារមិនប្រសើរ) នេះមាន ៨ យ៉ាង ។ ៨ យ៉ាង តើអ្វីខ្លះ ។ គឺមិនឃើញ និយាយថា ឃើញ ១ មិនឮ និយាយថា ឮ ១ មិនបានហិតភ្លក់ និយាយថា បានហិតភ្លក់ ១ មិនដឹងនិយាយថា ដឹង ១ ឃើញនិយាយថា មិនឃើញ ១ ឮ និយាយថា មិនឮ ១ បានហិតភ្លក់ និយាយថា មិនបានហិតភ្លក់ ១ ដឹង និយាយថា មិនដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ អនរិយវោហារ មាន ៨ យ៉ាងនេះ ឯង ។

[៧៥] ម្នាលភិក្ខុទាំងឡាយ អរិយវោហារ (វោហារដ៏ប្រសើរ) នេះ មាន ៨ យ៉ាង ។ ៨ យ៉ាង តើអ្វីខ្លះ ។ គឺមិនឃើញ និយាយថា មិនឃើញ ១ មិនឮ និយាយថា មិនឮ ១ មិនបានហិតភ្លក់និយាយថា មិនបានហិត ភ្លក់ ១ មិនដឹង និយាយថា មិនដឹង ១ ឃើញ និយាយថា ឃើញ ១ ឮ និយាយថា ឮ ១ បានហិតភ្លក់ និយាយថា បានហិតភ្លក់ ១ ដឹង និយាយ ថាដឹង ១ ។ ម្នាលភិក្ខុទាំងឡាយ អរិយវោហារមាន ៨ យ៉ាងនេះឯង ។

[៧៦] អដ្ឋិមា ភិក្ខវេ បរិសា ។ កតមា អដ្ឋ ។ ខត្តិយបរិសា ព្រាហ្មណបរិសា គហបតិបរិសា សមណបរិសា ចាតុម្មហារាជិកបរិសា តាវត្តឹសបរិសា មារបរិសា ព្រហ្មបរិសា ។ អភិជានាមិ ខោ បនាហំ ភិក្ខវេ អនេកសតំ ខត្តិយបរិសំ ឧបសង្កមិត្វា[១] ។ តត្របិ មយា សន្និសិន្នបុព្វញ្ចេវ សល្លបិតបុព្វញ្ច សាកច្ឆា ច សមាបន្នបុព្វា តត្ថ យាទិសកោ តេសំ វណ្ណោ ហោតិ តាទិសកោ មយ្ហំ វណ្ណោ ហោតិ យាទិសកោ តេសំ សរោ ហោតិ តាទិសកោ មយ្ហំ សរោ ហោតិ ធម្មិយា ច កថាយ សន្ទស្សេមិ សមាទបេមិ សមុត្តេជេមិ សម្បហំសេមិ ភាសមានញ្ច មំ ន ជានន្តិ កោ នុ ខោ អយំ ភាសតិ ទេវោ វា មនុស្សោ វាតិ ធម្មិយា ច កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា សម្បហំសេត្វា អន្តរធាយាមិ អន្តរហិតញ្ច មំ ន ជានន្តិ កោ នុ ខោ អយំ អន្តរហិតោ ទេវោ វា មនុស្សោ វាតិ ។

១ ឧបសង្កមិតាតិបិ ។

[៧៦] ម្នាលភិក្ខុទាំងឡាយ បរិសទ្យមាន ៨ ពួក ។ ៨ ពួក តើអ្វីខ្លះ ។ គឺខត្តិយបរិសទ្យ ១ ព្រាហ្មណបរិសទ្យ ១ គហបតិបរិសទ្យ ១ សមណបរិសទ្យ ១ ចាតុម្មហារាជិកបរិសទ្យ ១ តាវត្តិង្សបរិសទ្យ ១ មារ-បរិសទ្យ ១ ព្រហ្មបរិសទ្យ ១ ។ ម្នាលភិក្ខុទាំងឡាយ តថាគតធ្លាប់បានចូលទៅរកខត្តិយបរិសទ្យ ជាច្រើនរយ ។ ក្នុងបរិសទ្យនោះ តថាគតធ្លាប់អង្គុយជាមួយផង ធ្លាប់ចរចាជាមួយផង ធ្លាប់ដល់នូវការសាកច្ឆាជាមួយផង សម្បុររបស់ជនទាំងនោះ ក្នុងបរិសទ្យនោះ យ៉ាងណា សម្បុររបស់តថាគតក៏យ៉ាងនោះដែរ សំឡេងរបស់ជនទាំងនោះ យ៉ាងណា សំឡេងរបស់តថាគត ក៏យ៉ាងនោះដែរ មួយទៀត តថាគត បានញុំាងជនទាំងនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា កាលដែលតថាគតកំពុងនិយាយ ជនទាំងនោះ មិនស្គាល់ថា ជនដែលកំពុងនិយាយនេះ ជាអ្វីហ្ន៎ ជាទេវតា ឬ មនុស្សដូច្នេះឡើយ លុះតថា-គតញុំាងជនទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយ ដោយធម្មីកថាហើយ ក៏បាត់ទៅ កាលដែលតថាគតបាត់ទៅហើយ ចំណែកជនទាំងនោះ នៅតែមិនស្គាល់ថា ជនដែលបាត់ទៅហើយនេះ ជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។

អភិជានាមិ ខោ បនាហំ ភិក្ខវេ អនេកសតំ ព្រាហ្ម-
ណបរិសំ ។ បេ ។ គហបតិបរិសំ សមណបរិសំ
ចាតុម្មហារាជិកបរិសំ តាវត្តឹសបរិសំ មារបរិសំ ព្រហ្ម-
បរិសំ ឧបសង្កមិត្វា ។ តត្របិ មយា សន្និសិន្នបុព្វញ្ចេវ
សល្លបិតបុព្វញ្ច សាកច្ឆា ច សមាបន្នបុព្វា តត្ថ
យាទិសកោ តេសំ វណ្ណោ ហោតិ តាទិសកោ មយ្ហំ
វណ្ណោ ហោតិ យាទិសកោ តេសំ សរោ ហោតិ
តាទិសកោ មយ្ហំ សរោ ហោតិ ធម្មិយា ច កថាយ
សន្ទស្សេមិ សមាទបេមិ សមុត្តេជេមិ សម្បហំសេមិ
ភាសមានញ្ច មំ ន ជានន្តិ កោ នុ ខោ អយំ
ភាសតិ ទេវោ វា មនុស្សោ វាតិ ។ ធម្មិយា ច
កថាយ សន្ទស្សេត្វា សមាទបេត្វា សមុត្តេជេត្វា
សម្បហំសេត្វា អន្តរធាយាមិ អន្តរហិតញ្ច មំ ន
ជានន្តិ កោ នុ ខោ អយំ អន្តរហិតោ ទេវោ វា
មនុស្សោ វាតិ ។ ឥមា ខោ ភិក្ខវេ អដ្ឋ បរិសាតិ ។

ម្នាលភិក្ខុទាំងឡាយ តថាគត ធ្លាប់ចូលទៅរកព្រាហ្មណបរិសទ្យ ជាច្រើនរយ ។ បេ ។ បានចូលទៅរក គហបតិបរិសទ្យ សមណបរិសទ្យ ចាតុម្មហារាជិកបរិសទ្យ តាវត្តិង្សបរិសទ្យ មារបរិសទ្យ ព្រហ្មបរិសទ្យ ។ ក្នុងព្រហ្មបរិសទ្យនោះ តថាគតធ្លាប់អង្គុយជាមួយផង ធ្លាប់ចរចាជាមួយផង ធ្លាប់ដល់នូវការសាកច្ឆាជាមួយផង សម្បុររបស់ព្រហ្មទាំងនោះ ក្នុងបរិសទ្យនោះយ៉ាងណា សម្បុររបស់តថាគត ក៏យ៉ាងនោះដែរ សំឡេងរបស់ព្រហ្មទាំងនោះយ៉ាងណា សំឡេងរបស់តថាគត ក៏យ៉ាងនោះដែរ មួយទៀត តថាគតបានញុំាងព្រហ្មទាំងនោះឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថា កាលដែលតថាគតកំពុងនិយាយ ចំណែកព្រហ្មទាំងនោះមិនស្គាល់ថា ជនដែលកំពុងនិយាយនេះ ជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។ លុះតថាគតញុំាងព្រហ្មទាំងនោះ ឲ្យឃើញច្បាស់ ឲ្យកាន់យក ឲ្យអាចហ៊ាន ឲ្យរីករាយដោយធម្មីកថាហើយ ក៏បាត់ទៅ កាលដែលតថាគត បាត់ទៅហើយ ចំណែកព្រហ្មទាំងនោះ នៅតែមិនស្គាល់ថា ជនដែលបាត់ទៅហើយនេះ ជាអ្វីហ្ន៎ ជាទេវតា ឬជាមនុស្សដូច្នេះឡើយ ។ ម្នាលភិក្ខុទាំងឡាយ បរិសទ្យ ៨ ពួកនេះឯង ។

[៧៧] ឯកំ សមយំ ភគវា វេសាលិយំ វិហរតិ មហាវនេ កូដាគារសាលាយំ ។ អថខោ ភគវា បុព្វណ្ហសមយំ និវាសេត្វា បត្តចីវរមាទាយ វេសាលី បិណ្ឌាយ បាវិសិ ។ វេសាលិយំ បិណ្ឌាយ ចរិត្វា បច្ឆាភត្តំ បិណ្ឌបាតប្បដិក្កន្តោ អាយស្មន្តំ អានន្ទំ អាមន្តេសិ គណ្ហាហិ អានន្ទ និសីទនំ យេន ចាបាលចេតិយំ[១] តេនុបសង្កមិស្សាម ទិវាវិហារាយាតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុណិត្វា និសីទនំ អាទាយ ភគវន្តំ បិដ្ឋិតោ បិដ្ឋិតោ អនុពន្ធិ ។

អថខោ ភគវា យេន ចាបាលចេតិយំ តេនុបសង្កមិ ឧបសង្កមិត្វា បញ្ញត្តេ អាសនេ និសីទិ ។ និសជ្ជ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ រមណីយា អានន្ទ វេសាលី រមណីយំ ឧទេនចេតិយំ រមណីយំ គោតមកចេតិយំ រមណីយំ ពហុបុត្តកចេតិយំ រមណីយំ សត្តម្ពចេតិយំ រមណីយំ សារន្ទទចេតិយំ រមណីយំ ចាបាលចេតិយំ ។

១ ឱ. ម. ចាបាលចេតិយំ ។

[៧៧] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់ក្នុងកូដាគារ-សាលា នាមហាវ័ន ជិតក្រុងវេសាលី ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ស្បង់ប្រដាប់បាត្រនិងចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅកាន់ក្រុងវេសាលី ដើម្បីបិណ្ឌបាត ។ លុះទ្រង់ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងវេសាលីហើយ ត្រឡប់អំពីបិណ្ឌបាត ក្នុងវេលាខាងក្រោយភត្ត ហើយទ្រង់ត្រាស់ហៅព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ ចូរអ្នកកាន់យកនិសីទនៈទៅ យើងនឹងចូលទៅសម្រាក ក្នុងវេលាថ្ងៃឯបាវាលចេតិយ ។ ព្រះអានន្ទដ៏មានអាយុ បានទទួលព្រះពុទ្ធដីកា នៃព្រះដ៏មានព្រះភាគ ដោយពាក្យថា ព្រះករុណាព្រះអង្គ ហើយក៏កាន់និសីទនៈទៅតាមខាងក្រោយ ៗ ព្រះដ៏មានព្រះភាគទៅ ។

គ្រានោះ ព្រះដ៏មានព្រះភាគ កាលស្តេចចូលទៅកាន់បាវាល-ចេតិយ លុះចូលទៅដល់ហើយ ក៏គង់លើអាសនៈ ដែលព្រះអានន្ទក្រាលថ្វាយ ។ លុះព្រះដ៏មានព្រះភាគគង់ហើយ ក៏ទ្រង់ត្រាស់នឹងព្រះអានន្ទដ៏មានអាយុថា ម្នាលអានន្ទ ក្រុងវេសាលី ជាទីគួរត្រេកអរ ឧទេនចេតិយ ជាទីគួរត្រេកអរ គោតមកចេតិយ ជាទីគួរត្រេកអរ ពហុបុត្តកចេតិយ ជាទីគួរត្រេកអរ សត្តម្ពចេតិយ ជាទីគួរត្រេកអរ សា-រន្ទទចេតិយ ជាទីគួរត្រេកអរ បាវាលចេតិយ ជាទីគួរត្រេកអរ ។

យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អាកង្ខមានោ សោ អានន្ទ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វា ។ តថាគតស្ស ខោ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ ។ ឯវម្បិ ខោ អាយស្មា អានន្ទោ ភគវតា ឱឡារិកេ និមិត្តេ ករិយមានេ ឱឡារិកេ ឱភាសេ ករិយមានេ នាសក្ខិ បដិវិជ្ឈិតុំ ន ភគវន្តំ យាចិ តិដ្ឋតុ ភន្តេ ភគវា កប្បំ តិដ្ឋតុ ភន្តេ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ យថាតំ មារេន បរិយុដ្ឋិតចិត្តោ ។ ទុតិយម្បិ ខោ ភគវា ។

ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយ បានចម្រើនហើយ បានធ្វើឲ្យច្រើន បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយ ម្នាលអានន្ទ បុគ្គលនោះ ទោះបីប្រាថ្នានឹងគប្បីឋិតនៅអស់ ១ អាយុកល្ប ឬ លើសជាង ១ អាយុកល្បក៏បាន ។ ម្នាលអានន្ទ ឯឥទ្ធិបាទទាំង ៤ តថាគតបានចម្រើនហើយ បានធ្វើឲ្យច្រើន បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយ ម្នាលអានន្ទ តថាគត បើប្រាថ្នាគប្បីឋិតនៅអស់ ១ អាយុកល្ប ឬ លើសជាង ១ អាយុកល្បក៏បាន ។ ឯព្រះអានន្ទដ៏មានអាយុ ទុកជាព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិក ទ្រង់ធ្វើឱភាសជាឱឡារិកយ៉ាងនេះហើយ ក៏មិនអាចនឹងយល់សេចក្តីច្បាស់លាស់បាន មិនបានអារាធនាព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ឋិតនៅអស់ ១ អាយុកល្ប បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះសុគត ឋិតនៅអស់ ១ អាយុកល្ប ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ពួកទេវតា និងមនុស្សដូច្នេះសោះ ព្រោះមារចូលមកជ្រែកគំនិត ។ ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកា ជាគម្រប់ពីរដងផង ។

តតិយម្បិ ខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ រមណីយា អានន្ទ វេសាលី រមណីយំ ឧទេនចេតិយំ រមណីយំ គោតមកចេតិយំ រមណីយំ ពហុបុត្តកចេតិយំ រមណីយំ សត្តម្ពចេតិយំ រមណីយំ សារន្ទទចេតិយំ រមណីយំ ចាបាលចេតិយំ ។ យស្ស កស្សចិ អានន្ទ ចត្តារោ ឥទ្ធិបាទា ភាវិតា ពហុលីកតា យានីកតា វត្ថុកតា អនុដ្ឋិតា បរិចិតា សុសមារទ្ធា ។ បេ ។ អាកង្ខមានោ អានន្ទ តថាគតោ កប្បំ វា តិដ្ឋេយ្យ កប្បាវសេសំ វាតិ ។ ឯវម្បិ ខោ អាយស្មា អានន្ទោ ភគវតា ឱឡារិកេ និមិត្តេ ករិយមានេ ឱឡារិកេ ឱភាសេ ករិយមានេ នាសក្ខិ បដិវិជ្ឈិតុំ ន ភគវន្តំ យាចិ តិដ្ឋតុ ភន្តេ ភគវា កប្បំ តិដ្ឋតុ ភន្តេ សុគតោ កប្បំ ពហុជនហិតាយ ពហុជនសុខាយ លោកានុកម្បាយ អត្ថាយ ហិតាយ សុខាយ ទេវមនុស្សានន្តិ យថាតំ មារេន បរិយុដ្ឋិតចិត្តោ ។

ព្រះដ៏មានព្រះភាគ ទ្រង់មានព្រះពុទ្ធដីកានឹងព្រះអានន្ទដ៏មានអាយុ ជាគម្រប់ ៣ ដងផងថា ម្នាលអានន្ទ ក្រុងវេសាលី ជាទីគួរត្រេកអរ ឧទេនចេតិយ ជាទីគួរត្រេកអរ គោតមកចេតិយ ជាទីគួរត្រេកអរ ពហុបុត្តកចេតិយ ជាទីគួរត្រេកអរ សត្តម្ពចេតិយ ជាទីគួរត្រេកអរ សារន្ទទចេតិយ ជាទីគួរត្រេកអរ បាវាលចេតិយ ជាទីគួរត្រេកអរ ។ ម្នាលអានន្ទ ឥទ្ធិបាទទាំង ៤ បើបុគ្គលណាមួយ បានចម្រើនហើយ បានធ្វើឲ្យច្រើន បានធ្វើឲ្យដូចជាយាន បានតម្កល់ស៊ប់ បានប្រព្រឹត្តរឿយៗ បានសន្សំទុក បានប្រារព្ធល្អហើយ ។ បេ ។ ម្នាលអានន្ទ តថាគត បើប្រាថ្នា គប្បីឋិតនៅ អស់ ១ អាយុកល្ប ឬ លើសជាង ១ អាយុកល្បក៏បាន ។ ឯព្រះអានន្ទដ៏មានអាយុ ទុកជាព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនិមិត្តជាឱឡារិក ទ្រង់ធ្វើឱកាសជាឱឡារិក យ៉ាងនេះហើយ ក៏នៅតែមិនអាចយល់សេចក្តីច្បាស់លាស់បានឡើយ ហើយមិនបានអារាធនាព្រះដ៏មានព្រះភាគ ថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ ឋិតនៅអស់ ១ អាយុកល្ប បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះសុគត ឋិតនៅអស់ ១ អាយុកល្ប ដើម្បីប្រយោជន៍ ដល់ជនច្រើន ដើម្បីសេចក្តីសុខ ដល់ជនច្រើន ដើម្បីអនុគ្រោះ ដល់សត្វលោក ដើម្បីសេចក្តីចម្រើន ដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខ ដល់ទេវតានិងមនុស្សទាំងឡាយដូច្នេះសោះឡើយ ព្រោះមារចូលមកជ្រែកគំនិត ។

អថខោ ភគវា អាយស្មន្តំ អានន្ទំ អាមន្តេសិ គច្ឆ ត្វំ អានន្ទ យស្សទានិ កាលំ មញ្ញសីតិ ។ ឯវំ ភន្តេតិ ខោ អាយស្មា អានន្ទោ ភគវតោ បដិស្សុណិត្វា ឧដ្ឋាយាសនា ភគវន្តំ អភិវាទេត្វា បទក្ខិណំ កត្វា ភគវតោ អវិទូរេ អញ្ញតរស្មឹ រុក្ខមូលេ និសីទិ ។

អថខោ មារោ បាបិមា អចិរបក្កន្តេ អាយស្មន្តេ អានន្ទេ ភគវន្តំ ឯតទវោច បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ភិក្ខូ ន សាវកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា បត្តយោគក្ខេមា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមី-ចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសិស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ

លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងអានន្ទដ៏មានអាយុថា ម្នាល អានន្ទ អ្នកចូរទៅចុះ អ្នកចូរសម្គាល់នូវកាលដែលគួរនឹងទៅក្នុងកាល ឥឡូវនេះចុះ ។ ព្រះអានន្ទដ៏មានអាយុ បានទទួលព្រះពុទ្ធដីកាព្រះមានព្រះ ភាគដោយពាក្យថា ព្រះករុណាព្រះអង្គ រួចក៏ក្រោកចាកអាសនៈ ហើយ ថ្វាយបង្គំព្រះដ៏មានព្រះភាគ ធ្វើប្រទក្សិណ រួចអង្គុយទៀបគល់ឈើមួយ ជិតព្រះដ៏មានព្រះភាគ ។

គ្រានោះ កាលបើព្រះអានន្ទដ៏មានអាយុ ចៀសចេញទៅ មិនយូរ ប៉ុន្មាន មារមានចិត្តបាប ក៏បានពោលពាក្យនេះ នឹងព្រះដ៏មានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគបរិនិព្វានក្នុងកាលឥឡូវនេះ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរ នឹងបរិនិព្វានរបស់ព្រះដ៏មានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះ ថា ព្រះដ៏មានព្រះភាគ បានត្រាស់វាចានេះហើយថា នែមារមានចិត្តបាប ពួកភិក្ខុ ជាសាវ័ករបស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ដល់នូវ ការក្សេមចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិសមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ បានរៀននូវវាទៈនៃអាចារ្យរបស់ ខ្លួនហើយ ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន

ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសិស្សន្តីតិ ។ ឯតរហិ ភន្តេ ភិក្ខូ ភគវតោ សាវកា វិយត្តា វិនីតា វិសារទា បត្ត-យោគក្ខេមា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ ។ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ បាបិម បរិនិព្វាយិស្សាមិ យាវ មេ ភិក្ខុនិយោ ន សាវិកា ភវិស្សន្តិ ។ បេ ។ យាវ

បានសង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលខ្លួនបាន សង្កត់សង្កិនដោយល្អតាមពាក្យ ដែលសមហេតុ ហើយសម្តែងធម៌ ប្រកប ដោយបាដិហារ្យ នៅមិនទាន់បាន ដរាបណាទេ តថាគតនឹងមិនទាន់ បរិនិព្វានដរាបនោះដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកភិក្ខុជា សាវករបស់ព្រះដ៏មានព្រះភាគ បានឈ្លាសវៃ ក្លៀវក្លា ដល់នូវការក្សេម ចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ សមគួរដល់ធម៌ ប្រតិបត្តិ ដ៏សមគួរ ប្រព្រឹត្តតាមធម៌ ទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយ ប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបានហើយ ទាំង សង្កត់សង្កិនបរប្បវាទ ដែលកើតឡើងហើយ ឲ្យជាកិច្ចដែលបានសង្កត់ សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ប្រកបដោយ បាដិហារ្យបានហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះ ដ៏មានព្រះភាគបរិនិព្វានទៅ សូមព្រះសុគតបរិនិព្វានទៅ បពិត្រព្រះអង្គ ដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វាន របស់ព្រះដ៏មានព្រះភាគ ហើយ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះដ៏មានព្រះភាគ ត្រាស់វាចានេះ ហើយថា ម្នាលមារមានចិត្តបាប ពួកភិក្ខុនី ជាសាវិកា របស់តថាគត មិនទាន់មានដរាបណា តថាគតនឹងមិនទាន់បរិនិព្វានដរាបនោះ ។ បេ ។

មេ ឧបាសកា ន សាវកា ភវិស្សន្តិ ។ បេ ។ យាវ មេ ឧបាសិកា ន សាវិកា ភវិស្សន្តិ វិយត្តា វិនីតា វិសារទា បត្តយោគក្ខេមា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខិស្សន្តិ ទេសិស្សន្តិ បញ្ញបេស្សន្តិ បដ្ឋបេស្សន្តិ វិវរិស្សន្តិ វិភជិស្សន្តិ ឧត្តានីករិស្សន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសិស្សន្តីតិ ។ ឯតរហិ ភន្តេ ឧបាសិកា ភគវតោ សាវិកា វិយត្តា វិនីតា វិសារទា បត្តយោគក្ខេមា ពហុស្សុតា ធម្មធរា ធម្មានុធម្មប្បដិបន្នា សាមីចិប្បដិបន្នា អនុធម្មចារិនិយោ សកំ អាចរិយកំ ឧគ្គហេត្វា អាចិក្ខន្តិ ទេសេន្តិ បញ្ញបេន្តិ បដ្ឋបេន្តិ វិវរន្តិ វិភជន្តិ ឧត្តានីករោន្តិ ឧប្បន្នំ បរប្បវាទំ សហធម្មេន សុនិគ្គហិតំ និគ្គហេត្វា សប្បាដិហារិយំ ធម្មំ ទេសេន្តិ ។ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ

ពួកឧបាសក ជាសាវ័ក របស់តថាគត មិនទាន់មាន ដរាបណា ។ បេ ។ ពួកឧបាសិកា ជាសាវិកា របស់តថាគត ដែលឈ្លាសវាងវៃ ក្លៀវក្លា ដល់នូវការក្សេមចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌សមគួរដល់ធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ បានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបាន បានសង្កត់សង្កិននូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ សម្តែងធម៌ប្រកបដោយបាដិហារ្យ នៅមិនទាន់មាន ដរាបណាទេ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ពួកឧបាសិកា ជាសាវិកា របស់ព្រះដ៏មានព្រះភាគ ដែលឈ្លាសវាងវៃ ក្លៀវក្លា ដល់នូវការក្សេមចាកយោគៈ ជាពហុស្សូត ទ្រទ្រង់ធម៌ ប្រតិបត្តិធម៌ ប្រតិបត្តិដ៏សមគួរ ប្រព្រឹត្តតាមធម៌ហើយ ទាំងបានរៀននូវវាទៈនៃអាចារ្យរបស់ខ្លួន ហើយប្រាប់ សម្តែង បញ្ញត្ត តាំងទុក បើក ចែក ធ្វើឲ្យងាយបានហើយ ទាំងសង្កត់សង្កិននូវបរប្បវាទដែលកើតឡើងហើយ ឲ្យជាកិច្ចដែលសង្កត់សង្កិនដោយល្អ តាមពាក្យដែលសមហេតុ ហើយសម្តែងធម៌ ប្រកបដោយបាដិហារ្យបានហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគ បរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ

២៩៩



បរិនិព្វានកាលោទានិ ភន្តេ ភគវតោ ភាសិតា ខោ បនេសា ភន្តេ ភគវតា វាចា ន តាវាហំ ចាបិម បរិនិព្វាយិស្សាមិ យាវ មេ ឥទំ ព្រហ្មចរិយំ ន ឥទ្ធញ្ចេវ ភវិស្សតិ ផីតញ្ច វិត្ថារិកំ ពាហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតន្តិ ។ ឯតរហិ ភន្តេ ភគវតោ ព្រហ្មចរិយំ ឥទ្ធញ្ចេវ ផីតញ្ច វិត្ថារិកំ ពាហុជញ្ញំ បុថុភូតំ យាវ ទេវមនុស្សេហិ សុប្បកាសិតំ ។ បរិនិព្វាតុទានិ ភន្តេ ភគវា បរិនិព្វាតុ សុគតោ បរិនិព្វានកាលោទានិ ភន្តេ ភគវតោតិ ។ អប្បោស្សុក្កោ ត្វំ ចាបិម ហោហិ ន ចិរំ តថាគតស្ស បរិនិព្វានំ ភវិស្សតិ ឥតោ តិណ្ណំ មាសានំ អច្ចយេន តថាគតោ បរិនិព្វាយិស្សតីតិ ។ អថខោ ភគវា ចាបាលចេតិយេ សតោ សម្បជានោ អាយុសង្ខារំ ឱស្សជ្ជិ ។

បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វានរបស់ព្រះដ៏មានព្រះភាគហើយ បពិត្រព្រះអង្គដ៏ចម្រើន មួយទៀត ព្រះដ៏មានព្រះភាគបានត្រាស់វាចានេះហើយថា ម្នាលមារមានចិត្តបាប ព្រហ្មចារ្យរបស់តថាគតនេះ នៅមិនទាន់ខ្ជាប់ខ្ជួន មិនទាន់ចម្រើន មិនទាន់ផ្សាយទៅសព្វទិស គេមិនទាន់ដឹងច្រើនគ្នា និងមិនទាន់ពេញបរិបូណ៌ដរាបណា មួយទៀត ពួកទេវតានិងមនុស្ស មិនទាន់ចេះសម្តែងបាន ដោយប្រពៃ ដរាបណា តថាគតនឹងមិនបរិនិព្វាន ដរាបនោះដូច្នេះ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ព្រហ្មចារ្យរបស់ព្រះដ៏មានព្រះភាគនេះ បានខ្ជាប់ខ្ជួនហើយ បានចម្រើនហើយ បានផ្សាយទៅសព្វទិសហើយ គេបានដឹងច្រើនគ្នាហើយ បានពេញបរិបូណ៌ហើយ ពួកទេវតានិងមនុស្ស ចេះសម្តែងបានដោយល្អហើយ ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគបរិនិព្វានទៅ សូមព្រះសុគត បរិនិព្វានទៅ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ជាកាលគួរនឹងបរិនិព្វាន របស់ព្រះដ៏មានព្រះភាគហើយ ។ ម្នាលមារមានចិត្តបាប ចូរអ្នកមានសេចក្តីខ្វល់ខ្វាយតិចចុះ ការបរិនិព្វានរបស់តថាគត មិនយូរប៉ុន្មានទេ កន្លង ៣ ខែអំពីថ្ងៃនេះទៅ តថាគតនឹងបរិនិព្វានហើយ ។ លំដាប់នោះ ព្រះដ៏មានព្រះភាគ ទ្រង់មានសតិសម្បជញ្ញៈ ទ្រង់ដាក់អាយុសង្ខារ ឰដ៏បាវាលចេតិយ ។

ឱស្សដ្ឋិតេ ភគវតា អាយុសង្ខារេ មហាភូមិចាលោ អហោសិ ភឹសនកោ សលោមហំសោ ទេវទុន្ទុភិយោ ច ផលឹសុ ។ អថខោ ភគវា ឯតមត្ថំ វិទិត្វា តាយំ វេលាយំ ឥមំ ឧទានំ ឧទានេសិ

តុលមតុលញ្ច សម្ភវំ ភវសង្ខារមវស្សជ្ជិ មុនិ

អជ្ឈត្តរតោ សមាហិតោ អភិន្ទិ កវចមិវត្តសម្ភវន្តិ ។

អថខោ អាយស្មតោ អានន្ទស្ស ឯតទហោសិ មហា វតាយំ ភូមិចាលោ សុមហា វតាយំ ភូមិចាលោ ភឹសនកោ សលោមហំសោ ទេវទុន្ទុភិយោ ច ផលឹសុ ។ កោ នុ ខោ ហេតុ កោ បច្ចយោ មហតោ ភូមិចាលស្ស ចាតុភាវាយាតិ ។ អថខោ អាយស្មា អានន្ទោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។

លុះព្រះដ៏មានព្រះភាគ ទ្រង់ដាក់អាយុសង្ខារហើយ ក៏កើតការកក្រើកផែនដីយ៉ាងធំ គួរឲ្យភ្ញាក់ភ្ញើកព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង ។ គ្រានោះ ព្រះដ៏មានព្រះភាគ ទ្រង់ជ្រាបច្បាស់នូវសេចក្តីនេះហើយ ក៏បន្លឺនូវឧទាននេះ ក្នុងវេលានោះថា

ព្រះពុទ្ធ ជាអ្នកប្រាជ្ញ ទ្រង់ពិចារណាឃើញ នូវព្រះនិព្វាន
ដែលមានគុណថ្លឹងមិនបានផង នូវភពផង ទ្រង់លះបង់នូវ
សង្ខារ ដែលនាំសត្វទៅកាន់ភព ទ្រង់ត្រេកអរនូវអារម្មណ៍
ខាងក្នុង (ដោយអំណាចវិបស្សនា) មានព្រះហឫទ័យតាំងមាំ
ហើយ (ដោយអំណាចសមថៈ) ទ្រង់បានទម្លាយនូវ
បណ្តាញគឺកិលេស ដែលកើតមានទៅ ក្នុងព្រះអង្គដូចជាក្រោះ ។

លំដាប់នោះ ព្រះអានន្ទដ៏មានអាយុ មានសេចក្តីត្រិះរិះយ៉ាងនេះថា អើហ្ន៎ ការកក្រើកផែនដីនេះជាយ៉ាងធំ ការកក្រើកផែនដីនេះធំណាស់តើ គួរឲ្យភ្ញាក់ភ្ញើក ឲ្យព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង ។ ហេតុដូចម្តេច បច្ច័យដូចម្តេចហ្ន៎ ដែលនាំឲ្យការកក្រើកផែនដី ជាយ៉ាងធំម្ល៉េះ ។ ទើបព្រះអានន្ទដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ហើយ ក៏ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយគង់ក្នុងទីដ៏សមគួរ ។

៣០១



ឯកមន្តំ និសិន្នោ ខោ អាយស្មា អានន្ទោ ភគវន្តំ ឯតទវោច មហា វតាយំ ភន្តេ ភូមិចាលោ សុមហា វតាយំ ភន្តេ ភូមិចាលោ ភឹសនកោ សលោមហំសោ ទេវទុន្ទុភិយោ ច ផលឹសុ ។ កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ មហតោ ភូមិចាលស្ស ចាតុភាវាយាតិ ។

អដ្ឋិមេ អានន្ទ ហេតូ អដ្ឋ បច្ចយា មហតោ ភូមិចាលស្ស ចាតុភាវាយ ។ កតមេ អដ្ឋ ។ យំ អានន្ទ មហាបឋវី ឧទកេ បតិដ្ឋិតា ឧទកំ វាតេ បតិដ្ឋិតំ វាតោ អាកាសដ្ឋោ ហោតិ សោ អានន្ទ សមយោ យំ មហាវាតា វាយន្តិ មហាវាតា វាយន្តា ឧទកំ កម្បេន្តិ ឧទកំ កម្បិតំ បឋវឹ កម្បេតិ អយំ អានន្ទ បឋមោ ហេតុ បឋមោ បច្ចយោ មហតោ ភូមិចាលស្ស ចាតុភាវាយ ។ បុន ចបរំ អានន្ទ សមណោ វា ព្រាហ្មណោ វា ឥទ្ធិមា ចេតោវសិប្បត្តោ ទេវតា មហិទ្ធិកា មហានុភាវា

លុះព្រះអានន្ទដ៏មានអាយុ គង់ក្នុងទីសមគួរហើយ ក៏ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ការកក្រើកផែនដីនេះជាយ៉ាងធំ បពិត្រព្រះអង្គដ៏ចម្រើន ការកក្រើកផែនដីនេះ ធំពេកណាស់តើ គួរឲ្យក្អកក្អឹក គួរឲ្យព្រឺព្រួចរោម ទាំងផ្គរក៏លាន់ឮឡើង ។ បពិត្រព្រះអង្គដ៏ចម្រើន ហេតុដូចម្ដេច បច្ច័យដូចម្ដេចហ្ន៎ ដែលនាំឲ្យកើតការកក្រើកផែនដី ជាយ៉ាងធំម្ល៉េះ ។

ព្រះអង្គត្រាស់ថា ម្នាលអានន្ទ ហេតុបច្ច័យដែលនាំឲ្យកើតការកក្រើកផែនដីនេះមាន ៨ យ៉ាង ។ ហេតុបច្ច័យទាំង ៨ យ៉ាង តើដូចម្ដេចខ្លះ ។ ម្នាលអានន្ទ មហាប្រឹថពីនេះ ប្រតិស្ឋាននៅលើទឹក ឯទឹកប្រតិស្ឋាននៅលើខ្យល់ ខ្យល់ប្រតិស្ឋាននៅលើអាកាស ម្នាលអានន្ទ សម័យដែលមានខ្យល់បក់ ខ្យល់ធំដែលបក់នោះ រមែងធ្វើទឹកឲ្យកក្រើក ឯទឹកដែលកក្រើកមកហើយ ក៏ធ្វើផែនដី ឲ្យកក្រើកដែរ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ១ ដែលនាំឲ្យកើតការកក្រើកផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត សមណៈក្តី ព្រាហ្មណ៍ក្តី ដែលមានឫទ្ធិដល់នូវការស្ទាត់ជំនាញក្នុងចិត្ត ឬទេវតាដែលមានឫទ្ធិធំ មានអានុភាពធំ

តស្ស បរិត្តា បឋវីសញ្ញា ភាវិតា ហោតិ អប្បមាណា អាបោសញ្ញា សោ ឥមំ បឋវឹ កម្បេតិ សំកម្បេតិ សម្បកម្បេតិ អយំ អានន្ទ ទុតិយោ ហេតុ ទុតិយោ បច្ចយោ មហតោ ភូមិចាលស្ស បាតុភាវាយ ។ បុន ចបរំ អានន្ទ យទា ពោធិសត្តោ តុសិតា កាយា ចវិត្វា សតោ សម្បជានោ មាតុ កុច្ឆឹ ឱក្កមតិ តទាយំ បឋវី កម្បតិ សំកម្បតិ សម្បកម្បតិ អយំ អានន្ទ តតិយោ ហេតុ តតិយោ បច្ចយោ មហតោ ភូមិចា-លស្ស បាតុភាវាយ ។ បុន ចបរំ អានន្ទ យទា ពោធិ-សត្តោ សតោ សម្បជានោ មាតុ កុច្ឆិស្មា និក្ខមតិ តទាយំ បឋវី កម្បតិ សំកម្បតិ សម្បកម្បតិ អយំ អានន្ទ ចតុត្ថោ ហេតុ ចតុត្ថោ បច្ចយោ មហតោ ភូមិចាលស្ស បាតុភាវាយ ។ បុន ចបរំ អានន្ទ យទា តថាគតោ អនុត្តរំ សម្មាសម្ពោធឹ អភិសម្ពុជ្ឈតិ តទាយំ បឋវី កម្បតិ សំកម្បតិ សម្បកម្បតិ

បុគ្គលនោះ បានចម្រើនបឋវីសញ្ញា ឲ្យមានកម្លាំងតិច ចម្រើនអាបោសញ្ញា ឲ្យមានកម្លាំងច្រើន បុគ្គលនោះ រមែងធ្វើផែនដីនេះ ឲ្យកក្រើករំភើប ញាប់ញ័របាន ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ២ ដែលនាំឲ្យកើតការកក្រើកផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះពោធិសត្វ ច្យុតចាកពួកទេវតា ដែលឋិតនៅក្នុងឋានតុសិតមានសតិនិងសម្បជញ្ញៈ យាងចុះកាន់ព្រះមាតុឧទរ ក្នុងកាលនោះផែនដីនេះ តែងកក្រើករំភើប ញាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៣ ដែលនាំឲ្យកក្រើកផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលពោធិសត្វ មានសតិនិងសម្បជញ្ញៈ ទ្រង់ប្រសូតចាកព្រះមាតុឧទរ ក្នុងកាលនោះ ផែនដីនេះ តែងកក្រើករំភើបញាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៤ ដែលនាំឲ្យកក្រើកផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណា ដែលព្រះតថាគត ត្រាស់ដឹងនូវអនុត្តរសម្មា-សម្ពោធិញ្ញាណ ក្នុងកាលនោះ ផែនដីនេះ តែងកក្រើករំភើបញាប់ញ័រ

បណ្ណាសកាសង្គហិតោ ចាលវគ្គោ

អយំ អានន្ទ បញ្ចមោ ហេតុ បញ្ចមោ បច្ចយោ មហតោ ភូមិចាលស្ស ចាតុភាវាយ ។ បុន ចបរំ អានន្ទ យទា តថាគតោ អនុត្តរំ ធម្មចក្កំ បវត្តេតិ តទាយំ បឋវី កម្បតិ សំកម្បតិ សម្បកម្បតិ អយំ អានន្ទ ឆដ្ឋោ ហេតុ ឆដ្ឋោ បច្ចយោ មហតោ ភូមិចា-លស្ស ចាតុភាវាយ ។ បុន ចបរំ អានន្ទ យទា តថាគតោ សតោ សម្បជានោ អាយុសង្ខារំ ឱស្សជ្ជតិ តទាយំ បឋវី កម្បតិ សំកម្បតិ សម្បកម្បតិ អយំ អានន្ទ សត្តមោ ហេតុ សត្តមោ បច្ចយោ មហតោ ភូមិចាលស្ស ចាតុភាវាយ ។ បុន ចបរំ អានន្ទ យទា តថាគតោ អនុបាទិសេសាយ និព្វានធាតុយា បរិនិព្វាយតិ តទាយំ បឋវី កម្បតិ សំកម្បតិ សម្បកម្បតិ អយំ អានន្ទ អដ្ឋមោ ហេតុ អដ្ឋមោ បច្ចយោ មហតោ ភូមិចាលស្ស ចាតុភាវាយ ។

ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៥ ដែលនាំឲ្យកើតការកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគត ញុំាងអនុត្តរធម្មចក្រ ឲ្យប្រព្រឹត្តទៅ កាលនោះផែនដីនេះ តែងកក្រើករំភើបញាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៦ ដែលនាំឲ្យកើតការកក្រើកផែនដីជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណា ដែលព្រះតថាគតមានសតិនិងសម្បជញ្ញៈ ដាក់ចុះនូវអាយុសង្ខារ ក្នុងកាលនោះ ផែនដីនេះ តែងកក្រើករំភើបញាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៧ ដែលនាំឲ្យកក្រើកផែនដី ជាយ៉ាងធំ ។ ម្នាលអានន្ទ មួយទៀត កាលណាដែលព្រះតថាគត បរិនិព្វាន ដោយអនុបាទិសេសនិព្វានធាតុ ក្នុងកាលនោះផែនដីនេះ តែងកក្រើករំភើបញាប់ញ័រ ម្នាលអានន្ទ នេះជាហេតុ ជាបច្ច័យទី ៨ ដែលនាំឲ្យការកក្រើកផែនដី ជាយ៉ាងធំ ។

ឥមេ ខោ អានន្ទ អដ្ឋ ហេតូ អដ្ឋ បច្ចយា មហតោ ភូមិចាលស្ស បាតុភាវាយាតិ ។

ចាលវគ្គោ ទុតិយោ[១] ។

## តត្រុទ្ទានំ

ឥទ្ធា អលញ្ច សំខិត្តំ គយា អភិភុនា តេ សហ វិមោក្ខោ ទ្វេ ច វោហារា បរិសា ភូមិចាលេន ចាតិ ។

១ ឱ. ម. ភូមិចាលវគ្គោ ទុតិយោ ។

ម្នាលអានន្ទ ហេតុបច្ច័យ ដែលនាំឲ្យកើតការកក្រើកផែនដី ជាយ៉ាងធំ មាន ៨ យ៉ាងនេះឯង ។

ចប់ ចាលវគ្គទី ២ ។

# ឧទ្ទានក្នុងចាលវគ្គនោះគឺ

និយាយអំពីសេចក្តីប្រាថ្នា ១ ភិក្ខុដែលគួរ ១ ព្រះដ៏មានព្រះភាគទ្រង់សម្តែងធម៌ ដោយសង្ខេប ១ ព្រះដ៏មានព្រះភាគទ្រង់គង់ក្នុងគយាសីសប្រទេស ១ អភិភាយតនៈ ១ វិមោក្ខ ១ វោហារ ២ លើក បរិសទ្យ ១ ផែនដីកក្រើក ១ ។

---

# យមកវគ្គោ

[៧៨] សទ្ធោ ភិក្ខវេ ភិក្ខុ ហោតិ នោ សីលវា ឯវំ សោ តេន អង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតព្វំ កិន្ទាហំ[១] សទ្ធោ ច អស្សំ សីលវា ចាតិ យតោ ច ខោ ភិក្ខវេ ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច ឯវំ សោ តេន អង្គេន បរិបូរោ ហោតិ ។ សទ្ធោ ច ភិក្ខវេ ភិក្ខុ ហោតិ សីលវា ច នោ ពហុស្សុតោ ឯវំ សោ តេន អង្គេន អបរិបូរោ ហោតិ តេន អង្គំ បរិបូរេតព្វំ កិន្ទាហំ សទ្ធោ ច អស្សំ សីលវា ច ពហុស្សុតោ ចាតិ យតោ ច ខោ ភិក្ខវេ ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច ពហុស្សុតោ ច ឯវំ សោ តេន អង្គេន បរិបូរោ ហោតិ ។ សទ្ធោ ច ភិក្ខវេ ភិក្ខុ ហោតិ សីលវា ច ពហុស្សុតោ ច នោ ធម្មកថិកោ ។ បេ ។ ធម្មកថិកោ ច នោ បរិសាវចរោ ។ បេ ។ បរិសាវចរោ ច នោ វិសារទោ បរិសាយ ធម្មំ ទេសេតិ ។ បេ ។

---

១ ឱ. ម. កិន្តាហំ ។

# យមកវគ្គ

[៧៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធា តែមិនមានសីលទេ យ៉ាងនេះ ភិក្ខុនោះឈ្មោះថា មិនបរិបូរដោយអង្គនោះ ភិក្ខុនោះ គួរបំពេញអង្គនោះ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញគប្បីជាអ្នកមានសទ្ធាផង មានសីលផង ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង យ៉ាងនេះ ទើបភិក្ខុនោះ ឈ្មោះថា បរិបូរដោយអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង តែមិនមែនជាពហុស្សូតទេ យ៉ាងនេះ ភិក្ខុនោះ ឈ្មោះថា មិនបរិបូរដោយអង្គនោះ ភិក្ខុនោះគួរបំពេញអង្គនោះ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផង ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផងហើយ យ៉ាងនេះ ទើបភិក្ខុនោះ ឈ្មោះថា បរិបូរដោយអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផង តែមិនមែនធម្មកថិកទេ ។ បេ ។ ជាធម្មកថិកផង តែមិនមែនជាអ្នកចូលទៅកាន់បរិសទ្យទេ ។ បេ ។ ជាអ្នកចូលទៅកាន់បរិសទ្យផង តែមិនមែនជាអ្នកក្លៀវក្លា ខាងសម្តែងធម៌កណ្តាលបរិសទ្យទេ ។ បេ ។

វិសារទោ ច បរិសាយ ធម្មំ ទេសេតិ នោ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី ។ បេ ។ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី នោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឯវំ សោ តេន អង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតព្វំ កិន្តាហំ សទ្ធោ ច អស្សំ សីលវា ច ពហុស្សុតោ ច ធម្មកថិកោ ច បរិសាវចរោ ច វិសារទោ ច បរិសាយ ធម្មំ ទេសេយ្យំ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី អស្សំ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ

ជាអ្នកក្លៀវក្លា ខាងសម្តែងធម៌កណ្តាលបរិសទ្យផង តែជាអ្នកមិនបានតាមប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវឈានទាំង ៤ ដែលជាធម៌អាស្រ័យនៅនឹងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នទេ ។ បេ ។ ជាអ្នកបានតាមប្រាថ្នា បានដោយងាយ បានដោយស្រួល នូវឈានទាំង ៤ ដែលជាធម៌អាស្រ័យនៅនឹងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខក្នុងបច្ចុប្បន្នផង តែមិនធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្នទេ យ៉ាងនេះ ទើបភិក្ខុនោះ ឈ្មោះថាមិនបរិបូរដោយអង្គនោះ ភិក្ខុនោះ គួរបំពេញអង្គនោះ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផង ជាធម្មកថិកផង ជាអ្នកចូលទៅកាន់បរិសទ្យផង ជាអ្នកក្លៀវក្លាខាងសម្តែងធម៌កណ្តាលបរិសទ្យផង ជាអ្នកបានតាមប្រាថ្នា បានដោយងាយ បានដោយស្រួល នូវឈានទាំង ៤ ដែលជាធម៌អាស្រ័យនៅនឹងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នផង ហើយធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្នផង

យតោ ច ខោ ភិក្ខវេ ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច ពហុស្សុតោ ច ធម្មកថិកោ ច បរិសាវចរោ ច វិសារទោ ច បរិសាយ ធម្មំ ទេសេតិ ចតុន្នំ ឈានានំ អាភិចេតសិកានំ ទិដ្ឋធម្មសុខវិហារានំ និកាមលាភី ហោតិ អកិច្ឆលាភី អកសិរលាភី អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឯវំ សោ តេន អង្គេន បរិបូរោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សមន្តប្បាសាទិកោ ច ហោតិ សព្វាការបរិបូរោ ចាតិ ។

[៧៩] សទ្ធោ ភិក្ខវេ ភិក្ខុ ហោតិ នោ សីលវា ឯវំ សោ តេន អង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតព្វំ កិន្ត្តាហំ សទ្ធោ ច អស្សំ សីលវា ចាតិ យតោ ច ខោ ភិក្ខវេ ភិក្ខុ សទ្ធោ ច ហោតិ

ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផង ជាធម្មកថិកផង ជាអ្នកចូលទៅកាន់បរិសទ្យផង ជាអ្នកក្លៀវក្លាខាងសម្តែងធម៌កណ្តាលបរិសទ្យផង ជាអ្នកបានតាមប្រាថ្នា បានដោយងាយ បានដោយស្រួល នូវឈានទាំង ៤ ដែលជាធម៌អាស្រ័យនៅនឹងចិត្តដ៏ថ្លៃថ្លា ជាគ្រឿងនៅជាសុខ ក្នុងបច្ចុប្បន្នផង ហើយបានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្នផង យ៉ាងនេះ ទើបភិក្ខុនោះ ឈ្មោះថា បរិបូរ ដោយអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិបូរ ដោយធម៌ទាំង ៨ យ៉ាងនេះ ឈ្មោះថា ជាអ្នកបណ្តុះសេចក្តីជ្រះថ្លា ឲ្យកើតដោយគ្រប់គ្រាន់ផង ឈ្មោះថា ជាអ្នកបរិបូរ ដោយអាការៈ គឺចំណែកនៃសមណធម៌សព្វគ្រប់ផង ។

[៧៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធា តែមិនមានសីលទេ យ៉ាងនេះ ភិក្ខុនោះឈ្មោះថា មិនបរិបូរ ដោយអង្គនោះ ភិក្ខុនោះគួរបំពេញអង្គនោះ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីជាអ្នកមានសទ្ធាផង មានសីលផង ម្នាលភិក្ខុទាំងឡាយ កាលណាភិក្ខុជាអ្នកមានសទ្ធាផង

សីលវា ច ឯវំ សោ តេន អង្គេន បរិបូរោ ហោតិ ។ សទ្ធោ ច ភិក្ខវេ ភិក្ខុ ហោតិ សីលវា ច នោ ពហុស្សុតោ ។ បេ ។ ពហុស្សុតោ ច នោ ធម្មកថិកោ ។ បេ ។ ធម្មកថិកោ ច នោ បរិសា-វចរោ ។ បេ ។ បរិសាវចរោ ច នោ វិសារទោ បរិសាយ ធម្មំ ទេសេតិ ។ បេ ។ វិសារទោ ច បរិសាយ ធម្មំ ទេសេតិ[១] យេ ច តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អរូបា តេ កាយេន ផុសិត្វា វិហរតិ នោ អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឯវំ សោ តេន អង្គេន អបរិបូរោ ហោតិ តេន តំ អង្គំ បរិបូរេតព្វំ កិន្តាហំ សទ្ធោ ច អស្សំ សីលវា ច ពហុស្សុតោ ច ធម្មកថិកោ ច បរិសាវចរោ ច វិសារទោ ច បរិសាយ ធម្មំ ទេសេយ្យំ យេ ច តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អរូបា តេ កាយេន ផុសិត្វា វិហរេយ្យំ

---

១ ឱ. ម. ឯត្ថន្តរេ នោ ចាតិ អយំ បាឋោ ទិស្សតិ ។

មានសីលផង យ៉ាងនេះ ទើបភិក្ខុនោះឈ្មោះថា បរិបូរ ដោយអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង តែមិនមែនជាពហុស្សូតទេ ។ បេ ។ ជាពហុស្សូតផង តែមិនមែនជាធម្មកថិកទេ ។ បេ ។ ជាធម្មកថិកផង តែមិនមែនជាអ្នកចូលទៅកាន់បរិសទ្យទេ ។ បេ ។ ជាអ្នកចូលទៅកាន់បរិសទ្យផង តែមិនមែនជាអ្នកក្លៀវក្លាខាងសម្តែងធម៌កណ្តាលបរិសទ្យទេ ។ បេ ។ ជាអ្នកក្លៀវក្លាខាងសម្តែងធម៌កណ្តាលបរិសទ្យផង ជាអ្នកពាល់ត្រូវនូវពួកវិមោក្ខដ៏ល្អិត ជាអរូបជ្ឈានដែលកន្លងផុតនូវរូបជ្ឈាន ដោយនាមកាយផង តែមិនទាន់ធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ននៅឡើយ យ៉ាងនេះ ភិក្ខុនោះឈ្មោះថា មិនទាន់បរិបូរ ដោយអង្គនោះ ភិក្ខុនោះគួរបំពេញអង្គនោះ ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផង ជាធម្មកថិកផង ជាអ្នកចូលទៅកាន់បរិសទ្យផង ជាអ្នកក្លៀវក្លាខាងសម្តែងធម៌កណ្តាលបរិសទ្យផង ជាអ្នកពាល់ត្រូវនូវពួកវិមោក្ខដ៏ល្អិត ជាអរូបជ្ឈាន ដែលកន្លងផុតរូបជ្ឈាន ដោយនាមកាយផង

អាសវានំ ខយា អនាសវំ ចេតោវិមុត្តឹ បញ្ញាវិមុត្តឹ ទិដ្ឋេវ ធម្មេ សយំ អភិញ្ញា សច្ឆិកត្វា ឧបសម្បជ្ជ វិហរេយ្យន្តិ យតោ ច ខោ ភិក្ខវេ ភិក្ខុ សទ្ធោ ច ហោតិ សីលវា ច ពហុស្សុតោ ច ធម្មកថិកោ ច បរិសាវចរោ ច វិសារទោ ច បរិសាយ ធម្មំ ទេសេតិ យេ ច តេ សន្តា វិមោក្ខា អតិក្កម្ម រូបេ អរូបា តេ កាយេន ផុសិត្វា វិហរតិ អាសវានំ ខយា ។ បេ ។ សច្ឆិកត្វា ឧបសម្បជ្ជ វិហរតិ ឯវំ សោ តេន អង្គេន បរិបូរោ ហោតិ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតោ ភិក្ខុ សមន្ត-ប្បាសាទិកោ ច ហោតិ សព្វាការបរិបូរោ ចាតិ ។

[៨០] ឯកំ សមយំ ភគវា ញាតិកេ វិហរតិ គិញ្ជកាវសថេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ភិក្ខវោតិ ។ ភទន្តេតិ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច មរណស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ

បានធ្វើឲ្យជាក់ច្បាស់ សម្រេចនូវចេតោវិមុត្តិ និងបញ្ញាវិមុត្តិ ដែលមិនមានអាសវៈ ព្រោះអស់អាសវៈទាំងឡាយ ដោយប្រាជ្ញាដ៏ឧត្តម ដោយខ្លួនឯង ក្នុងបច្ចុប្បន្ន ម្នាលភិក្ខុទាំងឡាយ កាលណា ភិក្ខុជាអ្នកមានសទ្ធាផង មានសីលផង ជាពហុស្សូតផង ជាធម្មកថិកផង ជាអ្នកចូលទៅកាន់បរិសទ្យផង ជាអ្នកក្លៀវក្លាខាងសម្តែងធម៌កណ្តាលបរិសទ្យផង ជាអ្នកពាល់ត្រូវនូវពួកវិមោក្ខដ៏ល្អិត ជាអរូបជ្ឈាន ដែលកន្លងផុតនូវរូបជ្ឈាន ដោយនាមកាយផង បានធ្វើឲ្យជាក់ច្បាស់ ។ បេ ។ ព្រោះអស់អាសវៈទាំងឡាយ យ៉ាងនេះ ទើបភិក្ខុនោះ ឈ្មោះថា បរិបូរ ដោយអង្គនោះ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុបរិបូរ ដោយធម៌ទាំង ៨ យ៉ាងនេះ ឈ្មោះថា ជាអ្នកបណ្តុះសេចក្តីជ្រះថ្លា ឲ្យកើតដោយគ្រប់គ្រាន់ផង ឈ្មោះថា ជាអ្នកបរិបូរ ដោយអាការៈ គឺចំណែកនៃសមណធម៌សព្វគ្រប់ផង ។

[៨០] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងគិញ្ជកាវសថៈ (ប្រាសាទឥដ្ឋ) ជិតនាទិកគ្រាម ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់ហៅពួកភិក្ខុថា ម្នាលភិក្ខុទាំងឡាយ ។ ភិក្ខុទាំងនោះ ទទួលព្រះពុទ្ធដីកា របស់ព្រះដ៏មានព្រះភាគថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគទ្រង់ត្រាស់យ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ មរណស្សតិ ដែលភិក្ខុចម្រើនហើយ ធ្វើឲ្យច្រើនហើយ មានផលច្រើន

មហានិសំសា អមតោគធា អមតបរិយោសានា ភាវេថ នោ តុម្ហេ ភិក្ខវេ មរណស្សតិន្តិ ។

ឯវំ វុត្តេ អញ្ញតរោ ភិក្ខុ ភគវន្តំ ឯតទវោច អហំ ខោ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ យថាកថំ បន ត្វំ ភិក្ខុ ភាវេសិ មរណស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ អហោ វតាហំ រត្តិន្ទិវំ ជីវេយ្យំ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ឯវំ ខោ អហំ ភន្តេ ភាវេមិ មរណស្សតិន្តិ ។

អញ្ញតរោបិ ខោ ភិក្ខុ ភគវន្តំ ឯតទវោច អហំបិ ខោ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ យថាកថំ បន ត្វំ ភិក្ខុ ភាវេសិ មរណស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ អហោ វតាហំ ទិវសំ ជីវេយ្យំ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ឯវំ ខោ អហំ ភន្តេ ភាវេមិ មរណស្សតិន្តិ ។

មានអានិសង្សច្រើន ឈមចុះកាន់អមតៈ មានអមតៈជាទីបំផុត ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយ បានចម្រើនមរណស្សតិ ឬទេ ។

កាលព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់យ៉ាងនេះហើយ ភិក្ខុមួយរូប ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្ដីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ អាត្មាអញ គប្បីរស់នៅ អស់យប់និងថ្ងៃ អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន (ក្នុងសាសនារបស់ព្រះអង្គ) បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើនមរណស្សតិ យ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិដូចម្ដេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្ដីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្ដេចហ្ន៎ អាត្មាអញ គប្បីរស់នៅ អស់ ១ ថ្ងៃ អាត្មាអញ ធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើនមរណស្សតិយ៉ាងនេះ ។

៣១១



អញ្ញតរោបិ ខោ ភិក្ខុ ភគវន្តំ ឯតទវោច អហំបិ ខោ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ យថាកថំ បន ត្វំ ភិក្ខុ ភាវេសិ មរណស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ អហោ វតាហំ ឧបឌ្ឍទិវសំ ជីវេយ្យំ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ឯវំ ខោ អហំ ភន្តេ ភាវេមិ មរណស្សតិន្តិ ។

អញ្ញតរោបិ ខោ ភិក្ខុ ភគវន្តំ ឯតទវោច អហំបិ ខោ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ យថាកថំ បន ត្វំ ភិក្ខុ ភាវេសិ មរណស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ឯកំ បិណ្ឌបាតំ ភុញ្ជាមិ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ឯវំ ខោ អហំ ភន្តេ ភាវេមិ មរណស្សតិន្តិ ។

អញ្ញតរោបិ ខោ ភិក្ខុ ភគវន្តំ ឯតទវោច អហំបិ ខោ ភន្តេ ភាវេមិ មរណស្សតិន្តិ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅអស់កន្លះថ្ងៃ អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិ យ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅត្រឹមខណៈឆាន់ចង្ហាន់បិណ្ឌបាតម្តង អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើនមរណស្សតិដែរ ។

យថាកថំ បន តុំ្វ ភិក្ខុ ភាវេសិ មរណស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ឧបឌ្ឍបិណ្ឌបាតំ ភុញ្ជាមិ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតំ អស្សាតិ ឯវំ ខោ អហំ ភន្តេ ភាវេមិ មរណស្សតិន្តិ ។

អញ្ញតរោបិ ខោ ភិក្ខុ ភគវន្តំ ឯតទវោច អហំបិ ខោ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ យថាកថំ បន តុំ្វ ភិក្ខុ ភាវេសិ មរណស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ចត្តារោ បញ្ច អាលោបេ សង្ខាទិត្វា[១] អជ្ឈោហរាមិ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតំ អស្សាតិ ឯវំ ខោ អហំ ភន្តេ ភាវេមិ មរណស្សតិន្តិ ។

១ ម. សង្ខរិត្វា ។

ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅបានត្រឹមខណៈឆាន់ចង្ហាន់បិណ្ឌបាតពាក់កណ្តាល អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើននូវមរណស្សតិ យ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។ បពិត្រព្រះអង្គដ៏ច្រើន ឥឡូវនេះ ខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះ យ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅបានត្រឹមខណៈ ដែលទំពាពំនូតបាយ ៤ ឬ ៥ ពំនូត លេបចូលទៅ អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើនមរណស្សតិ យ៉ាងនេះ ។

៣១៣



អញ្ញតរោបិ ខោ ភិក្ខុ ភគវន្តំ ឯតទវោច អហំបិ ខោ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ យថាកថំ បន ត្វំ ភិក្ខុ ភាវេសិ មរណស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ឯកំ អាលោបំ សង្ខាទិត្វា អជ្ឈោហរាមិ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ឯវំ ខោ អហំ ភន្តេ ភាវេមិ មរណស្សតិន្តិ ។

អញ្ញតរោបិ ខោ ភិក្ខុ ភគវន្តំ ឯតទវោច អហំបិ ខោ ភន្តេ ភាវេមិ មរណស្សតិន្តិ ។ យថាកថំ បន ត្វំ ភិក្ខុ ភាវេសិ មរណស្សតិន្តិ ។ ឥធ មយ្ហំ ភន្តេ ឯវំ ហោតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ អស្សសិត្វា វា បស្សសាមិ បស្សសិត្វា វា អស្សសាមិ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ឯវំ ខោ អហំ ភន្តេ ភាវេមិ មរណស្សតិន្តិ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះខ្ញុំព្រះអង្គ មានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅត្រឹមខណៈ ទំពាលេបបាយអស់ ១ ពំនូត អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិយ៉ាងនេះ ។

មានភិក្ខុមួយរូបទៀត ក្រាបទូលព្រះដ៏មានព្រះភាគ យ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គចម្រើនមរណស្សតិដែរ ។ ម្នាលភិក្ខុ ចុះអ្នកចម្រើនមរណស្សតិ ដូចម្តេច ។ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះខ្ញុំព្រះអង្គមានសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញគប្បីរស់នៅត្រឹមខណៈដែលដកដង្ហើមចូល ហើយចេញ ឬដកដង្ហើមចេញ ហើយចូល អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការ ឲ្យបានច្រើន បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គ ចម្រើនមរណស្សតិ យ៉ាងនេះ ។

ឯវំ វុត្តេ ភគវា តេ ភិក្ខូ ឯតទវោច យ្វាយំ ភិក្ខវេ ភិក្ខុ ឯវំ មរណស្សតឹ ភាវេតិ អហោ វតាហំ រត្តិន្ទិវំ ជីវេយ្យំ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ។ យោ ចាយំ(១) ភិក្ខវេ ភិក្ខុ ឯវំ មរណស្សតឹ ភាវេតិ អហោ វតាហំ ទិវសំ ជីវេយ្យំ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ។ យោ ចាយំ ភិក្ខវេ ភិក្ខុ ឯវំ មរណស្សតឹ ភាវេតិ អហោ វតាហំ ឧបឌ្ឍទិវសំ ជីវេយ្យំ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ។ យោ ចាយំ ភិក្ខវេ ភិក្ខុ ឯវំ មរណស្សតឹ ភាវេតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ឯកំ បិណ្ឌបាតំ ភុញ្ជាមិ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ។ យោ ចាយំ ភិក្ខវេ ភិក្ខុ ឯវំ មរណស្សតឹ ភាវេតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ឧបឌ្ឍបិណ្ឌបាតំ ភុញ្ជាមិ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ។

---

១ ម. ឱ. យោបាយំ ។

កាលបើពួកភិក្ខុទាំងនោះ ក្រាបទូលយ៉ាងនេះហើយ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់នឹងពួកភិក្ខុទាំងនោះយ៉ាងនេះថា ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចម្រើនមរណស្សតិ ដោយសេចក្តីត្រិះរិះ យ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅ អស់យប់និងថ្ងៃ អាត្មាអញ គប្បីធ្វើទុកក្នុងចិត្ត នូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចម្រើនមរណស្សតិដោយសេចក្តីត្រិះរិះ យ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅអស់ ១ ថ្ងៃ អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចម្រើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ អាត្មាអញ គប្បីរស់នៅ អស់កន្លះថ្ងៃ អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណាចម្រើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញគប្បីរស់នៅត្រឹមខណៈឆាន់ចង្ហាន់បិណ្ឌបាតម្តង អាត្មាអញគប្បីធ្វើទុកក្នុងចិត្ត នូវពាក្យប្រៀនប្រ-ដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញគប្បីធ្វើកិច្ចការ ឲ្យបានច្រើន ។

យោ ចាយំ ភិក្ខវេ ភិក្ខុ ឯវំ មរណស្សតឹ ភាវេតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ចត្តារោ បញ្ច អាលោបេ សង្ខាទិត្វា អជ្ឈោហរាមិ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ ភិក្ខុ បមត្តា វិហរន្តិ ទន្ធំ មរណស្សតឹ ភាវេន្តិ អាសវានំ ខយាយ ។

យោ ចាយំ[១] ភិក្ខវេ ភិក្ខុ ឯវំ មរណស្សតឹ ភាវេតិ អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ ឯកំ អាលោបំ សង្ខាទិត្វា អជ្ឈោហរាមិ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ។ យោ ចាយំ ភិក្ខវេ ភិក្ខុ ឯវំ មរណស្សតឹ ភាវេតិ

១ ឱ. ម. យោ ច ខ្វាយំ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចម្រើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅត្រឹមខណៈឆាន់ចង្ហាន់បិណ្ឌបាតពាក់កណ្តាល អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចម្រើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅត្រឹមខណៈទំពាពំនូតបាយ ៤ ឬ ៥ ពំនូត លេបចូលទៅ អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអម្បាលនេះហៅថា មានសេចក្តីប្រមាទនៅឡើយ ចម្រើនមរណស្សតិ ដើម្បីធ្វើឲ្យអស់អាសវៈទាំងឡាយ យឺតយូរទេ ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចម្រើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា ធ្វើដូចម្តេចហ្ន៎ ឲ្យអាត្មាអញ គប្បីរស់នៅត្រឹមខណៈទំពាលេបបាយ ១ ពំនូត អាត្មាអញ គប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការ ឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុណា ចម្រើនមរណស្សតិ ដោយសេចក្តីត្រិះរិះយ៉ាងនេះថា

អហោ វតាហំ តទន្តរំ ជីវេយ្យំ យទន្តរំ អស្សសិត្វា វា បស្សសាមិ បស្សសិត្វា វា អស្សសាមិ ភគវតោ សាសនំ មនសិករេយ្យំ ពហុ វត មេ កតមស្សាតិ ។ ឥមេ វុច្ចន្តិ ភិក្ខវេ ភិក្ខូ អប្បមត្តា វិហរន្តិ[១] មរណស្សតឹ ភាវេន្តិ អាសវានំ ខយាយ ។ តស្មាតិហ ភិក្ខវេ ឯវំ សិក្ខិតព្វំ អប្បមត្តា វិហរិស្សាម មរណស្សតឹ ភាវេស្សាម អាសវានំ ខយាយាតិ ឯវញ្ហិ វោ ភិក្ខវេ សិក្ខិតព្វន្តិ ។

[៨១] ឯកំ សមយំ ភគវា ជាតិកេ វិហរតិ គិញ្ជកាវសថេ ។ តត្រ ខោ ភគវា ភិក្ខូ អាមន្តេសិ ។ បេ ។ មរណស្សតិ ភិក្ខវេ ភាវិតា ពហុលីកតា មហប្ផលា ហោតិ មហានិសំសា អមតោគធា អមតបរិយោសានា ។

---

១ ឱ. ម. ឯត្តន្តរេ តិក្ខន្តិ អយំ បាឋោ ទិស្សតិ ។

ធ្វើដូចម្ដេចហ្ន៎ អាត្មាអញគប្បីរស់នៅត្រឹមខណៈដែលដកដង្ហើមចូលហើយចេញឬដកដង្ហើមចេញ ហើយចូល អាត្មាអញគប្បីធ្វើទុកក្នុងចិត្តនូវពាក្យប្រៀនប្រដៅ របស់ព្រះដ៏មានព្រះភាគ អាត្មាអញ គប្បីធ្វើកិច្ចការឲ្យបានច្រើន ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុទាំងអម្បាលនេះ ហៅថាមិនមានសេចក្ដីប្រមាទ ចម្រើនមរណស្សតិ ដើម្បីឲ្យអស់អាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ភិក្ខុក្នុងសាសនានេះ ត្រូវសិក្សាយ៉ាងនេះថា ពួកយើងនឹងមិនមានសេចក្ដីប្រមាទ នឹងចម្រើនមរណស្សតិដើម្បីធ្វើឲ្យអស់អាសវៈទាំងឡាយ ម្នាលភិក្ខុទាំងឡាយ អ្នកទាំងឡាយត្រូវសិក្សា យ៉ាងនេះឯង ។

[៨១] សម័យមួយ ព្រះដ៏មានព្រះភាគ កាលគង់នៅក្នុងគិញ្ជកាវសថៈ ជិតនាទិកគ្រាម ។ ក្នុងទីនោះឯង ព្រះដ៏មានព្រះភាគទ្រង់ត្រាស់នឹងភិក្ខុទាំងឡាយថា ។ បេ ។ ម្នាលភិក្ខុទាំងឡាយ មរណស្សតិដែលភិក្ខុចម្រើនហើយ សន្សំរឿយៗ ហើយ មានផលច្រើន មានអានិសង្សច្រើន ឈមចុះកាន់អមតៈ មានអមតៈជាទីបំផុត ។

កថំ ភាវិតា ច ភិក្ខវេ មរណស្សតិ កថំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា អមតោគធា អមត-បរិយោសានា ។ ឥធ ភិក្ខវេ ភិក្ខុ ទិវសេ និក្ខន្តេ រត្តិយា បដិហិតាយ ឥតិ បដិសញ្ចិក្ខតិ ពហុកា ខោ មេ បច្ចយា មរណស្ស អហិ វា មំ ឌំសេយ្យ វិច្ឆិកា វា មំ ឌំសេយ្យ សតបទី វា មំ ឌំសេយ្យ តេន មេ អស្ស កាលកិរិយា សោ មមស្សន្តរាយោ ឧបក្ខលិត្វា វា បបតេយ្យំ ភត្តំ វា មេ ភុត្តំ ព្យាបជ្ជេយ្យ បិត្តំ វា មេ កុប្បេយ្យ សេម្ហំ វា មេ កុប្បេយ្យ សត្ថកា វា មេ វាតា កុប្បេយ្យុំ មនុស្សា វា មំ ឧបក្កមេយ្យុំ អមនុស្សា វា មំ ឧបក្កមេយ្យុំ តេន មេ អស្ស កាលកិរិយា សោ មមស្សន្តរាយោតិ តេន ភិក្ខវេ ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ អត្ថិ នុ ខោ មេ បាបកា អកុសលា ធម្មា អប្បហីនា យេ មេ អស្សុ រត្តឹ កាលំ ករោន្តស្ស អន្តរាយាយាតិ

ម្នាលភិក្ខុទាំងឡាយ ចុះមរណស្សតិ ដែលភិក្ខុចម្រើនហើយ តើដូចម្តេច សន្សំរឿយៗហើយ មានផលច្រើន មានអានិសង្សច្រើន ឈមចុះកាន់ អមត: មានអមត:ជាទីបំផុត តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុ ក្នុងសាសនានេះ កាលបើថ្ងៃកន្លងទៅហើយ យប់មកដល់វិញ តែង ពិចារណាដូច្នេះថា ហេតុនៃសេចក្តីស្លាប់ របស់អាត្មាអញ មានច្រើន ណាស់តើ (ដូចជា) ពស់ចឹកអាត្មាក្តី ខ្ទួយទិចអាត្មាអញក្តី ក្អែបខាំ អាត្មាអញក្តី អាត្មាអញនឹងស្លាប់ អន្តរាយ[១] នោះនឹងមានដល់អាត្មា អញ ព្រោះហេតុតែពស់ចឹកជាដើមនោះ អាត្មាអញភ្លាត់ដួលក្តី ភត្ត ដែលអាត្មាអញ បរិភោគហើយហល់ក្តី ប្រមាត់របស់អាត្មាអញកម្រើក ក្តី ស្លេស្មរបស់អាត្មាអញកម្រើកក្តី កង់ខ្យល់ដូចសស្ត្រាវុធរបស់អាត្មាអញ កម្រើកក្តី ពួកមនុស្សព្យាយាមសម្លាប់អាត្មាអញក្តី ពួកអមនុស្សព្យាយាម សម្លាប់អាត្មាអញក្តី អាត្មាអញនឹងស្លាប់ អន្តរាយនោះ នឹងមានដល់ អាត្មាអញ ព្រោះហេតុតែភ្លាត់ដួលជាដើមនោះ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវពិចារណាថា អកុសលធម៌ទាំងឡាយ ដ៏លាមកណា នាំឲ្យ អន្តរាយដល់អាត្មាអញ ដែលធ្វើមរណកាល ក្នុងរាត្រី អកុសលធម៌ដ៏ លាមកនោះ អាត្មាអញ មិនទាន់បានលះបង់នៅឡើយ មានដែរឬទេ

---

១-អន្តរាយមាន ៣ យ៉ាងគឺ ជីវិតអន្តរាយ ១ សមណធម្មន្តរាយ ១ សគ្គមគ្គន្តរាយ ១ ។ អដ្ឋកថា ។

សចេ ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អត្ថិ មេ ចាបកា អកុសលា ធម្មា អប្បហីនា យេ មេ អស្សុ រត្តឹ កាលំ ករោន្តស្ស អន្តរាយាយាតិ តេន ភិក្ខវេ ភិក្ខុនា តេសញ្ញេវ ចាបកានំ អកុសលានំ ធម្មានំ បហានាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ សេយ្យថាបិ ភិក្ខវេ អាទិត្តចេលោ វា អាទិត្តសីសោ វា តស្សេវ ចេលស្ស វា សីសស្ស វា និព្វាបនាយ អធិមត្តំ ឆន្ទញ្ច វាយាមញ្ច ឧស្សាហញ្ច ឧស្សោឡ្ហិញ្ច អប្បដិវានិញ្ច សតិញ្ច សម្បជញ្ញញ្ច ករេយ្យ ឯវមេវ ខោ ភិក្ខវេ តេន ភិក្ខុនា តេសញ្ញេវ ចាបកានំ អកុសលានំ ធម្មានំ បហានាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើភិក្ខុពិចារណាដឹងយ៉ាងនេះថា អកុសល-ធម៌ទាំងឡាយដ៏លាមកណា នាំឲ្យអន្តរាយដល់អាត្មាអញ ដែលធ្វើមរណ-កាល ក្នុងរាត្រី អកុសលធម៌ដ៏លាមកទាំងនោះ អាត្មាអញមិនទាន់បាន លះបង់ហើយ នៅមានមែន ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះ ត្រូវធ្វើឆន្ទៈ ផង សេចក្តីព្យាយាមផង ឧស្សាហៈផង សេចក្តីខ្នះខ្នែងផង សេចក្តីមិន រួញរាផង សតិផង សម្បជញ្ញៈផង ឲ្យខ្លាំង ដើម្បីលះបង់នូវអកុសលធម៌ ដ៏លាមកទាំងនោះចេញឲ្យដាច់ ម្នាលភិក្ខុទាំងឡាយ ដូចបុគ្គលមានសំពត់ ឆេះក្តី មានក្បាលឆេះក្តី ត្រូវធ្វើឆន្ទៈផង សេចក្តីព្យាយាមផង ឧស្សាហៈផង សេចក្តីខ្នះខ្នែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យខ្លាំង ដើម្បីនឹងលត់សំពត់នោះផង លត់ក្បាលនោះផង យ៉ាងណាមិញ ម្នាល ភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវធ្វើឆន្ទៈផង សេចក្តីព្យាយាមផង ឧស្សាហៈផង សេចក្តីខ្នះខ្នែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យខ្លាំង ដើម្បីនឹងលះអកុសលធម៌ ដ៏លាមកទាំងនោះចេញ ឲ្យដាច់យ៉ាងនោះដែរ

៣១៩



សចេ បន ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ នត្ថិ មេ បាបកា អកុសលា ធម្មា អប្បហីនា យេ មេ អស្សុ រត្តឹ កាលំ ករោន្តស្ស អន្តរាយាយាតិ តេន ភិក្ខវេ ភិក្ខុនា តេនេវ បីតិប្បាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។

ឥធ បន ភិក្ខវេ ភិក្ខុ រត្តិយា និក្ខន្តាយ ទិវសេ បដិហិតេ ឥតិ បដិសញ្ចិក្ខតិ ពហុកា ខោ មេ បច្ចយា មរណស្ស អហិ វា មំ ឌំសេយ្យ វិច្ឆិកា វា មំ ឌំសេយ្យ សតបទី វា មំ ឌំសេយ្យ តេន មេ អស្ស កាលកិរិយា សោ មមស្សន្តរាយោ ឧបក្ខលិត្វា វា បបតេយ្យំ ភត្តំ វា មេ ភុត្តំ ព្យាបជ្ជេយ្យ បិត្តំ វា មេ កុប្បេយ្យ សេម្ហំ វា មេ កុប្បេយ្យ សត្ថកា វា មេ វាតា កុប្បេយ្យុំ មនុស្សា វា មំ ឧបក្កមេយ្យុំ អមនុស្សា វា មំ ឧបក្កមេយ្យុំ តេន មេ អស្ស កាលកិរិយា សោ មមស្សន្តរាយោតិ

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុពិចារណាដឹងយ៉ាងនេះថា អកុសល-ធម៌ទាំងឡាយ ដ៏លាមកណា នាំឲ្យអន្តរាយ ដល់អាត្មាអញ ដែលផ្ដើមរណោកាល ក្នុងរាត្រី អកុសលធម៌ដ៏លាមកទាំងនោះ អាត្មាអញមិនទាន់បានលះហើយ មិនមានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីជាអ្នកសិក្សារឿយៗ ទាំងថ្ងៃទាំងយប់ ក្នុងកុសលធម៌ទាំងឡាយ ដោយបីតិនិងបាមោជ្ជនោះចុះ ។

មួយទៀត ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ កាលបើយប់កន្លងទៅហើយ ថ្ងៃមកដល់វិញ តែងពិចារណាដូច្នេះថា ហេតុនៃសេចក្ដីស្លាប់ របស់អាត្មាអញមានច្រើនណាស់តើ (ដូនជា) ពស់ចឹកអាត្មាអញក្ដី ខ្ទួយទិចអាត្មាអញក្ដី ក្អែបខាំអាត្មាអញក្ដី អាត្មាអញនឹងស្លាប់អន្តរាយនោះ នឹងមានដល់អាត្មាអញ ព្រោះហេតុតែពស់ចឹកជាដើមនោះ (ឬមួយ) អាត្មាអញភ្លាត់ដួលក្ដី ភត្តដែលអាត្មាអញ បរិភោគហើយហល់ក្ដី ប្រមាត់របស់អាត្មាអញកម្រើកក្ដី ស្លេស្មរបស់អាត្មាអញកម្រើកក្ដី កងខ្យល់ដូចសស្ត្រាវុធរបស់អាត្មាអញកម្រើកក្ដី ពួកមនុស្សព្យាយាមសម្លាប់អាត្មាអញក្ដី ពួកអមនុស្សព្យាយាម សម្លាប់អាត្មាអញក្ដី អាត្មាអញនឹងស្លាប់អន្តរាយនោះ នឹងមានដល់អាត្មាអញ ព្រោះហេតុតែភ្លាត់ដួលជាដើមនោះ

តេន ភិក្ខវេ ភិក្ខុនា ឥតិ បដិសញ្ចិក្ខិតព្វំ អត្ថិ នុ ខោ មេ បាបកា អកុសលា ធម្មា អប្បហីនា យេ មេ អស្សុ ទិវា កាលំ ករោន្តស្ស អន្តរាយាយាតិ សចេ ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ អត្ថិ មេ បាបកា អកុសលា ធម្មា អប្បហីនា យេ មេ អស្សុ ទិវា កាលំ ករោន្តស្ស អន្តរាយាយាតិ តេន ភិក្ខវេ ភិក្ខុនា តេសញ្ញេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ សេយ្យថាបិ ភិក្ខវេ អាទិត្តចេលោ វា អាទិត្តសីសោ វា តស្សេវ ចេលស្ស វា សីសស្ស វា និព្វាបនាយ អធិមត្តំ ឆន្ទញ្ច វាយាមញ្ច ឧស្សាហញ្ច ឧស្សោឡ្ហិញ្ច អប្បដិវានិញ្ច សតិញ្ច សម្បជញ្ញញ្ច ករេយ្យ ឯវមេវ ខោ ភិក្ខវេ តេន ភិក្ខុនា តេសញ្ញេវ បាបកានំ អកុសលានំ ធម្មានំ បហានាយ អធិមត្តោ ឆន្ទោ ច វាយាមោ ច ឧស្សាហោ ច ឧស្សោឡ្ហី ច អប្បដិវានី ច សតិ ច សម្បជញ្ញញ្ច ករណីយំ

ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវពិចារណាថា អកុសលធម៌ទាំង-ឡាយដ៏លាមកណា នាំឲ្យអន្តរាយដល់អាត្មាអញ ដែលធ្វើមរណកាល ក្នុងវេលាថ្ងៃ អកុសលធម៌ដ៏លាមកទាំងនោះ អាត្មាអញមិនទាន់បាន លះបង់ហើយ មានដែរឬទេ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុពិចារ-ណាដឹងយ៉ាងនេះថា អកុសលធម៌ទាំងឡាយដ៏លាមកណា នាំឲ្យអន្តរាយ ដល់អាត្មាអញ ដែលធ្វើមរណកាល ក្នុងវេលាថ្ងៃ អកុសលធម៌ដ៏លាមក ទាំងនោះ អាត្មាអញមិនទាន់បានលះនៅឡើយ នៅមានមែន ម្នាលភិក្ខុ ទាំងឡាយ ភិក្ខុនោះត្រូវធ្វើឆន្ទៈផង សេចក្តីព្យាយាមផង ឧស្សាហៈផង សេចក្តីខ្នះខ្នែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈ ផង ឲ្យខ្លាំង ដើម្បីនឹងលះអកុសលធម៌ដ៏លាមក ទាំងនោះចេញ ឲ្យ ផាច់ ម្នាលភិក្ខុទាំងឡាយ ដូចបុគ្គលមានសំពត់ឆេះក្តី មានក្បាលឆេះក្តី ត្រូវធ្វើឆន្ទៈផង សេចក្តីព្យាយាមផង ឧស្សាហៈផង សេចក្តីខ្នះ-ខ្នែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យខ្លាំង ដើម្បីនឹងលត់សំពត់ ឬក្បាលនោះ យ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះត្រូវធ្វើឆន្ទៈផង សេចក្តីព្យាយាមផង ឧស្សាហៈផង សេចក្តី ខ្នះខ្នែងផង សេចក្តីមិនរួញរាផង សតិផង សម្បជញ្ញៈផង ឲ្យខ្លាំង ដើម្បីនឹងលះអកុសលធម៌ដ៏លាមកទាំងនោះចេញ ឲ្យផាច់ យ៉ាងនោះដែរ

សចេ បន ភិក្ខវេ ភិក្ខុ បច្ចវេក្ខមានោ ឯវំ ជានាតិ នត្ថិ មេ បាបកា អកុសលា ធម្មា អប្បហីនា យេ មេ អស្សុ ទិវា កាលំ ករោន្តស្ស អន្តរាយាយាតិ តេន ភិក្ខវេ ភិក្ខុនា តេនេវ បីតិប្បាមោជ្ជេន វិហាតព្វំ អហោរត្តានុសិក្ខិនា កុសលេសុ ធម្មេសុ ។ ឯវំ ភាវិតា ខោ ភិក្ខវេ មរណស្សតិ ឯវំ ពហុលីកតា មហប្ផលា ហោតិ មហានិសំសា អមតោគធា អមតបរិយោសានាតិ ។

[៨២] អដ្ឋិមា ភិក្ខវេ សម្បទា ។ កតមា អដ្ឋ ។ ឧដ្ឋានសម្បទា អារក្ខសម្បទា កល្យាណមិត្តតា សមជីវិតា សទ្ធាសម្បទា សីលសម្បទា ចាគសម្បទា បញ្ញាសម្បទា ។ ឥមា ខោ ភិក្ខវេ អដ្ឋ សម្បទាតិ ។

ឧដ្ឋាតា កម្មធេយ្យេសុ អប្បមត្តោ វិធានវា
សមំ កប្បេតិ ជីវិតំ សម្ភតំ អនុរក្ខតិ
សទ្ធោ សីលេន សម្បន្នោ វទញ្ញូ វីតមច្ឆរោ
និច្ចំ មគ្គំ វិសោធេតិ សោត្ថានំ សម្បរាយិកំ

ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ ភិក្ខុពិចារណាដឹងយ៉ាងនេះថា អកុសលធម៌ទាំងឡាយដ៏លាមកណា នាំឲ្យអន្តរាយដល់អាត្មាអញ ដែលធ្វើមរណកាល ក្នុងវេលាថ្ងៃ អកុសលធម៌ដ៏លាមកទាំងនោះ អាត្មាអញមិនទាន់បានលះហើយ មិនមានទេ ម្នាលភិក្ខុទាំងឡាយ ភិក្ខុនោះគប្បីជាអ្នកសិក្សារឿយៗ ទាំងថ្ងៃទាំងយប់ ក្នុងកុសលធម៌ទាំងឡាយ ដោយបីតិនិងបាមោជ្ជនោះចុះ ។ ម្នាលភិក្ខុទាំងឡាយ មរណស្សតិ ដែលភិក្ខុចម្រើនហើយយ៉ាងនេះ សន្សំរឿយៗ ហើយយ៉ាងនេះ មានផលច្រើន មានអានិសង្សច្រើន ឈមចុះកាន់អមតៈ មានអមតៈជាទីបំផុត ។

[៨២] ម្នាលភិក្ខុទាំងឡាយ សម្បទានេះមាន ៨ យ៉ាង ។ ៨ យ៉ាងគឺអ្វីខ្លះ ។ គឺឧដ្ឋានសម្បទា ១ អារក្ខសម្បទា ១ កល្យាណមិត្តតា ១ សមជីវិតា ១ សទ្ធាសម្បទា ១ សីលសម្បទា ១ ចាគសម្បទា ១ បញ្ញាសម្បទា ១ ។ ម្នាលភិក្ខុទាំងឡាយ នេះសម្បទា ៨ យ៉ាង ។

បុគ្គលអ្នកប្រឹងប្រែង មានវិធានការ មិនបណ្តោតបណ្តោយ
ក្នុងការងារទាំងឡាយ តែងចិញ្ចឹមជីវិតស្មើ រក្សាទ្រព្យ
ដែលខ្លួនរកបានមក មានសទ្ធា បរិបូណ៌ ដោយសីល
ឈ្លាស ក្នុងសម្តី លះបោលសេចក្តីកំណាញ់ ជម្រះនូវផ្លូវ
សម្រាប់ទៅកាន់លោកខាងមុខ ឲ្យមានសួស្តី ជានិច្ច

ឥច្ចេតេ អដ្ឋ ធម្មា ច សទ្ធស្ស ឃរមេសិនោ
អក្ខាតា សច្ចនាមេន ឧភយត្ថ សុខាវហា
ទិដ្ឋធម្មហិតត្ថាយ សម្បរាយសុខាយ ច
ឯវមេតំ គហដ្ឋានំ ចាគោ បុញ្ញំ បវឌ្ឍតីតិ ។

[៨៣] អដ្ឋិមា ភិក្ខវេ សម្បទា ។ កាតមា អដ្ឋ ។ ឧដ្ឋានសម្បទា អារក្ខសម្បទា កល្យាណមិត្តតា សម-ជីវិតា សទ្ធាសម្បទា សីលសម្បទា ចាគសម្បទា បញ្ញាសម្បទា ។

កាតមា ច ភិក្ខវេ ឧដ្ឋានសម្បទា ។ ឥធ ភិក្ខវេ កុលបុត្តោ យេន កម្មដ្ឋានេន ជីវិកំ កប្បេតិ យទិ កសិយា យទិ វណិជ្ជាយ យទិ គោរក្ខេន យទិ ឥស្សត្ថេន យទិ រាជបោរិសេន យទិ សិប្បញ្ញតរេន តត្ថ ទក្ខោ ហោតិ អនលសោ តត្រុបាយាយ វីមំសាយ សមន្នាគតោ អលំ កាតុំ អលំ សំវិធាតុំ អយំ វុច្ចតិ ភិក្ខវេ ឧដ្ឋានសម្បទា ។

ធម៌ទាំង ៨ យ៉ាងនេះ នាំមកនូវសេចក្តីសុខ ក្នុងលោកទាំងពីរ ដែលព្រះសម្ពុទ្ធទ្រង់ព្រះនាមថាសច្ចៈ ទ្រង់សម្តែងហើយ ដល់កុលបុត្តអ្នកមានសទ្ធា នៅគ្រប់គ្រងផ្ទះ មួយទៀត ការបរិច្ចាគនិងបុណ្យដ៏សេសនេះ តែងចម្រើនដល់ពួកគ្រហស្ថ ដើម្បីសេចក្តីចម្រើននិងប្រយោជន៍ ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខ ក្នុងលោកខាងមុខផង យ៉ាងនេះ ។

[៨៣] ម្នាលភិក្ខុទាំងឡាយ សម្បទានេះមាន ៨ យ៉ាង ។ ៨ យ៉ាង គឺអ្វីខ្លះ ។ គឺឧដ្ឋានសម្បទា ១ អារក្ខសម្បទា ១ កល្យាណមិត្តតា ១ សមជីវិតា ១ សទ្ធាសម្បទា ១ សីលសម្បទា ១ ចាគសម្បទា ១ បញ្ញាសម្បទា ១ ។

ម្នាលភិក្ខុទាំងឡាយ ចុះឧដ្ឋានសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងលោកនេះ ចិញ្ចឹមជីវិតដោយខំធ្វើការងារ ទោះបីធ្វើស្រែចម្ការក្តី ជំនួញក្តី រក្សាគោក្តី ធ្វើសេនាយោធាក្តី ធ្វើជារាជបុរសក្តី ចេះសិល្បៈណាមួយក្តី ជាអ្នកឈ្លាស ក្នុងអំពើនោះៗ មិនខ្ជិលច្រអូស បរិបូណ៌ដោយការលៃលក មានល្បិចក្នុងការនោះថា គួរធ្វើ គួរចាត់ចែង ម្នាលភិក្ខុទាំងឡាយ នេះហៅថា ឧដ្ឋានសម្បទា ។

៣២៣



កតមា ច ភិក្ខវេ អារក្ខសម្បទា ។ ឥធ ភិក្ខវេ កុលបុត្តស្ស ភោគា ហោន្តិ ឧដ្ឋានវីរិយាធិគតា ពាហាពលបរិចិតា សេទាវក្ខិត្តា ធម្មិកា ធម្មលទ្ធា តេ អារក្ខេន គុត្តិយា សម្បាទេតិ កិន្តិ មេ ឥមេ ភោគេ នេវ រាជានោ ហរេយ្យុំ ន ចោរា ហរេយ្យុំ ន អគ្គិ ឌហេយ្យ ន ឧទកំ វហេយ្យ ន អប្បិយា ទាយាទា ហរេយ្យុន្តិ អយំ វុច្ចតិ ភិក្ខវេ អារក្ខសម្បទា ។

កតមា ច ភិក្ខវេ កល្យាណមិត្តតា ។ ឥធ ភិក្ខវេ កុលបុត្តោ យស្មឹ គាមេ វា និគមេ វា បដិវសតិ តត្រ យេ តេ ហោន្តិ គហបតិ វា គហបតិបុត្តា វា ទហរា វា វុឌ្ឍសីលិនោ វុឌ្ឍា វា វុឌ្ឍសីលិនោ សទ្ធាសម្បន្នា សីលសម្បន្នា ចាគសម្បន្នា បញ្ញាសម្បន្នា តេហិ សទ្ធឹ សន្តិដ្ឋតិ សល្លបតិ សាកច្ឆំ សមាបជ្ជតិ យថារូបានំ សទ្ធាសម្បន្នានំ សទ្ធាសម្បទំ អនុសិក្ខតិ

ម្នាលភិក្ខុទាំងឡាយ ចុះអារក្ខសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងលោកនេះ មានភោគៈច្រើនដែលខ្លួនរកបានមកដោយការប្រឹងប្រែង ព្យាយាម សន្សំដោយកម្លាំងដៃ បែកញើសហូរញើស ប្រកបដោយធម៌ បានមកដោយធម៌ ហើយថែទាំភោគៈទាំងនោះដោយការរក្សា គ្រប់គ្រង ដោយបំណងថា ធ្វើដូចម្តេចហ្ន៎ កុំឲ្យព្រះរាជាទាំងឡាយ រឹបជាន់យក កុំឲ្យពួកចោរលួចយក កុំឲ្យភ្លើងឆេះ កុំឲ្យទឹកលិច កុំឲ្យពួកទាយាទ មិនជាទីគាប់ចិត្តយកទៅបាន ម្នាលភិក្ខុទាំងឡាយ នេះហៅថា អារក្ខសម្បទា ។

ម្នាលភិក្ខុទាំងឡាយ ចុះកល្យាណមិត្តតា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងលោកនេះ នៅក្នុងស្រុកណាក្តី និគមណាក្តី ក្នុងស្រុក ឬនិគមនោះ មានពួកគហបតី ឬពួកគហបតិបុត្ត ទោះបីនៅក្មេងតែជាអ្នកចម្រើនដោយសីល ទោះបីចាស់ក៏ចម្រើនដោយសីល មានសទ្ធាបរិបូណ៌ មានសីលបរិបូណ៌ មានចាគៈបរិបូណ៌ មានបញ្ញាបរិបូណ៌ កុលបុត្តតែងឋិតនៅ ចរចា សាកសួរ ជាមួយនឹងពួកគហបតីទាំងនោះ ហើយសិក្សារឿយៗនូវសទ្ធាសម្បទា នឹងពួកបុគ្គលដែលជាអ្នកមានសទ្ធាបរិបូណ៌ តាមសមគួរ

យថារូបានំ សីលសម្បន្នានំ សីលសម្បទំ អនុសិក្ខតិ យថារូបានំ ចាគសម្បន្នានំ ចាគសម្បទំ អនុសិក្ខតិ យថារូបានំ បញ្ញាសម្បន្នានំ បញ្ញាសម្បទំ អនុសិក្ខតិ អយំ វុច្ចតិ ភិក្ខវេ កល្យាណមិត្តតា ។

កតមា ច ភិក្ខវេ សមជីវិតា ។ ឥធ ភិក្ខវេ កុលបុត្តោ អាយញ្ច ភោគានំ វិទិត្វា វយញ្ច ភោគានំ វិទិត្វា សមជីវិកំ កប្បេតិ នាច្ចោគាឡ្ហំ នាតិហីនំ ឯវំ មេ អាយោ វយំ បរិយាទាយ ឋស្សតិ ន ច មេ វយោ អាយំ បរិយាទាយ ឋស្សតីតិ សេយ្យថាបិ ភិក្ខវេ តុលាធារោ វា តុលាធារន្តេវាសី វា តុលំ បគ្គហេត្វា ជានាតិ ឯត្តកេន វា ឱនតំ ឯត្តកេន វា ឧន្នតន្តិ

សិក្សារៀយៗ នូវសីលសម្បទា នឹងពួកបុគ្គល ជាអ្នកមានសីលបរិបូណ៌ តាមសមគួរ សិក្សារៀយៗ នូវចាគសម្បទា នឹងពួកអ្នកមានចាគៈបរិបូណ៌ តាមសមគួរ សិក្សារៀយៗ នូវបញ្ញាសម្បទា នឹងពួកបុគ្គលអ្នកមានបញ្ញា បរិបូណ៌តាមសមគួរ ម្នាលភិក្ខុទាំងឡាយ នេះហៅថា កល្យាណមិត្តតា ។

ម្នាលភិក្ខុទាំងឡាយ ចុះសមជីវិតា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្តក្នុងលោកនេះស្គាល់សេចក្តីចម្រើនភោគៈទាំងឡាយផង ស្គាល់សេចក្តីសាបសូន្យភោគៈទាំងឡាយផងហើយចិញ្ចឹមជីវិតតាមសមគួរមិនទូលាយពេក មិនក្បិតក្បៀតពេក ដោយបំណងយ៉ាងនេះថា សេចក្តីចម្រើនរបស់អាត្មាអញ នឹងគ្របសង្កត់សេចក្តីវិនាសបាន ឯសេចក្តីវិនាសរបស់អាត្មាអញនឹងមិនគ្របសង្កត់ សេចក្តីចម្រើនយ៉ាងនេះបានទេ ម្នាលភិក្ខុទាំងឡាយ ប្រៀបដូចអ្នកថ្លឹងក្តី សិស្សរបស់អ្នកថ្លឹងក្តី លើកជញ្ជីងឡើងហើយដឹងថា ស្រាល ព្រោះ (ខ្វះ) ប៉ុណ្ណេះឬធ្ងន់ព្រោះ (លើស) ប៉ុណ្ណេះយ៉ាងណាមិញ

៣២៤



ឯវមេវ ខោ ភិក្ខវេ កុលបុត្តោ អាយញ្ច ភោគានំ វិទិត្វា វយញ្ច ភោគានំ វិទិត្វា សមជីវិកំ កប្បេតិ នាច្ចោគាឡ្ហំ នាតិហីនំ ឯវំ មេ អាយោ វយំ បរិយាទាយ ឋស្សតិ ន ច មេ វយោ អាយំ បរិយាទាយ ឋស្សតីតិ ។ សចាយំ ភិក្ខវេ កុលបុត្តោ អប្បាយោ សមានោ ឧឡារំ ជីវិកំ កប្បេតិ តស្ស ភវន្តិ វត្តារោ ឧទុម្ពរខាទកញ្ចាយំ កុលបុត្តោ ភោគេ ខាទតីតិ ។ សចេ បនាយំ ភិក្ខវេ កុលបុត្តោ មហាយោ សមានោ កសិរំ ជីវិកំ កប្បេតិ តស្ស ភវន្តិ វត្តារោ អជទ្ធមារកញ្ចាយំ កុលបុត្តោ មរិស្សតីតិ ។ យតោ ច ខោយំ ភិក្ខវេ កុលបុត្តោ អាយញ្ច ភោគានំ វិទិត្វា វយញ្ច ភោគានំ វិទិត្វា សមជីវិកំ កប្បេតិ នាច្ចោគាឡ្ហំ នាតិហីនំ ឯវំ មេ អាយោ វយំ បរិយាទាយ ឋស្សតិ ន ច មេ វយោ អាយំ បរិយាទាយ ឋស្សតីតិ អយំ វុច្ចតិ ភិក្ខវេ សមជីវិតា ។

ម្នាលភិក្ខុទាំងឡាយ កុលបុត្តស្គាល់សេចក្ដីចម្រើន នូវភោគៈទាំងឡាយផង ស្គាល់សេចក្ដីសាបសូន្យភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតតាមសមគួរ មិនទូលាយដែពេក មិនក្បិតក្បៀតពេក ដោយបំណងយ៉ាងនេះថា សេចក្ដីចម្រើនរបស់អាត្មាអញ នឹងគ្របសង្កត់សេចក្ដីវិនាសបាន ឯសេចក្ដីវិនាសរបស់អាត្មាអញ នឹងមិនអាចគ្របសង្កត់សេចក្ដីចម្រើន យ៉ាងនេះបានទេ ក៏យ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើកុលបុត្តនេះ មានសេចក្ដីចម្រើនតិច គឺខ្សត់ទ្រព្យ ហើយចិញ្ចឹមជីវិតលើសលុប អ្នកផងតែងតិះដៀលកុលបុត្តនោះថា កុលបុត្តនេះស៊ីភោគៈ ដូចគេស៊ីផ្លែល្វា ។ ម្នាលភិក្ខុទាំងឡាយ ប្រសិនបើ កុលបុត្តនេះ មានសេចក្ដីចម្រើនច្រើន គឺមានទ្រព្យ ហើយចិញ្ចឹមជីវិតរលីបរលោប អ្នកផងតែងតិះដៀលកុលបុត្តនោះថា កុល-បុត្តនេះ មុខតែនឹងស្លាប់ឥតមានទីពឹង ។ ម្នាលភិក្ខុទាំងឡាយ កាលណាបើកុលបុត្តនេះ ស្គាល់សេចក្ដីចម្រើនភោគៈទាំងឡាយផង ស្គាល់សេចក្ដីវិនាសភោគៈទាំងឡាយផង ហើយចិញ្ចឹមជីវិតស្មើ មិនទូលាយដែពេក មិនក្បិតក្បៀតពេក ដោយបំណងថា សេចក្ដីចម្រើនរបស់អាត្មាអញ នឹងគ្របសង្កត់សេចក្ដីវិនាសបាន ឯសេចក្ដីវិនាសរបស់អាត្មាអញនឹងមិនអាចគ្របសង្កត់សេចក្ដីចម្រើន យ៉ាងនេះបានទេ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សមជីវិតា ។

### ៣២៦



កាតមា ច ភិក្ខវេ សទ្ធាសម្បទា ។ ឥធ ភិក្ខវេ កុលបុត្តោ សទ្ធោ ហោតិ សទ្ទហាតិ តថាគតស្ស ពោធឹ ឥតិបិ សោ ភគវា ។ បេ ។ សត្ថា ទេវមនុស្សានំ ពុទ្ធោ ភគវាតិ អយំ វុច្ចតិ ភិក្ខវេ សទ្ធាសម្បទា ។

កាតមា ច ភិក្ខវេ សីលសម្បទា ។ ឥធ ភិក្ខវេ កុលបុត្តោ បាណាតិបាតា បដិវិរតោ ហោតិ ។ បេ ។ សុរាមេរយមជ្ជប្បមាទដ្ឋានា បដិវិរតោ ហោតិ អយំ វុច្ចតិ ភិក្ខវេ សីលសម្បទា ។

កាតមា ច ភិក្ខវេ ចាគសម្បទា ។ ឥធ ភិក្ខវេ កុលបុត្តោ វិគតមលមច្ឆេរេន ចេតសា អគារំ អជ្ឈាវសតិ ។ បេ ។ យាចយោគោ ទានសំវិភាគរតោ អយំ វុច្ចតិ ភិក្ខវេ ចាគសម្បទា ។

កាតមា ច ភិក្ខវេ បញ្ញាសម្បទា ។ ឥធ ភិក្ខវេ កុលបុត្តោ បញ្ញវា ហោតិ ។ បេ ។

ម្នាលភិក្ខុទាំងឡាយ ចុះសទ្ធាសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្ត ក្នុងលោកនេះ ជាអ្នកមានសទ្ធា ជឿការត្រាស់ដឹងរបស់ព្រះតថាគតថា ព្រះដ៏មានព្រះភាគអង្គនោះ ។ បេ ។ ជាគ្រូនៃទេវតានឹងមនុស្សទាំងឡាយ ត្រាស់ដឹងនូវសច្ចៈទាំង ៤ លែងវិលត្រឡប់មកកាន់ភពថ្មីទៀត ម្នាលភិក្ខុទាំងឡាយ នេះហៅថា សទ្ធាសម្បទា ។

ម្នាលភិក្ខុទាំងឡាយ ចុះសីលសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្ត ក្នុងលោកនេះ ជាអ្នកវៀរចាកកិរិយាសម្លាប់សត្វ ។ បេ ។ ជាអ្នកវៀរចាកហេតុជាទីតាំងនៃសេចក្តីប្រមាទ គឺការផឹកនូវទឹកស្រវឹង បានខាងឯសុរានិងមេរ័យ ម្នាលភិក្ខុទាំងឡាយ នេះហៅថា សីលសម្បទា ។

ម្នាលភិក្ខុទាំងឡាយ ចុះចាគសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្ត ក្នុងលោកនេះ មានចិត្តប្រាសចាកមន្ទិល គឺសេចក្តីកំណាញ់ ហើយនៅគ្រប់គ្រងផ្ទះ ។ បេ ។ ជាអ្នកគួរឲ្យគេសូមបាន ត្រេកអរ ក្នុងការឲ្យនិងការចែករលែក ម្នាលភិក្ខុទាំងឡាយ នេះហៅថា ចាគសម្បទា ។

ម្នាលភិក្ខុទាំងឡាយ ចុះបញ្ញាសម្បទា តើដូចម្តេច ។ ម្នាលភិក្ខុទាំងឡាយ កុលបុត្ត ក្នុងលោកនេះ ជាអ្នកមានបញ្ញា ។ បេ ។

សម្មាទុក្ខក្ខយគាមិនិយា អយំ វុច្ចតិ ភិក្ខវេ បញ្ញាសម្បទា ។ ឥមា ខោ ភិក្ខវេ អដ្ឋ សម្បទាតិ ។

ឧដ្ឋាតា កម្មធេយ្យេសុ អប្បមត្តោ វិធានវា
សមំ កប្បេតិ ជីវិតំ សម្ភតំ អនុរក្ខតិ
សទ្ធោ សីលេន សម្បន្នោ វទញ្ញូ វីតមច្ឆរោ
និច្ចំ មគ្គំ វិសោធេតិ សោត្ថានំ សម្បរាយិកំ
ឥច្ចេតេ អដ្ឋ ធម្មា ច សទ្ធស្ស ឃរមេសិនោ
អក្ខាតា សច្ចនាមេន ឧភយត្ថ សុខាវហា
ទិដ្ឋធម្មហិតត្ថាយ សម្បរាយសុខាយ ច
ឯវមេតំ គហដ្ឋានំ ចាគោ បុញ្ញំ បវឌ្ឍតីតិ ។

[៨៤] តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ អាវុសោ ភិក្ខវោតិ ។ អាវុសោតិ ខោ តេ ភិក្ខូ អាយស្មតោ សារីបុត្តស្ស បច្ចស្សោសុំ ។

ជាដំណើរអាចយល់សេចក្តីអស់ទៅ នៃទុក្ខដោយប្រពៃ ម្នាលភិក្ខុទាំង-ឡាយ នេះហៅថា បញ្ញាសម្បទា ។ ម្នាលភិក្ខុទាំងឡាយ នេះសម្បទាទាំង ៨ យ៉ាង ។

បុគ្គលអ្នកប្រឹងប្រែង មានវិធានការ មិនបណ្តោតបណ្តោយ ក្នុងការងារទាំងឡាយ តែងចិញ្ចឹមជីវិតស្មើ រក្សាទ្រព្យ ដែលខ្លួនរកបានមក មានសទ្ធា បរិបូណ៌ដោយសីល ឈ្លាស ក្នុងសម្តី លះចោលសេចក្តីកំណាញ់ ជម្រះនូវផ្លូវសម្រាប់ទៅ កាន់លោកខាងមុខ ឲ្យមានសួស្តីជានិច្ច ធម៌ទាំង ៨ យ៉ាងនេះ នាំមកនូវសេចក្តីសុខ ក្នុងលោកទាំងពីរ ដែលព្រះសម្ពុទ្ធទ្រង់ ព្រះនាមថាសច្ចៈ ទ្រង់សម្តែងហើយ ដល់កុលបុត្តអ្នកមាន សទ្ធា នៅគ្រប់គ្រងផ្ទះ មួយទៀត ការបរិច្ចាគនិងបុណ្យ ដ៏សេសនេះ តែងចម្រើនដល់ពួកគ្រហស្ថ ដើម្បីសេចក្តី ចម្រើននិងប្រយោជន៍ ក្នុងបច្ចុប្បន្នផង ដើម្បីសេចក្តីសុខ ក្នុងលោកខាងមុខផង យ៉ាងនេះ ។

[៨៤] ក្នុងទីនោះ ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចានឹងពួកភិក្ខុ ថា ម្នាលភិក្ខុទាំងឡាយ ដ៏មានអាយុ ។ ពួកភិក្ខុទាំងនោះ ទទួល ថេរវាចា របស់ព្រះសារីបុត្តដ៏មានអាយុថា បពិត្រលោកដ៏មានអាយុ ។

អាយស្មា សារីបុត្តោ ឯតទវោច អដ្ឋិមេ អាវុសោ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មឹ ។ កតមេ អដ្ឋ ។

ឥធាវុសោ ភិក្ខុនោ បវិវិត្តស្ស វិហរតោ និរាយត្ត-វុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ សោ ឧដ្ឋហតិ ឃដតិ វាយមតិ លាភាយ តស្ស ឧដ្ឋហតោ ឃដតោ វាយ-មតោ លាភាយ លាភោ នុប្បជ្ជតិ សោ តេន អលាភេន សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ អយំ វុច្ចតាវុសោ ភិក្ខុ ឥច្ឆោ វិហរតិ លាភាយ ឧដ្ឋហតិ ឃដតិ វាយមតិ លាភាយ ន ច លាភី សោចិ ច[១] បរិទេវិ ច ចុតោ ច សទ្ធម្មា ។

ឥធ បនាវុសោ ភិក្ខុនោ បវិវិត្តស្ស វិហរតោ និរាយត្តវុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ សោ ឧដ្ឋហតិ ឃដតិ វាយមតិ លាភាយ តស្ស ឧដ្ឋហតោ ឃដតោ វាយមតោ លាភាយ លាភោ ឧប្បជ្ជតិ សោ តេន លាភេន មជ្ជតិ បមជ្ជតិ បមាទមាបជ្ជតិ

---

១ ឱ. សោចិច្ច ។

ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចាដូច្នេះថា ម្នាលលោកដ៏មានអាយុទាំងឡាយ បុគ្គល ៨ ពួកនេះ មានពាសក្នុងលោក ។ ៨ ពួក តើដូចម្ដេចខ្លះ ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់កាយ តែប្រព្រឹត្តមិនដាប់លាប់ សេចក្ដីប្រាថ្នាដើម្បីលាភ កើតឡើងភិក្ខុនោះប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភ កាលភិក្ខុនោះប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភហើយ លាភក៏មិនកើតឡើង ភិក្ខុនោះ ក៏ក្រៀមក្រំ លំបាក ខ្សឹកខ្សួល គក់ទ្រូង យំ កន្ទក់កន្ទេញ ដល់នូវសេចក្ដីវង្វេង ព្រោះតែឥតលាភនោះ ម្នាលលោកដ៏មានអាយុទាំងឡាយ ភិក្ខុនេះហៅថា អ្នកមានសេចក្ដីប្រាថ្នា ដើម្បីលាភ ប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភ តែជាអ្នកឥតលាភផង ក្រៀមក្រំផង ខ្សឹកខ្សួលផង ឃ្លាតចាកព្រះសទ្ធម្មផង ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់កាយ តែប្រព្រឹត្តមិនដាប់លាប់ សេចក្ដីប្រាថ្នាដើម្បីលាភកើតឡើង ភិក្ខុនោះ ប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភ កាលភិក្ខុនោះប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភហើយ លាភក៏កើតឡើង ភិក្ខុនោះក៏ស្រវឹង ផេងផោង ដល់នូវសេចក្ដីប្រមាទ ព្រោះតែលាភនោះ

អយំ វុច្ចតាវុសោ ភិក្ខុ ឥច្ឆោ វិហរតិ លាភាយ ឧដ្ឋហតិ ឃដតិ វាយមតិ លាភាយ លាភី ច មទី ច បមាទី ច ចុតោ ច សទ្ធម្មា ។

ឥធ បនាវុសោ ភិក្ខុនោ បវិវិត្តស្ស វិហរតោ និរា-យត្តវុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ សោ ន ឧដ្ឋហតិ ន ឃដតិ ន វាយមតិ លាភាយ តស្ស អនុដ្ឋហតោ អឃដតោ អវាយមតោ លាភាយ លាភោ នុប្បជ្ជតិ សោ តេន អលាភេន សោចតិ កិលមតិ បរិទេវតិ ឧរត្តាឡឹ កន្ទតិ សម្មោហំ អាបជ្ជតិ អយំ វុច្ចតាវុសោ ភិក្ខុ ឥច្ឆោ វិហរតិ លាភាយ ន ឧដ្ឋហតិ ន ឃដតិ ន វាយមតិ លាភាយ ន ច លាភី សោចិ ច បរិទេវិ ច ចុតោ ច សទ្ធម្មា ។

ឥធ បនាវុសោ ភិក្ខុនោ បវិវិត្តស្ស វិហរតោ និរាយត្តវុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ សោ ន ឧដ្ឋហតិ ន ឃដតិ ន វាយមតិ លាភាយ

ម្នាលលោកដ៏មានអាយុទាំងឡាយ ភិក្ខុនេះហៅថា អ្នកមានសេចក្តីប្រាថ្នា ដើម្បីលាភ ប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភ ជាអ្នកមានលាភផង ស្រវឹងផង ធ្វេសប្រហែសផង ឃ្លាតចាកព្រះសទ្ធម្មផង ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់កាយ តែប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នាដើម្បីលាភ កើតឡើង ភិក្ខុនោះមិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភទេ កាលភិក្ខុនោះ មិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភហើយ លាភក៏មិនកើតឡើង ភិក្ខុនោះក៏ក្រៀមក្រំ លំបាក ខ្សឹកខ្សួល គក់ទ្រូង យំកន្ទក់កន្ទេញ ដល់នូវសេចក្តីវង្វេង ព្រោះតែឥតលាភនោះ ម្នាលលោកដ៏មានអាយុទាំងឡាយ ភិក្ខុនេះហៅថា អ្នកមានសេចក្តីប្រាថ្នា ដើម្បីលាភ តែមិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភទេ ជាអ្នកឥតលាភផង ក្រៀមក្រំផង ខ្សឹកខ្សួលផង ឃ្លាតចាកព្រះសទ្ធម្មផង ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់កាយ តែប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នាដើម្បីលាភ កើតឡើង ភិក្ខុនោះ មិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភទេ

តស្ស អនុដ្ឋហតោ អឃដតោ អវាយមតោ លាភាយ លាភោ ឧប្បជ្ជតិ សោ តេន លាភេន មជ្ជតិ បមជ្ជតិ បមាទមាបជ្ជតិ អយំ វុច្ចតាវុសោ ភិក្ខុ ឥច្ឆោ វិហរតិ លាភាយ ន ឧដ្ឋហតិ ន ឃដតិ ន វាយមតិ លាភាយ លាភី ច មទី ច បមាទី ច ចុតោ ច សទ្ធម្មា ។

ឥធ បនាវុសោ ភិក្ខុនោ បវិវិត្តស្ស វិហរតោ និរាយត្តវុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ សោ ឧដ្ឋហតិ ឃដតិ វាយមតិ លាភាយ តស្ស ឧដ្ឋហតោ ឃដតោ វាយមតោ លាភាយ លាភោ នុប្បជ្ជតិ សោ តេន អលាភេន ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ អយំ វុច្ចតាវុសោ ភិក្ខុ ឥច្ឆោ វិហរតិ លាភាយ ឧដ្ឋហតិ ឃដតិ វាយមតិ លាភាយ ន ច លាភី ន ច សោចិ ន ច បរិទេវិ អច្ចុតោ ច សទ្ធម្មា ។

ភិក្ខុនោះ មិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភហើយ លាភក៏កើតឡើង ភិក្ខុនោះក៏ស្រវឹង ផ្ងែងផ្ងោង ដល់នូវសេចក្តីប្រមាទ ព្រោះតែលាភនោះ ម្នាលលោកដ៏មានអាយុទាំងឡាយ ភិក្ខុនេះហៅថា អ្នកមានសេចក្តីប្រាថ្នា ដើម្បីលាភ តែមិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភ ជាអ្នកមានលាភផង ស្រវឹងផង ផ្ងែងផ្ងោងផង ឃ្លាតចាកព្រះសទ្ធម្មផង ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់កាយ តែប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នាដើម្បីលាភ កើតឡើង ភិក្ខុនោះប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភ កាលភិក្ខុនោះ ប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភហើយ លាភក៏មិនកើតឡើង ភិក្ខុនោះ ក៏មិនក្រៀមក្រំ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងយំ កន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេង ព្រោះតែឥតលាភនោះទេ ម្នាលលោកដ៏មានអាយុទាំងឡាយ ភិក្ខុនេះហៅថា អ្នកមានសេចក្តីប្រាថ្នាដើម្បីលាភ ប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភ ជាអ្នកឥតលាភផង មិនក្រៀមក្រំផង មិនខ្សឹកខ្សួលផង មិនឃ្លាតចាកព្រះសទ្ធម្មផង ។

ឥធ បនាវុសោ ភិក្ខុនោ បវិវិត្តស្ស វិហរតោ និរា-យត្តវុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ សោ ឧដ្ឋហតិ ឃដតិ វាយមតិ លាភាយ តស្ស ឧដ្ឋហតោ ឃដតោ វាយមតោ លាភាយ លាភោ ឧប្បជ្ជតិ សោ តេន លាភេន ន មជ្ជតិ ន បមជ្ជតិ ន បមាទមាបជ្ជតិ អយំ វុច្ចតាវុសោ ភិក្ខុ ឥច្ឆា វិហរតិ លាភាយ ឧដ្ឋហតិ ឃដតិ វាយមតិ លាភាយ លាភី ច ន ច មទី ន ច បមាទី អច្ចុតោ ច សទ្ធម្មា ។

ឥធ បនាវុសោ ភិក្ខុនោ បវិវិត្តស្ស វិហរតោ និរា-យត្តវុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ សោ ន ឧដ្ឋហតិ ន ឃដតិ ន វាយមតិ លាភាយ តស្ស អនុដ្ឋហតោ អឃដតោ អវាយមតោ លាភាយ លាភោ នុប្បជ្ជតិ សោ តេន អលាភេន ន សោចតិ ន កិលមតិ ន បរិទេវតិ ន ឧរត្តាឡឹ កន្ទតិ ន សម្មោហំ អាបជ្ជតិ

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់កាយ តែប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នាដើម្បីលាភ កើតឡើង ភិក្ខុនោះប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភ កាលភិក្ខុនោះប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភហើយ លាភក៏កើតឡើង តែភិក្ខុនោះ មិនស្រវឹង មិនង៉េងង៉ោង មិនដល់នូវសេចក្តីប្រមាទ ព្រោះតែលាភនោះទេ ម្នាលលោកដ៏មានអាយុទាំងឡាយ ភិក្ខុនេះហៅថាអ្នកមានសេចក្តីប្រាថ្នា ដើម្បីលាភ ប្រឹងប្រែង ខ្វល់ខ្វាយ ព្យាយាម ដើម្បីលាភ ជាអ្នកមានលាភផង ជាអ្នកមិនស្រវឹងផង មិនង៉េងង៉ោងផង មិនឃ្លាតចាកព្រះសទ្ធម្មផង ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់កាយ តែប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នាដើម្បីលាភកើតឡើង ភិក្ខុនោះមិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភទេ កាលភិក្ខុនោះមិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភហើយ លាភក៏មិនកើតឡើងដែរ ភិក្ខុនោះមិនក្រៀមក្រំ មិនលំបាក មិនខ្សឹកខ្សួល មិនគក់ទ្រូងយំ កន្ទក់កន្ទេញ មិនដល់នូវសេចក្តីវង្វេង ព្រោះតែឥតលាភនោះឡើយ

អយំ វុច្ចតាវុសោ ភិក្ខុ ឥច្ឆោ វិហរតិ លាភាយ ន ឧដ្ឋហតិ ន ឃដតិ ន វាយមតិ លាភាយ ន ច លាភី ន ច សោចិ ន ច បរិទេវិ អច្ចុតោ ច សទ្ធម្មា ។

ឥធ បនាវុសោ ភិក្ខុនោ បវិវិត្តស្ស វិហរតោ និរាយត្តវុត្តិនោ ឥច្ឆា ឧប្បជ្ជតិ លាភាយ សោ ន ឧដ្ឋហតិ ន ឃដតិ ន វាយមតិ លាភាយ តស្ស អនុដ្ឋហតោ អឃដតោ អវាយមតោ លាភាយ លាភោ ឧប្បជ្ជតិ សោ តេន លាភេន ន មជ្ជតិ ន បមជ្ជតិ ន បមាទមាបជ្ជតិ អយំ វុច្ចតាវុសោ ភិក្ខុ ឥច្ឆោ វិហរតិ លាភាយ ន ឧដ្ឋហតិ ន ឃដតិ ន វាយមតិ លាភាយ លាភី ច ន ច មជ្ជី ន ច បមាទី អច្ចុតោ ច សទ្ធម្មា ។ ឥមេ ខោ អាវុសោ អដ្ឋ បុគ្គលា សន្តោ សំវិជ្ជមានា លោកស្មិន្តិ ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ភិក្ខុនេះហៅថា អ្នកមានសេចក្តីប្រាថ្នា ដើម្បីលាភ តែមិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភ ជាអ្នកមិនមានលាភផង មិនក្រៀមក្រំផង មិនខ្សឹកខ្សួលផង មិនឃ្លាតចាកព្រះសទ្ធម្មផង ។

ម្នាលលោកដ៏មានអាយុទាំងឡាយ ក្នុងសាសនានេះ ភិក្ខុជាអ្នកស្ងាត់កាយ តែប្រព្រឹត្តមិនជាប់លាប់ សេចក្តីប្រាថ្នាដើម្បីលាភ កើតឡើង ភិក្ខុនោះមិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភទេ កាលភិក្ខុនោះ មិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភហើយ លាភក៏កើតឡើង តែភិក្ខុនោះ មិនស្រវឹង មិនង៉ើងង៉ោង មិនដល់នូវសេចក្តីប្រមាទ ព្រោះតែលាភនោះទេ ម្នាលលោកដ៏មានអាយុទាំង-ឡាយ ភិក្ខុនេះហៅថា អ្នកមានសេចក្តីប្រាថ្នា ដើម្បីលាភ មិនប្រឹងប្រែង មិនខ្វល់ខ្វាយ មិនព្យាយាម ដើម្បីលាភ ជាអ្នកមានលាភផង មិនស្រវឹងផង មិនង៉ើងង៉ោងផង មិនឃ្លាតចាកព្រះសទ្ធម្មផង ។ ម្នាលលោកដ៏មានអាយុទាំងឡាយ បុគ្គលទាំង ៨ ពួកនេះ មានពាសក្នុងលោក ។

[៨៥] តត្រ ខោ អាយស្មា សារីបុត្តោ ភិក្ខូ អាមន្តេសិ ។ បេ ។ ឆហាវុសោ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ អលំ បរេសំ ។ កតមេហិ ឆហិ ។ ឥធាវុសោ ភិក្ខុ ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុតានញ្ច ធម្មានំ ធារកជាតិកោ ហោតិ ធតានញ្ច ធម្មានំ អត្ថុបបរិក្ខី ហោតិ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ច ហោតិ កល្យាណវាចោ ច ហោតិ កល្យាណវាក្ករណោ ចោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា សន្ទស្សកោ ច ហោតិ សមាទបកោ សមុត្តេជកោ សម្បហំសកោ សព្រហ្មចារីនំ ។ ឥមេហិ ខោ អាវុសោ ឆហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ អលំ បរេសំ ។

[៨៦] បញ្ចហាវុសោ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ អលំ បរេសំ ។ កតមេហិ បញ្ចហិ ។

[៨៥] ក្នុងទីនោះ ព្រះសារីបុត្តដ៏មានអាយុ មានថេរវាចានឹងពួកភិក្ខុថា ។ បេ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ ៦ យ៉ាង គួរដល់ខ្លួន (ផង) គួរដល់ពួកជនដទៃ (ផង) ។ ៦ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកចុះចិត្តក្នុងកងធម៌ ជាកុសលដោយឆាប់ ១ ជាអ្នកចាំកងធម៌ ដែលខ្លួនស្តាប់ហើយ ១ ជាអ្នករំពឹងនូវសេចក្តីនៃកងធម៌ ដែលខ្លួនចាំហើយ ១ ជាអ្នកយល់អត្ថយល់ធម៌ ហើយប្រតិបត្តិធម៌សមគួរតាមធម៌ ១ ជាអ្នកមានសម្តីពីរោះ មានសំឡេងពីរោះ ប្រកបដោយវាចា របស់អ្នកក្រុង ជាវាចាក្បោះក្បាយ មិនរអាក់រអួល អាចបំភ្លឺសេចក្តីឲ្យបុគ្គលដទៃដឹងច្បាស់ ១ ជាអ្នកសម្តែងធម៌ ពន្យល់ ណែនាំ ឲ្យពួកសព្រហ្មចារី យល់ប្រយោជន៍ ក្នុងបច្ចុប្បន្ននិងបរលោក ឲ្យជឿជាក់ក្នុងកុសលធម៌ ឲ្យរីករាយ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ ដោយធម៌ទាំង ៦ យ៉ាងនេះ គួរដល់ខ្លួនឯង (ផង) គួរដល់ពួកជនដទៃ (ផង) ។

[៨៦] ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ ៥ យ៉ាង គួរដល់ខ្លួនឯង (ផង) គួរដល់ពួកជនដទៃ (ផង) ។ ៥ យ៉ាង តើដូចម្តេចខ្លះ ។

ឥធាវុសោ ភិក្ខុ ន ហេវ ខោ ចិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុតានញ្ច ធម្មានំ ធារកជាតិកោ ហោតិ ធតានញ្ច ធម្មានំ អត្ថុបបរិក្ខី ហោតិ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ច ហោតិ កល្យាណវាចោ ច ហោតិ ។ បេ ។ សន្ទស្សកោ ច ហោតិ ។ បេ ។ សព្រហ្មចារីនំ ។ ឥមេហិ ខោ អាវុសោ បញ្ចហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ អលំ បរេសំ ។

[៨៧] ចតូហាវុសោ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ នោ បរេសំ ។ កតមេហិ ចតូហិ ។ ឥធាវុសោ ភិក្ខុ ចិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុតានញ្ច ធម្មានំ ធារកជាតិកោ ហោតិ ធតានញ្ច ធម្មានំ អត្ថុបបរិក្ខី ហោតិ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ច ហោតិ នោ ច កល្យាណវាចោ ហោតិ ។ បេ ។ នោ ច សន្ទស្សកោ ហោតិ ។ បេ ។ សព្រហ្មចារីនំ ។ ឥមេហិ ខោ អាវុសោ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ នោ បរេសំ ។

ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ មិនជាអ្នកចុះចិត្ត ក្នុងកង កុសលធម៌ដោយឆាប់ តែជាអ្នកចាំកងធម៌ ដែលខ្លួនស្តាប់ហើយ ១ ជាអ្នក រំពឹងសេចក្តីនៃកងធម៌ ដែលខ្លួនចាំហើយ ១ ជាអ្នកយល់អត្ថ យល់ធម៌ ហើយប្រតិបត្តិធម៌សមគួរតាមធម៌ ១ ជាអ្នកមានសម្តីពីរោះ ១ ។ បេ ។ ជាអ្នកសម្តែងធម៌ ពន្យល់ណែនាំឲ្យពួក ។ បេ ។ របស់សព្រហ្មចារីទាំង-ឡាយ ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ ដោយធម៌ទាំង ៥ យ៉ាងនេះ គួរដល់ខ្លួនឯង (ផង) គួរដល់ពួកជនដទៃ (ផង) ។

[៨៧] ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ ៤ យ៉ាង គួរដល់ខ្លួនឯង តែមិនគួរដល់ពួកជនដទៃឡើយ ។ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកចុះចិត្តក្នុងកង កុសលធម៌ ដោយឆាប់ផង ចាំកងធម៌ដែលខ្លួនស្តាប់ហើយផង ១ ជាអ្នក រំពឹងសេចក្តីនៃកងធម៌ ដែលខ្លួនចាំហើយផង យល់អត្ថ យល់ធម៌ហើយ ប្រតិបត្តិធម៌សមគួរតាមធម៌ផង ១ តែជាអ្នកមិនមានសម្តីពីរោះ ១ ។ បេ ។ ជាអ្នកមិនសម្តែងធម៌ ពន្យល់ ណែនាំ ។ បេ ។ របស់សព្រហ្មចារី ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ ៤ យ៉ាងនេះ គួរដល់ខ្លួនឯង តែមិនគួរដល់ជនដទៃឡើយ ។

[៨៨] ចតូហាវុសោ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ បរេសំ នោ អត្តនោ ។ កាតមេហិ ចតូហិ ។ ឥធា-វុសោ ភិក្ខុ ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុតានញ្ច ធម្មានំ ធារកជាតិកោ ហោតិ នោ ច ធតានំ ធម្មានំ អត្ថុបបរិក្ខី ហោតិ នោ ច អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ កល្យាណវាចោ ច ហោតិ ។ បេ ។ សន្ទស្សកោ ច ហោតិ ។ បេ ។ សព្រហ្មចារីនំ ។ ឥមេហិ ខោ អាវុសោ ចតូហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ បរេសំ នោ អត្តនោ ។

[៨៩] តីហាវុសោ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ នោ បរេសំ ។ កាតមេហិ តីហិ ។ ឥធាវុសោ ភិក្ខុ ន ហេវ ខោ ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុតានញ្ច ធម្មានំ ធារក-ជាតិកោ ហោតិ ធតានញ្ច ធម្មានំ អត្ថុបបរិក្ខី ហោតិ

[៨៨] ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ ៤ យ៉ាង គួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឯងឡើយ ។ ៤ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកចុះចិត្តក្នុងកងកុសលធម៌ ដោយឆាប់ផង ចាំកងធម៌ ដែលខ្លួនស្តាប់ហើយផង ១ មិនរំពឹងសេចក្តីនៃកងធម៌ ដែលខ្លួនចាំហើយផង យល់អត្ថ យល់ធម៌ ហើយមិនប្រតិបត្តិធម៌សមគួរតាមធម៌ផង ១ មានសម្តីពីរោះ ១ ។ បេ ។ សម្តែងធម៌ ពន្យល់ ណែនាំ ។ បេ ។ របស់ពួកសព្រហ្មចារី ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ទាំង ៤ យ៉ាងនេះ គួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឯងឡើយ ។

[៨៩] ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ ដោយធម៌ ៣ យ៉ាង គួរដល់ខ្លួនឯង តែមិនគួរដល់ពួកជនដទៃឡើយ ។ ៣ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនចុះចិត្តក្នុងកងកុសលធម៌ ដោយឆាប់ផង ជាអ្នកចាំកងធម៌ ដែលខ្លួនស្តាប់ហើយផង ជាអ្នករំពឹងសេចក្តីកងធម៌ ដែលខ្លួនចាំហើយផង

អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ច ហោតិ នោ ច កល្យាណវាចោ ហោតិ ។ បេ ។ នោ ច សន្ទស្សកោ ហោតិ ។ បេ ។ សព្រហ្មចារីនំ ។ ឥមេហិ ខោ អាវុសោ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ នោ បរេសំ ។

[៩០] តីហាវុសោ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ បរេសំ នោ អត្តនោ ។ កតមេហិ តីហិ ។ ឥធាវុសោ ភិក្ខុ ន ហេវ ខោ ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុតានញ្ច ធម្មានំ ធារណជាតិកោ ហោតិ នោ ច ធាតានំ ធម្មានំ អត្ថុបបរិក្ខី ហោតិ នោ ច អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ កល្យាណវាចោ ច ហោតិ ។ បេ ។ អត្ថស្ស វិញ្ញាបនិយា សន្ទស្សកោ ច ហោតិ ។ បេ ។ សព្រហ្មចារីនំ ។ ឥមេហិ ខោ អាវុសោ តីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ បរេសំ នោ អត្តនោ ។

[៩១] ទ្វីហាវុសោ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ នោ បរេសំ ។ កតមេហិ ទ្វីហិ ។

ជាអ្នកយល់អត្ថ យល់ធម៌ ហើយប្រតិបត្តិធម៌ សមគួរតាមធម៌ផង ១ ជាអ្នកមិនមានសម្តីពីរោះ ១ ។ បេ ។ ជាអ្នកមិនសម្តែងធម៌ ពន្យល់ ណែនាំ ។ បេ ។ របស់ពួកសព្រហ្មចារី ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ទាំង ៣ យ៉ាងនេះ គួរដល់ខ្លួនឯង តែមិនគួរដល់ពួកជនដទៃឡើយ ។

[៩០] ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ ដោយធម៌ ៣ យ៉ាង គួរដល់ជនដទៃ តែមិនគួរដល់ខ្លួនឯងឡើយ ។ ៣ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនចុះចិត្តក្នុងកងកុសលធម៌ ដោយឆាប់ផង ជាអ្នកចាំកងធម៌ ដែលខ្លួនស្តាប់ហើយផង តែជាអ្នកមិនរំពឹងនូវសេចក្តីនៃកងធម៌ ដែលខ្លួនចាំហើយផង យល់អត្ថ យល់ធម៌ហើយមិនប្រតិបត្តិធម៌សមគួរតាមធម៌ផង ១ ជាអ្នកមានសម្តីពីរោះ ។ បេ ។ ជាវាចាបំភ្លឺនូវសេចក្តីឲ្យអ្នកដទៃដឹងច្បាស់ ១ ជាអ្នកសម្តែងធម៌ ពន្យល់ ណែនាំ ។ បេ ។ របស់ពួកសព្រហ្មចារី ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ ៣ យ៉ាងនេះ គួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឯងឡើយ ។

[៩១] ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ ២ យ៉ាងគួរដល់ខ្លួនឯង តែមិនគួរដល់ពួកជនដទៃឡើយ ។ ២ យ៉ាង តើដូចម្តេចខ្លះ ។

ឥធាវុសោ ភិក្ខុ ន ហេវ ខោ ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ សុតានញ្ច ធម្មានំ ធារកជាតិកោ ហោតិ ធតានញ្ច ធម្មានំ អត្ថុបបរិក្ខី ហោតិ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ច ហោតិ នោ ច កល្យាណវាចោ ហោតិ ។ បេ ។ នោ ច សន្ទស្សកោ ហោតិ ។ បេ ។ សព្រហ្មចារីនំ ។ ឥមេហិ ខោ អាវុសោ ទ្វីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ អត្តនោ នោ បរេសំ ។

[៩២] ទ្វីហាវុសោ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ បរេសំ នោ អត្តនោ ។ កតមេហិ ទ្វីហិ ។ ឥធាវុសោ ភិក្ខុ ន ហេវ ខោ ខិប្បនិសន្តិ ច ហោតិ កុសលេសុ ធម្មេសុ នោ ច សុតានំ ធម្មានំ ធារកជាតិកោ ហោតិ នោ ច ធតានំ ធម្មានំ អត្ថុបបរិក្ខី ហោតិ នោ ច អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ កល្យាណវាចោ ច ហោតិ

ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនទាន់ចុះចិត្ត ក្នុងកុសលធម៌ដោយឆាប់ផង ជាអ្នកចាំកងធម៌ដែលខ្លួនស្តាប់ហើយផង រំពឹងសេចក្តីនៃកងធម៌ ដែលខ្លួនចាំហើយផង យល់អត្ថ យល់ធម៌ ហើយប្រតិបត្តិធម៌សមគួរតាមធម៌ផង ១ ជាអ្នកមិនមានសម្តីពីរោះ ។ បេ ។ ផង ជាអ្នកមិនសម្តែងធម៌ ពន្យល់ ណែនាំ ។ បេ ។ របស់ពួកសព្រហ្មចារី ១ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ទាំង ២ យ៉ាងនេះ គួរដល់ខ្លួនឯង តែមិនគួរដល់ពួកជនដទៃឡើយ ។

[៩២] ម្នាលអាវុសោទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ ២ យ៉ាង គួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឯងឡើយ ។ ២ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលអាវុសោទាំងឡាយ ភិក្ខុក្នុងសាសនានេះ ជាអ្នកមិនទាន់ចុះចិត្តក្នុងកងកុសលធម៌ដោយឆាប់ផង មិនចាំកងធម៌ដែលខ្លួនស្តាប់ហើយផង មិនបានរំពឹងសេចក្តីនៃកងធម៌ ដែលខ្លួនចាំហើយផង យល់អត្ថ យល់ធម៌ ហើយមិនប្រតិបត្តិធម៌សមគួរតាមធម៌ផង ១ ជាអ្នកមានសម្តីពីរោះ

កល្យាណវាក្ករណោ បោរិយា វាចាយ សមន្នាគតោ វិស្សដ្ឋាយ អនេលគឡាយ អត្ថស្ស វិញ្ញាបនិយា សន្ទស្សកោ ច ហោតិ សមាទបកោ សមុត្តេជកោ សម្បហំសកោ សព្រហ្មចារីនំ ។ ឥមេហិ ខោ អាវុសោ ទ្វីហិ ធម្មេហិ សមន្នាគតោ ភិក្ខុ អលំ បរេសំ នោ អត្តនោតិ ។

[៩៣] អដ្ឋិមេ ភិក្ខវេ ធម្មា សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។ កតមេ អដ្ឋ ។ កម្មារាមតា ភស្សារាមតា និទ្ទារាមតា សង្គណិការាមតា ឥន្ទ្រិយេសុ អគុត្តទ្វារតា ភោជនេ អមត្តញ្ញុតា សំសគ្គារាមតា បបញ្ចារាមតា ។ ឥមេ ខោ ភិក្ខវេ អដ្ឋ ធម្មា សេក្ខស្ស ភិក្ខុនោ បរិហានាយ សំវត្តន្តិ ។

មានសំឡេងពីរោះ ប្រកបដោយវាចារបស់អ្នកក្រុង ជាវាចាក្បោះក្បាយ មិនរអាក់រអួល ជាវាចាបំភ្លឺសេចក្តីឲ្យអ្នកដទៃដឹងច្បាស់ផង ជាអ្នកពន្យល់ណែនាំ ពួកសព្រហ្មចារី ឲ្យជឿជាក់ ក្នុងកុសលធម៌ ឲ្យរីករាយ ១ ។ ម្នាលអាវុសោ ធម៌ទាំងឡាយ ភិក្ខុបរិបូណ៌ដោយធម៌ទាំង ២ យ៉ាងនេះ គួរដល់ពួកជនដទៃ តែមិនគួរដល់ខ្លួនឯងឡើយ ។

[៩៣] ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ យ៉ាងនេះ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ ដល់សេក្ខភិក្ខុ ។ ៨ យ៉ាង តើដូចម្តេចខ្លះ ។ គឺ សេចក្តីត្រេកអរ ក្នុងការងារ ១ សេចក្តីត្រេកអរ ក្នុងតិរច្ឆានកថា ១ សេចក្តីត្រេកអរ ក្នុងការដេក ១ សេចក្តីត្រេកអរ ក្នុងពួក ១ សេចក្តីមិនគ្រប់គ្រងទ្វារ ក្នុងពួកឥន្ទ្រិយ ១ សេចក្តីមិនស្គាល់ប្រមាណ ក្នុងភោជន ១ សេចក្តីត្រេកអរ ក្នុងការជាប់ជំពាក់[១] ១ សេចក្តីត្រេកអរ ក្នុងធម៌ជាគ្រឿងយឺតយូរ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៨ យ៉ាងនេះ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីសាបសូន្យ ដល់សេក្ខភិក្ខុ ។

---

១-ធមិសម្រាប់ជាប់ជំពាក់មាន៥យ៉ាងគឺសវនសំសគ្គៈ ជាប់ជំពាក់ដោយការឮសំឡេង ១ ទស្សនសំសគ្គៈ ជាប់ជំពាក់ដោយការឃើញរូប ១ សមុល្លាបសំសគ្គៈ ជាប់ជំពាក់ដោយពាក្យសម្តី ១ សម្ភោគសំសគ្គ ជាប់ជំពាក់ដោយការប្រើរបស់ភិក្ខុ-ភិក្ខុនី ១ កាយសំសគ្គៈ ជាប់ជំពាក់ដោយកាយសម្ផស្ស ១ ។ អដ្ឋកថា មជ្ឈិមនិកាយ មូលបណ្ណាសកត្រង់រថវនីតសូត្រ ។

[៩៨] អដ្ឋិមេ ភិក្ខវេ ធម្មា សេក្ខស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។ កតមេ អដ្ឋ ។ នកម្មារាមតា នភស្សារាមតា ននិទ្ទារាមតា នសង្គណិការាមតា ឥន្ទ្រិយេសុ គុត្តទ្វារតា ភោជនេ មត្តញ្ញុតា អសំសគ្គារាមតា និប្បបញ្ចារាមតា ។ ឥមេ ខោ ភិក្ខវេ អដ្ឋ ធម្មា សេក្ខស្ស ភិក្ខុនោ អបរិហានាយ សំវត្តន្តិ ។

[៩៩] អដ្ឋិមានិ ភិក្ខវេ កុសីតវត្ថូនិ ។ កតមានិ អដ្ឋ ។ ឥធ ភិក្ខវេ ភិក្ខុនា កម្មំ កត្តព្វំ ហោតិ តស្ស ឯវំ ហោតិ កម្មំ ខោ មេ កត្តព្វំ ភវិស្សតិ កម្មំ ខោ បន មេ ករោន្តស្ស កាយោ កិលមិស្សតិ ហន្ទាហំ និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ ភិក្ខវេ បឋមំ កុសីតវត្ថុ ។

[៩៤] ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ យ៉ាងនេះ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យ ដល់សេក្ខភិក្ខុ ។ ៨ យ៉ាង តើដូចម្តេចខ្លះ ។ គឺសេចក្តីមិនត្រេកអរ ក្នុងការងារ ១ សេចក្តីមិនត្រេកអរ ក្នុងតិរច្ឆានកថា ១ សេចក្តីមិនត្រេកអរ ក្នុងការដេក ១ សេចក្តីមិនត្រេកអរ ក្នុងពួកគណៈ ១ សេចក្តីគ្រប់គ្រងទ្វារ ក្នុងពួកឥន្ទ្រិយ ១ សេចក្តីស្គាល់ប្រមាណ ក្នុងភោជន ១ សេចក្តីមិនត្រេកអរ ក្នុងការជាប់ជំពាក់ ១ សេចក្តីមិនត្រេកអរ ក្នុងធម៌ជាគ្រឿងយឺតយូរ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ទាំង ៨ យ៉ាងនេះ តែងប្រព្រឹត្តទៅ ដើម្បីសេចក្តីមិនសាបសូន្យ ដល់សេក្ខភិក្ខុ ។

[៩៥] ម្នាលភិក្ខុទាំងឡាយ កុសីតវត្ថុនេះ មាន ៨ យ៉ាង ។ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អំពើ គឺការលៃលកវាស់កាត់ចីវរជាដើម ដែលភិក្ខុក្នុងសាសនានេះ គួរធ្វើក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អំពើដែលអាត្មាអញ គួរធ្វើ គង់នឹងមាន តែបើអាត្មាអញធ្វើអំពើ (នោះហើយ) កាយក៏នឹងលំបាក បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណគឺឈាន វិបស្សនា មគ្គ ផលដែលខ្លួនមិនទាន់ដល់ ដើម្បីដឹងនូវគុណដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់ នូវគុណដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ទេ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ១ ។

បុន ចបរំ ភិក្ខវេ ភិក្ខុនា កម្មំ កតំ ហោតិ តស្ស ឯវំ ហោតិ អហំ ខោ កម្មំ អកាសឹ កម្មំ ខោ បន មេ ករោន្តស្ស កាយោ កិលន្តោ ហន្ទាហំ និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ ភិក្ខវេ ទុតិយំ កុសីតវត្ថុ ។

បុន ចបរំ ភិក្ខវេ ភិក្ខុនា មគ្គោ គន្តព្វោ ហោតិ តស្ស ឯវំ ហោតិ មគ្គោ ខោ មេ គន្តព្វោ ភវិស្សតិ មគ្គំ ខោ បន មេ គច្ឆន្តស្ស កាយោ កិលមិស្សតិ ហន្ទាហំ និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ ភិក្ខវេ តតិយំ កុសីតវត្ថុ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀតអំពើដែលភិក្ខុធ្វើរួចហើយក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ បានធ្វើអំពើ (នោះ) រួចហើយ តែកាលដែលអាត្មាអញ ធ្វើអំពើនោះ រាងកាយលំបាកហើយ បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ទេ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ២ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ផ្លូវដែលភិក្ខុគួរដើរទៅក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ផ្លូវដែលអាត្មាអញ គួរដើរទៅ គង់នឹងមាន តែថាកាលបើអាត្មាអញ ដើរទៅកាន់ផ្លូវ (នោះហើយ) រាងកាយនឹងលំបាក បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ទេ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៣ ។

៣៤១



បុន ចបរំ ភិក្ខវេ ភិក្ខុនា មគ្គោ គតោ ហោតិ តស្ស ឯវំ ហោតិ អហំ ខោ មគ្គំ អគមាសឹ មគ្គំ ខោ បន មេ គច្ឆតោ កាយោ កិលន្តោ ហន្ទាហំ និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ ភិក្ខវេ ចតុត្ថំ កុសីតវត្ថុ ។

បុន ចបរំ ភិក្ខវេ ភិក្ខុ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ ន លភតិ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ តស្ស ឯវំ ហោតិ អហំ ខោ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ នាលត្ថំ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ តស្ស មេ កាយោ កិលន្តោ អកម្មញ្ញោ ហន្ទាហំ និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារភតិ ។ បេ ។ ឥទំ ភិក្ខវេ បញ្ចមំ កុសីតវត្ថុ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ផ្លូវដែលភិក្ខុដើរទៅហើយក៏មាន ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ បានដើរទៅកាន់ផ្លូវ (នោះ) រួចហើយ តែថាកាលអាត្មាអញ ដើរទៅកាន់ផ្លូវ រាងកាយលំបាកហើយ បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្តងព្យាយាម ដើម្បីឲ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ទេ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៤ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបាននូវភោជនថោកទាប ឬថ្លៃថ្លា គ្រាន់តែ ១ ចម្អែតឡើយ ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលអាត្មាអញត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបានភោជនថោកទាប ឬ ថ្លៃថ្លា គ្រាន់តែ ១ ចម្អែតសោះ អាត្មាអញនោះមានរាងកាយលំបាកហើយ មិនគួរដល់សមណកម្ម បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្តងព្យាយាមឡើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៥ ។

បុន ចបរំ ភិក្ខវេ ភិក្ខុ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ លភតិ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ តស្ស ឯវំ ហោតិ អហំ ខោ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ អលត្ថំ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ តស្ស មេ កាយោ គរុកោ អកម្មញ្ញោ មាសាចិតំ មញ្ញេ ហន្ទាហំ និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារភតិ ។ បេ ។ ឥទំ ភិក្ខវេ ឆដ្ឋំ កុសីតវត្ថុ ។

បុន ចបរំ ភិក្ខវេ ភិក្ខុនោ ឧប្បន្នោ ហោតិ អប្បមត្តកោ អាពាធោ តស្ស ឯវំ ហោតិ ឧប្បន្នោ ខោ មេ អយំ អប្បមត្តកោ អាពាធោ អត្ថិ កប្បោ និបជ្ជិតុំ ហន្ទាហំ និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារភតិ ។ បេ ។ ឥទំ ភិក្ខវេ សត្តមំ កុសីតវត្ថុ ។

បុន ចបរំ ភិក្ខវេ ភិក្ខុ គិលានា វុដ្ឋិតោ ហោតិ អចិរវុដ្ឋិតោ គេលញ្ញា តស្ស ឯវំ ហោតិ អហំ ខោ គិលានា វុដ្ឋិតោ អចិរវុដ្ឋិតោ គេលញ្ញា តស្ស មេ កាយោ ទុព្វលោ

ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏បាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មម ១ ចម្អែត ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា កាលអាត្មាអញ ត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ហើយបានភោជនថោកទាប ឬថ្លៃថ្លា ល្មម ១ ចម្អែតដែរ អាត្មាអញនោះ មានកាយធ្ងន់ ដូចសណ្តែករាជមាសទទឹក មិនគួរដល់សមណកម្ម បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្តងព្យាយាមឡើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុ ទី ៦ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមានអាពាធតិចតួចកើតឡើង ភិក្ខុនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ មានអាពាធតិចតួចនេះកើតឡើង ហើយគួរតែដេកសិន បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្តងព្យាយាមឡើយ ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុ ទី ៧ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុចេញចាកជំងឺ ទើបតែស្បើយជំងឺថ្មីៗ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញចេញចាកជំងឺ ទើបតែស្បើយជំងឺថ្មីៗ អាត្មាអញនោះ មានរាងកាយ ថមថយកម្លាំង

អកម្មញ្ញោ ហន្ទាហំ និបជ្ជាមីតិ សោ និបជ្ជតិ ន វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកាតស្ស សច្ឆិកិរិយាយ ឥទំ ភិក្ខវេ អដ្ឋមំ កុសីតវត្ថុ ។ ឥមានិ ខោ ភិក្ខវេ អដ្ឋ កុសីតវត្ថូនីតិ ។

[៩៦] អដ្ឋិមានិ ភិក្ខវេ អារព្ភវត្ថូនិ ។ កតមានិ អដ្ឋ ។ ឥធ ភិក្ខវេ ភិក្ខុនា កម្មំ កាតព្វំ ហោតិ តស្ស ឯវំ ហោតិ កម្មំ ខោ មេ កាតព្វំ ភវិស្សតិ កម្មំ ខោ បន មេ ករោន្តេន ន សុករំ ពុទ្ធានំ សាសនំ មនសិកាតុំ ហន្ទាហំ បដិកច្ចេវ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកាតស្ស សច្ឆិកិរិយាយាតិ សោ វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកា-តស្ស សច្ឆិកិរិយាយ ឥទំ ភិក្ខវេ បឋមំ អារព្ភវត្ថុ ។

មិនគួរដល់សមណកម្ម បើដូច្នោះ អាត្មាអញដេកសិន ភិក្ខុនោះក៏ដេក មិនផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ទេ ម្នាលភិក្ខុទាំងឡាយ នេះជាកុសីតវត្ថុទី ៨ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងកុសីតវត្ថុ ៨ យ៉ាង ។

[៩៦] ម្នាលភិក្ខុទាំងឡាយ អារព្ភវត្ថុនេះ មាន ៨ យ៉ាង ។ ៨ យ៉ាង តើដូចម្តេចខ្លះ ។ ម្នាលភិក្ខុទាំងឡាយ អំពើដែលភិក្ខុក្នុងសាសនានេះ គួរធ្វើក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អំពើដែលអាត្មាអញ គួរធ្វើគង់នឹងមាន តែថា កាលអាត្មាអញធ្វើអំពើ (នោះហើយ) មិនងាយនឹងធ្វើពុទ្ធសាសនាឲ្យតាំងនៅក្នុងចិត្តបានឡើយ បើដូច្នោះអាត្មាអញ ផ្គងព្យាយាមមុនសិន ដើម្បីឲ្យដល់នូវគុណគឺឈាន វិបស្សនា មគ្គ ផលដែលអាត្មាអញមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណ ដែលអាត្មាអញមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យច្បាស់លាស់ ភិក្ខុនោះ ក៏ផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ១ ។

បុន ចបរំ ភិក្ខវេ ភិក្ខុនា កម្មំ កតំ ហោតិ តស្ស ឯវំ ហោតិ អហំ ខោ កម្មំ អកាសឹ កម្មំ ខោ បនាហំ ករោន្តោ នាសក្ខឹ ពុទ្ធានំ សាសនំ មនសិកាតុំ ហន្ទាហំ វិរិយំ អារភាមិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយាតិ សោ វិរិយំ អារភតិ ។ បេ ។ ឥទំ ភិក្ខវេ ទុតិយំ អារព្ភវត្ថុ ។

បុន ចបរំ ភិក្ខវេ ភិក្ខុនា មគ្គោ គន្តព្វោ ហោតិ តស្ស ឯវំ ហោតិ មគ្គោ ខោ មេ គន្តព្វោ ភវិស្សតិ មគ្គំ ខោ បន មេ គច្ឆន្តេន ន សុករំ ពុទ្ធានំ សាសនំ មនសិកាតុំ ហន្ទាហំ វិរិយំ អារភាមិ ។ បេ ។ ឥទំ ភិក្ខវេ តតិយំ អារព្ភវត្ថុ ។

បុន ចបរំ ភិក្ខវេ ភិក្ខុនា មគ្គោ គតោ ហោតិ តស្ស ឯវំ ហោតិ អហំ ខោ មគ្គំ អគមាសឹ

ម្នាលភិក្ខុទាំងឡាយ មួយទៀត អំពើដែលភិក្ខុធ្វើរួចហើយក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះ យ៉ាងនេះថា អាត្មាអញ បានធ្វើអំពើរួចហើយ តែថា កាលអាត្មាអញ ធ្វើអំពើ (នោះ) មិនអាចនឹងធ្វើពុទ្ធសាសនា ឲ្យតាំងនៅក្នុងចិត្តបានឡើយ បើដូច្នោះ អាត្មាអញផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណ ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណ ដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលអាត្មាអញ មិនទាន់បានធ្វើឲ្យច្បាស់លាស់ ភិក្ខុនោះ ក៏ផ្គងព្យាយាម ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ២ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ផ្លូវដែលភិក្ខុ គួរដើរទៅក៏មាន ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា ផ្លូវដែលអាត្មាអញ គួរដើរទៅគង់នឹងមាន តែថាអាត្មាអញដើរទៅកាន់ផ្លូវ (នោះ) មិនងាយនឹងធ្វើពុទ្ធសាសនា ឲ្យតាំងនៅក្នុងចិត្តបានឡើយ បើដូច្នោះ អាត្មាអញផ្គងព្យាយាម ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៣ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ផ្លូវដែលភិក្ខុដើរទៅហើយក៏មានភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ បានដើរទៅកាន់ផ្លូវហើយ

មគ្គំ ខោ បនាហំ គច្ឆន្តោ នាសក្ខឹ ពុទ្ធានំ សាសនំ មនសិកាតុំ ហន្ទាហំ វីរិយំ អារភាមិ ។ បេ ។ ឥទំ ភិក្ខវេ ចតុត្ថំ អារព្ភវត្ថុ ។

បុន ចបរំ ភិក្ខវេ ភិក្ខុ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ ន លភតិ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ តស្ស ឯវំ ហោតិ អហំ ខោ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ នាលត្ថំ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ តស្ស មេ កាយោ លហុកោ កម្មញ្ញោ ហន្ទាហំ វីរិយំ អារភាមិ ។ បេ ។ ឥទំ ភិក្ខវេ បញ្ចមំ អារព្ភវត្ថុ ។

បុន ចបរំ ភិក្ខវេ ភិក្ខុ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ លភតិ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ តស្ស ឯវំ ហោតិ អហំ ខោ គាមំ វា និគមំ វា បិណ្ឌាយ ចរន្តោ អលត្ថំ លូខស្ស វា បណីតស្ស វា ភោជនស្ស យាវទត្ថំ បារិបូរឹ

តែថាកាលណា អាត្មាអញដើរទៅកាន់ផ្លូវ មិនអាចធ្វើពុទ្ធសាសនាឲ្យតាំងនៅក្នុងចិត្តបានឡើយ បើដូច្នោះ អាត្មាអញផ្គងព្យាយាម ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៤ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មម ១ ចម្អែតទេ ភិក្ខុនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា កាលអាត្មាអញត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏មិនបាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មម ១ ចម្អែតឡើយ អាត្មាអញនោះ មានរាងកាយស្រាលគួរដល់សមណកម្ម បើដូច្នោះ អាត្មាអញ ផ្គងព្យាយាម ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៥ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត កាលភិក្ខុត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏បាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មម ១ ចម្អែត ភិក្ខុនោះមានសេចក្ដីត្រិះរិះយ៉ាងនេះថា កាលអាត្មាអញ ត្រាច់ទៅកាន់ស្រុក ឬនិគម ដើម្បីបិណ្ឌបាត ក៏បាននូវភោជនថោកទាប ឬថ្លៃថ្លា ល្មម ១ ចម្អែតហើយ

តស្ស មេ កាយោ លហុកោ កម្មញ្ញោ ហន្ទាហំ វីរិយំ អារភាមិ ។ បេ ។ ឥទំ ភិក្ខវេ ឆដ្ឋំ អារព្ភវត្ថុ ។

បុន ចបរំ ភិក្ខវេ ភិក្ខុនោ ឧប្បន្នោ ហោតិ អប្បមត្តកោ អាពាធោ តស្ស ឯវំ ហោតិ ឧប្បន្នោ ខោ មេ អយំ អប្បមត្តកោ អាពាធោ ឋានំ ខោ បនេតំ វិជ្ជតិ យំ មេ អាពាធោ បវឌ្ឍេយ្យ ហន្ទាហំ បដិ-កាច្ចេវ វីរិយំ អារភាមិ ។ បេ ។ ឥទំ ភិក្ខវេ សត្តមំ អារព្ភវត្ថុ ។

បុន ចបរំ ភិក្ខវេ ភិក្ខុ គិលានា វុដ្ឋិតោ ហោតិ អចិរវុដ្ឋិតោ គេលញ្ញា តស្ស ឯវំ ហោតិ អហំ ខោ គិលានា វុដ្ឋិតោ អចិរវុដ្ឋិតោ គេលញ្ញា ឋានំ ខោ បនេតំ វិជ្ជតិ យំ មេ អាពាធោ បច្ចុទាវត្តេយ្យ ហន្ទាហំ បដិកាច្ចេវ វីរិយំ អារភាមិ អប្បត្តស្ស បត្តិយា

អាត្មាអញនោះ មានរាងកាយស្រាល គួរដល់សមណកម្ម បើដូច្នោះ អាត្មាអញ ផ្គងព្យាយាម ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៦ ។

ម្នាលភិក្ខុទាំងឡាយ មួយទៀត ភិក្ខុមានអាពាធតិចតួចកើតឡើង ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញ កើតអាពាធតិចតួចនេះហើយ អាពាធចម្រើនដល់អាត្មាអញ ដោយហេតុណា ហេតុនុ៎ះ ជាហេតុតែងមាន ជាធម្មតាទេ បើដូច្នោះ អាត្មាអញ ផ្គងព្យាយាមឲ្យបានមុនសិន ។ បេ ។ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៧ ។

ម្នាលភិក្ខុទាំងឡាយ មួយវិញទៀត ភិក្ខុចេញចាកជំងឺ ទើបតែស្បើយជំងឺថ្មីៗ ភិក្ខុនោះមានសេចក្តីត្រិះរិះយ៉ាងនេះថា អាត្មាអញចេញចាកជំងឺ ទើបតែស្បើយជំងឺថ្មីៗ អាពាធរបស់អាត្មាអញ រើឡើងវិញ ដោយហេតុណា ហេតុនុ៎ះ ជាហេតុតែងមាន ជាធម្មតាទេ បើដូច្នោះ អាត្មាអញផ្គងព្យាយាមឲ្យបានមុន ដើម្បីឲ្យដល់នូវគុណ ដែលអាត្មាអញមិនទាន់បានដល់ ដើម្បីឲ្យដឹងនូវគុណ ដែលអាត្មាអញមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណ ដែលអាត្មាអញមិនទាន់បានធ្វើឲ្យច្បាស់លាស់សិន ភិក្ខុនោះក៏ផ្គងព្យាយាម ដើម្បីឲ្យដល់នូវគុណ ដែលខ្លួនមិនទាន់បានដល់

៣៤៧



អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយាតិ សោ វីរិយំ អារភតិ អប្បត្តស្ស បត្តិយា អនធិគតស្ស អធិគមាយ អសច្ឆិកតស្ស សច្ឆិកិរិយាយ ឥទំ ភិក្ខវេ អដ្ឋមំ អារព្ភវត្ថុ ។ ឥមានិ ខោ ភិក្ខវេ អដ្ឋ អារព្ភវត្ថូនីតិ ។

យមកវគ្គោ  តតិយោ ។

## តត្រុទ្ទានំ

ទ្វេ បដិបទា អបរេ[១] ឥច្ឆា លច្ឆា[២] បរិហានំ
កុសីតំ អារព្ភវត្ថូនីតិ ។

១ ឱ. ម. ទ្វេ សទ្ធា ទ្វេ មរណស្សតិ ទ្វេ សម្បទា អថាបរេ ។ ២ ឥច្ឆា អលំ ។

ដើម្បីឲ្យដឹងនូវគុណដែលខ្លួនមិនទាន់បានដឹង ដើម្បីធ្វើឲ្យច្បាស់លាស់នូវគុណដែលខ្លួនមិនទាន់បានធ្វើឲ្យច្បាស់លាស់ ម្នាលភិក្ខុទាំងឡាយ នេះជាអារព្ភវត្ថុទី ៨ ។ ម្នាលភិក្ខុទាំងឡាយ នេះឯងអារព្ភវត្ថុទាំង ៨ យ៉ាង ។

ចប់ យមកវគ្គទី ៣ ។

## ឧទ្ទានក្នុងយមកវគ្គនោះគឺ

និយាយពីភិក្ខុបរិបូរ ដោយអង្គពីរលើក សម្បទា ១ ភិក្ខុចម្រើនមរណស្សតិដទៃទៀត ១ សេចក្តីប្រាថ្នាលាភ ១ គួរដល់ខ្លួននិងអ្នកដទៃ ១ សេចក្តីសាបសូន្យ របស់សេក្ខភិក្ខុ ១ កុសីតវត្ថុ ១ អារព្ភវត្ថុ ១ ។

---

# សតិវគ្គោ

[៩៧] សតិសម្បជញ្ញេ ភិក្ខវេ អសតិ សតិសម្បជញ្ញវិបន្នស្ស ហតូបនិសំ ហោតិ ហិរោត្តប្បំ ហិរោត្តប្បេ អសតិ ហិរោត្តប្បវិបន្នស្ស ហតូបនិសោ ហោតិ ឥន្ទ្រិយសំវរោ ឥន្ទ្រិយសំវរេ អសតិ ឥន្ទ្រិយសំវរវិបន្នស្ស ហតូបនិសំ ហោតិ សីលំ សីលេ អសតិ សីលវិបន្នស្ស ហតូបនិសោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ អសតិ សម្មាសមាធិវិបន្នស្ស ហតូបនិសំ ហោតិ យថាភូតញ្ញាណទស្សនំ យថាភូតញ្ញាណទស្សនេ អសតិ យថាភូតញ្ញាណទស្សនវិបន្នស្ស ហតូបនិសោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ អសតិ និព្វិទាវិរាគវិបន្នស្ស ហតូបនិសំ ហោតិ វិមុត្តិញ្ញាណទស្សនំ ។ សេយ្យថាបិ ភិក្ខវេ រុក្ខោ សាខាបលាសវិបន្នោ តស្ស បបដិកាបិ ន បារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ ន បារិបូរឹ គច្ឆតិ

# សតិវគ្គ

[៩៧] ម្នាលភិក្ខុទាំងឡាយ កាលបើសតិនិងសម្បជញ្ញៈ មិនមាន ហិរិនិងឱត្តប្បៈ របស់បុគ្គលវិបត្តិចាកសតិនិងសម្បជញ្ញៈ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យ កាលបើហិរិនិងឱត្តប្បៈ មិនមាន ឥន្ទ្រិយសំវរៈ របស់បុគ្គលវិបត្តិចាកហិរិនិងឱត្តប្បៈ ឈ្មោះថា មានឧបនិស្ស័យ សាបសូន្យ កាលបើឥន្ទ្រិយសំវរៈ មិនមាន សីលរបស់បុគ្គលវិបត្តិចាកឥន្ទ្រិយសំវរៈ ឈ្មោះថាមានឧបនិស្ស័យសាបសូន្យ កាលបើសីល មិនមាន សម្មាសមាធិ របស់បុគ្គលវិបត្តិចាកសីល ឈ្មោះថាមានឧបនិស្ស័យសាបសូន្យ កាលបើ សម្មាសមាធិមិនមាន យថាភូតញ្ញាណទស្សនៈ របស់បុគ្គលវិបត្តិចាក សម្មាសមាធិ ឈ្មោះថា មានឧបនិស្ស័យសាបសូន្យ កាលបើយថាភូតញ្ញាណទស្សនៈ មិនមាន និព្វិទាវិរាគៈ របស់បុគ្គលវិបត្តិចាកយថាភូតញ្ញាណទស្សនៈ ឈ្មោះថាមានឧបនិស្ស័យសាបសូន្យ កាលបើនិព្វិទាវិរាគៈមិនមាន វិមុត្តិញ្ញាណទស្សនៈ របស់បុគ្គលវិបត្តិចាកនិព្វិទាវិរាគៈឈ្មោះថា មានឧបនិស្ស័យសាបសូន្យ ។ ម្នាលភិក្ខុទាំងឡាយ ដើមឈើដែលមិនមានមែក និងស្លឹកហើយ ក្រមរឈើនោះក្តី មិនដល់នូវការពេញលេញទេ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី ក៏មិនដល់នូវការពេញលេញ មានឧបមាយ៉ាងណាមិញ

ឯវមេវ ខោ ភិក្ខវេ សតិសម្បជញ្ញេ អសតិ សតិសម្ប-ជញ្ញវិបន្នស្ស ហតូបនិសំ ហោតិ ហិរោត្តប្បំ ហិរោត្តប្បេ អសតិ ហិរោត្តប្បវិបន្នស្ស ហតូបនិសំ ហោតិ ។ បេ ។ វិមុត្តិញ្ញាណទស្សនំ ។ សតិសម្បជញ្ញេ ភិក្ខវេ សតិ សតិសម្បជញ្ញសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ ហិរោត្តប្បំ ហិរោត្តប្បេ សតិ ហិរោត្តប្បសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ ឥន្ទ្រិយសំវរោ ឥន្ទ្រិយសំវរេ សតិ ឥន្ទ្រិយសំវរសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ សីលំ សីលេ សតិ សីលសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ សម្មាសមាធិ សម្មាសមាធិម្ហិ សតិ សម្មាសមាធិ-សម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ យថាភូតញ្ញាណ-ទស្សនំ យថាភូតញ្ញាណទស្សនេ សតិ យថាភូត-ញ្ញាណទស្សនសម្បន្នស្ស ឧបនិសសម្បន្នោ ហោតិ និព្វិទាវិរាគោ និព្វិទាវិរាគេ សតិ និព្វិទាវិរាគសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ វិមុត្តិញ្ញាណទស្សនំ ។

ម្នាលភិក្ខុទាំងឡាយ កាលបើសតិនិងសម្បជញ្ញៈ មិនមាន ហិរិនិងឱត្តប្បៈ របស់បុគ្គលវិបត្តិចាកសតិនិងសម្បជញ្ញៈ ឈ្មោះថាមានឧបនិស្ស័យសាបសូន្យ កាលបើហិរិនិងឱត្តប្បៈ មិនមាន (ឥន្ទ្រិយសំវរៈ) របស់បុគ្គលវិបត្តិចាកហិរិនិងឱត្តប្បៈ ឈ្មោះថា មានឧបនិស្ស័យ សាបសូន្យ ។ បេ ។ វិមុត្តិញ្ញាណទស្សនៈ មានឧបមេយ្យយ៉ាងនោះដែរ ។ ម្នាលភិក្ខុទាំង-ឡាយ កាលបើសតិនិងសម្បជញ្ញៈ មាន ហិរិនិងឱត្តប្បៈ របស់បុគ្គលបរិ-បូណ៌ដោយសតិនិងសម្បជញ្ញៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើហិរិនិងឱត្តប្បៈ មាន ឥន្ទ្រិយសំវរៈ របស់បុគ្គលបរិបូណ៌ដោយហិរិនិងឱត្តប្បៈ ឈ្មោះថាមានឧបនិស្ស័យបរិបូណ៌ កាលបើឥន្ទ្រិយសំវរៈមាន សីលរបស់បុគ្គលបរិបូណ៌ដោយឥន្ទ្រិយសំវរៈ ឈ្មោះថាមានឧបនិស្ស័យបរិបូណ៌ កាលបើសីលមាន សម្មាសមាធិរបស់បុគ្គលបរិបូណ៌ដោយសីល ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើសម្មាសមាធិមាន យថាភូតញ្ញាណ-ទស្សនៈរបស់បុគ្គលបរិបូណ៌ដោយសម្មាសមាធិ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើយថាភូតញ្ញាណទស្សនៈមាន និព្វិទាវិរាគៈ របស់បុគ្គលបរិបូណ៌ដោយយថាភូតញ្ញាណទស្សនៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ កាលបើនិព្វិទាវិរាគៈ មាន វិមុត្តិញ្ញាណទស្សនៈ របស់បុគ្គលបរិបូណ៌ដោយនិព្វិទាវិរាគៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ ។

សេយ្យថាបិ ភិក្ខវេ រុក្ខោ សាខាបលាសសម្បន្នោ តស្ស បបដិកាបិ បារិបូរឹ គច្ឆតិ តចោបិ ផេគ្គុបិ សារោបិ បារិបូរឹ គច្ឆតិ ឯវមេវ ខោ ភិក្ខវេ សតិសម្បជញ្ញេ សតិ សតិសម្បជញ្ញសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ ហិរោត្តប្បំ ហិរោត្តប្បេ សតិ ហិរោត្តប្បសម្បន្នស្ស ឧបនិសសម្បន្នំ ហោតិ ។ បេ ។ វិមុត្តិញ្ញាណទស្សនន្តិ ។

[៩៨] អថខោ អាយស្មា បុណ្ណិយោ យេន ភគវា តេនុបសង្កមិ ឧបសង្កមិត្វា ភគវន្តំ អភិវាទេត្វា ឯកមន្តំ និសីទិ ។ ឯកមន្តំ និសិន្នោ ខោ អាយស្មា បុណ្ណិយោ ភគវន្តំ ឯតទវោច កោ នុ ខោ ភន្តេ ហេតុ កោ បច្ចយោ យេន អប្បេកទា តថាគតំ ធម្មទេសនា បដិ-ភាតិ អប្បេកទា ន បដិភាតីតិ ។ សទ្ធោ បុណ្ណិយ ភិក្ខុ ហោតិ នោ ឧបសង្កមិតា នេវ តាវ តថាគតំ ធម្មទេសនា បដិភាតិ យតោ ច ខោ បុណ្ណិយ ភិក្ខុ សទ្ធោ ច ហោតិ ឧបសង្កមិតា ច ឯវំ តថាគតំ ធម្មទេសនា បដិភាតិ

ម្នាលភិក្ខុទាំងឡាយ ដើមឈើ ដែលបរិបូណ៌ ដោយមែកនិងស្លឹកហើយ ក្រមរឈើនោះ ក៏ដល់នូវការពេញលេញ សម្បកក្តី ស្រាយក្តី ខ្លឹមក្តី (របស់ឈើនោះ) ក៏ដល់នូវការពេញលេញ មានឧបមាយ៉ាងណាមិញ ម្នាលភិក្ខុទាំងឡាយ កាលបើសតិនិងសម្បជញ្ញៈ មាន ហិរិនិងឱត្តប្បៈ របស់បុគ្គលបរិបូណ៌ដោយសតិនិងសម្បជញ្ញៈ ឈ្មោះថាមានឧបនិស្ស័យបរិបូណ៌ កាលបើហិរិនិងឱត្តប្បៈ មាន (ឥន្ទ្រិយសំវរៈ) របស់បុគ្គលបរិ-បូណ៌ដោយហិរិនិងឱត្តប្បៈ ឈ្មោះថា មានឧបនិស្ស័យបរិបូណ៌ ។ បេ ។ វិមុត្តិញ្ញាណទស្សនៈ មានឧបមេយ្យយ៉ាងនោះដែរ ។

[៩៨] គ្រានោះ ព្រះបុណ្ណិយៈដ៏មានអាយុ ចូលទៅគាល់ព្រះដ៏មានព្រះភាគ លុះចូលទៅដល់ ក្រាបថ្វាយបង្គំព្រះដ៏មានព្រះភាគ ហើយក៏អង្គុយក្នុងទីសមគួរ ។ លុះព្រះបុណ្ណិយៈដ៏មានអាយុ អង្គុយក្នុងទីសមគួរហើយ ទើបក្រាបបង្គំទូលសួរព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះអង្គដ៏ចម្រើន ហេតុអ្វី បច្ច័យអ្វី បានជាក្នុងកាលខ្លះ ព្រះតថាគតទ្រង់សម្តែងធម្មទេសនា ក្នុងកាលខ្លះ ក៏មិនសម្តែង ។ ព្រះអង្គត្រាស់តបថា ម្នាលបុណ្ណិយៈ ភិក្ខុមានសទ្ធាហើយ តែមិនចូលមករកទេ តថាគតក៏មិនទាន់សម្តែងធម្មទេសនា ម្នាលបុណ្ណិយៈ កាលបើភិក្ខុមានសទ្ធាផង បានចូលមករកផង យ៉ាងនេះ ទើបតថាគតសម្តែងធម្មទេសនា

សទ្ធោ ច បុណ្ណិយ ភិក្ខុ ហោតិ ឧបសង្កមិតា ច នោ បយិរុបាសិតា ។ បេ ។ បយិរុបាសិតា ច នោ បរិបុច្ឆិតា បរិបុច្ឆិតា ច នោ ឱហិតសោតោ ធម្មំ សុណាតិ ឱហិតសោតោ ច ធម្មំ សុណាតិ នោ សុត្វា ធារេតិ សុត្វា ច ធម្មំ ធារេតិ នោ ធាតានញ្ច ធម្មានំ អត្ថំ ឧបបរិក្ខតិ ធាតានញ្ច ធម្មានំ អត្ថំ ឧបបរិក្ខតិ នោ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ហោតិ នេវ តាវ តថាគតំ ធម្មទេសនា បដិភាតិ ។ យតោ ច ខោ បុណ្ណិយ ភិក្ខុ សទ្ធោ ច ហោតិ ឧបសង្កមិតា ច បយិរុបាសិតា ច បរិបុច្ឆិតា ច ឱហិតសោតោ ច ធម្មំ សុណាតិ សុត្វា ច ធម្មំ ធារេតិ ធាតានញ្ច ធម្មានំ អត្ថំ ឧបបរិក្ខតិ អត្ថមញ្ញាយ ធម្មមញ្ញាយ ធម្មានុធម្មប្បដិបន្នោ ច ហោតិ ឯវំ តថាគតំ ធម្មទេសនា បដិភាតិ ។ ឥមេហិ ខោ បុណ្ណិយ[១] ធម្មេហិ សមន្នាគតោ ឯកន្តប្បដិភាណំ តថាគតំ ធម្មទេសនា ហោតីតិ ។

---

១ ម. ឯត្ថន្តរេ អដ្ឋហីតិ អយំ បាឋោ ទិស្សតិ ។

ម្នាលបុណ្ណិយៈ ភិក្ខុមានសទ្ធាផង បានចូលមករកផង តែមិនបាន ចូលមកអង្គុយជិត ។ បេ ។ បានចូលមកអង្គុយជិតហើយ តែមិនបាន សាកសួរ បានសាកសួរហើយ តែមិនបានផ្ទៀងត្រចៀកស្ដាប់ធម៌ ផ្ទៀងត្រចៀកស្ដាប់ហើយ តែមិនស្ដាប់ឲ្យចាំធម៌ ស្ដាប់ចាំធម៌ហើយ តែមិនពិចារណានូវសេចក្ដីនៃធម៌ ដែលខ្លួនចង់ចាំហើយ ពិចារណានូវសេចក្ដីនៃធម៌ដែលខ្លួនចង់ចាំហើយ តែមិនដឹងនូវអត្ថមិនដឹងនូវធម៌ ហើយប្រតិបត្តិនូវធម៌ដ៏សមគួរដល់ធម៌ទេ តថាគត ក៏មិនសម្ដែងធម្មទេសនានោះឡើយ ។ ម្នាលបុណ្ណិយៈ កាលបើ ភិក្ខុមានសទ្ធាផង បានចូលមករកផង បានចូលមកអង្គុយជិតផង បានសាកសួរផង បានផ្ទៀងត្រចៀងស្ដាប់ធម៌ផង ស្ដាប់ឲ្យចាំធម៌ផង ពិចារណានូវសេចក្ដីនៃធម៌ដែលខ្លួនចង់ចាំផង ដឹងនូវអត្ថដឹងនូវធម៌ហើយ ប្រតិបត្តិធម៌ដ៏សមគួរដល់ធម៌ផង យ៉ាងនេះទើបតថាគតសម្ដែងធម្មទេសនា ។ ម្នាលបុណ្ណិយៈ ភិក្ខុប្រកបដោយធម៌ (៨ យ៉ាង) នេះឯង ទើបតថាគត សម្ដែងនូវធម្មទេសនា យ៉ាងច្បាស់លាស់ ។

[៩៩] សចេ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ កឹមូលកា អាវុសោ សព្វេ ធម្មា កឹសម្ភវា សព្វេ ធម្មា កឹសមុទយា សព្វេ ធម្មា កឹសមោសរណា សព្វេ ធម្មា កឹបមុខា សព្វេ ធម្មា កឹអាធិបតេយ្យា សព្វេ ធម្មា កឹឧត្តរា សព្វេ ធម្មា កឹសារា សព្វេ ធម្មាតិ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ កិន្តិ ព្យាករេយ្យាថាតិ ។ ភគវំមូលកា នោ ភន្តេ ធម្មា ភគវំនេត្តិកា ភគវំបដិសរណា សាធុ ភន្តេ ភគវន្តំយេវ បដិភាតុ ឯតស្ស ភាសិតស្ស អត្ថោ ភគវតោ សុត្វា ភិក្ខូ ធារេស្សន្តីតិ ។ តេនហិ ភិក្ខវេ[១] សុណាថ សាធុកំ មនសិករោថ ភាសិស្សាមីតិ ។ ឯវំ ភន្តេតិ ខោ តេ ភិក្ខូ ភគវតោ បច្ចស្សោសុំ ។ ភគវា ឯតទវោច សចេ ភិក្ខវេ អញ្ញតិត្ថិយា បរិព្វាជកា ឯវំ បុច្ឆេយ្យុំ កឹមូលកា អាវុសោ សព្វេ ធម្មា កឹសម្ភវា សព្វេ ធម្មា កឹសមុទយា សព្វេ ធម្មា កឹសមោសរណា សព្វេ ធម្មា កឹបមុខា

១ ម. ឯត្ថន្តរេ ទេសិស្សាមិ តន្តិ អយំ បាឋោ ទិស្សតិ ។

[៩៩] ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជក ជាអន្យតិរ្ថិយសួរយ៉ាងនេះថា ម្នាលអាវុសោ ធម៌ទាំងអស់គឺបញ្ចក្ខន្ធ មានអ្វីជាមូល ធម៌ទាំងអស់កើតអំពីអ្វី ធម៌ទាំងអស់ប្រជុំកើតអំពីអ្វី ធម៌ទាំងអស់ប្រជុំចុះក្នុងអ្វី ធម៌ទាំងអស់មានអ្វីជាប្រធាន ធម៌ទាំងអស់មានអ្វីជាអធិបតី ធម៌ទាំងអស់មានអ្វីជាវិសេស ធម៌ទាំងអស់មានអ្វីជាខ្លឹម ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជកជាអន្យតិរ្ថិយ សួរយ៉ាងនេះ តើអ្នកទាំងឡាយ គប្បីដោះស្រាយដូចម្តេចដល់ពួកបរិព្វាជក ជាអន្យតិរ្ថិយនោះ ។ បពិត្រព្រះអង្គដ៏ចម្រើន ធម៌ទាំងឡាយមានព្រះដ៏មានព្រះភាគជាមូល មានព្រះដ៏មានព្រះភាគជាអ្នកណែនាំ មានព្រះដ៏មានព្រះភាគជាទីពឹង របស់យើងខ្ញុំព្រះអង្គស្រាប់ហើយ បពិត្រព្រះអង្គដ៏ចម្រើន សូមព្រះដ៏មានព្រះភាគ សម្តែងនូវសេចក្តីនៃភាសិតនេះឲ្យទាន ពួកភិក្ខុបានស្តាប់ភាសិតរបស់ព្រះអង្គហើយ នឹងចងចាំទុក ។ ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ ចូរប្រុងស្តាប់ ចូរធ្វើទុកក្នុងចិត្តដោយប្រពៃចុះ តថាគតនឹងសម្តែង ។ ភិក្ខុទាំងនោះ បានទទួលតបថា ព្រះករុណាព្រះអង្គ ។ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ បើពួកបរិព្វាជក ជាអន្យតិរ្ថិយ សួរយ៉ាងនេះថា ម្នាលអាវុសោ ធម៌ទាំងអស់មានអ្វីជាមូល ធម៌ទាំងអស់កើតអំពីអ្វី ធម៌ទាំងអស់ប្រជុំកើតអំពីអ្វី ធម៌ទាំងអស់ប្រជុំចុះក្នុងអ្វី ធម៌ទាំងអស់មានអ្វីជាប្រធាន

សព្វេ ធម្មា កឹអាធិបតេយ្យា សព្វេ ធម្មា កឹឧត្តរា សព្វេ ធម្មា កឹសារា សព្វេ ធម្មាតិ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថ ឆន្ទមូលកា អាវុសោ សព្វេ ធម្មា មនសិការសម្ភវា សព្វេ ធម្មា ផស្សសមុទយា សព្វេ ធម្មា វេទនាសមោសរណា សព្វេ ធម្មា សមាធិប្បមុខា សព្វេ ធម្មា សតាធិបតេយ្យា សព្វេ ធម្មា បញ្ញុត្តរា សព្វេ ធម្មា វិមុត្តិសារា សព្វេ ធម្មាតិ ឯវំ បុដ្ឋា តុម្ហេ ភិក្ខវេ តេសំ អញ្ញតិត្ថិយានំ បរិព្វាជកានំ ឯវំ ព្យាករេយ្យាថាតិ ។

[១០០] អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតោ មហាចោរោ ខិប្បំ បរិយាបជ្ជតិ ន ចិរដ្ឋិតិកោ ហោតិ ។ កតមេហិ អដ្ឋហិ ។ អប្បហរន្តស្ស បហរតិ អនវសេសំ អាទិយតិ ឥត្ថឹ ហរតិ[១] កុមារឹ ទូសេតិ បព្វជិតំ វិលុម្បតិ រាជកោសំ វិលុម្បតិ អច្ចាសន្នេ កម្មំ ករោតិ ន ច និធានកុសលោ ហោតិ ។

១ ម. ហនតិ ។

ធម៌ទាំងអស់មានអ្វីជាអធិបតី ធម៌ទាំងអស់មានអ្វីជាវិសេស ធម៌ទាំងអស់មានអ្វីជាខ្លឹម ម្នាលភិក្ខុទាំងឡាយ កាលបើ ពួកបរិព្វាជកអន្យតិរ្ថិយសួរយ៉ាងនេះ អ្នកទាំងឡាយគប្បីដោះស្រាយដល់បរិព្វាជកអន្យតិរ្ថិយទាំងនោះយ៉ាងនេះថា ម្នាលអាវុសោ ធម៌ទាំងអស់មានឆន្ទៈជាមូល ធម៌ទាំងអស់កើតអំពីមនសិការៈ ធម៌ទាំងអស់ប្រជុំកើតអំពីផស្សៈ ធម៌ទាំងអស់ប្រជុំចុះក្នុងវេទនា ធម៌ទាំងអស់មានសមាធិជាប្រធាន ធម៌ទាំងអស់មានសតិជាអធិបតី ធម៌ទាំងអស់មានបញ្ញាជាវិសេស ធម៌ទាំងអស់មានវិមុត្តិជាខ្លឹម ម្នាលភិក្ខុទាំងឡាយ កាលបើពួកបរិព្វាជកអន្យតិរ្ថិយ សួរយ៉ាងនេះហើយ អ្នកទាំងឡាយ គប្បីដោះស្រាយដល់បរិព្វាជកអន្យតិរ្ថិយទាំងនោះ យ៉ាងនេះឯង ។

[១០០] ម្នាលភិក្ខុទាំងឡាយ មហាចោរប្រកបដោយអង្គ ៨ ប្រការរមែងវិនាសឆាប់ មិនតាំងនៅយូរឡើយ ។ ប្រកបដោយអង្គ ៨ ប្រការ តើដូចម្តេច ។ គឺប្រហារនូវបុគ្គលដែលមិនប្រហារតប[១] ១ កាន់យកទ្រព្យរបស់គេមិនឲ្យមានសេសសល់ ១ នាំយកស្ត្រី ១ ប្រទូស្តនឹងក្មេងស្ត្រី ១ ប្លន់បព្វជិត ១ ប្លន់ព្រះរាជឃ្លាំង ១ ធ្វើចោរកម្មក្នុងទីជិត (ស្រុកឬនិគមរាជធានីជាដើម) ១ ជាអ្នកមិនឈ្លាសវៃ ក្នុងការកប់ទ្រព្យទុក (ក្នុងទក្ខិណេយ្យបុគ្គល) ១ ។

១-បុគ្គលដែលមិនចងពៀរនឹងខ្លួន សម្បូណ៌ដោយគុណធម៌ មនុស្សចាស់ កូនក្មេងតូច ។ អដ្ឋកថា ។

ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតោ មហា-
ចោរោ ខិប្បំ បរិយាបជ្ជតិ ន ចិរដ្ឋិតិកោ ហោតិ ។

[១០១] អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតោ
មហាចោរោ ន ខិប្បំ បរិយាបជ្ជតិ ចិរដ្ឋិតិកោ ហោតិ ។
កតមេហិ អដ្ឋហិ ។ ន អប្បហរន្តស្ស បហរតិ ន អន-
វសេសំ អាទិយតិ ន ឥត្ថឹ ហនតិ ន កុមារឹ ទូសេតិ ន
បព្វជិតំ វិលុម្បតិ ន រាជកោសំ វិលុម្បតិ ន អច្ចាសន្នេ
កម្មំ ករោតិ ន ច សន្និធិការកោ ហោតិ ។ ឥមេហិ
ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតោ មហាចោរោ
ន ខិប្បំ បរិយាបជ្ជតិ ចិរដ្ឋិតិកោ ហោតីតិ ។

[១០២] សមណោតិ ភិក្ខវេ តថាគតស្សេតំ អធិ-
វចនំ អរហតោ សម្មាសម្ពុទ្ធស្ស ព្រាហ្មណោតិ ភិក្ខវេ
តថាគតស្សេតំ អធិវចនំ អរហតោ សម្មាសម្ពុ-
ទ្ធស្ស វេទគូតិ ភិក្ខវេ តថាគតស្សេតំ អធិវចនំ
អរហតោ សម្មាសម្ពុទ្ធស្ស ភិសក្កោតិ ភិក្ខវេ
តថាគតស្សេតំ អធិវចនំ អរហតោ សម្មាសម្ពុទ្ធស្ស

ម្នាលភិក្ខុទាំងឡាយ មហាចោរប្រកបដោយអង្គ ៨ ប្រការនេះឯង រមែងវិនាសឆាប់ មិនតាំងនៅយូរឡើយ ។

[១០១] ម្នាលភិក្ខុទាំងឡាយ មហាចោរ ប្រកបដោយអង្គ ៨ ប្រការ រមែងមិនវិនាសឆាប់ ជាអ្នកតាំងនៅយូរបាន ។ ប្រកបដោយអង្គ ៨ ប្រការ តើដូចម្ដេចខ្លះ ។ គឺមិនប្រហារនូវបុគ្គល ដែលមិនប្រហារតប ១ មិនកាន់យកទ្រព្យរបស់គេមិនឲ្យមានសេសសល់ ១ មិននាំយកស្ត្រី ១ មិនប្រទូស្តក្មេងស្រី ១ មិនប្លន់បព្វជិត ១ មិនប្លន់ព្រះរាជឃ្លាំង ១ មិនធ្វើចោរកម្មក្នុងទីជិត ១ ជាអ្នកឈ្លាសវៃ ក្នុងការកប់ទ្រព្យទុក (ក្នុងទក្ខិ-ណេយ្យបុគ្គល) ១ ។ ម្នាលភិក្ខុទាំងឡាយ មហាចោរ ប្រកបដោយអង្គ ៨ ប្រការនេះឯង រមែងមិនវិនាសឆាប់ ជាអ្នកតាំងនៅយូរបាន ។

[១០២] ម្នាលភិក្ខុទាំងឡាយ ពាក្យថា សមណៈ (អ្នកស្ងប់រម្ងាប់) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ព្រាហ្មណ៍ (អ្នកបន្សាត់បង់នូវបាប) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា វេទគូ (អ្នកចេះចប់ត្រៃវេទ) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ភិសក្កៈ (គ្រូពេទ្យវះកាត់) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ

បណ្ណាសកាសង្គហិតោ សតិវគ្គោ

ជិម្ហលោតិ ភិក្ខវេ តថាគតស្សេតំ អធិវចនំ អរហតោ សម្មាសម្ពុទ្ធស្ស វិមលោតិ ភិក្ខវេ តថាគតស្សេតំ អធិវចនំ អរហតោ សម្មាសម្ពុទ្ធស្ស ញាណីតិ ភិក្ខវេ តថាគតស្សេតំ អធិវចនំ អរហតោ សម្មាសម្ពុទ្ធស្ស វិមុត្តោតិ ភិក្ខវេ តថាគតស្សេតំ អធិវចនំ អរហតោ សម្មាសម្ពុទ្ធស្សាតិ ។

យំ សមណេន បត្តព្វំ ព្រាហ្មណេន វុសីមតា
យំ វេទគុនា បត្តព្វំ ភិសក្កេន អនុត្តរំ
យំ ជិម្ហលេន បត្តព្វំ វិមលេន វុសីមតា
យំ ញាណិនា ច បត្តព្វំ វិមុត្តេន អនុត្តរំ
សោហំ វិជិតសង្គាមោ មុត្តោ មោចេមិ ពន្ធនា
នាគោម្ហិ បរមទន្តោ អសេក្ខោ បរិនិព្វុតោតិ ។

ម្នាលភិក្ខុទាំងឡាយ ពាក្យថា និម្មលៈ (អ្នកគ្មានមន្ទិល) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា វិមលៈ (អ្នកប្រាសចាកមន្ទិល) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា ញាណី (អ្នកមានញាណ) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ម្នាលភិក្ខុទាំងឡាយ ពាក្យថា វិមុត្ត (អ្នកផុតស្រឡះ) នេះ ជាឈ្មោះរបស់តថាគត ជាអរហន្តសម្មាសម្ពុទ្ធ ។

គុណជាតណា ដែលតថាគតជាសមណៈ ជាព្រាហ្មណ៍ មានព្រហ្មចរិយៈនៅរួចហើយ គប្បីសម្រេចក្តី គុណជាតណា ដែលតថាគត អ្នកចេះចប់ត្រៃវេទ ជាគ្រូពេទ្យវះកាត់ គប្បីសម្រេចក្តី គុណជាតនោះប្រសើរបំផុត គុណជាតណា ដែលតថាគត គ្មានមន្ទិល ប្រាសចាកមន្ទិល មានព្រហ្មចរិយៈនៅរួចហើយ គប្បីសម្រេចក្តី គុណជាតណា ដែលតថាគត មានញាណ អ្នករួចស្រឡះ គប្បីសម្រេចក្តី គុណជាតនោះ ប្រសើរបំផុត តថាគតនោះ ជាអ្នកឈ្នះសង្គ្រាម រួចចាកចំណង ទាំងស្រាយមហាជន ឲ្យរួចចាកចំណង ជាបុគ្គលប្រសើរ មានខ្លួនទូន្មានហើយដោយប្រពៃ ជាអសេក្ខបុគ្គលបរិនិព្វានហើយ ។

[១០៣] ឯកំ សមយំ ភគវា កោសម្ពីសុ ចារិកំ ចរមានោ មហតា ភិក្ខុសង្ឃេន សទ្ធឹ យេន ឥច្ឆានង្គលំ នាម កោសលានំ ព្រាហ្មណគាមោ តទវសរិ ។ តត្រ សុទំ ភគវា ឥច្ឆានង្គលេ វិហរតិ ឥច្ឆានង្គលវនសណ្ឌេ ។ អស្សោសុំ ខោ ឥច្ឆានង្គលកា ព្រាហ្មណគហបតិកា សមណោ ខលុ ភោ គោតមោ សក្យបុត្តោ សក្យកុលា បព្វជិតោ ឥច្ឆានង្គលំ អនុប្បត្តោ ឥច្ឆានង្គលេ វិហរតិ ឥច្ឆានង្គលវនសណ្ឌេ ។ តំ ខោ បន ភវន្តំ គោតមំ ឯវំកល្យាណោ កិត្តិសទ្ទោ អព្ភុគ្គតោ ឥតិបិ សោ ភគវា អរហំ សម្មាសម្ពុទ្ធោ ។ បេ ។ សាធុ ខោ បន តថារូបានំ អរហតំ ទស្សនំ ហោតីតិ ។ អថខោ ឥច្ឆានង្គលកា ព្រាហ្មណគហបតិកា តស្សា រត្តិយា អច្ចយេន បហូតំ ខាទនីយំ ភោជនីយំ អាទាយ យេន ឥច្ឆានង្គលវនសណ្ឌោ តេនុបសង្កមឹសុ ឧបសង្កមិត្វា ពហិទ្វារកោដ្ឋកេ អដ្ឋំសុ ឧច្ចាសទ្ទា មហាសទ្ទា ។

[១០៣] សម័យមួយ ព្រះដ៏មានព្រះភាគ ព្រមដោយភិក្ខុសង្ឃច្រើនរូប ទ្រង់ពុទ្ធដំណើរទៅកាន់ចារិក ក្នុងក្រុងកោសម្ពី បានស្តេចទៅដល់ព្រាហ្មណគ្រាម ឈ្មោះឥច្ឆានង្គលៈរបស់ពួកអ្នកដែនកោសល ។ បានឮថា ព្រះដ៏មានព្រះភាគ ទ្រង់គង់នៅក្នុងដងព្រៃឥច្ឆានង្គលៈ ជិតស្រុកឥច្ឆានង្គលៈនោះ ។ ពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកឥច្ឆានង្គលៈបានឮដំណឹង (ប្រកាសប្រាប់គ្នា) ថា ម្នាលគ្នាយើង ឮថា ព្រះសមណគោតមជាសក្យបុត្ត ចេញចាកសក្យត្រកូលទៅទ្រង់ព្រះផ្នួស ឥឡូវបានស្តេចមកដល់ស្រុកឥច្ឆានង្គលៈហើយ ទ្រង់គង់ក្នុងដងព្រៃឥច្ឆានង្គលៈជិតស្រុកឥច្ឆានង្គលៈ ។ កិត្តិសព្ទដ៏ពីរោះយ៉ាងនេះ របស់ព្រះគោតមដ៏ចម្រើនអង្គនោះ ល្បី ឮ សុសសាយទៅថា ព្រះដ៏មានព្រះភាគអង្គនោះ ជាអរហន្តសម្មាសម្ពុទ្ធ ។ បេ ។ ក៏ការដែលបានជួបប្រទះនឹងព្រះអរហន្តទាំងឡាយមានសភាពដូច្នោះ ជាការប្រពៃពេកណាស់ ។ គ្រានោះ ពួកព្រាហ្មណ៍និងគហបតី អ្នកស្រុកឥច្ឆានង្គលៈ កាលកន្លងរាត្រីនោះទៅហើយ ក៏នាំយកខាទនីយភោជនីយាហារដ៏ក្រាស់ក្រៃល នាំគ្នាដើរចូលសំដៅទៅរកដងព្រៃឥច្ឆានង្គលៈ លុះចូលទៅដល់ហើយ ក៏ឈរស្រែកហ៊ោនិយាយខ្លាំង ទៀបក្លោងទ្វារខាងក្រៅ ។

៣៨៧



តេន ខោ បន សមយេន អាយស្មា នាគិតោ ភគវតោ ឧបដ្ឋាកោ ហោតិ ។ អថខោ ភគវា អាយស្មន្តំ នាគិតំ អាមន្តេសិ កេ បន តេ នាគិត ឧច្ចាសទ្ទា មហាសទ្ទា កេវដ្ដា មញ្ញេ មច្ឆំ វិលោបេន្តីតិ ។ ឯតេ ភន្តេ ឥច្ឆានង្គលកា ព្រាហ្មណគហបតិកា បហូតំ ខាទនីយំ ភោជនីយំ អាទាយ ពហិទ្វារកោដ្ឋកេ ឋិតា ភគវន្តញ្ញេវ ឧទ្ទិស្ស ភិក្ខុសង្ឃញ្ចាតិ ។ មាហំ នាគិត យសេន សមាគមំ មា ច មយា យសោ យោ ខោ នាគិត ន យិមស្ស នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី អស្ស អកិច្ឆលាភី អកសិរលាភី យស្សាហំ នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី អស្សំ អកិច្ឆលាភី អកសិរលាភី សោ តំ មិឡ្ហសុខំ មិទ្ធសុខំ លាភសក្ការសិលោកសុខំ សាទិយេយ្យាតិ ។

បណ្ណាសកាសង្គហិត សតិវគ្គ

សម័យនោះឯង ព្រះនាគិតៈដ៏មានអាយុ ជាឧបដ្ឋាកព្រះដ៏មានព្រះភាគ ។ វេលានោះ ព្រះដ៏មានព្រះភាគ ទ្រង់ត្រាស់សួរព្រះនាគិតៈដ៏មានអាយុថា ម្នាលនាគិតៈ ចុះពួកណាស្រែកហ៊ោ និយាយឮខ្លាំងម៉្ងេះ ហាក់ដូចជាព្រានសំណាញ់ ដណ្ដើមត្រីគ្នា ។ ព្រះនាគិតៈដ៏មានអាយុក្រាបបង្គំទូលថា សូមទ្រង់ព្រះមេត្តាប្រោស អ្នកទាំងនុ៎ះ ជាព្រាហ្មណ៍និងគហបតី នៅក្នុងស្រុកឥច្ឆានង្គលៈ នាំយកខាទនីយភោជនីយាហារដ៏ក្រាស់ក្រៃល ឧទ្ទិសចំពោះព្រះដ៏មានព្រះភាគផង ព្រះភិក្ខុសង្ឃផង ហើយឈរទៀបក្លោងទ្វារខាងក្រៅ ។ ម្នាលនាគិតៈ តថាគតសូមកុំឲ្យជួបប្រសព្វនឹងយសបរិវារ ទាំងយសបរិវារ ក៏សូមកុំឲ្យជួបប្រសព្វនឹងតថាគតឡើយ ម្នាលនាគិតៈ បុគ្គលណា មិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ នេះដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគតបានដូចប្រាថ្នា បានដោយងាយ បានដោយស្រួលទេ បុគ្គលនោះឯង គប្បីត្រេកអរចំពោះសេចក្ដីសុខ មិនស្អាត សុខក្នុងការដេកលក់ សុខកើតអំពីលាភសក្ការៈនិងពាក្យសរសើរ ។

អធិវាសេតុទានិ ភន្តេ ភគវា អធិវាសេតុ សុគតោ អធិវាសនកាលោទានិ ភន្តេ ភគវតោ យេន យេនបិ-ទានិ ភន្តេ ភគវា គមិស្សតិ តន្និទា ច ភវិស្សន្តិ ព្រាហ្ម-ណគហបតិកា នេគមា ចេវ ជានបទា ច ។ សេយ្យថាបិ ភន្តេ ថុល្លផុសិតកេ ទេវេ វស្សន្តេ យថានិន្នំ ឧទកានិ សំវត្តន្តិ ឯវមេវ ខោ ភន្តេ យេន យេនបិទានិ ភគវា គមិស្សតិ តន្និទា ច ភវិស្សន្តិ ព្រាហ្មណគហបតិកា នេគមា ចេវ ជានបទា ច ។ តំ កិស្ស ហេតុ ។ តថា ហិ ភន្តេ ភគវតោ សីលប្បញ្ញាណន្តិ ។ មាហំ នាគិត យសេន សមាគមំ មា ច មយា យសោ យោ ខោ នាគិត ន យិមស្ស នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី អស្ស អកិច្ឆលាភី អកសិរលាភី

ព្រះនាគិតៈក្រាបបង្គំទូលថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ សូមព្រះដ៏មានព្រះភាគទទួលនិមន្ត្រន៍ សូមព្រះសុគតទទួលនិមន្ត្រន៍ បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះ កាលនេះជាកាលគួរព្រះដ៏មានព្រះភាគទទួលនិមន្ត្រន៍ហើយ បពិត្រព្រះអង្គដ៏ចម្រើន បើព្រះដ៏មានព្រះភាគនឹងស្តេចទៅក្នុងទីណាៗ ក្នុងកាលឥឡូវនេះ ក៏គង់ពួកព្រាហ្មណ៍និងគហបតី ជាអ្នកនិគមក្តី អ្នកជនបទក្តី នឹងតាមទៅក្នុងទីនោះៗ មិនខាន ។ បពិត្រព្រះអង្គដ៏ចម្រើន កាលបើភ្លៀងមានតំណក់ទឹកថ្លោសៗ បង្អុរចុះមក ទឹកទាំងឡាយ តែងហូរធ្លាក់ទៅកាន់ទីទាប ដូចម្តេចមិញ បពិត្រព្រះអង្គដ៏ចម្រើន បើព្រះដ៏មានព្រះភាគនឹងស្តេចទៅក្នុងទីណាៗ ក្នុងកាលឥឡូវនេះ ក៏គង់ពួកព្រាហ្មណ៍និងគហបតី ជាអ្នកនិគមក្តី អ្នកជនបទក្តី នឹងតាមទៅក្នុងទីនោះៗមិនខាន ដូច្នោះឯង ។ ដំណើរនោះ ព្រោះហេតុអ្វី ។ បពិត្រព្រះអង្គដ៏ចម្រើន ព្រោះព្រះដ៏មានព្រះភាគព្រះអង្គមានសីលនិងប្រាជ្ញា ។ ម្នាលនាគិតៈ តថាគត សូមកុំឲ្យជួបប្រសព្វនឹងយសបរិវារ ទាំងយសបរិវារ ក៏សូមកុំឲ្យជួបប្រសព្វនឹងតថាគតឡើយ ម្នាលនាគិតៈ បុគ្គលណា មិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខនេះ

យស្សាហំ នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី អស្សំ អកិច្ឆលាភី អកសិរលាភី សោ តំ មិឡ្ហសុខំ មិទ្ធសុខំ លាភសក្ការសិលោកសុខំ សាទិយេយ្យ ។ ទេវតាបិ ខោ នាគិត ឯកច្ចា ន យិមស្ស នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភិនិយោ អស្សុ អកិច្ឆលាភិនិយោ អកសិរលាភិនិយោ យស្សាហំ នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី អស្សំ អកិច្ឆលាភី អកសិរលាភី តុម្ហាកម្បិ ខោ នាគិត សំគម្ម សមាគម្ម សង្គណិកាវិហារំ អនុយុត្តានំ វិហរតំ ឯវំ ហោតិ ន ហនូនមេ អាយស្មន្តោ ឥមស្ស នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភិនោ អស្សុ អកិច្ឆលាភិនោ អកសិរលាភិនោ

ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគតបានដូចប្រាថ្នា បានដោយងាយ បានដោយស្រួលទេ បុគ្គលនោះ គប្បីត្រេកអរចំពោះសេចក្តីសុខមិនស្អាត សុខក្នុងការដេកលក់ សុខដែលកើតអំពីលាភសក្ការៈ និងពាក្យសរសើរ ។ ម្នាលនាគិតៈ សូម្បីទេវតាពួកខ្លះ ក៏មិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខនេះ ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគតបានដូចប្រាថ្នា បានដោយងាយ បានដោយស្រួលដែរ ម្នាលនាគិតៈ អ្នកទាំងឡាយ កាលមកប្រជុំសមាគមគ្នា ខ្វល់ខ្វាយខាងការនៅច្រឡូកច្រឡំដោយពួកហើយ រមែងមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកទាំងឡាយនេះ មុខជាមិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខនេះ

យស្សាហំ នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី អស្សំ អកិច្ឆលាភី អកសិរលាភី តថា ហិ បនមេ អាយស្មន្តោ សំគម្ម សមាគម្ម សង្គណិការាមំ អនុយុត្តា វិហរន្តិ ។ ឥធាហំ ជាតិត ភិក្ខូ បស្សាមិ អញ្ញមញ្ញំ អង្គុលិប្បតោទកេន(១) សញ្ជគ្ឃន្តេ សំកីឡន្តេ តស្ស មយ្ហំ ជាតិត ឯវំ ហោតិ ន ហន្ទមេ អាយស្មន្តោ ឥមស្ស នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភិនោ អស្សុ អកិច្ឆលាភិនោ អកសិរលាភិនោ យស្សាហំ នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាមលាភី អស្សំ អកិច្ឆលាភី អកសិរលាភី តថា ហិ បនមេ អាយស្មន្តោ អញ្ញមញ្ញំ អង្គុលិប្បតោទកេន សញ្ជគ្ឃន្តិ សំកីឡន្តិ ។

១ ឱ. ម. អង្គុលិបតោទកេហិ ។

ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគត បានដូចប្រាថ្នា បានដោយងាយ បានដោយស្រួល ដោយពិត ព្រោះថា លោកដ៏មានអាយុទាំងនេះ មកប្រជុំសមាគមគ្នា ប្រកបរឿយៗ ខាងការនៅច្រឡូកច្រឡំដោយពួក ។ ម្នាលនាគិតៈ ក្នុងទីឯណោះ តថាគតឃើញពួកភិក្ខុ កំពុងសើចក្អាកក្អាយ សើចប្រឡែងគ្នា ដោយការចាក់ដោយជន្លួញគឺម្រាមដៃទៅវិញទៅមក ម្នាលនាគិតៈ តថាគតមានសេចក្តីត្រិះរិះយ៉ាងនេះថា លោកដ៏មានអាយុទាំងនេះ មុខជាមិនបានដូចប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិវេកសុខ ឧបសម-សុខ សម្ពោធសុខនេះ ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគតបានដូចប្រាថ្នា បានដោយងាយ បានដោយស្រួល ដោយពិត ព្រោះថា លោកដ៏មានអាយុទាំងនេះ សើចក្អាកក្អាយ សើចប្រឡែងគ្នា ដោយការចាក់ដោយជន្លួញគឺម្រាមដៃ ទៅវិញទៅមក ។

ឥធ បនាហំ នាគិត ភិក្ខូ បស្សាមិ យាវទត្ថំ ឧទរាវ-
ទេហកំ ភុញ្ជិត្វា សេយ្យសុខំ បស្សសុខំ មិទ្ធសុខំ
អនុយុត្តេ វិហរន្តេ តស្ស មយ្ហំ នាគិត ឯវំ ហោតិ ន
ហាន្វិមេ អាយស្មន្តោ ឥមស្ស នេក្ខម្មសុខស្ស បវិវេក-
សុខស្ស ឧបសមសុខស្ស សម្ពោធសុខស្ស និកាម-
លាភិនោ អស្សុ អកិច្ឆលាភិនោ អកសិរលាភិនោ
យស្សាហំ នេក្ខម្មសុខស្ស បវិវេកសុខស្ស ឧបសម-
សុខស្ស សម្ពោធសុខស្ស និកាមលាភី អស្សំ អកិច្ឆ-
លាភី អកសិរលាភី តថា ហិ បនមេ អាយស្មន្តោ
យាវទត្ថំ ឧទរាវទេហកំ ភុញ្ជិត្វា សេយ្យសុខំ បស្សសុខំ
មិទ្ធសុខំ អនុយុត្តា វិហរន្តិ ។ ឥធាហំ នាគិត ភិក្ខុំ
បស្សាមិ គាមន្តវិហារេ(១) សមាហិតំ និសិន្នំ តស្ស
មយ្ហំ នាគិត ឯវំ ហោតិ ឥទានិ ឥមំ អាយស្មន្តំ
អារាមិកោ វា ឧបដ្ឋហិស្សតិ(២) សមណុទ្ទេសោ វា តំ
តម្ហា សមាធិម្ហា ចាវេស្សតីតិ(៣) តេនាហំ នាគិត តស្ស
ភិក្ខុនោ ន អត្តមនោ ហោមិ គាមន្តវិហារេន ។

១ ម. គាមន្តវិហារឹ ។ ២ ឱ. សច្ចេស្សតិ ។ ៣ ឱ. ម. ចាវិស្សតីតិ ។

ម្នាលនាគិតៈ មួយទៀត ក្នុងទីឯណោះ តថាគតឃើញពួកភិក្ខុ បរិភោគ ដរាបទាល់ឆ្អែតពេញពោះ ហើយខ្វល់ខ្វាយខាងសេចក្ដីសុខនឹងដំណេក សុខនឹងបង្អែក សុខនឹងការដេកលក់ ម្នាលនាគិតៈ តថាគតនោះ មាន សេចក្ដីត្រិះរិះយ៉ាងនេះថា លោកទាំងឡាយនេះ មុខជាមិនបានដូច ប្រាថ្នា មិនបានដោយងាយ មិនបានដោយស្រួល នូវនេក្ខម្មសុខ បវិ-វេកសុខ ឧបសមសុខ សម្ពោធសុខនេះ ដូចជានេក្ខម្មសុខ បវិវេកសុខ ឧបសមសុខ សម្ពោធសុខ ដែលតថាគតបានដូចប្រាថ្នា បានដោយងាយ បានដោយស្រួល ដោយពិត ព្រោះថា លោកទាំងឡាយនេះ បរិភោគ ដរាបទាល់ឆ្អែតពេញពោះ ខ្វល់ខ្វាយខាងសេចក្ដីសុខនឹងដំណេក សុខ នឹងបង្អែក សុខនឹងការដេកលក់ ។ ម្នាលនាគិតៈ ក្នុងទីឯណោះ តថាគតឃើញភិក្ខុមានចិត្តតម្កល់នៅនឹង អង្គុយក្នុងវិហារជិតស្រុក តថាគត នោះ មានសេចក្ដីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ អារាមិកជន ឬក៏សម-ណុទ្ទេស នឹងមកបម្រើលោកនេះ ឯការបម្រើនោះ នឹងញុំាងលោក នេះ ឲ្យឃ្លាតចាកសមាធិនោះពុំខាន ម្នាលនាគិតៈ ព្រោះហេតុនោះ តថាគត មិនត្រេកអរនឹងភិក្ខុនោះ ដោយការនៅ ក្នុងទីជិតស្រុក ។

ឥធ បនាហំ នាគិត ភិក្ខុំ បស្សាមិ[១] អរញ្ញេ ច បលាយមានំ និសិន្នំ តស្ស មយ្ហំ នាគិត ឯវំ ហោតិ ឥទានិ អយមាយស្មា ឥមំ និទ្ទាកិលមថំ បដិវិនោទេត្វា អរញ្ញសញ្ញាយេវ មនសិករិស្សតិ ឯត្តកន្តិ[២] តេនាហំ នាគិត តស្ស ភិក្ខុនោ អត្តមនោ ហោមិ អរញ្ញវិហារេន ។ ឥធ បនាហំ នាគិត ភិក្ខុំ បស្សាមិ អរញ្ញេ អសមាហិតំ និសិន្នំ តស្ស មយ្ហំ នាគិត ឯវំ ហោតិ ឥទានិ អយមាយស្មា អសមាហិតំ វា ចិត្តំ សមាទហិស្សតិ សមាហិតំ វា ចិត្តំ អនុរក្ខិស្សតីតិ តេនាហំ នាគិត តស្ស ភិក្ខុនោ អត្តមនោ ហោមិ អរញ្ញវិហារេន ។ ឥធ បនាហំ នាគិត ភិក្ខុំ បស្សាមិ អារញ្ញកំ សមាហិតំ និសិន្នំ តស្ស មយ្ហំ នាគិត ឯវំ ហោតិ ឥទានិ អយមាយស្មា អវិមុត្តំ វា ចិត្តំ វិមុច្ចិស្សតិ វិមុត្តំ វា ចិត្តំ អនុរក្ខិស្សតីតិ តេនាហំ នាគិត តស្ស ភិក្ខុនោ អត្តមនោ ហោមិ អរញ្ញវិហារេន ។

---

១ ឱ. ម. ឯត្ថន្តរេ អារញ្ញកន្តិ អយំ បាឋោ ទិស្សតិ ។ ២ ឯកត្តន្តិ ។

ម្នាលនាគិត: មួយទៀត ក្នុងទីឯណោះ តថាគតឃើញភិក្ខុ រត់ចេញទៅអង្គុយនៅក្នុងព្រៃ ម្នាលនាគិត: តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ លោកនេះ មុខជានឹងកម្ចាត់បង់នូវសេចក្តីងោកងក់ និងសេចក្តីលំបាកនេះ ហើយនឹងធ្វើទុកក្នុងចិត្តនូវអរញ្ញសញ្ញា ជាធម្មជាតិមានចិត្តមូលតែមួយពុំខាន ម្នាលនាគិត: ព្រោះហេតុនោះ តថាគតត្រេកអរនឹងភិក្ខុនោះ ដោយការនៅក្នុងព្រៃ ។ ម្នាលនាគិត: មួយទៀត ក្នុងទីឯណោះ តថាគតឃើញភិក្ខុ មានចិត្តមិនទាន់តម្កល់នៅនឹងទេ អង្គុយនៅក្នុងព្រៃ ម្នាលនាគិត: តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ លោកនេះ នឹងតម្កល់ចិត្តដែលមិនទាន់តម្កល់ ឬនឹងរក្សាចិត្តដែលខ្លួនបានតម្កល់ហើយពុំខាន ម្នាលនាគិត: ព្រោះហេតុនោះ តថាគតមានចិត្តត្រេកអរនឹងភិក្ខុនោះ ដោយការនៅក្នុងព្រៃ ។ ម្នាលនាគិត: មួយវិញទៀត ក្នុងទីឯណោះ តថាគតឃើញភិក្ខុមួយរូប អ្នកនៅក្នុងព្រៃ មានចិត្តតម្កល់នៅនឹង កំពុងអង្គុយ ម្នាលនាគិត: តថាគតនោះ មានសេចក្តីត្រិះរិះយ៉ាងនេះថា ឥឡូវនេះ លោកនេះ នឹងធ្វើចិត្តដែលមិនទាន់រួចឲ្យរួចស្រឡះ ឬនឹងរក្សាចិត្តដែលរួចស្រឡះហើយពុំខាន ម្នាលនាគិត: ព្រោះហេតុនោះ តថាគតមានចិត្តត្រេកអរនឹងភិក្ខុនោះ ដោយការនៅក្នុងព្រៃ ។

យស្មាហំ ជាតិត សមយេ អទ្ធានមគ្គប្បដិបន្នោ ន កិញ្ចិ បស្សាមិ បុរតោ វា បច្ឆតោ វា ផាសុ មេ ជាតិត តស្មឹ សមយេ ហោតិ អន្តមសោ ឧច្ចារប្បស្សាវ-កម្មស្សាតិ(១) ។

[១០៤] អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ឧបាសកស្ស អាកង្ខមានោ សង្ឃោ បត្តំ និក្កុជ្ជេយ្យ ។ កតមេហិ អដ្ឋហិ ។ ភិក្ខូនំ អលាភាយ បរិសក្កតិ ភិក្ខូនំ អនត្ថាយ បរិសក្កតិ ភិក្ខូនំ អនាវាសាយ បរិសក្កតិ ភិក្ខូ(២) អក្កោសតិ បរិភាសតិ ភិក្ខូ ភិក្ខូហិ វិភេទេតិ ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតស្ស ឧបាសកស្ស អាកង្ខមានោ សង្ឃោ បត្តំ និក្កុជ្ជេយ្យ ។

---

១ ឱ. ឧច្ចារបស្សាវកម្មាយាតិ ។ ២ ឱ. ភិក្ខូនំ ។

ម្នាលនាគិតៈ សម័យណា ដែលតថាគតដើរទៅកាន់ផ្លូវឆ្ងាយ មិនបាន ជួបប្រទះអ្វីតិចតួច ក្នុងខាងមុខក្តី ខាងក្រោយក្តី ម្នាលនាគិតៈ សម័យ នោះ តថាគតមានតែសេចក្តីសប្បាយ ដោយហោចទៅ សូម្បីការ ធ្វើឧច្ចារៈឬបស្សាវៈក៏ស្រួល ។

[១០៤] ម្នាលភិក្ខុទាំងឡាយ ឧបាសក ប្រកបដោយអង្គ ៨ ប្រការ សង្ឃកាលប្រាថ្នា គប្បីផ្កាប់បាត្របាន ។ អង្គ ៨ ប្រការ តើដូច ម្តេចខ្លះ ។ គឺឧបាសកព្យាយាម ដើម្បីមិនឲ្យភិក្ខុទាំងឡាយបានលាភ ១ ព្យាយាម ដើម្បីមិនឲ្យភិក្ខុទាំងឡាយបានប្រយោជន៍ ១ ព្យាយាមដើម្បីមិន ឲ្យភិក្ខុទាំងឡាយបានទីលំនៅ ១ ជេរប្រទេចភិក្ខុទាំងឡាយ ១ បំបែកភិក្ខុ ទាំងឡាយឲ្យបែកចាកភិក្ខុទាំងឡាយ ១ តិះដៀលព្រះពុទ្ធ ១ តិះដៀល ព្រះធម៌ ១ តិះដៀលព្រះសង្ឃ ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកប ដោយអង្គ ៨ ប្រការនេះឯង សង្ឃកាលប្រាថ្នា គប្បីផ្កាប់បាត្របាន ។

[១០៥] អដ្ឋហិ ភិក្ខវេ អង្គេហិ សមន្នាគតស្ស ឧបាសកស្ស អាកង្ខមានោ សង្ឃោ បត្តំ ឧក្កុជ្ជេយ្យ ។ កតមេហិ អដ្ឋហិ ។ ន ភិក្ខូនំ អលាភាយ បរិសក្កតិ ន ភិក្ខូនំ អនត្ថាយ បរិសក្កតិ ន ភិក្ខូនំ អនាវាសាយ បរិសក្កតិ ន ភិក្ខូ អក្កោសតិ បរិភាសតិ ន ភិក្ខូ ភិក្ខូហិ វិភេទេតិ ពុទ្ធស្ស វណ្ណំ ភាសតិ ធម្មស្ស វណ្ណំ ភាសតិ សង្ឃស្ស វណ្ណំ ភាសតិ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហង្គេហិ សមន្នាគតស្ស ឧបាសកស្ស អាកង្ខមានោ សង្ឃោ បត្តំ ឧក្កុជ្ជេយ្យាតិ ។

[១០៦] អដ្ឋហិ ភិក្ខវេ ធម្មេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានា ឧបាសកា អប្បសាទំ បវេទេយ្យុំ ។ កតមេហិ អដ្ឋហិ ។ គិហីនំ អលាភាយ បរិសក្កតិ គិហីនំ អនត្ថាយ បរិសក្កតិ គិហី[១] អក្កោសតិ បរិភាសតិ គិហី គិហីហិ វិភេទេតិ

១ ឱ. គិហីនំ ។ ម. គិហឹ ។

[១០៥] ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយអង្គ ៨ ប្រការ សង្ឃកាលប្រាថ្នា គប្បីផ្ងារបាត្របាន ។ ដោយអង្គ ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺឧបាសក មិនព្យាយាមដើម្បីមិនឲ្យភិក្ខុទាំងឡាយបានលាភ ១ មិនព្យាយាម ដើម្បីមិនឲ្យភិក្ខុទាំងឡាយបានប្រយោជន៍ ១ មិនព្យាយាម ដើម្បីមិនឲ្យភិក្ខុទាំងឡាយបានទីលំនៅ ១ មិនជេរប្រទេចភិក្ខុទាំងឡាយ ១ មិនបំបែកភិក្ខុទាំងឡាយឲ្យបែកចាកភិក្ខុទាំងឡាយ ១ ពោលសរសើរព្រះពុទ្ធ ១ ពោលសរសើរព្រះធម៌ ១ ពោលសរសើរព្រះសង្ឃ ១ ។ ម្នាលភិក្ខុទាំងឡាយ ឧបាសកប្រកបដោយអង្គ ៨ ប្រការនេះឯង សង្ឃកាលប្រាថ្នា គប្បីផ្ងារបាត្របាន ។

[១០៦] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការ ពួកឧបាសកកាលប្រាថ្នា គប្បីសម្តែងសេចក្តីមិនជ្រះថ្លាបាន ។ ប្រកបដោយធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺ ភិក្ខុព្យាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានលាភ ១ ព្យាយាមដើម្បីមិនឲ្យពួកគ្រហស្ថបានប្រយោជន៍ ១ ជេរប្រទេចពួកគ្រហស្ថ ១ បំបែកពួកគ្រហស្ថឲ្យបែកចាកពួកគ្រហស្ថ ១

ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ តតោ ច នេវ នំ[១] បស្សន្តិ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានា ឧបាសកា អប្បសាទំ បវេទេយ្យុំ ។

[១០៧] អដ្ឋហិ ភិក្ខវេ ធម្មេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានា ឧបាសកា បសាទំ បវេទេយ្យុំ ។ កតមេហិ អដ្ឋហិ ។ ន គិហីនំ អលាភាយ បរិសក្កតិ ន គិហីនំ អនត្ថាយ បរិសក្កតិ ន គិហី អក្កោសតិ បរិភាសតិ ន គិហី គិហីហិ ភេទេតិ ពុទ្ធស្ស វណ្ណំ ភាសតិ ធម្មស្ស វណ្ណំ ភាសតិ សង្ឃស្ស វណ្ណំ ភាសតិ តតោ ច នេវ នំ បស្សន្តិ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានា ឧបាសកា បសាទំ បវេទេយ្យុន្តិ ។

---

១ ឱ. ម. អគោចរេ ច នំ ។ អដ្ឋកថាយំ អគោចរេតិបិ ទិស្សតិ ។

តិះដៀលព្រះពុទ្ធ ១ តិះដៀលព្រះធម៌ ១ តិះដៀលព្រះសង្ឃ ១ ទាំងពួកទេវតា ក៏ឃើញនូវភិក្ខុនោះដោយហេតុនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការនេះឯង ពួកឧបាសក កាលប្រាថ្នា គប្បីសម្តែងសេចក្តីមិនជ្រះថ្លាបាន ។

[១០៧] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការ ពួកឧបាសក កាលប្រាថ្នា គប្បីសម្តែងសេចក្តីជ្រះថ្លាបាន ។ ប្រកបដោយធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺភិក្ខុមិនព្យាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានលាភ ១ មិនព្យាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានប្រយោជន៍ ១ មិនជេរប្រទេចពួកគ្រហស្ថ ១ មិនបំបែកពួកគ្រហស្ថ ឲ្យបែកចាកពួកគ្រហស្ថ ១ ពោលសរសើរព្រះពុទ្ធ ១ ពោលសរសើរព្រះធម៌ ១ ពោលសរ-សើរព្រះសង្ឃ ១ ពួកទេវតាឃើញភិក្ខុនោះ ដោយហេតុនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការនេះឯង ពួកឧបាសក កាលប្រាថ្នា គប្បីសម្តែងនូវសេចក្តីជ្រះថ្លាបាន ។

[១០៨] អដ្ឋហិ ភិក្ខវេ ធម្មេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បដិសារណីយកម្មំ ករេយ្យ ។ កតមេហិ អដ្ឋហិ ។ គិហីនំ អលាភាយ បរិសក្កតិ គិហីនំ អនត្ថាយ បរិសក្កតិ គិហី អក្កោ-សតិ បរិភាសតិ គិហី គិហីហិ វិភេទេតិ ពុទ្ធស្ស អវណ្ណំ ភាសតិ ធម្មស្ស អវណ្ណំ ភាសតិ សង្ឃស្ស អវណ្ណំ ភាសតិ ធម្មិកញ្ច គិហិប្បដិស្សវំ ន សច្ចាបេតិ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បដិសារណីយកម្មំ ករេយ្យ ។

[១០៩] អដ្ឋហិ ភិក្ខវេ ធម្មេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បដិសារណីយកម្មំ បដិប្បស្សម្ភេយ្យ ។ កតមេហិ អដ្ឋហិ ។ ន គិហីនំ អលាភាយ បរិសក្កតិ ន គិហីនំ អនត្ថាយ បរិសក្កតិ ន គិហី អក្កោសតិ បរិភាសតិ ន គិហី គិហីហិ វិភេទេតិ

[១០៨] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការ សង្ឃកាលប្រាថ្នា គប្បីធ្វើបដិសារណីយកម្មបាន ។ ប្រកបដោយធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺភិក្ខុព្យាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានលាភ ១ ព្យាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានប្រយោជន៍ ១ ជេរប្រទេចពួកគ្រហស្ថ ១ បំបែកពួកគ្រហស្ថឲ្យបែកចាកពួកគ្រហស្ថ ១ តិះដៀលព្រះពុទ្ធ ១ តិះដៀលព្រះធម៌ ១ តិះដៀលព្រះសង្ឃ ១ ញុំាងពាក្យនិមន្តរបស់គ្រហស្ថប្រកបដោយធម៌ឲ្យឃ្លៀងឃ្លាត ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការនេះឯង សង្ឃកាលប្រាថ្នា គប្បីធ្វើបដិសារណីយកម្មបាន ។

[១០៩] ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការ សង្ឃកាលប្រាថ្នា គប្បីរម្ងាប់នូវបដិសារណីយកម្មបាន ។ ប្រកបដោយធម៌ ៨ ប្រការ តើដូចម្តេចខ្លះ ។ គឺភិក្ខុមិនព្យាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានលាភ ១ មិនព្យាយាម ដើម្បីមិនឲ្យពួកគ្រហស្ថបានប្រយោជន៍ ១ មិនជេរប្រទេចពួកគ្រហស្ថ ១ មិនបំបែកពួកគ្រហស្ថឲ្យបែកចាកពួកគ្រហស្ថ ១

ពុទ្ធស្ស វណ្ណំ ភាសតិ ធម្មស្ស វណ្ណំ ភាសតិ សង្ឃស្ស វណ្ណំ ភាសតិ ធម្មិកញ្ច តិហិប្បដិស្សវំ សច្ចាបេតិ ។ ឥមេហិ ខោ ភិក្ខវេ អដ្ឋហិ ធម្មេហិ សមន្នាគតស្ស ភិក្ខុនោ អាកង្ខមានោ សង្ឃោ បដិសារណីយកម្មំ បដិប្បស្សម្ភេយ្យាតិ ។

[១១០] តស្ស បាបិយសិកាកម្មកតេន ភិក្ខវេ ភិក្ខុនា អដ្ឋសុ ធម្មេសុ សម្មាវត្តិតព្វំ ន ឧបសម្បាទេតព្វំ ន និស្សយោ ទាតព្វោ ន សាមណេរោ ឧបដ្ឋាបេតព្វោ ន ភិក្ខុនោវាទកសម្មតិ[១] សាទិតព្វា សម្មតេនបិ ភិក្ខុនិយោ ន ឱវទិតព្វា ន កាចិ សង្ឃសម្មតិ សាទិតព្វា ន កិស្មិញ្ចិ បច្ចេកដ្ឋានេ និយមេតព្វា[២] ន ច តេន មូលេន វុដ្ឋាបេតព្វំ ។ តស្ស បាបិយសិកាកម្មកតេន ភិក្ខវេ ភិក្ខុនា ឥមេសុ អដ្ឋសុ ធម្មេសុ សម្មាវត្តិតព្វន្តិ ។

សតិវគ្គោ សមត្តោ ។

១ ឱ. ម. ភិក្ខុនោវាទកសម្មុតិ ។ ២ ឱ. ម. បបេតព្វោ ។

ពោលសរសើរព្រះពុទ្ធ ១ ពោលសរសើរព្រះធម៌ ១ ពោលសរសើរព្រះសង្ឃ ១ ញុំាងពាក្យនិមន្តរបស់ពួកគ្រហស្ថ ប្រកបដោយធម៌ឲ្យទៀងទាត់ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៨ ប្រការនេះឯង សង្ឃកាលប្រាថ្នា គប្បីរម្ងាប់នូវបដិសារណីយកម្មបាន ។

[១១០] ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃធ្វើ តស្សបាបិយសិកាកម្មរួចហើយ ត្រូវប្រព្រឹត្តឲ្យល្អ ក្នុងធម៌ ៨ ប្រការគឺ មិនត្រូវឲ្យឧបសម្បទា ១ មិនត្រូវឲ្យនិស្ស័យ ១ មិនត្រូវឲ្យសាមណេរបម្រើ ១ មិនត្រូវត្រេកអរនឹងការសន្មតជាអ្នកឲ្យឱវាទដល់ភិក្ខុនី ១ បើទុកជាសង្ឃសន្មតហើយ ក៏មិនត្រូវឲ្យឱវាទពួកភិក្ខុនី ១ មិនត្រូវត្រេកអរនឹងសង្ឃសម្មតិណាមួយ ១ មិនត្រូវនិយមខ្លួនក្នុងទីជាអធិបតីណាមួយ ១ មិនត្រូវឲ្យ (ភិក្ខុ) ចេញចាកអាបត្តិដោយមូលនោះ ១ ។ ម្នាលភិក្ខុទាំងឡាយ ភិក្ខុដែលសង្ឃធ្វើ តស្ស បាបិយសិកាកម្ម រួចហើយ ត្រូវប្រព្រឹត្តឲ្យល្អ ក្នុងធម៌ ៨ ប្រការនេះឯង ។

ចប់ សតិវគ្គ ។

សុត្តន្តបិដកេ អង្គុត្តរនិកាយស្ស អដ្ឋកនិបាតោ

## តត្រុទ្ទានំ

សតិ បុញ្ញិយមូលេន ចោរសមណេន បញ្ចមំ
យសោ បត្តាប្បសាទេន[១] បដិសារណីយញ្ច វត្តតីតិ ។

១ ឱ. ម. បត្តប្បសាទេន ។

សុត្តន្តបិដក អង្គុត្តរនិកាយ អដ្ឋកនិបាត

# ឧទ្ទានក្នុងសតិវគ្គនោះគឺ

និយាយអំពីសតិសម្បជញ្ញៈ ១ អំពីរឿងបុណ្ណិយភិក្ខុ ១ អំពីធម៌ជាមូល ១ អំពីមហាចោរ ១ អំពីព្រះនាមព្រះតថាគតមានព្រះនាមថា សមណៈជាដើម ១ ត្រូវជា ៥ អំពីព្រះអង្គមិនចង់ជួបនឹងយសបរិវារ ១ អំពីការផ្កាប់បាត្រនិងផ្ងារបាត្រ ១ អំពីសេចក្ដីជ្រះថ្លានិងមិនជ្រះថ្លា ១ អំពីបដិសារណីយកម្ម ១ អំពីភិក្ខុប្រព្រឹត្តល្អ ១ ។

---

ពោជ្ឈា សិរិមា បទុមា សុជម្មា[១] មណុជា ឧត្តរា មុត្តា ខេមា[២] រុចី[៣] ចុន្ទី ពិម្ពី សុមនា មល្លិកា តិស្សមាតា សោណមាតា កាណមាតា[៤] ឧត្តរមាតា[៥] វិសាខា មិគារមាតា ខុជ្ជុត្តរា ឧបាសិកា សាមាវតី ឧបាសិកា សុប្បវាសា កោឡិយធីតា សុប្បិយា ឧបាសិកា នកុលមាតា គហបតានីតិ ។

[១១១] រាគស្ស ភិក្ខវេ អភិញ្ញាយ អដ្ឋ ធម្មា ភាវេតព្វា ។ កតមេ អដ្ឋ ។ សម្មាទិដ្ឋិ សម្មាសង្កប្បោ សម្មាវាចា សម្មាកម្មន្តោ សម្មាអាជីវោ សម្មាវាយាមោ សម្មាសតិ សម្មាសមាធិ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ អដ្ឋ ធម្មា ភាវេតព្វា ។

[១១២] រាគស្ស ភិក្ខវេ អភិញ្ញាយ អដ្ឋ ធម្មា ភាវេតព្វា ។ កតមេ អដ្ឋ ។ អជ្ឈត្តំ រូបសញ្ញី

---

១ ឱ. សុធនា ។ ២ ឱ. ឯត្ថន្តរេ សោមាតិ ទិស្សតិ ។ ៣ ឱ. រូបី ។ ៤ ឱ. តិស្សា តិស្សាយ មាតា សោណា សោណាយ មាតា កាណា កាណាយ មាតា ។ ៥ ឱ. ម. ឧត្តរា នន្ទមាតា ។

រឿងក្រៅពីនេះទៅ ដែលព្រះសម្មាសម្ពុទ្ធទ្រង់សម្ដែងឧបោសថកម្ម ប្រកបដោយអង្គ ៨ ប្រការ ដល់ពួកឧបាសិកាទាំងអម្បាលនេះ គឺពោជ្ឈាឧបាសិកា សិរិមាឧបាសិកា បទុមាឧបាសិកា សុធម្មាឧបាសិកា មណុជាឧបាសិកា ឧត្តរាឧបាសិកា មុត្តាឧបាសិកា ខេមាឧបាសិកា រុចីឧបាសិកា ចុន្ទីរាជកុមារី ពិម្ពីឧបាសិកា សុមនារាជកុមារី មល្លិកាទេវី តិស្សមាតាឧបាសិកា សោណមាតាឧបាសិកា កាណមាតាឧបាសិកា ឧត្តរានន្ទមាតាឧបាសិកា វិសាខាមិគារមាតាឧបាសិកា ខុជ្ជុត្តរាឧបាសិកា សាមាវតីឧបាសិកា សុប្បវាសាកោឡិយធីតាឧបាសិកា សុប្បិយាឧបាសិកា នកុលមាតាគហបតានីឧបាសិកា ។

[១១១] ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការ បុគ្គលត្រូវចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៨ ប្រការ តើដូចម្ដេចខ្លះ ។ គឺសម្មាទិដ្ឋិ ១ សម្មាសង្កប្បៈ ១ សម្មាវាចា ១ សម្មាកម្មន្តៈ ១ សម្មាអាជីវៈ ១ សម្មាវាយាមៈ ១ សម្មាសតិ ១ សម្មាសមាធិ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការនេះ បុគ្គលត្រូវចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។

[១១២] ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការ បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៨ ប្រការ តើដូចម្ដេចខ្លះ ។ គឺបុគ្គលមានសេចក្ដីសម្គាល់ ក្នុងរូបខាងក្នុង (មានសក់ជាដើមរបស់ខ្លួន)

ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ។ អជ្ឈត្តំ រូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ អប្បមាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ។ អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ បរិត្តានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ។ អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ អប្ប-មាណានិ សុវណ្ណទុព្វណ្ណានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ។ អជ្ឈត្តំ អរូបសញ្ញី វា ពហិទ្ធា រូបានិ បស្សតិ នីលានិ នីលវណ្ណានិ នីលនិ-ទស្សនានិ នីលនិភាសានិ ។ បេ ។ បីតានិ បីតវណ្ណានិ បីតនិទស្សនានិ បីតនិភាសានិ ។ បេ ។ លោហិតកានិ

ឃើញរូបខាងក្រៅ គឺកសិណ មាននីលកសិណជាដើម ជារូបមានប្រ-មាណតិច មានសម្បុរល្អ ឬសម្បុរអាក្រក់ ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ១ ។ បុគ្គលមានសេចក្តីសម្គាល់ក្នុងរូបខាងក្នុង តែងឃើញនូវរូបខាងក្រៅ ជារូបប្រមាណមិនបាន មានសម្បុរល្អ ឬសម្បុរអាក្រក់ ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ១ ។ បុគ្គលមិនមានសេចក្តីសម្គាល់ ក្នុងរូបខាងក្នុង តែងឃើញនូវរូបខាងក្រៅ ជារូបមានប្រមាណតិច មានសម្បុរល្អ ឬសម្បុរអាក្រក់ ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ១ ។ បុគ្គលមិនមានសេចក្តីសម្គាល់ ក្នុងរូបខាងក្នុង តែងឃើញរូបខាងក្រៅ ជារូបប្រមាណមិនបាន មានសម្បុរល្អ ឬ សម្បុរអាក្រក់ ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្តីសម្គាល់យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ១ ។ បុគ្គល មិនមានសេចក្តីសម្គាល់ ក្នុងរូបខាងក្នុង តែងឃើញនូវរូបខាងក្រៅ ជារូបខៀវ មានសម្បុរខៀវ ធ្លុះចេញនូវពណ៌ខៀវ មានពន្លឺខៀវ ១ ។ បេ ។ ជារូបលឿង មានសម្បុរលឿង ធ្លុះចេញនូវពណ៌លឿង មានពន្លឺលឿង ១ ។ បេ ។ ជារូបក្រហម មានសម្បុរក្រហម

លោហិតកវណ្ណានិ លោហិតកនិទស្សនានិ លោហិតកនិភាសានិ ។ បេ ។ ឱទាតានិ ឱទាតវណ្ណានិ ឱទាតនិទស្សនានិ ឱទាតនិភាសានិ តានិ អភិភុយ្យ ជានាមិ បស្សាមីតិ ឯវំសញ្ញី ហោតិ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ អដ្ឋ ធម្មា ភាវេតព្វា ។

[១១៣] រាគស្ស ភិក្ខវេ អភិញ្ញាយ អដ្ឋ ធម្មា ភាវេតព្វា ។ កតមេ អដ្ឋ ។ រូបី រូបានិ បស្សតិ អជ្ឈត្តំ អរូបសញ្ញី ពហិទ្ធា រូបានិ បស្សតិ សុភន្តេវ អធិមុត្តោ ហោតិ ។ សព្វសោ រូបសញ្ញានំ សមតិក្កមា បដិឃសញ្ញានំ អត្ថង្គមា នានត្តសញ្ញានំ អមនសិការា អនន្តោ អាកាសោតិ អាកាសានញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។ សព្វសោ អាកាសានញ្ចាយតនំ សមតិក្កម្ម អនន្តំ វិញ្ញាណន្តិ វិញ្ញាណញ្ចាយតនំ ឧបសម្បជ្ជ វិហរតិ ។

ធ្លុះចេញនូវពណ៌ក្រហម មានពន្លឺក្រហម ១ ។ បេ ។ ជារូបស មានសម្បុរស ធ្លុះចេញនូវពណ៌ស មានពន្លឺស ក៏គ្របសង្កត់នូវរូបទាំងនោះ ហើយមានសេចក្ដីសម្គាល់ យ៉ាងនេះថា អាត្មាអញដឹង អាត្មាអញឃើញ ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការនេះ បុគ្គលត្រូវពិចារណា ដើម្បីដឹងច្បាស់នូវរាគៈ ។

[១១៣] ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការ បុគ្គលត្រូវចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។ ធម៌ ៨ ប្រការ តើដូចម្ដេចខ្លះ ។ បុគ្គលមានរូបជ្ឈាន តែងឃើញរូប គឺកសិណទាំងឡាយ មាននីលកសិណជាដើម មិនមានសេចក្ដីសម្គាល់ក្នុងរូបខាងក្នុង (មានសក់ជាដើមរបស់ខ្លួន) តែងឃើញរូបខាងក្រៅ គឺកសិណ មាននីលកសិណជាដើម ជាអ្នកមានចិត្តចុះស៊ប់ថា វណ្ណកសិណបរិសុទ្ធ ១ ។ ព្រោះកន្លងបង់នូវរូបសញ្ញាដោយប្រការទាំងពួង វិនាសទៅនៃបដិឃសញ្ញា មិនបានធ្វើទុកក្នុងចិត្តនូវនានត្តសញ្ញា ក៏ចូលកាន់អាកាសានញ្ចាយតនជ្ឈាន ដោយធ្វើទុកក្នុងចិត្ត ថា អាកាសមិនមានទីបំផុត ១ ។ ព្រោះកន្លងនូវអាកាសានញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលកាន់វិញ្ញាណញ្ចាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្ត ថា វិញ្ញាណមិនមានទីបំផុត ១ ។

សព្វសោ វិញ្ញាណញ្ចាយតនំ សមតិក្កម្ម នត្ថិ កិញ្ចីតិ អាកិញ្ចញ្ញាយតនំ ឧបសម្បជ្ជ វិហរតិ ។ សព្វសោ អាកិញ្ចញ្ញាយតនំ សមតិក្កម្ម នេវសញ្ញានាសញ្ញា-យតនំ ឧបសម្បជ្ជ វិហរតិ ។ សព្វសោ នេវសញ្ញានា-សញ្ញាយតនំ សមតិក្កម្ម សញ្ញាវេទយិតនិរោធំ ឧបសម្បជ្ជ វិហរតិ ។ រាគស្ស ភិក្ខវេ អភិញ្ញាយ ឥមេ អដ្ឋ ធម្មា ភាវេតព្វា ។

[១១៤] រាគស្ស ភិក្ខវេ បរិញ្ញាយ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ អដ្ឋ ធម្មា ភាវេតព្វាតិ ។ ទោសស្ស មោហស្ស កោធស្ស ឧបនាហស្ស មក្ខស្ស បឡាសស្ស ឥស្សាយ មច្ឆរិយស្ស មាយាយ សាឋេយ្យស្ស ថម្ភស្ស សារម្ភស្ស មានស្ស អតិមានស្ស មទស្ស បមាទស្ស អភិញ្ញាយ បរិញ្ញាយ បរិក្ខយាយ បហានាយ ខយាយ វយាយ វិរាគាយ និរោធាយ ចាគាយ បដិនិស្សគ្គាយ ឥមេ អដ្ឋ ធម្មា ភាវេតព្វាតិ ។

អដ្ឋកនិបាតោ សមត្តោ ។

ព្រោះកន្លងនូវវិញ្ញាណញ្ចាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលកាន់អាកិញ្ចញ្ញាយតនជ្ឈាន ដោយការធ្វើទុកក្នុងចិត្តថា អ្វីតិចតួចមិនមាន ១ ។ ព្រោះកន្លងនូវអាកិញ្ចញ្ញាយតនជ្ឈាន ដោយប្រការទាំងពួង ក៏ចូលកាន់នេវសញ្ញានាសញ្ញាយតនជ្ឈាន ១ ។ ព្រោះកន្លងនូវនេវសញ្ញានាសញ្ញាយតនជ្ឈានដោយប្រការទាំងពួង ក៏ចូលកាន់សញ្ញាវេទយិតនិរោធ (សេចក្ដីរលត់នៃសញ្ញានិងវេទនា) ១ ។ ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការនេះ បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់នូវរាគៈ ។

[១១៤] ម្នាលភិក្ខុទាំងឡាយ ធម៌ ៨ ប្រការនេះ បុគ្គលគប្បីចម្រើន ដើម្បីកំណត់ដឹង ដើម្បីអស់រលីង ដើម្បីលះបង់ ដើម្បីអស់ទៅ ដើម្បីសូន្យទៅ ដើម្បីវិនាសទៅ ដើម្បីរលត់ ដើម្បីលះលែង ដើម្បីរលាស់ចេញនូវរាគៈ ។ ធម៌ ៨ ប្រការនេះ បុគ្គលគប្បីចម្រើន ដើម្បីដឹងច្បាស់ ដើម្បីកំណត់ដឹង ដើម្បីអស់រលីង ដើម្បីលះបង់ ដើម្បីអស់ទៅ ដើម្បីសូន្យទៅ ដើម្បីវិនាសទៅ ដើម្បីរលត់ ដើម្បីលះលែង ដើម្បីរលាស់ចេញនូវទោសៈ មោហៈ កោធៈ ឧបនាហៈ មក្ខៈ បលាសៈ ឥស្សា មច្ឆរិយៈ មាយា សាថេយ្យៈ ថម្ភៈ សារម្ភៈ មានៈ អតិមានៈ មទៈ បមាទៈ ។

ចប់ អដ្ឋកនិបាត ។

---

# សុត្តន្តបិដកេ

# អង្គុត្តរនិកាយស្ស អដ្ឋកនិបាតោ

# នវមោ ភាគោ

---

មាតិកា　　　　　　　　　　　　　　　　　　　　　　អង្កេ

## បណ្ណាសកោ


| | | | |
|---|---|---|---|
| *បណ្ណាសកេ* | *មេត្តាវគ្គោ* | *បឋមោ*........................ | *១* |
| | *មហាវគ្គោ* | *ទុតិយោ*...................... | *៤១* |
| | *គហបតិវគ្គោ* | *តតិយោ*...................... | *១០៨* |
| | *ទានវគ្គោ* | *ចតុត្ថោ*....................... | *១៦០* |
| | *ឧបោសថវគ្គោ* | *បញ្ចមោ* ................. | *១៨៣* |


## បណ្ណាសកាសង្គហិតា វគ្គា


| | | | |
|---|---|---|---|
| *បណ្ណាសកាសង្គហិតវគ្គេសុ* | *សទ្ធានវគ្គោ* | *បឋមោ*...................... | *២២៩* |
| | *ចាលវគ្គោ* | *ទុតិយោ*..................... | *២៦៦* |
| | *យមកវគ្គោ* | *តតិយោ*..................... | *៣០៥* |
| | *សតិវគ្គោ* | *ចតុត្ថោ*...................... | *៣៤៨* |
| | *វគ្គោ* | *បញ្ចមោ*.................... | *៣៦៩* |

# សុត្តន្តបិដក

# អង្គុត្តរនិកាយ អដ្ឋកនិបាត

# នវមភាគ

---

## មាតិកា　　　　　　　　　　　　　　　　　　　　　　　　　　　　　　　　លេខទំព័រ

## បណ្ណាសក


| | | | |
|---|---|---|---|
| *បណ្ណាសក* | *មេត្តាវគ្គ* | *ទី ១.........................* | *១* |
| | *មហាវគ្គ* | *ទី ២.........................* | *៤១* |
| | *គហបតិវគ្គ* | *ទី ៣.........................* | *១០៨* |
| | *ទានវគ្គ* | *ទី ៤.........................* | *១៦០* |
| | *ឧបោសថវគ្គ* | *ទី ៥.........................* | *១៨៣* |


## បណ្ណាសកាសង្គហិតវគ្គ


| | | | |
|---|---|---|---|
| *បណ្ណាសកាសង្គហិតវគ្គ* | *សទ្ធានវគ្គ* | *ទី ១.........................* | *២២៩* |
| | *ចាលវគ្គ* | *ទី ២.........................* | *២៦៦* |
| | *យមកវគ្គ* | *ទី ៣.........................* | *៣០៥* |
| | *សតិវគ្គ* | *ទី ៤.........................* | *៣៤៨* |
| | *វគ្គ* | *ទី ៥.........................* | *៣៦៩* |

